41 (5

៥

# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ

## ផ្នែកសាសនា

ទំព័រ

១– សេចក្ដីក្លាហាន សហ. ផេង ជ្រីវ រៀបរៀង . . . . ៤៦៧

២– រឿងសុតនបណ្ឌិត សហ. ហេង សមអាន នាយទាហានរងកង យោធពលខេមរភូមិន្ទ រៀបរៀង . . . . . . ៤៧៤

## ផ្នែកអក្សរសាស្ត្រ

៣– វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង ខាត់ . . . . ៤៨៩

៤– វប្បធម៌ មន-ខ្មែរ សហ. ឌឹក-ជាម រៀបរៀង . . . . ៤៩៣

៥– រឿងសាមកុក (ត) ឧកញ៉ានូ-កន ប្រែរៀបរៀង . . . . ៥១០

៦– រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ សហជីវិន ពេជ-សល់ ប្រែរៀបរៀង ៥២១

## ផ្នែកកំណត់-ប្រវត្តិការណ៍

៧– ពិធីប្រគល់ព្រះត្រៃបិដកខ្មែរ ជូនចំពោះមជ្ឈមណ្ឌលពុទ្ធសាសនា នៅ ក្រុងហាលេ សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ . . . ៥៣៩

៨– ពិធីនមស្ការសក្យមុនីចេតិយ . . . . . . ៥៤២

៩– សេចក្ដីអំពាវនាវ នៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ . . . ៥៥១

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០៛០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ,
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព

# សេចក្ដីក្លាហាន

ពាក្យថា "ក្លាហាន" នេះ ជាកម្លាំងចិត្តយ៉ាង ដែលអាចតទល់ប្រឆាំងនឹងបច្ចាមិត្រគ្រប់បែបយ៉ាង ។ កម្លាំងចិត្តនេះ ត្រូវចាត់ទុកជាគុណសម្បត្តិដ៏កម្រមួយ បណ្ដាគុណសម្បត្តិទាំងឡាយនៃមនុស្សទូទៅក្នុងលោក ដ្បិតដោយអំណាចគុណសម្បត្តិនេះ មនុស្សអាចយកជោគជ័យមកឲ្យជាតិបាន ហើយធ្វើខ្លួនឲ្យក្លាយទៅជា "សត្វមួយក្រុម" មានឋានៈសមល្មមគួរនឹងនាមរបស់ខ្លួនដែលហៅថា "មនុស្ស" នោះបាន ។

មានមនុស្សភាគច្រើនណាស់ដែលនិយមពោលថា: ហេតុម្ដេចក៏មិនឃើញមានអគ្គិភ័យ មិនឃើញមានកើតអសន្តិសុខ មិនឃើញមានកើតចម្បាំង មិនឃើញមានមនុស្សលង់ទឹក ។ល។ ខ្លួននឹងគាប់បញ្ចេញសេចក្ដីក្លាហានឲ្យអ្នកផងទាំងពួងយល់ ព្រមទាំងកោតស្ញប់ស្ញែងសរសើរខ្លួន និងរាប់អានផង ។

អ្នកដែលតាំងចិត្តដូច្នេះ ហៅថាអ្នកមានសេចក្ដីក្លាហានបានទេ ?

ត្រូវតែចាត់ទុកគេ ជាអ្នកមានសេចក្ដីក្លាហានដែរ ប៉ុន្តែ សេចក្ដីក្លាហានដូចបានពោលមកនេះ ហៅថា សេចក្ដីក្លាហានគ្រោតគ្រាត ជាសេចក្ដីក្លាហានប្រាសចាកការសុខុម ការហ្មត់ចត់ ។

សួរថា : បច្ចាមិត្ររបស់លោកិយ ដែលត្រូវយកសេចក្ដីក្លាហានទៅផ្ចាញ់ គឺអ្វីខ្លះ ?

ត្រង់នេះហើយជាចំណុចធំ ដែលសម្រាប់ឲ្យអ្នកឲ្យឃើញថា ណាជាសេចក្ដីក្លាហានគ្រោតគ្រាត ណាជាសេចក្ដីក្លាហានហ្មត់ចត់ ណាជាសេចក្ដីក្លាហានក្លែងក្លាយ ។

ឆ្លើយថា : បច្ចាមិត្ររបស់លោកិយ ដែលត្រូវយកសេចក្ដីក្លាហានមកផ្ចាញ់ មានពីរប្រការ គឺពាហិរបច្ចាមិត្រ ១ អជ្ឈត្តិកបច្ចាមិត្រមួយ ។

ចំពោះបច្ចាមិត្រទាំងពីរប្រការនេះ បានតែពាហិរបច្ចាមិត្រទេ ដែលមនុស្សខ្លះអាចយកសេចក្ដីក្លាហានរបស់ខ្លួន ទៅផ្ចាញ់បានយ៉ាងងាយ, រីអជ្ឈត្តិកបច្ចាមិត្រវិញ មានមនុស្សគាត់តិចណាស់ ដែលអាចយកសេចក្ដីក្លាហានរបស់ខ្លួនទៅផ្ចាញ់បាន ។ បើពោលឲ្យចំទៅ គឺ មនុស្សគ្មានសេចក្ដីក្លាហានតែម្ដង ។

ឯអជ្ឈត្តិកបច្ចាមិត្រ គ្មានអ្វីក្រៅពីអកុសលធម៌ឡើយ ។

កូនសិស្សបានការណ៍យកចិត្តទុកដាក់សិក្សា ដ៏ត្រូវទន្ទេញមេរៀន ព្រម

ទាំងមេសូត្របង្ហើយ គ្រាប់តែឃើញគេបើកវិទ្យុទូរទស្សន៍ ក៏បញ្ឈប់កិច្ចសិក្សារបស់ខ្លួន ហើយមកអង្គុយមើលការបញ្ចាំងនោះទៅវិញ ។ នេះឈ្មោះថា ខ្វះសេចក្តីក្លាហាន ។ កូនសិស្សជំទង់បណ្តែតបណ្តោយឲ្យសេចក្តីស្នេហាញាំញី ហើយបោះបង់ចោលនូវកិច្ចសិក្សា ក៏ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។ ល ។

គ្រូបង្រៀនបង្ហាត់សិស្សយ៉ាងខ្ជីខ្ជា មិនព្រមយកចិត្តទុកដាក់កែនិងពិនិត្យមើលកិច្ចការសិស្សឲ្យបានហ្មត់ចត់, ដោយស្ដីវាយសិស្សទាំងគម្រោល ទាំងនេះ ក៏ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។

ក្មេងបម្រើឬកូនចៅ មានទោះធ្វើឲ្យបែកចានឬកែវ ។ ល ។ លុះទៅហ្វាយនាយឬមាតាបិតា ហៅមកសួរ បែរជាឆ្លើយបដិសេធ នេះក៏ហៅថា ខ្វះសេចក្តីក្លាហាន ។

មុខរបរឬកិច្ចការដែលខ្លួនត្រូវធ្វើរាល់ថ្ងៃ ខ្លួនមិនធ្វើដោយសតិសម្បជញ្ញៈព្រោះការខ្ជិលច្រអូស ហើយបែរទៅប្រព្រឹត្តចោរកម្ម នេះក៏ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។ ភ្នាក់ងាររាជការដែលមិនបំពេញករណីយកិច្ចដែលច្បាប់បានតម្រូវទុក ឈ្មោះថា ខ្វះសេចក្តីក្លាហាន, ជាងសំណង់និងកម្មករដែលមិនបានបំពេញកិច្ចការឲ្យត្រឹមត្រូវតាមលក្ខណៈកម្រិតទុក និងឲ្យត្រឹមត្រូវតាមពេលម៉ោង ឈ្មោះថា ខ្វះសេចក្តីក្លាហាន ។

ផ្លែកល់ផ្សារ ដែលបន្ទំយកតែមានគុណភាពអន់ ទៅលាយជាមួយ តែមានគុណភាពល្អ ព្រោះតែចង់បានចំណេញច្រើន ឬដែលថ្លឹងបំបាត់ ខ្នាតជញ្ជីង ឈ្មោះថា ខ្វះសេចក្ដីក្លាហាន ។

ចៅក្រម ដែលកាត់សេចក្ដីប្រកបដោយអគតិធម៌ ឈ្មោះថា ខ្វះសេចក្ដីក្លាហាន ។ កូនក្ដី ដែលនិយមយកសំណូកទៅជូនចៅក្រម ដើម្បីហេតុរបស់ខ្លួន ឈ្មោះថា ខ្វះសេចក្ដីក្លាហាន ។

មនុស្សដែលបណ្ដោយឲ្យអភិជ្ឈាចិត្តគ្របសង្កត់ ហើយប្រព្រឹត្តអំពើទុច្ចរិតគ្រប់បែបយ៉ាង ឈ្មោះថា ខ្វះសេចក្ដីក្លាហាន ។ មនុស្សដែលបណ្ដែតបណ្ដោយឲ្យសេចក្ដីស្នេហាញាំញី ហើយទៅប្រព្រឹត្តបរទារកម្មក្ដី ទៅប្រព្រឹត្តរួមរ័កជាមួយកូនប្រើអ្នកដទៃក្ដី ទៅរួមរ័កជាមួយស្រីពេស្យាក្ដី ឈ្មោះថា ខ្វះសេចក្ដីក្លាហាន ។

មនុស្ស ដោយចង់បានបុណ្យស័ក្តិពេក ដោយលោភអំណាចពេក ដោយប្រាថ្នាទ្រព្យធនពេក ហើយទៅឃោសនាមួលបង្កាច់កេរ្តិ៍អ្នកដទៃ ទៅទិញចិត្តអ្នកដទៃ ឬឲ្យអ្នកដទៃទិញខ្លួនដូចសត្វធាតុ នេះឈ្មោះថា ខ្វះសេចក្ដីក្លាហាន ។

បើបព្វជិតណាមួយ ព្រោះតែចង់សប្បាយ ព្រោះតែចង់ហិហាដូចគ្រហស្ថ ហើយភ្លេចគិតដល់វិន័យ ដល់ធម៌របស់ក្រុម ទៅប្រព្រឹត្តអំពើមិនគប្បី ឈ្មោះថា ខ្វះសេចក្ដីក្លាហាន ។

រួមសេចក្ដីទៅ ឃើញថា មនុស្សក្នុងលោក ភាគច្រើនណាស់សុទ្ធសឹងជាអ្នកខ្សត់ខ្សោយ សុទ្ធសឹងជាអ្នកប្រកបដោយមហាទុព្វលភាពក្រៃលែង ចំពោះការតព្វកិច្ចដ៏សុចរិតរបស់ខ្លួនប្រចាំថ្ងៃ ជាការតព្វកិច្ចដែលខ្លួនឥតយល់ពាល់តែសោះថា ត្រូវតែយកសេចក្ដីក្លាហានទៅប្រឆាំងទើបបាន នោះ ៗ ហេតុដូច្នេះហើយ ទើបគេនិយមទុកជីវភាពនៃមនុស្សម្នាក់ ៗ ថាជាការប្រយុទ្ធ ។

តាមការសង្កេតឃើញថា មនុស្សចំប្រឹងធ្វើការប្រយុទ្ធអ៊ីចឹងមែនហើយ តែជាការប្រយុទ្ធផ្ទុយពីគោលច្បាប់របស់ខ្លួន ។ ដូចម្ដេចក៏ថាខុសពីគោលច្បាប់ ? ព្រោះម្នាក់ ៗ មិនគិតប្រឆាំងនឹងបច្ចាមិត្ររបស់ខ្លួន បែរទៅចំប្រយុទ្ធវាយបែកជាមួយបច្ចាមិត្ររបស់ខ្លួនទៅវិញ ដើម្បីរកប្រយោជន៍ទម្លាក់មកលើខ្លួនតែម្នាក់ឯង ៗ ការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន គឺជាច្បាប់ធម្មជាតិដ៏ពិតប្រាកដនៃមនុស្សគ្រប់រូប ។ អ្នកណាដែលនិយាយថាកុំឲ្យស្វែងរកប្រយោជន៍ផ្ទាល់ខ្លួននោះ គឺយល់ខុសស្រឡះ ។ តែសូមឲ្យការស្វែងរកប្រយោជន៍ផ្ទាល់ខ្លួននេះ ប្រព្រឹត្តទៅយ៉ាងណា កុំឲ្យក្បត់នឹងសិទ្ធិរបស់ខ្លួន ធ្វើយ៉ាងណា កុំឲ្យជិះជាន់ ឬ គងទៅលើសិទ្ធិអ្នកដទៃ តែប៉ុណ្ណោះ ។

សេចក្ដីក្លាហានដែលឈ្មោះថាត្រឹមត្រូវ ហើយមិនធ្ងន់នោះ សំដៅទៅលើសេចក្ដីក្លាហានណាកើតឡើងហើយ ដើម្បីតទប់នឹងអកុសលចិត្តរបស់ខ្លួន ប្រាសចាកគំនិតលាក់ពុត ប្រាសចាកគំនិតកេងបន្លំ ។ សព្វថ្ងៃមានមនុស្សភាគច្រើនរាប់មិនអស់ និយមយកសេចក្ដីក្លាហានក្លែងក្លាយមកអនុវត្ត ដើម្បីញ៉ាំងជីវភាព របស់ខ្លួន ឲ្យប្រព្រឹត្តទៅប្រសើរលើសគេ ហើយអ្នកផង ក៏នាំគ្នានិយម គោរពសរសើរ ព្រមទាំងលើកតម្កើង ថាជាមនុស្សឯកថែមទៀត, តែតាមការណ៍ពិតវិញ ទាំងអ្នកមានសេចក្ដីក្លាហាននេះ ទាំងអ្នកគោរពសរសើរ សុទ្ធសឹងជាមនុស្សប្រភេទ "ដូនប៉ង់" ជាមនុស្សប្រភេទ "ទៀម" ។

ដូច្នេះ សេចក្ដីក្លាហាន ជាកុសលចេតសិកមួយ មិនងាយមនុស្សសាមញ្ញនឹងអាចបង្កើតឲ្យមានបានឡើយ ព្រោះសេចក្ដីក្លាហាននេះ គឺជាគួមហាត្ថនមួយក្រុមនឹងរកបានណាស់ ។ គឺសេចក្ដីក្លាហានដែលកើតឡើងសម្រាប់ប្រឆាំងនឹងអកុសលចិត្តរបស់អាត្មាប្រចាំថ្ងៃនេះហើយ ទើបឈ្មោះថា សេចក្ដីក្លាហានឯក ទើបឈ្មោះថា សេចក្ដីក្លាហានដ៏ហ្មត់ចត់បរិសុទ្ធកម្រកេបាន ដែលអ្នកប្រាជ្ញទាំងឡាយក្នុងលោកមានព្រះបរមគ្រូសម្ពុទ្ធជាដើមទ្រង់និយមសរសើរនោះ ។

សារុបសេចក្ដីទៅ សេចក្ដីក្លាហាន ជាគុណធម៌មួយយ៉ាងប្រពៃ សម្រាប់ឲ្យមនុស្សទុកប្រើប្រឆាំងតទល់នឹងឧបសគ្គទាំងខាងក្រៅ ទាំងខាងក្នុង,

ឧបសគ្គខាងក្រៅ សំដៅទៅលើធម្មជាតិ តែឧបសគ្គនេះ ងាយនឹងប្រឆាំង ណាស់ ឲ្យតែមនុស្សមានមនោព្យាយាមគ្រប់គ្រាន់ ព្រមទាំងមានសុធន្ធៈ ផង ៗ ជាទីអវសាន ឧបសគ្គខាងក្នុង សំដៅទៅលើអកុសលចិត្តគ្រប់បែប យ៉ាង ៗ មនុស្សណា ដែលមានសេចក្តីក្លាហាន អាចប្រឆាំងនឹងអកុសលចិត្តបាន ទើបចាត់ទុកអ្នកនោះថា ជាមនុស្សឯកប្រសើរផុតគេ ៗ មនុស្សមានចិត្តទូន្មានបាន ទុកជាមនុស្សក្រប្រក្រៅក្រៃលែង នឹងជាទីគោរព រាប់អាន នឹងគោតសរសើរ ពីសំណាក់កល្យាណជនទាំងឡាយ ទាំងក្នុង ទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ។

ជាទីបញ្ចប់ អ្នកមានសេចក្តីក្លាហានក្នុងសង្គ្រាម ក្នុងអគ្គិភ័យ ក្នុង ចោរកម្ម ។ល។ ក៏ទុកជាការណ៍គ្រាន់បើគួរសមឲ្យសរសើរបានខ្លះដែរ តែមិនត្រូវបានទទួលនាមបញ្ញត្តិថា ជាអ្នកក្លាហានដ៏ឧត្តមបានទេ ព្រោះ សេចក្តីក្លាហាននេះកើតឡើង ដោយហេតុដោយខណៈ ហើយដោយ សារគោរពទាល់ច្រក ដោយសារគេបង្ខំ ឬដោយសារចំណង់គ្លួយខានពុំ បានតែប៉ុណ្ណោះ ៗ ឯសេចក្តីក្លាហានខាងកម្ចាត់អកុសលចិត្ត ទើបចាត់ ទុកជាសេចក្តីក្លាហានមែនទែន ដ្បិតសេចក្តីក្លាហាននុះ បញ្ចេញពីចិត្តពិតស្មោះ របស់ខ្លួន ដូចព្រះអាទិត្យ ដែលរះហើយ ត្រូវតែរះបំភ្លឺពន្លឺរស្មី បំភ្លឺលោក ទោះបីមានពពកខ្មៅ ឬមានខ្យល់ភ្លៀងនិងព្យុះសង្ឃរាដូចម្តេចក្តី ។

# រឿងសុតនបណ្ឌិត

សហជីវិន ហោ ង៉ សម អាង នាយទាហានរងកងយោធពលខេមរភូមិន្ទ

ធ្វើការនៅសេនាធិការយោធភូមិភាគទី ១

តែងនិងរៀបរៀង

ក្នុងកាលកន្លងយូរយារអង្វែងណាស់ទៅហើយ ព្រះសម្មាសម្ពុទ្ធ បរមសាស្ដាចារ្យ ទ្រង់យោនយកកំណើតក្នុងត្រកូលកម្មករ ព្រះនាមសុតនបណ្ឌិត ប្រកបការងារស៊ីឈ្នួលលីសែងចិញ្ចឹមឪពុក-ម្ដាយ នៅក្រុងពារាណសីនៃប្រទេសកាសី ។

កាលពីកុមារ មាតាបិតាខំប្រឹងអត់ធ្មត់ ធ្វើការស៊ីឈ្នួលគេទាំងយប់ទាំងថ្ងៃ យកប្រាក់ធ្វើសោហ៊ុយ បញ្ជូនឲ្យទៅសិក្សាសិល្បសាស្ដ្រនៅសកលវិទ្យាល័យ នាក្រុងតក្កសិលា ដោយបិតាប្រកាន់គតិបុរាណ ថាបណ្ដាបុគ្គលដែល

គ្មានកូន ១

កូនស្លាប់ ១

កូនល្ងង់ ១

អ្នកគ្មានកូន និងកូនស្លាប់ហើយ ប្រសើរជាងកូនរស់នៅល្ងង់ទៀត ព្រោះកូនស្លាប់ ធ្វើឲ្យឪពុកម្ដាយកើតទុក្ខ អស់រយៈតែ ១ ខែ ឬ ២ ខែ ។ ចំណែកកូនល្ងង់ទៀត ធ្វើឲ្យឪពុកម្ដាយកើតទុក្ខអស់មួយជីវិត ។

សុភាសិត

មានកូនមិនឲ្យកូនសូត្ររៀន   ចំណេះរៀនការនានា
អាចារលោកថាជាវេក   បិតាទុកជាសត្រូវធំ ។
កូនគោព្រៃប្រពាលពត់មិនឡើង   ហៅថាមិនចេះក្នុងជំនុំ
ប្រៀបដូចកុកគ្រោនចូលទ្រនំ   កណ្ដាលជំនុំនៃកដហង្ស ។

ដកស្រង់សុត្តន្តប្រីជា ពន្ធបណ្ឌិត

ក្រុងតក្កសិលា ជាក្រុងធំប្រជុំនៃវិជ្ជា មានអ្នកប្រាជ្ញជាបណ្ឌិតជាន់ខ្ពស់ជាច្រើន អាចទទួលបង្រៀនសិល្បសាស្ត្រគ្រប់យ៉ាង តាមបំណងសិស្សត្រូវការ ។ ស្ដេច, មន្ត្រី, គហបតី, អ្នកមាន, អ្នកក្រ ក្នុងដែននានា សូម្បីនៅឆ្ងាយប៉ុន្មានក៏ដោយ តែងបញ្ជូនបុត្ររបស់ខ្លួនឱ្យទៅសិក្សាក្នុងក្រុងនេះជាច្រើន ។

របៀបសុំចូលរៀនមាន ២ បែបគឺ:

១. ត្រូវបង់ថ្លៃចំនៀមទម្លាប់;

២. មិនបង់ថ្លៃចំនៀមទម្លាប់ តែត្រូវធ្វើការគ្រប់ជំពូក ។

សុតនកុមារ បានសិក្សាក្នុងសកលវិទ្យាល័យ ដោយរបៀបទី ២ គឺស្នាក់នៅគេហដ្ឋាន មហាវិទ្យាធិការ ធ្វើការបម្រើតាមតែលោកប្រើ ។

លុះសិក្សាចេះចប់ហើយ ក៏លោកគរុសាស្ត្រាចារ្យនិមន្តមេសាលា គ្រប់ប្រជុំជាតកុមារ ធ្វើការសុំឈ្មោលគេចំពាមចពុកឈ្មាយ ថៃក្សាប៉ាក់·

ថ្មមិនដែលឃ្លើសចិត្ត ។

កាលនោះ ព្រះបាទព្រហ្មទត្តព្រះចៅក្រុងពារាណសី ស្ដេចចេញប្រពាតព្រៃព្រឹក្សា មួយអន្ទើដោយសេវកាមាត្យជាច្រើនតាមដង្ហែជាព្រះកិត្តិយស, លុះយាងចូលដល់ព្រៃជ្រៅ ស្ដេចត្រាស់បង្គាប់ឲ្យសេវកាមាត្យៈចោមព័ទ្ធជុំវិញព្រៃរាយបង្អើលសត្វ ហើយទ្រង់ផ្ដាំថាបើម្រឹគរត់រួចបៈពារៈមុខអ្នកណា អ្នកនោះត្រូវសង ។ ក្នុងព្រៃនោះមានប្រើសមួយដេកនៅ, កាលបើឃើញមនុស្សរាយព្រៃឈរចោមព័ទ្ធ គិតភ័យស្ទុះរត់ផ្លោះទម្លាយចំពោះព្រះភក្ត្រព្រះមហាក្សត្ររួចទៅ, ព្រះចៅទ្រង់ខត្តិយមានះលេះលាំងគង់លើអាជានេយ្យចេញតាមម្រឹគ កាប់នឹងព្រះខ័នដាច់ជា ២ កំណាត់ យកសាច់ត្រឡប់មកវិញ ។ ដោយអស់ព្រះកាយពលខ្លាំងពេក ស្ដេចចូលឈប់សម្រាកក្រោមម្លប់សាខាដើមជ្រៃ ។ ពេលនោះ មក្ខទេវយក្សអ្នករក្សាដើមជ្រៃចាប់ព្រះអង្គ ហើយគំរាមថា "អ្នកឯងត្រូវបានជាអាហាររបស់យើង", ព្រះរាជាតក់ស្លុតព្រះទ័យភ័យណាស់អង្វរថា "បពិត្រមហាយក្ស អ្នកបរិភោគតែម្ដងទេឬក៏រាល់ថ្ងៃ"? យក្សប្រាប់ថា "បើបានរាល់ថ្ងៃ យើងបរិភោគរាល់ថ្ងៃ", ព្រះរាជាតបថា "បើដូច្នោះ ថ្ងៃនេះ អ្នកបរិភោគសាច់ប្រើសចុះ, ចាប់ពីថ្ងៃស្អែកទៅ យើងនឹងបញ្ជូនមនុស្សម្នាក់នាំអាហារ ១ សម្រាប់ឲ្យអ្នករៀងរាល់ៗថ្ងៃ" ។ យក្សថា "បើមិនបញ្ជូនមនុស្សម្នាក់និងអាហារ ១ សម្រាប់ទេ យើងនឹងចូលទៅចាប់បរិភោគទាំងបុត្តធីតា",

ព្រះរាជាយល់ព្រមជាមួយយក្សហើយ ក៏យាងចូលព្រះរាជវាំង ។ ចាត់រាជ-បុរសឲ្យដោះយកមនុស្សទោសពីក្នុងគុក ១ ថ្ងៃម្នាក់ ៗ ឲ្យនាំយកសម្រាប់ទៅឲ្យមគ្គទេវយក្សជាអចិន្ត្រៃយ៍ ទាល់តែអស់មនុស្សទោស ។ កាលបើទ្រង់ជ្រាបថាអស់មនុស្សទោសហើយ ទើបទ្រង់ត្រាស់បង្គាប់ឲ្យយកប្រាក់ ១.០០០ កហាបណៈដាក់លើដំរីមង្គល ឲ្យមន្ត្រីប៉ាវគងស្រែកប្រកាសថា "បើនរណា អាចនាំសម្រាប់ទៅឲ្យយក្សបាន, នរនោះ ចូរមកទទួលយកប្រាក់ ១.០០០ កហាបណៈនេះចុះ" ។

កាលនោះ សុតនបណ្ឌិតអ្នកចិញ្ចឹមមាតាបិតាបានស្ដាប់រាជប្រកាសហើយ ក៏ចូលទៅទទួលយកប្រាក់ ១.០០០ កហាបណៈនោះទៅជូនមាតាបិតាហើយជម្រាបថា "លោកឪពុក-ម្ដាយ! កូនសូមលាលោកមានគុណថ្ងៃនេះហើយ នាំសម្រាប់ទៅឲ្យយក្ស ដើម្បីទូន្មានយក្សឲ្យលះបង់អំពើទុច្ច-រិតផង" ។ ឪពុកម្ដាយតបថា "កូនអើយកុំទៅប្រថុយយក្ស មិនបានទេ! វាមិនស្ដាប់កូនទេ! វាមុខតែវាស៊ីកូនឯងមិនខានទេ ណាកូនប្រុស!" ។

សុតនបណ្ឌិតជម្រាបថា "លោកអ្នកមានគុណ ជាទីគោរព! សូមកុំព្រួយឲ្យសោះ, កូនជាអាចទូន្មានយក្សឲ្យបានប្រាកដមិនខាន, បើវាមិនស្ដាប់ទេ កូននឹងសម្លាប់វាភ្លាម ដើម្បីជាតិរបស់យើងរស់នៅ ៗ បើផ្ទុយទៅវិញ កូនត្រូវបរាជ័យ ក៏លោកឪពុកម្ដាយបានប្រាក់ ១.០០០ កហាបណៈដែរ, សូមលោកឪពុកម្ដាយជ្រាបថា "យុទ្ធសិល្បករ មានចិត្តបម្រើផលប្រយោជន៍

ជាតិ មិនត្រូវរាប់គ្រោះថ្នាក់ធ្លាក់មកលើខ្លួនឡើយ ។ គេត្រូវទទួលទុក្ខមុន គេនឹងសុខក្រោយគេ ។ ទោះជាមានឧបសគ្គយ៉ាងណា ក៏កូនត្រូវតែចេញទៅបង្ក្រាបយក្ខ ជាដាច់ខាត" ។ ឪពុកម្ដាយយល់ព្រមតាមសុំហើយថា "ទៅចុះណាកូនប្រុស! សូមឲ្យកូនមានជ័យជម្នះ! សូមគុណព្រះរតនត្រ័យជួយកូន!" ។ ព្រះពោធិសត្វសំពះលាម្ដាយឪពុកហើយ ក៏ដប់រសនាំទៅថ្វាយបង្គំព្រះមហាក្សត្រក្នុងព្រះកដភិន ។ ព្រះរាជាត្រាស់សួរថា "អ្នកនាំសម្រាប់ទៅឲ្យយក្ខ តើចង់បានអ្វីយកទៅខ្លះ?" ។ ព្រះពោធិសត្វក្រាបទូលថា "ទូលព្រះបង្គំចង់បានសុពណ៌បាទុក ស្បែកជើង និងព្រះខ័ន យកទៅជាមួយ" ។ ព្រះរាជា- "ហេតុអ្វីទើបអ្នកចង់បានរបស់ទាំងនេះយកទៅជាមួយ?", ព្រះពោធិសត្វ- "បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានជាទូលព្រះបង្គំចង់បានរបស់ទាំងនេះ ជាការសម្ងាត់របស់ទូលព្រះបង្គំផង តែសូមព្រះអង្គទ្រង់ជ្រាបថា បំណងរបស់ទូលព្រះបង្គំ គឺចង់ទូន្មានយក្ខឲ្យបានស្លូត, តែបើវាមិនតាមដំបូន្មានទេ ទូលព្រះបង្គំសម្លាប់ចោល ។ ព្រះរាជា- "ម្នាលអ្នកកំលោះ! យក្ខមានឥទ្ធិឫទ្ធិខ្លាំងពូកែណាស់, មិនអាចប្រយុទ្ធទប់ទល់នឹងវាបានឡើយ" ។ ព្រះពោធិសត្វ- "បពិត្រព្រះមហារាជ, ទូលព្រះបង្គំបានប្ដេជ្ញាចិត្តបូជាជីវិតប្រយុទ្ធនឹងយក្ខហើយ, សូមព្រះអង្គកុំទ្រង់បារម្ភ ព្រោះទូលព្រះបង្គំ បានសិក្សាយុទ្ធសិល្បដល់ថ្នាក់កំពូល, ទោះយក្ខក្ដី នាគក្ដី គ្រុឌក្ដី មិនអាចប្រយុទ្ធទប់ទល់នឹងទូល

ព្រះបង្គំបានឡើយ" ។ ព្រះរាជា– "សាធុ! សាធុ! ប្រពៃណាស់! តើលោកចង់បានអ្វីខ្លះទៀត" ។ ព្រះពោធិសត្វ– "សូមព្រះរាជទាន មនុស្សកាន់សុវណ្ណភាជន៍តាមទូលព្រះបង្គំ" ។ ព្រះរាជា ក៏ទ្រង់យល់ព្រម ហើយទ្រង់មានព្រះបន្ទូលថា "សូមលោកអញ្ជើញទៅឲ្យមានជ័យជម្នះ, ខ្ញុំនឹងប្រជាជនទាំងអស់ មានសង្ឃឹមនឹងចាំទទួលសេចក្ដីសុខសាន្តពីលោក" ។ ព្រះពោធិសត្វ ក្រាបថ្វាយបង្គំលាព្រះរាជា នាំបុរសអ្នកបម្រើទៅដើមជ្រៃ ឲ្យអ្នកបម្រើឈរចាំ នៅឆ្ងាយពីដើមជ្រៃ ។ ព្រះពោធិសត្វ ពាក់ស្បែកជើងមាស ប៉ាំងឆត្រស កាន់ព្រះខ័ននិងភាជន៍មាស ដើរចូលយ៉ាងរហ័សដល់ហើយឈរក្រោមម្លប់ជ្រៃ យកចុងព្រះខ័នថ្តក់ភាជន៍នោះ ហុចទៅឲ្យយក្ខ ។

តាមពិត យក្ខនោះ បើនរណាចូលទៅឈរក្រោមម្លប់ជ្រៃ ទើបយក្ខហ៊ានចាប់ជននោះបរិភោគ ។ ព្រះពោធិសត្វដឹងរឿងនោះ ទើបមិនចូលក្នុងម្លប់ជ្រៃរបស់យក្ខ ។ មគ្គទេវយក្ខ ក៏ពោលលួងលោមថា "ម្នាលបុរស! ចូរអ្នកមកបរិភោគជាម្ហូបយើង" ។ ព្រះពោធិសត្វឆ្លើយថា "ម្នាលមគ្គ-ទេវយក្ខ យើងស្គាល់ពុតកំហូចរបស់អ្នកហើយ, អ្នកមិនបាច់លួងយើងទេ, អ្នកស្គាល់យើងទេ? យើងឈ្មោះ សុតនបណ្ឌិត ជាអ្នកចិញ្ចឹមមាតាបិតា ជាបញ្ញាជន ជាយុទ្ធសិល្បករថ្នាក់កំពូល ។ បើអ្នកចង់បរិភោគយើង ក៏មិនបាន ព្រោះយើងនេះមិនបានជាន់លើដីអ្នក មិនបានជ្រកក្រោម

ម្លប់ជ្រៃអ្នក, យើងឈរជាន់លើសុពណ៌បាទុករបស់យើង! យើងឈរតែក្រោមម្លប់ឆត្ររបស់យើង ៗ យើងមកនេះបានប្រុងប្រយ័ត្នហើយ យើងប៉ងប្រយុទ្ធជាមួយអ្នកឲ្យដឹងថ្វីដៃគ្នាក្នុងគ្រានេះឯង" ៗ មគ្គទេវយក្ខបានស្តាប់ មានចិត្តជ្រះថ្លា គិតថាបុរសនេះមានប្រាជ្ញា ពោលពាក្យពីរោះគួរចង់ស្តាប់ ។

លុះយក្ខបរិភោគអាហាររួចហើយ ក៏និយាយទៅកាន់ព្រះពោធិសត្វថា "ម្នាលយុវជន! ចូរអ្នកមកយកភាជន៍របស់អ្នកត្រឡប់ទៅវិញចុះ" ៗ ព្រះពោធិសត្វសួរថា "ម្នាលមគ្គទេវយក្ស! ចុះមនុស្សនាំសម្រាប់មកឲ្យអ្នក ត្រូវអ្នកចាប់គេស៊ីជាងមួយឆ្នាំហើយនោះ តើត្រូវគិតដូចម្តេច?" ៗ មគ្គទេវ-យក្ខ- "រឿងនោះ ជារឿងរបស់យើងជាមួយព្រះរាជា គ្មានទាក់ទងនឹងអ្នកទេ ព្រោះព្រះរាជាបានសន្យាជាមួយយើងថា ឲ្យមនុស្សម្នាក់និងអាហារ ១ សម្រាប់យកមកឲ្យយើង" ៗ ព្រះពោធិសត្វ– "ពិតមែនហើយមហាយក្ខ! តែថាយើងជាពលរដ្ឋមួយរូប មិនបណ្តោយឲ្យអ្នកឯងរឹបជាន់ស៊ីគេទាំងអំ-ណាចទេ, ព្រះរាជារបស់យើង បានបញ្ជូនមនុស្សនិងសម្រាប់មកឲ្យអ្នកជាច្រើនណាស់ ហួសពីល្មមទៅហើយ គួរណាស់តែអ្នកបរិភោគតែអាហារបានហើយ, មិនសមបើហ៊ានរំលោភ ចាប់អ្នកនាំសម្រាប់បរិភោគទៀតសោះ ។ ម្នាលមគ្គទេវយក្ខ! អ្នកដឹងទេ ជាតិមុនអ្នកប្រព្រឹត្តអំពើបាប ទើបជាតិនេះ អ្នកកើតជាយក្ខ រង់ទុក្ខវេទនានៅយាមដើមជ្រៃ ៗ ហេតុនេះ ចូរ

អ្នកកុំប្រព្រឹត្តអំពើបាបបញ្ចវេរ គឺ មិនសម្លាប់មនុស្ស សត្វជាដើម ហើយត្រូវប្រព្រឹត្តនូវអំពើជាកុសល ចាប់ពីថ្ងៃនេះទៅ ទើបបានកើតជាមនុស្សមានសេរីភាពបរិបូរ” ។ មគ្គទេវយក្ខ “បពិត្រមហាបុរស! សូមលោកសម្ដែងអំពីបុណ្យបាប ឲ្យបានពិស្ដារឲ្យខាន ដោយអនុគ្រោះ” ។ ព្រះពោធិសត្វសម្ដែងថា

ម្នាលមគ្គទេវយក្ខ ចូរអ្នកលះបង់អំពើបាប ព្រោះអំពើបាបពុំមែនជាអំពើនាំមកនូវសេចក្ដីសុខត្រជាក់ឡើយ សុទ្ធតែជាអំពើនាំមកឲ្យអ្នកធ្វើមានសេចក្ដីក្ដៅក្រហាយ តាំងពីមានជីវិតរស់នៅ រហូតដល់ពេលស្លាប់ទៅ ក៏ត្រូវទៅកើតក្នុងអបាយភូមិទាំង ៤ ណាមួយថែមទៀត ដូចព្រះពុទ្ធដីកាថា ទុក្ខោ បាបស្ស ឧច្ចយោ ការសន្សំនូវបាប ជាហេតុនាំមកនូវទុក្ខ បាបានំ អករណំ សុខំ ការមិនធ្វើបាបទាំងឡាយនាំមកនូវសេចក្ដីសុខ ។

ម្នាលយក្ខ! ការលះបង់អំពើបាប ឈ្មោះថាអំពើល្អ ជាអំពើឲ្យអភ័យដល់ជីវិត, ទ្រព្យសម្បត្តិ, ទីកន្លែងនិងទឹកដីអ្នកដទៃ ឈ្មោះថាជាអំពើល្អ ដើម្បីសេចក្ដីសុខ-ចម្រើន ដល់អ្នកដទៃផង ដល់ខ្លួនឯងផង ។ ការលះបង់អំពើបាប ជាផ្លូវនាំសេចក្ដីសុខ-ចម្រើន តាំងពីមានជីវិតរហូតមរណកាល ក៏ត្រូវទៅកើតក្នុងសុគតិភព ។

ម្នាលយក្ខ! បុណ្យនិងបាប កើតមកអំពីបុគ្គលអ្នកធ្វើ ពុំមែន

កើតដោយទេវណាមួយ ដែលសក្តិសិទ្ធិប្រគល់ឲ្យ ឬទទួលយកបាបជំនួសអ្នកធ្វើបានឡើយ ។ បុណ្យបាប គ្មានពិធីអ្វីគេបន់ស្រន់ឲ្យរួចចាកបាប ឬឲ្យបានបុណ្យទេ គឺថាពុំមានករណីយកិច្ចអនុញ្ញាត ឲ្យធ្វើបុណ្យលាងបាបដោយការលុតក្រាបសំពះសុំអង្វរនោះឡើយ ដូចពុទ្ធភាសិតថា

អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធី អសុទ្ធី បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

បុគ្គលធ្វើបាបហើយ ដោយខ្លួនឯង រមែងសៅហ្មង ដោយខ្លួនឯង បុគ្គលមិនធ្វើបាបហើយ ដោយខ្លួនឯង រមែងបរិសុទ្ធ ដោយខ្លួនឯង, សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធ ឲ្យផលចំពោះខ្លួន, បុគ្គលដទៃ មិនអាចញុំាងបុគ្គលដទៃឲ្យបរិសុទ្ធបានទេ ។

បាបនិងបុណ្យដែលបុគ្គលណាធ្វើដោយផ្ទាល់ខ្លួន បុគ្គលនោះត្រូវបានទទួលផលរបស់បាបនិងបុណ្យ ដោយផ្ទាល់ខ្លួនវិញដែរ ពុំមានព្រះអាទិទេព ឬវត្ថុស័ក្តិសិទ្ធិណាមួយក្នុងលោក អាចជួយកាត់បន្ថយទុក្ខទោសពៃរ៍ជំនួសអ្នកធ្វើ ឬដោយ របស់អាត្មាប្រណីបានឡើយ ។

ម្នាលយក្ខ! កាលអ្នកពិចារណាឃើញទោស នៃការប្រព្រឹត្តអាក្រក់, ឃើញអានិសង្ស នៃការប្រព្រឹត្តល្អហើយ គប្បីលះបង់នូវទុច្ចរិត វៀរចាកអំពើបាបអកុសល គប្បីចម្រើនសុចរិត បំពេញកុសលកម្ម ឲ្យមានបរិបូណ៌ឡើងក្នុងសន្តាន ។ ការវៀរចាកអំពើបាប ដោយកាយវាចាចិត្តហើយ ឈ្មោះថាជាអ្នកជម្រះខ្លួនប្រាណ ឲ្យជ្រះមន្ទិលគ្រោតគ្រាត ជាអ្នកមានកាយវាចាចិត្តបរិសុទ្ធស្អាត គួរដល់ភាវនាកម្ម ប្រៀបដូចសាច់សំពត់ស្អាត អាចទទួលនូវការជ្រលក់ ដោយពណ៌ផ្សេង ៗ បានដោយល្អ ។

ម្នាលយក្ខ! ចូរអ្នក បំពេញកុសលឲ្យបរិបូណ៌ឡើង, ពាក្យថាកុសលនេះ បានដល់អំពើល្អទាំងអស់ ដែលលោកសង្គ្រោះយក សុចរិតធម៌ និងបុញ្ញកម្មផ្សេង ៗ មានការធ្វើទានរក្សាសីលជាដើម ។ ការដែលធ្វើ គ្រាន់តែលះបាបកម្មទុកជាកិច្ចវត្តដ៏ប្រសើរដែរហើយ ប៉ុន្តែមិនទាន់សម្រេចត្រឹមនេះទេ ត្រូវធ្វើសេចក្តីល្អ ដោយញុំាងកុសលកម្ម ឲ្យកើតឡើងក្នុងសន្តាន ជំនួសសេចក្តីអាក្រក់ ដែលលះបានហើយថែមឡើងទៀត ។

ម្នាលយក្ខ! ដើម្បីអប់រំកាយវាចាចិត្ត ឲ្យមានសីលធម៌ ត្រូវបំពេញកុសលធម៌ឲ្យបរិបូណ៌ឡើង ព្រោះកុសលធម៌ ជា

ឧបាយនាំមកនូវសេចក្តីសុខសប្បាយរីករាយ តាំងពីលោក

នេះ រហូតលោកខាងមុខ ដូចពុទ្ធភាសិតថា

ឥធ មោទតិ បេច្ច មោទតិ

កតបុញ្ញោ ឧភយត្ថ មោទតិ ។

បុគ្គលអ្នកមានបុណ្យធ្វើហើយ រមែងរីករាយត្រេកអរ

ក្នុងលោកទាំងពីរ គឺរីករាយក្នុងលោកនេះ លុះលះ

លោកនេះទៅហើយ ក៏រមែងរីករាយទៀត ។

ម្នាលយក្ខ! ការញ៉ាំងកុសលឲ្យកើតឡើង បានដល់ការ

បណ្តុះ បង្កើត សន្សំរឿយៗ ឲ្យកើតមានឡើង ដោយការ

បំពេញទាន, រក្សាសីល និងចម្រើនសមថកម្មដ្ឋាន ដើម្បី

រម្ងាប់នូវនីវរណធម៌ជាគ្រឿងសៅហ្មងចិត្តទាំង ៥ គឺ:

១- កាមច្ឆន្ទៈ សេចក្តីប្រាថ្នា ស្រឡាញ់ជាប់ក្នុងកាម,

២- ព្យាបាទៈការញ៉ាំងប្រយោជន៍ និងសេចក្តីសុខអ្នកដទៃឲ្យវិនាស,

៣- ថីនមិទ្ធៈ សេចក្តីខ្ជិលច្រអូស,

៤- ឧទ្ធច្ចកុក្កុច្ចៈ សេចក្តីរាយមាយក្តៅក្រហាយ,

៥- វិចិកិច្ឆា សេចក្តីសង្ស័យ ។

ដើម្បីបើបឈមទៅរកប្រយោជន៍ និងសេចក្តីសុខ ក្នុងមនុស្សលោក

និងទេវលោក ។

ម្នាលមគ្គទេវយក្ខ! ចូរអ្នកលះបង់នូវអំពើអកុសលចេញ, ចូរអ្នកបំពេញអំពើកុសលឡើង ៗ

ព្រះពោធិសត្វ សម្ដែងសង្ខេបតែប៉ុណ្ណេះ មគ្គទេវយក្ខស្ដាប់ហើយក៏កើតចិត្តជ្រះថ្លា លុតជង្គង់សំពះហើយពោលថា "បពិត្រមហាបុរស ជាទីគោរពស្មើជីវិត! សូមមេត្តាអនុគ្រោះទទួលខ្ញុំបាទជាសិស្ស ប្រៀនប្រដៅឲ្យបាន ខ្ញុំបាទល្ងិតល្ងង់ខ្លៅណាស់ ៗ បពិត្រមហាបុរស! តាំងពីថ្ងៃនេះទៅ ខ្ញុំបាទ ទទួលស្ដាប់តាមឪវាទដ៏មានខ្លឹមសារពីរោះនេះ ហើយនិងវៀរចាកអំពើអកុសល តម្កល់ខ្លួនបំពេញអំពើកុសល, មហាបុរសជឿខ្ញុំបាទចុះ ខ្ញុំបាទឈប់ដើរដេរជាន់សន្ធឹកសន្ធិន រំលោភបំពានលើសិទ្ធិសេរីភាពអ្នកទន់ខ្សោយ ហើយនិងជួយការពារគាំទ្រអ្នកតូចតាច ឲ្យរស់សមគ្គ-ភាពនិងកម្លាំងកាយចិត្ត" ៗ ព្រះពោធិសត្វដឹងថា យក្ខលុះដោយដំបូន្មានហើយ លោកត្រេកអរណាស់ ក៏ពោលថា "ម្នាលមគ្គទេវយក្ខមានអាយុ! ប្រពៃណាស់ ប្រពៃណាស់ ប្រពៃណាស់ ចូរចម្រើនដល់អ្នក ៗ

ព្រះពោធិសត្វ នាំមគ្គទេវយក្ខទៅក្រាបថ្វាយបង្គំ ព្រះមហាក្សត្រទូលតាមដំណើរហេតុការណ៍ថ្វាយទ្រង់ព្រះសណ្ដាប់ ៗ ព្រះទៅ ទ្រង់មានព្រះទ័យសោមនស្សក្រៃលែងចំពោះព្រះពោធិសត្វ ៗ ព្រះទៅ ទ្រង់ព្រះចិន្តាថា "រាជនេះ មានប្រាជ្ញាឈ្លាសវាងវៃ មានយុទ្ធសិល្បដល់កម្រិតកំពូល, អក្សរសាស្ត្រ និងធម្មសាស្ត្រដល់ថ្នាក់បណ្ឌិតហើយ, មានស្វាមីភក្ដិចំពោះ

ជាតិ សាសនា ព្រះរាជបល្ល័ង្ក និងកេរដំណាប្រៀបឲ្យប្រហែលពុំបាន ឡើយ, គួរលើកតម្កើងជាមន្ត្រីធំ ទើបសមនឹងគុណូបការៈ ដែលបាន ធ្វើហើយចំពោះជាតិ" ទ្រង់ព្រះចិន្តាដូចនេះហើយ ក៏ត្រាស់បង្គាប់ឲ្យរាជ-អាមាត្យនាំព្រះពោធិសត្វ និងយក្ខទៅសម្រាក ។ ទើបទ្រង់ប្រជុំអ្នក ប្រាជ្ញរាជបណ្ឌិត មហាបុរោហិតព្រឹទ្ធហោរា ព្រឹទ្ធសភានិងមន្ត្រីធំៗទាំង អស់ក្នុងព្រះរាជាណាចក្រ លុះជួបជុំហើយទ្រង់ត្រាស់ថា "ថ្ងៃនេះ អស់ លោក! ជាថ្ងៃជោគជ័យមហាប្រសើរ ដែលត្រូវកត់ចំណាំទុកក្នុងក្រាំង មាសនៃប្រវត្តិសាស្ត្រប្រទេសយើង, ជ័យជម្នះនេះ គឺ មហាវីរបុរសនាម សុតនបណ្ឌិត បានស្ម័យប្រទេសជាតិផុតពីមរណភាព ដឹកនាំយក្ខឲ្យលុះ តាមដំបូន្មានដ៏ប្រពៃរបស់លោក; គុណូបការៈនេះ គួរតែងតាំងលោក ក្នុង តំណែងជាមន្ត្រីធំ, តើអស់លោកយល់យ៉ាងណា?" ។ អង្គប្រជុំយល់ព្រម ដោយរីករាយ ។ លោកប្រធានព្រឹទ្ធសភាក្រាបទូលថា "បពិត្រព្រះករុណា ថ្ងៃពិសេស ប្រទេសជាតិយើង បើកុំតែបានមហាបុរសនេះ, យក្ខនឹង ចូលមកកាត់ក្បាល គួរណាស់ព្រះអង្គប្រទានតំណែងជា "មហាឧបរាជ" ទើបសមនឹងគុណូបការៈនេះ ក្រាបទូល ។ បន្ទាប់មកលោកអគ្គនាយកក្រ-សួងនានាក្នុងរាជវាំង ក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព, តាមយោ-បល់ទូលព្រះបង្គំជាខ្ញុំយល់ថា វាសនាអនាគតនៃប្រទេសកាសី ពឹងផ្អែក ផ្ទើលើមហាបុរសនេះពិតប្រាកដ ដើម្បីដឹកនាំប្រទេសទៅកាន់សន្តិភាព

បម្រើនូវរឿង, ដូចនេះទូលព្រះបង្គំជាខ្ញុំ សូមស្នើព្រះរាជយោបល់ សូមព្រះអង្គតាំងជាព្រះរជ្ជទាយាទ និងរៀបអភិសេកព្រះរាជធីតានៅក្នុងថ្ងៃធ្វើពិធីបុណ្យប្រទានតំណែង និងឋានន្តរសក្តិ "សម្តេចព្រះមហាឧបរាជ" តែម្តងទៅក្រាបទូល" ។ ព្រះមហាក្សត្រទ្រង់មានបន្ទូលថា "អស់លោក! តើមានយោបល់យ៉ាងណា ចំពោះរឿងនេះ? ខ្ញុំនឹងចាត់ការតាមអង្គប្រជុំ" ។ អង្គប្រជុំយល់ស្របទាំងអស់ ដោយអបអរសាទរយ៉ាងក្រៃលែង ។ ព្រះចៅក្រុងពារាណសី ស្តេចទ្រង់ត្រាស់ថ្លែងអំណរគុណអង្គប្រជុំថា "អស់លោក! ខ្ញុំត្រេកអរណាស់! អរគុណអស់លោកជាអនេក ព្រោះយោបល់អស់លោកស្របនឹងយោបល់របស់ខ្ញុំទាំងស្រុង, ៧ថ្ងៃទៀតយើងត្រូវធ្វើពិធីប្រទានតំណែងនិងអភិសេកព្រះរាជធីតារបស់ខ្ញុំ ដូចនេះ, សូមអស់លោកចាត់រៀបចំពិធីនេះឲ្យបានទៀងទាត់ និងឲ្យអ្នករាជការ-កម្មករក្នុងព្រះរាជាណាចក្រឈប់សម្រាក៣ថ្ងៃ ដើម្បីនឹងបានមករួបរួមក្នុងពិធីនេះផង ។

កាលព្រះពោធិសត្វ ទ្រង់បានទទួលការតែងតាំង ជាសម្តេចព្រះមហាឧបរាជ-ព្រះរជ្ជទាយាទនិងជាព្រះរាជសុណិសានៃព្រះចៅពារាណសីហើយ ទ្រង់បានសាងប្រាសាទមួយជូនមាតាបិតា នៅក្បែរប្រាសាទរបស់ព្រះអង្គ និងទ្រង់បញ្ជូនភោជនាហារ ទៅឲ្យមគ្គទេវយក្ស រាល់ៗថ្ងៃ ។ រាល់ៗខែ ព្រះអង្គធៀតយាងទៅសួរសុខទុក្ខប្រជារាស្ត្រ និងអ្នករាជការដែលនៅដាច់ស្រយាលឆ្ងាយៗពីរាជធានី ឬទីប្រជុំខេត្ត, ព្រះអង្គទ្រង់

ណែនាំពន្យល់ឲ្យចេះស្រឡាញ់គ្នា ចេះជួយធុរៈគ្នាទៅវិញទៅមក ចេះស្រឡាញ់ការហត្ថកម្ម ចេះស្រឡាញ់ផលប្រយោជន៍ជាតិ ចេះស្រឡាញ់ស្រែចំការ ។ល។ ថ្ងៃសីល ពេលព្រឹកទ្រង់ទទួលប្រជាជនដែលកើតទុក្ខមិនសុខចិត្តអំពីរឿងការក្ដី ។ ព្រះអង្គទ្រង់វែកញែកកាត់ដោយយុត្តិធម៌ ហើយទ្រង់ទូន្មានឲ្យលះបង់អំពើលោភលន់ជាហេតុនាំឲ្យវិនាសផង ។ ពេលល្ងាច ទ្រង់សម្ដែងធម៌ថ្វាយព្រះរាជា មន្ត្រី មហាជន និងមគ្គទេវយក្ខ ។ ទ្រង់បង្រៀនច្បាប់ និងអប់រំមន្ត្រីឲ្យចេះស្រឡាញ់យុត្តិធម៌ ចេះស្រឡាញ់រាស្ត្រ ចេះស្រឡាញ់ជាតិ ចេះស្រឡាញ់ផលប្រយោជន៍រាស្ត្រ និងចេះស្រឡាញ់អាជីវកម្មរបស់រាស្ត្រ ។ ដោយការដឹកនាំដ៏ឈ្លាសវៃ នៃព្រះពោធិសត្វ, ប្រជាពលរដ្ឋក្នុងប្រទេសមានការស្រុះស្រួលមូលមិត្តសាមគ្គីចងបាច់គ្នា ។ បើមានជនណាមួយមានធុរៈម្ដងៗ អ្នកផងតែងលើកគ្នាទៅជួយ រហូតដល់ការនោះបានសម្រេចជាស្ថាពរ ។ ប្រជាពលរដ្ឋក្នុងប្រទេសនេះ ឧស្សាហ៍ធ្វើការព្យាយាម និងបផ្ដាច់ចំពោះឧបសគ្គនានាដោយពុំមានចិត្តរាថយឡើយ ។ អ្វីៗ ដែលគេចង់បានហើយ គេពុះពារឧបសគ្គគ្រប់ជំពូក យកជ័យជម្នះឲ្យខាងតែបាន ។ បើមានទំនាស់គ្នានិងគ្នា គេតែងតែពិភាក្សា ដោះស្រាយភ្លាម គេមិនយកកំហឹងទល់កំហល់ទេ ។ ភោគផល ដែលកើតឡើងដោយការសាមគ្គី បានធ្វើឲ្យអ្នកស្រុកក្នុងប្រទេសទាំងមូល រស់នៅដោយសុខស្រួល ។

- ចប់ -

# ផ្នែកអក្សរសាស្ត្រ

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

(៣)

*ព្រះមហា អ៊ាង-ខាត់ រៀបរៀង*

អភិមទ៌ ពុ. កិរិយាកម្ទេច ។

អភិមទ៌ន នបុ. កិរិយាសង្កត់សង្កិន កិរិយាបំផ្លាញ ។ គុ. ពេលក្ដួលចិត្តបំផ្លាញ ។ -ម៌ទ៌ក គុ. ដែលបំផ្លិចបំផ្លាញ ។

អភិមឝ៌ ពុ. កិរិយាប៉ះពាល់ កិរិយាសេព ។ មឝ៌ក គុ. ដែលប៉ះពាល់ ។

អភិមឝ៌ន នបុ. កិរិយាបះ (ការបះធម្មតា) ។ គុ. ដែលបះ។ -ម៌ឝ៌ីន គុ. ដូចមុន ។

អភិមឝិ ដូចអភិមឝ៌ ។

អភិមាន ពុ. អភិមាន: គំនិត ម៉ត់ខ្លួនឯង ។ កិរិយាក្រអឺត។

-វុត្តិ គុ. ដែលយកតែគំនិតខ្លួនឯង ។ គុណ-
សព្ទនៃះ១ត រូប ។ -តាវៀត គុ. កើត
ហើយតែរ ។

អភិមានិន គុ. ដែលមានអភិមានៈ ។ -មានិតា ស្រី.
ភាពនៃ..មានអភិមានៈ ។

អភិមារុតបិ ព្រ.ន. ដោយប្រាណខ្ពស់ ។

អភិមុខ គុ. អភិមុខ ដែលមានមុខឆ្ពោះ ដែលចំពោះមុខ
-តា ស្រី. ភាពនៃកិរិយាមានមុខឆ្ពោះសេចក្តី
អនុគ្រោះ ។

អភិមុបិ ប្រស្រឡះ ។

អភិមុនិ ក្រិ.វិ. ចំពោះមុខមុនិ ។

អភិមុធិតិ គុ. ដែលជម្រុញ ដែលពន្យុះ។

អភិមូធិ ធាតុ លុប ។

អភិមូទ ធាតុ រីកកួញ យល់ ។

អភិមូគ ធាតុ [illegible] ។ -គ្រឿ គុ. [illegible]

ដែលបះពាល់ ដែលវាយ ។ -ម្ឫថជិ គុ.

ដែលកើតពីកិរិយាប៉ះពាល់ ដែលខុសច្បាប់ ។

អភិយជិ ធាតុ បូជាក្រៃលែង ជូនចំពោះ ធ្វើយញ្ញ ។

អភិយា ធាតុ ចូលទៅជិត ចូលកាន់ ចូលទៅគម្រាម ចូល លុក ។ —យ៉ាត គុ. ដែលចូលទៅចំពោះ មុខ ដែលជួប ដែលដល់ ។

អភិយា គុ. ដែលប្រុងប្រយ័ត្ន ។

អភិយាចិ ធាតុ អង្វរ ។

អភិយាចន នបុ. កិរិយាអង្វរ កិរិយាសុំ ។

អភិយាតុ ការក. អ្នកវាយលុក ។

អភិយាន នបុ. អភិយាន កិរិយាចូលលុក ។

អភិយាយិន គុ. ដែលចូលទៅជិត ដែលចូលលុក ។

អភិយុជិ ធាតុ ប្រកបក្រៃលែង ។ ចោទ វាយលុក ។ និយាយ ។ អញ្ជើញ ។ —យុត្ត គុ. ដែលវាយលុក ដែលចោទប្រកាន់ ដែលពិសោធ ។

អភិយុធ ធាតុ ច្បាំង ។

អភិយោក្តព្វ ដែលគប្បីប្តឹងក្តី ។

អភិយោក្តឫ ការក. អ្នកវាយលុក អ្នកប្តឹង អ្នកចោទ សត្រូវ ។

អភិយោគ បុំ. អភិយោគ កិរិយាយកចិត្តទុកដាក់ ។ បដិបត្តិ ។ កិរិយាចូលវាយ ។ កិរិយាប្តឹងក្តី ។

អភិយោគ្យ ដែលគួរតស៊ូ ។

អភិយោជ្យ ដែលគួរច្បាំង ។

អភិរក្ស៑ ធាតុ អភិរក្ស រក្សា ។ – រក្សិត គុ. ដែលរក្សា ។

អភិរក្សណ នបុំ. អភិរក្សណំ កិរិយារក្សា ។ – រក្សា ស្ត្រី. ដូចគ្នា ។

អភិរក្សិតឫ ការក. អ្នករក្សា អ្នកការពារ ។

អភិរញ្ជ៑ ធាតុ រីករាយ, ស្រើបស្រាល ។ – រក្ត គុ. ដែលស្រើបស្រាល ។ – រញ្ជិត គុ. ដែលឡើងពណ៌ ។

អភិរតិ ស្ត្រី អភិរតិ កិរិយាត្រេកត្រអាល ។

(នៅមានត)

# វប្បធម៌ មន-ខ្មែរ

លោក ឌីកា - តាម រៀបរៀង

---

ហេតុដែលខ្ញុំយកវប្បធម៌ មន-ខ្មែរ មកសរសេរនេះ ព្រោះខ្ញុំយល់ឃើញថា ជាតិទាំងពីរនេះមានអារ្យធម៌ វប្បធម៌ច្រើនណាស់ ដែលដូចគ្នា ដូចការគោរព ការប្រតិបត្តិជាដើម ។ សូម្បីតែអក្សរ ក៏មានកិនភាគ ឬ ន័យថា មន-ខ្មែរ ដែរ ។ ដើម្បីឲ្យងាយយល់នូវវប្បធម៌ខ្លះ ៗ ដែលស្រដៀងគ្នា ខ្ញុំសូមជូននូវតែខ្លះដូចតទៅនេះ ។

## អត្ថន័យ

ដើម្បីឲ្យងាយយល់នូវន័យនៃពាក្យថា មន សូមលោកអ្នកអានសង្កេតនូវន័យនៃពាក្យនេះឲ្យហ្មត់ចត់ ដូចតទៅនេះ ៖

តាមបរិភាសាបាលី ( Pali terminology ) ថា ពីដើមគេហៅមនថា រាមញ្ញៈ ឬ រាមញ្ញទេស (Ramaññadesa) តែពួកកុលសម្ពន្ធទាំគ្នា ហៅជនពួកនេះថា រ្ម័ន (Rman) បានជាក្លាយមកជា មន ដូច្នេះ ។ ពាក្យថា មន នេះជាឈ្មោះនៃជនមួយពួក ដែលពួកកុលសម្ពន្ធហៅថារ្មន ។

## ប្រជាជាតិមន និង ភារតារ

The Mòn people and Their History

ប្រជាជាតិដែលគេហៅថា មន ច្រើនគ្នាណាស់ដែលយល់ថា ជា

ប្រទេសភូមា ឬ ជាប្រជារាស្ត្រនៃប្រទេសភូមា ។ ឯពួកអឺរុបវិញ គេតែង តែនឹកថា មន នេះគឺជាជាតិតាឡាំង (Talaing)

ជាតិមនសព្វថ្ងៃនេះ ពិតមែនតែមានជាតិនិងគេដែរ តែមិនបាន នៅតែមួយកន្លែង ឬមានសិទ្ធិដូចសម័យដែលមនមានឥស្សរភាពពេញ បរិបូណ៌ទេ បើនិយាយឲ្យងាយចូលចិត្តទៅ មន សម័យនេះដូចគ្នានឹង ចាម នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ តែចាមរត់មកជ្រកនៅប្រទេសខ្មែរ ឯ មននៅក្នុងប្រទេសរបស់ឯង តែនៅត្រង់នេះបន្តិច ត្រង់នោះបន្តិច ។ ម្ចាស់ ស្រុក គឺមននេះនៅជាយជុំៗ ក្នុងប្រទេសភូមា ។ ជាតិមន ដែលមាន ច្រើននៅក្នុងប្រទេសភូមា ច្រើនតែនៅតាមដងទន្លេទាំងសងខាង ក្បែរ មាត់ទន្លេ (Salween) ក្បែរបេគូ ( Pegu ) ។

នៅឆ្នាំ ១៩១១ ការិយាល័យជំរឿនប្រជារាស្ត្រនៃប្រទេសភូមា បាន ធ្វើនូវការជំរឿនប្រជារាស្ត្រទៅ ឃើញមានជាតិមន នៅសល់ត្រឹមតែ ៣២០.៦៦៩ នាក់ តែបណ្ដាមនទាំងនេះ មានតែចំនួន ១៧៩.៤៤៣ នាក់ទេ ដែលអាចនិយាយភាសាមនបាន ។

ជាតិមននៅក្នុងប្រទេសភូមាសព្វថ្ងៃ នៅរាយតាមតែកន្លែងដែលខ្លួន ធ្លាប់នៅ ឬតាមតែការងារគេប្រើឲ្យនៅ ។ ទីដំបន់ដែលមានជាតិមននៅ ច្រើន ក្នុងប្រទេសភូមានឹ នៅដំបន់តេណាសេរ៉ិម (Tenasserim) មាន ចំនួនត្រឹមតែ ១៣៩.១៦៧ នាក់ នៅដំបន់អាមហឺស្ត (Amherst ចំនួន

១៣៩.៩៧០ នាក់ នៅដំបន់ថាទន (Thaton ចំនួន ៣៤.៨០៥ នាក់ ឯដំបន់បេគូ (Pegu វិញមានចំនួនតែ ១៩៦០ នាក់ ។ ក្រៅពីដំបន់ទាំងនេះ ជាតិមនមានចំនួនតិចណាស់ហើយ ស្ទើរតែរកសំគាល់ថាជាជាតិមនមិនបានផង ព្រោះពួកនេះមិនចេះភាសាមន មិនមានទំនៀមទំលាប់មន ។

សម័យដើម ដំបន់នៅប្រទេសភូមា ដែលមានជាតិមននៅកាន់កាប់នៅឡើយ ភាសាមនផ្សាយអំណាចរកតទៅទៅស្ទើរតែគ្រប់ដំបន់ ដោយធាប់ហើសណាស់ ។ នៅដំបន់ខាងជើង ភាសាមនបានផ្សាយអំណាចទៅដល់ប្រូម (Prome) ឯខាងត្បូងវិញ ក៏ជាតិមនទំផ្សាយរកតទីអំណាចរបស់ខ្លួនណាស់ដែរ តែមកដល់ក្រោយ ជាតិមនត្រូវថយអំណាចហើយចំនួនជនជាតិមន ក៏ថយចំនួនទៅតាមលំដាប់ដែរ ពីព្រោះជាតិភូមាចូលមកកត្សាតប្រទេសមន ហើយភូមាបានតាំងអំណាចស៊ីប់នៅលើពួកមនបានហើយ ទើបបង្កើតជាអាណាចក្រឡើងហៅថាអាណាចក្រភូមានៅបាគន (Bagan) ហើយប្រជាជាតិភូមាទៅតាំងទីនៅតាវ៉យ (Tavoy) និងនៅតេណាសេរ្សិមខាងត្បូង (South Tenasserim) ហេតុដូចនេះហើយ ដែលធ្វើឲ្យជាតិមននេះ ចេះតែថយចំនួនទៅជាដរាប ។

រាជាណាចក្រមននៅតាំងបានតែត្រឹម គ.ស. ១៥៤០ ព្រោះតែមានការកត្សាតរបស់ស្ដេចក្សត្រភូមាមកពីតូងគូ (Taungu) ហើយក្រោយមកទៀតបានទៅពួកភូមាមកគ្រួតត្រាភាគខាងលើ ។ ព្រឹត្តិការណ៍នេះហើយ

ដែលជាហេតុនាំឲ្យជាតិមន បាត់បង់ជាតិរបស់ខ្លួន ឬថយចំនួនជាតិរបស់ខ្លួនជាលំដាប់រហូតមកដល់ថ្ងៃនេះ ។

អំណាចភូមាលើជាតិមន និង ភាសា

ប្រជាជាតិណាក៏ដោយ ប្រទេសណាក៏ដោយ ឲ្យតែបាត់បង់ឯករាជ្យជាតិហើយ ភាសាក៏បាត់បង់តាមនោះទៅដែរ ដូចមានភាសិតថា "ភាសាបាត់ ជាតិរលាយ" ។

លទ្ធផលដែលនាំឲ្យភាសាមននេះ បាត់បង់ថយឥទ្ធិពលជាលំដាប់នោះមកពីសន្តិវង្សអាលោមប្រា (Alompra Dynasty) នៅសតវត្សទី១៧ ដល់សតវត្សទី ១៩ បានប្រើអំណាចសង្កត់សង្កិន ជាតិមនពេករកតែងើបមុខមាត់មិនបាន ។ សម័យដែលភូមាមកគ្រប់គ្រងមន កន្លែងណាដែលមានជាតិមននៅ ច្រើននិយាយភាសាមនច្រើន កន្លែងនោះពួកការភូមារកមធ្យោបាយ ដើម្បីធ្វើឲ្យជាតិមនមានចំនួនតិចឬកុំឲ្យនៅមួយកន្លែងមានគ្នាច្រើន ។ ការធ្វើដូច្នេះ ដើម្បីកុំឲ្យពួកមនទាក់ទងគ្នា និងកុំឲ្យនិយាយភាសាមនរកគ្នា ។ ការបំបែកគ្នាឲ្យនៅដាច់ដោយឡែកដូច្នេះជាហេតុនាំឲ្យភាសាមនចុះថយ រកមនុស្សនិយាយជាមួយគ្នានៃភាសាថយហើយ ពួកភូមាយល់ថា ជាតិមននឹងមានចំនួនថយដែរ ។ ភាសាមនដែលចុះខ្សោយលែងប្រើប្រាស់នៅ គ.ស. ១៧៥៧ មាននិយាយទាក់ទងគ្នាបន្តិចបន្តួច ហើយមកពី គ.ស. ១៨១៦ ដល់ ១៨៥២ នៅ

បេគូ (Pegu) ក៏មិនមានច្បាប់ណាមួយជួយការពារភាសាមនឲ្យមាននិយាយ ឬប្រើប្រាស់ដែរ ។ សូម្បីតែនៅតេណាសេរីម ដែលជាកន្លែងធ្លាប់មានជាតិមននៅច្រើនស្រាប់ ហើយមននៅមានអំណាចខ្លះផង ក៏មិនមានច្បាប់ណាមួយជួយគាំពារភាសាមនឡើយ ដល់មកសម័យដែលរដ្ឋាភិបាលអង់គ្លេស ចូលមកគ្រប់គ្រងប្រទេសភូមា ក៏អង់គ្លេសមិនអើពើនឹងជួយការពារឲ្យជាតិមនមានការប្រើភាសាមនដែរ ។

ហេតុដែលខ្ញុំយកអាណាចក្រទ្វារាវតីមកនិយាយនេះ ព្រោះខ្ញុំចង់បង្ហាញឲ្យឃើញនូវវប្បធម៌មន-ខ្មែរដែលដូចគ្នាខ្លះ ។ ខ្មែរយើងពីដើមធ្លាប់ផ្សាយអាណាចក្រទៅទល់គ្នានឹងមន ដូចអាណាចក្រទ្វារាវតី លពបុរី សុខ្ទៃ អាណាចក្រដែលខ្មែរធ្លាប់គ្រួតត្រាមកជាច្រើនឆ្នាំ ។

## អាណាចក្រទ្វារាវតី

## ព.ស. ៨៦០ ដល់ ១១៥០

តាមសេចក្ដីកត់ហេតុរបស់ចិនថា មានអាណាចក្រមួយឈ្មោះថា ទ្វារាវតី នៅក្នុងរវាងស្រីក្សេត្រ គឺភូមា សព្វថ្ងៃ និងឥសានបុរី ខ្មែរ ។ អាណាចក្រនេះប្រហែលជាទីរួមខេត្រ គឺមណ្ឌលក្រុងទេព អាយុធ្យា នគរជយស្រី រាជបុរី នគរសួតិ ពិណ្ណុលោកនិងប្រាចីណ ជាអាណាខេត្ត ។ និយាយពីអាយុធ្យា និងបាងកកវិញ ក្រុងទាំងពីរនេះ អយុធ្យាកើតមានពី

ឆ្នាំ ១៧៨១(១) ។ អាណាចក្រទ្វារវតី ពីដើមជារបស់ លវោ (លាវ) តែមិនមែនលាវនៅលួងប្រាបាង ឬវៀងចាន់ទេ ។ តែវេលាក្រោយមក នៅ ព.ស. ១៥០០ ខ្មែរគម្រាបលវោបាន ហើយក៏ចូលទៅនៅគ្រប់គ្រងអស់កាលជាយូរ តែការគ្រប់គ្រងនៅសម័យនោះ ជាប្រទេសរាជ ។ សម័យដែលខ្មែរនៅគ្រប់គ្រងទីរាជធានី នៅលពបុរី ឬជួនកាលនៅអយុធ្យា តែច្រើននៅលពបុរី ព្រោះលពបុរី ជាទីក្រុងចាស់យូរមកហើយ ឯក្រុងអយុធ្យានេះ ពីដើមក្នុងសម័យលវោគ្រប់គ្រងមិនមានឈ្មោះទេ ទើបមាននៅពេលដែលខ្មែរចូលទៅនៅគ្រប់គ្រង ។

នៅលពបុរី គេឃើញមានសិលាចារឹកមួយ ដែលជាភាសាមន ។ នៅសិលាចារឹកនោះ មាននិយាយថា ជាតិមនបានមកនៅទីនេះ ។ អ្នកដែលបានមកតាំងទីនៅ២កន្លែងនោះគឺមន ដែលចុះមកពីលវោ មានព្រះនាងចាមទេវីជាមេ ។

ដល់ខ្មែរចូលទៅគ្រប់គ្រង មានធ្វើថ្នល់កាន់គ្នាទៅវិញទៅមករវាងក្រុងយសោធរបុរី និង លពបុរី ។

## ពង្សាវតារលពបុរី

ដើម្បីឲ្យងាយយល់ នូវវប្បធម៌មន-ខ្មែរ និងការទាក់ទងរវាងមននិងខ្មែរខ្ញុំសូមនិយាយយ៉ាងខ្លីពីអាណាចក្រលពបុរី សម័យដែលប្រទេសកម្ពុជា

---

១-២-Histoire Ancienne des Etats Hindouisés, par G. Coedès, page 94.

នៅក្នុងមហាអំណាច ។ នៅសម័យប្រមាណ ព.ស. ១៥០០ មានសិលាចារឹកខ្មែរជាដំបូង នៅក្រុងលពៅដែលមានព្រះនាមនៃមហាក្សត្រខ្មែរប្រាកដនៅសិលាចារឹកនោះផង គឺព្រះបាទព្រះសូរ្យវរ្ម័នទី ១ ។ ក្រៅពីសិលាចារឹកនេះ នៅមានវត្ថុថៃទៀតជាកស្តុតាងដូចជាការរចនាជាដើមដែលខ្ញុំនឹងនិយាយទៅខាងក្រោយ ។ ការទាំងនេះហើយ ដែលនាំឲ្យយើងដឹងច្បាស់ថា ក្រុងលពៅ ឬលពបុរី ធ្លាប់ជារាជធានីរបស់ខ្មែរ ជាក្រុងដែលខ្មែរធ្លាប់គ្រប់គ្រងត្រួតត្រាអស់កាលជាយូរឆ្នាំ ។

ការដែលថា ខ្មែរនៅត្រួតត្រាក្រុងលពៅ តាមសិលាចារឹកខ្មែរនេះឃើញថា នៅមិនទាន់អស់ចិត្តទេ តែបើសិនជាសង្កេតតាមឯកសារបរទេសដូចជាឯកសារភាសាលាវជាដើម ឬភាសាបាលី ក៏មាននិយាយដូចតែឯកសារខ្មែរដែរ ។ ឯកសារលាវ នៅឈៀងម៉ៃ ដំណាលថា ប្រមាណ ព.ស. ១៥៥០-១៦០០ ក្សត្រគ្រប់គ្រងក្រុងហរិបុញ្ជ័យ ព្រះនាមត្រាពក ឬអត្រាពក បានធ្វើសឹកនឹងស្តេចដែលជាអ្នកនៅគ្រប់គ្រង ក្រុងលពៅព្រះនាមថា ឧច្ឆិតចក្រវត្តិ ។ ខណៈនោះកំពុងតែធ្វើសឹកនឹងគ្នា មានក្សត្រដែលគ្រប់គ្រងនគរស្រីធម្មរាជ បានចូលមកវាយក្រុងលពៅបាន ។ ព្រះរាជឱរសរបស់ក្សត្រនគរស្រីធម្មរាជ បានឡើងគ្រប់គ្រងរាជសម្បត្តិ ហើយទើបតាំងព្រះវង្សថ្មី ។ ព្រះរាជឱរសនោះ គឺព្រះបាទសូរ្យវរ្ម័នទី ១ ។ ព្រះរាជគន្ថនេះ កាលបានឡើង សោយរាជប្រទេសកម្ពុជាហើយ ទ្រង់បានរួម

យកមណ្ឌលដែលព្រះបិតាវាយបាន ឲ្យចូលមកជាអាណាចក្រកម្ពុជា ។

ព្រះបាទសុរិយវរ្ម័នទី ១ ដែលស្តេចយាងមកពីប្រទេសស្រីធម្មកជ ដែលជាប្រទេសកាន់ព្រះពុទ្ធសាសនា ព្រះអង្គបានជួយទំនុកបំរុងព្រះពុទ្ធសាសនា ដល់ព្រះអង្គសោយទីវង្គតទៅ បានទទួលព្រះមរណៈបច្ឆានាមថា ព្រះនិព្វានបទ ។

ទំនៀមបូជាសពរបស់ពួកមន

ទំនៀមទម្លាប់របស់មនជាច្រើន ដែលមានការគោរព ឬប្រព្រឹត្តដូចគ្នា តែការយកទំនៀមទម្លាប់ទាំងអស់មកអធិប្បាយ ឃើញថាជាហេតុនាំឲ្យអស់ពេល តែពេលនេះ ខ្ញុំយកតែការបូជាសពរបស់មនដែលឃើញថាដូចគ្នានឹងខ្មែរជាច្រើន គឺៈ ។

## ១- ការលើកសពចំអាសទឹក

ការលើកសពចំអាសទឹក តាមទំនៀមរបស់មន ឃើញមានប្លែកពីខ្មែរសព្វថ្ងៃ មនពេលលើកយកសពមកចំអាសទឹក ត្រូវមានមនុស្ស ៧ នាក់ ៗ មនុស្សទាំង ៧ នាក់ នេះត្រូវកើតខុសថ្ងៃគ្នា ៗ ពេលចូលទៅកន្លែងតម្កល់សពដែលត្រូវយកសពមកចំកាសទឹក គេត្រូវឲ្យមនុស្សដែលកើតនៅថ្ងៃអាទិត្យទៅមុន ហើយទើបអ្នកដែលកើតនៅថ្ងៃចន្ទអង្គារ ជាបន្តបន្ទាប់គ្នារហូត ដល់អ្នកដែលកើតថ្ងៃសៅរ៍ចូលទៅ បន្តបន្ទាប់គ្នា ៗ កាលបើលើកសពចំកាសទឹករួចហើយ ពេលចេញមកវិញ ត្រូវឈរជាជួរសិន

មិនមែនម្នាក់ស្រោចទឹកលើសពហើយចេញមកទេ ត្រូវចេញមកបន្តបន្ទាប់គ្នាដែរ តែត្រូវអ្នកដែលកើតថ្ងៃសៅរ៍ចេញមកមុន ហើយសឹមអ្នកកើតថ្ងៃសុក្រ ព្រហស្បតិ៍ រហូតដល់អ្នកកើតថ្ងៃអាទិត្យចេញក្រោយគេ ។

ចំណែកទឹកដែលត្រូវយកទៅចំអាសសពនោះ ត្រូវដាំឲ្យពុះ ឬឲ្យក្តៅសិនហើយតម្កល់លើជើងក្រាន ដែលតម្កល់ថ្ម ៣ ដុំ ដែលជានិមិត្តរូបនៃភូមិទាំង ៣ គឺកាមាវចរភូមិ រូបាវចរភូមិ និងអរូបាវចរភូមិ ។

## ២ – ការបង់លុយក្នុងមាត់នៃសព

លុះចំអាសទឹករួចហើយ គេតែងបង់លុយទៅក្នុងមាត់នៃសព ។ ហេតុដូចម្តេចបានជាចាំបង់លុយទៅក្នុងមាត់នៃសព : តាមទំនៀមមនុស្សយល់ថា ការស្លាប់ទៅកាន់ឋានខាងមុខ ត្រូវឲ្យមានទ្រព្យសម្បត្តិខ្លះយកទៅជាមួយផង បើពុំនោះទេត្រូវឲ្យមានលុយកាក់ខ្លះ គ្រាន់ចាយវាយទិញរបស់ដែលត្រូវការ ។

ចំណែកខាងខ្មែរ- តាមឯកសាររបស់លោក ប៊ូ ប៊ូ ថា ការបង់លុយទៅក្នុងមាត់សព ដោយមានរឿងដូចតទៅនេះ :

មានប្តីប្រពន្ធពីរនាក់ ស្រឡាញ់គ្នាណាស់ មានមាសប្រមាណជា ១ ប្រាក់ ៗ ប្តីប្រពន្ធបានដាំគ្នាទៅវិញទៅមកថា បើនរណាស្លាប់ទៅសូមឲ្យយកមាសបង់ទៅក្នុងមាត់ផង ។ ស្រាប់តែះក្រោយមក ប្តីស្លាប់មុន ប្រពន្ធក៏យក

មាសនោះទៅបង់ក្នុងមាត់ប្ដីតាមបណ្ដាំ ។ លុះបូជាសពប្ដីរួច ឃើញមាសនៅសល់ប្រហែល ៣ ស្លឹង ។

ថ្ងៃក្រោយមក ព្រះរាជាមានព្រះរាជបញ្ជា ឲ្យរៃមាសម្នាក់ ១ បាទ តែអ្នកមេម៉ាយនោះ មានមាសត្រឹមតែ ៣ ស្លឹង ទើបចូលទៅក្រាបថ្វាយមាសដែលសល់ពីភ្លើង ព្រះរាជាទ្រង់ព្រះសង្កេត ទើបឈប់ឲ្យរៃមាសទៅ ។

## ៣-ការរំកិលសព

ថ្ងៃរំកិលសពចេញពីផ្ទះ តាមទំនៀមមន គេមិនយក ឬរំកិលសពចេញតាមទ្វារដែលចេញចូលសព្វថ្ងៃទេ ហើយមិនឲ្យចុះតាមជណ្ដើរដែលមនុស្ស ឬម្ចាស់ផ្ទះចុះឡើងទេ ។ គេត្រូវទំលាយជញ្ជាំង ហើយត្រូវធ្វើជណ្ដើរផ្សេងមួយទៀត ទុកសម្រាប់តែរំកិលសពចុះប៉ុណ្ណោះ ។ សពត្រូវសែងចេញយកទៅបូជា ត្រូវសែងយកក្បាលទៅមុន ព្រោះកាលដែលព្រះសមណគោតម បានរៀបចំពិធីឈាបនកិច្ចព្រះបិតារបស់ព្រះអង្គ ក៏ហែព្រះសពយកព្រះកេសទៅមុនដែរ ។ តែសម័យមុននេះ គេសែងសពយកជើងទៅមុន ។

លុះទៅដល់ឈាបនដ្ឋានហើយ គេត្រូវហែប្រទក្សិណទីបូជាសពឬឈាបនដ្ឋាន ៣ ជុំនេះជានិមិត្តរូបនៃការកើត ឈឺ ស្លាប់ ។ តាមឯកសាររបស់លោក ប៊ូ ប៉ុ ដា បុព្វជនដែលមានកិលេសច្រើន តែងតែវិលវល់

ចាស់ ឈឺ ស្លាប់ កើតនៅក្នុងរាលវដ្តសង្សារ ហេតុដូច្នេះហើយបានជាគេហៅប្រូចក្សិណឈាបនដ្ឋាន ៣ ជុំដែរ ។

តាមទំនៀម នៅក្នុងពិធីបូជាសពនៅមានច្រើនណាស់ ដែលមានពិធីប្រហាក់ប្រហែលនឹងខ្មែរ តែពេលនេះ ខ្ញុំយកតែពិធី ៣ យ៉ាងនេះមកជូនជាឧទាហរណ៍ ដើម្បីឲ្យឃើញថា ពួកមនមានទំនៀមច្រើនដែលដូចនឹងខ្មែរ ។ ទំនៀមបូជាសពពួកមន មិនមែនដូចគ្នាតែទាំងអស់ទេ មានកន្លែងខ្លះ ក៏ខុសដែរ ។ ដូចលោក R.ហាលីដេថា ទំនៀមក្នុងការបូជាសពមនមានពិធីខុសគ្នាផ្សេងៗ ខ្លះ ដូចពួកមនខ្លះ តែមានអាយុឬមានសភាពនិងវ្ល័មណាកាល គេតែងធ្វើផ្ទះ ឬពេងដាច់ដោយឡែកសម្រាប់តែឲ្យមនុស្ស គេមិនចង់ឲ្យមនុស្សស្លាប់នៅក្នុងផ្ទះជាមួយទេ ព្រោះគេខ្លាចក្រែងចង្រៃ ។

## ចេតិយ

ការរចនារបស់មន-ខ្មែរមិនដូចគ្នាប៉ុន្មានទេ គេនៅសង្កេតបានថានេះជារបស់ខ្មែរ នេះជារបស់មន ដូចការកសាងព្រះពុទ្ធរូបជាដើម ។ ការកសាងព្រះពុទ្ធរូបតាមបែបខ្មែរ និងមន គ្រាន់តែក្រឡេកមើលភ្លាមគេអាចសំគាល់បានថា នេះជារបស់មន នេះជារបស់ខ្មែរ ។

មុនពុទ្ធសករាជ ៩៤៣ ដល់ ១៥៤៣ នៅប្រទេសសៀម គេឃើញ

ក្បាច់រចនា ថែបមនច្រើនជាង មនដែលយកមកសាងព្រះពុទ្ធរូបនេះ សុទ្ធតែពួកមនមកពីប្រទេសភូមាខាងក្រោម ។ ថែបរចនារបស់មននេះ ជាក្បាច់ដែលមានលំនាំតាមថែបរចនារបស់ហិណ្ឌូ តាំងពីពុទ្ធសករាជ ៨៤៣ ដល់ ៩៤៣ ។ ក្បាច់រចនារបស់មននេះហើយ ដែលគេស្គាល់បានថាវង្សនៃស្តេចមន ក្នុងសម័យគុប្តៈ ឥណ្ឌាភាគខាងជើង ។

លុះមកដល់ពុទ្ធសករាជ ១៥៤៣ ដល់ ១៧៩៣ រចនារបស់ខ្មែរក៏ចូលទៅនៅប្រដែងជាមួយរចនាមន ព្រោះតាំងពីពុទ្ធសករាជ ១៥៤៣ ស្រុកសៀមកណ្តាល នៅក្នុងអំណាចស្តេចខ្មែរគ្រប់គ្រង ដូច្នេះហើយ បានជាគេឃើញមានរចនាខ្មែរនិងមននៅលាយឡំគ្នា ។

តែបែបរចនាទាំងពីរនេះ នៅឃើញផ្សេងគ្នា ។ ថែបឬកិនភាគនៃការរចនារបស់មន-ខ្មែរ ដូចការកសាងព្រះពុទ្ធរូបជាដើម ព្រះពុទ្ធរូបខ្មែរមានទ្រង់ទ្រាយជារូបបុរស ឃើញស្តែងជាងព្រះពុទ្ធរូបថែបមន ។

អាស្រ័យហេតុនេះហើយ បានជាគេអាចសន្និដ្ឋានបានថា ខ្មែរ-មន មានវប្បធម៌ច្រើនដូចគ្នា មិនមែនតែខាងរចនាទេ ដែលនៅលាយឡំគ្នា សូម្បីតែខាងភាសា និងអក្សរ ក៏ឃើញនៅលាយឡំគ្នាដែរ ។ គេឃើញមានសិលាចារឹករបស់ខ្មែរជាច្រើនដែលនៅលពបុរី ជាភាសាខ្មែរខ្លះ មានលាយភាសាមនខ្លះ ។ សូមអានទៅខាងក្រោយ លោកអ្នកនឹងឃើញ សិលាចារឹករបស់ខ្មែរនៅលពបុរី :

## សិលាចារឹកខ្មែរនៅលពបុរី

សិលាចារឹកនេះហើយ ជាស្នាដៃមួយសរឲ្យឃើញថា អក្សរធម៌របស់ខ្មែរនៅតែពាសពេញប្រទេសសៀម ។ សិលាចារឹកខាងក្រោមនេះជាសិលាចារិករបស់ខ្មែរនៅលពបុរី :



សរសេរជាខ្មែរសព្វថ្ងៃ :

១- រៅបុណ្យជុស្នាចយុគ្រោះ

២- ជេកមុនជុនតក្យាកល

៣- ត្នាចរិតយមោញះ

៤- ខះចបុណ្យតាបឥន្ទ

៥- ជេកមុនជុនតក្យាក

៦- វ្ទេរគ្យសះបជ្ជោ

៧- វបិបូះ

សេចក្ដីប្រែសំរួល: ១ នេះគឺជាបុណ្យរបស់គ្រហស្ថឈ្មោះ ផុស្វចយុ ។ ២- មានសទ្ធា បរិចាគខ្ញុំកំដរឲ្យបំរើវត្តអាកម ។ ៣- សទ្ធាចរិត ជាឈ្មោះអ្នកធ្វើអំណោយ ៤- ចាប ឥន្ទ្ន បានធ្វើបុញ្ញកម្ម ៥- ខ្ញុំកំដរដែល បានថ្វាយទៅវត្តអាកម ៦- ឈ្មោះជាវត្តិទៃ្យស្រះ ទិដ សិ ៧- ក្របីបី ។

សិលាចារឹកនៅលពបុរី ដែលយកមកធ្វើជាឧទាហរណ៍នេះ ជាសិលាចារឹករបស់មន-ខ្មែរ ។ ម៉ែចបានជាហៅថារបស់មន ខ្មែរ:

បញ្ហានេះ ខ្ញុំដែលជាអ្នកសរសេរអត្ថបទនេះ ក៏មិនដឹងជាភាសាមនដូចម្ដេចដែរ តែការអានតាមឯកសាររបស់អ្នកប្រាជ្ញចេះដឹងធំៗ ដូចលោកហ្ស.សឺដេស G. Coedès ជាដើមឃើញថាសិលាចារឹកនេះ ជាភាសាមនមានលាយភាសាខ្មែរលោកហ្ស.សឺដេស បានយោងប្រាប់ទៅតាមឯកសាររបស់លោក M. Duroiselle ជាអគ្គិក្សបុរាណវត្ថុនៅប្រទេសភូមា ។

សិលាចារឹកនេះមានអត្ថបទយ៉ាងសង្ខេប ដែលមានអក្សរមានលំនាំជាអក្សរខ្មែរ ។ បែបអក្សរដែលចារនៅ លើសិលាចារឹកនេះ មានលំនាំជាអក្សរខ្មែរ នៅសតវត្សទី ៦ ឬ ៧ ។ បើបែរទៅមើលសិលាចារឹកជាភាសាបាលីវិញនៅស្រុកសៀម ដូចជាសិលាចារឹកនៅព្រះបឋមស្ដូបជាដើម ។ សិលាចារឹកនៅលពបុរីនេះ មានអត្ថបទ ជាភាសាបុរាណហើយរលប់ខ្លះ ។ ។

សូមអានអត្ថបទនៅទំព័រ ៥០៥ ហើយសូមប្រៀបធៀបនឹងសិលាចារឹកខ្មែរដទៃទៀត ។

## ការប្រៀបធៀបភាសា

ដើម្បីឲ្យឃើញថាភាសាមន និង ខ្មែរមានអំបូរមកជាមួយគ្នា សូមលោកអ្នកអានសង្កេតពិនិត្យ នូវភាសាទាំងពីរនេះ និងភាសាកុល-សម្ពន្ធនៅក្បែរ ៗ បានជាខ្ញុំយកភាសាអ្នកនៅភ្នំមកនិយាយផង ព្រោះខ្ញុំយល់ឃើញថា ពួកអ្នកនៅភ្នំមានភាសានិយាយមិនទាន់ប្រែទៅរកភាសានេះ ឬ ភាសានោះនៅឡើយ :

| ខ្មែរ | មន(១) | ស្ទៀង |
|---|---|---|
| ត្រី | កា | កា |
| កោង | កុន | |
| កូន | កន | កុន |
| ទៅ | ចារ | សៅ |
| ដើង | ជើង | ជឹង |
| ដៃ | ចាយ | ស៊ិស |
| ដី | តី | តេះ |
| ថ្ម | ថ្ម | តឹះមៅ |

១- សូមអភ័យទោស បើការអានភាសាមន និង ស្ទៀង មិនបានត្រឹមត្រូវតាមសូរសាស្ត្រ ។

| | | |
|---|---|---|
| ល្ពៅ | គ្ពិ | |
| ឆ្នាំ | ស្នាំ | សឹណាំ |
| ទី | ទក | ទក |
| ប្រមុះ | មុះ | គ្រេមុះ |
| ថ្មី | ភះមឺ | មុី |
| បុណ | រើស | រៀស |
| រុយ | រូយ | រូយ |
| សក់ | សុក | សុក |

## ការប្រៀបធៀបភាសាខ្មែរ-មន ១:

| ខ្មែរ | មន | ខ្មែរ | មន |
|---|---|---|---|
| សេះ | ឆេះ | ដើម | គេម |
| អុស | អស់ | សុបាយ | ជាក់ប៊ុង |
| កូន | កន | កូនប្រុស | កនប្រុស |
| ដក់ថ្នាំ | ជាក់កះអ៊ុ | កូនស្រី | កនស្រី |
| បាយ | ប៊ុង | វត្ត | ពោង |
| វត្តឧណ្ណាលោម | ឧណ្ណាលោមពោង | អាចម៍ | អ៊ិក |
| ដៃ | តៃ | បួន | ប៉ាន |
| ក្ដយ | ក្ទិន | ស្រូវ | ស្រូ |

# ការរាប់ចំនួន

ដើម្បីឲ្យងាយយល់ក្នុងការអាន សូមប្រៀបធៀបតាមអក្សរ

| ខ្មែរ | មន | ស្ទៀង | ព្រាក | |
|---|---|---|---|---|
| Muoy | Moy | Mui | Muoi | 1 |
| Pir | | Bar | Bar | 2 |
| Bei | Pi | Pe | Pe | 3 |
| Buon | Pan | Puon | Poun | 4 |
| Pram | | Pram podam | Pram | 5 |
| Pram muoy | | Prau | Prau | 6 |
| Pram pir | Tapah | Poh | Pah | 7 |
| Pram bei | D-cam | P'ham | Pham | 8 |
| Pram buon | | Sienh | Chin | 9 |
| Dap | | djemat | djet | 10 |

ការប្រៀបធៀបនូវភាសាទាំង ៤ បែបនេះ ឃើញមានភាសាខ្លះរាប់ដូចគ្នា ខ្លះស្រដៀងគ្នា ។

ក្រៅពីភាសាទាំង ៤ នេះ សូមលើកយកភាសាអ្នកនៅក្នុងខេត្តមកប្រៀបធៀប ដើម្បីឲ្យឃើញច្បាស់ នូវភាសាទាំងនោះ តែពេលនេះសូមយកតែការរាប់ចំនួនមកជូន ដូចតទៅនេះ

| ជ្រាយ | រដែ | ចាម | |
|---|---|---|---|
| Sa | Sa | Sa | 1 |
| Duà | Dòa | Dua | 2 |
| Klao | Tlao | Klau | 3 |
| [illegible] | Pa | Pak | 4 |
| Roma | Ema | Limo | 5 |
| Nam | Nam | Nam | 6 |
| Tojuh | Kjuh | Tijuh | 7 |
| Sopan | Fpan | Dalapan | 8 |
| Duaropan | Doapen | Salapan | 9 |
| Pluh | Pluh | Pluh | 10 |

ទោះបីមានការអានមិនត្រឹមត្រូវតាមភាសាដើមដែលភាសានីមួយ ៗ

សូមមេត្តាជួយអានតាមដែលលោកអ្នកប្រើប្រាស់ទៅចុះ ។

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ឆ្នូ-ការ ៨

ប្រែ-រៀបរៀង

(៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្ដានស្នេហាជាតិ

យូរ-អ៊ុន

ម៉ាតាយឃើញ បេងហេក-បេងហ៊ីវ ក៏យកដាវចង្អុលមុខហើយថា បើយើងចាប់ខ្លួនបានម្ដងទៀត មុខជាមិនលែងទេ ៗ បេងហេក-បេងហ៊ីវ មិនឆ្លើយតបថាម្ដេចសោះ ចេះតែឱនដាក់មុខហើយដើរទៅ, លុះដើរទៅដល់បន្ទាយវៀង ទើបចូលទៅ ទទួលក្រឡេកឃើញជូឡុង ទ័ពទាហាន នៅពេញក្នុងបន្ទាយនោះ ៗ ជូឡុង ក៏ស្រែកឲ្យបេងហេក-បេងហ៊ីវថា ចៅហ្វាយយើងមានគុណលើអ្នកឯងច្រើនណាស់ ហេតុម្ដេច អ្នកឯងមិនដឹងគុណសោះ?, បេងហេក-បេងហ៊ីវមិនឆ្លើយតបសោះ ក៏ឱនដាក់មុខដើរប្រញាប់ទៅ, លុះទៅដល់ប្រហបច្រកភ្នំ ឃើញអ៊ុយអៀនមានទាហាននៅស្កាត់ពីមុខ ក៏ទឹកភ័យណាស់, អ៊ុយអៀនស្រែកថា ឥឡូវយើងបានឆ្លងមកត្រើយខាងនេះ ចូលក្នុងដែនរបស់ខ្លួនហើយ ខ្លួននៅកើរផ្លូវទៅ

ដល់ណាទៀតទើបចង់ច្បាំងនឹងយើង បើយើងចាប់បានខ្លួនម្តងទៀតនឹងកាប់ចញ្ច្រាំជា ១០ កំណាត់ ៗ ប៉េងហោក-ប៉េងហ៊ីវមិនឆ្លើយតបសោះ ឱនដាក់មុខដើរទៅ ៗ

ខណៈកាលខុងបេង បើកលែងប៉េងហោក-ប៉េងហ៊ីវទៅផុតហើយ ក៏លើកទាហានចូលទៅរៀបចំកងទ័ពក្នុងបន្ទាយប៉េងហោក ហើយបង្គាប់ឲ្យរៀបតុលៀងអាហារអស់បណ្តានាយទ័ព នាយកង និងពួកទាហាន, លុះបរិភោគរួចអស់ហើយ ទើបខុងបេងនិយាយថា យើងគិតនឹងទំនុកបម្រុងផែនដីព្រះចៅឡៅសៀន ឲ្យបានសុខចម្រើនតទៅ បានជាត្រូវខិតខំតាំងម៉ោះ, អស់អ្នកទាំងនេះ ដែលបានវាយច្បាំងនឿយហត់ បើមិនគិតឲ្យដឹងក៏នឹងខឹងតូចចិត្តថា ចាប់បានប៉េងហោក-ប៉េងហ៊ីវហើយ ហេតុម្តេចបានជាបើកលែងទៅវិញជាច្រើនដងច្រើនសានោះ ព្រោះយើងឃើញថា ប៉េង-ហោក នេះជាចៅហ្វាយស្រុក ៗ ក្រៅ ចិត្តកម្ចៅរឹងរូសខុសនឹងមនុស្សស្រុកយើង, ដែលចាប់បានខ្លួនមកហើយ វាក៏នៅចម្លើយមិនព្រមទទួលសារភាពចំណុះចុះចាញ់តែម្តង ដែលយើងចាប់បានម្តងពីរដង ហើយបើកលែងវាទៅវិញនោះ ព្រោះចង់ឲ្យវាចាល់តម្រិះប្រាជ្ញា មានចិត្តអរគោតខ្លាចឯង ៗ ទាំងខាងក្នុងទាំងខាងក្រៅ មិនត្រូវឲ្យវានៅប្រកួតអួតថ្វីដៃបាន, បើនឹងប្រមាណយកតែជ័យជម្នះក្តៅ ៗ ហើយត្រឡប់ចូលទៅក្រុងវិញ ដើម្បីនឹងលើកចេញទៅវាយស្រុកខាងព្រះចៅចូកីទៀត ទោះម្តេចម្តា ប៉េងហោកវា

គង់ធ្វៀតលើកទៅប្រទូសរ៉ាយស្រុកយើងពុំខាន, អស់អ្នកទាំងប៉ុន្មាន ត្រូវតែខំយកចិត្តទុកដាក់ធ្វើបេងហោក ឲ្យបាក់បបខ្ទបខ្ទាចពុំអាចនឹងប្រទូស្តដល់យើងតទៅ ទើបយើងនឹងអស់ទុក្ខក្តៅតែព្រោះវា ។ ពួកទាហានពលគ្នាបានស្តាប់ ក៏ចាប់ចិត្តគិតឃើញត្រូវណាស់ លើកដៃសំពះថា គំនិតលោកគិតនោះប្រពៃពេក, យើងខ្ញុំសុំទទួលអាសា ត្រាតែវែកទម្លាយរូបកាយមិនស្តាយជីវិតឡើយ ។

ឯបេងហោក-បេងហ៊ីវនោះ លុះទៅដល់ស្រុកងិនខែ ហើយក៏គ្នាន់ក្នាញ់ក្នុងចិត្តណាស់ ទើបរួតរះឲ្យកេណ្ឌទាហាន ៩៣ ខែត្រ ដែលនៅក្រោមបង្គាប់ ឲ្យលើកប្រញាប់ចូលមកព្រមគ្នា រួមគណនាបាន ៥០ ម៉ឺននាក់, ឯនាយទ័ពនាយកងជាមេទាំងប៉ុន្មាននាក់ ក៏ចូលទៅគំនាប់បេងហោកទាំងអស់គ្នាតាមទំនៀម, បេងហោក-បេងហ៊ីវ ក៏ឲ្យត្រួតត្រៀមទាហានបានពេលាហើយ ក៏លើកទៅតាំងនៅក្បែរស្ទឹងសៀងយី ។

ខណៈនោះ ទាហានល្បាតបានភតត្បាតស៊ើបយកសេចក្តីបានច្បាស់ ក៏ចូលទៅក្រាបសំពះប្តឹងខុងបេងថា បេងហោកឲ្យកេណ្ឌទាហានទាំង ៩៣ ខែត្របានពល ៥០ ម៉ឺន ហើយលើកមកតាំងនៅស្ទឹងសៀងយើ ។ ខុងបេងបានឮដូច្នោះ ក៏អស់សំណើចហើយថា អស់អ្នកពលគ្នាកុំព្រួយវិតក្កឡើយនឹងទ័ពនោះ ហើយយើងចង់ឲ្យលើកមកទៀតឲ្យច្រើនជាងនេះ ទើបនឹងឃើញតម្រិះយើង, ហើយក៏បង្គាប់នាយទ័ព នាយកងទាំងពួងឲ្យរៀបលើក

ទ័ពរំកិលចូលទៅ ៗ ខុនបេង ក៏ឡើងជិះរទេះតូចនាំទាហានសេះ ៥០០ ឲ្យជាអ្នកនាំផ្លូវទៅមុខ, លុះទៅដល់មាត់ស្ទឹងសៀងយី ទទួលដូឡុង, ម៉ា-តាយ, អ៊ុយអៀន, ទៀវអេក លើកទ័ពមកប្រទះគ្នា, ខុនបេងក៏បង្គាប់ពលយោធាឲ្យទៅកាប់ឈើមកធ្វើផែ ក៏មិនបាន, ទើបសួរលីយីដែលនាំផ្លូវថា យើងនឹងឆ្លងស្ទឹងទៅឥឡូវនេះ ក៏ទញ់ទាល់ណាស់ ព្រោះគ្មានអ្វីជាពាហ-ណៈនាំទៅបាន, តើអ្នកនឹងគិតអានុះឃើញប្រកផ្លូវយ៉ាងណា? ៗ

លីយីឆ្លើយតបថា លើក្ខាងដើងមានព្រៃឈើច្រើនណាស់ ឃើញល្មមនឹងកាប់យកមកធ្វើស្ពានឆ្លងទៅបាន ៗ ខុនបេង ឮដូច្នេះ ទើបចាត់ទាហាន ៣០.០០០ ឲ្យទៅកាប់ឈើនិងឫស្សីមកចងជាក្បូនផែ ទទឹង ១ ស៊ិន (គឺ ៤ ម៉ែត្រ) ធ្វើស្ពាន លើកទាហានឆ្លងទៅ ដល់ត្រើយម្ខាង ទើបឲ្យរៀបធ្វើបន្ទាយធំ ៣ ធ្វើទ្វារចេញចូលត្រង់ស្ពាន ៗ

ឯបេងហោកតាំងបន្ទាយក្រោមទឹក ឃើញខុនបេងលើកទ័ពឆ្លងមកបាន ក៏នាំទាហានចំនួន ១០ ម៉ឺនលើកឆកវាយបន្ទាយខុនបេង ៗ ឃើញបេងហោកពាក់អាវស្បែកមាស ពាក់មួកក្រហម ជិះក្របីឃ្មៀច ដៃឆ្វេងកាន់ខែល ដៃស្តាំកាន់ដាវ លើកទាហានទន្ទ្រានចូលមកដូច្នោះ ក៏បញ្ជាឲ្យលើកពលចូលតនឹងបេងហោក ៗ កាំខែលដេញពលខ្លួនឲ្យប្រជួនចូលតដៃជាជ្រួលច្របល់, ខុនបេងមើលយល់មិនជារបៀបក្បួនទ័ព ក៏ថយត្រឡប់ចូលបន្ទាយ ឲ្យបិទទ្វារមាំមួន, បេងហោកឲ្យទាហានខ្លួនទៅស្រែកជេរ ប្រគោះជេរ

ខុងបេង ត្រង់មុខបន្ទាយជាអ៊ូអរ, ទាហានខុងបេងក៏មានសេចក្តីខឹងឡើង ជ្រួលច្របល់ពន់ប្រមាណ បាននាំសេចក្តីនោះទៅជម្រាបខុងបេងថា យើងខ្ញុំសុំយកអាសាចេញទៅច្បាំងនឹងបេងហេក សងសឹកឲ្យបាន, ខុងបេងទើបមានវាចាប្រស្រ័យតបថា បេងហេកជាខ្មាំងសត្រូវផ្សេងស្រុកទេសពីយើង ចំនើងចិត្ត នឹងធ្វើការតែះផ្តេសផ្តាសមិនតាមក្បួនទ័ព ដូចទម្លាប់ពិជ័យសង្គ្រាម, យើងត្រូវនៅឲ្យស្ងៀម ចាំមើលកលការសិនចុះ បើឃើញមានចន្លោះស្រួលពេលណា សឹមប្រើប្រាជ្ញាឧបាយយកជ័យជម្នះវាតែម្តង, អ្នកទាំងពួងកុំពេលមើលងាយសត្រូវ, ត្រូវតែនាំគ្នាជួយការពារបន្ទាយឲ្យមាំមួនចុះ ។ ទាហានទាំងនោះទទួលបង្គាប់ហើយ ក៏ថយចេញទៅ ។

ឯបេងហេកមិនបានឃើញខុងបេងបញ្ចេញទាហានមកតសោះ ក៏លើកទាហានចូលបន្ទាយ, នៅ ៣ ថ្ងៃទើបខុងបេងឲ្យហៅជូឡុង-អ៊ុយអៀនមកឲ្យបង្គាប់ថា អ្នកទាំង ២ ចូរនាំទាហានឆ្លងទៅត្រើយម្ខាង ហើយត្រូវទៅតាំងបន្ទាយ នៅពីមុខបន្ទាយបេងហេក, បើឃើញយើងបណ្តែតគោមទៅកាលណា ត្រូវឲ្យជូឡុង យកទង់ជ័យដោតក្នុងបន្ទាយឲ្យច្រើនកាលណោះជាបែបបញ្ឆោត, ជូឡុង នឹងអ៊ុយអៀនទទួលបង្គាប់ហើយក៏លើកពលចេញទៅតាំងបន្ទាយ នៅមុខបន្ទាយបេងហេក, ឯអ៊ុយអៀន ឲ្យនាំពលទៅពួនបង្កប់នៅក្នុងព្រៃញាតស្បាត ប្របជើងភ្នំខាងទិសឯកើត ហើយ

ឲ្យជីករំលុងទុកឲ្យច្រើន យកស្លឹកឈើគ្របពីលើមាត់រំលុងកុំឲ្យស្គាល់បាន, ដើម្បីនឹងបានធ្វើការតាមកំណត់ ។

កាលដូច្នោះ និងអ៊ុយអៀន លាខុងបេងទៅហើយ លុះពេលយប់ ខុងបេង ក៏បង្គាប់ម៉ាតាយឲ្យលេងភ្លើងបណ្ដុតទៅ ហើយឲ្យចេញទៅពួនបង្កប់នៅក្រៅបន្ទាយខាងទិសឯលិច, ម៉ាតាយ ក៏ទៅធ្វើតាមបង្គាប់គ្រប់ប្រការ ។ ខុងបេង ក៏ឲ្យដុតភ្លើងក្នុងបន្ទាយក៏ស្អាងគ្រប់បន្ទាយទាំង ៣ ហើយឲ្យទៀវអេក ចេញទៅពួនបង្កប់ក្រៅបន្ទាយខាងទិសឯជើង, ឯខ្លួន ខុងបេង ក៏លើកចេញទៅតាំងទ័ពនៅក្រៅបន្ទាយ ។

ឯបេងហេកនោះ លុះបយទាហានត្រឡប់មកបន្ទាយជាច្រើនថ្ងៃ ឃើញខុងបេងតាំងទ័ពខ្ជាប់មាំណាស់ ទើបលើកទាហានទាំងចុងទាំងចាស់ មកប្រជុំគ្នាជាច្រើន ដើម្បីនឹងប្លន់បន្ទាយខុងបេង, លុះទាហានកងមុខមកដល់ ឃើញភ្លើងក្នុងបន្ទាយខុងបេងក៏ស្ងាត់ច្បាស់ ក៏មិនអាចនឹងចូលប្លន់យកជ័យជម្នះបាន នាំទាហានរារង់ទាល់តែព្រឹកព្រាហាម, លុះបេងហេកលើកមកថែមចូលនឹងទាហានកងមុខ នាយទាហានទាំងនោះក៏ទៅថ្លែងការណ៍ពិតមានឲ្យបេងហេកស្ដាប់គ្រប់ប្រការ, បេងហេកបានឮពាក្យ ទើបគិតថា ខុងបេងលើកទាហានត្រឡប់ទៅវិញហើយជាប្រាកដ បានជាភ្លើងដុតភ្លើងឲ្យយើងសង្ស័យ, ហើយបេងហេកក៏លើកទាហានចូលទៅដល់ឃើញក្នុងបន្ទាយនោះស្ងាត់ឈឹងសូន្យ គ្មានមនុស្សម្នាគ្រប់បន្ទាយទាំង ៣, បេងហេក

ក៏ស្រដីថា ប្រហែលខុងបេងលើករត់ទៅហើយ មុខជាះចោលស្បៀង-អាហារជាច្រើនណាស់ ។

បេងហ៊ុំជាប្អូនថា ដែលខុងបេងលះបង់ចោលបន្ទាយហើយរត់ទៅនោះ មិនមែនទេ, ប្រហែលគេគិតជាកលឧបាយបញ្ឆោតយើងទេដឹង ? បេងហេកថា ចៅនិយាយនេះ មិនមែនសោះ ដែលថាខុងបេងធ្វើកលទុកនោះ, ប្រហែលស្រុកកាំងតាំងទិងស្រុកហ៊្វីគោ លើកទ័ពមកវាយស្រុកសែឈួនជាប្រាកដ គឺខុងបេងមានកំហឹងទឹងលើកទ័ពវិលទៅជាការរូតរះ បានជាគ្រឡាស់ធ្វើកលឧបាយទុក ប្រាថ្នាទឹងឲ្យយើងមានសង្ស័យមិនឲ្យកៃខៃលើកទ័ពតាមទាន់; ហេតុនេះ, គួរយើងទឹងរួសរាន់លើកតាមទៅជាប្រញាប់ចុះ ។

លុះថាហើយ បេងហេក ក៏បែងចាហានឲ្យចូលទៅដញ្ញនស្បៀងក្នុងបន្ទាយខុងបេងខ្ទះ ក្រោយពីនោះ ឲ្យលើកស្រុះកាត់ទៅតាមក្បែរខាត់ស៊ីង ប្រុងទឹងទៅតាមចាប់ខ្លួនខុងបេងឲ្យបាន, លុះបេងហេកប្រមាណទឹងឆ្លងទៅត្រើយម្ខាង ក៏ឃើញបន្ទាយដែលដូឡុងតាំងទុកក្បែរខាត់ព្រៃឆ្នេរស៊ីងដោតទង់ទៀននៅជាច្រើន សម្គាល់ថា បន្ទាយខុងបេងឈប់ស្នាក់នៅទីនោះ ទើបចាត់ចាហានឲ្យទៅកាប់ឈើចងផែឆ្លងតាមទៅ, វេលានោះ ទទួលកើតខ្យល់ព្យុះខ្លាំងណាស់ ខុងបេងក៏ឲ្យដុតភ្លើងជាសញ្ញាគ្រប់តាំងៗ បន្ទាយ ហើយឲ្យចាហានស្រែកហ៊ោវាយបោះគោះគងទូងគ្រឹះ លើក

ទាហានពីគ្រប់ទិសទី ព័ទ្ធចូលមកហាក់បីដូចរលកនៃមហាសមុទ្រធំ ៗ បេងហោកនៅជាកណ្ដាលប្រជុំកងទ័ព ក៏ភ័យញ័រញាប់សព្វសារពាង្គ ទើបស្ទុះឡើងជិះលើក្របី នាំពលឃាតទ្វីស្ទុះបំពារកងទ័ពដែលព័ទ្ធ រត់កាត់តម្រង់ត្រង់ទៅបន្ទាយ ។

ខណៈនោះ ជូឡុង ធ្វង់ពីត្រើយនាយមកតាំងទ័ពនៅបន្ទាយបេង-ហោក តាំងពីកណ្ដាលយប់ស្ងាត់ លុះឃើញបេងហោកនាំទាហានរត់ស្កាត់តម្រង់មក ក៏លើកទាហានចេញទៅទទួលនៅមុខបន្ទាយ ។ បេងហោកក្រឡេកឃើញច្បាស់ពីចម្ងាយក៏ភ័យណាស់ ក្រឡាស់រត់គេចតាមផ្លូវទៅខាងទិសឯលិច ដែលម៉ាតាយតួនបង្កប់នៅនោះ, លុះបេងហោកទៅដល់ម៉ាតាយក៏នាំទាហានចេញស្កាត់ពីមុខ ចូលគ្រលុកតយុទ្ធគ្នាបាន ៩ ក្លេង, បេងហោកពុំឈ្នះក៏ប្រេះរត់ទៅឯជើងត្រង់បន្ទាយទៀវអេក ដែលស្កាត់ចាំ, ទៀវអេកក៏លើកពលពីធ្វេង-ស្ដាំចេញមកហោមព័ទ្ធស្កាត់ចាប់បានខ្លួនបេង-ហ៊ុវ, ឯបេងហោកក៏គេចរត់ស្ទើរទៅទិសឯកើតដល់ទីព្រៃញឹកទឹកថា ទឹងគេចទៅតាមច្រកភ្នំ, លុះទៅដល់ទីជម្រំដែលអ៊ុយអៀនជីករំលុងទុកនោះ ក៏ប្រទះនឹងខុងបេងកំពុងបររទេះតូច ១ នាំទាហានមកស្កាត់ពីមុខ, ខុង-បេងក៏មានទំនុកសើចចំអកឲ្យបេងហោកថា ថ្ងៃនេះចៅបេងហោងនឹងធ្លាក់ខ្លួនមកពានលើគ្រោះកាក្រក់ ទឹងគេចហក់រត់ទៅឯណាឲ្យរួចខ្លួនសោត! យើងមកចាំបញ្ញាតនឹងចាប់ខ្លួនជាយូរហើយ ។

បេងហោកបានស្តាប់ដូច្នោះ ក៏ប្រះទៅនិយាយនឹងពួកទាហានថា : អាដែងនេះ វាបេះធ្វើកលឧបាយឲ្យយើងចាញ់បញ្ឆោតវាដល់ ៣ គ្រាមកហើយ, ឲ្យអ្នកពលគ្នាខំមានះចូលប៉ះកាប់វាឲ្យល្អិត កុំគិតញញើតដៃឲ្យសោះ, ហើយបេងហោក ក៏ដេញពលទាំងអស់ឲ្យទ្រនាន ចូលទៅដោយកម្លាំងតោសោ មិនបានពិចារណា, ទាំងអស់គ្នាក៏ពារទៅលើរលុងធ្លាក់ផុងទៅគ្មានសល់, ខុងបេងវិលមកបន្ទាយវិញ, ឯអ៊ុយអៀនដែលពួនបង្កប់នៅទីនោះ លុះឃើញបេងហោកធ្លាក់រលុងក៏លើកទាហានប្រមាណ ១០០ នាក់, នៅស្ទាក់ចាប់បេងហោកនិងទាហានបង ហើយនាំខ្លួនទៅជូនខុង-បេង ។ កាលខុងបេងត្រឡប់មកបន្ទាយ ក៏បញ្ចុះបញ្ចូលពួកទាហានបេងហោកបានច្រើនណាស់ ។

ខុងបេងឲ្យត្រួតពិនិត្យមើលទាហានទាំងពួងស្រេចហើយ ទើបសួរបញ្ជាក់ថា: ខ្លួនឯងពលគ្នានឹងស្ម័គ្រចិត្តគិតនៅធ្វើការជាមួយនឹងយើងក៏ដោយមិនស្ម័គ្រនឹងនៅក៏ដោយតាមចិត្តចុះ, ពួកទាហានទាំងនោះបានស្តាប់ក៏ពេញអំណរនាំគ្នាក្រាបសំពះអរគុណហើយ ក៏លាទៅទាំងអស់, ខណៈនោះ ទទួលទៀវអេក ចងខ្លួនបេងហ៊ុវចូលទៅជូនខុងបេង ។ ក៏ប្រស្រ័យសួរថា: បងអ្នកឯងធ្វើខុសមោះពុំគាប់, យើងចាប់ខ្លួនបានពាដងទៅហើយ អ្នកឯងជាប្អូន គួរចេញខ្លួនទន្នានបងឲ្យយល់សេចក្តី ហេតុអ្វីនៅតែសមគំនិតគ្នាប្រកួតប្រជែងស្រែករកទីងយ៉ាងដូចណាទៅទៀត, ឥឡូវយើងចាប់

បាន ៤ ដងនឹងគ្រានេះផង, តើខ្លួននឹងនៅទៀតគិតយ៉ាងណា បើតាមជាតិ
ជាតាហានក្លៀវក្លា មិនគួរនឹងប្រាថ្នាឲ្យឃើញមុខគេសោះឡើយ ។

បេងហ៊ីវបានស្តាប់ហើយក៏ក្រាបសំពះហើយជម្រាបថា: ទោសខ្ញុំបាទ
គ្រានេះ ដល់ស្លាប់ពិតណាស់, តែសូមលោកម្ចាស់ប្រោសមេត្តាទុកជីវិត
ម្តងទៀតចុះ, ខុងបេងថា: ជីវិតអ្នកឯងនោះនៅក្នុងកណ្តាប់ដៃយើងហើយ,
យើងមិនមែនសម្លាប់អ្នកឯងបានតែត្រឹមថ្ងៃនេះទេ, ទោះបីទៅថ្ងៃមុខទៀត
យើងក៏គង់នឹងសម្លាប់បាន, វេលានេះ បើអ្នកឯងសុំអាយុជីវិតយើង ។
ក៏អាណិតលើកលែងទៀតចុះ, តែបើខ្លួនត្រឡប់ពីនេះទៅ ត្រូវទៅគិតគូ
នឹងបងប្រុសឲ្យស្រួលបួល កុំឲ្យធុកធួលគំនិត គិតធ្វើសឹកនឹងយើងទៀត
ឡើយ, លុះនិយាយហើយ ខុងបេង ក៏ឲ្យស្រាយចំណងបេងហ៊ីវហើយ
លែងទៅ ។ កាលបេងហ៊ីវក្រោកចេញទៅដល់ខាងក្រៅ, ទទួលអ៊ុយ-
អៀននាំខ្លួនបេងហោកទាំងចំណងចូលមក; ខុងបេងឃើញបេងហោក ក៏
ខឹងណាស់, និយាយហោះថា យើងចាប់បានខ្លួនហើយលែងទៅវិញ ៣
ដងហើយ, ខ្លួនមិនស្គាល់គុណយើង, ខំចេះបើងមកធ្វើសង្គ្រាមត, ឥឡូវ
យើងចាប់បានខ្លួនជា ៤ តំណាមកទៀត, តើខ្លួននឹងគិតប្រការម្តេច ?
បេងហោកឆ្លើយថា: យើងធ្វើសឹកនេះ ព្រោះលោកធ្វើកលកិច្ចជាឧបាយ
ដោយប្រការផ្សេង ៗ ទើបយើងចាញ់, លោកចាប់ខ្លួនយើងបានមកវិញ,
មិនមែននឹងចាញ់ដោយពលាការ, បើនឹងស្លាប់ជីវិតសង្ខារ ក៏គួរឲ្យនៅ

ស្តាយណាស់ ព្រោះធ្វើការនឹងលោកមិនទាន់ស្រឡះឲ្យពេញថ្វីដៃ ។

ខុនបេងបានព្រួសម្តីបេងហេកថាដូច្នោះ ទើបក្លែងប្រើមនុស្សឲ្យនាំខ្លួនបេងហេកទៅសម្លាប់ចេញ, ឯបេងហេកនោះវិញ ក៏មិនមានតក់ស្លុតរន្ធត់ភ័យខ្លាចសោះ, នៅមានទឹកមុខថ្លាស្រស់ដូចធម្មតា, ខុនបេងយល់ឃើញអស្ចារ្យក៏គិតថា បេងហេកនេះជាមនុស្សមានចិត្តហៅហាន, បើយើងនឹងសម្លាប់ឲ្យបានក៏មិនជាទីស្រេចការ អាណាប្រជានុរាស្ត្រចំណុះស្រុកក៏នឹងបែកបាក់ខ្ចាត់ខ្ចាយទៅអស់, បើដូច្នេះ យើងគួរនឹងដោះលែងបេងហេកទៅឲ្យវាធ្វើជាសឹកសត្រូវតនឹងយើងឲ្យអស់ថ្វីដៃវាចុះ, ទុកឲ្យព្រមចំណុះចុះចាញ់ពីខ្លួនវា ១ យកស្រុកដែលឡើងតាំងប៉ុន្មាន មកឲ្យយើងឲ្យបាន ។ ទើបខុនបេង ប្រើភាហានឲ្យស្រាយចំណងបេងហេកចេញ, ហើយធ្វើជាអស់អញលំគេញចិត្តយកស្រាមកឲ្យផឹកហើយថា តាំងពីយើងចាប់អ្នកឯងបានគម្រប់ ៤ ដងក្នុងគ្រានេះហើយ, យើងក៏មិនបានធ្វើអន្តរាយ; មេត្រីចិត្តនៃយើង ក៏រសាយរាប់អានអ្នកជាច្រើនណាស់; ហេតុអ្វីអ្នកមិនប្រែផ្លាស់គំនិតគិតមកចុះចូលយើង តាមស្រួលទៅ ។

(នៅមានត)

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ១៩

- ស្រីនោះជាអ្នកណា (ជោជេន្ទ្រាសួររ៉ាមេស្ហ)

- បងប្អូនខ្ញុំ (រ៉ាមេស្ហឆ្លើយ)

- បងប្អូនយ៉ាងម៉េចហ្នឹង ខ្ញុំស្គាល់គ្រួសារឯងទាំងអស់ ហើយខ្ញុំដូចជាមិនដែលបានឃើញនាងនេះម្ដងណាសោះ ។

- គិច ! ជោជេន្ទ្រា (អាក់ស្ហាយឃាត់ មានរឿងខ្លះប្រុសៗ គេមិនចូលចិត្តឲ្យគេឯងដឹងទេណា+ ។

- តើជារឿងអាថ៌កំបាំងរបស់ឯងឬរ៉ាមេស្ហ ? (ជោជេន្ទ្រាសួរ)

- ទីងហើយ ជាអាថ៌កំបាំងរបស់ខ្ញុំ (អ្នកឆ្លើយទាំងអៀនអន់)

- មិនគួរសោះរ៉ាមេស្ហ ប៉ុន្តែធ្វើម្ដេច បើខ្ញុំដឹងចំរឿងដែលឯងលាក់នោះតែម្ដង ហើយប្រសិនជាឯងមិនបានស្ដីដណ្ដឹងប្អូនស្រីខ្ញុំ ។ ក៏មិនលូកដៃចូលក្នុងរឿងឯងដែរ ចូរឯងជឿចិត្តខ្ញុំចុះ ហើយខ្ញុំមិនត្រូវការចង់ស្គាល់ញាតិសាលោហិតឯងធ្វើអ្វីដែរ ។

- ការដែលខ្ញុំអាចប្រាប់ឯងបាន ក្នុងការអ្វីទាំងអស់ដែលឯងសង្ស័យមាន តែថា ខ្ញុំនឹងរៀបការជាមួយនឹងនាងហិមណាលិទី ទាំងមានសតិសម្បជញ្ញៈ ស្អាតបរិសុទ្ធ ហើយខ្ញុំមិនដែលមានធ្វើអំពើអ្វីក្បត់នឹងចិត្តនាងឡើយ ។

– ប្រហែលជាពិតមែន ប៉ុន្តែឪពុកម្តាយរបស់នាងហិមណាលិទីអាចមិនស្របតាមយោបល់ឯង ខ្ញុំចង់សួរឯងតែប៉ុណ្ណោះថា តើឯងជាសាច់ញាតិនឹងនាងនេះមែនឬមិនមែន? ហើយហេតុដូចម្តេច បានជាឯងយកនាងនេះមកលាក់នៅទីនេះ ? ។

– បើនិយាយប្រាប់ឯងដូច ជាហែកកេរ្តិ៍គេ ដែលខ្ញុំត្រូវលាក់ ចុះខ្ញុំនិយាយប៉ុណ្ណឹងហើយមិនទាន់អស់ចិត្តទេឬ ?

– ក្រែងនាងហ្នឹងហើយ ឬដែលឈ្មោះកាមាលា ?

– ហ្នឹងហើយ!

– ឯងមានទុកនាងជាប្រពន្ធឯងទេ ?

– មានមែន ។

– ហ៊ា ចុះម៉េចក៏ឯងថាឲ្យខ្ញុំអស់ចិត្តនឹងពាក្យឯង ប៉ុណ្ណឹង ?

– ណ្ហើយ ! ជោដេត្រា មានការពិសេសដែល . . . .

(អាក់ស្ហាយនិយាយបែបចំអក )

– ខ្ញុំគ្មានត្រូវការប្រាប់អ្វីក្រៅពីថា ខ្ញុំមិនបានក្បត់ចិត្តនាងហិមណា-

លិទីប៉ុណ្ណោះទេ  ពោះជាអ្នកទាំងអស់គ្នាមើលឃើញខាងក្រៅយ៉ាងនេះហើយក្តី ហើយពោះជាអ្នកទាំងអស់គ្នាយល់ថាស្រីអំបាញមិញនេះ ជាអ្នកដោយខ្ញុំក៏មិនត្រូវការជជែកជាមួយនឹងអ្នកដែរ ពុំនោះទេខ្ញុំជាមនុស្សពោលមៀត ប្រសិនជាថា និយាយទៅហើយ ត្រូវអសោចកេរ្តិ៍តែត្រឹមរូបខ្ញុំមួយប៉ុណ្ណោះ ខ្ញុំមិនកោតលំតែសោះ ប៉ុន្តែបើសិនជាខ្ញុំធ្វើឲ្យខូចអនាគតនាងផងនោះ ខ្ញុំមិនព្រមនិយាយជាដាច់ខាត ។ (ក៏មេស្ត្រីនិយាយ)

– ការដែលឯងលាក់ទីនឹងយើង តើឯងបាននិយាយប្រាប់ប្អូនយើងហើយឬនៅ ?

– នៅទេ ចាំដល់រៀបការហើយ ទើបខ្ញុំប្រាប់ បើនាងចង់ដឹងខ្ញុំប្រាប់ឥឡូវហ្នឹងក៏បាន ។

– ឯងឲ្យខ្ញុំសួរនាងអំបាញមិញពាប៉ះពាត់បានទេ ? (ដោះដៃនោស្ត្រី)

– ទេ! ត្រង់ហ្នឹងប្រាកដជាមិនបានហើយ បើឯងយល់ថាខ្ញុំអាក្រក់ឯងត្រូវគេរៀងតែត្រឹមរូបខ្ញុំមួយប៉ុណ្ណោះ កាមារណាគ្មានបានដឹងការណ៍អ្នករឿងនេះផងទេ ខ្ញុំមិនត្រូវការយកនាងមកឲ្យឯងសួរដូចមនុស្សពាសទេ ។

– ណ្ហើយ ខ្ញុំមិនត្រូវការអ្នកណាទៀតទេ ការដែលខ្ញុំចង់ដឹងតាំងប៉ុន្មាន ខ្ញុំដឹងអស់ហើយ តែបើឯងហ៊ានជាក់ជើងដល់ផ្ទះខ្ញុំទៀត ខ្ញុំប្រាប់ឯងមុនស្រេចហើយ ថាឯងមុខជាគាប់សម្រេចមិនខាន ម្យ៉ាងទៀត ខ្ញុំហាមដាច់ឯងត្រូវឈប់ទាក់ទងជាមួយនឹងប្អូនស្រីខ្ញុំទៀត ខាងកូនខ្ញុំ តាំងពីសំបុត្រ-

ស្នាម ហើយបើកាលណា មានគេសួរខ្ញុំថា ហេតុម្តេចបានជាហាមណាលិទីមិនរៀបការ ខ្ញុំឆ្លើយថាខ្ញុំមិនព្រមឲ្យ ប៉ុន្តែបើឯងមិនធ្វើឲ្យត្រឹមត្រូវតាមពាក្យខ្ញុំទេ ខ្ញុំនឹងបើកកកាយកញ្ចប់ឈាមកឯងឲ្យគេដឹងឲ្យអស់ ៗ ឯងត្រូវយល់ឲ្យច្បាស់ថា ការដែលខ្ញុំសំចៃឯងប៉ុណ្ណឹង មិនមែនដោយសារខ្ញុំស្រឡាញ់ឯងទេ គឺដោយសារតែកេរ្តិ៍ឈ្មោះប្អូនខ្ញុំប៉ុណ្ណោះ ហើយចូរចាំឲ្យច្បាស់ ឯងកុំបញ្ចេញពាក្យសំដី ថាឯងស្គាល់ប្អូនខ្ញុំឲ្យសោះ ៗ ខ្ញុំស្គាល់តម្លៃនៃពាក្យសន្យាឯងហើយ ខ្ញុំមិនបាច់សុំឲ្យឯងសន្យាទៀតទេ ប្រសិនជាឯងគោរពពាក្យសន្យាបាន មិនគឺអ្វីក្រៅអំពីការ ការពារកេរ្តិ៍ឈ្មោះឯងទេ ៗ

— នែ! ជោដេន្រ្ទា! មិនអាណិតក៉ាមេស្ហផងទេឬ? មិនឃើញគ្នាមុខស្មឿក ទៅហើយទេឬ? មកទៅប៉ុណ្ណឹងបានហើយ ៗ (គាត់ស្ហាយនិយាយ)

អ្នកទាំងពីរនាក់ដើរចេញទៅ ទុកក៉ាមេស្ហនៅក្រទប រកតែធ្វើការអ្វីបន្តិចក៏មិនកើត ៗ មួយសន្ទុះក្រោយមក លុះស្ងាំងខឹងបន្តិចអ្នកគិតចុះដើរទៅដើម្បីឲ្យទូលាយខួរក្បាលនឹងស្រាយបញ្ហាដ៏ស្មុគស្មាញនេះ ប៉ុន្តែនាងកាមាលានៅតែម្នាក់ឯង ៗ អ្នកដើរចូលទៅក្នុងបន្ទប់ជិតនោះ ឃើញនាងកាមាលាអង្គុយនៅមាត់បង្អួច មើលមនុស្សដើរចុះឡើងនៅតាមផ្លូវ នាងសួរថា :

— អ្នកណាហ្នឹងបង? ពីព្រឹកមិញខ្ញុំឃើញពីរនាក់ហ្នឹងទៅឯសាលាខ្ញុំដែរ គេមករកអ្វី?

ឮដូច្នោះ ក៉ាមេស្ហចង់ភ្ញាក់មាត់ស្រែក ប៉ុន្តែគេទប់វិញធ្វើព្រងើយ

– គេចង់ដឹងថា នាងជាបងប្អូននឹងខ្ញុំមែនឬយ៉ាងម៉េច ៗ នាងឮដូច្នោះនាងអៀនឡើងមុខក្រហម ៗ

– ខ្ញុំបានប្រាប់គេវិញថា ឥតមានជាប់សាច់ញាតិអ្វីទេ ៗ

នាងទឹកស្មានថា ក៉ាមេស្ហនិយាយចំអន់នាងលេង នាងក៏ឆ្លើយតប:

– ម៉េចក៏បងនិយាយផ្ដេសផ្ដាសអីចឹង ?

នៅពេលនោះ ក៉ាមេស្ហចង់និយាយរឿងក៏ប្រាប់នាងឲ្យអស់ ប៉ុន្តែនាងស្រែកកាត់ :

- ហ្ន៎! ក្អែកឆក់ផ្លែឈើយើងអស់ហើយបង!

នាងរត់ទៅយកពាន ហើយត្រឡប់មករកក៉ាមេស្ហវិញ:

- បងមិនពិសាទៀតទេ ?

នាងដាក់ពាននៅចំពោះមុខក៉ាមេស្ហ ៗ ពុទ្ធោអើយ! ក៉ាមេស្ហបាត់ឃ្លានអស់ទៅហើយ ប៉ុន្តែដោយឃើញនាងខំទៅយកពានមកដាក់ឲ្យ អ្នកក៏យកផ្លែប៉ោម ១ ចំណិតហុចទៅឲ្យនាង ៗ

– បងពិសាមុនទៅ ចាំខ្ញុំញុំាក្រោយ ៗ

ឃើញសេចក្ដីស្មាម័គ្គីរបស់នាងដ៏ស្មោះចំពោះខ្លួនយ៉ាងនេះ ក៉ាមេស្ហគយគន់រូបនាង ទឹកអៈណិតស្ទើរស្រក់ទឹកភ្នែក អ្នករកពាក្យអ្វីនិយាយតបទឹងនាងទៀតមិនកើត ក៏បរិភោគផ្លែឈើនោះទៅ ៗ លុះបរិភោគហើយ អ្នកប្រាប់នាងកាមាលាថា:

- យើងត្រឡប់ទៅផ្ទះវិញល្ងាចនេះហើយ

នាងកាមាណាដាក់ទឹកមុខស្រពោនមួយរំពេច ហើយនិយាយតិចៗ ថា :

- ខ្ញុំមិនចង់សោះបង

- ចង់ត្រឡប់ទៅសាលារៀនវិញឬ ?

- ទេ ! ទេ ! កុំឲ្យខ្ញុំត្រឡប់ទៅទីនោះទៀត ពួកនិស្សិតនាំគ្នាជជីក សួរខ្ញុំពីរឿងបង ខ្ញុំពិបាកឆ្លើយនឹងគេណាស់ ។

- ឆ្លើយប្រាប់គេថាម៉េចខ្លះទៅហើយ ?

- មានថាម៉េច ! គេចង់ដឹងថា ហេតុអ្វីបានជាបងទុកខ្ញុំឲ្យនៅ សាលានៅពេលវិស្សមកាល (មកដល់ត្រង់នេះ នាងហាក់ដូចជាបើកមុខ ដំបៅម្តងទៀត នាងអួលដើមក រកនិយាយតទៅទៀតមិនកើត ។

- ចុះម៉េចក៏មិនឆ្លើយថា ខ្ញុំគ្មានត្រូវជាអ្វីនឹងនាងទៅ ?

នាងចោលភ្នែក សំឡក់កាមេស្ហ

- ម្តេចក៏បងឲ្យខ្ញុំ ឆ្លើយ ឆ្កួសផ្តាសអីចឹង ?

កាមេស្ហមិនដឹងធ្វើម្តេច រឿងអាថ៌កំបាំងនោះ ទៅជាដង្កូវស៊ីរូងសាច់ ឈាមអ្នកទៅហើយ ។ អ្នកចេះតែនឹកមកក្នុងចិត្តអ្នកថា មិនដឹងជា ដោដន្រោទៅនិយាយយ៉ាងម្តេចខ្លះប្រាប់ហេមណាលិនីទេ មិនដឹងជានាង យល់ថាយ៉ាងម្តេចទៅ ហើយអ្នកនឹងរកពាក្យទៅពន្យល់ប្រាប់នាងថាយ៉ាងម្តេច

នឹងកើត ? ឱ ! ហិមណាលិនីអើយ ! តើអ្នកអាចរស់នៅឆ្ងាយពីនាងបានឬទេ ? អ្នកចេះតែពោទតែម្នាក់ឯង ហើយដោយអ្នកពិបាកគិតពេក អ្នករកពាក្យអ្វីឆ្លើយក៏មិនកើត ។

ការដែលអ្នកដឹងពិតនោះ គឺជារឿងកាមាលានិងអ្នក មុខជាត្រូវពួកមិត្រ និងពួកបញ្ញាមិត្រគេនិយាយពេញកំពង់មាត់ហើយ ។ អ្នកបានធ្វើកំហុសមួយធំណាស់ កាលដែលអ្នកបានប្រាប់គេថា នាងជាប្រពន្ធអ្នក នៅពេលដែលអ្នកត្រឡប់មកកាល់កុត្តាវិញ ។ អ្នកមិនចង់នៅជាមួយនាងតទៅទៀតទេ សូម្បីតែមួយថ្ងៃថែម ក៏អ្នកមិនចង់ដែរ ឃើញក៉ាមេស្ហអង្គុយធ្ងឹងបែបដូចជាគិត នាងកាមាលាសួរថា :

– ព្រួយរឿងអ្វីហ្នឹងបង ? បើថាត្រឡប់ទៅផ្ទះ ខ្ញុំមុខជានឹងទៅតាមបងទេ ។

តែក៉ាមេស្ហចង់ធ្វើអ្វី នាងកាមាលាធ្វើតាមតាំងអស់ ការដែលនាងមិនទទឹងទាស់ ធ្វើឲ្យក៉ាមេស្ហរឹតតែអាណិតនាងខ្លាំងថែមទៀត អ្នកមើលមុខនាងហាក់ដូចជាគ្មានវិញ្ញាណក្នុងខ្លួន ដោយអ្នករវល់តែបណ្តែតអារម្មណ៍ទៅឆ្ងាយពេក ពុំបានរកពាក្យឆ្លើយតបនឹងនាងវិញសោះ ។ នាងទ្រាំមិនបាន សួរថា:

– បងប្រាប់ខ្ញុំឲ្យត្រង់មកមើល បងខឹងព្រោះខ្ញុំមិនព្រមនៅសាលាវិញឬ ? ។

– តាមពិត គឺខ្ញុំចង់និងខ្លួនខ្ញុំទេ ថាហើយអ្នកខំធ្វើឫករើកកាយ ដើម្បីឲ្យនាងសប្បាយចិត្ត ។

– មើល៍ នាងទៅសាលា គេបង្រៀនអ្វីខ្លះ ប្រាប់ខ្ញុំផងមើល ។

នាងកាមាលា ខំនិយាយប្រាប់ក៏មេស្ហអំពីការដែលនាងបានរៀន នៅសាលាថា : គ្រូប្រាប់នាងថាដីមានរាងមូល ក៏មេស្ហធ្វើជាមិនជឿ នាងកាមាលាខំបើកភ្នែកធំ ។ ហើយរត់ទៅយកសៀវភៅ មកបង្ហាញ ក៏មេស្ហជាបន្ទាល់ ។

– ម៉េចក៏បងមិនជឿ ក្នុងសៀវភៅដែលខ្ញុំរៀន គេដាក់ថាអីចឹង ។

– និយាយបំផ្លើសច្រើនណាស់ ! នៅក្នុងសៀវភៅធំប៉ុណ្ណាទៅ ដែលគេនិយាយថាដូច្នេះ ?

នាងឆ្លើយប្រកែក មិនព្រមចាញ់:

– មិនមែនក្នុងសៀវភៅធំណាទេបង សៀវភៅនេះនែ៎ មើល មានទាំងរូបផង ។

នាងនិយាយពីការរៀនសូត្ររួចហើយ នាងនិយាយពីសិស្សស្រី ពីគ្រូ និងអំពីវិន័យរបស់សាលា ប៉ុន្តែក្នុងពេលនោះ ក៏មេស្ហ គ្មានឮអ្វីប៉ុន្មានទេ អារម្មណ៍របស់អ្នកវល់ហោះហើរទៅឆ្ងាយ តែអ្នកចេះតែងក់ក្បាល ហាក់ដូចជាបានស្តាប់ហូរហែ ហើយតែកាលណានាងរៀបនឹងនិយាយចប់ គេចាប់ចុងពាក្យដើម្បីសួរបន្តទៅទៀត មិនយូរប៉ុន្មាន នាង

យល់ថាក៏មេស្ហឥតមានស្ដាប់នាងទេ តូចចិត្តណាស់ នាងស្ទុះក្រោកឡើង:

– បងគ្មានស្ដាប់ខ្ញុំសោះ !

– កុំខឹង ថ្ងៃនេះខ្ញុំមិនសូវស្រួលខ្លួនទេកាមាលា

– បងឈឺ ! ឈឺអីបង ?

– ឥតឈឺអ្វីធ្ងន់ទេ តែយូរៗវាធ្វើអីចឹងម្ដង និយាយតទៅទៀតចុះ ។

បើអីចឹងបងមើលរូបផែនទីរបស់ខ្ញុំ នាងបើកយកគំនូរមកដាក់នៅមុខក៏មេស្ហ, នែ ! បងឃើញទេ ខ្ញុំគូររូបផែនដី ខ្ញុំគូរវង់មូលពីរ ព្រោះយើងមិនអាចមើលដុំអ្វីមូលឃើញទាំងសងខាងតែម្ដងបានទេ ។

ក៏មេស្ហ ធ្វើហាក់ជាគិតបន្តិច រួចឆ្លើយថា:

– បើរបស់នោះសំប៉ែត ក៏យើងមិនអាចមើលឃើញទាំងសងខាងដែរ ។

នេះហើយជាថ្ងៃទី ១ នៃវិស្សមកាលរបស់នាងកាមាលា ។

## វគ្គទី ២០

ក្រោយពេលដែលកូនប្រុសគាត់ចេញផុតទៅ លោកអាណាដា បាប៊ូ ខំបន់ស្រន់ ដើម្បីឲ្យកូនគាត់នាំដំណឹងល្អមកឲ្យគាត់វិញ ទីងឲ្យបានក្ដីស្វាងអំពីរឿងអាថ៌កំបាំងទាំងប៉ុន្មាន ប៉ុន្តែ លុះគាត់ក្រឡេកឃើញ កូនគាត់ត្រឡប់មកវិញជាមួយអាក់ស្ហាយ គាត់ស្រងាកចិត្ត ។

ដោដេទ្រា— តាមពិត គឺខ្ញុំមិនស្មានថាពុក ទុកឲ្យក៉ាមេស្ហក៉ះធ្វើអំពើបែបនេះសោះ ប្រសិនជាខ្ញុំដឹងមុន ខ្ញុំមិនមែននាំវាមកឲ្យស្គាល់ពុកទេ ។

អាណាដា បាប៊ូ– ឯងប្រាប់ពុកជាញយៗ ថា ឯងសប្បាយចិត្តណាស់បើបានក៉ាមេស្ហធ្វើប្ដីហិមណាលិទី ហេតុម៉េចបានជាឯងមិនចង់ . . .

– ខ្ញុំគ្មានចង់បង្អាក់ទេ តែធ្វើម្ដេចបើ . . .

– ពុកមិនយល់ពាក្យ "ធ្វើម្ដេចបើ" របស់ឯងទេ មានតែរៀបការ ឬឈប់ តែប៉ុណ្ណឹង គ្មានត្រូវការធ្វើពាក់កណ្ដាលទេ ។

– ចុះម្ដេចក៏បណ្ដោយឲ្យវាទៅឆ្ងាយម្ល៉េះ ? . . . .

អាក់ស្ហាយព្រុះពុកទិងកូនដៃគ្នា លួចញញឹម

មានការខ្វះ បើទោះជាគេមិនបណ្ដោយ ក៏វាទៅដែរ មិនចាំបាច់ញុំថែមទេ ។ ម្យ៉ាងទៀត បើទឹកដោះគោកំពុបដល់ដីទៅហើយ ទោះយំសោកទៅក៏ឥតប្រយោជន៍ដែរ ឥឡូវត្រូវគិតធ្វើអ្វីធ្វើទៅកុំចាំសាញ ។

ចុះឯងបានឃើញក៉ាមេស្ហដែរ ? (លោកអាណាដា បាប៊ូសួរទាំងពោរពេញដោយសេចក្ដីបារម្ភ)

ដោដេទ្រា— ប្ដីក៏មិនឃើញ ឃើញនៅកណ្ដាលគ្រួសារគេ ឃើញទាំងប្រពន្ធគេទៅទៀត ។

លោកអាណាដា បាប៊ូ ពុំតែប៉ុណ្ណោះ ស្ទុតដូចត្រូវការកន្ទុះ បន្តិចមកទើបគាត់រកទឹកមាត់លេបបាន ហើយបញ្ចេញវាចាសួរ កូនទាំងមិន

សួរដៀផង :

– ប្រពន្ធហ៎ ?

– ហ្នឹងឯង

– អញមិនជឿទេ ប្រពន្ធរបស់ក៏មេស្ហណាទៅ ?

– ក៏មេស្ហរបស់ពុកហ្នឹងណា៎ ! តាំងពីព្រាំងមិញ មិនទៅផ្ទះៗ គឺទៅការប្រពន្ធហ្នឹងហើយ !

- ទេ ចុះថាឪពុករ៉ាស្លាប់ រឿងការនោះក៏ខកខានទៅហើយតើ?

- រ៉ាការរួចទៅហើយ បានឪពុករ៉ាស្លាប់ក្រោយ ៗ

លោកអាណាដា ប៉ាប៊ូ គប់ក្បាលខ្លួនគាត់ ព្រោះរ៉ាត្រូវតើចិងមែន ៗ មួយស្របក់មកទៀត ទើបគាត់និយាយថែម :

– បើដូច្នេះ រ៉ារៀបការជាមួយហិមណាលិនីម្ដេចបាន ?

– ព្រោះតែអ៊ីចឹងហើយបានជាខ្ញុំថា :

– ថាអីថាទៅ បើតរ៉ាន់រៀបចំស្រេចប្រុងតែនឹងចូលពេលទៅហើយ ពាល់តែទៅប្រាប់គេវិញឲ្យឈប់អស់ទៅ ៗ

– មិនបាច់ទៅប្រាប់គេឲ្យឈប់ទេ ប្ដូរតែរឿងមួយទៅបានហើយ រឿងឯទៀត ទុកអ៊ីចឹងចុះ (កូនតានិយាយ លោកតា បែបស្រម្លាំងកាំង)

– អ៊ូទៅ តែរឿងមួយដែលឯងប្ដូរនោះ ?

គ្រាន់តែមើលទៅឃើញហើយ ប្ដូរក៏ ! ប្ដូរប្ដីណា៎ រកប្ដីម្នាក់ទៀត

មកដាក់ជំនួសទៅ ចប់ទៅហើយ បើមិនធ្វើអីចឹងទេ យើងមុខជាលែងហ៊ានងើបមើលមុខអ្នកផងចំហើយ ។

ថាហើយ គេងាកទៅមើលមុខអាក់ស្ហាយ អាក់ស្ហាយទុនមុខចុះធ្វើឫកស្លុតសុភាព ។

អាណាថា ប៉ាប៊ូ— ឯងទៅរកប្តីឯណា បានទាំងតក់ក្រហល់យ៉ាងនេះ?

ជោដេទ្រា· កុំព្រួយពុក ខ្ញុំរកបានភ្លាម

- ធ្វើម្ដេចហិមណាលីនព្រម

— តែវាដឹងរឿងរ៉ាមេស្ហ វាហួសពីព្រមទៅទៀតផង ។

— អើ ឯងគិតឃើញអ៊ីល្អធ្វើទៅចុះ គួរឲ្យស្ដាយណាស់មែន ព្រោះថារ៉ាមេស្ហមានគុណសម្បត្តិល្អ មានប្រាជ្ញាឆ្លាតវៃ ដឹងគួរដឹងសមថែមទៀតផង ។ ទើបតែម្សិលមិញសោះ ភញ្ញ. បាន:បង្គ ពេក ឲ្យវាទៅទិញផ្ទះមួយសម្រាប់ធ្វើទីសំណាក់ការមេធាវីនៅឯអេតាវ, រួច . . .

- យី កុំគិតដល់ម៉្លេះពេក វាទិញអីនៅឯណាទិញទៅ ឈប់គិតគិតតែរឿងប្រាប់ហិមណាលីនឲ្យវាដឹងផងឯនេះ កុំនាំឲ្យបាត់ពេលវេលាទឹកដល់ច្រមុះហើយ ។

ជោដេទ្រា ដើរចេញទៅ បន្តិចត្រឡប់មកវិញ នាំទាំងនាងហិមណាលីមកផង ។ អាក់ស្ហាយ គេចចូលទៅបំបាំងខ្លួនក្រោយទូ ។

ជោជ្រោបង្គាប់ឲ្យប្អូនអង្គុយចុះ រួចតែទឹកគេពាក្យ ទើបនិយាយឲ្យបាន ស្រួល :

— អូនឯងមានសម្គាល់អ្វីប្លែក លើអាកប្បកិរិយារបស់ក៉មេស្ហទេ ?

នាងគ្រវីក្បាលបដិសេធ

— អូនឯងមានសង្ស័យថាវាមានរឿងអ្វីទេ បានជាវាសុំផ្អាកអាពាហ៍-ពិពាហ៍ ?

- ខ្ញុំគ្រាន់តែដឹងថា គេមានការ (នាងនិយាយដោយមិនងើបមុខសោះ)

— អ៊ីចឹងមិនឃើញប្លែកទេ ?

នាងនៅតែគ្រវីក្បាលថាមិនដឹងទៀត ។ អាកប្បកិរិយាប្អូនស្រីនិងលោកតាដែលទុកចិត្តលើក៉មេស្ហពាំងនឹងតងផល់ធ្វើឲ្យជោជ្រោទប់កំហឹងមិនបាន ក៏ប្រែកលែងសំដៃឲ្យប្អូនតែម្តង :

- តាំងរឿងដែលក៉មេស្ហវាទៅផ្ទះជាមួយនឹងឪពុកវា ហើយដល់វាត្រឡប់មកតាល់គ្នាវិញ វាសម្ងំស្ងៀមអស់ប៉ុន្មានខែទេ ? វាទៅពួននៅឯជារដំប៉ាក៉ឯនោះ ទាល់តែវាសិយវាជួបនឹងអូនឯង ហើយអូនឯងហៅវាឲ្យវាមកលេងផ្ទះដូចមុនទៀត ទើបវាមក បើបងនៅផ្ទះ រឿងហ្នឹងមិនបានដល់ទៅម៉្លឹងទេ ។ ចុះបើមានរឿងទៅនឹងតហើយ. ម្តេចក៏មិនរកឧបាយធ្វើឲ្យបានឃើញច្បាស់ទៅ អីក៏គ្មានបេះបង់ដឹងអ្វីបន្តិចសោះយ៉ាងនេះ .

ឥឡូវអូនឯងត្រូវស្ដាប់ ហើយជឿការដែលបងនឹងនិយាយប្រាប់អូនៈ "ពីព្រឹកមិញបងទៅឯសាលារៀន បងបានការណ៍ថា កាំមេស្លាំយកប្រពន្ធវាទៅឲ្យដេកនៅសាលា ហើយដល់ពេលវិស្សមកាល វាគិតឲ្យប្រពន្ធវានៅទីនោះទៀត ប៉ុន្តែនៅពេលក្រោយបំផុត អ្នកស្រីចាងហ្វាងសាលាបានប្រាប់វាថា គាត់មិនអាចរក្សាកាមាលា (គឺជាឈ្មោះប្រពន្ធវា) ទៀតបានទេ ព្រោះសាលាត្រូវបិទទ្វារថ្ងៃនេះ ហេតុនេះហើយបានជាកាមាលាត្រូវចេញទៅនៅផ្ទះ ឯដារជីប៉ាក់ ជាមួយកាំមេស្លា ។

បងទៅផ្ទះវា ហើយបងឃើញស្រីនោះ កំពុងតែចិតផ្លែប៉ោមឲ្យកាំមេស្លាញុំា បងបានសួរកាំមេស្លាឲ្យប្រាប់រឿងកាំវបង វាប្រកែក ។ ប្រសិនជាវាដោះសារថា មិនមែនជាប្រពន្ធវាទេ បងជឿវាទៅហើយ ប៉ុន្តែវាមិនប្រកែក រួចបើឃើញប៉ុណ្ណឹងហើយអូនឯងនៅតែជឿវាទៀតឬ ?

ជោរដេន្រ្ទា និយាយហើយ ទៅសំឡឹងមុខប្អូន ដើម្បីឲ្យនាងឆ្លើយ ប៉ុន្តែនាងមិនឆ្លើយសោះ នាងទៅជាមានមុខស្ងាំង មួយសន្ទុះស្រាប់តែខន់ខ្លួនដួលពីលើកៅអីសន្ទប់មួយរំពេច ។

លោកអាណាជាបាប៊ូ ភ័យស្លុតនឹងកូន គាឲ្យអាស្សូពេក គាត់ស្ទុះទៅលើកត្រកងកូន ទាំងស្រែកផង :

- ជោរដេន្រ្ទាលើកប្អូនយកទៅដាក់លើកៅអីវែងទៅ យកទឹកមកស្រប់មុខឲ្យប្អូន ឯអាក់ស្មាយ ក៏ខំទៅយកផ្ដិតមួយអកបក់ឲ្យនាងដែរ ។

នាងបើកភ្នែកដ៏ធំរបស់ខ្លួនឡើងចំយកក្លាយដៃប្រត់ងើប មានអាការៈវិបចដ្ឋល់ ប៉ុន្តែនាងងាកទៅរកឪពុក ហើយនិយាយតិច ៗ ថា:

– សុំពុកឲ្យអាក់ស្កាយថយបេញឲ្យបាត់ទៅ ។

អាក់ស្កាយដ៏ធំខ្លួន ទម្លាក់ផ្តិតចុះ ដកខ្លួនថយទៅល្វែងម្ខាង យ៉ាងរហ័ស ។ លោកអាណាបាប៊ូ អង្គុយអង្អែលសក់កូន ហើយចេះតែ ដកដង្ហើមធំ ។

– កូនស្រីសំឡាញ់ឪពុក ! កូនស្រីសំឡាញ់ឪពុក !

រំពេចនោះ ស្រាប់តែភ្នែកនាងហាមណាលិទីពោរពេញទៅដោយ ទឹកភ្នែក ហើយដើមទ្រូងនាងមានភាពផឹតប៉ោង ១ នាងខុនបំបាំងមុខ ដើម្បីកុំឲ្យអ្នកដទៃមើលឃើញទុក្ខព្រួយរបស់នាង ។ លោកអាណាដា បាប៊ូអាណិតកូនណាស់ ចំនិយាយលួងលោមកូន :

– ឲ្យគេនិយាយអ្វីក៏និយាយទៅចុះ ពុកស្គាល់ចិត្តកាមេស្កាហើយ វា មិនមែនអាចក្បត់កូនបែបនេះកើតទេ ដោះដន្រ្ទាច្បាស់ជាប្រទូមិនខាន ហើយ ។

ដោះដន្រ្ទាពុ្មពុកចេះតែនិយាយលួងកូន ដើម្បីកុំឲ្យកូនព្រួយពេក ទ្រាំអត់មិនបាន ក៏គំហកឲ្យឪពុក ។

– ពុកកុំមានប្រសាសន៍ឲ្យវាសង្ស័យឥតអំពើនោះ បើពុកចង់ជៀស វាងមិនឲ្យវាជ្រុំងពីឥឡូវ ទៅថ្ងៃមុខនោះវារឹតតែចូលទៅទៀត ។ ឲ្យវាគិត

មើលឲ្យមែនទែនទៅ ។

នាងហិមណាលិនី ពុជ្ជូខ្លោះខ្ទឹងណាស់ ទើបសំឡឹងមុខបងហើយស្តីថា :

— ជកបណាខ្ញុំមិនទាន់បានពុកមេស្រូនិយាយអ្វីពីមាត់គេទេ ខ្ញុំគ្មានជឿអ្នកណាទាំងអស់ ។

ថាហើយ នាងខំក្រោកដើរតម្រង់ទៅក្នុងបន្ទប់ ឪពុកនាងជួយគ្រាកូនហូតដល់គ្រែដេក ។

- ពុកទុកឲ្យខ្ញុំសម្រាកបន្តិច ពុកអញ្ជើញចេញចុះ ។

- កូនឲ្យយាយមេដោះ មកបក់ឲ្យកូនឬ ?

ទេនាំសុំកុំឲ្យអ្នកណាមកជិតនាងឲ្យសោះ ព្រោះនាងចង់នៅតែម្នាក់ឯង ។ លោកតាអញ្ជើញចូលទៅសម្រាកក្នុងបន្ទប់របស់គាត់ ដែលនៅជាប់នឹងបន្ទប់នាង ។ លោកនឹកដល់ប្រពន្ធលោក ដែលទទួលអនិច្ចកម្មតាំងពីនាងទើបនឹងបានអាយុ ៣ ឆ្នាំម៉្លេះ លោកនឹកដល់សេចក្តីស្មោះត្រង់ដល់ការអត់ធ្មត់នឹងទឹកមុខដ៏រីកពាយជាធម្មតារបស់ប្រពន្ធលោក ហើយមានសេចក្តីខ្មោចផ្សាចិត្តអាណិតកូន ដែលតាំងពីម្តាយស្លាប់ចោលទៅនៅតែជាមួយលោក ។ ម្យ៉ាងទៀត នាងហិមណាលិនី នៅពេលដែលនាងចំរើនវ័យធំឡើង នាងរឹតតែដូចម្តាយនាងថែមទៀត ។ លោកខំបន់ព្រះសំពះទេវតា សូមឲ្យលោកជួយគ្រួសគ្រាយ កុំឲ្យមានឧបសគ្គ

កកំណផ្លូវលោកឲ្យសោះ ដើម្បីឲ្យកូនស្រីលោក រស់នៅក្នុងសេចក្តីសុខ សេចក្តីសប្បាយ ហើយមុននឹងលោកស្លាប់ លោកចង់ឃើញកូនស្រីលោករស់នៅជាមួយនឹងស្វាមីដែលជាទីគាប់ចិត្តរបស់នាងពេញទៅដោយសុខភាព ទឹកសព្វគ្រប់ទៅ ទឹកនេត្រាលោកជោរជលហោរហូរឲ្យអាសូរៗ

តាំងតែពីដើមរៀងមក ជោជេន្ទ្រាតែងតែមើលឃើញកម្លាំងចិត្តរបស់ស្រីភាព លុះមានបញ្ហាបែបនេះកើតឡើង យោបល់ដែលគេយល់ថាសំគិះនោះ ទៅជាត្រូវយ៉ាងពេញទំហឹងទៅវិញ ៗ ចុះអ្នកណាៈចះដដែកជាមួយនឹងស្រ្តីយ៉ាងម្តេចកើតបើឃើញការពិតផ្ទាល់ភ្នែកហើយ នៅតែមិនព្រមជឿទៀត តែមានដំពាក់ចិត្តហើយគេប្រាប់ថា ពីរនិងពីរត្រូវជាបួន ក៏មិនជឿដែរ ៗ ក្បួនតក្កវិជ្ជា (La logique) និយាយថា តែពណ៌សគឺ ស ប៉ុន្តែបើមានរឿងស្នេហាមកលាយជាមួយផងនោះពណ៌សមុខជាទៅជាខ្មៅហើយ នៅពេលនោះ អាក់ស្នាយដើរលេប ៗ ចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ជោជេន្ទ្រាហៅមកវិញ :

-ឯងឮអស់ហើយ ធ្វើម៉េចឥឡូវ (ជោជេន្ទ្រាសួរ )

-ម៉េចក៏ហៅខ្ញុំឲ្យចូលក្នុងរឿងហ្នឹងធ្វើអ្វី? មែនទែនទៅខ្ញុំគ្មាននាទីជាអ្វីក្នុងរឿងនេះសោះទេណា ៗ ខ្ញុំឈប់និយាយប៉ុន្មានថ្ងៃហើយ ឥឡូវកុំនាំខ្ញុំឲ្យរវាងក្នុងរឿងនេះទៀត ៗ

-ចាំថ្ងៃក្រោយសឹមឯងសបន្ទោសខ្ញុំ ។ ឥឡូវនេះ ខ្ញុំគ្មានទឹកឃើញអ្វីក្រៅអំពីទៅនិយាយកំមេស្ទូ ឲ្យរក់សារគោពតោសប្រាប់ប្អូនខ្ញុំឲ្យរស់ទៅប៉ុណ្ណោះទេ ។

— ឯងឆ្កួតទេ ឯងស្មានថារក់ . . .

- បើឲ្យស្រួល ស្រេចតែនិយាយឲ្យរក់សរសេរមកឲ្យវិញ ឯងជួយគិតអីចឹងផងទៅមើល ហើយបើបានធាប់តែតែប្រសើរទៅទៀត ។

(នៅមានត)

# ពិធីប្រគល់ព្រះត្រៃបិដកខ្មែរ

ជូនចំពោះមជ្ឈមណ្ឌលពុទ្ធសាសនានៅក្រុងហាលេ
សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់

តាមសេចក្ដីរាយហេតុរបស់សហជីវិន មាស កោន-កែមុំ ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅក្រុងប្រាគ សរសេរផ្ញើមកថ្វាយអ្នកអង្គម្ចាស់រដ្ឋមន្ត្រីក្រសួងការបរទេស ហើយដែលបញ្ជូនសេចក្ដីចម្លងមួយច្បាប់ មកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យនោះ, យើងបានដឹងថា សហជីវិនឯកអគ្គរាជទូតយើងប្រចាំក្រុងប្រាគ បានទទួលកិត្តិយសជាតំណាងរាជរដ្ឋាភិបាលខ្មែរ នាំយកអំណោយគម្ពីរព្រះត្រៃបិដកខ្មែរយើងមួយចប់មាន ១១០ ភាគ ទៅប្រគល់ជូនមជ្ឈមណ្ឌលពុទ្ធសាសនានៅទីក្រុងហាលេ នៅសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ កាលពីថ្ងៃទី ២០ មីនា ១៩៦៩ ។

ពិធីប្រគល់អំណោយនេះ បានប្រព្រឹត្តទៅជាមហោឡារិកនៅក្នុងវិទ្យាធិការដ្ឋាននៃសកលវិទ្យាល័យ ម៉ារតាំង-លុកធើរ នៅចំពោះមុខអ្នករាជការអាល្លឺម៉ង់ តំណាងក្រសួងការបរទេស, ក្រសួងអប់រំជាតិ, លោកសាកលវិទ្យាធិការ, លោកស្រីតំណាងសមាគមមិត្តភាពជាមួយ

ប្រទេសអាស៊ីប៉ែកអគ្នេយ៍ និង អស់លោកមហាវិទ្យាធិការជាច្រើនរូប ។

វេលានោះ មានការប្តូរយោបល់គ្នាជាច្រើន អំពីការទាក់ទងខាងវប្បធម៌រវាងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ជាពិសេស គឺការផ្លាស់ប្តូរឯកសារដែលបោះពុម្ពផ្សាយព្រមទាំងការពិសោធន៍រវាងមជ្ឈមណ្ឌលពុទ្ធសាសនានៅទីក្រុងហាលេ និងវិជ្ជាបាទពុទ្ធសាសនបណ្ឌិត្យយើង ។ បន្ទាប់ពីការសន្ទនាជាមេត្រីភាពនេះមក ក៏មានធ្វើពិធីជាផ្លូវការ ដោយមានសុន្ទរកថាបី ថ្លែងបន្តបន្ទាប់គ្នា គឺទី ១ សុន្ទរកថារបស់លោកហោរ្ស៊ីការគោ ជានាយកផ្នែកសិក្សាអំពីវិទ្យាសាស្ត្របុរាណនៃបូព៌ាប្រទេស, បន្ទាប់មកសុន្ទរកថាលោក វុលហ្វ៍ ជាសាកលវិទ្យាធិការ និងទីបីសុន្ទរកថាសហជីវិនឯកអគ្គរាជទូតខ្មែរ ។ ក្នុងសុន្ទរកថាទាំងពីររបស់មិត្តអាល្លឺម៉ង់ បានដំបញ្ជាក់អំពីមិត្តភាពនៃប្រទេសយើងទាំងពីរ ជាពិសេសៈលោកថ្លែងអំណរព្រះគុណថ្វាយសម្តេចព្រះប្រមុខរដ្ឋខ្មែរ និងអំណរគុណជូនរាជរដ្ឋាភិបាលខ្មែរ ដែលបានធ្វើអំណោយក៏មានទូមសា គឺព្រះត្រៃបិដក ចំពោះមជ្ឈមណ្ឌលពុទ្ធសាសនា នៅប្រទេសលោកក្នុងវេលានេះ ព្រមទាំងជាឧត្តមប្រយោជន៍ ខាងការសិក្សាជាន់ខ្ពស់ នៃសាកលវិទ្យាល័យលោកផង ។

បន្ទាប់ពីសុន្ទរកថាទាំងបីនេះមក លោកសាស្ត្រាចារ្យមេត្រីក បានធ្វើសន្និសីទមួយស្តីអំពីព្រះពុទ្ធសាសនា ដោយលើកយកគោលគំនិតទស្សនៈ

របស់ព្រះពុទ្ធ មកធៀបផ្ទឹមនឹងទ្រឹស្ដីរបស់លោក កាល់ម៉ាក ។ ក្នុងខនេះ លោកសាស្ត្រាចារ្យមេត្តី៊ បានបំផុសឲ្យឃើញច្បាស់ថា ព្រះពុទ្ធជាម្ចាស់ បានរកឃើញជាស្រេច នូវគម្រោងដែលជាមូលដ្ឋាននៃលទ្ធិរួមសម្បាច់ ឯលោកកាល់ម៉ាក គ្រាន់តែជាអ្នកដើរតាមគម្រោងនេះ ហើយបង្កបង្កើត ឲ្យទៅជាគោលគំនិតណែនាំក្នុងលទ្ធិនេះឡើងតែប៉ុណ្ណោះ ( Le Bouddha aurait dijà tracé la base du communisme et Marx n' a fait que suivre cette base pour creér les principes directeurs du communisme)

មុននឹងបញ្ចប់ពិធីនេះ លោកវុល្ហ៍ បានយកមេដាយអនុស្សាវរីយ៍ នៃសាកលវិទ្យាល័យរបស់លោក មកបំពាក់ជូនសហាដីវិនឯកអគ្គរាជទូតខ្មែរ ព្រមទាំងមានការជប់លៀងជាកិត្តិយសផង រួចហើយលោកអញ្ជើញ ភ្ញៀវចូលទស្សនា មជ្ឈមណ្ឌលពុទ្ធសាសនាដែលនៅទីនោះ មានតម្កល់ គម្ពីរក្បួនច្បាប់ជាច្រើន ដែលបានទៅពីប្រទេសនានា នៅចុងបូព៌ា ហើយដែលសុទ្ធតែស្ដីពីព្រះពុទ្ធសាសនាទាំងអស់ ។

# ពិធីនមស្ការព្រះសក្យមុនីចេតិយ

ពិធីបុណ្យពិសាខបូជា ជាបុណ្យមួយដ៏ធំក្នុងព្រះពុទ្ធសាសនា ។ បណ្ដាជនខ្មែរពុទ្ធសាសនិក បានប្រារព្ធធ្វើបុណ្យនេះរៀងរាល់ឆ្នាំនៅគ្រប់វត្តអារាមទាំងអស់ក្នុងព្រះរាជាណាចក្រ ។

នៅទីក្រុងភ្នំពេញ, ក្រៅពីពិធីដែលរៀបចំឡើងដោយពុទ្ធបរិស័ទនៅតាមអារាមនានា, ព្រះរាជរដ្ឋាភិបាលបានប្រារព្ធធ្វើបុណ្យនេះ ជាផ្លូវការ នៅទីលានមុខស្ថានីយកដាយស្វ័យយាន ចំពោះមុខព្រះសក្យមុនីចេតិយ គឺព្រះចេតិយដែលតម្កល់ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ។

ពិធីនេះប្រារព្ធឡើងនៅថ្ងៃពេញបូណ៌មីខែពិសាខ ត្រូវនឹងថ្ងៃអាទិត្យទី ១ ខែឧសភា គ.ស. ១៩៦៩ នៅក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភ ដោយមានឥស្សរជនជាន់ខ្ពស់គ្រប់តំណែង ព្រមទាំងអ្នករាជការ អ្នកមុខអ្នកការ ឧបាសក ឧបាសិកា ដែលអញ្ជើញមកពីគ្រប់ទិសទីក្នុងក្រុងភ្នំពេញ ចូលរួបរួមដង្ហែព្រះអគ្គមគ្គុទ្ទេសក៍ជាតិក្នុងពេលនេះផង ។

វេលាម៉ោង ១៨ គឺនៅពេលដែលសម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងដល់ ហើយព្រះអង្គទ្រង់បានគោរពព្រះសង្ឃចំនួន ៨០ អង្គដ៏មានសម្ដេចព្រះសង្ឃរាជ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះពោធិវង្ស និងព្រះ

សង្ឃរាជាគណៈ ហ៊ានាទុក្រមជាអាទិ៍នោះមក ក្រុមភ្លេងនៃកងយោធា ចាប់បន្ទឺសព្ទស្គរឡើងកំដរបទម្រៀងដ៏ពិរោះ បទនគររាជរបស់និស្សិតប្រុសស្រីនៃសាកលវិទ្យាល័យវិចិត្រសិល្បៈ ។ ពេលនោះ គ្រហស្ថទាំងអស់ ក៏ទ្រង់សណ្ឋិតនិងក្រោកឈរគោរពភ្លេងជាតិ តមកពីបទនគររាជ អ្នកបម្រៀងក៏ស្ងូត្របទសរភញ្ញ ពេលនោះព្រះសង្ឃទាំងអស់ ក៏ទ្រង់សណ្ឋិត និមន្តក្រោកឈរដែរ ឯពួកគ្រហស្ថទាំងអស់ក៏លើកហត្ថប្រណម្យអញ្ជលីឆ្ពោះទៅព្រះសក្យមុនីចេតិយ ដែលពេលនោះ ទង់ជាតិនិងទង់សាសនា បានអណ្ដែតឡើងទៅចុងដងទង់បក់រវិចតាមខ្យល់ ហាក់សម្ដែងការរីករាយសប្បាយនៃពុទ្ធបរិស័ទក្នុងមហាពិធីនេះ។ លុះចប់ការគោរពទង់ជាតិទង់សាសនានេះហើយ សហជីវិន អ៊ុង ហុង សាត ឧបនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកក្រសួងមហាផ្ទៃ ធម្មការ និងការប្រស្រ័យជាមួយសភា បានថ្លែងសុន្ទរកថាមួយ សម្ដែងអំណរព្រះមហាករុណាធិគុណ នៃសម្ដេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ និងអភិវន្ទនាការចំពោះព្រះបរមធាតុ នៃព្រះពុទ្ធជាម្ចាស់ (សុន្ទរកថានេះ យើងចុះផ្សាយជូនទាំងស្រុងនៅទំព័របន្ទាប់) ។ តពីនេះមកទៀតក៏មានពិធីនមស្ការជាឧឡារិក ដោយមានអាចារ្យម្នាក់ស្ងូត្រនាំមុខ ។

បន្ទាប់ពីនេះ សម្ដេចឪជាអម្ចាស់ ទ្រង់យាងប្រទក្សិណព្រះសក្យមុនីចេតិយដោយមានព្រះរាជបរិពារ ឥស្សរជននាម៉ឺនសព្វមុខមន្ត្រីគ្រប់តំណែងអញ្ជើញដង្ហែផង និងមានយុវជន-យុវតី, កងរាជតម្រួត កងយោធា

និងភ្ជាក់ងារពេតការស៊ើរល ឈរព័ទ្ធជាកិត្តិយសជុំវិញបរិវេណព្រះចេតិយ ដោយបញ្ចេញជ័យឃោសន៍ពួកនំពេនផង ៗ គ្រប់ជុំហើយ សម្ដេចឪ ព្រះប្រមុខរដ្ឋ ស្ដេចទ្រង់ថ្វាយកម្រងមាលាចំពោះព្រះសារីរិកធាតុ ដែល តម្កល់ក្នុងទីនេះ សម្ដែងព្រះរាជវន្ទនកិច្ច ៗ

ក្រោយពីពេលសម្ដេចព្រះអគ្គសាសនូបត្ថម្ភក៏ ស្ដេចយាងត្រឡប់វិញ ហើយ មានរៀបចំធ្វើពិធីវិសាខបូជាជាលំដាប់ ដោយមានព្រះសង្ឃសូត្រ វិសាខបូជា និងទេសនាហូតដល់ពេលអធ្រាត្រ ៗ

លុះព្រឹកឡើងថ្ងៃ ១ រោច ខែពិសាខ ចាប់តាំងពីម៉ោង ៨ និង ៤០ នាទី ក៏មានពិធីដាក់ប្រាត្រព្រះសង្ឃ ជាផ្លូវការនៅលើវេទិកាបុណ្យចំនួន ៨០ អង្គ ក្រោមព្រះរាជាធិបតីភាពនៃសម្ដេចឪ ព្រះប្រមុខរដ្ឋ ៗ បន្ទាប់ពីនេះទៀត មានការដាក់បាត្រព្រះសង្ឃ ២៥០០ អង្គ នៅពេញទីសួនបណ្ដោយតាម វិថីព្រះកុសុមៈ និងវិថីឧកញ៉ាផ្លុង ក្រោមការរៀបចំនៃពុទ្ធិកសមាគមទាំងបី គឺពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ សមាគមមិត្តពុទ្ធិកវិទ្យាល័យ និង សមាគមគិលានសង្គ្រោះព្រះមហាក្សត្រិយានី នៅក្រោមកិច្ចចាត់ចែង នៃក្រសួងធម្មការ ៗ

# សុន្ទរកថា

សហជីវិនឧបនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកក្រសួងធម្មការ

ថ្លែងក្នុងឱកាសបុណ្យនមស្ការព្រះសក្យមុនីចេតិយ

(ថ្ងៃទី ១-៥-៦៩)

---

សូមព្រះតេជៈតម្កល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ

នៃសម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ជាព្រះឯកអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

ថ្ងៃនេះជានក្ខត្តឫក្ស ពេញបូណ៌មីខែពិសាខ ដែលពុទ្ធសាសនិកជនទូទៅ ប្រារព្ធធ្វើពិធីបុណ្យរំឭកដល់អភិលក្ខិតសម័យនៃព្រះសម្ពុទ្ធបរមគ្រូ គឺជាថ្ងៃដែលព្រះអង្គទ្រង់ប្រសូត្រជាជាតិចុងក្រោយបំផុត ថ្ងៃដែលព្រះអង្គទ្រង់បានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ និង ជាថ្ងៃដែលព្រះអង្គយាងចូលកាន់ព្រះបរិនិព្វាន ។ បណ្ដាជនខ្មែរទូទាំងប្រទេស ក៏បានប្រារព្ធធ្វើពិធីនេះ ជាទំនៀមជាប់រៀងមកគ្រប់វត្តអារាម ។ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ មានបីតិរីករាយឥតឧបមាដោយបានឱកាសដង្ហែព្រះប្រមុខរដ្ឋដ៏ជាទីគោរព ជាទីស្នេហាស្មើដោយជីវិតរបស់ខ្លួន គឺអង្គសម្ដេចឪជាអម្ចាស់ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ស្ដេចយាងមកជាព្រះរាជាធិបតី ក្នុងឱកាសដ៏មហោឡារិកនេះ ។ ព្រះរាជវត្តមានរបស់

ព្រះអង្គ រឹងរឹតតែបន្ថែមនូវសក្តិភាពដ៏ច្បាស់ឡើងទៀត បញ្ជាក់អំពីទឹកព្រះចិន្តាដ៏សែនត្រជាក់ ក្រាលដណ្តប់ប្រោះព្រំទៅលើសន្តានចិត្តខេមរជនគ្រប់ឋានៈគ្រប់ពេលវេលា ទាំងកិច្ចការកសាងប្រទេសជាតិ, ទាំងការកសាងបុណ្យកុសល តាមសេនុវាទ នៃព្រះពុទ្ធជាអម្ចាស់ ។

សូមទ្រង់ព្រះមេត្តាប្រោស !

ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ ជាពិធីបុណ្យជាតិដែលជាព្រះកេរ្តិ៍ឧត្តមរបស់សម្តេចឪជាម្ចាស់ ដែលព្រះអង្គទ្រង់ប្រោសព្រះរាជទាននូវព្រះសារីរិកធាតុនៃព្រះសម្ពុទ្ធដែលព្រះអង្គបានមកពីប្រទេសស្រីលង្កា នៅគ្រាដែលស្តេចយាងធ្វើព្រះរាជទស្សនកិច្ចនៅប្រទេសនោះ ឲ្យយកមកប្រតិស្ឋាននៅទីព្រះចេតិយនេះ ។ ព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិតទ្រង់ព្រះមេត្តាប្រោសឲ្យសាងព្រះចេតិយនេះឡើង ហើយទ្រង់ប្រកាសឲ្យធ្វើបុណ្យនមស្ការជាផ្លូវការរៀងរាល់ឆ្នាំ តាំងពី គ.ស. ១៩៥៧ មក ។ ព្រះរាជកេរ្តិ៍ថ្លៃថ្លានេះឯង ក៏បានដិតជាប់ក្នុងសន្តានចិត្តនៃពុទ្ធមាមកជនខ្មែរ ឲ្យរឭកឃើញជានិច្ច នូវព្រះករុណាធិគុណប្រពៃពិសេសនេះពុំមានភ្លេចមួយគ្រាណាឡើយ ។ ព្រះរាជូបត្ថម្ភ គ្រប់បែបគ្រប់យ៉ាងក្នុងផ្លូវព្រះពុទ្ធសាសនា ទុកដូចជាព្រះអំណោយទានមួយយ៉ាងធំ ខាងផ្លូវប្រាជ្ញានិងផ្លូវបដិបត្តិចំពោះបណ្តាជនខ្មែរជាកូនចៅរបស់ព្រះអង្គ ។ ជាភស្តុតាងមួយថ្មីទៀត គឺដោយសារព្រះរាជតម្រិះដ៏ជ្រះថ្លា និងវាងវៃរបស់សម្តេចឪជា

អម្ចាស់ ទ្រង់ត្រាស់បញ្ជាឲ្យក្រសួងធម្មការចាត់ចែងការ ជាមួយក្រសួងនានា ធ្វើពិធីសម្ពោធព្រះត្រៃបិដកជាផ្លូវការនោះ បណ្ដាជនខ្មែរពេញចិត្តឥតអ្វីប្រៀបផ្ទឹមបាន ហើយក៏នាំគ្នាចាត់ចែងធ្វើពិធីនេះយ៉ាងគគ្រឹកគគ្រេង នៅគ្រប់ទីវត្តអារាមគ្រប់សង្កាត់ គ្រប់ស្រុក គ្រប់ខេត្ត គ្រប់ក្រុង ៗ ដូច្នោះហើយ បានជាគម្ពីរព្រះត្រៃបិដក ដែលរាជរដ្ឋាភិបាលបានចាត់ការបោះពុម្ពតាំងពីច្រើនឆ្នាំមកហើយនោះ មានពុទ្ធបរិស័ទមកជាវយកទៅធ្វើពិធីដង្ហែយ៉ាងអឹកធឹក បើគិតជាប្រាក់បំណុលក្នុងថវិកាជាតិ ដោយការជាវសៀវ-ភៅនេះ ឃើញថាបានចំនួនប្រាំបួនលាន ប្រាំមួយសែនរៀល ហើយសព្វថ្ងៃនេះ ក៏នៅតែមានពុទ្ធបរិស័ទមកជាវជាហូរហែយកទៅតម្កល់ជាក្បួនខ្នាតសម្រាប់សិក្សាប្រចាំវត្តអារាមរៀង ៗ ខ្លួន ៗ សក្ខីភាពយ៉ាងទៀតនៃសទ្ធាជ្រះថ្លាយ៉ាងមុះមុតនៃពុទ្ធមាមកជននៅកម្ពុជរដ្ឋ ចំពោះព្រះពុទ្ធសា-សនានោះ គឺនៅពេលហែក្បួនសម្ពោធព្រះត្រៃបិដក ព័ទ្ធជុំវិញព្រះរាជធានីកាលពីថ្ងៃទី ១ មេសា ១៩៦៩ មានសប្បុរសជន បរិច្ចាគបច្ច័យចូលចាប់កុសលដំគ្រកាលនេះ រួមទៅបានចំនួន ៧៥៤.០៦៩ រៀល ៗ មិនតែប៉ុណ្ណោះ គោលចារិកព្រះពុទ្ធវចនៈនៅក្នុងព្រះត្រៃបិដក បានជ្រួតជ្រាបសស្រាក់សស្រឹមៈទៅក្នុងសន្ដានចិត្ត នៃពុទ្ធបរិស័ទខ្មែរយើងកាន់តែខ្លាំងក្លាឡើងទៀត ដូចជាព្រះឱវាទ ដែលសម្ដេចឪជាអម្ចាស់ ទ្រង់បានថ្លែងកាលពីថ្ងៃទី ១ មេសា ក្នុងវេលាប្រារព្ធពិធីសម្ពោធព្រះត្រៃបិដក នៅទី

លានពុទ្ធិកវិទ្យាល័យ ព្រះសុក្រម៉ិតថា : គម្ពីរក្បួនខ្នាតទាំងនេះ មិនត្រឹមតែជាគោលសិក្សារបស់ព្រះសង្ឃ នៅតម្កល់តាមវត្តអារាមប៉ុណ្ណោះទេ អស់លោកជាគ្រហស្ថមានយុវជនជាដើម ក៏ត្រូវមានក្បួនច្បាប់ទាំងនេះ ជាឯកសារផ្ទាល់ខ្លួនដែរ ព្រោះសេនុវាទនៃព្រះសទ្ធម្មរបស់ព្រះសម្ពុទ្ធនេះ ហើយ ជាមេគំនិតបណ្ដុះបញ្ញាស្មារតីរបស់យើងឲ្យបានដុះដាស់ក្ដីត្រកាល គ្រប់ពេលវេលា ត្រូវតាមគន្លងមនោគមវិជ្ជាជាតិ គឺសង្គមនិយមព្រះពុទ្ធ-សាសនា ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជវរោកាស ថ្វាយអភិវន្ទនាការចំពោះព្រះសារីរិកធាតុ ដែលមានតម្កល់នៅទីចេតិយនេះ ដូចតទៅ ។

បពិត្រព្រះអរហន្ត សម្មាសម្ពុទ្ធ បរមគ្រូ

នៅវេលានេះ ខ្ញុំព្រះអង្គទាំងឡាយ ជាពុទ្ធបរិស័ទនៅប្រទេសកម្ពុជា មានសម្តេចព្រះមហាក្សត្រិយានីបរមបពិត្រ សម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ សកាទាំងពីរ រាជរដ្ឋាភិបាល នាម៉ឺនសព្វមុខមន្ត្រីគ្រប់តំណែង មានទាហាន ស៊ីវិល កងពលតម្រួត កងអាសាស្ម័គ្រ និង យុវជន-យុវតី ព្រមទាំងឧបាសក ឧបាសិកា បានមកប្រជុំគ្នា ធ្វើពិធីនមស្ការចំពោះព្រះសារីរិកធាតុរបស់ព្រះអង្គដើម្បីសម្តែងនូវព្រះរាជហឫទ័យ និង ទឹកចិត្តគោរពដ៏ជ្រាលជ្រៅចំពោះព្រះមហាករុណាធិគុណរបស់ព្រះអង្គ ដែលបានទុកព្រះសាសនា ពោល

គឺពាក្យប្រៀនប្រដៅ ដែលតាមដល់យើងខ្ញុំព្រះអង្គគ្រប់គ្នា ៗ រសព្រះសទ្ធម្ម ទុកដូចជាទឹកអម្រឹតប្រោះព្រំបណ្ដុះសតិបញ្ញា ចំពោះយើងខ្ញុំព្រះអង្គគ្រប់ពេលគ្រប់វេលា ព្រមទាំងជាបទដ្ឋានមួយយ៉ាងវិសេសថ្លៃថ្លា ឲ្យមនុស្សលោកទាំងពួងចេះនឹក ឃើញដល់រសជាតិសន្តិភាព សេចក្ដីស្ងប់ក្សេមក្សាន្ត ជាពិសេសគឺបណ្ដាជនខ្មែរដែលប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ថែមទាំងដកស្រង់នូវគោលគំនិតដ៏ល្អប្រពៃទាំងនេះ ធ្វើជាគោលនយោបាយជាតិផង គឺនយោបាយសង្គមនិយមព្រះពុទ្ធសាសនា ដែលសម្ដេចព្រះ **នរោត្តម សីហនុ** ទ្រង់សព្វព្រះរាជហឫទ័យបង្កើតឡើង ដើម្បីញ៉ាំងកម្ពុជឲ្យបានជួបតែនឹងសេចក្ដីសុខ សេចក្ដីចម្រើនរុងរឿង រហូតដល់បានឈ្មោះថាជាកោះសន្តិភាព នៅក្នុងភូមិភាគអាស៊ីប៉ែកអគ្នេយ៍ ដែលសព្វថ្ងៃច្រើនតែមានក្នក់នរក គឺសង្គ្រាមដុតពេលពលនោះ ៗ ហេតុនេះ សូមសម្ដេចព្រះបរមសាស្ដាសម្មាសម្ពុទ្ធ មេត្តាប្រោសទទួលនូវអភិវន្ទនាការ ព្រមទាំងគ្រឿងសក្ការៈបូជាទាំងឡាយ មានទៀន ធូប ផ្កាភ្ញី ប្រទីបជ្វាលានិង សេចក្ដីគោរពទាំងកាយវាចាចិត្តរបស់យើងខ្ញុំព្រះអង្គ ៗ

សូមទ្រង់ព្រះមេត្តាប្រោស !

ដោយព្រះគុណានុភាពនៃពិធីបុណ្យដែលកើតឡើងក្នុងគ្រានេះ, ទូលព្រះបង្គំជាខ្ញុំសូមថ្វាយនូវព្រះរាជកុសល ចំពោះសម្ដេចព្រះមហាក្សត្រិយានីជាម្ចាស់ជីវិត និង សម្ដេចឪជាម្ចាស់ សូមព្រះអង្គទ្រង់បានប្រកបដោយ

ព្រះបរមសុខសួស្តី មានព្រះជន្មាទីឃាយុយឺនយូរ និង បានឈ្នះអស់មារសត្រូវគ្រប់ទិសទី ដើម្បីបានជាម្លប់យ៉ាងសែនសុខ របស់បណ្តាជនខ្មែរទូទៅ ។

មួយចំណែកទៀត សូមបុញ្ញកុសលនេះ ជួយទ្រទ្រង់សម្តេចព្រះសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះពោធិវង្ស សូមទ្រង់ប្រកបតែនឹងសេចក្តីសុខព្រះកាយពល ផុតចាកពេលាពាធផងទាំងពួង ដើម្បីបានទ្រទ្រង់ព្រះពុទ្ធសាសនា ឲ្យរីកតែថ្កុំថ្កើងឡើង ។

ទីបំផុត សូមតេជានុភាពនៃកងការកុសលនេះ ជួយឧបត្ថម្ភបរិស័ទខ្មែរទាំងអស់ ទាំងព្រះសង្ឃទាំងគ្រហស្ថ មាននាម៉ឺនសព្វមុខមន្ត្រី ទាហាន ស៊ីវិល កងពលតម្រួត កងអាសាស្ម័គ្រ យុវជន·យុវតី ជីវពល នារី ក្លាហាន និង បណ្តាជនទូទៅ សូមឲ្យបានជួបតែនឹងសេចក្តីសុខ សេចក្តីចំរើនគ្រប់ប្រការ ព្រមទាំងមានចិត្តព្រមព្រៀងគ្នាជាធ្លុងមួយក្នុងការកសាងជាតិ ព្រះពុទ្ធសាសនា និងរាជបល្ល័ង្ក ដង្ហែតាមព្រះមាគ៌ានយោបាយដ៏ភ្លឺស្វាងនៃសម្តេចឪ ព្រះអគ្គមគ្គុទ្ទេសក៍ជាតិ គ្រប់ពេលវេលា តរៀងទៅកុំបីឃ្លាត ។

ជយោ ! សង្គមនិយមព្រះពុទ្ធសាសនា

សូមព្រះតេជះតម្កល់លើត្បូង !

# សេចក្ដីអំពាវនាវ

## នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

សូមពិតពុទ្ធដីកា ព្រះតេជព្រះគុណ សូមជំរាបសមាជិកនៃ ជាសមាជិកា-សមាជិក នៃក្រុមទំនៀមទម្លាប់

សូមជ្រាប ។

កម្មវត្ថុ : អំពីពិធីឡើងរេង និងល្បែងកូនគោលក្លើង ។

មានអ្នកស្រាវជ្រាវបរទេសជាច្រើន ត្រូវការចង់ដឹងឲ្យច្បាស់លាស់អំពីពិធីឡើងរេង និងល្បែងកូនគោលក្លើង ដែលជាប្រពៃណីនិងទំនៀមទម្លាប់នៃប្រជាពលរដ្ឋខ្មែរយើង ។ ហេតុនេះការិយាល័យទំនៀមទម្លាប់ សូមអំពាវនាវដល់ព្រះតេជព្រះ គុណ អស់លោកអ្នក ជាសមាជិកា សមាជិក ក្រុមទំនៀមទម្លាប់ ទាំងអស់នៅគ្រប់ស្រុក គ្រប់ខេត្ត មេត្តាផ្ដល់ពត៌មានអំពីពិធីឡើងរេង និងល្បែងកូនគោលក្លើង ដែលគេធ្លាប់ធ្វើ ធ្លាប់លេងនៅស្រុក ភូមិរបស់ព្រះតេជព្រះគុណ អស់លោក អ្នក តាមសំនួរដូចខាងក្រោមនេះរួចផ្ញើទៅការិយាល័យក្រុមទំនៀមទម្លាប់នៅពុទ្ធសាសនបណ្ឌិត្យឲ្យទាន់មុនដាច់ឆ្នាំ ១៩៦៩ នេះ ព្រោះអ្នកស្រាវជ្រាវនោះ គេចង់ទៅមើលដល់ទីកន្លែង និង បានថតរូបផង ។

ឯគោលសេចក្ដីដែលត្រូវឆ្លើយ គឺត្រូវឆ្លើយឲ្យខ្លី ដូចមានសំនួរតទៅនេះ :

នៅស្រុក ភូមិ ព្រះតេជព្រះគុណ អស់លោក អ្នក មានធ្វើពិធីឡើងពេញ និងលេងល្បែងកូនគោលក្តើងនេះដែរ ឬទេ? បើមានធ្វើ មានលេង តើគេធ្វើពិធីនោះធំដុំ ឬ តូចតាចទេ?

- គេធ្វើពិធីនេះ នៅថ្ងៃ ខែ ណា ? ធ្វើនៅកន្លែងណា (កំណត់យកក្នុងឆ្នាំ ១៩៧០) ។

- សូមប្រាប់ផ្លូវដែលទៅកាន់កន្លែងនោះ តើរាបជិះយានអ្វីទើបទៅបានតើពិបាកទៅ ឬ ងាយទៅ ?

- ឯរឿងល្បែងកូនគោលក្តើងក៏ដូចគ្នាដែរ តើគេលេងល្បែងនេះនៅថ្ងៃ-ខែ ណា សព្វថ្ងៃនេះនៅមានគេលេងដែរឬទេ សូមផ្តល់ពត៌មានឲ្យច្បាស់លាស់ ។

សូមព្រះតេជព្រះគុណ សហជីវិនី សហជីវិន មេត្តាឲ្យពត៌មាននេះឲ្យច្បាស់លាស់, ក្រុមទំនៀមទម្លាប់ នឹងចាត់ឲ្យជូនអ្នកស្រាវជ្រាវតាំងនោះឲ្យមកពិនិត្យមើលដល់ទីកន្លែង ។

សូមព្រះតេជព្រះគុណ សហជីវិនី សហជីវិន ទទួលនូវសេចក្តីគប់អានដ៏ស្មោះអំពីខ្ញុំ ។

នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

លាង ហាប់ អាន

៦

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤១ ខែ មិថុនា

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-

៦

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

| អត្ថបទ | ផ្នែកសាសនា | ទំព័រ |
|---|---|---|


១— អត្ថសាវត្ថីវប្បវត្តិ លោក ហេង-សមអាន រៀបរៀង . . . ៥៥៣

២— កម្លាំងនៃស្ត្រី លោក ប៊ុ-ប៊ី រៀបរៀង. . . . . . ៥៨២


## ផ្នែកអក្សរសាស្ត្រ


៣— វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង ខាត់ . . . . ៥៨៦

៤— របៀបរៀបចំខាងគុណការ ស.ហ. ហ៊ែល-ស៊ុំផា រៀបរៀង . . ៥៩០

៥— រឿងសាមកុក (ត) ឧកញ៉ានូ-កន ប្រែរៀបរៀង . . . . ៦០៩

៦— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ សហជីវិន ពេជ-សល់ ប្រែរៀបរៀង ៦១៩

៧—ការប្រយុទ្ធ និងមធ្យោបាយដោះស្រាយសេចក្ដីល្អង់ លោក វ៉ាយ-ប៊ុក រៀបរៀង ៦៣០

៨— សិលាចារឹកជ្រះគោ សហ. ឌឹក-គាម ស្រាវជ្រាវ . . . . ៦៣៦


## ផ្នែកកំណត់-ប្រវត្តិការណ៍


៩— ប្រកាសប្រគួតប្រជែងទំនៀមទម្លាប់ សម្រាប់ឆមាសទី ២ ឆ្នាំ ១៩៦៩
អំពីរឿងចម្រៀងប្រណាប្រិយ៍ និង ទោសនិងការផ្ដន្ទារបៀបបុរាណ . . ៦៤៨

១០— **ឯកសារ** : ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង ឧកញ៉ាប្រសើរលិខិត
ម៉ែន-ទន់ រៀបរៀង . . . . . . . ៦៥៣

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ។

## ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក | ឲ្យធ្វើល្អទៅ, |
| ឲ្យជុំសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា - |

ប. ព

# អគ្គសាវកជីវប្បវត្តិ

សហជីវិនហោ ង៍ សមអាង នាយទាហានរងកងយោធពលខេមរភូមិន្ទ

ធ្វើការទៅសេនាធិការយោធភូមិភាគទី ១

តែងនិងរៀបរៀង

## នមស្ការព្រះអគ្គសាវ័ក

ខ្ញុំព្រះករុណា នាម ហោ ង៍ សមអាង

សូមបន្ទន់ប្រាណ អញ្ជលីប្រណម្យ
ដាក់លើសិរសា ហត្ថាក្រពុំ
ក្រាបថ្វាយបង្គំ ព្រះអគ្គសាវ័ក ។

ព្រះសារីបុត្រ ប្រាជ្ញមុតពិច័ត្ត
លើសឥន្ទព្រហ្មយក្ស សាវ័កទាំងឡាយ
គាបទិនសម្តែង ថ្លែងអធិប្បាយ
ព្រះធម៌ទាំងឡាយ ដូចព្រះសាស្តា ។

ព្រះមោគ្គល្លាន មានឫទ្ធិខ្លាំងក្លា
លើសព្រហ្មទេព្តា សាវ័កទាំងឡាយ
អាចនឹងបំប្លែង ប្រែព្រះរូបកាយ
ហិតហោះផ្លោះឆ្ងាយ បានដូចព្រះពុទ្ធ ។
ព្រះអគ្គសាវ័ក ព្រះទ័យបរិសុទ្ធ
ប្រសើរលើសផុត សាវ័កទាំងឡាយ
ខ្ញុំព្រះករុណា ក្រាបបង្គំថ្វាយ
ហើយសូមបរិយាយ ប្រវត្តិព្រះអង្គ ។

## សេចក្តីផ្តើម

កាលមិនយូរទៅ មានច្រើនជាតិ ច្រើនសាសន៍ ច្រើនប្រទេស ដែលនៅក្នុងពិភពលោកនេះ សុទ្ធតែមានជំនឿរៀងមួយ ទោះមិនតិចក៏ច្រើន ដែលខ្ញុំយល់ឃើញថា ជាវត្ថុដ៏សក្តិសិទ្ធិ គួរតាំងពាក់អាស្រ័យ គោរពរាប់អាន, ក្នុងរបស់មាននៅតែឯកឯង ឥតទីពឹងឡើយ ។ វត្ថុដ៏សក្តិសិទ្ធិទាំងនោះ គេច្រើនហៅយកសាសនា ឬលទ្ធិដែលជាប្រពៃណី របស់បុព្វបុរស សម្រាប់ជាតិនីមួយ ៗ តែងប្រព្រឹត្តជាប់ត ៗ គ្នាមក ទើបឈ្មោះថា សាសនា ។ សាសនានេះមានផ្សេង ៗ គ្នា តាមមតិរបស់សាស្តានីមួយ ៗ បង្កើតឡើងបានឡើង ដើម្បីញ៉ាំងបរិស័ទឲ្យចូលជឿស្តាប់គោរពរាប់អាន ដូចឃើញស្រាប់ហើយ បានឮមកហើយ ដែលមានក្នុងលោកនេះ ។

បណ្ដាសាសនាទាំងអស់ក្នុងលោក មានតែព្រះពុទ្ធសាសនាមួយទេ ដែលជាសាសនាមានសារៈសំខាន់ កំពូលលើសាសនាទាំងអស់ ព្រោះជាសាសនាអាចធ្វើឲ្យមនុស្សគ្រប់ឋានៈ ដែលជាអ្នកប្រតិបត្តិតាម ឲ្យមានសន្តិភាព សេរីភាព សាមគ្គីភាព និងវឌ្ឍនភាព ក្នុងលោក ។

ព្រះមហាបុរសមួយរូប អ្នកមានវិចារណញ្ញាណដ៏ជ្រាលជ្រៅ បានរកឃើញសេចក្ដីប្រតិបត្តិដែលមានខ្លឹមសារពិសេស អាចធ្វើមនុស្សគ្រប់ឋានៈឲ្យបានរួចចាកភ្លើងកិលេស ភ្លើងទុក្ខ ហើយបានប្រកាសផ្សាយទុកជាបដល់សព្វថ្ងៃនេះ, ព្រះមហាបុរសនោះ គឺព្រះសម្មាសម្ពុទ្ធហ្នឹងឯង ។

បញ្ហាប្រវត្តិសាស្ត្រ បានកើតឡើងបែបនេះថា ព្រះពុទ្ធមានរូបកាយជាមនុស្សពិតមែនឬ ? ឬក៏គ្រាន់តែជានិមិត្តបុគ្គលទេ ?

ចំពោះរឿងនេះ អ្នកប្រវត្តិសាស្ត្រជំនាញខាងអារ្យធម៌ឥណ្ឌា មានយោបល់ប្លែក ៗ គ្នា, តែទោះយ៉ាងណាក៏ដោយ សព្វថ្ងៃពុំមានអ្នកណាអាចទុកព្រះពុទ្ធជានិមិត្តបុគ្គលបានឡើយ ។ ព្រះសម្មាសម្ពុទ្ធពិតជាមនុស្សមួយរូប ពុំមែនជាអាទិទេព ឬអំណាចដែលអាចកំបាំងមើលមិនឃើញឯណាឡើយ ដោយបុរាណវត្ថុ បានចង្អុលនូវភស្តុតាង យ៉ាងច្បាស់លាស់ណាស់ ភស្តុតាងបានស្ថិតនៅមកតាំងពីសតវត្សទី ៣ មុនគ្រិស្តសករាជម្ល៉េះ ។

ដូចនេះហើយ អ្នកប្រាជ្ញខាងប្រវត្តិសាស្ត្រយល់ថា គេពុំអាចដកអច្ឆរិយហេតុពីព្រះពុទ្ធ ឬព្រះពុទ្ធពីអច្ឆរិយហេតុ ដោយពុំប៉ះពាល់ធ្វើឲ្យខូចដល់ព្រះពុទ្ធសាសនា ព្រោះជីវភាពព្រះពុទ្ធនេះ ពិតជាឧទាហរណ៍ ដ៏ល្អបំផុត ជាពិសេសក្រៃលែង សម្រាប់ព្រះធម៌ គឺក្នុងការប្រៀនប្រដៅរបស់ព្រះពុទ្ធ, ព្រះជីវភាពនេះ ជាជីវភាពគម្រូសម្រាប់ប្រជាជនទូទៅ ដែលស្វែងរកសុភមង្គល ឬព្រះនិព្វាន ។

ព្រះពុទ្ធ ជាមនុស្សពិត ជាព្រះរាជបុត្រនៃព្រះបាទសុទ្ធោទន៍ និងព្រះមហាមាយាទេវី ត្រកូលគោតម ជាស្តេចសក្យៈសោយរាជ្យនៅក្រុងកបិលពស្តុ ប្រទេសសក្កៈ ។ ព្រះអង្គប្រសូតនៅឧទ្យានលុម្ពិនីវ័ន ចន្លោះក្រុងកបិលពស្តុនិងទេវទហៈ ក្នុងប្រទេសនេប៉ាល សព្វថ្ងៃនេះ ។

ពុទ្ធប្បវត្តិបានតំណាលថា ព្រះសម្មាសម្ពុទ្ធប្រសូតមក ទ្រង់ឈរលើផែនដី ឈាន ៧ ជំហានទៅទិសខាងជើង ហើយផ្ចោះព្រះនេត្រគ្រប់ទិស មើលបន្លឺវាចាថា

អគ្គោហមស្មិ លោកស្ស
សេដ្ឋោហមស្មិ លោកស្ស
ជេដ្ឋោហមស្មិ លោកស្ស
អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោ ។

# ប្រែជាខេមរភាសា

អាត្មាអញ ជាកំពូលនៃលោក

ជាបុគ្គលប្រសើរជាងគេក្នុងលោក

ជាច្បងជាងគេក្នុងលោក

ជាតិកំណើតនេះក្រោយបំផុត លែងកើតទៀតហើយ ។

កាលប្រសូតបាន ៥ ថ្ងៃ ព្រាហ្មណ៍ ៨ នាក់ បានតាំងពិធីថ្វាយព្រះនាមថា សិទ្ធត្ថៈ ។

ក្រោយដែលបានពិនិត្យលក្ខណៈនៃរូបព្រះសិទ្ធត្ថៈ, ព្រាហ្មណ៍ ៧ នាក់លើកម្រាមដៃ ២ ហើយទាយថា "បើនៅក្នុងនគរ ព្រះរាជកុមារនេះ នឹងបានជាស្តេចចក្រពត្រាធិរាជ, បើចេញពីនគរទៅបួស នឹងបានត្រាស់ជាព្រះពុទ្ធ" ។

ឯព្រាហ្មណ៍ទី ៨ ឈ្មោះកោណ្ឌញ្ញព្រាហ្មណ៍ លើកម្រាមដៃតែមួយ ទាយថា "ព្រះរាជកុមារនេះ ប្រាកដជាបានត្រាស់ជាព្រះពុទ្ធ" ។

ព្រះសុទ្ធោទន៍ ជាព្រះវរបិតា ទ្រង់ព្រះសណ្តាប់ទំនាយព្រាហ្មណ៍ ហើយទ្រង់ត្រាស់សួរថា "ម្នាលព្រាហ្មណ៍ ! ព្រះរាជបុត្រយើងឃើញអារម្មណ៍ដូចម្តេច ទើបចេញទៅបួស ? ។

ព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ! ព្រះរាជកុមារនឹងចេញចាកនគរទៅបួស នៅវេលាដែលបានឃើញនិមិត្ត ៤ យ៉ាង គឺឃើញ

មនុស្សជរា ១ មនុស្សឈឺ ១ មនុស្សស្លាប់ ១ និងអ្នកបួស ១ ។

ព្រះបាទសិរីសុទ្ធោទន-គោតម ទ្រង់ចាត់ការម៉ឺនម៉ាត់ប្រយ័ត្នមិនឲ្យព្រះរាជបុត្រឃើញនិមិត្តទាំងនេះ ទុកឲ្យឋិតនៅតែក្នុងទីសប្បាយរីករាយសម្បូណ៌ដោយភោគទ្រព្យនិងគ្រឿងត្រេកគ្រប់យ៉ាង មានព្រះស្រីស្នំ ៤ ម៉ឺនជាបរិវារ ។

លុះព្រះជន្ម ១៦ ឆ្នាំ ទ្រង់អភិសេកព្រះនាងយសោធរា (ពិម្ពា) ជាឯកអគ្គមហេសី សោយរាជសម្បត្តិដ៏ថៃទសុខរហូតដល់ព្រះជន្ម ២៩ ឆ្នាំ ទើបមានព្រះរាជឱរសមួយអង្គព្រះនាម រាហុល ។ តែទោះជាយ៉ាងណាក៏ដោយ ព្រះសិទ្ធត្ថ ពុំអាចចៀសឲ្យផុតពីសង្គមមនុស្ស និងដំណើរដែលជាច្បាប់នៃធម្មជាតិមនុស្ស ។

ក្រោយពេលដែលបានប្រទះនិមិត្តទាំង ៤ គឺ ជរា ព្យាធិ មរណៈនិងបព្វជិតហើយ ព្រះសិទ្ធត្ថទ្រង់ចាប់អារម្មណ៍ នឿយណាយក្នុងរាជសភោគ នឹងចេញបព្វជ្ជា ដោយទ្រង់យល់ថា មានតែបព្វជ្ជាទេ ដែលអាចនឹងបើកឱកាសស្វែងរកឧបាយដោះស្រាយ បញ្ហាចាស់ ឈឺ ស្លាប់ ដែលគ្របសង្កត់សព្វសត្វក្នុងពិភពលោកបាន ។

“ការស្គាល់តែសេចក្តីសុខសប្បាយ ពុំដែលស្គាល់សោះនូវទុក្ខ,
ការស្គាល់តែសេចក្តីត្រេកត្រអាល ពុំដែលស្គាល់សោះនូវព្រួយ,
ការស្គាល់តែរូបស្អាតស្រស់បំព្រង ពុំដែលស្គាល់សោះ នូវរូប

អាក្រក់ក្រខ្វក់ ហើយស្រាប់តែប្រទះឃើញនូវហេតុដែលផ្ទុយពីការភ្ជាប់ ភ្ជាប់ដីង ភ្ជាប់ពុ ភ្ជាប់ឃើញ ភ្ជាប់ស្នានក្ដាម ក៏បណ្ដាលឲ្យប្រែគំនិត សតិអារម្មណ៍ ដូចព្រះសិទ្ធត្ថ-គោតមនេះឯង” ៗ

បើព្រះសុទ្ធោទនជាព្រះវរបិតា ពុំចាត់វិធានការបង្ខាំងទេ ព្រះសិទ្ធត្ថជាកូនបុត្រ ពុំអាចសម្រេចព្រះទ័យទៅបួសឡើយ ព្រោះអារម្មណ៍ទាំង-ឡាយរបស់ព្រះអង្គទ្រង់ស្របទៅតាមច្បាប់ទម្លាប់ ដែលពោលថា “ទម្លាប់បង្អន់នូវការភ្ញាក់ផ្អើល” ៗ

ត្រង់នេះ ជាខ ១ បង្ហាញឲ្យឃើញច្បាស់ថា ព្រះពុទ្ធសាសនាស្របទៅតាមហេតុនិយម ដែលជាគោលនៃវិទ្យាសាស្ត្រ ៗ

ព្រះសិទ្ធត្ថ ព្រះអង្គពុំមែនចេញទៅបួសដោយខ្លាច ពុំហ៊ានតស៊ូនឹងជីវភាពរបស់ខ្លួនទេ ព្រះអង្គពុំមែនជាអត្តទត្តបុគ្គល រត់ចោលកូនប្រពន្ធសង្គមជាតិ ដើម្បីស្វែងរកសេចក្ដីសុខស្រួលតែម្នាក់ឯងនោះទេ ៗ

ផ្ទុយទៅវិញ ព្រះសិទ្ធត្ថជាវិញ្ញូជន ពោរពេញដោយបរមត្ថភាព ទ្រង់ចេញបព្វជ្ជា ដើម្បីស្វែងរកអនុត្តរសម្មាសម្ពោធិញ្ញាណ ពោលគឺលោកុត្តរ-ធម៌ ដើម្បីជួយស្រោចស្រង់សត្វលោកឲ្យផុតពីសេចក្ដីវិនាស កុំឲ្យលង់ក្នុងវដ្ដសង្សារ ៗ

ក្នុងអឌ្ឍរាត្រសង្ងាត់ ព្រះសិទ្ធត្ថទ្រង់យាងចេញចាកនគរទៅបព្វជ្ជា

ដើម្បីស្វែងរកមោក្ខធម៌, មិនយូរប៉ុន្មាន ទ្រង់បានយល់បានឃើញច្បាស់ នូវសព្វញ្ញុតញ្ញាណនោះនៅលើរតនបល្ល័ង្ក ក្រោមដើមពោធិព្រឹក្ស ពេលព្រះអាទិត្យរះបំព្រាង ៗ នៃថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំរកា ក្រោយអំពីទុក្ករកិរិយា ៦ ឆ្នាំ ។ ព្រះសិទ្ធត្ថទ្រង់បានព្រះនាមថា ព្រះពុទ្ធ ចាប់តាំងពីថ្ងៃនោះមក ។

ចាប់តាំងពីថ្ងៃដែលបានត្រាស់ដឹងមក ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ប្រកាសសាសនធម៌ដល់សត្វនិករទូទៅក្នុងលោក ។ លុះដល់ថ្ងៃ ១៥ កើត ខែមាឃ ឆ្នាំរកាជាគម្រប់ ៩ ខែគត់ គិតពីថ្ងៃដែលព្រះអង្គបានត្រាស់ ព្រះអង្គទ្រង់ប្រជុំព្រះអរហន្តទាំងឡាយធ្វើមហាសន្និបាត ក្នុងវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះនៃសហរដ្ឋមគធៈ ទ្រង់ប្រទានតែងតាំងតំណែងអគ្គសាវ័កនិងមហាសាវ័កហើយទ្រង់ប្រកាសគោលច្បាប់ព្រះពុទ្ធសាសនា ។

១- តំណែងអគ្គសាវ័កប្រទានចំពោះព្រះមហាថេរ ២ អង្គគឺៈ

អគ្គសាវ័កស្តាំ ឬអគ្គសាវ័កទី ១ បានដល់ព្រះសារីបុត្រ ហើយទ្រង់តាំងក្នុងឋានៈជាឯតទគ្គៈខាងបញ្ញា គឺជាព្រះអរហន្តមានបញ្ញាកំពូលអាចនឹងសម្តែងធម្មចក្រ និងចតុរារិយសច្ច ដូចព្រះអង្គបាន ។

-អគ្គសាវ័កឆ្វេង ឬទុតិយសាវ័ក បានដល់ព្រះមោគ្គល្លាន ហើយទ្រង់តាំងក្នុងឋានៈ ជាឯតទគ្គៈខាងឫទ្ធិ គឺព្រះអរហន្តមានឫទ្ធិកំពូលអាចនឹងសម្តែងបាដិហារ្យ បានដូចព្រះអង្គ ។

៤. តំណែងមហាសាវ័ក ប្រធានចំពោះព្រះមហាថេរ ៨០ អង្គ មាន ព្រះមហាកស្សបត្ថេរ ព្រះកុមារកស្សបត្ថេរ ព្រះអង្គុលិមាលត្ថេរ ព្រះអនុរុទ្ធត្ថេរ ព្រះអានន្ទត្ថេរជាដើម ។

ព្រះបរមសាស្ដាចារ្យ ទ្រង់បានអគ្គសាវ័ក មានប្រាជ្ញាឆ្នើម មានឫទ្ធិឆ្នើម និងអសីតិមហាសាវ័ក បានជួយទ្រទ្រង់ជាកម្លាំងយ៉ាងក្រៃលែង ក្នុងការប្រកាសផ្សាយព្រះពុទ្ធសាសនា ទើបព្រះពុទ្ធសាសនា រីកសាយទូលំទូលាយ ផ្សាយទូទៅគ្រប់ទិសទី ជាប់តរហូតដល់សព្វថ្ងៃនេះ ។

លំដាប់តពីនេះ ខ្ញុំនឹងលើកយករឿងស្ដីអំពីព្រះអគ្គសាវ័ក ដែលស្រាវជ្រាវនិងដកស្រង់ចេញពីគម្ពីរនានា មករៀបរៀងទុកជាប្រវត្តិ ដើម្បីលោកអ្នកត្រូវការចង់ដឹង ចង់ចេះ ចង់សិក្សានូវព្រះជីវប្រវត្តិព្រះអគ្គសាវ័ក ទាំងពីរព្រះអង្គ ដូចតទៅ៖

## ជីវភាពគ្រហស្ថ

ក្នុងសម័យពុទ្ធកាល មានរឿងតំណាលថា មានគហបតី ២ នាក់ជាមិត្តជិតស្និទ្ធនឹងគ្នា, ម្នាក់ឈ្មោះ វង្គន្តព្រាហ្មណ៍ ប្រពន្ធឈ្មោះសារីព្រាហ្មណី នៅក្នុងភូមិឧបតិស្សៈ, ម្នាក់ទៀតឈ្មោះ គោលិតព្រាហ្មណ៍ ប្រពន្ធឈ្មោះ មោគ្គលីព្រាហ្មណី នៅក្នុងភូមិគោលិតៈ ក្បែរក្រុងរាជគ្រឹះនៃដែនមគធៈ ។

គ្រកូលទាំងពីរនេះ ជាត្រកូលស្ដុកស្ដម្ភ បរិបូណ៌ដោយភោគសម្បត្តិ និងបរិវារសម្បត្តិ ហើយត្រូវជាមិត្តចំណងគ្នារាប់ ៧ តំណាត្រកូលមកហើយ ។

មានថ្ងៃមួយ នាងព្រាហ្មណីជាភរិយានៃមិត្តទាំងពីរ បានប្រសូតបុត្រាមួយម្នាក់ ក្នុងថ្ងៃជាមួយគ្នា ។ កុមារកូនលោកវង្គន្តៈ ឈ្មោះឧបតិស្សៈ គឺហៅតាមឈ្មោះភូមិដែលកើត, កុមារកូនលោកកោលិតៈ ឈ្មោះកោលិតៈ គឺហៅតាមឈ្មោះបិតា ឬហៅតាមឈ្មោះភូមិដែលកើត ។

លុះកុមារទាំងពីរមានវ័យល្មមសិក្សា មាតាបិតានៃកុមារទាំងពីរបានបញ្ជូនឲ្យទៅសិក្សាគម្ពីរសាស្ត្រនិងសិល្បសាស្ត្រ ចេះចប់សព្វគ្រប់ទាំងអស់ ។

យុវជនឧបតិស្សៈ, កាលបើត្រូវការទៅលេងទឹកស្ទឹងក្តី ឧទ្យានក្តី ទស្សនាមហោស្រពក្តី តែងតែជិះវិមានដែលមានបុរសកម្លោះច្រើននាក់សែងដង្ហែទៅ ។ យុវជនកោលិតៈ, កាលបើត្រូវការទៅលេងទឹកស្ទឹងក្តី ឧទ្យានក្តី ទស្សនាមហោស្រពក្តី តែងតែជិះរថ ដែលទឹមដោយសេះអាជានេយ្យ មានបុរសកម្លោះច្រើននាក់ហែហមទៅដូចឧបតិស្សៈដែរ ។

នៅក្រុងរាជគ្រឹះ, មានការលេងមហោស្រពមួយជាទំនៀមរាល់ៗឆ្នាំ ។ ពួកជនបរិវារនាំគ្នាចងគ្រែតូចដាក់បន្តើតលើគ្រែធំក្នុងកន្លែងមួយ ដើម្បីឲ្យគហបតិបុត្រទាំងពីរនោះអង្គុយមើលមហោស្រព ។ គហបតិបុត្រទាំងពីរនាក់អង្គុយមើលមហោស្រពជាមួយគ្នា, ក្នុងវេលាកំពុងមើលនោះ នាកដែលគួរសើចក៏សើច នាកដែលគួរស្ញើតក៏ស្ញើត នាកដែលល្អពេញ [illegible] ។

[illegible] គហបតិបុត្រទាំងពីរនាក់នោះ កំពុងមើលមហោស្រពដូច

សព្វផង, ធាតុគួរសើចក៏មិនសើច ធាតុគួរសង្វេគ ក៏មិនសង្វេគ គួរឲ្យរន្ធត់ ក៏មិនឲ្យរន្ធត់ មិនដូចជាថ្ងៃមុន ៗ ឡើយ ព្រោះអ្នកកម្លោះទាំងពីរនាក់មានញាណបារមីដ៏ចាស់ក្លា សញ្ជឹងគិតពិចារណាថា "ប្រយោជន៍អ្វីយើងនឹងមើលមហោស្រពនេះ បើមនុស្សយើងរស់នៅមិនបាន ១០០ ឆ្នាំផង, គួរតែយើងស្វែងរកមោក្ខធម៌មួយ ដើម្បីដោះខ្លួនចេញឲ្យផុតអំពីការមិនទៀងទាត់" ។

ពេលនោះ កោលិតមាណពនិយាយនឹងឧបតិស្សមាណពថា "ម្នាលមិត្ត! ថ្ងៃនេះ មិត្តឯងដូចជាមិនសប្បាយរីករាយដូចថ្ងៃមុនៗសោះ មិត្តឯងមិនសូវស្រួលក្នុងខ្លួនឬ ឬក៏មិត្តឯងកំណត់ឃើញអ្វី?" ។ ឧបតិស្សមាណពក៏និយាយថា "ម្នាលសំឡាញ់! យើងកំពុងតែគិតថា ការមើលមហោស្រពនេះឥតប្រយោជន៍ គ្មានខ្លឹមសារអ្វីសោះ គួរតែស្វែងរកមោក្ខធម៌, ចុះមិត្តឯង ដូចជាមិនសូវរីករាយ តើព្រោះអ្វីដែរ ?" ។ កោលិតមាណពនោះក៏និយាយប្រាប់តាមដំណើរខ្លួនប្រាប់ឧបតិស្សៈ ដោយសព្វគ្រប់ ។

ខណៈនោះ ឧបតិស្សមាណពដឹងថា កោលិតៈជាមិត្តមានគំនិតត្រូវគ្នានឹងខ្លួនដែរ ក៏និយាយថា "នែមិត្ត! យើងទាំងពីរនាក់ត្រូវស្វែងរកមោក្ខធម៌ ដែលយើងបានគិតទុកល្អហើយនោះ ។ ការស្វែងរកមោក្ខធម៌នោះ យើងត្រូវតែបួសសិន, តើយើងនឹងបួសក្នុងសម្នាក់អ្នកណា?" ។ កោលិតៈ និយាយថា "យើងត្រូវតែចេញពីទីនេះសិន ទើបរកបទីរក

អាចារ្យ" ។ ឧបតិស្សៈថា យោបល់របស់មិត្តប្រពៃណាស់ យើងត្រូវតែចេញទៅឥឡូវនេះ ។

## ការស្វែងរកមោក្ខធម៌

សម័យនោះ មានបរិព្វាជក (អ្នកបួសក្រៅព្រះពុទ្ធសាសនា) ឈ្មោះ សញ្ជ័យ អាស្រ័យនៅក្រុងរាជគ្រឹះ ជាមួយបរិព្វាជកជាបរិវារ ២៥០ នាក់ ។ ឧបតិស្សៈនិងកោលិតៈទាំងពីរនាក់ បានចូលមកដល់អាស្រមរបស់បរិព្វាជក ហើយ ក៏បញ្ជូនបរិវារ ៥០០ នាក់ឲ្យនាំមាសនិងរថត្រឡប់ទៅស្រុកវិញ ។ មិត្តទាំងពីរនាក់នេះ នាំបរិវារ ៥០០ នាក់ ដែលនៅសល់ ចូលទៅបួសក្នុងសម្នាក់អាចារ្យសញ្ជ័យ ។ ចាប់តាំងពីឧបតិស្សៈនិងកោលិតៈបួសថ្ងៃណាមក អាចារ្យសញ្ជ័យបរិបូណ៌ដោយយសនិងលាភយ៉ាងក្រៃលែង ។

ចំណែកឧបតិស្សៈនិងកោលិតៈ នៅបានពីរបីថ្ងៃ ក៏កំណត់ដឹងនូវលទ្ធិអាចារ្យសញ្ជ័យទាំងអស់ ហើយក៏សួរថា "បពិត្រលោកអាចារ្យ! លទ្ធិអស់ត្រឹមតែប៉ុណ្ណោះ ឬមានតទៅទៀត ?" ។ អាចារ្យសញ្ជ័យប្រាប់ថា "ការចេះដឹងរបស់យើង អស់ត្រឹមនេះឯង" ។ ឧបតិស្សៈនិងកោលិត ឮអាចារ្យសញ្ជ័យប្រាប់ដូច្នោះហើយ ក៏គិតថា ការប្រព្រឹត្តធម៌ក្នុងសម្នាក់អាចារ្យសញ្ជ័យនេះ នាំឲ្យខាតប្រយោជន៍ ខាតពេលវេលា ទាំងមិនអាចញ៉ាំងគុណវិសេសណាមួយឲ្យកើតបានឡើយ. យើងត្រូវតែចេញទៅស្វែងរកមោក្ខធម៌ក្នុងទីដទៃទៀត ព្រោះថា ជម្ពូទ្វីបនេះធំទូលាយណាស់, យើងត្រូវ

តែស្វែងឲ្យគ្រប់និគមជនបទនិងរាជធានី គង់តែមិនបានអាចារ្យណាមួយ សម្តែងមោក្ខធម៌ប្រាប់ដល់យើងមិនខាន ។

ចាប់តាំងពីថ្ងៃនោះមក ឧបតិស្សៈនិងកោលិតៈ ក៏ចាំស្វែងរកអាចារ្យ ដែលចេះមោក្ខធម៌ក្នុងរាជធានីរាជគ្រឹះ, បើឮគេនិយាយថា មានសមណ-ព្រាហ្មណ៍បណ្ឌិតមាននៅទីណា ក៏នាំគ្នាទៅទីនោះ ហើយសាកសួរប្រ-ស្នាផ្សេងៗ, កាលបើសមណព្រាហ្មណ៍ទាំងនោះ មិនអាចឆ្លើយដោះស្រាយ នូវប្រស្នានោះបានទេ ក៏ត្រឡប់មក កាន់ទីលំនៅរបស់ខ្លួនវិញ ហើយធ្វើសេចក្តីប្តេជ្ញានឹងគ្នាថា នែសំឡាញ់! បណ្តាយើងទាំងពីរនាក់ អ្នកណា លុះនូវអមតធម៌មុនគេ អ្នកនោះ ត្រូវតែប្រាប់ដល់អ្នកដែលមិនទាន់បានលុះផងកុំខាន ។

កាលឧបតិស្សៈនិងកោលិតៈទាំងពីរនាក់ បានប្តេជ្ញានឹងគ្នាហើយ ក៏ត្រាច់ទៅកាន់ទីផ្សេងៗ ។ ពេលនោះ ព្រះមហាថេរព្រះនាម អស្សជិ ជាព្រះអរហន្តមួយអង្គ ដែលព្រះបរមសាស្តាចារ្យ ទ្រង់បញ្ជូនឲ្យប្រកាសសាសនា, លោកក៏បានចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ នៅវេលាព្រឹក, បរិព្វាជកឧបតិស្សៈ បានឃើញព្រះអស្សជិ មានអាយុ ក៏គិតថា ឱហ្ន៎! បព្វជិតមានភាពបែបនេះ អាត្មាអញមិនដែលប្រទះសោះ, បណ្តាព្រះអរ-ហន្តទាំងឡាយក្នុងលោក, បព្វជិតអង្គនេះ ពិតជាព្រះអរហន្តមួយអង្គដែរ, ដូច្នេះ គួរអាត្មាអញចូលទៅសាកសួរភិក្ខុអង្គនេះល្បងមើល, លុះគិតហើយ

ក៏យល់ថា ពេលនេះ ជាពេលមិនគួរសមនឹងសាកសួរប្រស្នា ចំពោះកិច្ចអង្គនេះទេ ព្រោះលោកកំពុងតែដើរចូលទៅបិណ្ឌបាត ក្នុងចន្លោះផ្ទះ, អាត្មាអញគ្រាន់តែតាមលោកពីខាងក្រោយទៅសិនចុះ ចាំលោកឆាន់រួច សឹមសួរ ។

លុះព្រះអស្សជិត្ថេរ បានបង្ហាន់បិណ្ឌបាតហើយ ក៏និមន្តទៅកាន់ទីស្ងាត់មួយប្រាថ្នាទីឆាន់ ។ ឧបតិស្សបរិព្វាជក ក៏យកគ្រឿងប្រដាប់របស់ខ្លួនទៅរៀបចំប្រគេនព្រះថេរៈ ហើយយកទឹកក្នុងកុណ្ឌីរបស់ខ្លួន ទៅប្រគេនទៀត, លុះព្រះអស្សជិត្ថេរឆាន់រួចហើយ ក៏ចូលក្រាបថ្វាយបង្គំទូលសួរថា "បពិត្រលោកម្ចាស់! ឥន្ទ្រិយរបស់លោកម្ចាស់ស្រគត់ស្រគំល្អណាស់ ទាំងពណ៌សម្បុរ របស់លោកម្ចាស់ ក៏បរិសុទ្ធផូរផង់ល្អណាស់ដែរ ។ តើលោកម្ចាស់បួសចំពោះលោកណា ? មានលោកណាជាគ្រូ ? ពេញចិត្តនឹងធម៌សាស្ដាណា ?" ។

ព្រះអស្សជិត្ថេរ បានស្ដាប់ពាក្យសួរ របស់ឧបតិស្សបរិព្វាជកនោះហើយឆ្លើយថា "ម្នាលបរិព្វាជក! អាត្មាបួសចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គជាសាស្ដាចារ្យ ជាគ្រូរបស់អាត្មា" ។ ឧបតិស្សបរិព្វាជក សួរថា ចុះគ្រូរបស់លោកម្ចាស់ សម្ដែងធម៌ដូចម្ដេចខ្លះ ? ។ ព្រះអស្សជិត្ថេរឆ្លើយថា "អាត្មាទើបនឹងបួសថ្មី ទើបនឹងបានរៀនធម៌បន្តិច, អាត្មាមិនអាចសម្ដែងធម៌ដោយពិស្ដារបានទេ តែអាត្មាអាចពោលនូវធម៌ខ្លី ៗ ឲ្យស្ដាប់

បាន" ។ ឧបតិស្សបរិព្វាជក ក៏ទូលតបវិញថា "ខ្ញុំព្រះករុណា នាម ឧបតិស្សបរិព្វាជក, សូមលោកម្ចាស់សម្ដែងធម៌តិចក្ដី ច្រើនក្ដី ឲ្យឃើញជាទំនងជាលំអានចុះ មិនចាំបាច់ពោលនូវព្យញ្ជនៈឲ្យច្រើនឡើយ, ឯការយល់ ឬមិនយល់នោះ ជាភារៈនៃខ្ញុំព្រះករុណាទេ, សូមលោកម្ចាស់មេត្តាសម្ដែងឲ្យបានដោយអនុគ្រោះ ។

ព្រះអស្សជិត្ថេរមានអាយុ ក៏ពោលនូវគាថា ប្រកបដោយអក្សរ ៣២ តួថា ៖

យេ ធម្មា ហេតុប្បភវា
តេសំ ហេតុំ តថាគតោ
តេសញ្ច យោ និរោធោ ច
ឯវំវាទី មហាសមណោ

ប្រែជាភាសាខ្មែរ

ធម៌ទាំងឡាយណា តែងកើតអំពីហេតុ, ព្រះតថាគតពោលនូវហេតុ នៃធម៌ទាំងឡាយនោះផង ពោលនូវសេចក្ដីរលត់និងឧបាយជាគ្រឿងរំលត់នូវធម៌ទាំងឡាយនោះផង, ព្រះមហាសមណៈ (ជាគ្រូរបស់ភន្តា) តែងតែពោលយ៉ាងនេះជាប្រក្រតី ។

ឧបតិស្សបរិព្វាជក បានស្ដាប់សេចក្ដីត្រឹមប៉ុណ្ណោះ ក៏បានសម្រេចសោតាបត្តិផលក្នុងពេលនោះភ្លាម, ទើបទូលឃាត់ថា "សូមលោកម្ចាស់

កុំសម្តែងឲ្យហួសទៅវាងលើទៀត ត្រឹមតែប៉ុណ្ណោះបានហើយ, តែឥឡូវនេះ ព្រះបរមគ្រូជាម្ចាស់គង់នៅទីណា ?” ព្រះអស្សជិត្ថេរ ប្រាប់ថា “ព្រះមានព្រះភាគ គង់នៅវត្តវេឡុវ័ន” ។ ឧបតិស្សបរិព្វាជកក្រាបទូលថា “បើដូច្នោះ សូមលោកម្ចាស់និមន្តទៅមុនចុះ ដ្បិតខ្ញុំព្រះករុណាមានមិត្តម្នាក់បានប្តេជ្ញានឹងគ្នាថា បើអ្នកណាបានអមតធម៌មុន អ្នកនោះត្រូវប្រាប់គ្នាកុំខាន, ឥឡូវនេះ ខ្ញុំព្រះករុណាត្រូវទៅប្រាប់មិត្ត” ។ ទូលហើយក៏ថ្វាយបង្គំលាព្រះអស្សជិត្ថេរ ដើរយ៉ាងលឿនសំដៅទៅបរិព្វាជការាម ។

ឯកោលិតបរិព្វាជក ក្រឡេកឃើញសំឡាញ់ដើរមកពីចម្ងាយក៏គិតថា “ទឹកមុខសំឡាញ់អញថ្ងៃនេះស្រស់ប្រិមប្រិយណាស់ តាំងដំណើរក៏រហ័សរហួនណាស់ មិនដូចថ្ងៃមុនៗទេ, ប្រហែលជាបានលុះអមតធម៌ទេដឹង?” ហើយសួរថា “នែមិត្ត! ថ្ងៃនេះប្លែកពីថ្ងៃមុនៗ តើបានលុះអមតធម៌ហើយមែនឬ? ឧបតិស្សបរិព្វាជក ក៏ប្រាប់តាមដំណើរហេតុ ហើយសម្តែងនូវគាថានោះឲ្យកោលិតៈស្តាប់ ។ កោលិតបរិព្វាជក បានស្តាប់ចប់ហើយក៏បានសម្រេចសោតាបត្តិផលភ្លាម ។

មិត្តតាំងពីរនាក់ប្រឹក្សាគ្នាថា “យើងបានលុះនូវអមតធម៌ហើយ គួរតែយើងទៅប្រាប់សញ្ជយបរិព្វាជកជាអាចារ្យផង, បើគាត់ជឿយើង មុខជាគាត់ទៅសម្នាក់ព្រះសាស្តា ស្តាប់ធម៌ទេសនាហើយ នឹងបានសម្រេចមគ្គផលមិនខាន” ហើយក៏នាំគ្នាទៅកាន់សម្នាក់អាចារ្យសញ្ជ័យ ពិត

ទូលថា “បពិត្រលោកអាចារ្យ! ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតឡើងក្នុងលោកហើយ, សូមលោកអាចារ្យ ឈប់ប្រព្រឹត្តធម៌ឥតខ្លឹមសារនេះទៅ! សូមអញ្ជើញទៅកាន់សម្នាក់ព្រះបរមសាស្តា ជាមួយយើងខ្ញុំ” ។ សញ្ជយ-បរិព្វាជកឆ្លើយថា “មិនគួរទេ អ្នកទាំងឡាយកុំទៅឡើយ, យើងទាំងបីនាក់នឹងគ្រប់គ្រងគណៈនេះ”, មិត្តទាំងពីរនាក់និយាយថា “នៅគ្រប់គ្រងគណៈនេះ បានប្រយោជន៍អ្វី បើធម៌គ្មានខ្លឹមសារសោះ?”. អាចារ្យសញ្ជ័យថា “អ្នកទាំងពីរទៅចុះ ខ្ញុំមិនទៅទេ ព្រោះយើងជាគ្រូអាចារ្យធំរបស់មហាជន បើយើងទៅធ្វើសិស្សគេ ប្រហែលគ្នានឹងការកម្រើករញ្ជួយនៃទឹកក្នុងពាងដែរ” ។ មិត្តទាំងពីរនាក់ ក៏អង្វរថា “បពិត្រលោកអាចារ្យ! ចាប់តាំងពីកាលព្រះពុទ្ធបានត្រាស់ឡើងក្នុងលោក មានពួកមហាជនច្រើនណាស់ នាំគ្នាកាន់គ្រឿងសក្ការៈទៅបូជាព្រះពុទ្ធជាម្ចាស់នោះ ទាំងពួកយើងក៏ទៅក្នុងទីនោះដែរ ចុះលោកអាចារ្យ នៅធ្វើអ្វីទៀត” អាចារ្យសញ្ជ័យថា “បើដូច្នោះយើងសួរអ្នកថា ក្នុងលោកនេះ មនុស្សល្ងង់ខ្លៅច្រើន ឬមនុស្សចេះដឹងមានច្រើនជាង?”, មិត្តពីរនាក់ឆ្លើយថា “មនុស្សល្ងង់ខ្លៅច្រើនជាងមនុស្សចេះដឹង”, អាចារ្យសញ្ជ័យថា “អើ! បើដូច្នោះ មនុស្សដែលជាបណ្ឌិត ចេះដឹងជ្រៅជ្រះ ទៅកាន់សម្នាក់ព្រះមហាស្រមណ៍កំៈណារនោះចុះ, មនុស្សដែលល្ងង់ ៗ មកកាន់សម្នាក់យើងចុះ” ។

ឧបតិស្សៈនិងកោលិតៈ អង្វរយ៉ាងនេះ៣ដងហើយ សញ្ជយបរិព្វាជក

នៅតែរឹងមិនព្រមតាមឡើយ, ហើយក៏លានាំទាំងបរិព្វាជកជាបរិវាររបស់សញ្ជយាចារ្យ ២៥០ នាក់ ទៅសម្នាក់ព្រះមានព្រះភាគ ។

ឯអាចារ្យសញ្ជ័យ ឃើញបរិវាររបស់ខ្លួន ២៥០ នាក់តាមឧបតិស្សៈ និងកោលិតៈ ទៅចូលទឹងព្រះសម្ពុទ្ធ ក៏កើតសេចក្ដីទោមនស្សវិប្បដិសារី ក្ដៅក្រហាយ រហូតដល់ក្អួតឈាមចេញពីមាត់ ។

## ការសូមផ្ដិស

នៅក្រុងរាជគ្រឹះ ប្រជាជនទាំងឡាយនោះ មិនទាន់បានឃើញព្រះសាស្ដាក្ដី បានឃើញហើយក្ដី សុទ្ធតែមានសេចក្ដីប្រាថ្នាចង់ឃើញព្រះសាស្ដាមិនចេះឆ្អែត ក៏ប្រជ្រៀតគ្នាចូលទៅលដ្ឋិវនុទ្យាន ជាទីដែលព្រះអង្គគង់នៅ ។ ឧទ្យានគ្មានកន្លែងសល់ទំនេរ ពាសពេញដេរដាសសព្វទីទាំងអស់ ដោយប្រជាជនទិករ ។

ក្រោយពីទទួលនិមន្តនៃព្រះបាទពិម្ពិសារ ព្រះបរមសាស្ដាស្ដេចយាងចូលព្រះរាជនិវេសន៍ មួយអន្លើដោយព្រះភិក្ខុសង្ឃ ។ ព្រះរាជាទ្រង់អង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារ ទើបទ្រង់ព្រះចិន្ដាថា "វេឡុវនឧទ្យាន មិនឆ្ងាយពេក មិនជិតពេក ល្មមទៅមកបានដោយងាយ គួរតែអាត្មាអញថ្វាយឧទ្យាននេះដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន" ហើយទ្រង់ក្រាបបង្គំទូលព្រះមានព្រះភាគថា "ខ្ញុំព្រះអង្គសូមថ្វាយនូវឧទ្យានវេឡុវ័ននេះចំពោះព្រះអង្គ

និងព្រះសង្ឃ" ។ ព្រះសាស្តា ទ្រង់ទទួលគង់នៅក្នុងឧទ្យានវេឡុវ័ននោះ ហើយទ្រង់អនុញ្ញាតអាកមដល់ព្រះភិក្ខុសង្ឃតាំងពីពេលនោះមក ។

សម័យថ្ងៃមួយ ព្រះសាស្តាកំពុងគង់លើគេនបល្ល័ង្កក្នុងវត្តវេឡុវ័ន សម្តែងធម៌ទេសនាក្នុងកណ្តាលបរិស័ទតាំង ៤ គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទ្រង់ទតឃើញមាណពតាំងពីរនោះដើរមកអំពីចម្ងាយ ក៏ទ្រង់ត្រាស់ប្រាប់ភិក្ខុតាំងឡាយថា "ម្នាលភិក្ខុតាំងឡាយ ជនពីរនាក់នោះ ឈ្មោះឧបតិស្សៈនិងកោលិតៈ ជាមិត្តនឹងគ្នា ជាគូសាវ័កស្តាំ-ឆ្វេង របស់តថាគត ។

ឧបតិស្សៈ និងកោលិតៈ ចូលមកដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះសាស្តាសូមបព្វជ្ជានិងឧបសម្បទាថា "បពិត្រព្រះមានព្រះភាគ! ខ្ញុំព្រះអង្គតាំងឡាយសូមបព្វជ្ជានិងឧបសម្បទា ក្នុងសម្នាក់ព្រះអង្គ" ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុតាំងឡាយ ចូរអ្នកតាំងឡាយមកចុះ! ធម៌ដែលតថាគតសម្តែងហើយដោយប្រពៃ, អ្នកតាំងឡាយ ចូរប្រព្រឹត្តព្រហ្មចរិយ-ធម៌ ដើម្បីធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខ ដោយប្រពៃចុះ" ។ ព្រះពុទ្ធ-ដីកានេះ ជាឧបសម្បទា របស់ឧបតិស្សៈនិងកោលិតៈ ។

ព្រះសព្វញ្ញុតញ្ញាណ ទ្រង់ប្រទានផ្នួសជាឯហិភិក្ខុឧបសម្បទាហើយ ទើបព្រះអង្គទ្រង់ប្រទាននាមទៀត "ឧបតិស្សៈ ជា សារីបុត្រ, កោលិតៈ ជាមោគ្គល្លាន" វិញ យកតាមនាមមាតារបស់លោក ។

# ការតែងតាំងអគ្គសាវ័ក

ក្រោយពេលដែលព្រះមានព្រះភាគប្រទានផ្នួសដល់ព្រះសារីបុត្រ ព្រះមោគ្គល្លាននិងបរិវារទាំងអស់ ជាឯហិភិក្ខុហើយ ទើបទ្រង់សម្តែងធម៌ទេសនាតម្រូវតាមបុព្វចរិតរបស់បរិស័ទទាំងនោះ ។ ក្នុងចំណោមភិក្ខុទាំងនោះ ពួកភិក្ខុដែលជាបរិវារទាំងប៉ុន្មាន ក៏បានសម្រេចអរហត្តទាំងអស់ ។

ព្រះមោគ្គល្លានមានអាយុ ចូលទៅអាស្រ័យនៅស្រុកកល្លវាឡគ្រាម ក្នុងរដ្ឋមគធៈ, ក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃដែលបួសមក លោកបានស្តាប់នូវធាតុកម្មដ្ឋាន បានសម្រេចនូវប្រជុំបីនៃមគ្គខាងលើ ហើយដល់នូវសាវកបារមីញាណ ជាព្រះអរហន្តមួយអង្គ ។

ព្រះសារីបុត្រ ចូលទៅអាស្រ័យនៅក្នុងគុហាឈ្មោះ សូករខាតៈ បានស្តាប់វេទនាបរិគ្គហសូត្រ ដែលព្រះសាស្តាកំពុងសម្តែង ចំពោះទីឃនខបរិព្វាជកជាក្មួយរបស់លោក ក៏បានសម្រេចនូវសាវកបារមីញាណជាព្រះអរហន្តមួយអង្គក្នុងព្រះពុទ្ធសាសនា ក្នុងរវាង ១៥ ថ្ងៃ រាប់ពីថ្ងៃដែលបួសមក ។

ថ្ងៃដែលព្រះសារីបុត្របានសម្រេចអរហត្ត គឺថ្ងៃ ១៥ កើតខែមាឃ ឆ្នាំរកា ជាថ្ងៃគម្រប់ ៩ ខែគត់ គិតពីថ្ងៃដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ដឹង ។ ក្នុងថ្ងៃនោះ ព្រះបរមសាស្តាទ្រង់ប្រជុំព្រះអរហន្តទាំងឡាយ ធ្វើមហាសន្និបាតក្នុងវត្តវេឡុវ័ន ប្រទាននូវទីអគ្គសាវកដល់ :

- ព្រះសារីបុត្រ ជាអគ្គសាវកស្តាំ,
- ព្រះមោគ្គល្លាន ជាអគ្គសាវកឆ្វេង,

ហើយទ្រង់សម្ដែងគោលព្រះពុទ្ធសាសនាជាលំដាប់លំដោយដរាបមកៗ

ព្រះអគ្គសាវក ទាំងពីរអង្គនេះ បានបួសនិងសម្រេចអរហត្ត ក្រោយព្រះអរហន្ត ១០៩១ អង្គដែលចាស់ ៗ ជាងនោះទេ តែលោកបានឋានន្តរជាអគ្គសាវក ជាតំណែងធំជាងព្រះអរហន្ត ១០៩១ អង្គនោះ ៗ ។ ដោយហេតុនេះ ទើបភិក្ខុទាំងឡាយផ្ដើមសួរសំណាងដែលសាងទុកពីអតីតជាតិចំពោះព្រះសាស្ដាថា! "បពិត្រព្រះមានព្រះភាគដ៏ចម្រើន! ចុះព្រះអគ្គសាវកទាំងពីរអង្គបានធ្វើបុញ្ញកម្មដូចម្ដេច?" ព្រះមានព្រះភាគទ្រង់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ១ អសង្ខេយ្យនិង ១ សែនកប្ប សារីបុត្រកើតក្នុងត្រកូលព្រាហ្មណមហាសាល មានឈ្មោះ សរទមាណព មោគ្គល្លានកើតក្នុងត្រកូលគហបតិមហាសាល មានឈ្មោះសិរីវឌ្ឍកុដុម្ពិក, មាណពទាំងពីរនាក់នេះជាមិត្តនឹងគ្នាតាំងពីតូចៗមក ។ លុះមាតាបិតាធ្វើកាលកិរិយាទៅ, សរទមាណពបានទទួលទ្រព្យសម្បត្តិជាច្រើនដែលជាប្រពៃណីរបស់ត្រកូល ។ មានថ្ងៃមួយ សរទមាណពទៅបបួលសិរីវឌ្ឍកុដុម្ពិកទៅបួស, សិរីវឌ្ឍកុដុម្ពិកមិនព្រម, ទើបសរទមាណពទៅបើកយកទ្រព្យសម្បត្តិទាំងអស់មកបែងចែកជា ៣ ចំណែក, ១ ចំណែកឲ្យភរិយា, ១ ចំណែកឲ្យកូន, ១ ចំណែកយកខ្លួនឯង ។ ចំណែកខ្លួនឯង

បំណាយដាក់ទានទ្រព្យធនក្រៃក្រ ហើយចេញទៅបួសជាតាបសឥសី នៅជិតជើងភ្នំ មានជដិលចូលបួសតាមផង ម្តង ២ នាក់ ម្តង ៣ នាក់ បានចំនួន ៧៤.០០០ នាក់ ។ សរទតាបសបានសម្រេចអភិញ្ញា ៥ សមាបត្តិ ៨ ក៏បង្រៀនកសិណបរិកម្មឲ្យជដិលទាំងនោះសម្រេចផង ។

សម័យនោះ ព្រះសម្មាសម្ពុទ្ធព្រះនាមអនោមទស្សី បានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គនៅទីរបន្ទវតី ។ ថ្ងៃមួយទ្រង់ចេញពីមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលសត្វលោកក៏បានឃើញសរទតាបសព្រមទាំងបរិវារ ទើបទ្រង់យាងទៅតាមអាកាស តែមួយព្រះអង្គឯង យាងចុះត្រង់កន្លែងសរទតាបស ក្នុងពេលដែលសិស្សរបស់សរទតាបសទៅបេះផលានុផលអស់ ។ សរទតាបសឃើញព្រះសម្ពុទ្ធ ស្ទុះចុះពីអាសនៈចូលទៅក្រាបថ្វាយបង្គំ និមន្តព្រះអង្គឲ្យគង់លើអាសនៈដ៏ខ្ពស់ វិចិត្រដោយផ្កាគ្រប់បែប លុះជដិលជាកូនសិស្សត្រឡប់មកវិញ ឃើញអាចារ្យរបស់ខ្លួនអង្គុយទាបជាង ក៏និយាយគ្នាថា "ព្រះសមណៈនេះ ទំនងជាធំជាងលោកអាចារ្យរបស់យើងឬ?" សរទតាបសឮសិស្សនិយាយដូច្នោះក៏ឆ្លើយថា "ម្តេចក៏អ្នកទាំងឡាយប្រៀបធៀបខ្ញុំនឹងព្រះសម្ពុទ្ធយ៉ាងហ្នឹង មិនត្រូវទេ", ជដិលទាំងឡាយ ក៏ក្រាបថ្វាយបង្គំនូវសិរសាពបគ្រប់ៗគ្នា ហើយរើសយកផ្លែឈើយ៉ាងល្អៗ ម្ហូបឆ្ញាញ់ថ្វាយព្រះអង្គ ។ ព្រះសម្ពុទ្ធទ្រង់ព្រះចិន្តាចង់ឲ្យព្រះ

អគ្គសាវ័កទាំងពីរមកជាមួយនឹងព្រះភិក្ខុសង្ឃទាំងឡាយ, ក្នុងនោះព្រះអគ្គ-
សាវ័កទាំងពីរអង្គនិងព្រះភិក្ខុសង្ឃ ១ សែនអង្គយកដល់ផែន ៗ សរទតា-
បសឲ្យកូនសិស្សទាំងឡាយ ទៅរកផ្កាពីដើមឈើមកក្រាលជាអាសនៈ ប្រគេន
ព្រះអង្គ និងព្រះអគ្គសាវ័កព្រមទាំងព្រះភិក្ខុសង្ឃទាំងអស់ ៗ ព្រះពុទ្ធគង់
លើបុប្ផាសនៈហើយព្រះអគ្គសាវ័កទាំងពីរអង្គក៏គង់តាមលំដាប់ ព្រះភិក្ខុសង្ឃ
ទាំងឡាយគង់បន្តតាមវស្សាចាស់-ខ្ចីរៀងៗ មក ៗ សរទតាបសនិងពួក
កូនសិស្ស អង្គាសផលានុផលដល់ព្រះពុទ្ធ និងព្រះអគ្គសាវ័ក ព្រមទាំង
ភិក្ខុសង្ឃទាំងឡាយឆ្អែតស្កប់ស្កល់ ៗ ព្រះសាស្តាទ្រង់អនុមោទនាថា
"សេចក្តីប្រាថ្នាយ៉ាងណា ចូរសម្រេចដូចចិត្តយ៉ាងនោះចុះ" ហើយទើប
ទ្រង់ចូលនិរោធសមាបត្តិ ៗ ព្រះអគ្គសាវ័កនិងព្រះអរហន្តទាំងឡាយ ក៏
ចូលនិរោធសមាបត្តិជាលំដាប់ ១ ត ១ ទៅគ្រប់អង្គ ៗ

កាលព្រះសាស្តាទ្រង់ចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ពួកសិស្ស
សរទតាបស បានទុកកាលត្រឹមតែបេះផ្លែឈើបរិភោគប៉ុណ្ណោះ ហើយក៏ផ្គង
អញ្ជលីចំពោះព្រះសម្ពុទ្ធតែម្យ៉ាង ៗ ឯសរទតាបស មិនបរិភោគអ្វីទេ
នៅចាំផ្គងឆត្រផ្កាឈើថ្វាយព្រះអង្គគ្រប់ ៧ ថ្ងៃ ៗ

លុះព្រះសាស្តាចេញពីនិរោធហើយ ទ្រង់ [illegible] ដើម្បីអនុមោទនាពី
បុប្ផាសនៈ ពួកកូនសិស្សរបស់សរទតាបស [illegible] ព្រះអរហត្ត-

ផល បានបួសជាឯហិភិក្ខុ, នៅសល់តែសរទតាបស មិនបានសម្រេចឡើយ ព្រោះចិត្តលោករវើរវាយ តាំងពីបានឃើញព្រះអគ្គសាវ័កនោះមក, លោកតែងគិតថា ធ្វើម្ដេចអេះ ទើបបានដូចលោកម្ចាស់អង្គនេះ ក្នុងសាសនាព្រះពុទ្ធអង្គណាមួយក្នុងអនាគតកាល ។ សរទតាបសចូលទៅក្រាបថ្វាយបង្គំទូលថា “បពិត្រព្រះមានព្រះភាគដ៏ចម្រើន! ព្រះថេរៈដែលគង់ជិតព្រះអង្គនោះ តើជាអ្វីក្នុងសាសនាព្រះអង្គ ?” ព្រះសាស្ដាត្រាស់ថា “ភិក្ខុនេះជាអគ្គសាវ័កក្នុងសាសនាតថាគត” ។ សរទតាបសតាំងសេចក្ដីប្រាថ្នាថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន! ខ្ញុំព្រះករុណា បានធ្វើគ្រឿងសក្ការៈព្រមតាំងបាំងឆត្រថ្វាយព្រះអង្គអស់ ៧ ថ្ងៃយ៉ាងនេះ មិនប្រាថ្នាជាព្រះឥន្ទ្រ ឬព្រះព្រហ្មទេ សូមប្រាថ្នាជាអគ្គសាវ័កនៃព្រះពុទ្ធ ១ អង្គក្នុងអនាគត ដូចជាព្រះនិសភត្ថេរនេះ” ។ ព្រះសាស្ដាទ្រង់ប្រមើលឃើញថា សេចក្ដីប្រាថ្នានឹងបានសម្រេចពិតប្រាកដមែន ក៏ទ្រង់ត្រាស់ថា “សេចក្ដីប្រាថ្នារបស់អ្នកនឹងបានសម្រេចពិតមែន គឺថាដល់ផុតអំពី ១ អសំខេយ្យ និង ១ សែនកប្បទៅ នឹងមានព្រះពុទ្ធមួយអង្គត្រាស់ដឹងក្នុងលោកព្រះនាមព្រះសមណ-គោតម អ្នកឯងនឹងបានជាអគ្គសាវ័កឈ្មោះសារីបុត្រ ជាធម្មសេនាបតីរបស់ព្រះពុទ្ធនោះឯង” ។

លុះធ្វើពុទ្ធទំនាយហើយ ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ស្ដេចហោះតាមអាកាស ព្រមទាំងភិក្ខុសង្ឃជាបរិវារ ។

ឯសារទតាបស លើកហត្ថប្រណម្យថ្វាយបង្គំព្រះសាស្តានិងព្រះអរហន្តទាំងឡាយ រហូតដល់ផុតវិស័យមើលឃើញ ទើបដើរទៅទីលំនៅសិរីវឌ្ឍកុដុម្ពិក ។ និមន្តឲ្យគង់លើអាសនៈខ្ពស់ហើយសួរថា "លោកម្ចាស់ម៉េចក៏មិនឃើញពួកបរិស័ទជាសិស្សមកជាមួយផង ខ្លាចក្រែងខ្ញុំករុណាធុញទ្រាន់ឬ?" សារទតាបសឆ្លើយថា "មិនមែនទេ, លោកកុំនិយាយយ៉ាងនេះ, សូមលោកជ្រាបថា ព្រះពុទ្ធព្រះនាមអនោមទស្សីស្តេចយាងទៅអាស្រមរបស់យើង សម្តែងធម៌ទេសនា, ជដិលទាំងអស់ ជាបរិវាររបស់យើង បានសម្រេចអរហត្តផល ចូលបួសអស់ហើយ, នៅសល់តែអាត្មា ព្រោះអាត្មាប្រាថ្នានាទីជាអគ្គសាវ័ក, ឯលោកត្រូវប្រាថ្នានាទីជាទុតិយសាវ័កចុះ" ។ សិរីវឌ្ឍកុដុម្ពិក ទូលតបថា "ខ្ញុំព្រះករុណាគិតដូចម្តេច បើមិនដែលស្និទ្ធស្នាលនឹងព្រះពុទ្ធសោះ ។ សារទតាបសថា ការប្រឹក្សានឹងព្រះសម្ពុទ្ធ ស្រេចលើអាត្មា, ឯលោកត្រូវចាត់ចែងគ្រឿងសក្ការៈយ៉ាងថ្លៃថ្លាតែប៉ុណ្ណោះចុះ ។

សិរីវឌ្ឍកុដុម្ពិក ចាត់មនុស្សឲ្យឆាយដីក្បែរផ្ទះចំនួន ៨ ករីសឲ្យរាបស្មើ ហើយឲ្យរោយដីខ្សាច់និងផ្កាមានលាជជាគម្រប់ ៥ សង់រោងមណ្ឌបប្រក់ផ្កានិលុប្បល សម្រាប់ទទួលព្រះពុទ្ធនិងព្រះភិក្ខុសង្ឃ ។ រួចស្រេចក៏ឲ្យសញ្ញាដល់សារទតាបសឲ្យទៅនិមន្តព្រះពុទ្ធ ។ លុះព្រះសម្ពុទ្ធយាងមកដល់ សិរីវឌ្ឍកុដុម្ពិកទៅទទួល ក្រាបព្រះបាទ ហើយនិមន្តព្រះអង្គចូលគង់

មណ្ឌប អង្គាសចង្ហាន់យ៉ាងប្រណីតថ្វាយព្រះពុទ្ធមានព្រះភិក្ខុសង្ឃជាបរិវារ, លុះព្រះពុទ្ធនិងព្រះសង្ឃឆាន់ឆ្អែតស្កប់ស្កល់ហើយ ក៏លើកព្រះព័ស្ត្រមានតម្លៃច្រើនថ្វាយព្រះពុទ្ធនិងព្រះសង្ឃជាបរិវាររួច ទើបចូលទៅក្រាបថ្វាយបង្គំទូលថា “បពិត្រព្រះមានព្រះភាគដ៏ចម្រើន! សូមព្រះអង្គធ្វើនូវសេចក្ដីអនុគ្រោះគ្រប់ ៧ ថ្ងៃ”, ព្រះពុទ្ធទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ សិរីវឌ្ឍកុដុម្ពិកញុំាងមហាទានឲ្យប្រព្រឹត្តទៅតាមទំនងនេះអស់ ៧ ថ្ងៃ ទើបលើកដៃប្រណម្យទូលថា “បពិត្រព្រះមានព្រះភាគដ៏ចម្រើន សរទតាបសជាមិត្តខ្ញុំព្រះករុណានឹងបានជាព្រះអគ្គសាវកនៃព្រះពុទ្ធណា ខ្ញុំព្រះករុណាក៏សូមប្រាថ្នាជាទុតិយសាវកនៃព្រះពុទ្ធនោះដែរ” ។ ព្រះសាស្ដាក៏ទ្រង់ប្រមើលទៅអនាគតឃើញច្បាស់ថានឹងបានសម្រេចពិត ទើបទ្រង់ត្រាស់ថា “អ្នកឯងកន្លង ១ អសំខេយ្យនិង ១ សែនកប្បទៅ នឹងបានជាទុតិយសាវកនៃព្រះពុទ្ធគោតមដែរ”, ព្រះសាស្ដាទ្រង់ធ្វើពុទ្ធទំនាយនិងកត្តានុមោទនារួចហើយ ក៏និមន្តត្រឡប់ទៅវត្តវិញ ។

ម្នាលភិក្ខុទាំងឡាយ បុត្តតថាគត បានប្រាថ្នាដូច្នេះក្នុងកាលនោះ ឥឡូវនេះ បានសម្រេចដូចសេចក្ដីប្រាថ្នាមែន, តថាគត មិនមែនឲ្យបាននូវដោយយល់មុខទេ ។

## អគ្គសាវកបព្វជ្ជា

[illegible]

រទ្ធិឫស្សសាយផ្សាយទូទៅក្នុងលោកថា ជាអ្នកមានប្រាជ្ញាក្លៀវក្លាក្រៃ-លែងជាងសាវ័កទាំងអស់ អាចសំដែងធម៌ទេសនា ប្រហែលព្រះសាស្ដា បានទើបព្រះសាស្ដាទ្រង់សរសើរតាំងលោកក្នុងឋានៈជាឯតទគ្គៈកំពូលនៃភិក្ខុទាំងឡាយមានប្រាជ្ញា ។ ព្រះសាស្ដាទ្រង់ប្រៀបព្រះសារីបុត្រទុកដូចជាមាតាដែលបង្កើតកូន អាចណែនាំកុលបុត្រឲ្យឋិតនៅក្នុងសោតាបត្តិ-ផលជាដើម ។ ក្នុងគម្ពីរទាំងឡាយ បើលើកយកភាសិតរបស់ព្រះពុទ្ធចេញ ភាសិតរបស់ព្រះសារីបុត្រ ច្រើនជាងសាវ័កទាំងអស់មានសម្មាទិដ្ឋិសូត្រជាដើម ។

ព្រះសារីបុត្រ ជាអ្នកមានកតញ្ញូកតវេទិតាធម៌ ជាងសាវ័កទាំងអស់ សូម្បីគេធ្វើបានទឹងលោកត្រឹមតែបាយមួយវែក ក៏មិនភ្លេចដែរ ។ លោកមានព្រះជន្មាយុរហូតមកដល់បច្ឆិមពោធិកាល ក្នុងវស្សាទី ៤៥ ។

លុះដល់សម័យជិតបរិនិព្វាន លោកមានបំណងទឹងប្រោសមាតាទើបចូលទៅក្រាបបង្គំទូលលាព្រះមានព្រះភាគ ហើយនាំព្រះចុន្ទត្ថេរព្រមទាំងភិក្ខុជាបរិវារទៅស្រុកឧបតិស្សៈជាស្រុកកំណើតរបស់លោក ។ ក្នុងពេលយប់នោះ បក្ខន្ទិកាពាធ ក៏បណ្ដាលកើតឡើងដល់លោកៗ ចំប្រឹងទេសនាប្រោសមាតា លុះត្រាតែមាតាបានសម្រេចសោតាបត្តិផល ។ ក្នុងបច្ចូស-សម័យ ថ្ងៃពេញបូណ៌មី ខែកត្តិក ឆ្នាំ ម្សាញ់បញ្ចស័ក លោកចូលកាន់ព្រះនិព្វាន ។ ព្រះចុន្ទត្ថេរ លោកចាត់ចែងធ្វើឈាបនកិច្ចព្រះសពហើយ

លោករើសយកព្រះអដ្ឋិធាតុនាំទៅថ្វាយព្រះបរមសាស្តា, ព្រះអង្គត្រាស់ឲ្យធ្វើព្រះស្តូបបញ្ចុះព្រះអដ្ឋិធាតុ ទុកជាទីសក្ការៈបូជា នៃមហាជនក្នុងវត្តជេតពន ក្បែរក្រុងសាវត្ថី នៃប្រទេសកោសល ។

ព្រះអគ្គសាវ័កទី២ ឬអគ្គសាវ័កឆ្វេង ព្រះនាមព្រះមហាមោគ្គល្លាន លោកមានកិត្តិស័ព្ទល្បីល្បាញខ្ទរខ្ទារសុសសាយ ផ្សាយទូទៅក្នុងលោកថា ជាអ្នកមានឥទ្ធិឫទ្ធិខ្លាំងពូកែជាងសាវ័កទាំងអស់ អាចនឹងធ្វើបាដិហារ្យប្រហែលព្រះបរមសាស្តាបាន. ព្រះសាស្តាទ្រង់សរសើរថាជាអ្នកមានឧប-ការៈ ដល់ពួកភិក្ខុដែលទើបនឹងឧបសម្បទថ្មីៗ ហើយទ្រង់តែងតាំងក្នុងឋានៈជាឯតទគ្គៈកំពូលនៃភិក្ខុទាំងឡាយដែលមានឫទ្ធិ ។ ធម្មទេសនារបស់ព្រះមហាមោគ្គល្លាន មិនសូវមានសម្បូណ៌ក្នុងគម្ពីរទាំងឡាយទេ ឃើញមានតែក្នុងអនុមានសូត្រដែលព្រះធម្មសង្គាហកាចារ្យ បានរួបរួមក្នុងគម្ពីរមជ្ឈិមនិកាយ ។

ព្រះមហាមោគ្គល្លានមុនដែលនឹងបរិនិព្វាន លោកនិមន្តទៅគង់នៅតំបន់កាឡសិលាក្នុងរដ្ឋមគធៈ ។ ពេលនោះ ពួកតិរ្ថិយប្រឹក្សាគ្នាថា "ព្រះមហាមោគ្គល្លាន ជាកម្លាំងធំណាស់របស់ព្រះមហាសមណគោតម អាចទៅបានសួគ៌បាននរក នាំដំណឹងផ្សេងៗ មកសម្តែងប្រាប់មនុស្សលោក បើពួកយើងសម្លាប់ព្រះមហាមោគ្គល្លានឲ្យវិនាសចេញបានហើយ លទ្ធិខាងពួកយើង មុខជានឹងចម្រើនរុងរឿងឡើង", លុះមូលមតិគ្នា ក៏ទៅជួល

ពួកចោរឲ្យលបសម្លាប់ព្រះអគ្គ ។ ពួកចោរទាំងនោះនាំគ្នាទៅសម្លាប់អស់វារៈពីរលើក, លោកគេចផុតទាំងពីរលើក, ដល់លើកទីបី លោកបានពិចារណា ឃើញកម្មពីអតីតតាមទាន់ ទើបមិនគេចដូចមុន ។ ពួកចោរចូលចោមចាប់គាប់សម្លាប់ចិញ្ច្រាំគ្រាំតែខ្ទេចល្អិត លើកយកព្រះសរីរៈបោះទៅក្នុងគុម្ពោតព្រៃមួយ ហើយគេចរត់បាត់ទៅ ។ ព្រះមហាថេរមិនទាន់សុគតទេ លោកផ្គុំអត្តភាព ដោយកម្លាំងឈាន បានរឹងប៉ឹងឡើងវិញហើយ ក៏ហោះទៅតាមអាកាស ចូលទៅគាល់ព្រះសាស្តា ក្រាបទូលសូមលាបរិនិព្វាន ។ មុននឹងចូលបរិនិព្វាន លោកសម្តែងធម៌ សម្តែងឫទ្ធិផ្សេងៗ ថ្វាយព្រះសាស្តា ហើយវិលទៅបរិនិព្វានក្នុងកាឡសិលាវិញ ក្នុងថ្ងៃ ១៥ កេច ខែកត្តិក ឆ្នាំម្យាញ់បញ្ចស័ក ក្រោយព្រះសារីបុត្តបរិនិព្វាន ១៥ ថ្ងៃ និងមុនព្រះសម្ពុទ្ធយាងចូលបរិនិព្វាន ៦ ខែ ១៥ ថ្ងៃ ។

ព្រះបរមសាស្តា ស្តេចយាងទៅធ្វើឈាបនកិច្ចសព រួចហើយទ្រង់ត្រាស់បង្គាប់ឲ្យរើសយកព្រះអដ្ឋិធាតុ មកដាក់ក្នុងព្រះស្តូបទុកទៀបស៊ុមទ្វារនៃវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ នៃដែនមគធៈ ។

ចប់ អគ្គសាវកដីវប្បវត្តិ ដោយសង្ខេប ។

# កម្លាំងនៃស្ត្រី

ពលំ ចន្ទោ ពលំ សុរិយោ ពលំ សមណព្រាហ្មណា
ពលំ វេលា សមុទ្ទស្ស ពលាតិពលមិត្ថិយោ ។

ប. ប.

កម្លាំងព្រះចន្ទ, កម្លាំងព្រះអាទិត្យ, កម្លាំងសមណព្រាហ្មណ៍ និង កម្លាំងប្រាំងសមុទ្រ, ទាំង ៤ យ៉ាងនេះ មិនឈ្នះកម្លាំងនៃស្ត្រីទេ ព្រោះ ស្ត្រីមានកម្លាំងខ្លាំងក្លាក្រៃលែងជាងកម្លាំងទាំង ៤ យ៉ាងខាងដើមនោះ ។

អត្ថាធិប្បាយ : កម្លាំងស្ត្រីនោះ មិនមែនសំដៅយកកម្លាំងកាយទេ គឺសំដៅយកកម្លាំងចិត្ត ។ ឯចិត្តស្ត្រីមុតជាងចិត្តបុរស ហ៊ានសម្លាប់ខ្លួនឯងឬអ្នកដទៃងាយៗ សូម្បីតែប្ដីជាទីស្រឡាញ់ក៏អាចសម្លាប់បានដែរ ក្នុងខណៈចិត្តកំពុងក្រោធ ។ បើនិយាយពីចង់បានវត្ថុអ្វីៗវិញ ចិត្តស្ត្រីចង់បានជាងបុរស ។ ហេតុនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា បើអ្នកណាសម្លាប់មាតាបិតាស្លាប់ អ្នកនោះនឹងបានជាព្រះអរហន្ត ។ មាតានេះ ព្រះអង្គទ្រង់សំដៅយកតណ្ហា, បិតាសំដៅយកអស្មិមានះ ។ មិនមែនព្រះអង្គឲ្យសម្លាប់ម៉ែឪបង្កើតកូននោះទេ ។

ម្យ៉ាងទៀតក្នុងគម្ពីរសារសង្គ្រោះ ព្រះទន្តាចារ្យ អធិប្បាយពីចិត្តស្ត្រីជា ២ពេល គឺតាំងពីព្រឹកព្រហាមទៅដល់ថ្ងៃត្រង់ ចិត្តស្ត្រីច្រើនរឹង រញ៉ាំរញ៉ូវដោយមានកង្វល់នឹងចាត់ចែងអាហារភោជន ។ តាំងពីថ្ងៃជ្រេ

ទៅរហូតដល់អរុណរះចុះទៀត ចិត្តស្ត្រីច្រើន តែតោរទន់ទៅរកកាមពក ឬកាមគុណ បើបុរសចូលទៅនិយាយការគួរ មានខ្ញុំប្រាក់ជាដើម ក៏បានយ៉ាងឆាយ ៗ បើបុរសទៅនិយាយការគួរពេលព្រឹក មិនសូវបានការទេ ព្រោះចិត្តស្ត្រីច្រើនតែមួយបើគៅក្រហាយ ៗ

## សេចក្តីប្រាថ្នានៃស្ត្រី

យថា នទី ច បន្ថោ ច បានាគារំ សភា បបា

ឯវំ លោកិត្ថិយោ នាម វេលា តាសំ ន វិជ្ជតិ ។ ជា ។

សេចក្តីប្រាថ្នាកាមគុណរបស់ពួកស្ត្រីនៅអាះលោកិយនេះ គ្មានទីបំផុតទេ មិនចេះឆ្អែតឆ្អន់សោះឡើយ ៗ បើបានវត្ថុនេះហើយ ចង់បានវត្ថុនោះទៀត ដូចជាបានខ្សែដៃហើយ ចង់បានខ្សែ-កទៀតជាដើម ៗ សូម្បីតែរូបកាយបុរស ក៏ចង់បានបុរសមិនអស់ចិត្តដែរ ៗ ចិត្តស្ត្រីប្រៀបដូចស្ទឹង ផ្លូវថ្នល់, រោងជាទីផឹកស្រា, ទីប្រជុំ និងកំពង់ទឹក ៗ ទីទាំង ៦ នេះមិនចេះប្រកាន់បានៈមនុស្ស, មិនដែលហាមឃាត់មនុស្សទេ ៗ បើអ្នកណាត្រូវការពេលណា ក៏ចេះតែបានពេលនោះ, ឯកាមពករបស់ស្ត្រី ក៏ដូចជាទីទាំង ៦ នេះឯង ៗ

## សេចក្តីប្រៀបធៀបកាបគុណ

[illegible] កាម(១)ទាំងឡាយ មានសេចក្តីបញ្ញាយ

---

១ [illegible]

រីកាយតិចតួចណាស់ ។ ពហុទុក្ខា មានទុក្ខច្រើនណាស់ ។ ពហុ-បាយាសា មានសេចក្តីចង្អៀតចង្អល់ច្រើន ។ អាទីនវោ ឯត្ថ ភិយ្យោ ទោសក្នុងកាមគុណនុះច្រើនក្រៃលែង ។

១- អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ព្រះមានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយប្រៀបដូចឆ្អឹង ។

២- មំសបេសូបមា កាមា ... កាមទាំងឡាយប្រៀបដូចដុំសាច់ ។

៣- តិណុក្កូបមា កាមា ... កាមទាំងឡាយប្រៀបដូចគប់ភ្លើង ។

៤- អង្គារកាសូបមា កាមា ... កាមទាំងឡាយប្រៀបដូចរណ្តៅរងើកភ្លើង ។

៥- សុបិនកូបមា កាមា ... កាមទាំងឡាយប្រៀបដូចការយល់សប្តិ ។

៦- យាចិតកូបមា កាមា ... កាមទាំងឡាយប្រៀបដូចរបស់ខ្ចីគេ ។

៧- រុក្ខផលូបមា កាមា ... កាមទាំងឡាយប្រៀបដូចផ្លែឈើ ។

៨. អសិសូនូបមា កាមា ... កាមទាំងឡាយប្រៀបដូចកាំបិតនិងជ្រញ់ ។

៩. សត្តិសូលូបមា កាមា ... កាមទាំងឡាយប្រៀបដូចលំពែងនិងដែកស្រួច ។

១០. សប្បសិរូបមា កាមា វុត្តា ភគវតា ព្រះមានព្រះភាគទ្រង់ត្រាស់ថា កាមទាំងឡាយប្រៀបដូចក្បាលអាសិរពិស ។

នត្ថិ កាមា បរំ ទុក្ខំ ។ ជា. ។

ពុំមានទុក្ខណា ធ្ងន់ក្រៃលែងជាងកាមគុណទេ ។

នត្ថិ សន្តិបរំ សុខំ ។ ខុ. ធ. ។

ពុំមានសុខណា វិសេសវិសាលប្រសើរជាងសេចក្ដីស្ងប់ទេ ។

កាយប្បស្សទ្ធិ ស្ងប់កាយ ១ ចិត្តប្បស្សទ្ធិ ស្ងប់ចិត្ត ១ ។

១-៦-៦៩

ប៊ូ-ប៊ូ

៣៦១ មហាវិថីព្រះមុនីវង្ស ក្រុងភ្នំពេញ

ផ្នែកអក្សរសាស្ត្រ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ង៉ាង-ទាត់ រៀបរៀង*

អភិរភិ ធាតុ រុប ។ –រព្ធ គុ. ដែលរុប ដែលឆប ដែលចាប់

អភិរមិ ធាតុ ត្រេកអរ រីករាយ ៗ –រត គុ. ដែលរីករាយ ។

អភិរុចិមាលី ស្រី. ដោយប្រាសសែងព្រះអាទិត្យ ។

អភិរាជិ ធាតុ ភ្លឺ ព្រោងព្រាយ ។

អភិរាធិ ធាតុ ពេញចិត្ត ។ រាទ្ធ គុ. ដែលពេញចិត្ត ដែល

ចំរុងចំរើន ។

អភិរាធន នបុ. អភិរាធន៍ កិរិយាពេញចិត្ត ។

អភិរាម គុ. ដែលរីករាយ ដែលស្រឡាញ់ ល្អ ។ បុំ កិរិយារីករាយ ។

រាមតា ស្ត្រី. ភាវនៃ... គួរស្នេហា ស្នេហ៍ លំអ ។

អភិរុទិ ធាតុ [illegible] ។

អភិរុ [illegible]

ឧបុំ- សំឡេង ចម្រៀង ។

អភិរុចិ ធាតុ រុងរឿង ភ្លឺព្រោងព្រាត រីករាយ ។ —រុចិត

គុ ដែលរីករាយ ដែលសប្បាយ បុំ. សាហាយ ។

តាមព្រះរាជា ។

អភិរុចិ ស្ត្រី កិរិយារីករាយ កិរិយាពេញចិត្ត ។

អភិរុចិរ គុ. ដែលភ្លឺផ្លុះ ។

អភិរុទិត គុ. ដែលនិយាយបណ្តើរ យំបណ្តើរ ។

អភិរុជ ធាតុ វែក ញែក ។ រំខាន ។

អភិរបិត គុ. ដែលខ្ញាញ់ក្រៃលែង ដែលទឹងក្រទេក ។

អភិរុហ ធាតុ ឡើងលើ ។

អភិរូប គុ អភិរូប ល្អ ។ ដែលត្រូវគាប់ ។ ដែលបេះដឹង

ដែលស្រឡាញ់ ។ —រូបតា ស្ត្រី. ភាវនៃកិរិយា

បេះដឹង ។ —រូបវន្ត គុ. ដែលមានលំអ ។

អភិលក្ខ្យ គុ. ដែលគប្បីចំណាំបាន ។

អភិលក្ខិត គុ. ដែលដាក់ពាក់ ដែលពិសោធន៍ហើយ ។

អភិលង្ឃ ធាតុ លោតរំលង ។ រំលោបដើរ ។

អភិលង្ឃន នបុំ. កិរិយាលោតរំលង កិរិយារំលោភ ។–លង្ឃិត គុ. ដែលលោតរំលង ដែលរំលោភ ។

អភិលប ធាតុ ថ្លែងចំពោះ ។

អភិលភ ធាតុ កាន់ បាន បានចំណែក ។

អភិលម្ព គុ. ដែលប្រពោង ដែលធ្លាក់ចុះ ។

អភិលស ធាតុ ប៉ង ចង់បាន ។ លសិត គុ ដែលចង់បាន ។ នបុំ. ចំណង់ ប្រាថ្នា ។

អភិលសន នបុំ. កិរិយាចង់បាន ។ លសនីយ ដែលគួរចង់បាន ដែលគួរប្រាថ្នា ។

អភិលាប បុំ. កិរិយាថ្លាថ្លែង ពាក្យ កិរិយាឲ្យដឹង ។

អភិលាស បុំ. កិរិយាចង់បាន កិរិយាលំអៀង ។

អភិលាសក គុ. អ្នកចង់បាន ។ – លាសិន ឬ លាសុក គុ. ដូចគ្នា

អភិលាស្យ ដែលគប្បីលំអៀង ។

អភិលិខ ធាតុ ឆ្លាក់ គូរ សរសេរ វិចិត្រ ។

អភិលិប ធាតុ លាប ។

អភិលី ធាតុ ចង ។ –លីន គុ. ដែលចងភ្ជាប់ ដែលតាំងនៅ ។ ដែលយកជាលំនៅ ។

អភិលុប ធាតុ លួច ។

អភិលុលិត គុ. ដែលរង្គើ ដែលយោកយោក (ដោយខ្យល់) ។

អភិលោក ធាតុ ក្រឡេកមើល ។

អភិវច ធាតុ និយាយ ។

អភិវញ្ចិត គុ. ប្រវញ្ច ដែលបោក ។

អភិវាទ ធាតុ ពោល បង្គំ ។ –វាទន នបុំ. កិរិយាបង្គំនមស្ការ។

(នៅមានត)

# របៀបរៀបចំខាងតុលាការ

សហជីវិន ហ៊ែល សុំផា រៀបរៀង

ដោយយល់ឃើញថា អ្នកអានយើងត្រូវការជ្រាបសព្វគ្រប់ អំពីរបៀបរៀបចំកិច្ចការរដ្ឋ ដើម្បីប្រមូលក្រុងការចេះដឹងទូទៅសម្រាប់ខ្លួននោះ; យើងបានទាក់ទងជាមួយអស់លោកដែលមានចំណេះក្នុងវិស័យនោះ ៗ សុំយកអត្ថបទដែលមានសារៈប្រយោជន៍ យកមកចុះផ្សាយរហូតហែ ពីវិស័យនេះម្ដង នោះម្ដង ក្នុងខ្ទង់វប្បធម៌របស់យើង ។

ដំបូងនេះយើងសូមជូនអត្ថបទស្ដីពី «របៀបរៀបចំខាងតុលាការ» ដូចតទៅ :

លោកអ្នកនានាដែលបានចូលក្នុងសាលាដំបូងនានា នៃព្រះរាជាណាចក្រយើងតែងបានឃើញថា ក្នុងសាលាមួយ ៗ មានសាលជំនុំជម្រះតែមួយ ឬពីរ មានប្រធានមួយឬពីរ គឺចៅហ្វាយម្នាក់ ចៅហ្វាយរងម្នាក់ នៅសាលាខ្លះ មានចៅហ្វាយបន្ទប់ទី ១ ម្នាក់ ចៅហ្វាយបន្ទប់ទី ២ ម្នាក់ មានព្រះរាជអាជ្ញាម្នាក់ហើយនិងព្រះរាជអាជ្ញារងម្នាក់ ឬពីរនាក់ ព្រមទាំងមានក្រឡាបញ្ជី ជាច្រើននៅលាយឡំគ្នា ។ លោកអ្នកក៏តែងនឹកស្មានថា សាលាតុលាការមានសាលាដំបូងជាដើមនេះ មានការរៀបចំមិនខុសគ្នានឹងការរៀបចំខាងក្រសួងរដ្ឋការឯទៀតទេ គឺសាលាមួយ ៗ មានចែកជាផ្នែក ៗ គឺផ្នែកខាងអាជ្ញា ផ្នែកខាងបវេណី និងផ្នែកខាងពាណិជ្ជកម្ម ហើយថាក្នុងសាលាទាំងអស់ សាលាធំដូចជាសាលាវិនិច្ឆ័យត្រួតសាលាឧទ្ធរណ៍ សាលាឧទ្ធរណ៍ត្រួតសាលាដំបូង សាលាដំបូងត្រួតសាលាលហុទោស ៗ ម្យ៉ាងទៀតលោកអ្នកខានតែងនឹកស្មានថា ក្នុងសាលានីមួយ ៗ ដូចជា

សាលាដំបូងជាដើម ចាងហ្វាងត្រួត ចាងហ្វាងរង ឬចាងហ្វាងបន្ទប់ទី ១ ត្រួតចាងហ្វាងបន្ទប់ទី ២ ជាចាងហ្វាងត្រួតព្រះរាជអាជ្ញា ព្រះរាជអាជ្ញាត្រួតសុភាចារបុរស សុភាចារបុរស ត្រួតក្រឡាបញ្ជី ដូចគ្នានឹងក្រុមរាជការឯទៀត ដែលមានអគ្គនាយកត្រួតនាយកផ្នែកនេះ ផ្នែកនោះ នាយកក៏ត្រួតលេខាធិការ ត ៗ ទៅនោះទេ ។

យើងត្រូវដឹងថា ការរៀបចំនៃអង្គការកាន់អំណាចនីតិបញ្ញត្តិ អង្គការកាន់អំណាចនីតិប្រតិបត្តិ និង អង្គការកាន់អំណាចតុលាការ មានទម្រង់ខុសគ្នាទាំងអស់ ។

យើងដឹងហើយថា អង្គការកាន់អំណាចនីតិបញ្ញត្តិមានតែពីរទេ គឺ រដ្ឋសភានិងក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលមានសមាជិកសុទ្ធតែជាអ្នកតំណាង ដែលរាស្ត្រនិងអ្នកប្រកបរបរគ្រប់ជាន់ថ្នាក់បានបោះឆ្នោតឲ្យ ។ អ្នកទាំងនោះគ្មាននៅក្រោមបង្គាប់ក្រសួងណាទេ ទោះបីមានប្រាក់ផ្កាន់ប្រចាំខែក៏ដោយ ។

ប៉ុន្តែកុំភ្លេចថា ដើម្បីសម្រួលការ អង្គការទាំងនេះត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ដែលមានបុគ្គលិក ដោយចំនួនច្រើននៅប្រចាំការ ហើយបុគ្គលិកទាំងនេះ មិនមែនជាតំណាងរាស្ត្រនិងអ្នកប្រកបរបរទេ គឺសុទ្ធតែជាអ្នករាជការនៃក្រសួងមហាផ្ទៃ ដែលជាអង្គការមួយកាន់អំណាចនីតិប្រតិបត្តិ ឯណោះទេ ។

រដ្ឋសភានិងក្រុមប្រឹក្សាព្រះរាជាណាចក្រទាំងពីរនេះ គ្មានអង្គការណាត្រួតអង្គការណាទេ ហើយគ្មានអង្គការណាត្រួតត្រាពីលើឡើយ ។ អ្នកតំណាងរាស្ត្រ និងតំណាងអ្នកប្រកបរបរទាំងឡាយ ក៏មិនមែននៅក្រោមការត្រួតត្រារបស់ក្រសួងណា ឬអ្នកណាទេ លើកលែងតែព្រះមហាក្សត្រ ឬព្រះប្រមុខរដ្ឋតែមួយ ។ ប៉ុន្តែបុគ្គលិកលេខាធិការដ្ឋានអចិន្ត្រៃយ៍ត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់ក្រសួងមហាផ្ទៃ ។

ចំណែកអង្គការផ្សេង ១ ដែលកាន់អំណាចនីតិប្រតិបត្តិវិញ គេមានការរៀបរយតាមធម្មតា គឺអង្គការធំត្រួតអង្គការតូចៗទៅ ពោលគឺអង្គការធំបំផុតមានគណៈរដ្ឋមន្ត្រី ដែលមានលោកនាយករដ្ឋមន្ត្រីជាប្រធាន ឬជានាយកអធិបតី ។ នៅក្នុងការត្រួតត្រានៃគណៈរដ្ឋមន្ត្រីមានសមាគមក្រសួង ដ៏មានឧបនាយករដ្ឋមន្ត្រីមួយៗ ជានាយក ហើយក្នុងការត្រួតត្រានៃសមាគមក្រសួងនេះ មានក្រសួងមួយ ១ ដ៏មានរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជានាយក ។ ក្នុងការត្រួតត្រានៃក្រសួងមួយ ១ មានការិយាល័យដែលមាននាយកការិយាល័យជានាយក ព្រមទាំងមានក្រុមជាច្រើនដ៏មាននាយក្រុមជានាយក ។ បើដេញទៅទៀតឃើញថា ក្នុងការត្រួតត្រានៃក្រុមមួយ ១ មានផ្នែកជាច្រើនដ៏មាននាយផ្នែកជានាយក ។ ឧទាហរណ៍ក្រសួងមហាផ្ទៃមាននៅក្រោមបង្គាប់ខ្លួន ក្រៅពីការិយាល័យនានានៃក្រសួងដោយផ្ទាល់ នូវក្រុមជាច្រើនកាយទៅតាមក្រុងនិងខេត្ត ដែលគេ

ហៅថា សាលាក្រុង និងសាលាខេត្ត ដ៏មានអភិបាលក្រុង និងអភិបាល-ខេត្តជានាយក ៗ សាលាខេត្តត្រួតសាលាស្រុក ដ៏មានអភិបាលស្រុកជានាយក ៗ សាលាស្រុកត្រួតសាលាសង្កាត់ ដ៏មានចៅសង្កាត់ជានាយក ៗលៗ

ក្រសួងឯទៀត ដូចជាក្រសួងកសិកម្ម ត្រូវមាននៅក្រោមការត្រួតត្រារបស់ខ្លួននូវក្រុមកសិកម្ម ក្រុមគង្គាក្ខេបមាញ ក្រុមសុរិយោដី និងក្រុមបសុពេទ្យ ៗ ក្រុមមួយ ៗ មាននាយក្រុមជានាយកត្រូវត្រួតត្រាផ្នែកជាច្រើនទៀត ដែលមាននាយផ្នែកជានាយក ៗ

ឯអ្នកកជការសោក សុទ្ធតែស្ថិតនៅៈក្រោមការត្រួតត្រាតាមលំដាប់ថ្នាក់ គឺតាមផ្នែកតាមក្រុមនិងតាមក្រសួងដែរ ៗ ពោលគឺ រដ្ឋមន្ត្រីត្រួតនាយក្រុម ៗ ត្រួតនាយផ្នែក ៗ តាមលំដាប់ ៗ

ចំណែកឯអគ្គការកាន់អំណាចតុលាការ ពោលគឺសាលាក្តីវិញ គឺដាច់គ្នាស្រឡះ គ្មានសាលាក្តីណា នៅក្រោមបង្គាប់សាលាក្តីណាទេ ហើយសាលាក្តីទាំងអស់ ក៏មិនមែនស្ថិតនៅក្រោមបង្គាប់ក្រសួងយុត្តិធម៌ ឬក្រសួងណាមួយខាងនីតិប្រតិបត្តិទេ ៗ កាលណាសាលាក្តីទាំងនេះជំនុំជម្រះក្តី សាលាក្តីទាំងនេះគ្មានត្រូវស្តាប់បង្គាប់ក្រសួងណា ឬសាលាក្តីណាទេ លើកលែងតែអគ្គការមួយដែលមិនមែនជាសាលាក្តីទេ ហើយដែលគេហៅថា មហាអយ្យការ ឬ អយ្យការប៉ុណ្ណោះ ដែលត្រូវស្តាប់បង្គាប់

ក្រសួងយុត្តិធម៌ ព្រោះជាអង្គការតំណាងសង្គមមនុស្ស ហើយក្រសួងយុត្តិធម៌ ក៏ត្រូវមានភារៈការពារផលប្រយោជន៍សង្គមមនុស្សផង ។

ក្រសួងយុត្តិធម៌ ត្រូវចាត់ចែងឲ្យមានក្រុមអយ្យការ (Ministrèes publics) ពោលគឺមហាអយ្យការ (Parquet général) មួយ ៗ នៅជិតសាលាក្ដីធំ ៗ ហៅថាសាលាជាន់ខ្ពស់ ហើយនិងឲ្យមានអយ្យការ (Parquet) មួយៗ នៅជិតសាលាតូចៗ ហៅថា សាលាជាន់ទាប ។ នៅមហាអយ្យការមួយ ៗ មានអគ្គព្រះរាជអាជ្ញា (Procureur général du roi) ជានាយកព្រមទាំងមាន អគ្គព្រះរាជអាជ្ញារង (Avocats généraux) និងក្រឡាបញ្ជី ឬសមុហបញ្ជីនៅក្រោមបង្គាប់ខ្លួន ។ នៅអយ្យការមានព្រះរាជអាជ្ញា (Procureur du Roi) ជានាយកដែលមាន ព្រះរាជអាជ្ញារង (Substituts) និងក្រឡាបញ្ជី ឬសមុហបញ្ជី (Greffiers ou Commis-greffiers) នៅក្រោមបង្គាប់ ។

សាលាក្ដីមួយ ៗ ត្រូវមានបុគ្គលិកពិសេសប្រចាំសាលា ហើយដែលបំពេញសមាសភាពនៃសាលានោះផង ។

បុគ្គលិកទាំងអស់ នៃសាលាក្ដី មិនមែនដូចនៅក្នុងអង្គការកាន់អំណាចនីតិបញ្ញត្តិ ដែលគ្មានត្រូវនៅក្រោមបង្គាប់អង្គការណា ឬជនណានោះទេ ផ្ទុយទៅវិញ ត្រូវស្ថិតនៅក្រោមបង្គាប់ក្រសួងយុត្តិធម៌ទាំងអស់ ព្រោះគេទុកជាអ្នករាជការដែរ ដែលត្រូវតែមានក្រមចំណុះពិសេស

ផ្សេងគ្នា អំពីក្រុមខ័ណ្ឌនៃអ្នករាជការឯទៀត ។ ប៉ុន្តែបុគ្គលិកនៃសាលាក្តី ត្រូវមានឯករាជ្យចិត្តក្នុងការជំនុំជំរះក្តីដោយ អ្នករាជការទាំងនេះ ត្រូវស្តាប់បង្គាប់ក្រសួងយុត្តិធម៌ជាដរាប ព្រោះក្រសួងយុត្តិធម៌មានភារៈមើលខុសត្រូវក្នុងការប្រព្រឹត្តទៅនៃសាលាក្តីទាំងអស់ ។ បើនិយាយឲ្យល្អិតទៅទៀតទៅ អ្នករាជការខាងតុលាការ ពោលគឺបុគ្គលិកនៃសាលាក្តីទាំងឡាយ មានពីរពួក គឺពួកក្រឡាបញ្ជី ឬសមុហបញ្ជី និងពួកចៅក្រម ។ ពួកក្រឡាបញ្ជី ឬសមុហបញ្ជីដែលជាអ្នករាជការបានៈតាប ត្រូវស្ថិតនៅក្រោមបង្គាប់ផ្ទាល់ នៃក្រសួងយុត្តិធម៌ ប៉ុន្តែពួកចៅក្រមវិញ មិនមែននៅក្រោមបង្គាប់ផ្ទាល់នៃក្រសួងយុត្តិធម៌ ។ កាលណាគេកាត់សេចក្តី គេត្រូវស្តាប់បង្គាប់តែសតិសម្បជញ្ញៈរបស់គេទេ ។ កាលណាគេដល់ពេលឡើងថ្នាក់ គឺមានគណៈកម្មការមួយដែលស្ថិតនៅក្រោមអធិបតីភាព នៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវជំនុំជម្រះគ្នាសម្រេចឲ្យឡើង ឬ មិនឲ្យឡើង ។ ម្យ៉ាងទៀតកាលណាមានរឿង ឬ ហេតុការណ៍ យ៉ាងណាដែលត្រូវផ្លាស់ប្តូរ ឬធ្វើទោសចំពោះចៅក្រមត្រូវមានអង្គការធំមួយប្រជុំកាត់តែងផ្លាស់ប្តូរ ឬ ដាក់ទោសតាមគួរនូវការណ៍ ។ អង្គការនេះ ដែលហៅថា ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ត្រូវស្ថិតនៅក្រោមព្រះអធិបតីភាព នៃព្រះមហាក្សត្រ ឬព្រះប្រមុខរដ្ឋ ឬបើព្រះអង្គទ្រង់មានធុរៈ មិនអាចមកប្រជុំបាន ការប្រជុំនោះក៏ត្រូវស្ថិតនៅក្រោមអធិបតីភាព នៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាអនុ-

ប្រធាននៃក្រុមប្រឹក្សាជាន់ខ្ពស់នេះ ។ ឯសមាជិកត្រូវមានអ្នកតំណាងនៃព្រះបរមរាជវាំងខ្លះ, តំណាងនៃរដ្ឋសភាខ្លះ និងតំណាងនៃចៅក្រមខ្លះ ។

សរុបទៅ ចៅក្រមមិនមែនស្ថិតនៅក្រោមការត្រួតត្រានៃក្រសួងយុត្តិធម៌ទេ ប៉ុន្តែនាយកក្រសួងនេះ អាចដឹកនាំគណៈកម្មការនិងក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ដើម្បីឲ្យចៅក្រមណាឡើងថ្នាក់ ចៅក្រមណាផ្លាស់ប្តូរទៅខាងណា ឬត្រូវទទួលទោសក្តីដែរ ។ ហេតុនេះហើយចៅក្រមនៅតែគ្មានសេរីភាពក្នុងការជំនុំជម្រះជាដដែល ។

សាលាក្តីទាំងឡាយ ដែលមិនមែនស្ថិតនៅក្រោមការត្រួតត្រា នៃក្រសួងណា ឬសាលាក្តីណាទេនោះ ត្រូវចែកជាពួក ហើយក្នុងមួយពួក ៗ ត្រូវចែកទៅតាមវិស័យ ហើយក្នុងវិស័យនីមួយ ៗ ត្រូវចែកទៅតាមឋានៈទៀត ។

សាលាក្តីទាំងអស់ក្នុងព្រះរាជអាណាចក្រត្រូវមានពីរពួក គឺពួកសាលាក្តីធម្មតា និងពួកសាលាក្តីពិសេស ។ ពួកសាលាក្តីធម្មតាត្រូវមានសាលាក្តីខាងអាជ្ញានិងសាលាក្តីខាងរដ្ឋបវេណី ។ ឯពួកសាលាក្តីពិសេសមាន៖

១- សាលាក្តីពាណិជ្ជកម្ម,

២- សាលាក្តីតុលាការសឹក,

៣- សាលាក្តីក្រុមរាជរដ្ឋបាល,

៤ សាលាក្តីតុលាការកស្ត្រ ។

អំពីសាលាក្តីខាងអាជ្ញា (Des juridictions pénales ou répressives)

សាលាក្តីខាងអាជ្ញា គឺសាលាក្តីដែលជំនុំជម្រះដាក់ទោសចំពោះជនដែលប្រព្រឹត្តអំពើបណ្តាលឲ្យខូចការរៀបរយសាធារណៈ ពោលគឺប្រព្រឹត្តអំពើទាំងឡាយ ដែលត្រូវមានទោសដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌ ។ សាលាក្តីទាំងនេះប្រព្រឹត្តទៅតាមបញ្ញត្តិ នៃក្រមនីតិព្រហ្មទណ្ឌ ។

សាលាក្តីខាងអាជ្ញាមានថែកទៅតាមជាន់ទាបនិងជាន់ខ្ពស់ ។

## សាលាក្តីជាន់ទាប គឺ:

១. សាលាលហុ,

២. សាលាលហុមានសមត្ថកិច្ចធំទូលាយ,

៣. សាលាស៊ើបសួរ,

៤ សាលាដំបូង ។

## សាលាក្តីជាន់ខ្ពស់ គឺ:

១. សាលាឧក្រិដ្ឋ,

២. សាលាក្រមហោច,

៣. សាលាវិនិច្ឆ័យាធិបតី ឬ សាលាវិនិច្ឆ័យ ។

សាលាលហុ (Tribunal de simple police).—សាលាក្តីជាន់ទាប សម្រាប់ជំនុំជម្រះដាក់ទោស ជនដែលបានប្រព្រឹត្តបទលហុ គឺបទ

ត្រូវមានទោសស្រាល ៗ គឺដាក់គុកយ៉ាងតិច ១ ថ្ងៃយ៉ាងច្រើន ៥ ថ្ងៃ ឬពិន័យពី ១៥០ រៀលទៅ ១.២០០ រៀល ។

បើមិនសុខចិត្តនឹងសាលាលហុទេ មានករណីខ្លះទៅតវ៉ាឯណាទៀតមិនកើតឡើយ, មានករណីខ្លះ អាចទៅតវ៉ាចំពោះសាលាដំបូង ។

សមាសភាពនៃសាលាលហុ គឺមានចៅក្រមម្នាក់ជាប្រធាន ហើយនិងក្រឡាបញ្ជី ឬសមុហបញ្ជីម្នាក់ជាលេខាធិការ ។

សាលាលហុមានសមត្ថកិច្ចទូលាយ (Sala Lohuc à compétence, étendue) មានការៈតាំងខាងអាជ្ញា តាំងខាងបវេណី ។ ខាងអាជ្ញាគ្មានអ្វីប្លែកទេ គឺដូចជាសាលាលហុធម្មតាដែរ ប៉ុន្តែខាងបវេណីអាចមានសមត្ថកិច្ច ដូចសាលាដំបូងដែរ ។

បើមិនសុខចិត្តនឹងផ្នែកអាជ្ញា ត្រូវទៅប្តឹងតវ៉ានៅសាលាដំបូង ។ បើមិនសុខចិត្តនឹងផ្នែកបវេណី ត្រូវទៅតវ៉ាចំពោះ សាលាឧទ្ធរណ៍ កងករណីដែលគេបានជំនុំជម្រះ បើកផ្លូវឧទ្ធរណ៍ ។ បើគេបានជំនុំជម្រះ បិទផ្លូវឧទ្ធរណ៍គ្មានផ្លូវទៅតវ៉ាដល់ណាទេ ។

សមាសភាពមានដូចគ្នានឹងសាលាលហុធម្មតា ។

សាលាស៊ើបសួរ (Juridiction d'Instruction) គឺសាលាក្តីដែលមានការៈទទួលស៊ើបសួរចំពោះរឿងឧក្រិដ្ឋទាំងឡាយ ព្រមទាំងរឿងមជ្ឈិម

ដែលមានកស្តុតាងមិនជាក់ច្បាស់ ។ សាលានេះអាចសម្រេចត្រូវឲ្យអ្នកត្រូវទោទនៅក្រៅឃុំ ឬនៅក្នុងការឃុំឃាំង ហើយនៅពេលដែលស៊ើបសួរមួលហើយ អាចសម្រេចលើកលែងទោទប្រកាន់, បញ្ជូនរឿងនិងអ្នកត្រូវទោទទៅសាលាឧក្រិដ្ឋ, សាល.មជ្ឈិមឬសាលាលហុ ។

បើភាគីណាមិនសុខចិត្តនឹងសេចក្តីសម្រេច របស់សាលាស៊ើបសួរទេ ត្រូវប្តឹងតវ៉ាចំពោះសាលាក្រុមទោទ ។

សមាសភាពសាលានេះ ត្រូវមានចៅក្រមម្នាក់ហៅថា ចៅក្រមស៊ើបសួរ ឬ សុភាចារបុរសជាប្រធាន, មានពស្ត្រពីរនាក់ ហៅថា ទីប្រឹក្សាតុលាការជាសមាជិក ព្រមទាំងក្រឡាបញ្ជី ឬ សមុហបញ្ជីម្នាក់ជាលេខាធិការ ។ សាលាស៊ើបនេះតែងមានចំនួន តិចច្រើនទៅតាមរឿងដែលអយ្យការអមសាលាដំបូងបានទទួល ហើយសាលានេះត្រូវតាំងនៅអមជិតសាលាដំបូង ដូចជាក្រុមអយ្យការដែរ ដើម្បីបានស្រួលទាក់ទងគ្នា ។

សាលាដំបូង ឬ សាលាមជ្ឈិម (Tribunal de 1ère instance ou police correctionnelle) ជាសាលាក្តីជាន់ទាប ដែលមានភារៈជំនុំជម្រះបណ្តឹងឧទ្ធរណ៍នៃរឿងដែលគេមិនសុខចិត្ត នឹងសាលាលហុ ឬសាលាលហុគានសមត្ថកិច្ចជំនុំជម្រះយផង ជំនុំជម្រះដាក់ទោសជនដែលបានប្រព្រឹត្តបទល្មើសមជ្ឈិម គឺកំហុសដែលត្រូវមានទោសជាមធ្យមគឺ៖

ក) បទមជ្ឈិមថ្នាក់ទី ១ ដាក់គុកយ៉ាងតិច ៨ ថ្ងៃ, យ៉ាងច្រើន ១ ខែ ឬ ពិន័យពី ១.២០១ រៀល ទៅ ២.៥០០ រៀល ។

ខ) បទមជ្ឈិមទី ២ ដាក់គុកយ៉ាងតិច ១ ខែ យ៉ាងច្រើន ១ ឆ្នាំ ពិន័យ ២.៥០១ រៀលទៅ ៤.០០០ រៀល ។

គ) បទមជ្ឈិមទី ៣ ដាក់គុកយ៉ាងតិច ១ ឆ្នាំ យ៉ាងច្រើន ៥ ឆ្នាំ ឬ ពិន័យពី ៤.០០១ រៀលទៅ ៤០.០០០ រៀល ។

បើមិនសុខចិត្តនឹងសាលាដំបូងទេ គ្មានផ្លូវឧទ្ធរណ៍ទៅណាទេ, មានតែផ្លូវសាទុក្ខទៅសាលាវិនិច្ឆ័យប៉ុណ្ណោះ ។

សមាសភាពនៃសាលាដំបូង ឬ សាលាមជ្ឈិមត្រូវមានចៅក្រមម្នាក់ជាប្រធាន, កស្ត្រ ឬ ទីប្រឹក្សាតុលាការ ៤ នាក់ ជាសមាជិកព្រមទាំងក្រឡាបញ្ជី ឬ សមុហបញ្ជីម្នាក់ ជាលេខាធិការ ។

សម្គាល់: នៅខាងអាជ្ញានេះ គ្មានសាលាឧទ្ធរណ៍ទេ ។ សាលាឧទ្ធរណ៍មានតែនៅខាងបវេណីឯណោះ ។

សាលាឧក្រិដ្ឋ (Cours d'assises) ជាសាលាក្ដីជាន់ខ្ពស់, តាំងនៅជិតសាលាដំបូងខ្លះ ដើម្បីស្រួលទាក់ទងនឹងសាលាស៊ើបសួរ អមសាលាដំបូង ព្រោះសាលាឧក្រិដ្ឋទទួលសំណុំរឿងអំពីសាលាស៊ើបសួរ ។ សាលាឧក្រិដ្ឋនេះ មានភារៈជំនុំជម្រះដាក់ទោសជនដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋពោលគឺទោសធ្ងន់ដែលមាន ៣ ថ្នាក់ :

ក) បទឧក្រិដ្ឋថ្នាក់ទី ១ ឲ្យធ្វើការដោយបង្ខំយ៉ាងតិច ៥ ឆ្នាំ, យ៉ាងច្រើន ២០ ឆ្នាំគ្មានពិន័យទេ ។

ខ) បទឧក្រិដ្ឋថ្នាក់ទី២ ឲ្យធ្វើការដោយបង្ខំអស់ ១ ជីវិត, គ្មានពិន័យទេ ។

គ) បទឧក្រិដ្ឋថ្នាក់ទី ៣ គឺប្រហារជីវិត, គ្មានពិន័យទេ ។ សមាសភាពនៃសាលាឧក្រិដ្ឋត្រូវមានៈចៅក្រមម្នាក់ជាប្រធាន, ចៅក្រម ២ នាក់ជាចៅក្រមប្រឹក្សាសមាជិក, មានរាស្ត្រ ៦ នាក់ ជាទីប្រឹក្សាតុលាការសមាជិក ព្រមទាំងមានក្រឡាបញ្ជីពីរនាក់ជាលេខាធិការ ។

សាលាក្រមចោទ (Cours ou Chambre de mise en accusation) ជាសាលាក្តីជាន់ខ្ពស់ស្ថិតនៅអមជិតសាលាឧទ្ធរណ៍ ព្រោះមានតែមួយក្នុងព្រះរាជាណាចក្រ ។ សាលានេះមានភារៈទទួលជំនុំជម្រះនូវបណ្តឹងតវ៉ាអំពីការតម្កល់រឿងទុកនៃអយ្យការអមសាលាដំបូង, ទទួលបណ្តឹងទាស់ដែលគេមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាស៊ើបសួរ ព្រមទាំងបណ្តឹងតវ៉ាមិនសុខចិត្តនឹងក្រសួងឬក្រុមរាជការ ដែលមិនព្រមដាក់អ្នករាជការមានកំហុសមកឲ្យតុលាការជំនុំជម្រះ ។

សមាសភាពត្រូវមានចៅក្រមម្នាក់ជាប្រធាន ចៅក្រមប្រឹក្សា ២ នាក់ជាសមាជិក, ទីប្រឹក្សាតុលាការ ២ នាក់ ជាសមាជិក ព្រមទាំងក្រឡាបញ្ជី ឬ សមុហបញ្ជីម្នាក់ជាលេខាធិការ ។

សាលាវិនិច្ឆ័យាធិបតី ឬសាលាវិនិច្ឆ័យ (Cour de cassation ou Cour d'Annulation)

ជាសាលាជាន់ខ្ពស់ដែលមានតែមួយ ក្នុងព្រះរាជាណាចក្រ ហើយមានការៈ ទទួលជំនុំជម្រះបណ្ដឹងសាទុក្ខរបស់គាត់ ដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចបិទផ្លូវឧទ្ធរណ៍នៃសាលាលហុ ព្រមទាំងសេចក្ដីសម្រេចរបស់សាលាដំបូង ឬសាលាមជ្ឈិម ។

សមាសភាពនៃសាលានេះត្រូវមានចៅក្រមម្នាក់ជាប្រធាន, ចៅក្រមប្រឹក្សា ៤ នាក់ជាសមាជិកសំរាប់ជំនុំជម្រះពេលធម្មតា, បើជំនុំជម្រះជារួមក្រុមផង ត្រូវមានចៅក្រម ៩ នាក់លាយគ្នាទាំងខាងអាជ្ញា, ទាំងខាងបវេណី, ម្នាក់ជាប្រធាន ៨ នាក់ទៀតជាសមាជិក ព្រមទាំងមានក្រឡាបញ្ជី ឬ សមុហបញ្ជីម្នាក់ជាលេខាធិការ ។

អំពីសាលាក្ដីខាងបវេណី (Les juridictions civiles)

សាលាក្ដីខាងបវេណីមានការៈកាត់សេចក្ដីចំពោះការវិវាទរវាងឯកជននឹងឯកជនដូចគ្នាគ្មានប៉ះពាល់ដល់ប្រយោជន៍សាធារណៈទេ តាមបញ្ញត្តិក្រមបវេណីដូចជាមានការរំលោភសិទ្ធិ ដោយជនម្នាក់ ឬ មួយក្រុម ទៅលើជនម្នាក់ឬក្រុមមួយទៀត ជនឬក្រុមដែលខូចសិទ្ធិ បានមកប្ដឹងសាលាក្ដីឲ្យបង្ខំជនឬក្រុមដែលរំលោភសិទ្ធិនោះឲ្យស្គាល់នឹងគោរពសិទ្ធិខ្លួន ជួសជុលការខូចខាតដែលបានកើតមានអំពីការរំលោភសិទ្ធិនោះ ព្រមទាំងឲ្យសងសោហ៊ុយ [illegible]ចំពោះខ្លួនផង ។

សាលាក្តីខាងបវេណីមាន ចែកទៅតាមជាន់ទាប ជាន់ខ្ពស់ ដូចតទៅនេះ :

ក] សាលាជាន់ទាបមាន ៖

១- សាលាលហុ ឬ សន្តិសាលា,

២- សាលាលហុមានសមត្ថកិច្ចធំទូលាយ,

៣- សាលាដំបូង ។

ខ] សាលាជាន់ខ្ពស់មាន ៖

១- សាលាឧទ្ធរណ៍

២- សាលាវិនិច្ឆ័យាធិបតី ។

សាលាលហុ ( Justice de paix ) ជាសាលាក្តីបវេណី ជាន់ទាបទទួលការៈជំនុំជម្រះរឿងតម្លៃតិច គឺមិនដល់ ៥.០០០ រៀល ។ កាលណាតិចជាង ២.០០០ រៀល សាលាលហុ កាត់សេចក្តីបិទផ្លូវឧទ្ធរណ៍ ពោលគឺមិនអាចប្តឹងតក៏ទៅ សាលាដំបូងបានឡើយ បើមិនសុខចិត្តត្រូវទៅសាលាវិនិច្ឆ័យតែម្តង ។ បើច្រើនជាង ២.០០០ រៀលសាលាលហុ កាត់បើកផ្លូវឧទ្ធរណ៍ គឺអាចប្តឹងៈក៏ទៅសាលាដំបូង ។

សមាសភាពសាលាលហុ មានចៅក្រមម្នាក់ជាប្រធានព្រមទាំងមានក្រឡាបញ្ជី ឬ សមុហបញ្ជីម្នាក់ជាលេខាធិការ ។

សាលាលហុមានសមត្ថកិច្ចធំទូលាយ (Justice de paix à compétence étendue) ជាមួយគ្នានឹងខាងសាលាដែរដូចបានប្រាប់ស្រាប់ហើយ ។

សាលាដំបូង (Tribunal de 1ère instance) ជាសាលាក្តីខាងបរិវេណជាន់ទាប សម្រាប់ជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ដែលភាគីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាលហុជំនុំជម្រះបើកផ្លូវឧទ្ធរណ៍ ហើយនឹងរឿងជាបរិវេណមិនចំពោះតម្លៃ ប៉ុន្មានទេ ។ គឺសាលាដែលភាគីត្រូវចូលមកប្តឹងជាដំបូងបំផុត ក្រៅពីសាលាលហុ និង សាលាលហុមានសមត្ថកិច្ចធំទូលាយ ។ បើរឿងមានតម្លៃមិនដល់ ២០·០០០ រៀលទេ សាលាដំបូងកាត់សេចក្តីបិទផ្លូវឧទ្ធរណ៍ ពោលគឺ ភាគីមិនអាចតវ៉ាទៅសាលាឧទ្ធរណ៍បានទេ បើភាគីមិនសុខចិត្តអាចប្តឹងសាទុកទៅសាលាវិនិច្ឆ័យ បើតម្លៃច្រើនជាងនោះ សាលាដំបូងកាត់សេចក្តីបើកផ្លូវឧទ្ធរណ៍ ។

សមាសភាព នៃសាលាដំបូងមានចៅក្រមម្នាក់ជាប្រធាន, ប្រឹក្សាតុលាការ ៤ នាក់ជាសមាជិក ព្រមទាំងមានក្រឡាបញ្ជី សមុហបញ្ជីម្នាក់ជាលេខាធិការ ។

សាលាឧទ្ធរណ៍ (Cour d' Appel) ជាសាលាក្តីបរិវេណជាន់ខ្ពស់ ទទួលការៈជំនុំជំរះបណ្តឹង ឧទ្ធរណ៍ដែលធ្វើដោយភាគីមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលាដំបូង ។

សមាសភាពនៃសាលាឧទ្ធរណ៍ មានចៅក្រមម្នាក់ជាប្រធាន, ចៅក្រមប្រឹក្សា ២ នាក់ជាសមាជិក, ទីប្រឹក្សាតុលាការ ៤ នាក់ជាសមាជិក ព្រមទាំងមានក្រឡាបញ្ជី ឬ សមុហបញ្ជីម្នាក់ជាលេខាធិការ ។

សាលាវិនិច្ឆ័យហាជបតី ឬសាលាវិនិច្ឆ័យ (Cour de cassation ou d'Annulation) ជាសាលាក្ដីបវេណីជាន់ខ្ពស់បំផុត ទទួលការៈ ជំនុំជម្រះ បណ្ដឹងសាទុក្ខគាតី ដែលមិនសុខចិត្តនឹងសាលាលហុ និង សាលាដំបូងជំនុំជម្រះបទឧទ្ធរណ៍, ព្រមទាំងគាតីដែលមិនសុខចិត្តនឹង សាលាឧទ្ធរណ៍ ។

សមាសភាពនៃសាលាវិនិច្ឆ័យ ខាងបវេណី ក៏ដូចជាខាងអាជ្ញាដែរ ដូចយើងបានពោលរួចមកហើយ ។

## អំពីពួកសាលាក្ដីពិសេស (Des juridictions d'exception)

ពួកសាលាក្ដីពិសេស មានសាលាក្ដីពាណិជ្ជកម្ម, សាលាក្ដីតុលាការសឹក, សាលាក្ដីក្រុមវិវាទរដ្ឋបាល និង តុលាការស្ត្រ ។

សាលាក្ដីពិសេសមួយ ៗ សុទ្ធតែមានការរៀបចំតាមច្បាប់ ឬពិសេស របស់គេ មិនមែនជាមួយគ្នានឹងសាលាក្ដីខាងអាជ្ញា និងខាងបវេណីទេ ។

សាលាក្ដីពាណិជ្ជកម្ម មានសាលាដំបូងពាណិជ្ជកម្មមួយ ជាពិសេស (Tribunal de commerce) ហើយជំនុំជម្រះដោយចៅក្រម ជាពិសេស តែបើគាតីមិនសុខចិត្តនឹងសាលានេះទេ គេអាចប្ដឹងឧទ្ធរណ៍

តក៏មកសាលាឧទ្ធរណ៍ខាងបវេណី ព្រមទាំងប្តឹងសាទុក្ខសាលាវិនិច្ឆ័យខាងបវេណី ។

សាលាក្តីពាណិជ្ជកម្ម មានភារៈជំនុំជម្រះការវិវាទ រវាងពាណិជ្ជនិងពាណិជ្ជ ក្នុងការប្រកបរបរខាងពាណិជ្ជកម្ម ។

សាលាក្តីនៃតុលាការសឹក ( Justice militaire ) មានសាលាដំបូងខាងតុលាការសឹកមួយជាពិសេស ជំនុំជំរះដោយចៅក្រមម្នាក់ជាប្រធាន, សេនាទាហាន ២ នាក់ជាសមាជិក, បុគ្គលិកម្នាក់ជាលេខា-ធិការ ។ តែបើភាគីមិនសុខចិត្តនឹងសាលាក្តីនេះទេ អាចប្តឹងសាទុក្ខ តក៏ទៅសាលាវិនិច្ឆ័យខាងអាជ្ញា ។

សាលាក្តីខាងតុលាការសឹកនេះ មានភារៈជំនុំជម្រះ បទល្មើសទាំងឡាយប្រព្រឹត្តដោយទាហាន ឬ ប្រព្រឹត្តលើរូប និង ទ្រព្យសម្បត្តិទាហាន ព្រមទាំងលើសេចក្តីសុខសាន្តក្នុងប្រទេសនិងក្រៅប្រទេស ។

សាលាខាងក្រមវិវាទរដ្ឋបាល (Contentieux administratif)

ដែលជាសាលាក្តីសម្រាប់ជំនុំជម្រះ ការវិវាទរវាងឯកជននិងរាជការ ឬរាជការនិងរាជការ ។

សាលាក្តីនេះ មានសាលាដំបូងជាពិសេសដែលមានចៅក្រមម្នាក់ជាប្រធាន, មន្ត្រីខាងរដ្ឋបាល ២ នាក់ជាសមាជិក និងបុគ្គលិកម្នាក់ជាលេខាធិការ ។ បើមិនសុខចិត្តនឹងសាលាក្តីនេះ ភាគីអាចប្តឹងឧទ្ធរណ៍តក៏ទៅ

សាលាឧទ្ធរណ៍ជាពិសេសមួយទៀត ។

សាលាក្ដីខាងតុលាការរាស្ត្រ (Tribunal populaire) មានការៈជំនុំជម្រះសមាជិកគណៈរដ្ឋមន្ត្រីដែលបានប្រព្រឹត្តខុសចំពោះជាតិជាដើម ។ សមាសភាពនៃសាលាក្ដីនេះមានចៅក្រមម្នាក់ជាប្រធាន, ចៅក្រមពីរនាក់ជាអនុប្រធាន ព្រមទាំងមានរាស្ត្រ ៤០ នាក់ជាសមាជិក ។ ចៅក្រមជាប្រធាននិងជាអនុប្រធាននេះ គ្មានសិទ្ធិបោះឆ្នោតសម្រេចជាយ៉ាងណាទេ ពោលគឺគ្មានសម្លេងសម្រេចឡើយ គឺត្រូវទុកឲ្យរាស្ត្រជាសមាជិកបោះឆ្នោតយកភាគច្រើនដើម្បីវិនិច្ឆ័យសេចក្ដីអ្វីមួយ ។

បើសមាជិកមកប្រជុំមិនបាន ៣ ភាគ ៤ ទេ សេចក្ដីសម្រេចនៃសាលានេះ មិនត្រូវទុកជាបានការឡើយ ។ គូភាគីដែលមិនសុខចិត្តនឹងសេចក្ដីវិនិច្ឆ័យរបស់សាលាក្ដីនេះ គ្មានផ្លូវតវ៉ាទៅណាបានទៀតឡើយ ។

អំពីការរៀបចំនៃសាលាក្ដីនេះមានដាច់ ។ គ្នាទៅតាមប្រភេទនិងទៅតាមនាមនៃសាលាក្ដីមួយ ។ មិនមែនមួយនៅក្រោមបង្គាប់មួយទៀតឡើយ ។ បើសាលាក្ដីមាននាមដូចគ្នា គ្រាន់តែតាំងនៅទីកន្លែងខុសគ្នា ដូចជាសាលាដំបូងខាងកាត់ក្ដីកំពង់ចាម, បាត់ដំបង, កំពត ។ល។ ត្រូវមានការរៀបចំដូច ។ គ្នា ដូចមានគ្រោងទុកនៅក្នុងច្បាប់នីតិវិធីស្រាប់ ។ ដែលអស់លោកអ្នកបានឃើញនៅសាលាដំបូងនីមួយ ។ មានបាំងហ្វាងធំមួយ

ហើយមានតាំងហ្វាងរង, តាំងហ្វាងបន្ទប់ទី ១ ទី ២ មានព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង សុភាចារ្យបុរសទិន្រក្រឡាបញ្ជីនៅលាយឡំគ្នានោះ គឺមកពីរាជការខាងតុលាការមិនទាក់មានធនធានដើម្បីសង់ជាសាលាដាច់ ៗ ពីគ្នាទេ ដូនកាលកន្លងមក ៗ កាន់មុខការពីរយ៉ាង តាំងខាងអាជ្ញា តាំងខាងបវេណីក៏មាន ហើយសាលជំនុំជម្រះហៅជាសាលសវនា (Salle d'audience) ក៏មានតែមួយសម្រាប់ឲ្យខ្លីគ្នាប្រើជាបណ្ដោះអាសន្នសិនដែរ ៗ គ្រាន់តែជាផ្លូវរដ្ឋបាល រាជការបានដាក់ទុកឲ្យប្រធាន នៃសាលាក្ដីបវេណីកាន់ឋានៈជានាយកនៃសាលាទាំងមូល ដើម្បីឲ្យមានការរៀបរយជាផ្លូវរដ្ឋបាលប៉ុណ្ណោះ ៗ

X X
X

យើងសូមជម្រាបថា នៅលេខក្រោយ ៗ យើងនឹងចំរកឯកសារសំខាន់ ៗ ស្ដីពីអគ្គការធំ ៗ យកមកផ្សាយជូនជាហូរហែទៅទៀត ៗ

កម្ពុជសុរិយា

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ - ភាគ ៨

ប្រែ-រៀបរៀង

(៩)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នករាជវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ
>
> យូរ-អ៊ុន

ចេងពោកថា: យើងទាំងលោកជាមនុស្សផ្សេងស្រុកផ្សេងភាសាគ្នា, ដែលយើងទាំងស្ម័គ្រសមាគមសុំចំណុះចុះចូលនោះ មិនត្រូវសោះ, ព្រោះលោកជំនាញមានឈ្មោះ តែខាងកលឧបាយមួយយ៉ាង, ដែលចេងឈ្មោះ ដោយកម្លាំងថ្វីដៃជាសំខាន់គ្មាន, ខុងបេងអស់សំណើចហើយថា ឥឡូវ យើងទាំងបើកលែងអ្នកឯងទៅទៀត, តើអ្នកឯងទាំងទៅគិតធ្វើសឹកសង្គ្រាមនឹងយើងតទៅទៀតឬ? ចេងពោកថា បើលោកមានគុណបើកលែងយើងទៅស្រុកគ្រានេះហើយ យើងក៏ទាំងតាំងចិត្តសងគុណលោក មិនហ៊ានគិតធ្វើការសឹកតទៅទៀតទេ ។

ខុងបេងថា អ្នកឯងវិលទៅវិញ ហើយត្រូវរិះគិតមុខក្រោយឲ្យល្អ; ចេងពោក ក៏មានអំណរពន់ប្រមាណណាស់ ក្រាបសំពះខុងបេងហើយក៏

ណាចេញទៅ ហើយនាំទាហានរបស់ខ្លួនប្រមាណ ១.០០០ នាក់ ស្រូតចេញទៅតាមផ្លូវទិសឯជើង, ទៅប្រទះនឹងចេងហ៊ុវជាប្អូននាំទាហានលើកមក, ចេងហ៊ុវក៏និយាយប្រាប់ចេងហោកថា ខ្ញុំស្មានថា ខុងចេងសម្លាប់បងទៅហើយ បានជាខ្ញុំខំប្រមូលទាហានបានជាច្រើន លើកត្រឡប់មកប្រាថ្នានឹងសងសឹកខុងចេងឲ្យបាន, ចេងហោកលុះបានឮសម្ដីប្អូនដូច្នោះក៏ឲ្យទោមនស្សត្រូវចិត្តណាស់ស្ទុះទៅឱបកចេងហ៊ុវជាប្អូន ហើយយំសោកា ថា តាំងពីយើងធ្វើការសឹកមកច្រើនលើកហើយ ចេះតែបរាជ័យចាញ់ដៃគេគ្រប់គ្រា, វេលានេះ ក៏កាន់តែអស់កម្លាំងនឹងតម្រិះប្រាជ្ញាពន់ប្រមាណ យើងនឹងរិះគិតអានដូចម្ដេចទៅទៀត ទើបនឹងបានជ័យជម្នះខុងចេងវិញ ៗ

ចេងហ៊ុវថា សុំឲ្យបងនាំទាហានឡើងទៅសុំអាស្រ័យនៅនឹងគោស៊ូ-តៃរងឯភ្នំអិមតងសានចុះ, ព្រោះភ្នំនោះជាទីសំខាន់ស្រួលណាស់ មានភ្នំជាសន្ទុះជុំវិញ ដូចជាកំពែងខាងក្នុង មានកន្លែងតាំងបន្ទាយរាយរៀងគ្នាជាទីកក់ក្ដៅស្រួល, បើយើងមានទំនួលនឹងតាំងទីឲ្យខ្ជាប់ខ្ជួនវេលាណា, នោះខុងចេងនឹងមានឧបាយប្រាជ្ញាចង់ឲ្យយើងចំណុះចុះចូល ហើយលើកពលតាមមក ក៏គង់នឹងថ្លស់ការផងយើងជាប្រាកដ ៗ

ចេងហោក បានឮប្អូនថាដូច្នោះក៏យល់ឃើញត្រូវ, ទើបនាំគ្នាលើកទាហានសំដៅទៅភ្នំអិមតងសាន លុះដល់ហើយ ក៏ឲ្យចេងហ៊ុវឡើងទៅគំនាប់គោស៊ូ-តៃអងមុខជាផ្លូវគួរ ដើម្បីនឹងសុំលើកទ័ពមកស្នាក់អាស្រ័យ,

ឯគោស៊ូ-តៃអង់បានដឹងសេចក្ដី ក៏ចេញមកទទួលចេងហោកចូលទៅកាន់ទីបន្ទាយ, លុះដល់ហើយក៏គំនាប់គ្នាជាទីស្រួពយតាមទំនៀម, ហើយចេង-ហោកក៏នាំពតិមានតាមប្រព្រឹត្តិហេតុឲ្យគោស៊ូ-តៃអង់ស្ដាប់គ្រប់ប្រការ ។

គោស៊ូ-តៃអង់ថា អ្នកកុំព្រួយបារម្ភឡើយ, បើទាហានខុងចេងលើកតាមមកហើយដល់ទីនេះ, សូម្បីតែម្នាក់ ក៏មិនឲ្យត្រឡប់ថ្លាក់ទៅវិញបាន, ទោះបីខុងចេងដែលពូកែជំនាញ ក៏គង់នឹងសូន្យជីវិតនៅទីនេះ, ចេងហោកបានឮដូច្នោះក៏មានអំណរណាស់ រហ័សសួរប្រស្រ័យទៅវិញថា លោកនឹងគិតធ្វើយ៉ាងម្ដេច ?

គោស៊ូ-តៃអង់ថា: ភ្នំអិមគង់សាន់នេះ មានផ្លូវចំពោះចូលមកបានតែតាមលំអានខាងទិសបូព៌ា ដែលអ្នកមកនោះ ជាទីកបទាបស្រួល, ទឹកផឹកក៏មានទំនួលប្រើបានបរិបូណ៌ តែជាផ្លូវប្រកបចង្អៀតសុទ្ធតែថ្មសិលានិងដើមឈើធំ ៗ ខ្ញុំនឹងរំលំដើមឈើរគាស់ថ្មខ្ទប់បិទផ្លូវនោះឲ្យជិត កុំឲ្យខុង-ចេងគិតលើកទ័ពឡើងមកបាន, ទោះបីនឹងទន្ទ្រានឆ្ការផ្លូវ ទៅខាងទិសឯលិចក៏មិនបាន ព្រោះផ្លូវនោះជាចទីហាន់ឆ្ងាយស្រយាលណាស់; ហើយមិនស្រឡះធំទូលាយ សឹងជាផ្លូវចង្អៀតមិនងាយនឹងដើរ ខាងព្រៃលើមានសុទ្ធតែពស់ពិសកាចណាស់ ចំពោះដើរបានខ្លះតែពេលរសៀល, បើដល់ពេលព្រលប់ហើយ ពស់ពិសទាំងនោះក៏ចេញប្រពាក់ប្រពូនលូនទៅមករកអាហារទាល់តែថ្ងៃត្រង់កាលណា ទើបវាចូលរូងរន្ធទៅវិញ, ឯទឹកនោះមិញ

កំដាច់សោះចំពោះមានតែទឹកអាក្រក់ បើផឹកទៅកាលណាក៏បណ្ដាលឲ្យទោស, ជ្រោះមួយឈ្មោះ អែសួន បើអ្នកឯណាមិនទាន់ដឹងខ្លួន ដងយកមកផឹក ក៏ទៅជាគមិនបេះស្ដី គ្រប់កំណត់ ៧ ថ្ងៃទឹងស្លាប់; ជ្រោះទី ២ ឈ្មោះ បៀតសួន, ទឹកក្នុងជ្រោះនោះក្ដៅ, បើទឹងចុះទៅឆ្លងប្ដឹក, កំបែកជាពុះពងរលួយស៊ីទៅដល់ឆ្អឹង; ជ្រោះទី ៣ ឈ្មោះ ហោតសួន, ពណ៌ទឹកនោះខ្មៅ, បើអ្នកឯណាចុះឆ្លងប្ដឹក ខ្លួននោះក៏ខ្មៅដូចក្អែងឆេះឈើពាប់ពន់ប្រមាណណាស់លុះដាច់ខ្យល់ស្លាប់; ជ្រោះទី ៤ ឈ្មោះ យិវ-សួន, ទឹកនោះត្រជាក់ណាស់ ពណ៌ស, បើអ្នកឯណាដងយកមកផឹកឆ្លងប្ដលេបដល់កក៏ដាច់ខ្យល់ស្លាប់, ក្នុងផ្លូវនោះស្ងាត់ណាស់ គ្មានសត្វអម្រឹតបក្សីស៊ីសោះ, លុះហួសពីទីនោះទៅ មានផ្លូវទៅពានលើហ្វងពស់កាចសា-ហាវណាស់; កាលគ្រាព្រះចៅហាន់បេងគេសោយរាជសម្បត្តិ ម៉ាអ៊ួននាយទាហានលើកកងទ័ពទៅវាយស្រុកកៅជី, ម៉ាអ៊ួនមានតម្រិះប្រាជ្ញាឆ្លៀវឆ្លាត ដឹងកិច្ចការចាំងច្បាំងគ្មាននរណាស្មើ ក៏នាំទាហានដើរមកត្រូវផ្លូវនេះ, អ្នកដទៃក្រៅពីម៉ាអ៊ួននោះ គ្មាននរណាដែលបានដើរមកលើផ្លូវនេះឡើយ, បើខុងបេងហើយ អាចលើកទាហានពានមកលើផ្លូវទិសឯកើត ឃើញបើងកាប់ឈើរំលំគាស់ដុំថ្មបិទផ្លូវ មុខជានាំទាហានវិលទៅដើរពីទិសឯលិចវិញ, បើទាហានខុងបេងនោះមិញ ទឹងលើកមកប៉ុន្មានរយម៉ឺន ក៏គង់ទឹងស្លាប់ដោយពិកការនោះអស់មិនខាន, ទោះខ្លួនប្រាណខុងបេងឯង

ជាចៅប្រាជ្ញាពូកែខាងកលឧបាយ  ក៏មុខជាអន្តរាយជីវិតកុំបាប់គិតនឹងរស់រួចទៅវិញឡើយ ។

បេងហោកនិងបេងហ៊ីវ ស្តាប់ហើយ ក៏មានសេចក្តីត្រេកអរណាស់ថា ដែលលោកឲ្យខ្ញុំម្ចាស់អាស្រ័យនៅ ព្រះគុណរកទីបំផុតគ្មាន មុខជាខុង-បេង នឹងអន្តរធានជា ប្រាកដ, គោស៊ូ-តៃអង ក៏អញ្ជើញបេងហោក បេងហ៊ីវ ឲ្យនៅជាសុខ ហើយតែងតុលៀងភោជនាហារជានិរន្តរ៍ ។

ចប់ ភាគទី ៦៩ ។

---

# សាមកុក ភាគទី ៧០

តាំងពីខុងបេងបើកបេងហោកជាទីគម្រប់ ៤, បេងហោក បេងហ៊ីវបងប្អូនរត់ទៅពឹងគោស៊ូ-តៃ-អង រហូតដល់ខុងបេងឈ្នះទ័ពបេងហោក គម្រប់ ៧, បេងហោកទទួលចុះចាញ់, ខុងបេង លើកទ័ពត្រឡប់ទៅស្រុកសែឈួនវិញ ។

ឯខុងបេងនោះ លុះលែងបេងហោកទៅហើយ ក៏ចាំមើលផ្លូវយូរថ្ងៃ មិនឃើញបេងហោកវិលមកគំនាប់សោះ ក៏មិនស្មោះថាបេងហោកគេចវេះ មិនខ្លាចតម្រិះប្រាជ្ញា, ខុងបេងក៏លើកពលយោធាចេញពីបន្ទាយស្រួតតាម ទៅក្នុងផ្លូវទិសខាងជើង លុះទៅដល់កណ្តាលផ្លូវក៏បោះទ័ពឈប់ធ្វើបន្ទាយ ហើយឲ្យទាហានទាំងឡាយស៊ើបស្តាប់ដំណឹងថា បេងហោកលើកទៅតាំងនៅទីឯណា, បម្រើស៊ើបបាឧការ ក៏វិលមកជម្រាបវិញថា បេងហោកលើក

ទាហានឡើងទៅនៅលើភ្នំអិមតង់សាន់ ហើយរំលំឈើរួចបិទផ្លូវដែលនឹងឡើងទៅលើភ្នំនោះមាំមួនណាស់ ឃើញពួកទាហានប្ដូរផ្លាស់នៅយាមល្បាតជានិច្ច, បើយើងនឹងលើកតាមទៅកម្ដេចក៏ជាការលំបាក; ខុនបេងឮដូច្នោះ ក៏ពិគ្រោះសួរលីឃី ដែលជាអ្នកនាំផ្លូវថា ផ្លូវនឹងឡើងទៅលើភ្នំអិមតង់សាន់នោះ ចំពោះមានតែច្រកមួយប៉ុណ្ណោះ ឬមានក្រៅពីនោះទៅទៀតដែរ ? លីឃីៈឆ្លើយថា ឯភ្នំអិមតង់សាន់នោះ ខ្ញុំបាទមិនធ្លាប់ទៅមកសោះ, ទីនោះនឹងជាប្រការម្ដេចក៏ពុំអាចដឹង តែបានឮគេថាមានផ្លូវទៅទៀត, ខុនបេងបានឮដូច្នោះ ក៏ប្រុងប្រៀបរៀបទាហាននឹងលើកទៅ ។

ចៀវអួន នាយទាហានឆ្លើយថា លើកទ័ពមកធ្វើសង្គ្រាមគ្រានេះក៏មានចំណាប់នឹងចាប់ខ្លួនបេងហោកបានដល់ ៤ លើកហើយ, បេងហោកក៏ខ្លាចថ្វីដៃយើងខ្លាំងណាស់ កាលណាឡើយវានឹងហ៊ានលើកទាហានមកច្បាំងនឹងយើងទៀត, ឥឡូវក៏ជារដូវក្ដៅណាស់ ទាហានយើងសុទ្ធតែនឿយហត់បានសេចក្ដីអត់ឃ្លានលំបាកណាស់ សុំឲ្យលោកលើកទ័ពត្រឡប់វិលទៅស្រុកសៃឈួនវិញសិនចុះ ដើម្បីនឹងស្ដាប់ដំណឹងបេងហោកមើល បើនៅធ្វើការតនឹងយើងដូចពីដើម សឹមយើងត្រឡប់មកចាប់ខ្លួនឲ្យបាន ។

ខុនបេងថា ឥឡូវបេងហោកខ្លាចយើង បានជារត់ទៅឡើងលើភ្នំសម្ងំពួនមុខឲ្យ ក៏បាន, បើយើងលើកទ័ពត្រឡប់ទៅមិននៅច្បាំង គង់បេងហោកនឹងបានចំណាប់ត្រឡប់ចេញមុខធ្វើការតតកោតញញៀត, គួរតែយើងនឹង

លើកតាមទៅទិសឯកើត ចាប់ខ្លួនឲ្យបានកំពុងរាទូទំទូកដូច្នេះ ទើបបាន ស្រួល ហើយខុនបេងក៏ឲ្យអងប៉េងនាំទាហាន ១០០ ទៅពិនិត្យមើលប្រែកផ្លូវជាមុន, អងប៉េងក៏លាខុនបេងទៅដល់មាត់ផ្លូវខាងលិច ទឹងចូលទៅក្នុងមគងសាន់; ទាហានទាំងពួងស្រេកទឹកណាស់ ក៏បបួលគ្នាចុះទៅផឹកទឹកក្នុងជ្រោះអែស្ងួន, ទាហានទាំងនោះក៏ទៅជាគទាំងអស់ ។

អងប៉េងឃើញដូច្នោះ ក៏ភ័យណាស់ ត្រឡប់វិលមកប្រាប់ខុនបេងតាមរឿងសព្វគ្រប់ប្រការ, ខុនបេងឮហើយ ក៏តក្កមានិយាយថា ទឹកក្នុងជ្រោះនោះ ជាហេតុដូចម្តេចអេះបានជាដូច្នោះ ឬជាកលឧបាយបេងហោកដាក់ថ្នាំបំពុលទេដឹង! ចាំយើងទៅមើលឲ្យដឹងសិន, ថាហើយខុនបេងក៏ឡើងជិះរទេះតូចនាំទាហានស្និទ្ធ ១០ នាក់ទៅជាមួយនឹងអងប៉េង, លុះទៅដល់ផ្លូវទិសឯលិច ខុនបេងពិគ្រោះមើលទឹកជ្រោះនោះថ្លាហ្ងន់, សម្លឹងទៅមិនឃើញមានអ្វី ហើយស្ងាត់ឥតសត្វម្រឹគបក្សីអ្វីដើរហើរទៅមកសោះ, ខុនបេងគិតសង្ស័យណាស់ ទើបឡើងទៅមើលលើមាត់ជ្រោះ ឃើញមានខ្ទមអ្នកតាមួយចាស់យូរហើយនៅក្នុងព្រៃស្បាត, ខុនបេងក៏តោងវល្លិ ឡើងប្រតោងខ្លួនទៅដល់ខ្ទមអ្នកតានោះ ឃើញគេធ្វើអំពីថ្ម មានរូបទេព្រក្ស ១ អង្គ, ខុនបេង ពិគ្រោះមើលឃើញអក្ខរចារឹកនៅលើផែនថ្ម សេចក្តីថា

កាលគ្រាព្រះចៅហ័នបេងតេសោយរាជសម្បត្តិ ម៉ាអ្នួន នាំទាហានមកតាមផ្លូវនេះបាន, ខុនបេងឃើញដូច្នោះក៏សប្បាយចិត្តណាស់ទើបក្រាប

សំពះទេព្រក្សនោះហើយថា ខ្ញុំម្ចាស់ឈ្មោះខុនបេង ត្រង់សុចរិតចិត្តប្រកបដោយសត្យធម៌ តាំងសេចក្ដីទីងទំនុកបម្រុងព្រះបរមរាជវង្សៗឲ្យចេញមកបង្ក្រាបខ្មាំងសត្រូវផ្សេងភាសា បើការបានសម្រេច គិតទីងកាប់យកស្រុកកាំងតាំងទីងស្រុកហ្លូតោ ដើម្បីទីងអញ្ជើញព្រះរាជវង្សព្រះចៅហ៊ានបេងតេឡើងសោយរាជសម្បត្តិតទៅ, ឥឡូវខ្ញុំម្ចាស់បានមកដល់ទីនេះ មិនបានដឹងហេតុផលប្រការម្ដេចនោះ, ពួកទាហានទាំងអស់បានចុះផឹកទឹកជ្រោះនេះក៏វិបរិតទៅជាគទាំងអស់គ្នា, សូមអស់លោកចូរមេត្តាខ្ញុំម្ចាស់! ព្រោះខ្ញុំបាននឹករលឹកដល់គុណព្រះចៅហ៊ានបេងតេ សូមព្រះអង្គទ្រង់មកជួយណែនាំបំភ្លឺស្មារតីប្រាជ្ញាខ្ញុំម្ចាស់ ឲ្យបានដឹងច្បាស់សេចក្ដី, ហើយខុនបេងក៏គំនាប់ក្រាបសិរសីលាចេញមក ស្រាប់តែឃើញតាចាស់ម្នាក់កាន់ឈើច្រត់ដើរតម្រង់មកតាមជើងភ្នំ ។

ខុនបេងក៏មានអំណរណាស់ ស្រែកអញ្ជើញតាចាស់នោះឲ្យឡើងអង្គុយលើខ្ទមអ្នកតា គំនាប់គ្នាគួរសមតាមទំនៀមហើយ ខុនបេងក៏សួរថា អ្នកឈ្មោះអ្វី? សែអ្វី? ម៉ាអួនទេព្រក្ស ធ្វើជាមិនបានឮហើយថា ខ្លួនខ្ញុំចាស់ហើយបានឮកិត្តិស័ព្ទមកក៏យូរអង្វែង ថាមហាឧបរាជនេះ មានចិត្តសត្យទៀងត្រង់ទីងកប់អាទស្រឡាញ់អាណិតអាណាប្រជារាស្ត្រ, ឥឡូវខ្ញុំឃើញអ្នកមកដល់ទីនេះ ទើបមានចិត្តអំណរមកសួរគំនាប់; ខុនបេងសួរថា អ្នកជាបមក្នុងតំបន់នេះ តើបានដឹងខ្លះឬទេ? ទឹកជ្រោះនេះហេតុផលប្រការម្ដេច?

ម៉ាអ្នកទេព្រ័ក្សឆ្លើយប្រាប់ថា ទឹកជ្រោះដែលតាហានមកដួតផឹកនេះឈ្មោះ អែស្វូន, បើដួតផឹកហើយរមែងធ្វើឲ្យខ្លួនអ្នកនោះនិយាយមិនចេញដូចមនុស្សគ ដល់កំណត់ ៧ ថ្ងៃនឹងស្លាប់។ នៅមានជ្រោះវៀងត ៗ គ្នាជាលំដាប់ទៅទៀត ៣ ជ្រោះ; ជ្រោះ ១ ទឹកត្រជាក់, បើអ្នកណាដួតផឹកត្រជាក់ទៅដល់បំពង់កក៏ដាច់ខ្យល់ស្លាប់; ជ្រោះ ១ ទឹកខ្មៅ, បើអ្នកណាដួតផឹក ក៏ឡើងសម្បុរខ្មៅទៅអស់តាំងខ្លួន ឈឺចាប់ក្រាំក្រួនទាល់តែដាច់ខ្យល់ស្លាប់; ជ្រោះ ១ ទឹកក្តៅ, បើអ្នកណាដួតផឹក ក៏ក្តៅរលួយទៅអស់តាំងខ្លួន មានស៊ីទៅដល់ឆ្អឹងដាច់ខ្យល់ស្លាប់; ទឹកក្នុងជ្រោះជាលំដាប់តាំង ៤ នេះមានពិសកាចផ្សេងៗគ្នា ហើយមានផ្សែងពពកកើតឡើងពីជ្រោះតាំងពីព្រឹកដល់ថ្ងៃត្រង់ បើអ្នកដើរមកត្រូវត្រង់ពេលនោះ ឲ្យត្រូវប៉ះលើពពកនោះ ហើយក៏ឲ្យឈឺចាប់សព្វសារពាង្គកាយអន្តរាយជាតែ ។

ខុងបេងបានស្តាប់បព្ជាសេចក្តីទេពស្រដីថា បើដូច្នោះ កាលណាខ្ញុំនឹងបង្ក្រាបបេងហេកឲ្យបានដូចបំណង បើបេងហេកនៅចងជាសត្រូវហើយ ក៏ជាសឹកចាំវាយខ្នប់ពីក្រោយបាន ព្រោះខ្ញុំគិតគាននឹងទៅវាយយកស្រុកហួតោនិងស្រុកកាំងតាំងទៀត មុខជាមិនសម្រេចការ ខ្លួនខ្ញុំជាមនុស្សឥតវាសនាអភ័ព្វណាស់ មិនបានមានតបះនឹងទំនុកបម្រុងព្រះបាទឡៅសៀនហើយ នឹងស្លាប់ទៅវិញប្រុះសារជាង, ម៉ាអ្នក ទេព្រ័ក្សថា មហាឧបរាជកុំព្រួយបារម្ភ ជាការខ្ញុំនឹងបង្ហាញប្រាប់ថាំឲ្យបំបាត់ទឹកពុលនោះបាន, ខុង-

បេងថា តាជាចាស់ទុំអាយុច្រើន បើជ្រាបឃើញប្រការម្ដេច ត្រូវជួយណែនាំពន្យល់ខ្ញុំឲ្យបានការផងចុះ ។

ម៉ាអួនទេព្រ័ក្សប្រាប់ថា ភូំស័នអុកនៅទិសឯលិច ឆ្ងាយពីភូមិអិមតង-ស័ននេះ ៨០០សិន (៣២ គីឡូម៉ែត្រ) ចូងភូំនោះទៀត ២០ សិន (៨០០ ម៉ែត្រ ដល់ស្ទឹងប័នអ័ន, មានមនុស្សម្នាក់ឈ្មោះបេងចៀត សង់ផ្ទះនៅក្បែរមាត់ស្ទឹងនោះជាង ១០ ឆ្នាំហើយ, ក្រោយផ្ទះបេងចៀត មានជ្រោះឈ្មោះអ័នលុកចួ, ទឹកជ្រោះនោះហូរធ្លាក់មកលើស្ទឹងប័នអ័ន, បើនរណាកើតពេគបានផឹកទឹកខ្ទួតទឹកនោះ ក៏ជាសះពេគនោះទាំងអស់, មុខផ្ទះនោះ មានដើមឈើក្រអូបឈ្មោះហុយហៀចដុះនៅជាច្រើន ប្រសិនបើមានអ្នកណានឹងផឹកខ្ទួតទឹកកាចនៅជ្រោះទាំង ៤ នោះហើយ បើបានស្លឹកឈើនោះមកដាក់កន្ទុមាត់តែ ១ សម្ទឹក ក៏កែពិសនោះបាន, ការនេះបើមហាឧបពជនឹងចង់ចូលទៅក្នុងស្រុក អិមតងស័នឲ្យបាន ក៏ចូរទៅរើសយកថ្នាំនោះមកចុះៗ

ខុងបេងបានឮដូច្នោះ ក៏មានអំណរណាស់ ធ្វើអភិវាទក្រាបសំពះហើយសួរថែមថា តាឈ្មោះអ្វី? សែអ្វី? សុំអាណិតប្រាប់ឲ្យខ្ញុំដឹងផង, បើសម្រេចសេចក្ដីប្រាថ្នាវេលាណា ខ្ញុំនឹងវិលមកតបស្នងសងគុណតា, ម៉ា-អួន ទេព្រ័ក្សបានស្ដាប់ហើយ ក៏ឡើងទៅលើសាលានោះអង្គុយលើទីខ្ពស់ហើយប្រាប់ថា ខ្ញុំនយើងគឺម៉ាអួន ហើយក៏អន្តរធានបាត់ទៅ ។

(នៅមានត)

# រឿង
# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ២១

ល្ងាចថ្ងៃដដែលនោះ វេលាម៉ោងប្រាំបួនយប់ រ៉ាមេស្ហនាំនាងកាមាលាទៅស្ថានីយរថភ្លើងសាលដាហ៍ អ្នកបញ្ជាឲ្យអ្នកបររទេះ បរកាត់កាលូតូឡា ។ ដល់ជិតផ្ទះខ្លះ អ្នកចំអើតមើលតាមបង្អួចកញ្ចក់ តែមិនឃើញមានអ្វីប្លែកសោះ ។ អ្នកដកដង្ហើមធំ ធ្វើឲ្យនាងកាមាលាដែលសម្ងំគេងនៅក្បែរនោះភ្ញាក់ ហើយសួរថា "ស្អីបង!" ។

– ឥតមានអីទេ (រ៉ាមេស្ហឆ្លើយ ព្រមទាំងដកខ្លួនថយទៅកៀន)

នាងកាមាលាសម្ងំគេងទៅវិញ ។

រ៉ាមេស្ហបានទិញសំបុត្របន្ទប់រទេះភ្លើងថ្នាក់ លេខ ៦ ទុកជាស្រេច រួចនាំនាងចូលទៅក្នុងបន្ទប់នោះ ។ អ្នករៀបកន្ទេលមួយឲ្យនាងគេង អុជបង្គៀងមួយនៅក្បាលដេក ហើយប្រាប់នាងថា :

–គេងទៅ បានហើយ ។

–ចុះបើខ្ញុំនៅអង្គុយមើលគេនៅមាត់បង្អួច ចាំដល់រទេះភ្លើងចេញ សិមគេងបានឬទេបង ?

ក៏មេស្ហងក់ក្បាលបណ្ដោយតាមចិត្តនាង នាងកាមាលាទាញក្រមាគ្របក្បាល អង្គុយលើគែមគ្រែ សម្លឹងមើលមនុស្សដើរចុះ-ឡើងខាងក្រៅទូរទេះភ្លើង ។

រទេះភ្លើងវិលកង់បន្តិច ៗ ទៀបនឹងចេញទៅហើយស្រាប់តែក៏មេស្ហដែលនៅឈរពីក្រោយខ្នងនាង ពោលខ្សែក្អកទៅឃើញអ្នកដំណើរម្នាក់មកមិនទាន់រទេះភ្លើង មានដំណើរដូចជាប្រញាប់ណាស់ គេខំសង្កើតព្រោះអ្នកនោះដូចជាធ្លាប់ស្គាល់ ។ នាងកាមាលាលាន់សំណើចយ៉ាងខ្លាំងក៏មេស្ហក្រឡេកម្ដងទៅទៀត ឃើញអ្នកដំណើរដែលមកមិនទាន់នោះ កំពុងតែប្រវាយប្រតប់ជាមួយនឹងកម្មកររថភ្លើង ដែលចាប់ឃាត់ខ្លួនមិនឲ្យរត់ទៅតោងឡើងរទេះភ្លើងដែលកំពុងតែវិលកង់ទៅមុខបន្តិច ៗ ទៅហើយនោះអ្នកដំណើរខំបំរះទាល់តែរបូតឈ្នួតជាប់នៅដៃកម្មករ ទើបរួចរត់មកឡើងទូរថភ្លើង ។ លុះឡើងមកហើយ គេអើតតាមមាត់ទ្វារ ឈោងទៅយកឈ្នួតគេវិញ ទើបក៏មេស្ហមើលស្គាល់ច្បាស់ . . . . . . .
អាក់ស្ហាយទេតើ !

មួយសន្ទុះក្រោយមកទើបនាងកាមាលាឈប់សើចបាន ។ ក៏មេស្ហប្រាប់នាងថា ម៉ោងដប់កន្លះហើយ ត្រូវនាងគេងទៅកុំនៅទាល់យប់ពេក នាងកាមាលាធ្វើតាមបង្គាប់ក៏មេស្ហ យូរៗ នាងនៅតែផ្ទុះសើចម្ដង ឯក៏មេស្ហទឹករកសើចមិនកើតសោះ ព្រោះមើលទៅឃើញថាមិនមែនជាការសប្បាយ

ព្រោះអ្នកដឹងច្បាស់ថា អាក់ស្លាយ គ្មានផ្ទះកំសាន្តនៅឯស្រុកស្រែមួយទេ គាំងពីប៉ុន្មានតំណមកហើយ គ្រួសារអាក់ស្លាយរស់នៅតែក្នុងក្រុងកាល់គុត្តានេះទេ ចុះហេតុអ្វីបានជាវាទៅស្រុកស្រែ បើតាមគេស្មានគឺវាមកតាមស៊ើបមើលខ្លួនគេតែម្តង ៗ លុះនឹកឃើញថា ប្រហែលជាអាក់ស្លាយតាមទៅស៊ើបយកការណ៍អំពីភូមិកំណើតរបស់ខ្លួន ក៏មេស្ហនឹកបារម្ភជាច្រើន ព្រោះថា បើនៅទីក្រុងមានមនុស្សកុះករដូចជាកាល់គុត្តាទៅ មិនជាអ្វីទេ គេអាចលាក់ខ្លួនងាយ ចុះបើនៅក្នុងភូមិតូចមួយ អ្នកណានឹងអាចបិតជិត ៗ

លុះដល់ដំណាក់ប៉ាកក់ប៊ូរ៍ រថភ្លើងឈប់ ក៏មេស្ហខំឃ្លាំមើលអាក់ស្លាយក្នុងចំណោមអ្នកដំណើរដែលចុះ តែមិនឃើញអាក់ស្លាយចុះសោះ ។ ដល់មកចំណតណៃហាទីដែលសម្បូណ៍អ្នកដំណើរចុះឡើង ក៏មិនឃើញទៀត ដល់ដំណាក់ប៊ូគោឡា ក៏អំបឹងទៀត តើទៅដល់ណាទៀតទើបវាចុះ? មានការអ្វីនឹងទៅឆ្ងាយទៅទៀត ?

ក៏មេស្ហនឹកម្មរម៉ៅ ដេកក៏មិនលក់ទាល់តែយប់ជ្រៅមែនទែន ទើបអ្នកលង់លក់ទៅ ៗ ព្រលឹមស្រាង ៗ រថភ្លើងបរដល់កៅលុនដូដែលជាដំណាក់បំផុតចុងនៃផ្លូវរបស់គេ គឺពីដំណាក់នេះហើយ ដែលអ្នកដំណើរតែងតែចេញទៅបឹងគាល់ ( Bengale ) ផ្នែកខាងកើត ។

ក៏មេស្ហក្រឡេកទៅឃើញអាក់ស្លាយដើរលេះលាំងសំដៅផែកប៉ាល់មានទាំងយួរកូនហិបមួយផង ។

កុប៉ាល់ដែលចេញទៅស្រុកកំណើតក៉ាមេស្ហ ទាល់តែ-៣-៤ ម៉ោងទៀត ទើបចេញ ប៉ុន្តែមានកុប៉ាល់មួយទៀត ទាញស៊ីប្លេ យ៉ាងរន្ទើន ព្រោះដល់ម៉ោងចេញ ៗ ក៉ាមេស្ហសួរអ្នករទេះភ្លើងក៏ដឹងថា កុប៉ាល់នោះ ចេញទៅទិសខាងលិចរហូតដល់បេណារេសផង បើសិនជាទឹកនៅជ្រៅល្មមទៅបាន ៗ

ក៉ាមេស្ហនាំនាងកាមាលាទៅដាក់ក្នុងកប៉ាល់នោះភ្លាម រួចវិលចុះទៅរកទិញឥវ៉ាន់និងផ្លែឈើខ្លះផងសម្រាប់បរិភោគតាមផ្លូវ ៗ នៅពេលជាមួយគ្នានោះ អាក់ស្ហាយឡើងទៅរកន្លែងក្នុងកុប៉ាល់មួយយ៉ាងស្រួលដើម្បីចាំមើលអ្នកដំណើរឡើងទៅលើកុប៉ាល់ ៗ ប៉ុន្តែអ្នកដំណើរដែលត្រូវចុះកប៉ាល់នោះ មិនទាន់ប្រញាប់ចុះសោះ ព្រោះនៅពេលយូរទៀត ទើបកប៉ាល់ចេញ ៗ អ្នកខ្លះ ចំអិនអាហារបរិភោគនៅលើមាត់ច្រាំង អ្នកខ្លះចុះង្ងូតទឹកជម្រះកាយ សំរាន់ក្តៅសិន ៗល ៗ

ដោយមិនទាន់ឃើញនាងកាមាលានិងក៉ាមេស្ហ ចុះមកក្នុងកប៉ាល់ អាក់ស្ហាយគិតថា ច្បាស់ជាគេនាំនាងកាមាលាទៅបរិភោគអ្វីនៅភោជនីយដ្ឋានណាមួយនៅក្បែរនោះហើយ ប៉ុន្តែដោយគេមិនស្គាល់ស្រុកកា-លុនដូនោះផង គេនឹកថា កុំបាច់ទៅតាមរកអី នៅពួនចាំមើលលើកុប៉ាល់នេះបានហើយ ៗ

ប៉ុន្មានម៉ោងក្រោយមក កប៉ាល់ដែលអាក់ស្ហាយជិះនោះទាញស៊ីប្លែហៅអ្នកដំណើរ ៗ ក៉ាមេស្ហនៅតែមិនឃើញមកទៀត ស៊ីប្លែកាន់តែឲ្យ

សញ្ញាញាប់ឡើង ៗ អ្នកដំណើរចំប្រញាប់រត់តោងឡើងលើកប៉ាល់ ៗ កម្មករអូសស្ពានចេញ វរនាវិបញ្ជាឲ្យលើកយុថ្ការួចទៅហើយ ស្រាប់តែអាក់ស្ហាយស្រែកស្ទន់ឡើង "ខ្ញុំចង់ចុះវិញ!" ពួកអ្នកបើកកប៉ាល់គ្មានខ្វីយកចិត្តទុកដាក់សោះ ប៉ុន្តែដោយកប៉ាល់ស្ថិតនៅមិនឆ្ងាយប៉ុន្មានអំពីច្រាំងនៅឡើយ អាក់ស្ហាយក៏ប្រថុយលោតចុះមកឡើងគោកវិញ ។ ក៉ាមេស្ហក៏រកមិនឃើញ . . . . រថភ្លើងមួយដែលចេញទៅកាល់កត្តា ក៏ចេញផុត គេនឹកថា ប្រហែលជាក៉ាមេស្ហក៏ដឹងខ្លួនថាគេតាមរក ហើយក៏នាំនាងកាមាលាត្រឡប់ទៅវិញទៅហើយមើលទៅ មួយទៀត បើទៅកាល់កត្តាដែលជាទីក្រុងធំម៉្លេះឆ្ងាយអ៊ីចឹងរកក៏ឃើញ ? . . . .

## វគ្គទី ២២

នៅកាលុនដូ អាក់ស្ហាយដើររកក៉ាមេស្ហមួយថ្ងៃទាល់ល្ងាច លុះព្រលប់ទើបគេឡើងទៅរកកន្ទែងមួយក្នុងរថភ្លើងប្រៃសណីយ៍ ដែលត្រូវចេញទៅក្រុងកាល់កត្តាក្នុងយប់នោះ ៗ មកដល់កាល់កត្តាភ្លាម អាក់ស្ហាយសំដៅទៅផ្ទះក៉ាមេស្ហដែលនៅឯដារដីប៉ាក ប៉ុន្តែ គ្មានឃើញអ្នកណាសោះគេទៅឯកាលុត្តូឡា ក៏មិនឃើញអ្នកណាទៀត គេត្រឡប់មកដល់នៅផ្ទះលោកអាណាដា ចាប៊ូអស់ទាំងកម្លាំង អស់ទាំងសង្ឃឹម រួចទើបគេសារ-ភាពប្រាប់ដោះដន្ទ្រាថា ការដែលតាមក៉ាមេស្ហនោះ ឥតបានសម្រេចទេ ៗ

ពុំថាកាំមេស្ហគេចរត់បាត់ដូច្នេះ ដោយដេស្ត្រាតែតែសង្ស័យ ច្រើនថែមទៀត ។

ខ្ញុំទុករឿងរត់នេះ ជាការសារភាពកំហុសរបស់វាហើយ (ដោយដេស្ត្រានិយាយ) ប៉ុន្តែយើងឥតបានការណ៍អ្វីបន្ថែមទៀតសោះ ឯងត្រូវដឹង ខ្ញុំមិនមែនខមានការៈតែផ្ដាញ់ហ៊ាមណាលិនីម្នាក់ប៉ុណ្ណោះទេ ឪពុកខ្ញុំ ក៏គាត់យល់ដូចប្អូនខ្ញុំដែរ ត្រូវតែផ្ដាញ់គាត់ផង ហើយថ្វីបើឃើញប៉ុណ្ណឹងហើយក៏ដោយខ្ញុំជឿថា បើសិនជាកាំមេស្កូមកប្រាប់គាត់ឥឡូវហ្នឹងថា "ខ្ញុំដំរាបការណ៍អាថ៌កំបាំងរបស់ខ្ញុំពុំបានទេ" គាត់មុខជាសុខចិត្តឲ្យកូនស្រីគាត់ឥឡូវគ្មានរញ្ញាកទេ គ្មានផ្លូវដៃដកទេរ៉ុំ ព្រោះគាត់ភ័យណាស់តែឃើញកូនសម្លាញ់គាត់កើតទុក្ខ ។ នែ! បើទោះជាម៉េចក៏ដោយ យើងត្រូវតែគិតរកមធ្យោបាយឲ្យកាំមេស្ហូវានិយាយ រឿងវាប្រាប់យើងឲ្យអស់ទើបបាន កុំអាលអស់សង្ឃឹម ខ្ញុំធ្វើខ្លួនខ្ញុំមិនកើតទេ ព្រោះខ្ញុំមិនដឹងជាគេចចេញផ្លូវណាហើយខ្ញុំខ្លាចតែ មានរឿងទៀតផង ។ ឯងទៅងូតទឹកញាំបាយសិនចុះ . . . . .

អាក់ស្ហាយទៅបប់លាងខ្លួន រួចអង្គុយបរិភោគបាយតែម្នាក់ឯង ប៉ុន្តែគេមិនឈប់គិតពីរឿងនោះសោះ ។ នៅពេលនោះ ស្រាប់តែលោកអាណាជា បាប៊ុ ដឹកដៃកូនស្រីគាត់ចូលមក ។ គ្រាន់តែក្រឡេកឃើញអាក់ស្ហាយ នារីត្រឡប់ចេញទៅវិញភ្លាម ។

អីក៏ខ្លាំងដែម៉្លេះ! (ដោដេគ្រានិយាយ ដោយឃើញប្អូនបង្ហាញអា-កប្បកិរិយាមិនគប្បីចំពោះមិត្តខ្លួន ) ពុក មិនត្រូវធ្វើឲ្យវាប៉ាខចិត្តហើយឲ្យវាព្រហើនដូច្នេះទេណា៎ ពុកត្រូវហៅឲ្យវាចូលមកវិញភ្លាម រួចគេស្រែកហៅហ៊ិមណាលិនី! ហ៊ិម! ប៉ុន្តែនាងឡើងទៅដល់លើទៅហើយ ។

—ឯងធ្វើឲ្យខូចការអស់ ដោដេគ្រា ។ ខ្ញុំយល់ថា ស្ងួវឯងកុំដាក់ខ្ញុំជាត្រីមុខវិញ ចាំយូរបន្តិចសិនកុំប្រញាប់ពេក គង់បានសម្រេចទេ តែធ្វើឲ្យនាងមួម៉ៅ មុខជារកថ្នាំដាក់លែងត្រូវហើយ ។

លុះបរិភោគអាហាររួច អាក់ស្នាយក៏ត្រឡប់ទៅផ្ទះខ្លួនវិញ គេព្រួយអត់ធ្មត់ណាស់ តែកាលណាគេដឹងថារឿងឈមមុខមករកគេហើយ គេចេះទ្រាំអត់នៅស្ងៀមឈឹង រង់ចាំបានឱកាសល្អ ។ រីឯទឹកមុខគេទៀតក៏នៅតែដដែល ទោះគេជេដាក់មុខ ក៏មិនចេះប្រែទឹកមុខដែរ ។ មិត្តទាំងអស់ដឹងថា ទោះជាគេប្រមាថវាដូចម្ដេច ក៏វាមិនអន់ដែរ ។

អាក់ស្នាយចេញផុតទៅ, ទើបលោកអាណាដា ប៉ាប៊ូ ចូលទៅរកកូន ។ នាងហ៊ិមណាលិនីមានមុខស្ងាំង រង្វង់ភ្នែកខ្មៅជាំ នាងមិនងើបមុខមើលឪពុកនាងទេ ហើយទោះជាសេចក្ដីស្នេហា ជួយទ្រឲ្យនាងទុកចិត្តយ៉ាងណា នាងក៏មិនមានវិចារណញ្ញាណទឹងវែកញែក ឲ្យឃើញហេតុ ឃើញផលដែរ ។ ពីល្ងាចនាងបានប្រាប់គេរាល់គ្នាថា នាងទុកចិត្តលើរ៉ាមេស្វប្រាកដណាស់ ប៉ុន្តែ លុះនាងគេងគិតអស់មួយយប់ទៅ កម្លាំងជឿ

របស់នាងគឺថយទៅវិញ ។ តាមពិត គឺនាងគិតមិនឃើញអំពីអាកប្បកិរិយា ចម្លែកនៃបុរសបណ្ដាលចិត្តនាងនោះ ។

យប់បន្ទាប់មក លោកអាណាជា ផាប៊ូ នៅសម្រាន្តក្នុងបន្ទប់មួយ ដែលនៅជាប់នឹងបន្ទប់នាងទៀត ហើយក្នុងមួយយប់នោះ លោកចូលទៅ មើលកូនលោក ៤-៥ ដង តែឃើញកូនលោកឥតដេកស្កុកសោះ លោក ព្រួយណាស់ សួរកូនថា "ម្ដេចកូនមិនគេងទៅ?"

— ចុះពុកម្ដេច មិនសម្រាន្តខ្លួនឯងទៅ ? (នាងឆ្លើយ)

ព្រឹកឡើង នាងក្រោកពីព្រលឹមរួចនាងឡើងទៅលើលានដំបូលផ្ទះ។ ផ្ទះក៏មេស្ហបិទទ្វារឈឹង ។ ព្រះអាទិត្យរះឡើង សន្សើម ៗ ពីខាងក្រោយ ដំបូល ប៉ុន្តែនាងហាមណាលិទី មើលឃើញទឹកលេចមកថ្មីនោះ ហាក់ដូច ជាមានរស្មីស្អាប់ស្រទំ នាងទម្លាក់អង្គុយចុះ យកដៃខ្ទប់មុខយំ ។

ក្នុងមួយថ្ងៃពេញ នាងមិនឃើញក៏មេស្ហមកសោះ ហើយនាងឥត សង្ឃឹមថាគេនឹងមក ថែមទាំងមិនជឿថាគេសម្ងំនៅផ្ទះគេនោះផងទេ ។

សំឡេងឪពុកហៅនាង ធ្វើឲ្យនាងភ្ញាក់ព្រើត នាងយកដៃជូតទឹក ភ្នែកយ៉ាងប្រញាប់ ។ លោកតាឡើងដំណើរ បណ្ដើរ និយាយបណ្ដើរ ។

— ពុកគេងលក់ទាល់ថ្ងៃតម្កង កូនអើយ ។

លោកអាណាជា ផាប៊ូ សម្រាន្តលង់ទាល់ថ្ងៃមែន ព្រោះពីល្ងាច គាត់សម្រាន្តមិនលក់ ។ គ្រាន់តែលុបលាងមុខហើយភ្លាម លោកដើររក

កូនលោកក្លាម លុះឃើញបន្ទប់នាងទទេ លោកនឹកខ្លាចចិត្តអាណិតកូនដែលចេះតែទៅសម្ងំនៅទីស្ងាត់តែឯង ៗ

លោកតាអង្វរកូនឲ្យចុះទៅរកស្រស់ស្រូប ទាល់តែនាងទ្រាំមិនបានចុះតាមមក ព្រោះនាងធ្លាប់តែចាក់ទឹកតែជូនឪពុកដរាប ៗ នៅពេលដែលនាងចុះដំណើរ នាងព្រួសប្រមាត់បងនិយាយនឹងអ្នកណាម្នាក់ក្នុងបន្ទប់ទទួលភ្ញៀវនាងរំភើបស្មារតីគិត ដោយនាងស្មានថា ក៏មេស្នេហ៍ ប៉ុន្តែ លុះនាងចូលដល់ក្នុងបន្ទប់គ្រឡប់ជាឃើញអាក់ស្រាយទៅវិញ នាងទៅជាញ័រដៃញ័រជើង ចូលដល់កន្លែង នាងមិនរវល់ទទួលទឹកមុខភ្ញៀវណាសោះ នាងគិតតែបម្រើឪពុកនាងម្នាក់ប៉ុណ្ណោះ ៗ អាកប្បកិរិយានេះ ធ្វើឲ្យដោ-ដេទ្រូងក្តៅចិត្តជាខ្លាំងព្រោះគេនឹកថា ហេតុអ្វីបានជានាងនៅតែប្រកាន់ចិត្តខឹងនឹងរឿងដែលគេប្រាប់ថា "ក៏មេស្នេហ៍ក្បត់នាង" អីក៏យូរម្ល៉េះ គេខឹងម្យ៉ាងទៀត ព្រោះលោកតា ចេះតែកាន់ជើងនាង ហើយក្នុងរឿងក៏វាំងប៉ុន្មាន នាងតែងយកឪពុកជារនាំងដរាប គេនឹកក្នុងចិត្តថា:

-មើល៍ វាមើលមកឯង ដូចជាមនុស្សមានទោសឧក្រិដ្ឋទាំងពីរនាក់ ឯងដែលជាអ្នកចង់ឲ្យវាបានសុខ វាគ្មានគិតអរគុណនឹងឯងទៅជាចង់បន្ទោសឯងទៅវិញ ពុកទៀត ក៏គាត់មិនចេះប្រដៅវា គាត់មិនគិតអារកាត់ឲ្យត្រឹម ៗ ទៅទេ គាត់បែរទៅជារវល់តែលួងលោមវាទៅវិញ ៗ ការដែលគាត់មិនហ៊ានធ្វើឲ្យវាពិបាកចិត្តនោះ គួរឲ្យចង់សើចណាស់ ៗ

—ពុកមានដឹងរឿងថ្មីទេ? (ដោះជ្រូនិយាយទៅកាន់ឪពុក)

—ទេ រឿងអីទៅ ?

—ប៉ាមេស្ហាប៉ានាំប្រពន្ធប៉ាទៅស្រុក ដល់ប៉ាដឹងខ្លួនថា អាក់ស្ហាយតាមលបមើលប៉ា ប៉ាគេចបាត់ភ្លាមមួយរំពេច ។

នាងហិមណាលិនីឮដូច្នោះ ញ័រដៃទាល់តែកំពប់ទឹកតែដែលនាងលើកជូនឪពុក ។ ដោះជ្រូឃើញទាំងអស់ ព្រោះគេតាមសម្គាល់អាកប្បកិរិយានាងមិនដាក់ភ្នែក ។ នាងទំប្រត់ទប់ខ្លួនលើកៅអី ដោះជ្រូនិយាយបន្តទៅទៀត :

—ប៉ានាំគ្នារត់ដូច្នោះ ដូចជាពិបាកយល់ដែរ ។ ការដែលប៉ាបានធ្វើពីមុនមិនសូវជាអ្វីទេ ដល់ប៉ានាំគ្នារត់ . . . នោះបានន័យថា ប៉ាមានទោសមែន ប៉ុន្តែខ្ញុំមិនដឹងជាហិមណាលិនី គេយល់ដូចខ្ញុំដែរឬយ៉ាងម្តេចទេហ្នឹង . . . . ។

នាងស្ទុះក្រោកឡើង ឆ្លើយទាំងញ័រចំប្រប់ថា :

—ខ្ញុំមិនត្រូវការស្តាប់ភស្តុតាងអ្នកកល់គ្នាទេ បងចង់ដាក់ទោសឲ្យគេប៉ុន្មានក៏ដាក់ទៅ ខ្ញុំមិនមែនចៅក្រមទេ ។

- យី តើបងមិនមានករណីយកិច្ចទឹងជម្រះមនុស្ស ដែលត្រូវធ្វើជាប្ដីអូនឯងទេឬយ៉ាងម៉េច ?

– បងផ្ដាច់ក៏ផ្ដាច់ទៅ ប៉ុន្តែបងមិនអាចផ្ដាច់សេចក្ដីសម្រេចចិត្តខ្ញុំបានឡើយ ។

នាងយំរកនិយាយតទៅទៀតមិនកើត ឥពុកឃើញដូច្នោះ ទុនថើបមុខកូនដែលមានទឹកភ្នែកហូរពាសពេញ រួចដឹកដៃនាងចេញទៅក្រៅ ។

(នៅមានត)

# ចំនុករច្រៀងបុរាណខ្មែរ

យើងដឹងហើយថា ប្រជាជាតិខ្មែរធ្លាប់មានអារ្យធម៌ពីព្រេងនាយរៀងរាយមកហើយ ។ សិល្បៈនេះឯងជាមែកជាងមួយធំណាស់ក្នុងអារ្យធម៌ ហើយសិល្បៈនេះទៀតបែកចេញជាផ្នែកច្រើនណាស់ទៅទៀត ដូចជាផ្នែកខាងសិល្បៈចម្រៀង មានចំនុកច្រៀងនិងបទភ្លេងជាដើម ។ បើលើកយកចំនុកមកនិយាយក៏អាចចែកចេញបានជាច្រើនប្រភេទទៅទៀត តែក្នុងទីនេះយើងលើកយកតែប្រភេទចំនុកបុរាណមកផ្សាយជាដំបូង ។ គឺថាយើងចុះផ្សាយចំនុកចាស់ៗដែលយើងប្រមូលក្រងបានពីនិគមជនបទនានាក្នុងព្រះរាជាណាចក្រ ។

ដូច្នេះ, យើងសូមអំពាវនាវចំពោះអ្នកអានទូទៅ សូមមេត្តាជួយផ្ញើចំនុកច្រៀងបុរាណខ្មែរយើង ដែលអស់លោកអ្នកបានចេះចាំ ទោះតិចក្ដី

ច្រើនក្តី សូម្បីតែ ២-៣ បន្ទាត់ក៏ដោយ យើងនឹងចុះផ្សាយបន្ត ទៅ ដោយចុះនាមអ្នកផ្តល់ឯកសារនេះផង ។

## ចំនុកឆ្លោះឆ្លងស្រី-ប្រុស

ប- ឱម្លប់ដូងអើយ ដែលបងអង្គុយ បងអត់ងងុយ ចាំស្រីរៃ ។
ចិត្តបងតែចាំ ភ្នែកបងរំពៃ ចាំស្រីរៃ ចុះមកជួបបង ។
ស- មួយយប់មួយថ្ងៃ បានបីកម្រង រៃរចាំបង ទម្រាំខែលិច ។
ស្រមោចរាំខាំ សង្អាររាំទិច ទម្រាំខែលិច ដាច់ខ្យល់បងហើយ ។
ប- ថ្ងៃអើយអ្នកថ្ងៃ ថ្ងៃអើយអ្នកថ្ងៃ ខែក៏ដូចថ្ងៃ នរណាឲ្យថ្ងៃមក ។
ស- កាំភ្លើងចាំបែង ដាវវែងចាំប្រេក នរណាឲ្យថ្ងៃមក មិនដឹងខ្លួនស្លាប់ ។

នេះចំនុក ម្លប់ដូង សម្រាប់ប្រុសច្រៀងផ្តើម បើស្រីផ្តើមវិញ មានដូច្នេះ :

ស- ឱម្លប់ដូងអើយ ដែលប្អូនធ្លាប់ជ្រក ចាំប្រុសពទូក ព្រលឹងថ្ងើមថ្ងៃ ។
ចិត្តប្អូនតែចាំ ភ្នែកប្អូនរំពៃ ចាំអ្នកប្រុសថ្ងៃ ថាមកជួបប្អូន ។
ប- បងបិតបន្ទោះ មិនទាន់គ្រប់ថ្នូន បងបិតចាំអូន ទម្រាំខែលិច ។
ស- ស្រមោចរាំខាំ សង្អាររាំទិច ទម្រាំខែលិច ដាច់ខ្យល់ប្អូនហើយ ។
ប- ថ្ងៃអើយស្រីថ្ងៃ ថ្ងៃអើយស្រីថ្ងៃ ខែក៏ដូចថ្ងៃ នរណាឲ្យថ្ងៃមក ។
ឪចាំផ្លូវកែង ម៉ែចាំស្លាក់ប្រេក ម៉េចក៏ថ្ងៃមក នៅពេលថ្ងារនេះ ។

# ការប្រយុទ្ធ និង មធ្យោបាយដោះស្រាយសេចក្ដីល្ងង់

លោក ក៉ាយ ប៊ុកា រៀបរៀង

---

## ១. បុព្វហេតុនៃការល្ងង់

បុព្វហេតុនៃការល្ងង់គឺ :

ក)- មកពីបិតាមាតាក្រខោកទ្រព្យមិនអាចឲ្យកូនសិក្សាបាន ។

ខ)- មកពីបុត្រធីតាបានចូលរៀនសាលា តែខ្ជិលប្រអូសសិក្សាមិនបានគ្រប់គ្រាន់តាមកម្មវិធីសិក្សា ។

គ)- មកពីចរិយាបុត្រធីតាប្រព្រឹត្តធម៌សេពគប់ និងពួកពាលទុច្ចរិតអបាយមុខ ។ល។

ក)- បិតាមាតាដែលក្រទ្រព្យមិនអាចបញ្ជូនកូន ឲ្យទៅសិក្សាឯសាលារៀនបាន ព្រោះគ្មានប្រាក់កាសទិញសៀវភៅសរសេរ សៀវភៅសម្រាប់សិក្សាសិក្ខូបករណ៍ សំលៀកបំពាក់ឲ្យបានសមរម្យ ។ល។ ម្ល៉ោះហើយត្រូវទុកបុត្រធីតានៅគេហដ្ឋានសម្រាប់ជួយថែទាំផ្ទះសម្បែង មើលប្អូនតូច ៗ ដាំបាយធ្វើម្ហូបអាហារ ដងទឹកពុសអុស ជួនកាលទៅជួយភ្ជួររាស់ដកស្ទូងច្រូតកាត់ ឬទៅជួយដាំដំណាំផ្សេង ៗ និងជួយមើលគោក្របី ៗ ដោយហេតុនេះហើយ បានជាបុត្រធីតាមិនបានសិក្សា គ្មានចំណេះ ត្រឡប់ជាមនុស្សល្ងង់ សមដូចលោកអ្នកឧកញ៉ាសុត្តន្តប្រីជាឥន្ទ្របានពោលក្នុងលោកនីតិបករណ៍ថា :

“មានកូនមិនឲ្យកូនសូត្ររៀន ចំណេះរបៀនការនានា មាតាលោកថាជាវេរា បិតាទុកជាសត្រូវធំ ៗ កូនពេញរូបពាលពត់មិនឡើង ហៅថាមិនថ្កើងក្នុងជំនុំ ប្រៀបដូចកុកគ្រោងចូលទ្រទំកណ្ដាលជំនុំនៃពពួកហង្ស” ៗ

តាមពិតបិតាមាតាមានបំណងចង់ឲ្យបុត្រធីតាមានវិជ្ជាណាស់ តែខ្វះក្រភោគទ្រព្យមិនអាចនឹងទំនុកបម្រុងកូនសិក្សារៀនសូត្រ បានដោយស្រួល ៗ បើដូច្នេះកូនល្ងង់នេះមកពីអ្វី? ៗ ចំពោះរឿងនេះ ខ្ញុំបានសង្កេតឃើញថា មានសិស្សខ្លះជាកូនអ្នកក្រីក្រលំបាក ដោយសារចង់បានចំណេះវិជ្ជា ក៏ស៊ូថ្ងៃនៅសិក្សារៀនសូត្រ, យប់ធាក់ត្រីចក្រយានយកប្រាក់មកទិញសៀវភៅសរសេរគ្រឿងប្រដាប់ប្រដាគ្រប់ ព្រោះសិស្សនេះយល់ថា ការល្ងង់នាំឲ្យថោកទាប ឲ្យគ្រួសារអាប់ឱន ឲ្យអ្នកផងទាំងពួងប្រមាថមើលងាយឲ្យលិចលង់ទៅក្នុងទីងងឹតអន្ធការ ដូចជាមានសុភាសិតក្នុងហិតោបទេសដែលព្រះវិរិយបណ្ឌិត ភិក្ខុ ប៉ាង ខាត់ បានប្រែមកថា :

“បណ្ដាកូន ៣ ពួកគឺកូនមិនទាន់កើត ១ ពួក កូនកើតហើយស្លាប់ទៅវិញ ១ ពួក និងកូនល្ងង់ ១ ពួក, កូនពីរពួកខាងដើមជាកូនគាប់ប្រសើរ ពួកកូនទីបីមិនប្រសើរឡើយ ព្រោះថាកូនពីរពួកខាងដើម ធ្វើទុក្ខព្រួយតែបន្តិច ក៏អស់ហើយទៅ ឯពួកកូនក្រោយទីបី ធ្វើទុក្ខមាតាបិតាឲ្យ

មែនពិត កូនកើតមកល្ងង់ឲ្យទុក្ខទោសបិតាមាតា គ្រួសារ, ជាតិ, សាសនា អស់មួយជីវិត ។ ការល្ងង់ប្រៀបដូចជាច្រេះដែលស៊ីដែកអស់យ៉ាងណាមិញ, ការល្ងង់ក៏ស៊ីកិត្តិនាមខ្លួន, គ្រួសារ, កិត្តិសព្ទរបស់ជាតិមិនឲ្យងើបមុខ កណ្ដាលទីប្រជុំជនបាន, មិនឲ្យមានមិត្ត, មិនមានអ្នកណាទៅពឹងពាក់, ខ្វះសេចក្ដីរាប់អាន ។

«កូនមានគុណតាប់តែម្នាក់ជាកូនប្រសើរ កូនល្ងង់រាប់រយមិនប្រសើរទេ ដូចព្រះចន្ទតែមួយដួង អាចកំចាត់ងងឹតអន្ធការបាន កងតារាទាំងឡាយកំចាត់បង់ងងឹតមិនបានឡើយ ។»

មែនពិត កូនមានគុណតាប់ម្នាក់ជាកូនប្រសើរ គឺកូនដែលមានវិជ្ជាទាំងផ្លូវលោកផ្លូវធម៌ ជាកូនមានគុណតាប់ថ្លៃថ្លា ជាកូនមានពលភាពដ៏វិសេសវិសាលជាកូនមគ្គុទេសក៍ ដឹកនាំគ្រួសារជាតិទៅរកវឌ្ឍនភាព, សន្តិសុខ, ជាកូនបានចេញមុខទៅក្នុងមហាសន្និបាតក្នុងឆាកអន្តរជាតិជាដើម ។

តែប្រយ័ត្ន ! បើកូននោះក៏ល្ងង់ដឹងខ្លួនជាល្ងង់ពិត ទើបកែជាបណ្ឌិតបាន, កូនណាក៏ល្ងង់ ថែមអួតអាងខ្លួនថាចេះ កូននោះក៏ស្ថិតនៅជាល្ងង់មួយជីវិត កែខ្លួនមិនរួចពីហិនជាតិឡើយ ។

១) មកពីបុត្រធីតាបានចូលរៀនសាលាតែខ្ជិលច្រអូស សិក្សាមិនបានគ្រប់គ្រាន់តាមកម្មវិធីសិក្សា

កូនខ្ជិលរៀនសូត្រនេះ ក៏ជាគុណវិបត្តិមួយធំ ចំពោះបិតាមាតាគ្រួសារជាតិ ប្រទេស ។ល។ កូនខ្ជិលនាំមិនឲ្យមានចំណេះវិជ្ជាដូចមនុស្សស្ថិតនៅក្នុងទីងងឹតអន្ធការ តែស្គាល់តែពណ៌ខ្មៅអាចម៍អួរ មិនដែលជួបពន្លឺព្រះអាទិត្យម្ដងសោះឡើយ ព្រោះថា : "ខ្ជិលរកមិនមាន, ខ្ជិលរៀនមិនចេះ ។ "

ខ្ជិលរក គឺខ្ជិលរកវិជ្ជាជីវៈរបរផ្សេងៗ, ដេកនៅផ្ទះ ចាំព្រេងសំណាង តើប្រាក់នឹងហូរចូលមាត់មកកាលណា! ។ ខ្ជិលធ្វើស្រែកាប់ចំការ ធ្វើពាណិជ្ជកម្ម, ឧស្សាហកម្ម នឹងមានភោគទ្រព្យពីណាមក ។ កុំគិតថាអ្នកធាក់ចក្រយានជារបរថោកទាប អ្នកចាក់សម្រាមជារបរមិនសមគួរ. ធម្មតារបរទាំងឡាយ នៅលើផែនដីគ្មានរបរណាថោកទាបទេ. មានតែជនដែលខ្ជិលច្រអូស មិនប្រកបការងារជាជនថោកទាប ។

បើដឹងខ្លួនថាខ្ជិលនោះវាចូលមកយាយីក្នុងសន្ដានចិត្តហើយ ត្រូវយកឧស្សាហ៍មកកំចាត់បង់ភ្លាមកុំបង្អង់ឲ្យវាដុះស្លែ ទើបកែជាខាងក្រោយៗ បាបធម៌និងអកុសលទាំងឡាយ តែងកើតឡើងដោយការខ្ជិលច្រអូសនេះឯង ព្រោះតែកាលណាខ្ជិល ហើយបានប្រាក់កាសពីណាមកចិញ្ចឹមជីវិតឲ្យបានស្រួល ។ ម្ល៉ោះហើយត្រូវទៅរកបាយហូបចំណីតាមទីកៀនកោះ ឬក៏ទៅលួចប្លន់គេ ឬក៏ទៅពឹងពាក់មិត្ត ឬក៏ទៅនៅជ្រកកោន

ក្រោមមួយបងប្អូនដែលជាមន្ត្រី បុរាណជាដើម ។ ខ្លួននេះនាំឲ្យកើតក្ដៅ

ក្តុហក ប្រព្រឹត្តអបាយមុខគ្រប់យ៉ាង.... ។ល។

ក) មកពីចរិយាបុត្រធីតា ប្រព្រឹត្តធម៌សេពគប់នឹងពួកពាលទុច្ចរិត

អបាយមុខ.... ។ល។

ធម៌សេពគប់ ជាមូលដ្ឋាននៃការប្រព្រឹត្តប្រតិបត្តិ, សេពគប់ពួក

បណ្ឌិតខ្លួនបានជាបណ្ឌិត; សេពគប់ពួកពាលខ្លួនទៅជាពាល ។ កូនចៅ

ទាំងឡាយត្រូវកុំភ្លេចថា ធម៌សេពគប់នេះ ជាប្រធាននៃជីវិតអ្នកតាំងពី

សម័យបច្ចុប្បន្នរហូតតទៅអនាគត ព្រោះថា ចិត្ត និងទម្លាប់ចិត្ត ជាមូល-

ដ្ឋាននៃចរិយា បើទម្លាប់ចិត្តខាងបាន មុខជាទៅខាងបាន ហើយមនុស្ស

នោះ មុខជាទៅខាងពាលទុច្ចរិតមិនខាន ។

មនុស្សខ្ជិលតែងវេទនាខ្លួនឲ្យធ្លាក់ ទៅក្នុងអបាយមុខ ជាមនុស្ស

ពាល អ្នសប្បុរស ទុច្ចរិត ។ មនុស្សពាលជាទីស្អប់ខ្ពើមនៃមហាជន

ទាំងឡាយ តែបើមនុស្សពាលនោះ ដឹងខ្លួនថាពាលពិត ទើបអាចជាកែ

ទៅជាបណ្ឌិតបាន សមដូចពុទ្ធភាសិតថា ៖

"អ្នកណាជាមនុស្សពាល ហើយដឹងនូវភាវៈនៃខ្លួន ថាពាលអ្នកនោះ

នឹងត្រឡប់ជាបណ្ឌិតបាន ,, ។

២) មធ្យោបាយដើម្បីកំចាត់ការល្ងង់

មធ្យោបាយដើម្បីកំចាត់ការល្ងង់មាន ៣ យ៉ាង គឺ :

ក ). ជួយឧបត្ថម្ភពង្រីកនូវមជ្ឈដ្ឋានធ្វើអក្ខរកម្ម ឲ្យបានទូទៅតាមភូមិទាំងអស់ ។

ខ ) ទំនុកបំរុងការស្ថាបនាគ្រឹះស្ថានសិក្សា តាមរាជធានី, ក្រុង, ខេត្ត, ស្រុក, សង្កាត់, ភូមិ ។

គ ) ជួយពង្រីក ឬការស្ថាបនា, នូវអង្គការផ្សេងៗ ជាការផ្សាយនូវវប្បធម៌-អារ្យធម៌ ដូចជា សមាគមពង្រីកការសិក្សា, សមាគមកសាងវត្តអារាម ឬអប់រំអ្នកស្រុកជាដើម ។

មធ្យោបាយទាំងប៉ុន្មានដែលរាប់រៀបត្រួសៗនេះ សុទ្ធសឹងតែកើតឡើងតាមនយោបាយកសាងជាតិ ដែលសម្តេចព្រះប្រមុខរដ្ឋ ទ្រង់បង្កើតឡើងស្រាប់ហើយ ឯអ្នកយល់ អ្នកប្រាជ្ញាឲ្យបានសម្រេចដូចបំណងនោះគ្រាន់តែរួបរួមគ្នាដង្ហែតាមព្រះរាជនយោបាយ ដ៏ប្រសើរនេះទៅ ក៏ពិតជាបានផលភ្លាម ។

*

* *

# សិលាចារឹកព្រះគោ

( គ. ស. ៨៩៣ )

សិលាចារឹកព្រះគោនេះ មានពីរផ្នែក មួយផ្នែកជាភាសាសំស្ក្រឹត មានចំនួន ៤៣ បន្ទាត់ គ.ស. ៨៧៩ ។ សិលាចារឹកជាភាសាខ្មែរ មាន ៣១ បន្ទាត់ គ.ស. ៨៩៣ ។ សិលាចារឹកទាំងពីរនេះ តាំងនៅក្នុងខេត្តសៀមរាប នៅតំបន់រលួស ។ សិលាចារឹកទាំងភាសាសំស្ក្រឹតនិងភាសាខ្មែរ មានរូបរាងតួអក្សរនៅច្បាស់ល្អណាស់ ដូចខ្ញុំជូនមកនេះស្រាប់ តែខាងសិលាចារឹកជាភាសាសំស្ក្រឹត ខ្ញុំមិនបានយកមកជូនជាឧទាហរណ៍ទេ ។

ដើម្បីឲ្យងាយក្នុងការអានសិលាចារឹកនេះ សូមអានតាមលេខ ដែលខ្ញុំចុះនៅតាមសិលាចារឹកគំរូដើមនិងសិលាចារឹក ដែលសរសេរមកតាមបែបអក្សរសម័យសព្វថ្ងៃ ។

១. [illegible]
២. [illegible]
៣ [illegible]
៤ [illegible]
៥ [illegible]
៦. [illegible]
៧ [illegible]
៨ [illegible]
៩ [illegible]
១០ [illegible]
១១ [illegible]
១២ [illegible]
១៣ [illegible]
១៤ [illegible]
១៥ [illegible]
១៦ [illegible]

[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]

## សិលាចារឹកព្រះគោ

១_ ៨១៥ ឝកបិកេតវៃឝាខគុ ជ្រ អាជ្ញាធ្លីជេងវ្រះកម្រតេង
អញគ្រឹយគោវម្មិទេវធ្វូនមាស៑ប្រាក៑អ្នក៑ប្លេ

២- យវ្រះកុដិមន៑ធ្វូន៑តវ្រះកម្រតេងអញតបរមេឝ្វរវ្រះស្វៃប្រុះ
អគ្រោមមាស៑ជេងមាស៑ ១ គាយត្រឹយមាស៑ស្នាក ១ គាយត្រឹ

៣_ យប្រាក៑ស្នាក ១ គ្វេត ១ វ្រះគទា ១ ឝ្វេតិហេរ ១ អាយោគ ១ ប្អុប
១ បច្ឆយ៑ ១ ភាជនបំទោង៑ប្រាក៑ ១ ភាជនស្រេះ ៤ ស្មោក៑ ៦ ក
ទាហ ៥ជេងត្រឹបាទ ២

៤_ ជេង៑បរស្ម ២ ជេង៑ទ្យាន ២ ត្មោបិបស៑ ២ ។ ក្ញុំគតិស្រុ
ក៑សំពោង៑អ៑រះសំអប៑ យោមគ្យារ ១ យោជង្វេរ ១ យោ
ប្យោង៑ ១ យោជឹរ ១ យោកំវៃ ១ គ្វាលុប

៥_ ទ្វហ ១ គ្វាល៑កន៑តិន៑ ១ គ្វាល៑ក្រោ ១ តៃតុន៑ ១ តៃរតកំ
ប្រួត៑ ១ លបបិន្លស៑ ១ តៃអត្យង ១ តៃអលង្កាយ៑ ១ ល
ប៑ភៀ ១ សរតិកស្នុំ ១ តៃក្រោ ១ យោកញ្ជ៊ែរ ១ គ្វាស៑កំជ្រៀ

៦_ គ្វាល៑ឝារាយក ១ លប៑ប៉េះស៑ ១ តៃកំប៉ុ ១ លប៑បំយេ

តៃកុំ ១ បិណ្ឌអំរៈ ១ ឆុអំរៈហយោ ៧ គ្វាល៏ ៥ តៃ ៤
លបី ១ សិរតិ១ តៃរតិ ១ តៃអ ២ ប្រុំម ២០-៤៖ វ្រកតគិ
៧_ ស្រុកអភិនវគ្រាមប្រមានជេងតវាញអំរះអន្រោក ១ យោ
ត្តបី១ យោវិប្ណុភរិ១ យោអ្គត ១ យោកំព្រើ ១ យោបន្ទាន
១ យោហរភារិ ១ យោកន្លេង ១ យោបន
៨_ ទន ១ យោកន្ទុប ១ យោទលុះ ១ តៃធ្វិក ១ គ្វាល់កុំ ១
យោកនអញ្ញ១តៃជំអរ ១ តៃបោប្ត១ តៃរកកំប្រ្វតអ្យ្វាក១
តៃកំវៃ ១ គ្វាល់សំអប ១ គ្វាល់កញ្ញ ១ តៃក្បុណ្ណរតី ១ សិរ
៩_ កកំបញ្ញ១ សិបោ១ កន អិស១ សិរតតង្កុ១ លបអ្នប ១
លបកន្សោ ១ តៃវ្រះគ្រិយ៉ ១ សិបោកន អស១ តៃរតប្ញ
ត ១ លបវិចិត្រ១ លបកប្តេប១ ប្រុំ២០-១០-២៰ អំរះវ្រះ
១០_ហៅយ ១ យោបន្សំ ១ គ្វាល់ក្បេ ១ តៃកំបង ១ តៃបោក
ន-អត ១ លបកន - អំ ១ តៃក្ឋ្ន ១ តៃកន-ឳយ ១ តៃ
កំដាប ១ តៃបោកន-អស ១ លបត្កប ១ តៃលង្គាយ ១
១១_តៃបោត្គល ១ សិរតព្រៅ ១ តៃក្ឋ្នក ១ តៃបំហោប ១

សិរតម្នាក់គ្រយ ១ តែសគ្គាប ១ តែបោប្បត ១ សិរតកញ្ញា ១ តែអគ្គត ១ តែព្រះធម្ម ១ តែសង្ការ ១ តែកត្រុក ១ តែក្ដិត ១ តែរ

១២-រ ១ តែរតបន្ទន ១ តែស្មៅ ១ សិរតសំអប ១ សិបោអំវិល ១ ប្រំម ២០- ០ ។ អំរះសុគជិភ ១ យោកញ្ញ ១ យោសំអប ១ យោប្បេង ១ តែកញ្ញ ១ សិ បោមាញ ១ តែបោបំបេង ១ តែ

១៣- រតកនអំ ១ លបត្តន ១ លបកំវៃ ១ គ្នាលកន្ទោញ ១ តែនាង ១ សិបោសិទ្ធិវរ ១ តែកន្តេង ១ តែទ្ធស ១ សិបោគិរវុបី ១ តែអទេគ្រីយ ១ តែរតកន្ទុះ ១ តៃ តែអសំគោះ ១ តែអ

១៤-កុលគ្រីយ ១ តៃ រត្នាវតី ១ តែកន្ធិ ១ តែអកន្លេង ១ លបកញ្ញន ១ តែទារំបួស ១ តែ៖រាគទេវ ១ តែកន អសី ១ ប្រំ ២០-៧ ។ បិណ្ឌអំរះ ៣ ឥអំរះបាយោ ១០-៧ គ្នាស៊ ៦ តៃ ២០-៨ លប ១០ សិរត ៦ តៃ

១៥- រត ៥ លិបោ ៦ តែបោ ៦ តែអ ៥ ប្រំម ៨០-៩-០

អ្នកប្ដេស្រុកសំរោងសោតិយោធនាគ្រូ ១ យោកនេ្យ ១
តែឧត្បល ១ គ្វាលិកន្ទេង ១-០ ប្រុំម អ្នកវ្រះកុដិតោ
យិឧត្តរប្ដេស្រុកអន្ទេ ២

១៦- អំរះ ៤ នុអំរះហាយោ ២០-៤ គ្វាលិ ១០-១ តែ ២០
១០-២ លបិ ១០-៤ សិរតិ ៧ តែរតី ៦ សិបៅ ៦ តែ ៦
តែអ ៧ ប្រុំម ១០០-១០-៣ ។ វ្រះកុដិតោយិ ទក្សិណា
មតិជូន្តវ្រះកម្រតេងអញ

១៧· គ្រឹប្ជប៊ីរីន្ទ្រេគ្វរវ្រះស្បែប្យហ ១ គាយត្រិយមាស្នក៏ ១
គាយត្រិយប្រក្នក៏ ១ គ្វេត ១ វ្រះគទា ១ វតិហារ ១ អា
យោគ ១ ប្ជប ១ បន្ទាយិ ១ រោទិបំនោងប្រក់រោទិស្រេះ៤
គទា

១៨– ហា ៥ ស្មោក ៦ ជេងត្រិបាទ ២ ជេងបរស្ប ១ ជេង
ទ្យាន ១ ត្មោបិបសិ ២-០ វ្នកតគិស្រុកតិបលិប្រមានិម
ល្បាងអំរះកន្ទាសិ ១ យោបិរោស ១ យោសុភិក្ស ១ យោ
ប្ពក ១ យោក្រោ ១ តែកំ

១៩– ប្រុ១ តែបន្ទានិ១ គ្វាលិទប្តិប ១ សិរតិន្ទេយិ២ តែលង្កះ២

តែរត៌ក៌រី ១ តែកំបង ១ គ្វាលិប្ចេ ១ លិបៀកញ្ញា ១ តែក្រៅ ១ គ្វាលិកញ្ញ ២ លបិកំរ៉ៃ ១ គ្វាលិគ្គបិ ២ តែរតិប្បោសិ ១ តែរតិសំ

២០–អបិ ១ តែបោកទិអសិ ១ តែតង្កេ ១ តែសម្រប្ ១ គ្វាលិកទ្យាន ១ សិបៀកឆ្នោក ១ តែស្មោក ១ សិបៀតង្កេ ១ តែកក្សា ១ សិរតិបន្ទនី សិបៀកន្លហ៊ា ១ តែក្រៅសោតិ ១ តែរតិអគ្គិតិ ១ តែរតិបន្ទនិ ១

២១–យោកតិអសិ ១ តែកន្លាង ១ គ្វាលិគ្រឹ ១ តែអគ្រោក ១ បិណ្ឌាអំរះ ១ គុអំរះហ៊ោយោ ៦ គ្វាលិ ៦ តែ ១០-២-លបី ១ សិរតិ ២ តែរតិ ៥ សិបៀ ៥ តែបៀ ១ ប្សុំមែ ២០-១០-៧-០ វ្លក៏តកិស្រុកិរិវេទ្រុបដ្ឋន

២២–ប្រមាតិផេធិវ្លអំរះមហោទ្រ ១ យោគិរុបី ១ យោកំបិតិ ១ យោគ្រឹ ១ គ្វាលិហរី ១ គ្វាលិឡបិកំរីសិ ១ តែសុធិន ១ តែគុបិយ ១ តែរតិគ្រឹទេរី ១ តែសរស្វតី ១ លបិបន្ទនិ ១ លិបៀមតិរា

២៣–ធិ ១ គ្វាលកិន្តេង៏ ១ គ្វាលគ្គិបិ ១ តែសុភទ្រា ១ តែរតិកន

អសេ១ តែបញ្ញសិ១ លប៉អ្អិតិ១ តែរតិកន្ទុប៉១ តែពៅកគ្វី១ តែផ្ចិស ១ គ្វាលិទ្យាចក្តេង ១ សិព្រៅនិលា ១ យោទ អាទ ១ យោមានុ១ប្រុំម ២០-៩

២៤- អំបុះ មករទ្ធជិ១ សិអកំរាសិ ១ យោក្រៅ ១ យោវេទ ១ យោប្រៀង ១ យោត្រៃ ១ យោព្រោស៊ិ ១ តែអលក្ខ័ទេវី ១ តែបិតិ ១ តែមតិ១ តែពៅកត្តេង១ តែកសុន្ទ១ តែអរុទទិ១ តែកលគ១ គ្វាលកញ្ញា១

២៥-តែអ្សស៊ិ១ តែកំរី១តែបន្ត្រៃ១ គ្វាលិបន្ទួន១សិរកិកំបិតិ១ តែក្រុមទេវី ១ តែផ្ទិកិ ១ លប៉ធលទេវី ១ គ្វាលិជង្ហេរ១ តែអ្គតិ១តែបុ្ឌលិ១ លប៉កគ្រេន១ គ្វាលិកញ្ញី១ សិរតិប្រេទុ១ សិព្រោកញ្ញ១

២៦-តែធម្ម១ លប៉ក្រៅ១ តែទក្សិណាទេវី១ តែបំនង់១ តែកញ្ញោស៊ិ១ តែសន្ទរ៉ុ១គ្វាលិហរិស្វទនិ១ ប្រុំម២០-១០ ៣-០ បិណ្ឌអំរះ ២ នុអំរះ ៣ យោ ១០.២ គ្វាលិ ៨ គ្វាលិទ្យប៉២តែ២៨.២ លប៉ ៩ សិរតិ ២ តែរតិ ៣

២៧- សិពៅ ៣ តែមៅ ៤ សិអ១តែអ១ ប្រុំម ៦០.២០ រុក្ខ

តគិស្រុកស្តុកកន្ទេលប្រិតគ្រែម្តបុរអំរះ វជិតករ១យោ
កន្សោ១ យោបទ្រភាវិ១ យោកត្ត១ យោគិរិភាវ១យោ
ស្នោស៊ី១យោរុបិភាវិ១ យោ

២៨- ភាជិអរ ១ យោលំងាប៊ិ១ យោលង្កះ១ យោជំនតិ១
យោមហោត្រភាវិ១ តែកព្ហោ១ តែកព្ហោង៍១ តែគ្រវិទេ
វិ១តែតាង៍១ តែស្នោស១ កិបសិ១ តែកន្ធ១ តែតាត៍
សោតិ១ តែកំប្រួគ១ តែកំបិតិ១

២៩- គ្វាល៊ិកញ្ញា១ លបិកតិអសិ១ ស៊ិរតិបន្ទសិ១ តែប្ញូគ១
លបិកតិអសិ១ លបិកំបង១ តែកន្សតិ១ គ្វាលិកន្ទោញ
១លបិកំបតិ១ បិណ្ឌាអំរះ១ នុតំរះបាយោ ១០.២គ្វាលី២
តែ១០.២ លបិ៤ សិរតិ១

៣០- ប្ញូ២០.០.១១០ ប្ញូម៊ិអ្នកំប្រះកុដ៊ីគោយ៉ទក្សីណាប្លេស្រុក៍
អន្លេា អំរះ៤នុអំរះបាយោ២០.១០ គ្វាលិ១០.៦ គ្វាលិ
ទ្សូប៊ិ២តែ៤០.៦ លបិ១០ សិរតិ៥ តែរតិ៨ សិបោត
តែបោ៣សិអ១ តែ

៣១- អរ២ប្ញូ១០០.២០.១០ ០ប្ញូរ១តិភាគតប្រះកុដ៊ីអន្លេ ២០

ពន្យល់ពាក្យពិបាក១:

១-២ បំកេ បំកើត

វែកាខ ពិសាខ

ប្រក ប្រាក់

ប៉ួយ ថ្លៃ

ជូន ជូន

វក្ក ពាក់

៣- គពា ដំបង

ស្មោក សួក

៤-១៣ ជាឈ្មោះខ្ញុំកំដរបាវព្រាវ ដែលមានងារជា

យោ, តៃ, គ្វាល (ឃ្វាល) ។

ខ្ញុំសូមជូនទូវចំនួននិងការពប់លេខខ្មែរខ្លះ ដែលមាននៅក្នុងសិលាចារឹកព្រះគោ ។ សូមលោកអានសិលាចារឹកត្រង់លេខ :

៩ = ប៉ៀ ២០-១០-២ អានថា ផៀជា ៣២

១២ = ប៉ៀម ២០-១០ អានថា ផៀជា ៣០

១៤ = ប៉ៀ ២០-៧ អានថា ផៀជា ២៧

យោ ១០-៧ អានថា យោ ១៧

តែ ២០-៨ អានថា តែ ២៨

១៥ = ប្រំម ៨០-៥ អានថា ផ្រំ ៨៥

១៦ = យោ ៦០-៦ អានថា យោ ៦៦

គ្មាល ១០-១ អានថា ឃ្មាល ១១

តែ ២០-១០-២ អានថា តែ ៣២

លប ១០-៤ អានថា លប ១៤

ប្រំម ១០០-១·៣ អានថា ផ្រំថា ១១៣

ឯលេខខ្មែរដែលមាននៅក្នុងសិលាចារឹកព្រះគោនោះ មានលំនាំដូចខាងក្រោមនេះ ៗ



## ផ្នែកកំណត់-ប្រវត្តិការណ៍

ពុទ្ធសាសនបណ្ឌិត្យ
ក្រុមទំនៀមទម្លាប់ខ្មែរ
ក្រុងភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

# ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៩

នៅឆមាសទី ២ គឺតាំងពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦៩ ក្រុមទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ ដោយបើកការប្រឡងប្រជែង ២ មុខគឺ :

១– ចម្រៀងប្រជាប្រិយ

២– ទោសនិងការផ្តន្ទាតាមរបៀបបុរាណ

*ដូច្នេះអស់លោក-អ្នកចេះដឹងទាំងឡាយ ជាស្ត្រី ជាបុរស ឬ ជាបព្វជិតក្តីដែលស្ម័គ្រចិត្តប្រឡង, សូមសរសេរតែងអត្ថបទ តាមគោលបញ្ហាដូចរៀបរាបខាងមុខ*

ឱ្យការណ៍ទៅក្រុមទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ យ៉ាងយូរបំផុត ត្រឹមថ្ងៃដាច់ខែ ធ្នូ ឆ្នាំ ១៩៦៩ ។

## ការប្រឡងប្រជែងនេះមានរង្វាន់ ៤ ថ្នាក់ :

លេខ ១ . . . . . ១.០០០រ០០

លេខ ២ . . . . . ៨០០រ០០

លេខ ៣ . . . . . ៦០០រ០០

លេខ ៤ . . . . . ៤០០រ០០

*បើអស់លោក-អ្នក ត្រូវការសរសេរអត្ថបទដូចខាងលើនេះទៅដាក់ប្រឡងសូមសរសេរលើសៀវភៅ កុំសរសេរលើក្រដាស តែ ១ សន្ទឹក ឬ ២ សន្ទឹកឡើយ ហើយសូមសរសេរនាម និង ទីលំនៅរបស់ខ្លួនឲ្យច្បាស់លាស់ លើក្រដាសមួយបន្ទឹកដោយឡែក ដាក់ក្នុងស្រោមជាមួយនឹងអត្ថបទនោះ យកទៅឲ្យក្រុមជំនុំផ្ទាល់ខ្លួនក៏បានៈផ្ញើទៅតាមរយៈប្រៃសណីយ៍ក៏បាន ដោយការខ្ទង់សំបុត្រថា :*

ពុទ្ធសាសនបណ្ឌិត្យ
ការិយាល័យទំនៀមទម្លាប់

## គោលបញ្ហានៃការប្រឡង

## ១- អំពីចម្រៀងប្រជាប្រិយ

*ដើម្បីកុំឲ្យមានការភ័ន្តច្រឡំ ក្រុមទំនៀមទម្លាប់ សូមជំរាបអស់*

លោក-អ្នកដែលស្ម័គ្រចិត្តសរសេរទៅប្រឡងឲ្យបានជ្រាបថា ចម្រៀងប្រជាប្រិយ ដែលក្រុមទំនៀមទម្លាប់ ត្រូវការរើសយកជាឯកសារក្នុងលើកនេះ មិនមែនជាទំនុកដែលក្រុមការ៉ៃយ៉ ឬប្រូបកៃ ច្រៀងលែបខាយឲ្យគ្នានោះទេ គឺជាទំនុកខ្លីៗ ដែលសម័យបុរាណ តែងនិយមច្រៀងលេង នៅពេលទំនេរ នៅពេលធ្វើការងារផ្សេងៗ ដូចជាបំពេរប្អូន-ស្ទូងស្រូវ-បោកស្រូវ-រវៃសូត្រនាពេលយប់ នៅពេលអុំទូក ឬ នៅពេលលេងល្បែង ដូចជាបោះឈូងនៅរដូវចូលឆ្នាំជាដើម . . . . ។

**ពេលជាន់អារក្ស:—** មានទំនុកអ្វីខ្លះ ? សម្រាប់ច្រៀងបញ្ចាន់អារក្ស ? គេច្រៀងបញ្ចាន់នៅពេលណាខ្លះ? ពេលមានជម្ងឺ? ពេលឡើងរេន? ពេលដាក់ទូកថ្មីពេលចេញទៅប្រណាំងទូក ? សូមសរសេរពាក្យចម្រៀងទាំងនោះឲ្យច្បាស់លាស់ផង ។

**ពេលរៀបអាវាហវិវាហមង្គល:—** សូមអធិប្បាយពន្យល់ថា ចម្រៀងណា គេច្រៀងនៅពេលណា (លើកកំណត់-សំពះមេបា-កាត់សក់-សែនចងដៃ-លៀងគ្រៀវ-បុកល័ក្ខ-ធ្វើធ្មេញ-ដោតផ្កាស្លា-កាត់ខាន់ស្លា-សំពះពេលា-ពំបើកវាំងនន-ផ្ទឹម តោងជាយស្បៃចូលបន្ទប់ . . . . ។ល។)

**ពោរពុំ—** ក្មេងស្រី ឬ ប្រុស មានទំនុកច្រៀងឬទេ ? ទំនុកថាម៉េចខ្លះ ?

ពេលបញ្ចូល-បញ្ចេញម្លប់កូនស្រី និង បំបួសនាគ:– មាន លេងក្មេងនិងចំនុកច្រៀងឬទេ? តើចំនុកច្រៀង និងក្មេងអ្វីខ្លះ? សូម សរសេរប្រាប់ផង ។

ពេលឡើងអ្នកតា:– តើនៅពេលធ្វើពិធីឡើងអ្នកតា គេមានលេង ក្មេងអ្វី? ចំនុកច្រៀងអ្វី? ជាម៉េចខ្លះ? សូមប្រាប់ឈ្មោះ និងទីកន្លែងដែល លោកអ្នកបានឃើញ ។

សូមអធិប្បាយអំពីចម្រៀងទាក់ទងដោយជនបរទេស . ទាក់ទងនឹង ការងារទាក់ទងនឹងផ្ទះសម្បែង - ទាក់ទងនឹងស្នេហា - ចំនុកច្រៀងចំអក ឲ្យប្រុស - ស្រី ឬ ឲ្យមេម៉ាយ, មនុស្សចាស់ ឬបព្វជិត, ឲ្យអ្នកក្រុង ឬ អ្នកស្រែ ។ល។ ចំនុកច្រៀងរិះគន់ជនបរទេសមាន យួន - ចិន - បារាំង ជាដើម ។ សូមប្រាប់អំពីដើមកំណើតនៃចម្រៀងទាំងនោះផងថា តើ មានដើមកំណើតពីណាមក ? បើមានរឿងព្រេងប្រាព្ធ ក៏សូមនិយាយ ផងកុំខាន ។

## ២- ទោសនិងការផ្តន្ទាតាមរបៀបបុរាណ

សូមលោក អ្នកប្រឡង អធិប្បាយអំពីទោស និង ការផ្តន្ទាទោស តាមដែលលោកអ្នកធ្លាប់បានឮចាស់ៗ ដំណាល និង តាមដែលលោកអ្នក ធ្លាប់បានឃើញ, សូមអធិប្បាយតាំងពីទោសបន្តិចបន្តួច រហូតដល់ទោស ប្រហារជីវិតបង់?

ព្រះគេថា : មានទោសម្យ៉ាង ហៅថា ទោស «គន្ទង់ខ្ចប់» តើលោកអ្នកធ្លាប់បានដឹងទេ? ទោសនេះដូចម្ដេចខ្លះ? ទោសវាយក៏វ, ចងគ្រពើ, ដាក់ឃ្នាងបណ្ដើរឲ្យធ្វើការ, ទោសដាក់ឲ្យទៅជាពលរបឹប តើដូចម្ដេច? បើត្រូវទោសដល់ទៅនិរទេស តើច្រើនបញ្ជូនទៅឯណា?

សេចក្ដីបញ្ជាក់— អត្ថបទដែលបេក្ខជនសរសេរទៅដាក់ប្រឡង ទោះជាប់ក្ដីមិនជាប់ក្ដី ត្រូវទុកជាសម្បត្តិរបស់ក្រសួងតទៅ មិនបង្វិលឲ្យសាមីខ្លួនវិញទេ ។

បានអស់លោក-អ្នក ជាច្រើនដែលមិនទាន់បានផ្ញើរូបថតទៅឲ្យ ក្រុមជំនុំ ហេតុនេះ សូមផ្ញើរូបថតសាមីខ្លួន លោក-អ្នកដែលសរសេរអត្ថបទប្រឡងបីសន្លឹកមកជាមួយផង គឺរូបមួយកំណាត់ខ្លួនទំហំ ៤ × ៦ លើកលែងតែអស់លោកណាដែលបានផ្ញើពីលើកមុនៗរួចមកហើយ ។

ក្រុមទំនៀមទម្លាប់ខ្មែរ

# ឯកសារ

## ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង

ដោយ

ឧកញ៉ាប្រសើរលិខិត ម៉ែន-ឌន់

ធ្វើការនៅទីចាត់ការគរុកោសល្យ ភ្នំពេញ

---

### ១- ភូមិជ្រោយស្មាច់ និង កោះជិតខាង

អ្នកផ្តល់ព័ត៌មាន គឺលោក ណាយ-សាំង អាយុ ៦៨ ឆ្នាំ និង លោក យិង-ឈៃ អាយុ ៥០ ឆ្នាំ នៅភូមិជ្រោយស្មាច់ ។ ក្រៅពីនេះ តាមការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ កាលពីថ្ងៃទី ១៦-២-៦៨ ។

ជ្រោយស្មាច់ ស្ថិតនៅក្នុងសង្កាត់ព្រែកខ្សាច់ ស្រុកគិរីសាគរ ខេត្តកោះកុង ។ បានជាហៅថាជ្រោយស្មាច់ ព្រោះទីនេះមានដីដុះលយចេញទៅផ្ទៃសមុទ្រហើយមានដើមស្មាច់ដុះជាច្រើន "អ្នកខ្លះហៅពយស្មាច់" ។

ជ្រោយនេះមានប្រជាពលរដ្ឋរស់នៅជាអចិន្ត្រៃយ៍ចំនួនជាង ២០ គ្រួសារក្រៅអំពីនេះមានពួកកម្មករចំនួនជាង ២០០ នាក់ ដែលប្រកបរបរស៊ីឈ្នួលកាប់ឈើឲ្យក្រុមហ៊ុនជប៉ុន ព្រោះមានក្រុមហ៊ុនជប៉ុនមកសុំទិញឈើពីរដ្ឋការខ្មែរ បានប្រកបអាជីវកម្មនៅទីនេះ ។

នាទីភូមិជ្រោយស្មាច់ តាំងលើឆ្នេរខ្សាច់បណ្តោយតាមបាត់សមុទ្រ មានចម្ងាយប្រហែល ៦០០ម ទទឹងភូមិប្រហែល ៤០ ម ។ គេហដ្ឋានអ្នក

ស្រុកសង់ជា ២ ជួរទល់មុខគ្នា ហើយឃ្លាតដាច់ៗពីគ្នា ។ ផ្ទះទាំងនោះ សង់អំពីឈើប្រក់ស័ង្កសីខ្លះ ប៉ុន្តែពុំសូវខ្ពស់ពីដីទេ ។ ទីធ្លាមុខផ្ទះ និង ជុំវិញផ្ទះច្រើនតែដីខ្សាច់ ដូច្នេះហើយបានជានៅក្នុងភូមិ ពុំមានដំណាំអ្វី ក្រៅពីដើមដូងឡើយ ហើយដូងទាំងនោះសោតក៏នៅទាបៗដែរ ព្រោះ ភូមិនេះ ទើបនឹងរៀបចំថ្មី ។

នៅមាត់សមុទ្រមានផែមួយយ៉ាងធំ ធ្វើអំពីដែក និងឈើដែលជា របស់ក្រុមហ៊ុនជប៉ុន ធ្វើសម្រាប់នាំឈើដាក់នាវា ហើយក្រៅអំពីនេះមាន រថយន្ត និងម៉ាស៊ីនស្ទូចឈើ " ឡាក្រេយ " ដែលជាសម្ភារៈក្នុងការ ដឹកនាំឈើចេញពីព្រៃ និង សម្រាប់ស្ទូចឈើដាក់នាវាដែរ ។

មុខរបរនៃប្រជាពលរដ្ឋនៅភូមិជ្រោយស្វាច់មានច្រើនយ៉ាង គឺអ្នកខ្លះ ខាងការនេសាទត្រី ខ្លះធ្វើចំការ ខ្លះស៊ីឈ្នួលកាប់ឈើឲ្យជប៉ុន និងមាន ខ្លះទៀតខាងការលក់ដូរ ដូចជាលក់កាហ្វេ ទឹកក្រូច នំបញ្ចុក នំក្រូច ស្រា បារី ។ល។ ប៉ុន្តែគុយទាវពុំមានលក់ទេ ។

អ្នកភូមិជ្រោយស្វាច់ កាន់លទ្ធិព្រះពុទ្ធសាសនា ប៉ុន្តែពុំទាន់មានវត្ត សម្រាប់ធ្វើបុណ្យទានទេ បើគេត្រូវការធ្វើបុណ្យម្តងៗ គេទៅធ្វើឯវត្ត ស្អិយៈនៅចម្លងគោ ឬទៅវត្តកិមាន នៅកោះកុង ។ ចំណែកសាលារៀន ក៏ពុំទាន់មានដែរ ព្រោះកុមារា-កុមារី នៅភូមិនេះ មានចំនួនតិចពេក ។

ភាសានិយាយនៃប្រជាពលរដ្ឋនៅភូមិជ្រោយស្វាច់ គឺភាសាខ្មែរ ប៉ុន្តែអ្នកទាំងនោះមានចេះភាសាចិនវៀតណាម និង ភាសាសៀមផងដែរ ។

ឯដីគោកឃើញដូងត្នោតច្រើន ស្មៀកពាក់ច្រើនស្អាត ៗ ហើយមានប៉ុស្តិ៍វិទ្យុទទួលសម្លេងស្ទើរគ្រប់ផ្ទះ ៗ

នៅខាងក្រោយភូមិមានវាលស្រែចំការ បណ្តោយប្រហែល ៥០០ម ទទឹងប្រហែល ២០០ម បន្ទាប់ពីនេះទៅ គឺព្រៃភ្នំ ៗ នៅខាងមុខភូមិ គឺសមុទ្រ ហើយនៅចម្ងាយប្រហែលពី ២ ទៅ ៤ គីឡូម៉ែត្រ មានកោះតូច ១ ដផ្ទៃគ្នា គឺកោះស្តាច់ កោះអំពិល កោះស្តេច កោះឆាន់ និង កោះទទឹង ៗ ឯកោះទាំងនោះមានស្ថានភាព និងប្រវត្តិផ្សេង ១ គ្នាដូចតទៅ :

១- កោះស្តាច់ នៅទិសនិរតីនៃជ្រោយស្តាច់ ៗ កោះនេះមានទំហំធំជាងគេក្នុងបណ្តាកោះទាំង ៥ ៗ កោះស្តាច់ពុំមានផ្ទះអ្នកស្រុកនៅទេ ប៉ុន្តែមានចំការដែលអ្នកស្រុកនៅជ្រោយស្តាច់ទៅកាប់គាស់រាន នៅឡើយ ៗ

២- កោះអំពិល ក៏នៅទិសនិរតីជ្រោយស្តាច់ដែរ បន្ទាប់កោះស្តាច់ៗ កោះនេះមានទំហំតូចទេ ហើយថៅកែឈ្មោះ រ៉ឹត នៅជ្រោយស្តាច់ បានទៅកាប់គាស់រានដាំដំណាំតែម្នាក់ឯង គឺមានដាំដូង កៅស៊ូជាដើម ៗ

៣- កោះស្តេច ស្ថិតនៅខាងលិច ចំពីមុខជ្រោយស្តាច់ ហើយមានទំហំធំជាងកោះអំពិល ៗ កោះនេះមានប្រជាពលរដ្ឋរស់នៅ ៥-៦ គ្រួសារ និងមានប៉ុស្តិ៍កងរាជតម្រួតមួយប្រចាំការនៅទីនេះ ៗ

កោះស្តេចមានអណ្តូងបុរាណមួយ ហៅថាអណ្តូងអ្នកគ្រង "អ្នកសង្ឃ" ៗ អណ្តូងនោះមានទំហំទទឹងមាត់ប្រហែល ៤០ ស ម. ជម្រៅប្រហែល ៥០ ស.ម. ហើយស្ថិតនៅត្រង់ដីទំនាបមួយ ដែលមានទឹកប្រៃ

ព័ទ្ធជុំវិញ ប៉ុន្តែគួរឲ្យអស្ចារ្យណាស់ ដោយអណ្ដូងនេះមានទឹកសាបចេញជានិច្ចមិនចេះរីង ។

តាមប្រវត្តិនៃអណ្ដូងនេះថា កាលពីដើមមានស្ដេច ១ ព្រះអង្គមាននាមពុំប្រាកដ បានស្ដេចយាងមកកាន់កោះនេះ ដោយមានព្រះរាជបរិ-ពារជាច្រើនតាមដង្ហែផង ។ ដោយនៅទីនេះមានតែទឹកសមុទ្រ ដែលមានរសជាតិប្រៃ រកទឹកសាបសោយពុំបាន ទើបព្រះអង្គទ្រង់អធិដ្ឋានហើយយកព្រះខាន់ជីកដីនៅកន្លែងនេះធ្វើជាអណ្ដូង ទឹកសាបក៏ចេញមកសម្រាប់ព្រះអង្គ និង ព្រះរាជបរិពារសោយ និង ពិសា ផ្គួតបរិបូណ៌ ។ អំណើះតមក អណ្ដូងនោះក៏រីងទៅជាថ្មូ ហើយកោះនេះក៏បានគេសន្មតនាមថា កោះស្ដេច ជាប់រហូតដល់សព្វថ្ងៃ ។

៤- កោះឆាន់ នៅទិសពាយ័ព្យ នៃភូមិជ្រោយស្វាច់ ហើយមានទំហំតូចជាងគេបំផុត កោះនេះមានដុំសីលា និងមានរុក្ខជាតិដុះត្រសំត្រសាយ ដូចជាកោះឯទៀត ៗ ដែរ ប៉ុន្តែពុំមានប្រជាពលរដ្ឋរស់នៅ ឬក៏កាប់គាស់ធ្វើចំការអ្វីទេ ហើយនៅឆ្ងាយពីដីគោកជាងគេផង ។

៥- កោះទទឹង នៅទិសឧត្ដរនៃភូមិជ្រោយស្វាច់ ។ កោះនេះមានពងវែង ប៉ុន្តែតូចជាងកោះស្ដេច ស្ថិតនៅជិតដីគោកជាងទេ ហើយពុំមានប្រជាពលរដ្ឋតាំងទីលំនៅ និង ពុំមានអ្នកណាប្រកបរបរស្រែចំការនៅកោះនេះទេ ។

បើគ្រាន់តែឮថា កោះទទឹង មិត្តអ្នកអានមុខជាយល់ថា មកពីកោះ

នេះទទឹងប៉ៃ ប៉ុន្តែតាមការពិត ពុំមែនដូច្នោះទេ គឺមកពីកោះនេះស្ថិតនៅទទឹងមុខអ្នកដំណើរ ព្រោះបើគេបើកបំពៅទៅ ឬបែរទូកសៀរតាមមាត់សមុទ្រគេឃើញកោះនេះនៅទទឹងពីមុខ ត្រូវតែបើក ឬបែរវាងបន្តិច ទើបទៅមុខរួច ។

\+

\+ \+

## ២- ប្រវត្តិឈូងយាយសែន

> អ្នកផ្តល់ពត៌មាន គឺលោក តាន់-ឡឹក នាយដំបន់អធិការកិច្ចបឋមសិក្សាស្រុកកោះកុង និងលោក តាន់-ធិន ជាប្អូនបង្កើតរបស់លោក តាន់-ឡឹក ។ ទាំង ២ នាក់បងប្អូនមានស្រុកកំណើតនៅកោះកាពិ ហើយសព្វថ្ងៃក៏នៅកោះកាពិទៀត ។ លោកបានផ្តល់ពត៌មាន កាលពីថ្ងៃ២០-២-៦៨ ។

ឈូងយាយសែន ស្ថិតនៅក្នុងសង្កាត់ព្រែកខ្សាច់-ស្រុកគិរីសាគរ ខេត្តកោះកុង ត្រង់ចន្លោះកោះក្រសា និងកោះកុង "ខាងត្បូងកោះកុង" ។ អ្នកស្រុកនោះខ្លះហៅថា "អៅយាយសែន" ជាប់ភាសាសៀម គឺសៀមហៅអៅ ខ្មែរហៅឈូង ។ ឯប្រវត្តិនៃឈូងយាយសែន មានដូចតទៅ ។

ជាយូរអង្វែងឆ្នាំកន្លងមកហើយ មានមេចោរស្រីម្នាក់ឈ្មោះ សែន ។ មេចោរនោះចេះមន្តវិជ្ជានិងស្ទាត់គុនខ្លាំងពូកែណាស់ ពោះបីទូក បំពៅដែលនៅឃ្លាតពីគ្នាចម្ងាយប្រហែល ១០ម ក៏អាចលោតផ្លោះពីទូក ១ទៅទូក ១ ទៀតយ៉ាងងាយ ។

មេចោរសែន មានកូនចោរប្រុស ៗ ជាច្រើននាក់ទៀត ជាបរិវារ ហើយដើរកាត់ក្បាលប្លន់អ្នកដំណើរដោយទូក សំពៅ តាមសមុទ្រ ៗ មេចោរប្រុសឯទៀត ៗ ក៏ពុំហ៊ានទើសមុខនាងសែនដែរ ម្ល៉ោះហើយនាងសែនត្រូវមានទ្រព្យសម្បត្តិសឹងប្រៀបបាននឹងមហាសេដ្ឋី ប៉ុន្តែទោះប្លន់បានទ្រព្យសម្បត្តិច្រើនយ៉ាងនេះក៏ដោយ ក៏មេចោរកំណាចនេះពុំចែកចាយដល់កូនចោរឲ្យល្មមនឹងកម្លាំងដែលគេបានឡើយ សុខចិត្តយកទៅជីកកប់ក្នុងធរណី ពុំឲ្យអ្នកណាដឹងកន្លែងទៅវិញ ៗ ដោយការល្មោភលោភលន់ហួសហេតុនេះហើយ ដែលបណ្ដាលឲ្យកូនចោរទាំងអស់កើតក្ដៅក្រហាយចិត្តហើយបានមូលមតិគ្នាថា ពេលណាមួយនឹងសម្លាប់មេរបស់ខ្លួនឲ្យទាល់តែបាន ៗ

ហេតុតែបាបកម្មតាមទាន់ កូនចោរទាំងអស់បានប្រើឧបាយគាប់គួរនឹងនាយចៅហ្វាយ បានតាក់តែងធ្វើម្ហូបយ៉ាងឆ្ងាញ់ ៗ ដោយមានស្រាក្រេបកំដរផង ៗ កូនចោរទាំងអស់ដណ្ដើមគ្នាចាក់ស្រាជូនចៅហ្វាយបន្តិច ៗ ម្នាក់ ហើយចៅហ្វាយក៏ចេះតែទទួលឥតបង្អង់ដៃទាល់តែអាសុរាចូលទៅកូរឹកថ្លើមប្រមាត់ ធ្វើឲ្យក្រេងកក់ដួលក្រោកលែងរួចតែម្ដង ៗ

ឱកាសល្អហុចឲ្យហើយ កូនចោរទាំងអស់ញាក់មុខដាក់គ្នា មិនយូរប៉ុន្មានក៏ទាញខ្សែមកចងដៃ ចងជើង ព័ទ្ធហើយព័ទ្ធទៀត កុំឲ្យបម្រះរួច ៗ ក្រោយដែលចងជាប់ហើយកូនចោរទាំងនោះ ខ្លះបានដាវ ខ្លះលំពែង ខ្លះដំបង គិតតែពី កាប់ ចាក់ វាយ ប៉ុន្តែជាការឥតប្រយោជន៍ សែននៅតែជា

សែនដដែល ឥតមានមុត ឬបែកបាក់ត្រង់ណាសោះឡើយ ។

ពិតមែនតែពុំមាន មុត ឬ បាក់ បែក ប៉ុន្តែការឈឺគ្រាំគ្រាបានធ្វើឲ្យនាងសែនវេទនាយ៉ាងក្រៃលែង ។ ដោយដឹងខ្លួនថាបើទឹងបម្រាស់ក៏ពុំរួច និងដោយដឹងថាគាត់បានកសាងអំពើអាក្រក់ជាយូរឆ្នាំហើយ ទើបគាត់សុខចិត្តទទួលផលកម្មនោះ គឺប្រាប់ទៅកូនចោរទាំងនោះថា "អ្នកទាំងអស់គ្នា កាប់ចាក់និងវាយខ្ញុំយ៉ាងណាក៏មិនស្លាប់ដែរ ណ្ហើយ! កុំឲ្យខ្ញុំវេទនាយូរពេក បើចង់ឲ្យខ្ញុំស្លាប់ លុះត្រាតែយកឈើស្រួចមករុកតាមទ្វារលាមករបស់ខ្ញុំទើបខ្ញុំស្លាប់ ។

ដោយជឿតាមសេចក្តីណែនាំនេះ កូនចោរទាំងអស់ក៏សម្រួចឈើដាំជាបង្គោល យកចុងស្រួចឡើងលើ រួចលើកគាត់ប្រកពីលើចុងស្រួចបញ្ចូលតាមទ្វារលាមក ហើយនាំគ្នាសង្កត់ទាល់តែចុងបង្គោលធ្លាយដល់មាត់ទើបឈប់ ។ ឯវិញ្ញាណក្ខន្ធនៃនាង សែន ក៏លាចាករូបកាយក្នុងពេលនោះទៅ ។

ក្រោយដែលបានផ្តាច់ជីវិតនាយចៅហ្វាយរបស់ខ្លួនរួចហើយ កូនចោរទាំងអស់នាំគ្នាលើកសពគាត់ដាក់នៅកន្លែងដ៏សមគួរមួយ រួចក៏ធ្វើកិច្ចសូមខមាទោស ហើយយកឧសមកគរដុតរលាយទៅជាផេះ ។ បន្ទាប់មកទើបចោរទាំងនោះនាំគ្នាពិចារណារកហេតុផលនៃអំពើបាប-បុណ្យ រួចក៏ផ្តេជា ចិត្តថា ទឹងលែងប្រព្រឹត្តអំពើចោរកម្មនេះទៀតហើយ ហើយក៏លាគ្នាទៅរកប្រកបរបរផ្សេង ៗ ខ្លះខាងកសិកម្ម ខ្លះខាងការនេសាទ តាមតែ

ការពេញចិត្តរៀងខ្លួន

កន្លែងដែលនាងសែន នៅស្ថិតស្ថេរជាងគេកាលនៅរស់ និងកន្លែងដែលគេសម្លាប់ផុតគាត់នោះ នៅត្រង់ល្អូងមួយ រវាងកោះក្រសាម្ខាងនិងកោះកុងម្ខាង ដូច្នេះហើយបានជាអ្នកស្រុកសន្មតហៅថា ល្អូងនាងសែន លុះចំណោរក្រោយមក គេហៅថាល្អូងយាយសែន ដរាបដល់សព្វថ្ងៃ ។ មិនតែប៉ុណ្ណោះវិញ្ញាណក្ខន្ធ នាង សែន បានទៅកើតជាព្រាយបិសាច ហើយអ្នកស្រុកក៏នាំគ្នាហៅ ថាយាយសែនដែរ ប៉ុន្តែបិសាចនេះពុំមានឥទ្ធិពលកាចសាហាវដើរធ្វើគេឯងទេ ។

តាមពត៌មានបន្ថែមទៀតថា ឈើដែលកួនបោរដាំជាបង្គោលរុកក្តិតនាងសែនកាលនោះនៅរហូតដល់សព្វថ្ងៃ គឺឈើទំហំប៉ុនកំភួនជើង រាងបួនជ្រុង កំពស់ប្រមាណ ១ ម ៥០ ពណ៌សប្រផេះ ស្ថិតនៅត្រង់ដីចំការរបស់អ្នកស្រុកម្នាក់ឈ្មោះ យាយលីវ នាល្អូងយាយសែននោះឯង ។

ម្យ៉ាងទៀតថា យាយសែននេះ កាលនៅរស់នៅឡើយមានកើតរោគឃ្លង់ផង លុះគាត់ស្លាប់ទៅ គាត់បានពន្យល់សប្តប្រាប់អ្នកស្រុកថា បើអ្នកណាសុខចិត្តកើតរោគឃ្លង់ដូចគាត់ គាត់នឹងប្រាប់ឲ្យទៅយកកំណប់គឺមាស ១ ពាង និង ប្រាក់ ១ ពាង ប៉ុន្តែពុំមាននរណាម្នាក់ សុខចិត្តទទួលមរតកនេះ អំពីគាត់ឡើយ ។

*

* *

## ៣- ភូមិពាមក្រសោប

អ្នកផ្តល់ពត៌មាន គឺលោកគ្រូព្រះនាម ពុត-ងួង ពៅអធិការវត្តសុវណ្ណភោគាទីបាភម " ពាមក្រសោប " និងការពិនិត្យផ្ទាល់ដល់ទីកន្លែងរបស់អ្នកនិពន្ធ កាលពីថ្ងៃ ២២-២-៦៨ ។

បានជាហៅថាពាមក្រសោប មកអំពីទីនេះមានដីទួលមួយដែលដុះសុទ្ធតែដើមកោងកាង ។ ដីទួលនេះ មានទទឹងប្រហែលជាង ១០០ម បណ្តោយវែងទៅលិចច្រើនគីឡូម៉ែត្រ ។ នៅខាងត្បូងជាផ្ទៃទឹកសមុទ្រ ជលរហាររហាវ ខាងកើតជាដៃសមុទ្រ និងខាងជើងមានព្រែកមួយតូច ៗ ផ្ទៃសមុទ្រ ដៃសមុទ្រ និងព្រែកនេះ បានព័ទ្ធទួលនិងព្រៃដូចគេក្រសោប ហើយមានប្រជាពលរដ្ឋទៅតាំងទីលំនៅត្រង់មាត់ពាមនៃព្រែក ទើបសន្មតហៅថា ភូមិពាមក្រសោប ។

ភូមិពាមក្រសោបស្ថិតនៅក្នុងសង្កាត់កោះកាពិ ស្រុកកោះកុង ខេត្តកោះកុង នាទិសទក្សិណនៃក្រុងខេមរភូមិន្ទ មានចម្ងាយប្រហែល ១០ គម និងមានប្រជាពលរដ្ឋរស់នៅចំនួន ១១០ គ្រួសារ ។

គេហដ្ឋានអ្នកស្រុកសង់ជា ២ ជួរអមមាត់ព្រែក ហើយព័ទ្ធរហូតដល់ក្បាលជ្រោយ ។ របៀបសង់សុទ្ធតែធ្វើលើចន្ទល់កំពស់ពីដី ពី ១ម.ទៅ ២ម. តាមកន្លែងទាបខ្ពស់ ។ គ្រឿងសំណង់ គឺឈើប្រក់សង្កសី ឬឈើប្រក់ស្លឹក ។ ទីធ្លាភ្ជាប់ពីផ្ទះមួយទៅផ្ទះមួយ សុទ្ធតែស្ពានទាំងអស់ ។ ដូច្នេះផ្ទះទាំងឡាយគេសង់ច្រើនតែជាប់ជញ្ជាំងគ្នាតាមរបៀបផ្ទះល្វែង ។

នៅក្រោមផ្ទះពុំប្រាកដជាទឹក ឬគោកទេ ព្រោះធម្មតាទឹកសមុទ្ររមែងមានជោរនាច បើពេលទឹកជោរមានទឹកកំពស់ពី ០ម ៥០ ទៅ ១ម បើពេលទឹកនាចវិញគឺដីគោក ឬមានទឹករហាល ៗ តាមកន្លែងជ្រៅ-រាក់ នៅមុខផ្ទះមានដៃសមុទ្រ និងតួព្រែក នៅក្រោយផ្ទះមានព្រៃដែលដុះសុទ្ធតែដើមកោងកាង ។

ក្រៅអំពីផ្ទះប្រជាពលរដ្ឋ មានវត្ត ១ និងមន្ទីរការងារផ្សេង ១ គឺ សាលារៀន គិលានដ្ឋាន ក្រុមគ្រូពេទ្យ និងនេសាទ កងរាជតម្រួតនិងទាហាន ប៉ុន្តែបុគ្គលិករាជការទាំងនោះ ច្រើនតែក្រុមអប់រំជាតិទេដែលមានចំនួនច្រើនជាងគេ ក្រៅអំពីនេះមាន ១ នាក់ឬ២ នាក់ សម្រាប់ប្រ-ចាំការតាមសមត្ថកិច្ចរៀងខ្លួន ។

មុខរបរនៃប្រជាពលរដ្ឋនៅភូមិពាមក្រសោប មានតែការនេសាទ ការលក់ទំនិញនិងម្ហូប អាហារ ហើយបើតាមការសង្កេតឃើញថា ទំនិញនិងម្ហូប អាហារទាំងនោះ ពុំដឹងជាលក់ឲ្យអ្នកណាទេ ព្រោះផ្ទះស្ទើរតែទាំងអស់ សុទ្ធតែលក់ដូរដូចគ្នា ប៉ុន្តែតាមការសួរបញ្ជាក់ទើបដឹងថា ទំនិញនិងម្ហូប-អាហារទាំងនោះ ត្រូវពួកទេសចរ-និងអ្នកស្រុកមកពីដំបន់ដីគោកដូចជាខាងភូមិស្ទឹងវែង ភូមិតាចាត ភូមិដូង ភូមិតាតៃ ជាដើមបានមកលក់ និងទិញ គ្រឿងឧបភោគ និងបរិភោគនៅទីនេះ ។

ភាសានិយាយគឺខ្មែរ តែអ្នកស្រុកចិនហៃណាំ និងវៀត ៗ ចាស់ ៗ ច្រើនចេះភាសាវៀតប៉ុន្តែចំពោះក្មេង ៗ វិញពុំសូវចេះទេ គឺចេះភាសាខ្មែរ

ហើយច្បាស់លាស់ផង ព្រោះមានសាលារៀន និងចលនាអក្ខរកម្ម ៗ ចំណែកខាងជំនឿវិញ គេគោរពព្រះពុទ្ធសាសនា ប៉ុន្តែមានអាស្រមអ្នកតាផងដែរ សម្រាប់ជំនឿបន្ទាប់បន្សំ ដូចជា យាយម៉ៅ និងអ្នកតាចិន ៗ

កុមារា កុមារី ត្រូវបានចូលរៀនគ្រប់គ្នា ប៉ុន្តែមានចំនួនច្រើនតែនៅថ្នាក់ទី ១២-១១-១០ ចាប់ពីថ្នាក់ទី ៩-៨ ឡើងទៅ ចេះតែរលោះបន្តិចម្តង ៗ ហើយជាពិសេសនៅថ្នាក់ទី ៧ រឹតតែតិចណាស់ ព្រោះគេយល់ឃើញថា ការនេសាទអាចផ្តល់លុយកាក់បានច្រើន ហើយទាន់ចិត្តជាងការរៀនសូត្រ ម្ល៉ោះហើយគេត្រូវតែទៅជួយឪពុកម្តាយខាងការនេសាទវិញ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ក៏ក្មេងទាំងនោះបានចេះភាសា និងអក្សរ-សាស្ត្រខ្មែរល្មមប្រើការបានខ្លះហើយដែរ ៗ

ប្រជាពលរដ្ឋនៅភូមិពាមក្រសោប មានវិបត្តិធម្មជាតិមួយ គឺទឹកសាបសម្រាប់ទទួលទានដោយគេត្រូវដឹកនាំទឹកសាបពីទីឆ្ងាយ ៗ ដូចជាពីកោះស្រឡៅ ឬដើងគ្រក់ (យុនធាង) ឬក៏ក្វងប៉ាកកា (កោះប៉ោ) ជាដើម ៗ

*

* *

៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤១ ខែ កក្កដា

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-

៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

បេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ — ផ្នែកសាសនា — ទំព័រ


១— មជ្ឈិមសីល លោក ប៊ូ-ប៊ូ រៀបរៀង . . . . . ៦៦៥

២— រឿងឧបគុត្ត និង មារ លោក ញុង-សឿង រៀបរៀង. . . . . ៦៧៣


## ផ្នែកអក្សរសាស្ត្រ


៣— វិបារណកថា . . . . . . . . . . ៦៨៣

៤— វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង ខាត់ . . . . . ៦៨៨

៥— រឿងសាមកុក (ត) ឧកញ៉ានូ-កន ប្រែរៀបរៀង . . . . . ៦៩១

៦— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ សហជីវិន ពេជ-សល់ ប្រែរៀបរៀង ៦៩៩

៧— ពាក្យកាព្យ : រាត្រីចតុមុខ លោក ញុង-សឿង រៀបរៀង . . ៧១០

៨— ឯកសារ : ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង ឧកញ៉ា
ប្រសើរលិខិតម៉ែន-ទន់ រៀបរៀង . . . . . . . ៧១៦

៩— ប្រវត្តិភូមិក្បាលអ្នក ឬ ភូមិ ប៉ូអង់ លោក ហ៊ុន-សារី រៀបរៀង . . ៧២៧

១០— ល្បើកអក សហ. លី-ធាមតេង ស្រាវជ្រាវ . . . . ៧៣៤

១១— សិលាចារឹកព្រះគោ សហ. ឌឹក-ធាម ស្រាវជ្រាវ . . . . . ៧៥១


## ផ្នែកកំណត់-ប្រចត្តិការណ៍


១២— សេចក្ដីជូនដំណឹង អំពីលទ្ធផលនៃការប្រឡងប្រជែងខាងទំនៀមទម្លាប់
នៅខែមាសទី ១ ឆ្នាំ ១៩៦៩ . . . . . . ៧៨៤

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក ឲ្យធ្វើល្អទៅ,
ឲ្យជុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។

ប. ព

# មជ្ឈិមសីល (១)

លោក ញ៊ុ-ញ៉ុ រៀបរៀង

មួយវិញទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយ ៗ នូវការធ្វើនូវពីជគាម និងភូតគាមឲ្យវិនាសមានសភាពដូច្នេះ ។ ពីជគាមនិងភូតគាមនោះ តើដូចម្តេចខ្លះ ។ គឺ មើមឬឫសជាពូជ ១ ដើមជាពូជ ១ ថ្នាំងជាពូជ ១ ចុងឬត្រួយជាពូជ១ គ្រាប់ជាពូជ១ ជាគម្រប់៥ ។ ភិក្ខុវៀរចាកនូវការធ្វើនូវពីជគាមនិងភូតគាមឲ្យវិនាស មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយ ៗ នូវការបរិភោគវត្ថុដែលសន្សំ

---

១- ចម្លងត្រង់តាមច្បាប់ដើម ពីព្រះត្រៃបិដក ប្រែ ឥតកែប្រែ ឬ បញ្ចេញបញ្ចូលឡើយ ។

ទុក មានសភាពដូច្នេះ ៗ ការសន្សំទុកនោះ តើដូចម្តេច ៗ គឺសន្សំបាយទុក ១ សន្សំទឹកទុក១ សន្សំសំពត់ទុក ១ សន្សំ យានទុក ១ សន្សំទីដេកទុក ១ សន្សំគ្រឿងក្រអូបទុក ១ សន្សំគ្រឿងអាមិសទុក ១ ភិក្ខុជាអ្នកវៀរចាកការបរិភោគវត្ថុ ដែលសន្សំទុក មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះរមែងប្រកបរឿយៗ នូវការមើលនិងស្តាប់នូវល្បែង ដែលជាសត្រូវដល់កុសលធម៌មានសភាពដូច្នេះ ៗ ល្បែងជាសត្រូវដល់កុសលធម៌នោះ តើដូចម្តេច ៗ គឺ ល្បែងរាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ មហោស្រពខ្លះ ចម្រៀងមហាភារតៈនិងរាមកេរ្តិ៍ជាដើមខ្លះ គន់ខ្លះ រគាំងខ្លះ ស្គរមានជ្រុងបួនខ្លះ គូរគំនូររូបរបាំខ្លះ ល្បែងដុំដែកខ្លះ ល្បែងប៉ាវខ្លះ ល្បែងលាងឆ្អឹងខ្លះ ដំរីជល់គ្នាខ្លះ សេះប្រទាំគ្នាខ្លះ ក្របីជល់គ្នាខ្លះ គោជល់គ្នាខ្លះ ពពែជល់គ្នាខ្លះ កែះជល់គ្នាខ្លះ មាន់ជល់គ្នាខ្លះ ចាបជល់គ្នាខ្លះ ល្បែងគុនដំបងខ្លះ ប្រដាល់ខ្លះ ចម្បាប់ខ្លះ ចម្បាំងខ្លះ ទីគេកប់ពលខ្លះ ទីលំនៅកងទ័ពខ្លះ ទីមើលពួកសេនាដែលប្រកបដោយអង្គ ៤ ខ្លះ ៗ ភិក្ខុជាអ្នកវៀរចាកការមើលនិងស្តាប់នូវល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយៗ នូវល្បែងបាស្កា ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទមានសភាពដូច្នេះ ។ ល្បែងបាស្កានោះតើដូចម្តេចខ្លះ ។ គឺ បាស្កាមានក្រឡាប្រាំបី(១)ខ្លះ បាស្កាមានក្រឡាដប់(២)ខ្លះ បាស្កាដែលលេងឰដ៏អាកាស(៣)ខ្លះ ល្បែងវាងផ្លូវដែលគូរវាង(៤)ខ្លះ ល្បែងផ្ទាត់គ្រាប់មានគ្រាប់ក្រួសជាដើមខ្លះ លេងបាស្កាក្នុងទីលានសម្រាប់លេងខ្លះ ល្បែងហ៊ឹងប្ដូកូនគោលខ្លះ ល្បែងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ ល្បែងអង្គញ់ខ្លះ ល្បែងផ្លុំប៉ីស្លឹកខ្លះ ល្បែងនង្គ័លតូចខ្លះ ល្បែងដាំដូងខ្លះ ល្បែងកង្ហារខ្លះ ល្បែងវាល់ដីទ្រព (បាយឡុកបាយឡ)ខ្លះ ល្បែងរថតូចខ្លះ ល្បែងធ្នូតូចខ្លះ ល្បែងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ ល្បែងទាយចិត្ត (ស្តេចចង់)ខ្លះ ល្បែងកំប្លែងត្រាប់គេខ្លះ ។ ឯភិក្ខុជាអ្នកវៀរចាកល្បែងបាស្កាដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ មានសភាពដូច្នេះឯង ។ នេះ ជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវឧច្ចាសយនមហាសយនៈ

---

១- ចត្រង្គមានក្រឡា ៨ ។ ២ ចត្រង្គមានក្រឡា ១០ ន័យខ្លះថាបាយទុំ ។ ៣ ចត្រង្គឥតក្ដារ លេងតែមាត់ទទេ ។ ៤ ប្រហែលជាលេងបិទមុខបិទពួន ។

(ទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើ) មានសភាពដូច្នេះ ។ ឧច្ចាសយនមហាសយនៈនោះ តើដូចម្តេចខ្លះ ។ គឺអាសនៈដែលខ្ពស់ហួសប្រមាណខ្លះ គ្រែដែលមានជើងវិចិត្តដោយរូបសត្វសាហាវខ្លះ គ្រាំដែលមានរោមវែងជាង ៤ ធ្នាប់ខ្លះ កម្រាលដែលធ្វើដោយរោម វិចិត្រដោយរូបសត្វសាហាវខ្លះ កម្រាលមានពណ៌សដែលធ្វើដោយរោមសត្វខ្លះ កម្រាលដែលធ្វើដោយរោមសត្វ មានផ្កាដេរដាសខ្លះ កម្រាលដែលញាត់ដោយសំឡីជាប្រក្រតីខ្លះ កម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវមានសីហៈនិងខ្លាធំជាដើមខ្លះ កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងឡើងតែម្ខាងខ្លះ កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងឡើងទាំងសងខាងខ្លះ កម្រាលដែលធ្វើដោយឱទខ្សែសយមាស និងសូត្រចាក់ស្រែះដោយរតនវត្ថុមានមាសជាដើមខ្លះ កម្រាលដែលធ្វើដោយសរសៃសូត្រ ចាក់ស្រែះដោយរតនវត្ថុខ្លះ កម្រាលដែលធ្វើដោយរោមសត្វល្មមចុះពួកស្រីរបាំ ១៦ នាក់ឈររាំបានខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងដំរីខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងសេះខ្លះ កម្រាលសម្រាប់ក្រាលលើរថខ្លះ កម្រាលដែលធ្វើដោយស្បែកខ្លាខ្លះ កម្រាលដ៏ឧត្តមដែលធ្វើដោយស្បែកសត្វឈ្លូសខ្លះ ខ្នើយមានពណ៌ក្រហមទាំង ២ ខាង គឺខ្នើយក្បាលនិងខ្នើយជើង ព្រមទាំងពិតានមានពណ៌ក្រហមខ្លះ ។ ភិក្ខុជាអ្នកវៀរចាកឧច្ចាសយនមហាសយនៈ មានសភាពដូច្នេះឯង ។ នេះ ជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណៈព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកងកាយ មានសភាពដូច្នេះ ៗ វត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកងកាយនោះ តើដូចម្តេចខ្លះ ៗ គឺ ការដុសខាត់បំបាត់ក្លិនអាក្រក់ (គ្រឿងអប់)ខ្លះ ការច្របាច់តែខ្លះ ការផ្ងូតទឹកខ្លះ ការគក់ច្របាច់ខ្លះ កញ្ចក់ខ្លះ វត្ថុសម្រាប់លាបគ្រឿងប្រដាប់ខ្លះ ផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបខ្លះ គ្រឿងលម្អិតសម្រាប់ប្រស់មុខខ្លះ វត្ថុសម្រាប់លាបមុខខ្លះ គ្រឿងប្រដាប់ដៃខ្លះ ចំណងផ្នួងសក់ខ្លះ ដំបងខ្លះ បំពង់ថ្នាំខ្លះ ដាវខ្លះ ព្រះខាន់ខ្លះ ឆត្រខ្លះ ស្បែកជើងដ៏វិចិត្រខ្លះ មកុដប្ញក្សាំងមុខខ្លះ (ស្នៀតសក់) កែវមណីខ្លះ ផ្លិតធ្វើដោយរោមកន្ទុយសត្វខ្លះ សំពត់សខ្លះ សំពត់មានជាយវែងខ្លះ ៗ ភិក្ខុ ជាអ្នកវៀរចាកការប្រកបរឿយៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកងកាយ មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗ នូវតិរច្ឆានកថា (ពាក្យនិយាយទទឹងផ្លូវសួគ៌ និងផ្លូវព្រះនិព្វាន) មានសភាពដូច្នេះ ៗ តិរច្ឆានកថានោះតើដូចម្តេចខ្លះ ៗ គឺ និយាយអំពីស្តេចខ្លះ និយាយអំពីចោរខ្លះ និយាយ

អំពីអាមាត្យធំខ្លះ និយាយអំពីសេនាពាហនខ្លះ និយាយអំពីភ័យខ្លះ និយាយអំពីចម្បាំងខ្លះ និយាយអំពីបាយម្ហូបចំណីខ្លះ និយាយអំពីទឹកផឹកខ្លះ និយាយអំពីសំពត់ខ្លះ និយាយអំពីទីដេកខ្លះ និយាយអំពីផ្កាកម្រងខ្លះ និយាយអំពីគ្រឿងក្រអូបខ្លះ និយាយអំពីញាតិខ្លះ និយាយអំពីយានខ្លះ និយាយអំពីស្រុកខ្លះ និយាយអំពីនិគមខ្លះ និយាយអំពីនគរខ្លះ និយាយអំពីជនបទខ្លះ និយាយអំពីស្ត្រីខ្លះ និយាយអំពីបុរសខ្លះ និយាយអំពីយោធាដែលក្លៀវក្លាខ្លះ និយាយអំពីច្រកផ្លូវខ្លះ និយាយអំពីកំពង់ទឹកខ្លះ និយាយអំពីញាតិ (ដែលចាកឋានទៅកាន់បរលោកហើយ) ខ្លះ និយាយអំពីពាក្យឥតប្រយោជន៍មានសភាពផ្សេង ៗ ខ្លះ និយាយអំពីលោកខ្លះ និយាយអំពីសមុទ្រខ្លះ និយាយអំពីសេចក្តីចម្រើន និងមិនចម្រើនខ្លះ ។ ភិក្ខុជាអ្នកវៀរចាកតិរច្ឆានកថា មានសភាពដូច្នេះឯង ។ នេះ ជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវពាក្យប្រណាំងប្រដែងមានសភាពដូច្នេះ ។ ពាក្យប្រណាំងប្រដែងនោះ តើដូចម្តេចខ្លះ ។ គឺ ពាក្យថា អ្នកមិនមែនចេះដឹងនូវធម៌និងវិន័យនេះទេ ខ្ញុំទើបដឹងនូវធម៌និងវិន័យនេះ, អ្នកនឹងបានឈ្មោះថាចេះដឹងនូវធម៌និងវិន័យនេះ ដូចម្តេចបាន អ្នកជាអ្នកប្រតិបត្តិខុស ខ្ញុំទើបជាអ្នកប្រតិបត្តិត្រូវល្អ, ពាក្យរបស់ខ្ញុំ ទើប

ប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ទេ សម្តីដែលគេត្រូវនិយាយមុន អ្នកត្រឡប់ជានិយាយក្រោយវិញ សម្តីដែលគេត្រូវនិយាយក្រោយ អ្នកត្រឡប់ជានិយាយមុនវិញ ពាក្យផ្ទុយអ្នកប្រព្រឹត្តមកជាយូរអង្វែងហើយ ទោសគឺសម្តីរបស់អ្នក ខ្ញុំបានលើកឡើងហើយ អ្នកជាមនុស្សត្រូវខ្ញុំសង្កត់សង្កិនបាន អ្នកចូរទៅសិក្សា ដើម្បីដោះស្រាយនូវទោសគឺសម្តី ឬបើអ្នកអាច ចូរអ្នកដោះស្រាយឲ្យរួចទោសចុះ ៗ ភិក្ខុជាអ្នកវៀរចាកពាក្យប្រណាំងប្រជែង មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយបរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗនូវទូតកម្ម គឺការនាំសំបុត្រឬពាក្យបណ្តាំដល់គ្រហស្ថ និងទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ មានសភាពដូច្នេះ ៗ ទូតកម្មជាដើមនោះ តើដូចម្តេចខ្លះ ៗ គឺ ពាក្យដែលស្តេច មហាមាត្យរបស់ស្តេច ក្សត្រ ព្រាហ្មណ៍ គហបតិ ឬកុមារក្តី បញ្ជូនទៅថា លោកចូរទៅកាន់ទីនេះដូច្នេះក្តី លោកចូរទៅកាន់ទីឯណោះដូច្នេះក្តី លោកចូរនាំយករបស់នេះទៅ ដូច្នេះក្តី លោកចូរនាំយករបស់នេះមកអំពីទីឯណោះ ដូច្នេះក្តី ៗ ភិក្ខុជាអ្នកវៀរចាកការប្រកបរឿយៗ នូវទូតកម្ម គឺការនាំសំបុត្រឬពាក្យបណ្តាំដល់គ្រហស្ថ និងទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុ

នោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ជាអ្នកកុហកគឺញុំាងសត្វលោកឲ្យកោត ឲ្យស្ងើច (ឲ្យជ្រះថ្លាដោយការប្រើប្រាស់បច្ច័យជាដើម) ខ្លះ ជាអ្នកនិយាយកក់ពាក់ (នឹងគ្រហស្ថ) ខ្លះ ជាអ្នកធ្វើនិមិត្តគឺពោលបញ្ចិតបញ្ចៀងខ្លះ ជាអ្នកដេរប្រទេចខ្លះ ជាអ្នកស្វែងរកនូវលាភដោយលាភខ្លះ ។ ភិក្ខុជាអ្នកវៀរចាកការកុហក និងការនិយាយកក់ពាក់មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះនោះដែរ ។

ចប់ មជ្ឈិមសីល ។

# រឿង ឧបគត និង មារ

សហ. ញ៉ុង-សៀង រៀបរៀង

ពុទ្ធសាសនាកន្លងទៅបាន ២១៨ ឆ្នាំ ព្រះបាទធម្មាសោក(១) ប្រារព្ធធ្វើបុណ្យឆ្លងព្រះវិហារ ៨ ម៉ឺន ៤ ពាន់ និងចេតិយ ៨ ម៉ឺន ៤ ពាន់ អស់រយៈកាល ៧ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ មុននឹងផ្ដើមធ្វើបុណ្យនេះ ទ្រង់មានព្រះចិន្ដាថា “អញធ្វើបុណ្យនេះធំហើយយូរផង គួរតែអញចូលទៅថ្វាយបង្គំព្រះសង្ឃសិន ដើម្បីឲ្យព្រះសង្ឃទាំងនោះជួយការពារឧបស័គ្គផ្សេង ៗ ដែលកើតឡើងដល់ការកុសលនេះ” ។ លុះទ្រង់ព្រះចិន្ដាហើយ ក៏ចូលទៅកាន់អាពមថ្វាយបង្គំព្រះសង្ឃ ទូលអំពីកដបំណងសព្វគ្រប់ប្រការហើយ ត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ។

លំដាប់នោះ ភិក្ខុសង្ឃសន្និបាត រំពឹងគិតពិចារណាក៏បានដឹងច្បាស់ថា “ក្នុងពេលដែលស្ដេចប្រារព្ធធ្វើបុណ្យនេះ មារាធិរាជ នឹងមកធ្វើអុកឡុកឲ្យអន្តរាយការកុសលនេះ ។ សង្ឃសន្និបាត ក៏ទូលដល់ព្រះសង្ឃត្ថេរ(២) ថា “បពិត្រព្រះថេរៈដ៏ចម្រើន លោកម្ចាស់អាចការពារនូវមារាធិរាជកុំឲ្យធ្វើអន្តរាយដល់ការកុសលនេះបានឬទេ?” ។ ព្រះថេរៈថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមានកិច្ចធុរៈច្រើន ទាំងកាយទៀតសោត ក៏ទុព្វលភាព

---

១ សៀវភៅ រឿងឧបគុត្ត និងមារ នៅពុទ្ធសាសនបណ្ឌិត្យលេខ ម-១៣-៦៨ ដែលលោក Paroiselle សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ នៃប្រទេសកម្ពុជាធ្វើជាភាសាបារាំង ដាក់ថា “ព្រះបាទអសោក” ។ ២- ព្រះសង្ឃត្ថេរក្នុងវេលានោះមិនឃើញប្រាប់នាមទេ ។

ណាស់ហើយ មិនអាចនឹងការពារនូវមាភធិភជបានទេ ។ សង្ឃសន្និបាត ក៏សួរអនុត្ថេរជាលំដាប់រហូតដល់ភិក្ខុ ទើបនឹងបួសថ្មី តែគ្មានភិក្ខុអង្គណាមួយអាចការពារបានឡើយ ។

ព្រឹកឡើងនៃថ្ងៃទី ២ សង្ឃសន្និបាត ក៏ប្រជុំដើម្បីពិភាក្សាជ្រើសរើសរកភិក្ខុដែលអាចការពារនូវមាភធិភជទៀត ។ ខណៈនោះ មាននាគភពជមួយ ឡើងមកពីពិភពនាគ ដើម្បីធ្វើនមស្ការបំពោះភិក្ខុសង្ឃ ។ ពេលនោះមានស្តេចគ្រុឌមួយ ហើរមកពីកណ្តាប់ចក្រវាឡ មើលមកឃើញនាគ ក៏សម្ទុបស្ទាបចុះមកចម្រុងចាប់ស្តេចនាគ ធ្វើជាភក្សាហារ ។

ស្តេចនាគឃើញ ភិតភ័យយ៉ាងខ្លាំង រត់ចូលទៅក្នុងទីសង្ឃសន្និបាត សូមឲ្យសង្ឃសន្និបាតជួយ ។ សង្ឃសន្និបាតប្រាប់ថា យើងមិនអាចជួយការពារមហាភជបានទេ ។ គ្រានោះមានសាមណេរ(១)មួយរូបមានជន្មវស្សា ១៧ ឆ្នាំ ទើបតែនិមន្តមកដល់ ។ ព្រះសង្ឃទាំងអស់ ក៏និយាយទៅកាន់សាមណេរថា "ម្នាលសាមណេរ អ្នកអាចការពារនូវភ័យរបស់ស្តេចនាគបានឬទេ?" ។ សមណេរបង្គំទូលថា "បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណា ជាសាមណេរនៅក្មេងណាស់ មិនអាចការពារបានទេ" ។ ពេលនោះ ព្រះសង្ឃសន្និបាតអង្វរករសាមណេរនោះជាច្រើនលើកច្រើនគ្រា រហូតដល់សាមណេរទទួលការពារនូវភ័យនៃស្តេចនាគនោះ ។

ក្នុងពេលដែលស្តេចគ្រុឌហោះពួយចុះមកចម្រុងចាប់នាគធ្វើជាភក្សា-

១- មិនឃើញមានប្រាប់នាមសាមណេរនោះទេ ។

ហារនោះ សាមណេរក៏ចូលឈានសមាបត្តិសម្តែងបាដិហារិយ៍ធ្វើឲ្យខ្យល់ព្យុះយ៉ាងខ្លាំង ក្តួចយកស្តេចគ្រុឌទៅដាក់នូវកំពែងចក្រវាឡ ។ ស្តេចនាគរួចជីវិតដោយសារសាមណេរនោះ សរសើរនូវគុណូបការៈនៃសាមណេរជាអនេកប្បការ ហើយថ្វាយបង្គំលាភិក្ខុសង្ឃនិងសាមណេរនោះទៅកាន់ពិភពនាគវិញ ។

ភិក្ខុសង្ឃទាំងនោះ លើកទោសសាមណេរនោះថា "នែសាមណេរអ្នកឯង កាលភិក្ខុសង្ឃនិយាយពីដំបូង អ្នកឯងមិនព្រមធ្វើតាមបង្គាប់ព្រះសង្ឃ លុះព្រះសង្ឃអង្វរជាច្រើនលើកច្រើនគ្រា ទើបអ្នកឯងទទួលធ្វើ ។ អ្នកធ្វើដូច្នេះ ជាការមិនគួរ គឺអ្នកមិនគោរពដល់សង្ឃសោះ សង្ឃនឹងដាក់ទណ្ឌកម្មដល់អ្នកឯង" ។ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះកុរណានេះប្រព្រឹត្តខុសហើយ ព្រះសង្ឃនឹងដាក់ទណ្ឌកម្មដល់ខ្ញុំយ៉ាងណា ខ្ញុំនឹងទទួលនូវទណ្ឌកម្មយ៉ាងនោះគ្រប់ទាំងអស់ ។ ព្រះសង្ឃថា "នែសាមណេរព្រះធម្មាសោក ជាពុទ្ធសាសនូបត្ថម្ភក៍ព្រះអង្គនឹងធ្វើបុណ្យឆ្លងចេតិយ អស់រយៈកាល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ អ្នកឯងត្រូវទៅការពារមារពធិរជ កុំឲ្យមកធ្វើអន្តរាយដល់បុណ្យនោះ ។ សាមណេរឆ្លើយថា "បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណានេះ ជាសាមណេរនៅក្មេងមានអានុភាពតិចណាស់ មិនអាចការពារបានទេ លោកដែលមានអានុភាពច្រើនអាចទូន្មានមារពធិរជនោះបាននៅមាន ហេតុអ្វី ក៏ព្រះសង្ឃមិនទៅនិមន្តលោកអង្គនោះមក" ។ ព្រះសង្ឃក៏សួរថា លោកដែលមានអានុភាពច្រើននោះ មាននាមដូចម្តេច

លោកគង់នៅទីណា? ។ លោកមានឈ្មោះថា តិស្សនាគឧបគត លោកនិម្មិតប្រាសាទកែវនៅក្នុងផ្ទៃនៃមហាសមុទ្រ ហើយគង់សម្រាកសិរីយាបថក្នុងទីនោះ ។ កាលឮពាក្យសាមណេរប្រាប់ភ្លាម ព្រះសង្ឃទាំងឡាយ មានចិត្តត្រាមោទ្យត្រេកអរពន់ពេក ហើយ មានថេរបញ្ជាប្រើភិក្ខុ[១]ពីររូប ដែលសុទ្ធតែបានអភិញ្ញា ឲ្យទៅអារាធនាតិស្សនាគឧបគត ។ ភិក្ខុពីររូប កាលទទួលសង្ឃបញ្ជាហើយ ក៏ជ្រែកមហាប្រថពីទៅផុសនៅប្រាសាទនៃព្រះថេរៈតិស្សនាគ ឧបគត ។

តិស្សនាគឧបគត កាលទទួលអារាធនាហើយ ក៏ឲ្យភិក្ខុទាំងពីររូបនោះត្រឡប់ទៅមុន ។ កាលភិក្ខុទាំងពីររូបចេញផុតទៅ តិស្សនាគឧបគតក៏សម្ដែងឥទ្ធិបាដិហារិយ៍ ហោះទៅដល់ទីសង្ឃសន្និបាត មុនភិក្ខុទាំងពីររូបនោះ ។ ដោយអស្ចារ្យពេក ភិក្ខុពីររូបនោះ ក៏ពោលអួតគុណវិសេសរបស់តិស្សនាគឧបគតប្រាប់ដល់សង្ឃសន្និបាតថា៖ ព្រះថេរៈនេះប្រាកដជាមានអានុភាពច្រើនមែន ។

កាលមកដល់ហើយ ថ្វាយបង្គំសង្ឃត្ថេរហើយសួរថា ព្រះសង្ឃមានការអ្វី? ប្រធាននៃសង្ឃសន្និបាត និយាយថា ម្នាលអាវុសោ ឧបគត អ្នកឯងជាអត្តទត្តបុគ្គល មិនមករួមរួមធ្វើឧបោសថជាមួយនឹងសង្ឃ មិនគោរពសង្ឃ ។ នឹងដាក់ទណ្ឌកម្មដល់អ្នក ។ ឧបគតឆ្លើយថា៖ បើព្រះសង្ឃដាក់ទណ្ឌកម្មដល់ខ្ញុំព្រះករុណាដូចម្ដេច ខ្ញុំព្រះករុណានឹងធ្វើតាមដូច្នោះ។

---

១- ភិក្ខុពីររូបនេះ មិនឃើញមានប្រាប់នាមទេ ។

ព្រះសង្ឃត្រូវពោលថា ម្នាលអាវុសោឧបគុត្ត ក្នុងពេលឆាប់ៗនេះ ព្រះបាទធម្មាសោកជាសាសនូបត្ថម្ភក៍ ស្តេចបម្រុងធ្វើបុណ្យឆ្លងចេតិយ ៨ ម៉ឺន ៤ ពាន់ និងព្រះស្តូបធំក្នុងព្រះនគរ ។ អ្នកឯងត្រូវការពារមារាធិរាជ កុំឲ្យមកធ្វើអន្តរាយដល់ការកុសលរបស់ព្រះមហាក្សត្រ នេះជាទណ្ឌកម្មដែលសង្ឃដាក់ដល់អ្នកឯង ។

ក្នុងពេលដែលសង្ឃសន្និបាត មិនទាន់បញ្ចប់ផង ព្រះមហាក្សត្រ ស្តេចយាងចូលទៅកាន់អារាមថ្វាយបង្គំព្រះសង្ឃ រួចទ្រង់ត្រាស់សួរថា "បពិត្រព្រះសង្ឃដ៏ចម្រើន ភិក្ខុដែលអាចការពារនូវមារាធិរាជនោះ តើព្រះសង្ឃជ្រើសរើសបានហើយឬនៅ" ? ។ ប្រធានសង្ឃនៃសន្និបាតថ្វាយព្រះពរថា "បពិត្រមហារាជ ភិក្ខុដែលអាចនឹងការពារនូវមារាធិរាជនោះ បានហើយគឺភិក្ខុឈ្មោះតិស្សនាគឧបគុត្តនេះឯង" ។ ព្រះសង្ឃបង្អុរប្រាប់ ។ ភិក្ខុអង្គនេះលោកប្រកបដោយសីល សមាធិ បញ្ញា មានអានុភាពច្រើន ។

ព្រះរាជា ស្តេចទ្រង់ចូលទៅថ្វាយបង្គំតិស្សនាគឧបគុត្ត ទ្រង់ទតឃើញកាយស្គាំងស្គម ទ្រង់គិតក្នុងព្រះរាជហឫទ័យថា "ភិក្ខុនេះមានកាយស្គាំងស្គមណាស់ ហេតុអ្វីក៏ព្រះសង្ឃប្រាប់អញថា អាចការពារនឹងមារបាន បើដូច្នេះ អញនឹងល្បងមើល ឲ្យដឹងថាមានឫទ្ធិឬឥតឫទ្ធិ ប្រាកដនឹងមំសចក្ខុនៃអាត្មាអញសិន" ។

ថ្ងៃព្រឹកឡើងតិស្សនាគឧបគុត្ត ចូលទៅបិណ្ឌបាតក្នុងព្រះបរមរាជវាំង ព្រះរាជាទ្រង់ឧបត្ថម្ភចង្ហាន់ បិណ្ឌបាតយ៉ាងប្រណីត ។ កាលបានចង្ហាន់

បិណ្ឌបាតហើយ ក៏ត្រឡប់ទៅអាកមវិញ ។ ក្នុងពេលដែលលោកត្រឡប់មកវិញនោះ ព្រះពជាទ្រង់បញ្ជាឲ្យហ្វដំរី លែងដំរីចុះប្រេងកាចសាហាវ ដេញព្រេច ។ តិស្សនាគឧបគតក្រះឡកឃើញដំរីក៏ដឹងថា ព្រះពជាទ្រង់ល្បងរិទ្ធិ ហើយចូលឈានសមាបត្តិ អធិដ្ឋានឲ្យដំរីនោះក្លាយទៅជាថ្មឈរនៅនឹងថ្កល់ ។ ព្រះពជាទ្រង់យាងតាមក្រោយ ដើម្បីលបមើល កាលឃើញដំរីក្លាយទៅជាថ្ម ក៏ដឹងថាព្រះថេរៈអង្គនេះប្រាកដជាមានឫទ្ធិមែន ទ្រង់ស្ញើចសរសើរព្រះថេរៈយ៉ាងក្រៃលែង ហើយចូលទៅថ្វាយបង្គំសូមព្រះថេរៈអត់ទោសឲ្យ ។ ព្រះថេរៈអត់ទោស ហើយធ្វើដំរីនោះឲ្យក្លាយទៅដូចប្រក្រតីដើមវិញ ។

ព្រះពជានិងមហាជនានុជនក្នុងព្រះនគរ ជ្រះថ្លាស្ញើចសរសើរបារមីព្រះថេរៈគ្រប់ ៗ គ្នា ។

ចាប់តាំងពីថ្ងៃនោះមក ព្រះពជាក៏ចាប់ផ្ដើមពិធីបុណ្យឡើង មានអុជប្រទីបផ្កាលាក្លំព្រោងព្រាតគ្រប់ព្រះស្តូបទាំងអស់ ។ ព្រះសង្ឃនិងមហាជនដែលជាពុទ្ធសាសនិក មកចូលរួមរួមក្នុងពិធីបុណ្យនោះយ៉ាងកុះករ ។

ពេលនោះ មារពធិកជ មានចិត្តបាប បង្កើតជាខ្យល់ព្យុះនិងភ្លៀងយ៉ាងខ្លាំង ដើម្បីធ្វើភ្លើងដែលអុជទាំងនោះឲ្យរលត់ ។ តិស្សនាគឧបគតក៏ចូលឈានសម្តែងរិទ្ធិគួបយកខ្យល់និងភ្លៀងនោះ ទៅពោលក្រៅកណ្ដាប់ចក្រវាឡ ។ មារពធិរាជ ក៏បណ្ដាលជាភ្លៀង គ្រាប់គ្រួស ភ្លៀងដុំថ្ម ភ្លៀង

រងើកភ្លើង និងភ្លៀងអាវុធផ្សេង ៗ ឲ្យធ្លាក់ចុះមកទៀត ព្រះថេរៈនេះ ក៏សម្តែងរិទ្ធិកួចយកភ្លៀងទាំងនោះ បោលទៅក្រៅចក្រវាឡទៀត ៗ មារា-ធិរាជបណ្តាលឲ្យងងឹតគ្រប់ទិសសានុទិស ៗ ព្រះថេរៈធ្វើឲ្យងងឹតនោះអន្តរធានទៀត ៗ មារាធិរាជ ក្រេវក្រោធយ៉ាងខ្លាំងនិម្មិតជាគោយ៉ាងធំ បោលទៅបម្រុងនឹងបុកពិធីនោះឲ្យវិនាសសូន្យសុង ៗ ព្រះថេរៈនិម្មិតជាខ្លាដេញខាំគោនោះ គោភិតភ័យស្រែកទូវសម្រែកយ៉ាងខ្លាំង ហើយក្លាយខ្លួនទៅជាស្តេចនាគមានក្បាល៧ ខ្លាធំក្លាយទៅជាស្តេចគ្រុឌចាប់ក្បាលនាគរួសចេញ ,នាគក្លាយខ្លួនទៅជាស្តេចយក្សយ៉ាងធំ កាន់ដំបងទន់ដៃងប៉ុនដើមត្នោត គ្រវីគ្រវាសបួលមកបម្រុងប្រហារស្តេចគ្រុឌ ៗ ស្តេចគ្រុឌក្លាយខ្លួនទៅជាស្តេចយក្ស ធំលើសនោះ២ដង ដៃទាំងពីរកាន់ដំបងយ៉ាងធំ ហើយចេញជាអណ្តាតភ្លើងដេញវាយយក្សមារនោះហូតដល់បរាជ័យ ៗ

មារតូចចិត្តណាស់គិតថា អញនិម្មិតខ្លួនទៅជារូបផ្សេង ៗ សម-ណៈនេះធ្វើបានគ្រប់ទាំងអស់ ហើយមានអានុភាពជាងអញដរាប អាត្មាអញឃើញថានឹងចាញ់សមណៈនេះប្រាកដ ៗ កាលគិតដូច្នេះហើយក៏សម្តែងរិទ្ធិឈរនៅចំពោះមុខព្រះថេរៈ ព្រះថេរៈឃើញមារហើយគិតថាអញនឹងធ្វើនូវមារនេះឲ្យអស់រិទ្ធិ អស់គំនិត មិនអាចនឹងកែខៃតទៅទៀតបាន លុះគិតហើយ ក៏និម្មិតជាឆ្កែស្អុយមានក្លិនអសោចគួរខ្ពើមរអើមក្រៃពេក យកទៅចងកមារាធិរាជ ហើយអធិដ្ឋានថា មនុស្សក្តី ទេវតាក្តី ឥន្ទព្រហ្មក្តី មិនអាចដោះស្រាយនូវចំណងនេះបានឡើយ ៗ មារាធិរាជកាល

ត្រូវចំណងដ៏អសោច៍ជាប់នឹងកហើយ អស់រឹទ្ធិ អស់តេជះ អស់គំនិត បញ្ញាបារមីរលីងពីខ្លួន នឹងស្រាយចំណង អសោចនោះមិនរួច ក៏ទៅកាន់សំណាក់ចតុលោកបាលទាំង ៤ អង្វរករឲ្យជួយដោះឆ្កែស្អុយចេញពីក ៗ ចតុលោកបាលប្រាប់ថា យើងមិនអាចនឹងស្រាយរួចទេ ៗ មារទៅកាន់សំណាក់សក្កទេវរាជ រហូតដល់ព្រហ្មលោក ជាទីបំផុត ៗ ទេវតាមានសក្កទេវរាជជាដើម មានព្រហ្មជាទីបំផុត ប្រាប់ថាយើងមិនអាចស្រាយចំណងសម្អុយនេះចេញបានទេ ព្រោះតិស្សនាគឧបគត លោកជាព្រះអរហន្តជាសាវករបស់ព្រះមានភាគ តែលោកចងហើយ មនុស្សក្តី ទេវតាក្តី ព្រហ្មក្តី មិនអាចស្រាយបានឡើយ ៗ ដូច្នេះ អ្នកឯងត្រូវចូលខ្លួនទៅកាន់សំណាក់លោក សុំទោសលោក ១ នឹងស្រាយវិញមិនខាន ៗ មារាធិរាជ អស់ទីពឹងហើយ ក៏ត្រឡប់ទៅកាន់សំណាក់ព្រះថេរៈ ថ្វាយបង្គំទាំងអៀនខ្មាស អង្វរសុំទោសព្រះថេរៈ ៗ ព្រះថេរៈឮពាក្យអង្វររបស់មារហើយ មានថេរៈវាចាថា នែមារអ្នកឯងចូរទៅកាន់ភ្នំធំឯណោះ ៗ

មារាធិរាជ ទៅតាមបង្គាប់ព្រះថេរៈ ១ ស្រាយសម្អុយឆ្កែនោះចេញពីក ហើយយកវត្តទ្ធចង្កេះចងកមារភ្ជាប់នឹងភ្នំ ហើយប្រាប់ថាអ្នកឯងត្រូវនៅទីនេះ ឲ្យអស់រយៈកាល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ៗ ព្រះថេរៈនិមន្តមកកន្លែងពិធីបុណ្យវិញ ៗ ពិធីបុណ្យនោះ បានប្រព្រឹត្តទៅយ៉ាងអធិករាធមសុខស្រួលរហូតដល់ចប់ ៗ

នៅពេលពិធីបុណ្យចប់សព្វគ្រប់ហើយ ព្រះថេរៈនិមន្តទៅកាន់ភ្នំ

ដែលបងមារនោះ តែលាក់ខ្លួន មិនឲ្យមារឃើញប្រុងស្តាប់មារនិយាយពីអ្វី ៗ ពេលនោះមារនិយាយថា ពីដើមអញបានធ្វើអំពើអាក្រក់ជាច្រើនចំពោះព្រះសម្មាសម្ពុទ្ធ តែព្រះអង្គមិនប្រទូស្តតបវិញសោះ មានតែព្រះទ័យប្រកបដោយមេត្តានិងខន្តី ឥឡូវនេះសាវ័ករបស់ព្រះអង្គ បែរជាមានចិត្តឃោរឃៅបានធ្វើទណ្ឌកម្មដល់អញយ៉ាងខ្លាំង ៗ

ព្រះថេរៈ គ្រាន់តែឮពាក្យនេះភ្លាម ក៏បង្ហាញខ្លួនហើយស្រាយចំណងនោះចេញប្រាប់ថា៖ នែមារ យើងធ្វើនេះ ដើម្បីជាកុសលរបស់អ្នកនិងទៀបង់នូវឧបសគ្គគ្រប់បែបយ៉ាងដល់ពិធីបុណ្យព្រះកជា ៗ ឥឡូវនេះអ្នកត្រូវមានគេស្រឡាញ់និងគោរព ព្រមទាំងបានជាអង្គព្រះសម្មាសម្ពុទ្ធមួយអង្គទៅអនាគត ៗ មារៈឆ្លើយថា មានសាវ័កជាច្រើន ដូចជាលោកម្ចាស់ជាដើម គ្មានមេត្តាធម៌បន្តិចសោះ អនាគត បើខ្ញុំបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ខ្ញុំខ្លាចក្រែងតែមានចិត្តឃោរឃៅដូចលោកម្ចាស់ ៗ ព្រះថេរៈថា៖ នែមារ អ្នកកុំគិតដូច្នោះ គឺដោយសារអានុភាពនៃយើងនេះហើយទើបអ្នកនឹងបានជាព្រះសម្មាសម្ពុទ្ធទៅអនាគត ៗ ពេលនោះ មារថា ខ្ញុំអាចនិម្មិតជាតួអង្គព្រះសម្មាសម្ពុទ្ធបានក្នុងកាលឥឡូវនេះ ៗ ព្រះថេរៈថាអ្នកចូលនិម្មិតជាតួអង្គព្រះសម្មាសម្ពុទ្ធឲ្យយើងឃើញផង ព្រោះយើងមិនដែលឃើញព្រះសម្មាសម្ពុទ្ធសោះ ឃើញតែធម៌និងវិន័យតែប៉ុណ្ណោះ ៗ មារថា៖ ខ្ញុំសុខចិត្តធ្វើតែលោកម្ចាស់កុំថ្វាយបង្គំខ្ញុំ ៗ ព្រះថេរៈក៏សុខចិត្ត ៗ មារចូលទៅក្នុងព្រៃហើយនិម្មិតជាតួអង្គព្រះសម្មាសម្ពុទ្ធ ប្រកបដោយមហា-

បុរិសលក្ខណៈ មានរស្មីភ្លឺផ្លេកត្រចះត្រចង់ មានទាំងអគ្គសាវ័កឆ្វេង-ស្តាំ ហែហមចេញពីព្រៃមក ៗ ឧបគតក្រឡេកឃើញ ភ្លេចពាក្យប្ដូរជាក៏ក្រាប ថ្វាយបង្គំ ៗ មារផ្លាស់ភេទមកដូចដើមវិញ ហើយសួរឧបគតថា ហេតុម្ដេចក៏លោកម្ចាស់ថ្វាយបង្គំខ្ញុំ ៗ ឧបគត ថា នែមារ អ្នកកុំថាយើងថ្វាយបង្គំអ្នកដូច្នោះ យើងថ្វាយបង្គំតួអង្គព្រះសម្មាសម្ពុទ្ធ ដែលយើងឃើញអំបាញ់មិញទេតើ ៗ មារពាល់ប្រាជ្ញក៏អង្គុយនៅស្ងៀម ៗ ចាប់តាំងពីថ្ងៃនោះមក មារក៏ចុះចូលក្នុងព្រះពុទ្ធសាសនារហូតមក ៗ

—ចប់—

វិចារណកថា

# ព្រះត្រៃបិដកជាមូលដ្ឋានមនោគមជាតិ

---

យើងទាំងអស់គ្នាបានស្ដាប់ ព្រះរាជសុន្ទរកថា ដ៏ពិរោះផ្អែមឆ្ងាញ់ មានសារៈជ្រាលជ្រៅជាអនេកប្បការ របស់សម្ដេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដ៏ជាទីគោរព ស្នេហាស្មើជីវិតរបស់យើង កាលក្នុងពិធីសម្ពោធព្រះត្រៃបិដកពីថ្ងៃទី២ មេសា ១៩៦៩ ។ ចំពោះព្រះរាជវាចានៅក្នុងព្រះរាជសុន្ទរកថានោះ ប្រសិនជាយើងគ្រាន់តែស្ដាប់ៗ រសជាតិពិរោះនោះឯង ហាក់ដូចជាធម្មតា ប៉ុន្តែបើយើងត្រិះរិះបណ្ដើរជាមួយព្រះសូរសៀង ឬយកអត្ថបទព្រះរាជសុន្ទរកថានេះ មកពិនិត្យឡើងវិញផងនោះ យើងនឹងរឹងរឹតតែកោតសរសើរស្ញប់ស្ញែងក្នុងចិត្តក្រៃលែងណាស់ ។ ព្រោះសេចក្ដីមួយៗក្នុងព្រះរាជវាចានោះ មានន័យធំទូលាយ អាចជាទ្រឹស្ដី ឬឱវាទដ៏កម្រកបាន ឬថា អាចទៅជាមេគំនិតក្នុងលទ្ធិជាតិនិយមជ្រៅជ្រះបំផុត មិនងាយប្រៀបផ្ទឹមបាន ។

ព្រះរាជឱវាទនេះហើយ ជាមូលដ្ឋាននៃមនោគមជាតិ ដែលកំពុងតែត្រូវការឲ្យមានគ្រប់គ្រាន់ នៅក្នុងគ្រាបច្ចុប្បន្ននេះ និងទៅអនាគត ។

ជាបឋម សម្ដេចឪជាអម្ចាស់ ព្រះអង្គទ្រង់ត្រាស់រំឭកចំពោះយុវជន ដែលកំពុងតែសិក្សាក្រេបជញ្ជាក់រសជាតិវិទ្យាសាស្ត្រសម័យថ្មី ព្រមទាំងវិជ្ជាផ្លូវលោកទូទៅ ប្រកបដោយល្បឿនយ៉ាងខ្លាំង ។ សម្ដេចជាអម្ចាស់ ទ្រង់

*ដោយបញ្ជាក់ច្បាស់ពន់ពេកណាស់ ឲ្យយុវជនយើងយល់ថា ការភ័ន្តច្រឡំរបស់អ្នកខ្លះ ដែលរវាតចិត្តចេញពីព្រះពុទ្ធសាសនា ហើយបែរទៅជ្រើសយកគោលទ្រឹស្ដីដែលជាមនោគមវិជ្ជាបរទេសមកដាក់ខ្លួននោះ ជាហេតុនាំឲ្យកើតវិនាសហិនហោចដល់ខ្លួនទៅវិញទេ គឺថា មនោគមវិជ្ជានោះឯង មានប្រយោជន៍ចំពោះជាតិគេមែន រីឯយើងឯនេះវិញ មិនអាចទទួលផលរបស់គេនោះកើតទេ ព្រោះខុសផ្លូវអំពីឧត្តមប្រយោជន៍ជាតិយើង ។*

*ត្រង់នេះ ព្រះរាជបន្ទូលបានថ្លែងថា ៖*

យុវជនយើង បើពុំបានទទួលព្រះពុទ្ធោវាទនិងទស្សនវិជ្ជាតាមផ្លូវព្រះពុទ្ធសាសនាទេ នឹងគ្មានអាវុធអ្វីសម្រាប់ការពារខ្លួន ទល់នឹងមនោគមវិជ្ជាបរទេស ដែលមានតម្លៃតាមរបៀបគេដែរ , ក៏ប៉ុន្តែនៅប្រទេសកម្ពុជា មនោគមវិជ្ជាបរទេសទាំងនោះ គ្មានបានហុចផលអ្វីក្រៅអំពីការច្របូកច្របល់គ្នានិងការភ្លាំងភ្លាត់ស្មារតីដ៏ខ្លោចផ្សា ដែលនាំឱ្យដើរខុសផ្លូវ ផ្ទុយនឹងឧត្តមប្រយោជន៍ជាតិ ហើយដែលយើងចាប់ទទួលផលអាក្រក់ខ្លះៗ ទៅហើយ នោះទេ ។ អាស្រ័យហេតុនេះ ព្រះត្រៃបិដកប្រែ បាលី - ខ្មែរ, ដែលយើងមាន ចាប់តាំងពីពេលនេះទៅ មានសារៈសំខាន់ណាស់ ក្នុងការពង្រីកផ្សព្វផ្សាយព្រះពុទ្ធោវាទ នៃព្រះបរមគ្រូនៅក្នុងសង្គមជាតិយើង ។

*បន្ទាប់ពីនេះ សម្ដេចឪអគ្គមគ្គុទេសក៍ជាតិ ទ្រង់ប្រោសព្រះរាជទានបញ្ជាក់ចំពោះយុវជនដែលមានការសិក្សាជ្រាលជ្រៅ ទៅក្នុងវិជ្ជាជាន់ខ្ពស់*

សម័យថ្មី ហើយដែលច្រើនយល់ច្រឡំថាក្បួនខ្នាតខាងព្រះពុទ្ធសាសនា មិនសូវជាសារៈប្រយោជន៍សម្រាប់ខ្លួន មានតែព្រះសង្ឃទេដែលលោកត្រូវការរៀនសូត្រ ចំណែកខ្លួនស្ថិតនៅក្នុងវិជ្ជាលោកទំនើបថ្មីផ្សេងប្លែកពីគម្ពីរទាំងនោះ ហើយអ្នកខ្លះរហូតដល់ទៅហ៊ានថាវិជ្ជាផ្លូវលោករបស់ខ្លួននោះ មានសុក្រិតភាពលើសលែងផង ។ ចំពោះការដោះស្រាយកំហាត់សំអាងឥតន័យទាំងនេះ សម្ដេចឪជាអម្ចាស់ទ្រង់ត្រាស់ដោយបញ្ជាក់នូវរសជាតិចំណីអាហារកើតពីព្រះត្រៃបិដក មានសេចក្ដីថា៖

ព្រះត្រៃបិដកនេះ មិនផល់ឧត្តមប្រយោជន៍ចំពោះតែព្រះសង្ឃទេ យុវជនយើងដែលជាអនាគតរបស់ជាតិ ហើយដែលទទួលចំណេះវិជ្ជាជ្រៅជ្រះខាងច្បាប់ ឬខាងអក្សរសាស្ត្រ, ខាងវិទ្យាសាស្ត្រ ឬខាងវិជ្ជាបច្ចេកទេសសម័យថ្មី ក៏មានលទ្ធភាពអាចក្រេបជញ្ជក់នូវរសជាតិ នៃអាហារខាងផ្លូវចិត្តគំនិតប្រាជ្ញាពីព្រះត្រៃបិដកនេះបាន ដូចព្រះសង្ឃយើងដែរ ។

តពីនេះមកទៀតព្រះបិតាជាតិទ្រង់ក្រើនរំឭកចំពោះអគ្គការរដ្ឋ និងអ្នករាជការទូទៅ សូមឲ្យចាប់អារម្មណ៍យ៉ាងណាស់ទៅលើព្រះត្រៃបិដករបស់ខ្មែរយើងនេះ ដោយព្រះអង្គទ្រង់បង្ហាញហេតុផល ចំពោះការអាន ការសិក្សាព្រះត្រៃបិដក ដែលអាចផ្ដល់មកវិញ នូវការចម្រើនលូតលាស់ខាងផ្លូវចិត្ត ពោលគឺមានប្រាជ្ញាវាងវៃ មានគំនិតទូលំទូលាយ មានការចេះដឹងទូទៅ និងមានចរិយាមារយាទប្រពៃថ្លៃថ្លា សមរម្យថ្លៃថ្នូរទៅតាមសង្គមជាតិដែលមានវឌ្ឍនភាពក្នុងគ្រាសព្វថ្ងៃ ។ មិនតែប៉ុណ្ណោះអាចបណ្ដុះស្មារតី

*ឲ្យជនអ្នកសិក្សានោះឯង មានឆន្ទៈល្អហ្មត់ហ្មង់ក្នុងការកសាងកម្ពុជរដ្ឋជាប្រទេសជាតិនៃយើង ឲ្យនៅមានលក្ខណៈល្អស្អាតជាខ្មែរព្រមទាំងឲ្យមានសភាពស្អាតស្អំបរិសុទ្ធក្នុងការងារបំរើកិច្ចការរដ្ឋ ពោលគឺការងារអចិន្ត្រៃយ៍របស់អ្នករាជការទាំងនោះ ហើយទីបំផុតអាចជាកម្លាំងមោះមុត ជួយរុញច្រានការកសាងជាតិឲ្យមានប្រសិទ្ធិភាពគ្រប់វិស័យផង ។ ព្រះរាជបណ្តាំនេះ មានសេចក្តីថា ៖*

ខ្ញុំសូមបន្ថែមថា សមាជិកគ្រប់ជាន់គ្រប់ថ្នាក់នៃអង្គការរដ្ឋ និងរាជការយើង ក៏ត្រូវតែចាប់អារម្មណ៍ចំពោះព្រះត្រៃបិដកនេះ ពីព្រោះសមាជិកគ្រប់រូបនោះ បើប្រសិនជាខ្លួនហើយ មានបំណង ចង់លូតលាស់ខាងផ្លូវចិត្ត ហើយមានឆន្ទៈចង់ជួយកម្ពុជរដ្ឋឱ្យនៅជាខ្មែរហើយ ជួយអង្គការរដ្ឋ រាជការជាតិ ឱ្យមានសភាពស្អាតស្អំ និងប្រសិទ្ធិភាពក្នុងវិស័យកសាងជាតិ ត្រូវតែមានព្រះត្រៃបិដកមួយចប់ នៅកំដរដំណេកខ្លួន ។

*ព្រះរាជបន្ទូលនៅចុងឃ្លានេះថា „ត្រូវតែមានព្រះត្រៃបិដកមួយចប់នៅកំដរដំណេកខ្លួន„ បានសេចក្តីថា ការសិក្សានេះមិនចាំបាច់ហ្វឹកហ្វឺនក្នុងសាលា ចំពោះមុខគ្រូអាចារ្យណាឡើយ ព្រោះអ្នកសិក្សានេះជាអ្នកចេះដឹងដែរហើយ មានវ័យក៏ចម្រើនដែរហើយ អាចអានសៀវភៅផ្សំជាមួយការត្រិះរិះរបស់ខ្លួនទៅ ក៏អាចនឹងបានយល់ហូរហៅដែរ ។ ប្រសិនជានៅងឿងឆ្ងល់ត្រង់អន្លើខ្លះ យើងអាចចាំទុក ឬកត់ត្រាទុក យកទៅសាក*

សួរលោកអ្នកប្រាជ្ញណាមួយ ក៏នឹងបានយល់ថែមឲ្យច្បាស់ជាមិនខាន ។ ឯពាក្យថា "នៅកំដរដំណេក" នោះ សម្រាប់ជម្រះសេចក្តីចង្អៀតចង្អល់របស់ជនខ្លះ ដែលតែងតែត្អូញត្អែរថា "គ្មានពេលទេ មួយថ្ងៃៗ រវល់ណាស់ កិច្ចការច្រើនធ្វើសឹងតែមិនអស់ពីលើគុ" កិច្ចការច្រើនពិតហើយតែនៅពេលមុននឹងសម្រាន្តលក់ គេអាចច្នៃតកអានសៀវភៅក្បួនខ្នាតទាំងនេះបានខ្លះដែរ ។ ម្ល៉ោះហើយ ក្បួនខ្នាតនេះ ត្រូវនៅជាគ្រឿងកំដរដំណេកជាដរាប ។

មុននឹងបញ្ចប់ព្រះរាជនិពន្ធក្នុងព្រះសុន្ទរកថានាវេលានោះ សម្តេចឪព្រះឧត្តមគុទេសក៍ជាតិ ទ្រង់ត្រាស់ផ្តាំយ៉ាងច្បាស់លាស់ថា ៖

"ខ្ញុំយល់ ហើយជឿជាក់ណាស់ថា យើងពុំអាចរកការពិត និងផ្លូវត្រូវឃើញ នៅទីដទៃណា ក្រៅពីព្រះធម៌នេះទេ ។"

ព្រះរាជបន្ទូលថា "ព្រះធម៌" ក្នុងទីនេះ សំដៅដល់ព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម ដែលមានក្នុងព្រះត្រៃបិដក ដែលអាចចាត់ទុកជាមូលដ្ឋាននៃឧត្តមជាតិ ព្រោះថាគោលនយោបាយខ្មែរ ដែលសម្តេចឪព្រះអង្គទ្រង់បង្កើតឡើងនោះ គឺ "សង្គមនិយមព្រះពុទ្ធសាសនា" បានន័យថា យើងយកទ្រឹស្តីដ៏ពិសិដ្ឋនៃព្រះសម្មាសម្ពុទ្ធធ្វើជាមូលដ្ឋាន ។ ទ្រឹស្តីដ៏ពិសិដ្ឋនេះហើយ គឺជាគម្ពីរព្រះត្រៃបិដក ។

រៀប-រៀងសម្រួល ដោយ

លី-ធាមតេង

នៅវិទ្យាល័យ ពុទ្ធសាសនបណ្ឌិត្យ

## ផ្នែកអក្សរសាស្ត្រ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(គ)

*ព្រះមហា ចាំង-ចាត់ រៀបរៀង*

អភិវធិ ធាតុ ភិយ ។

អភិវន្ទ ធាតុ ថ្វាយបង្គំ គោរព ។

អភិវន្ទន នបុំ. អភិវន្ទន៍ កិរិយាថ្វាយបង្គំដោយគោរព ។

អភិវណ៌ន នបុំ. អភិពណ៌ន ពិពណ៌នា ។ វណ៌ិត គុ. ដែលពិពណ៌នា ។

អភិវតិន គុ. ដែលទៅជួប ។

អភិវធិន នបុំ. អភិវឌ្ឍន៍ កិរិយាចំរើន ។

អភិវេបិ បុំ. ភ្លៀង ។ វេបិន គុ. ដែលភ្លៀង ។ - វេបិណា គុ. ដែលភ្លៀង ។ នបុំ. ភ្លៀង កិរិយាភ្លៀង ។

អភិវ្ឫត្ត ធាតុ លោតរំលង ។

អភិវស៊ ធាតុ នៅសំចត ។

អភិវហ៊ ធាតុ នាំទៅ ។

អភិភូ ធាតុ ផ្ទុំ ។

អភិវាញ្ឆ ធាតុ. ចង់បាន ។ វាញ្ឆិត គុ. ដែលចង់បាន ។ នបុំ.

ប្រាថ្នា ៗ

អភិវាញ្ឆា ស្រ្តី. បំណង ។

អភិវាទ បុំ អភិវាទ កិរិយាបង្គំ ។សំដីមើលងាយ ។

អភិវាទក គុ. អ្នកថ្វាយបង្គំ ។-វាទនីយ ឬ វាទ្យ គុ. ដែលគួរ

ថ្វាយបង្គំ ។

អភិវាទិន ការក. អភិវាទិន អ្នកបកភាសា ។

អភិវាសិ ធាតុ. ស្រែកគ្រលួច ។

អភិវាហ្យ នបុំ. កិរិយាគួរនាំយកទៅ កិរិយានាំ ។

អភិវិក្រម គុ. អភិវិក្រម ក្លាហានក្រៃលែង ។

អភិវិខ្យាត គុ. ដែលល្បីល្បាញ ។

អភិវិជ្ញា ធាតុ ដឹងច្បាស់ ។

អភិវិជ្ញេយ គុ. ដែលគប្បីស្គាល់បាន ។

អភិវិជ្វល ធាតុ ឆេះទ្រលោម ។

អភិវុធ ធាតុ ចំរើន និយាយចំរើន ។

អភិវិទ៑ ធាតុ ឃើញ ស្គាល់ ។

អភិវិទីបិត គុ. ដែលដេះខ្ទក ។

អភិវិទ្ធ គុ. ដែលមុត ដែលត្រូវរបួស ។

អភិវិទ្រុ៑ ធាតុ គេចរត់ ។

អភិវិនទ៑ ធាតុ ស្រែកធំទៀល។ -នាទិត គុ ដែលលាន់លឺ ។

អភិវិនីត គុ. ដែលចេះដឹង ជំនាញ ។

អភិវិនុទ៑ ធាតុ ធ្វើឲ្យស្ងប់ ធ្វើឲ្យរីករាយ ។

អភិវិបន្យ គុ. ដែលឆ្លៀងឆ្លាស្រឡះ ។

អភិវិមាន គុ. អភិវិមាន , ដែលមានគំនិត ? ។

អភិវិរាជ៑ ធាតុ ភ្លឺក្រៃលែង ។ - រាជិត ដែលភ្លឺច្បាស់ ។

អភិវិរុច៑ ធាតុ រុងរឿង ព្រោងព្រាយ ។

អភិវិស៑ ធាតុ ចូលក្រៃលែង ផុងខ្លួន ។-វិដ្ឋ គុ. ដែលផុងខ្លួន ។

អភិវិសង្កិន គុ. ដែលខ្លាច ។

អភិវិស្ស ធាតុ បែកជាចំណែក ៗ

[illegible] គុ [illegible]

[illegible] ធាតុ [illegible] ។

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ញូ-កាន

ប្រែ-រៀបរៀង

(៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ     អ្នកភិងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលចំណាន     ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

ខុងបេងបានឃើញដូច្នោះ ក៏រឹតតែមានសេចក្តីត្រេកអរពន់ប្រមាណណាស់ ក្រាបសំពះដោយសច្ចៈគារពហើយ ក៏ចុះចាកសាលទេព្រ័ក្សឡើងរទេះត្រឡប់មកបន្ទាយ, លុះដល់ពេលព្រឹក ខុងបេងក៏បបួលគងប៉េងនិងទាហានទាំងពួងដែលគមិនបេះស្តី ស្រូតទៅរើសស្ទឹកឈើតាមពាក្យទេព្រ័ក្សថា, លុះឆ្លងភ្នំស័នសុកទៅ ចម្ងាយ ២០ សិន ឃើញដើមឈើធំនៅក្បែរមាត់ជ្រោះ ជាច្រើនណាស់ ហើយមានផ្ទះអ្នកស្រុកនៅក្នុងព្រៃនោះប្រមាណផ្ទះ ១០ ខ្នង, ខុងបេងបានឃើញក្មេងម្នាក់ដើរមក ក៏អរណាស់ ខំដើរប្រួតរះចូលទៅជិត ខទួលបេងចៀត ពាក់អាវសម្លូកផ្តៅ សក់លឿង ក្អែកក្រហាមដើរចេញមក ឃើញខុងបេងក៏សួរថា អ្នកនេះឬជាមហាឧបរាជស្រុកសែឈួន? ខុងបេងសើចហើយថា ហេតុម្តេចបានជាអ្នកស្គាល់ខ្ញុំ? បេងចៀតឆ្លើយថា ខ្ញុំដឹងស្គាល់មកយូរហើយ ថាមហាឧបរាជលើកកង

ទ័ពមកច្បាំងនឹងបេងហេក នឹងបង្ក្រាបក្នុងដែននេះ, បេងបៀតក៏អញ្ជើញខុងបេងចូលទៅក្នុងផ្ទះអាត្មា; ខណៈនោះខុងបេងនិយាយនឹងបេងបៀតថា តម្រាស់ព្រះចៅឡើសៀន ឲ្យខ្ញុំលើកទ័ពមកប្រាបប្រាមបេងហេក ឲ្យចំ-ណុះចុះចូលះឡើងស្តាប់បង្គាប់ស្រុកសៃឈួនឲ្យបាន ឥឡូវបេងហេកមិនហ៊ានតដៃ រត់ទៅនៅក្នុងព្រៃភ្នំអិមតង់ស័ន ខ្ញុំលើកទាហានទៅដល់ផ្លូវទិសខាងលិចភ្នំ, ពួកទាហានខ្ញុំចុះផឹកទឹកជ្រោះមួយអន្ទើ ក៏ទៅជា-គទាំងអស់, ទេព្រ័ក្សប្រាប់ខ្ញុំ ថាមានថ្នាំកែទឹកពុលនោះនៅតំបន់នេះ បានជាខ្ញុំខំស្រូតរូតមករកអ្នក ប្រាថ្នានឹងរកថ្នាំនោះ, អ្នកចូរមេត្តាណែបង្ហាញឲ្យខ្ញុំទៅរកផង ដើម្បីនឹងបានជួយជីវិតមនុស្សឲ្យរស់រួចតទៅ ។

បេងបៀតថាខ្លួនខ្ញុំជាអ្នកព្រៃថោកទាបណាស់ មិនគួរមហាឧបកជខំស្វែងសួរមកខ្លួនឯងឲ្យព្រួយទេ, បើប្រើតែកូនទាហាន១ ឲ្យមករកខ្ញុំក៏បាន, ឯថ្នាំសោត ក៏មាននៅក្រោយភូមិច្រើនណាស់, បើមហាឧបកជនឹងត្រូវការដូចម្តេចខ្លះ ក៏ឲ្យមនុស្សទៅរើសយកចុះ; ហើយបេងបៀតក៏ឲ្យក្មេងម្នាក់នាំអង់បេង និងទាហានដែលគនោះចេញទៅដល់ទីជ្រោះ, ទាហានទាំងនោះបានផឹកទឹកជ្រោះទាំងអស់គ្នា ក៏ក្អួតធ្លាក់ស្លេស្មាគ្រក់ចេញមកអស់ហើយបានស្តីនិយាយគ្នាជាឡើងវិញដូចដើម; បេងបៀតក៏និយាយនឹងខុងបេងថា ផ្លូវដែលលោកនឹងទៅលើភ្នំអិមតង់ស័ននោះ ឆ្ងាយដាច់ស្រយាលណាស់ ប្រកបទៅដោយសត្វកាចសាហាវផ្សេង ៗ, លោកចូររើសយកស្លឹកឈើហុយហៀបនេះទៅឲ្យច្រើន នឹងបានការពារអន្តរាយតាមផ្លូវនោះ, ខុងបេង

បានស្តាប់ពាក្យដូច្នោះក៏ឆ្លើយតបថា អ្នកមានសេចក្តីមេត្រីនឹងខ្ញុំច្រើនណាស់, អ្នកឈ្មោះអ្វី ? សែអ្វី ? បើខ្ញុំបានធ្វើការសម្រេចសេចក្តីប្រាថ្នាហើយ ខ្ញុំនឹងបានតបស្នងសងគុណអ្នកវិញ ។

បេងចៀតឆ្លើយថា ខ្ញុំឈ្មោះចៀត សែបេង ជាបងបេងហេកបង្កើត, ខុងបេងបានឮជាក់ដូចគេភ្ញាក់លោះព្រលឹងដក ដង្ហើមធំហើយថា យីដូច្នោះឬ? បេងចៀតថា លោកកុំមានពិការល់ឆ្ងល់សង្ស័យចិត្តទៀតតែខ្ញុំជាបងប្អូនដូច្នោះ ព្រោះខ្ញុំជាបងរួមផ្ទៃមួយនឹងបេងហេកក៏មែន តែថាបេងហេក-បេងហ៊ីវ វាជាមនុស្សអន្ធពាលចិត្តបាប វាមិនបានយកច្បាប់តម្រាខ្ញុំជាបង បានជាខ្ញុំលះលែងចងមេត្រីជាសារលោហិតនឹងវា ដកឃ្លាមកពួនទៅទីនេះ ប្រាថ្នានឹងរកសេចក្តីសប្បាយ, ឥឡូវប្អូនខ្ញុំធ្វើការទាំងឡាយខុសមិនត្រូវនឹងផ្លូវប្រវេណី បានជាមហាឧបរាជមានទ័លំបាកមកដល់ស្រុកនេះ, ខ្លួនខ្ញុំជាបង ក៏គង់មានគំណុំនេះគេតិះដៀលបាន, ហេតុនេះ តាមតែមហាឧបរាជប្រោសប្រាណឲ្យមានអាយុជីវិតតទៅផងចុះ ។

ខុងបេងថា អ្នកកុំព្រួយបារម្ភឡើយ, ឯបេងហេកបេង-ហ៊ីវនោះឃើញថាវាជាមនុស្សដូជាតិមារយាទអាក្រក់ណាស់, វាប្រព្រឹត្តខុសទាស់តែពីខ្លួនវា ខ្លួនអ្នកជាមនុស្សល្អ មានសេចក្តីសត្យត្រង់នឹងខ្ញុំ ។ ក៏ត្រូវស្រឡាញ់រាប់អានដោយស្មោះ, បើកាលណាខ្ញុំធ្វើការនេះរួចទាំងអស់ត្រឡប់ចូលទៅស្រុកក្រុងវិញ ខ្ញុំនឹងក្រាបទូលព្រះចៅឡៅសៀនឲ្យស្តេចតែងប្រកាសតាំងអ្នកជាធំក្នុងដែននេះតទៅ ។

បេងបៀតថា ដែលប្រសាសន៍ប្រោសអនុកូលតាំងម្ល៉េះ ព្រះតេជព្រះគុណមិនមានទីបំផុត តែចិត្តខ្ញុំបាទស្រឡាញ់តែសេចក្តីសប្បាយស្ងាត់ ៗ មិនចូលចិត្តនឹងយសសក្តិសម្បត្តិស្តុកហ៊ានជាធំទេសោះ; ខុនបេងឮដូច្នោះ ក៏ឲ្យរបស់ទ្រព្យមានតម្លៃដល់បេងបៀតជាច្រើន, បេងបៀតក៏មិនបានទទួលយករបស់នោះ បែរជាលើកប្រគល់ឲ្យខុនបេងវិញ, ខុនបេងក៏លាបេងបៀតឡើងរទេះគួបនាំទាហានត្រឡប់មកបន្ទាយ ។

ខុនបេងក៏ឲ្យទាហានតាំងឡាយជីកអណ្តូងក្នុងបន្ទាយ១ អន្ទើ ជម្រៅ ៤០ ព្យាម ប្រាថ្នានឹងអាស្រ័យទឹក, ខុនបេងនឹងទាហានទាំងពួង ឃើញអណ្តូងនោះស្ងួតក្រៀមគ្មានទឹកសោះ ក៏ព្រួយបារម្ភពន់ប្រមាណ លុះវេលាយប់ខុនបេងក៏អុជទៀនធូបអធិដ្ឋានបូជាទេវតា ហើយប្រកាសថា ខ្ញុំម្ចាស់ខុនបេង តាំងចិត្តធ្វើរាជការថ្វាយចំពោះព្រះតេជព្រះគុណព្រះចៅឡៅពីដោយសុចរិតបានជាគិតលើកព្រះចៅឡៅសៀនឡើងគ្រងរាជសម្បត្តិ តាំងចិត្តថានឹងឲ្យបណ្តារាស្ត្របានសេចក្តីសុខសប្បាយតទៅ ឥឡូវពលទាហានគ្មានទឹកបរិភោគជាកម្លាំងសោះ, បើបុណ្យព្រះចៅឡៅសៀនមិនអស់ នឹងបានជាធំ, ខ្លួនខ្ញុំនៅបានជាអ្នកទំនុកបម្រុងតទៅ, ក៏សូមឲ្យទេវតាមកជួយបើកផ្លូវទឹកក្នុងអណ្តូងទាំងប៉ុន្មានឲ្យមានបរិបូណ៌ចុះ ដើម្បីជួយឲ្យរស់ជីវិតពលទាហានទាំងអស់នេះតទៅ, បើព្រះចៅឡៅសៀនគ្មានបុណ្យតទៀតទេ, ចូរបណ្តាលឲ្យខ្ញុំខុនបេងដ៏មានបុព្វអភ័ព្វស្លាប់ក្នុងខណៈនេះទៅចុះ, កុំបីឲ្យខ្ញុំមានអាយុរស់នៅឃើញទុក្ខភ័យណាឡើយ លុះផ្សងសច្ចារួចហើយ

កំចូលនិទ្រា ។

លុះពេលព្រឹកភ្លឺស្រាងកាលណា តាហានចូលទៅជម្រាបខុនបេងថា អណ្តូងដែលជីកទុកទាំងប៉ុន្មាន មានទឹកចេញពេញប្រៀបទាំងអស់, ខុន-បេងបានឮដូច្នោះ ក៏សប្បាយចិត្តសោមនស្ស បង្គាប់ឲ្យពលយោធាផង ផ្លូតជីកស្រេចហើយ ក៏លើកទ័ពគគ្រឹកឡើងទៅលើភ្នំមិតងស៊ន ហើយ ឲ្យដងទឹកនោះទៅជាកំណាន់សម្រាប់ផឹកតាមផ្លូវ ។

ឯតាហានល្បាត ក៏នាំគ្នាទៅប្រាប់បេងហោកថា ឥឡូវខុនបេង លើកទ័ពលួងចូលទៅទិសឯលិច ចូលមកបានហើយ, បេងហោកឮដូច្នោះ ក៏ភ័យណាស់, តោស៊ូតែអង ក៏និយាយទៅបេងហោកថា អ្នកកុំអាល ព្រួយបារម្ភដំណឹងដែលឮមកនេះ នៅមិនទាន់សមប្រកបទេ ចាំពិនិត្យ គិតគ្នាឲ្យឮនឹងត្រចៀកឃើញច្បាស់នឹងភ្នែកសិន, តោស៊ូតែអងក៏ឡើង ទៅឈរសម្លឹងមើលលើកំពូលភ្នំ ឃើញខុនបេងលើកទ័ពជំជិតចូលមក ឃើញតាហាននាំយកទឹកកៅកសែងជាច្រើនណាស់, តោស៊ូតែអងពិភាល់ ណាស់ក៏ត្រឡប់ចុះមកប្រាប់បេងហោកថា ខុនបេងលើកទ័ពមកបានមែន ហើយ ខ្ញុំសែនធ្ងល់ណាស់ ប្រហែលជាទេព្រ័ក្សអ្នកតាបទោប្រាប់ដំណើរ ទំនងខុនបេងជាប្រាកដ ។

បេងហោកថា បើដូច្នោះ ខ្ញុំនឹងបេងហ៊ុំកើរខាក់ចង់ប្អូន នឹងណាបោក ចេញទៅតស៊ូនឹងខុនបេងឲ្យត្រង់កៃទាស់ជាតែនៅទីនេះចុះ មិនឲ្យតាហាន

ខាងណោះ ចាប់ចងទៅឲ្យខុងបេងមើលមុខទៀតទេ, តោស៊ូតែអងថា ខ្ញុំនឹងអ្នកនឹងខ្ញុំ ជាពួកជាមួយគ្នា បើអ្នកចាញ់ប្រៀបខុងបេងកាលណា ខ្ញុំជាស្ម័គ្របក្សពួកដោយសារ ខុងបេងក៏គង់មិនទុកអាយុជីវិតដែរ ។

ខណៈនោះតោស៊ូតែអង ក៏ឲ្យសម្លាប់គោក្របីលៀងស្រាបណ្តាពលទាហានទាំងពួង ដើម្បីនឹងរៀបចំលើកកងទ័ពទៅច្បាំងនឹងខុងបេង, ទទួលមានទាហានចូលមកប្រាប់ថា អៀវហង ដែលជានាយធំនៅក្នុងនិគិស័ន លើកទាហាន ៣០.០០០ មកជួយ តោស៊ូតែអងបានឮដូច្នោះក៏មានអំណរណាស់ចេញទៅទទួលគំនាប់គ្នាតាមប្រវេណី ហើយនាំទាហាននិងអៀវហងចូលទៅក្នុងទីលំនៅ ។

អៀវហងសួរថា កូនខ្ញុំ ៤ នាក់នេះ មានសតិបញ្ញានិងប៉ីដៃខ្លាំងពូកែណាស់ ទាំងពលទាហានខ្ញុំក៏មានកម្លាំងក្លាហាន ពាក់គ្រោះដែកស្មើគ្រប់គ្នា, បើខុងបេងលើកពលយោធា១៥០ម៉ឺន ចូលមក សូម្បីតែត្រឹមកម្លាំងក៏នឹងសុំអាសាយកជ័យជម្នះឲ្យបាន, ហើយក៏ហៅកូនទាំង ៤ នាក់ឲ្យចូលមកគំនាប់តោស៊ូតែអងនិងបេងហេក ។ ឃើញបុត្រអៀវហងមានរូបរាងមុតមាំសមដូចខ្លាដំកាច ក៏មានសេចក្តីត្រេកអរណាស់ ទើបរៀបតែងលៀងអាហារឲ្យអៀវហងនិងបុត្រ ៤ នាក់បរិភោគជាមួយគ្នា ។

ខណៈកាលកំពុងសេពសុរានោះ អៀវហង តែងធ្វើស្រវឹងស្រា ហើយសម្តែងឫទ្ធិក្លៀវក្លាផ្សេងៗ មានកាំភ្លើងលំពែងនិងភ្លុកដែលលោតក្រវែលគ្រវាត់ថា បើខុងបេងមកកាលណា យើងនឹងកាត់សិរសាដោយ

អាវុធនេះ ទទួលមានស្រី១០នាក់ដែលអៀវហានផ្ញើកលមកនោះ រំសាយសក់ដើរចេញមកទះដៃធ្វើជាក្មេង អៀវហានក៏ឲ្យបុត្រយកពែងស្រា ងើយមុខឡើងនឹងផឹក, អៀវហានស្រែកឡើងតាមសញ្ញា, បុត្រអៀវហានក៏ម្នីម្នាស្ទុះស្រវាទៅព្រួតចាប់ចងចេងហេកនិងចេងហ៊ាវបាន, តោស៊ូតែអង់ឃើញដូច្នោះក៏ភ័យណាស់ ក្រោកឡើងគិតនឹងរត់ អៀវហាន ក៏ព័ទ្ធរួបចាប់បានទាំង៣នាក់, ស្រី១០នាក់ក៏ស្ទុះប្រពូនប្រញាក់ចូលទៅជួយចងចេងហេក, ចេងហេកថា អៀវហាន អ្នកឯងនិងយើង មិនដែលមានទោសទាស់ខុសចិត្តគ្នាអំពីអ្វីសោះ ហេតុម្តេចអ្នកឯងមានសេចក្តីអាឃាដព្យាបាទយើងដូច្នេះព្រោះប្រយោជន៍អ្វី? អ្នកឯងធ្វើដូច្នេះ អំណោះទៅមុខគង់នឹងមានទុក្ខក្តៅក្រហាយ, អៀវហានថា មហាឧបរាជស្រុកសែលឈួនមានចិត្តសប្បុរសមេត្តាដល់បណ្តាសត្វទាំងពួងណាស់ ចាប់បានកូនចៅយើង ច្រើនក្រៃក្រាស់ហើយទុកអាយុមិនសម្លាប់ ត្រឡប់បើកលែងមកវិញអស់, យើងគិតដល់គុណ ដែលគេមានសប្បុរសមេត្តា បានជានាំគ្នាមកចាប់អ្នកឯងយកទៅជូនមហាឧបរាជជាសេចក្តីតបគុណ ព្រោះយើងឃើញអ្នកឯងជាមនុស្សអា-ក្រក់សឹងពន់ប្រមាណ គ្មានស្គាល់គុណទោសសោះ គឺជាមនុស្សទុរយសទ្រុស្តអ្នកល្អ,ហើយអៀវហានស្រែកប្រកាសប្រាប់ទាហានទាំងពួងថា ចេងហេកធ្វើសេចក្តីខុស ឲ្យអស់អ្នកពលគ្នាបានសេចក្តីក្តៅក្រហាយ, គ្រានេះយើងប្រើកលឧបាយចាប់ខ្លួននាំយកទៅជូនទុងចេងហើយ អ្នកទាំងឡាយចូរត្រឡប់វិលទៅកាន់ភូមិស្រុក នៅជាសុខដោយករិយាបុត្រចុះ, ហើយ

អៀវហេងនោះ ក៏នាំយកខ្លួនបេងហោក បេងហ៊ុវ និង តោស៊ូតៃអង ទាំងចំណងទៅជូនខុងបេងក្រោយបន្ទាយ ។

ខុងបេងដឹងដូច្នោះ ក៏សោមនស្សប្រីតា ហៅអៀវហេងម្នីម្នានាំទៅធ្វើបដិសណ្ឋារៈគំនាប់ដោយប្រពៃ ហើយអៀងហេងក៏ស្រដីជម្រាបខុងបេងថា ខ្ញុំបាទជាមេឃុំត្រួតលើទីក្នុងនិតិស័ន មានចិត្តប្រតិព័ទ្ធគិតដល់គុណមហាឧបការដែលបានទុកអាយុជីវិតលែងញាតិមិត្រនិងកូនចៅខ្ញុំបាទ ឲ្យវិលមកស្រុកភូមិវិញ បានជាខ្ញុំបាទអស់អញលំគេញចិត្តគិតឧបាយ ចាប់ខ្លួនបេង-ហោក-បេងហ៊ុវនាំមកគាប់ស្នងសងគុណលោក, ខុងបេងក៏ឲ្យរង្វាន់បំណាច់ជាគ្រឿងឧបភោគដល់អៀវហេងច្រើនណាស់ ហើយឲ្យយកខ្លួនបេងហោកចូលទៅ ខុងបេងក្រឡេកឃើញបេងហោកក៏សើចហើយថា អ្នកឯងនឹងព្រមចំណុះចុះចាញ់យើងហើយឬនៅ? ។

(នៅមានត)

*

*   *

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក ក៉ាប៉ិទ្រ ណាត តាម្ព័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ២២

កប៉ាល់ដែលនាងកាមាលានិងក៉ាមេស្ហជិះដល់ម៉ោងហើយក៏ចេញអំពីកាលុនដូទៅ នៅថ្នាក់លេខមួយនិងថ្នាក់លេខ ២ គ្មានអ្នកដំណើរណាក្រៅអំពីនាងកាមាលានិងក៉ាមេស្ហទេ ក៉ាមេស្ហរៀបហិបហោយដាក់ចូលក្នុងបន្ទប់នាងកាមាលា អាស្រ័យទឹកដោះគោមួយកែវរួច ដាក់កៅអីអង្គុយនៅក្បែរមាត់ទ្វារបន្ទប់មើលទេសភាពស្រុកទេស ដែលដើរប្រាសនិងដំណើរកប៉ាល់នាងជិះ ៗ

– នាងដឹងថា យើងទៅណាទេហ្នឹង ? (ក៉ាមេស្ហសួរ)

– ទៅស្រុកបង ៗ

- មិនមែនទេ ទៅធ្វើអ្វី បើនាងមិនចង់ទៅ

- ឱ! មកពីខ្ញុំទេហ្នឹងបានជាបងប្រើចង ? ខ្ញុំនិយាយលេងសោះ មិនគួរបងយកជាមែន គ្រាន់តែនិយាយលេងក៏ខឹងដែរ ...

(និយាយហើយនាងធ្វើមុខក្រញូវ)

– ខ្ញុំឥតខឹងសោះទេ ព្រោះខ្ញុំក៏មិនចង់ទៅដែរ ៗ

- បើអីចឹងទៅណាទៅវិញ?

- ទៅស្រុកខាងលិច ។

ឮថាទៅស្រុកខាងលិចនាងបើកភ្នែកធំៗ បែបដូចជាសប្បាយព្រោះនាងធ្លាប់បានឮគេនិយាយថា ស្រុកនោះសម្បូណ៌ប្រាសាទបុរាណ, ព្រៃធំៗ ក្នុងដែលប្រកបដោយព្រឹក្សាលតាវល្លិចំឡែកៗ ហើយថែមទាំងមានខ្យល់អាកាសត្រជាក់ផងៗ នាងសួរបញ្ជាក់ក៏មេស្ហថា "យើងទៅកន្លែងណា" ក៏មេស្ហឆ្លើយថា "មិនទាន់ប្រាកដទេ" ។

- ប៉ុន្តែយើងមុខជាកាត់តាមមុង្គារ, ប៉ាត់ណា, ឌុណាបូរ, ប៊ុក្សារ, គាស៊ីបូរនិងបេណារេស ហើយក្នុងចំណោមក្រុងទាំងប៉ុន្មាននេះ យើងមុខជានឹងត្រូវឈប់នៅកន្លែងណាមួយមិនខាន ។

នាងកាមាលាធ្លាប់បានឮឈ្មោះស្រុកទាំងនោះដែរ ឈ្មោះខ្លះទៀតនាងមិនដែលបានឮសោះ ប៉ុន្តែនាងនៅតែគិតឃើញសប្បាយ ។

- មិនដឹងជាសប្បាយយ៉ាងណាទេបង ? ( នាងនិយាយ )

- កុំអាលគិតសប្បាយអីឡូវ យើងត្រូវរកអ្វីញ៉ាំសិន ខ្ញុំថាប្រហែលជានាងមិនចូលចិត្តញ៉ាំបាយកប៉ាល់ទេមើលទៅ ?

នាងធ្វើមុខជូរ ព្រោះនាងខ្ពើមអាហារដែលធ្វើមិនស្អាតនាងគិតមួយសន្ទុះទើបប្រាប់ថា :

- ចាំខ្ញុំដាំបាយធ្វើម្ហូបខ្លួនខ្ញុំ ។

- ធ្វើកើតឬទេ ហ្ន៎ ? (ក៏មេស្ហបែបមិនទុកចិត្ត )

ហួសចិត្តពេកនាងសើច ៖

–ចុះបងថាខ្ញុំជាមនុស្សអ៊ូទៅ ថាខ្ញុំឥតចេះអីសោះទេយ៉ាងមើលទៅ? នៅផ្ទះម៉ាខ្ញុំមានអ្នកណាធ្វើបាយទឹកក្រៅពីខ្ញុំ ។

–ខ្ញុំផ្ដាសតែម្ដងហើយ គិតស្មានខុស រៀបចំធ្វើទៅនាង ។

ក៏មេស្ហរត់ទៅរកខ្ទះជើងក្រានយួរតូចមួយមក ប៉ុន្តែមិនទាន់គ្រប់សព្វទេ ។ នៅលើកប៉ាល់នោះ មានក្មេងប្រុសម្នាក់ឈ្មោះ អ៊ុយមេស្ហ ដែលជាពួកកាយាស្ត(១) នៅក្រុងបឹងហ្គាល់ ចុះពីពួកព្រាហ្មណ៍មកមានតែពួកកាយាស្តនេះឯងទេ ក៏មេស្ហនិយាយជួលក្មេងនោះ ដើម្បីឲ្យជួយដាំស្លរនាងកាមាលា ។

· បានអ៊ីញ៉ាំនៅពេលថ្ងៃត្រង់ កាមាលា ? (ក៏មេស្ហសួរ)

-ចា៎ យើងបានអ៊ីញ៉ាំថ្ងៃត្រង់ ? បើបងយកតែអង្ករនិងបន្លែមកឲ្យខ្ញុំ តើឲ្យខ្ញុំធ្វើអ៊ីកើត ? បងទៅសុំគ្រឿងក្រៅអ្នកកប៉ាល់បន្តិចមក ។

បន្តិចក្រោយមក ក៏មេស្ហត្រឡប់មកវិញបានទាំងគ្រឿងទេសបន្តិច យកមកហុចឲ្យកាមាលា នាងទទួលយកហើយថា ៖

–ឲ្យខ្ញុំធ្វើម្ដេចទៅ ? បើបងយកគ្រឿងទាំងមូល ៗ មកឲ្យខ្ញុំហើយ គ្មានត្បាល់ គ្មានអង្រែ បងនេះចំតែម្ដងហើយ រកមិនបានទេបែបនេះ ប្រើម្ដងបានមួយមុខ ។

ឮនាងថាដូច្នោះ ក៏មេស្ហរត់ទៅវិញ យកបានប្រដាប់ម្យ៉ាងប្រហែលនិងត្បាល់ដែរ តែដល់ដាក់គ្រឿងបុកទៅ គ្រឿងខ្ទាតកំពប់អស់ ទ្រាំមិន

(១) វណ្ណៈអ្នកនិពន្ធ ។

បាន សើចទាំងអស់គ្នា នាងកាមាលាយកថោដមួយដែលនាងដាក់ស្ករពីក្រុងកាល់កុត្តា មកធ្វើជាឆ្នាំងសម្រាប់ស្ង ហើយប្រាប់ក៉ាមេស្ហឲ្យទៅដួតទឹកទៅ ទំរាំដួតហើយបាយម្ហូបក៏ឆ្អិនល្មមដែរ ។

– លុះដល់ក៉ាមេស្ហដួតទឹកស្រេច បាយក៏ឆ្អិនមែន តែនៅបញ្ហាចាន មិនដឹងជាបានចានពីណាមកដួសបាយបរិភោគសោះ ។ ក៉ាមេស្ហថា ទៅខ្ចីចានអ្នកកប៉ាល់ទៅ នាងកាមាលាបញ្ចេញទឹកមុខមិនស្រប ព្រោះនាងប្រកាន់សាសនាណាស់ នាងនិយាយកាត់ក្តាម :

ការហួស ថាហួសទៅចុះ តែមិនត្រូវធ្វើទៀតទេ ខ្ញុំទ្រាំមិនបានទេបង បើខុសម្ដងហើយ ធ្វើលើខុសទៀតនោះ ។ ថាហើយនាងយកគំរបថោដួតយ៉ាងស្អាតដួសបាយដាក់ជូននាងថា ៖

– យកគ្របនេះធ្វើចានទៅ ធ្វើម្ដេច ? ញ៉ាំបណ្ដោះអាសន្នទៅ ចាំក្រោយសឹមរកអ្វីឲ្យគ្រាន់បើជាងនេះ ។

ក៉ាមេស្ដក៏ចាប់បរិភោគ ទើបតែនឹងបរិភោគបានពីរម៉ាត់ក៏លាន់មាត់ថា

– យីកាមាលា បេះធ្វើម្ហូបឆ្ងាញ់ផង !

– ណ្ហើយបង កុំសរសើរខ្ញុំឲ្យហត់ធ្វើអី

– ខ្ញុំមិនមែនបញ្ចើចទេ នាងញ៉ាំខ្លួនឯងទៅដឹងហើយ ថាឆ្ងាញ់មែនឬខ្ញុំបញ្ចោរ ។

ក៉ាមេស្ដត្រូវមាត់នឹងអាហារនោះក៏បេះតែសុំថែមទៀត នាងកាមាលាសប្បាយចិត្តណាស់ ដោយឃើញក៉ាមេស្ហឆ្ងាញ់បាយ ។

ខែ! នាងនៅចាំអីទៀត តិចអស់ខានញ៉ាំ ។

— មិនអីទេបង នៅមានទៀត ។

— ចុះនាងបានចានឯណាដាក់បាយញ៉ាំ ?

— ញ៉ាំក្នុងគំរបធុងជាមួយបងទៅក៏បី ?

— ខ្ញុំមិនឲ្យនាងធ្វើដូច្នេះទេ

— ឱ! ចុះក្រែងខ្ញុំជាប្រពន្ធបងឬ? ណ្ហើយបានហើយបង ខ្ញុំដឹងករណីយកិច្ចរបស់ខ្ញុំពេក គិតតែរៀនបងទៅចុះ ។ អ៊ុយមេស្ហឯណោះ បានចានឯណាដាក់បាយញ៉ាំ ? (នាងកាមាលាងាកសួរទៅក្មេង) ។

— ជំរាបប្រសាសន៍មិនអីទេបាន ខ្ញុំស្គាល់អ្នកលក់ស្ករនៅឯក្រោមម្នាក់ ចាំខ្ញុំទៅសុំស្លឹកគេបន្តិចមកបានហើយ ។

ឯក៏មេស្ហ គ្រាន់តែឮនាងកាមាលាឆ្លើយថាញ៉ាំបាយជាមួយអ្នក អ្នកយល់ច្បាស់ណាស់ទៅហើយ ប៉ុន្តែអ្នកមិនដឹងរកមធ្យោបាយណានឹងធ្វើឲ្យនាងកាមាលាយល់ថាអ្នកនិងនាងមិនមែនជាប្តីប្រពន្ធទេ ក៏ឆ្លើយដូច្នោះទៅអ្នកយល់ជាក់ស្តែងថា នាងត្រៀមខ្លួនចាំតែទទួលភារៈជាប្រពន្ធស្រេចទៅហើយ ។ ការស្អាត ការប៉ុនប្រសប់ ទឹកមុខរីករាយរបស់នាងកាមាលានៅពេលធ្វើការងារតាំងអម្បាលម៉ាន ធ្វើឲ្យក៏មេស្ហពេញចិត្តណាស់ទៅហើយ ប៉ុន្តែក្នុងការពេញចិត្តទាំងនេះ មានគំនិតមួយចេះតែមករំខានឲ្យអ្នកនឹកថា តើនាងនិងអ្នក នឹងទៅជាយ៉ាងម្តេចទៅ ទៅថ្ងៃមុខទៀត ? តើអ្នកត្រូវទុកឲ្យនាងនៅជាមួយរហូត ឬឲ្យនាងត្រឡប់ទៅវិញ?

គិតសព្វ ៗ ទៅឃើញថាផ្លូវទាំងពីរនេះ ចេញផ្លូវណាក៏មិនរួច ៗ បើដូច្នេះ តើនឹងត្រូវកំរិតការទាក់ទងនឹងនាងកាមាលាត្រឹមណា ? បើប្រសិនជាមាននាងហិមណាលិនីមួយថែមមកទៀត បរិយាកាសដូចជាផ្លូវស្រាលបន្តិច ចុះបើនាងមិននៅជាមួយផងយ៉ាងនេះ . . . ឃើញថាចេញអំពីបញ្ហាទ្វេនេះមិនរួចតែម្តង ៗ

នៅទីបំផុត អ្នកក៏សម្រេចចិត្តលែងរវែក ចាំនិយាយការពិតប្រាប់នាងកាមាលាឲ្យអស់កុំឲ្យសាញាច្រើនទៀត ៗ

—ᯃᯃ—

# ភាគទី ២៣ និង ២៤

រសៀលជ្រេបន្តិច កប៉ាល់ទៅគៀងជាប់នៅកន្លែងកោះខ្សាច់មួយ ទោះជាកម្មករកប៉ាល់ខំរុញប្រានយ៉ាងណា ក៏នៅតែមិនរួចសោះ ព្រះអាទិត្យអស្តង្គតទៅហើយ កប៉ាល់នៅតែគៀងចន្លោងដដែល ៗ មើលទៅមាត់ច្រាំង មានឆ្នេរខ្សាច់ដុះតាំងពីស្នាមជាំ ដែលទឹកជន់ដល់ កាលពីរដូវស្សា ទេរដ៏កលចុះជាលំដាប់រហូតដល់មាត់ទឹក ៗ

ក្រមុំ ៗ នៅភូមិក្បែរមាត់ច្រាំង ដែលនាំគ្នាដើរទាំងហ្វូងមកដងទឹកយកទៅប្រើប្រាស់ កុំឲ្យយប់ងងឹតទាន់ នាំគ្នាឈរមើលកប៉ាល់គៀងរញ៉េង នាងខ្លះខ្មាសអៀនច្រើន មិនដោះក្រមាចេញពីក្បាលទេ នាងខ្លះបែបមិនសូវអៀន ហ៊ានឈរមើលគេដោយនៅមុខកណ្តាលវាល ៗ

កុមារតូច ៗ នាំគ្នាលោតកញ្ឆោងស្រែកចំអកឲ្យកប៉ាល់ដែលគេធ្លាប់តែឃើញ បើកយ៉ាងក្រអឺតហើយឥឡូវនេះទៅជាគៀងជាប់ច្រាំង ៗ

ក៉ាមេស្ហឈរច្រត់លើក្តាក់ដែកប៉ាល់ មើលព្រះអាទិត្យអស្តង្គតដែលលិចបាត់ នៅតែរស្មីក្រហមឆ្អៅ នាងកាមាលាចេញមកឈរនៅមាត់ទ្វារបន្ទប់ ហើយធ្វើជាក្អកដើម្បីឲ្យក៉ាមេស្ហងាក តែក៉ាមេស្ហមិនងាកសោះ នាងក៏ចេះតែធ្វើអឺចេះ-អឺចុះ បន្តិចអង្រ័ន់សោ បន្តិចធ្វើនោះ ទាល់តែក៉ាមេស្ហធុញហើយក៏ដើរតម្រង់មកនាង ៗ

- ចង់ហៅខ្ញុំធ្វើអីចឹងឬ កាមាលា ?

- ចា៎ ព្រោះខ្ញុំមិនដឹងធ្វើម្ដេច ក្រៅពីនេះ ៗ

- យី កាមាលា ឪពុកម្ដាយខ្ញុំបានឲ្យឈ្មោះខ្ញុំក្រែងសម្រាប់ឲ្យគេហៅឬ ? ចុះបើនាងត្រូវការខ្ញុំ ម្ដេចក៏មិនហៅ « នែ ក៉ាមេស្ហ-ជាប៊ូ » ទៅ ?

គ្រាន់តែក៉ាមេស្ហ និយាយចំអន់បែបនេះភ្លាម នាងឡើងមុខក្រហមផ្ទឹមបានទឹងរស្មីព្រះអាទិត្យ ដែលកំពុងតែសន្សឹមចុះ ៗ ដែលស្ត្រីឯណាណាហៅប្ដីចំឈ្មោះឬទេ ? នាងស្អប់ណាស់ពាក្យនិយាយលេងបែបនេះ នាងដើរចូលក្នុងបណ្ដើរនិយាយបណ្ដើរថា :

- «បងអញ្ជើញទៅពិសាបាយទៅល្ងាចហើយ ៗ

ខ្យល់ត្រជាក់បក់ចេញពីផ្ទៃទន្លេ ធ្វើឲ្យក៉ាមេស្ហឃ្លាន់អាហារណាស់ តែអ្នកមិនហ៊ានបញ្ចេញអាហារប្រាប់នាងកាមាលាទេ ដើម្បីកុំឲ្យនាងរំធ្វើ អស់កម្លាំងដោយសារតែអ្នកណាមួយប៉ុណ្ណោះណាមួយនៅលើកប៉ាល់គ្មាន

សម្ភារៈគ្រប់គ្រាន់នឹងរៀបចំអាហារឲ្យបានឆ្ងាញ់ផង ៗ មនោសញ្ចេតនាមួយយ៉ាងសាំញ៉ាំផុសចេញអំពីគំនិតអ្នក ព្រោះថាពិតមែនហើយ តែអ្នកសប្បាយចិត្តនឹងបានអាហារឆ្ងាញ់ ដើម្បីសម្រន់ការស្រេកឃ្លានរបស់អ្នក ប៉ុន្តែលុះនឹកឃើញថាមានមនុស្សម្នាក់ខំយកចិត្តទុកដាក់ ដើម្បីឲ្យអ្នកស្ថិតនៅក្នុងសុខុមាលភាពបែបនេះ ធ្វើឲ្យអ្នកស្រពោនចិត្តពេក ព្រោះអ្នកមិនសមបើនឹងឲ្យនាងបំរើអ្នកដល់ប៉ុណ្ណឹងសោះ ធ្វើដូច្នេះហាក់ដូចជាបោកបញ្ឆោតនាង ៗ នឹកហើយអ្នកដកដង្ហើមធំ នាងកាមាលាយល់ទាន់ក៏សួរភ្លាមថា :

– បងមិនទាន់ចង់ពិសាបាយនៅឡើយទេឬ ?

កាមេស្វាឮដូច្នេះខំធ្វើទឹកមុខរីករាយភ្លាម ហើយឆ្លើយតប :

– មិនមែននាងទេដែលហៅខ្ញុំឲ្យចូលមកនេះ គឺពោះខ្ញុំទេតើ ប៉ុន្តែមានអីញ៉ាំនៅទីនេះ មានតែតុ កៅអី ខ្ញុំទំពារម្តេចបែក ៗ

នាងកាមាលាផ្ទុះសំណើចយ៉ាងខ្លាំង កាមេស្វាសើចតាមដែរ ៗ នាងចូលទៅក្នុងបន្ទប់ជិតនោះ បន្តិចនាងចេញមកវិញបានទាំងថោមួយគ្របដោយស្លឹកស្រស់មកផង នាងដាក់នៅលើកូនព្រំមួយតូច ជិតជើងគ្រែនាងយកជាយសំពត់នាងជូតក្ដារក្រាលនៅជិតនោះថែមទៀត ហើយនិយាយបណ្ដើរថា :

– ណ្ហើយយកសំពត់ខ្ញុំជូតសិនចុះ ព្រោះខ្ញុំត្រូវផ្លាស់ល្ងាចនេះដែរ ៗ

នាងបើកគ្របស្លឹក យកទំរៀនទិនបន្ទុំពីក្នុងថោដាក់ឲ្យកាមេស្វា

បរិភោគ

- នាងបាននំពីណាមក ?

នាងមិនឆ្លើយភ្លាមទេ ទុកឲ្យក៏មេស្ហតាយសិន ។

ក៏មេស្ហនិយាយបន្ថែមទៀត ៖

- ប្រហែលជាព្រះអាទិទេពដែលបំរើចង្កៀងរបស់អាឡាដាំងaladin លោកផ្ញើនំនេះមកឲ្យខ្ញុំពីបាល្លស៊ុល្តង់មកៈទដឹង បានជានៅក្តៅ ៗ ។

នាងកាមាលាធុញទ្រាន់ការនិយាយលេងថែប៉ប្រែ ក៏និយាយកាត់ :

- កុំចេះតែនិយាយតាមតែចិត្តឃើញនោះបង !

- បើអីចឹង បងគិតគាត់អណ្តាតបងឲ្យឆ្កែស៊ីហើយ ព្រោះអណ្តាតនេះវាចេះតែឲ្យបងនិយាយផ្តេសផ្តាសមិនដឹងគេខឹង ។

ការពិត គឺនៅពេលកប៉ាល់ចូលផែមុនពេលជាប់គៀងនោះ នាងកាមាលា សល់ប្រាក់បន្តិចបន្តួចនឹងខ្លួន បានប្រើអ៊ុយមេស្ហឲ្យទៅទិញម្សៅនិង បឺរ ខ្លះមកទុកបំរុងធ្វើម្ហូបញ៉ាំតាមផ្លូវទេ ។

នាងសួរទៅ អ៊ុយមេស្ហ ដែលមិនទាន់បានអ្វីបរិភោគនៅឡើយ ។

- ចុះឯងបានអីញ៉ាំ អ៊ុយមេស្ហ ?

- បាទម៉ែ ឲ្យខ្ញុំសុំលុយខ្លះមក ចាំខ្ញុំទៅសុំថែកចិត្តដោះគោគេ យើងមាននៅសល់ចេកនិងបាយខ្លះដែរ ប៉ុណ្ណឹងបានហើយ ។

នាងកាមាលាអស់លុយហើយ !

- ចុះឯងគ្មានលុយទេ អ៊ុយមេស្ហ ?

— គ្មានសោះទេម៉ែ ។

ស្លាប់ហើយ ! វរធំហើយ ! នាងមិនចង់ហាមាត់សុំអ្វីពីក៉ាមេស្ហូសោះ នាងទ្រឹងគិតមួយសន្ទុះ ទើបនិយាយទៅកាន់ក្មេង ៖

— ណ្ហើយចុះ បើទុកជាឯងមិនបានទំទឹកដោះគោឥឡូវ ក៏មាននំចៀនដែរ មក ! ទៅជួយលាយម្សៅម៉ែបន្តិច ហើយបើកាលណាឯងឃើញលោកប្រុសឯងចូលមកពីសាបាយ សិមឯងទៅសុំលុយលោកវិញ ។

នៅពេលដែលក៉ាមេស្ហូបរិភោគអាហារ អ៊ុយមេស្ហូក៏ទៅឈរក្បែរនោះវាចាំឲ្យតែលោកមើលមកវាចំ វានិយាយតិច ៗ អេះក្បាលបណ្តើរ ៖

— ម៉ែឯណាលុយទៅផ្សារ ?

ឮពាក្យថាលុយ ក៉ាមេស្ហូហាក់ដូចជាភ្ញាក់ព្រើត

មែនហើយ ! បើមនុស្សត្រូវការអាហារ ក៏ពិតជាត្រូវចំណាយប្រាក់ដែរ ព្រោះគេគ្មានបង្គៀនទិញឯណា ? ទើបអ្នកទឹកឃើញថាកាលបើប្រគល់ការៈមេផ្ទះទៅឲ្យនាងកាមាលា អ្នកក៏ត្រូវប្រគល់ប្រាក់កាសឲ្យនាងដែរ ទើបនាងអាចចាត់ការបានតាមនាទីរបស់នាង គិតហើយ ទើបក៉ាមេស្ហូយកសំពៀតប្រាក់ប្រគល់ទៅឲ្យនាង ។ លុះបរិភោគរួចហើយ ក៉ាមេស្ហូក៏ចេញទៅក្រៅវិញ ។

អ៊ុយមេស្ហូបាននំមួយធំ គ្រាន់តែឃើញវាបរិភោគគួរឲ្យឆ្ងាញ់ នាងកាមាលាឈរនៅជិតវា ហើយសាកសួរអំពីរឿងរ៉ាវផ្សេង ៗ របស់វាតាំង

ពីមុនមក អ៊ុយមេស្រូនិយាយប្រាប់នាងថា វាទ្រាំរស់នៅជាមួយម្ដាយចុង វាមិនបាន ទើបវាលួចរត់មកនេះ ដើម្បីទៅរកសាច់ញាតិខាងម្ដាយវានៅ ឯក្រុងបេណារេស មុននឹងបញ្ចប់វានិយាយទៅនាងកាមាលាថា :

— បើម៉ែអនុញ្ញាតឲ្យខ្ញុំនៅជាមួយម៉ែរហូតទៅ ខ្ញុំសប្បាយរកអ្វីប្រៀបពុំបានឡើយ ។

ពាក្យសំដីក្មេងកំសត់និយាយដូច្នោះ ថែមទាំងហៅនាងថា ម៉ែ ម៉ែ យ៉ាងស្និត ហាក់ដូចជាដាស់សភាវគតិនាងជាមាតា នាងនឹកអាសូរក្មេងកំព្រាណាស់ក៏និយាយឲ្យវាមានការកក់ក្ដៅបន្តិចថា:

— ចុះឯងចង់ទៅណាទៀត ? ហើយមានអ្នកណាគេដេញឯង ? ។

(នៅមានត)

# រាត្រីចតុម្មុខ

សហ. ញូង-សៀង រៀបរៀង

## ពាក្យ ៧

❁ ទិនករគោចរចុះទន់ទាប
ទេរតាមសភាពលោកធម្មតា
បន្ទឹមលាក់ខ្លួនពួកអាត្មា
នាទិសបច្ចិមាពេលរស្មី ៗ
ក្រហមព្រឿងៗ លឿងចម្រុះ
ចែងចាំងភ្លាស់ចុះលើផែនដី
ក្រាលពាសធម្មជាតិស្រទន់ខ្ចី
ព័ណ៌ច្បិតពិសីកាត់ជើងមេឃ ៗ
លាលិចលិចចុះសន្សឹមទៅ
មនុស្សសត្វដែលនៅពេញតម្រេក
ស្រងូតស្រងាត់ស្ងប់ស្ងាត់ពេក
វិវេកតឹងតុះស្អុះស្អាប់ប្រាណ ៗ
រីកាលជាសខ្មៅងងឹតឈ្ងប់
បិទបាំងពិភពគ្រប់ដែនដាន
ដល់វេនកត្រីដណ្ដើមបាន
តាមដោយលំអានជាលំដាប់ ៗ
ព្រះពាយផាយផាត់កាត់ទៅមក
បក់រុញពពកពពួនអព្ទ
ខ្មៅកកងងឹតជិតខានខាប់
ប្រានចេញប្រញាប់ឲ្យឃ្លាតឆ្ងាយៗ
អាកាសស្រឡះស្អាតសំខាន់
ព្រះច័ន្ទរះភ្លឺតភ្លឺត្រឆាយ
រស្មីស្រអែតចាំងសព្វសាយ
ឯផ្កាយក៏រះបន្តគ្នា ៗ
ហោមជាបរិវារការពារពិត
ខ្លះនៅនៃបនិត្យជិតចន្ទ្រា
ខ្លះនៅឃ្លាតឆ្ងាយផ្សាយអាកា
ព្រោងព្រាយលាយគ្នាចម្រុះញឹក ៗ
អ្នកដែលស្ងួតស្ងប់ថប់ធុញណាយ
បែរបានសប្បាយយ៉ាងពន្លឹក

ដោយសារពន្លឺភ្លឺអធិក　　ដូចទឹកចេញចរកែកំសាន្ត ។
គន់ផ្ទៃទន្លេចតុម្មុខ　　ទឹកពេញបន្ទុកពន់ប្រមាណ
លិចអស់កោះត្រើយឥតសល់ខាន　　ហូរប្រានក្ដួចប្រាល់កាល់មាត់ច្រាំង ។
ត្រូវខ្យល់ដំនោរដោរបក់មក　　កើតជារលករំជួយខ្លាំង
ទូកតូចផ្ងេងផ្ងោងអុំប្រឆាំង　　តតាំងកាត់ទឹកនឹកភ័យក្រៃល ។
ផ្លែកផ្លត់លេកដូចត័ណ្ហិប្រាក់　　ផ្អើក·ផ្អើកឥតអាក់ហាក់ផលផែល
ដោយប៉ះពន្លឺព្រះច័ន្ទផែល　　ចែងចាំងឆ្នាត់ថ្លៃលស្រស់ស្រទន់ ។
ខាងឯអរ៍យ៍ក្សេត្រទិសបូព៌ា　　ប្រទីបផ្កាលាលន្ទោបលន់
ហែតាមមាត់ច្រាំងច្រើនពេកពន់　　គយគន់គឺពួកនេសាទត្រី ។
ងាកខាងត្រើយជ្រោយចង្វា　　ព្រោងព្រាតភ្លឺថ្លាដោយស្មើ
ចង្កៀងរៀងរាយតាមវិថី　　ប្រុសស្រីដើរលេងលំហែកាយ ។
នៅខាងមាត់ច្រាំងដំណាក់ផែ　　នំនែកហូរហែលក់ចែកចាយ
ស្រីយួនខ្លួនស្អាតឡកនាយអាយ　　ប្រុស-ប្រុសសប្បាយទិញស៊ីលាន់ ។
យូរ ៗ ឮសូរមាត់ខ្ទង់ស្រាក　　ស្រែកយំខ្លាក ៗ គួរភ័យក័ន្ត
គេនាំគ្នាដេរប្រទេចផ្គាន់　　រួសពន់ជាមួយសម្រែកវ៉ ។
មេចោរហើនហោចខ្ទោចចម្រុះ　　អន្តរធានចុះកុំយូរយារ
កុំហើរស្រែកយំទំរេក　　ឲ្យហោងវេទនាស្លាប់ក្សិណក្ស័យ ។
តាមចាប់បុកណាបានជៀមក　　សត្វខេះមិនរកស៊ីពេលថ្ងៃ
រកស៊ីតែយប់គតិត្រៃយ៍　　កែវខែបង្អិចបំផ្លាញគេ ។

ថាវាជាពលនៃស្តេចខ្មោច ចង្រៃអសោចិ៍ពីបុព្វ
ស្តេចខ្មោចតែងប្រើហើរវិះរេ យកព្រលឹងគេសព្វភូមិឋាន ។
ខ្លែងអើយខ្លែងស្រាកលំបាកម៉្លេះ រកស៊ីសោះអេះហើរហត់ប្រាណ
ត្រូវមាត់គេជេរឥតសល់ខាន កម្មអ្វីទៅបានជាយ៉ាងហ្នឹង ។
កាត្រីយប់យន់បន្តិចទៅ សែនច័ន្ទសន្ធៅបញ្ចាស់រឹតរឹង
ក្លឹសាយផាសពាសពេញទំហឹង វាយេះបករ័ងគ្រផាក់កាយ ។
លើចុងអំពិលខាងមុខវាំង អស់ទាំងសត្វក្អែកបែកខ្ចាត់ខ្ចាយ
ខ្លះហើរបៀសចេញទៅទីឆ្ងាយ ខ្វែកខ្វែកប្រញាយចឹកឈ្លោះគ្នា ។
ដើមចមជម្លោះទំនងផាក់ មួយដេកមួយភ្ញាក់នាំពាផា
រង្គើមែកអញ្ចាញ់មហិមា ពះវាមិនដឹងគេដេកពួន ។
នៅលើដើមម៉ាស៊ីម៉ន្តរែង ប្រុសស្រីផ្អែកជ្រែងសំដឹលខ្លួន
ខ្លះប៉ះសង្សារទើបជួបជួន គេរះគៀវប្រជួនសប្បាយក្រៃ ។
អ្នកខ្លះឥតបានដើងម៉ាទេ ពឹងមាត់ទទេគ្រាន់អាស្រ័យ
អង្គុយសណ្តូកទប់ជ្រែងដៃ មៀងមើលផលស័យកំសាន្តចិត្ត ។
ខ្លះខ្លាចក្រែងស្រីដោះគេបកៃ ទំកូតស្បថស្បៃយកសុបិត
ថាបើវៀចវេរក្បត់ផិត ហើយមិនអាណិតផលចរណៃ ។
នោះសូមព្រះអគ្គិផងកើតើយ កាប់កប់ឆ្អើយឲ្យហិនហៃ
កុំឲ្យខ្ញុំឃើញពន្លឺថ្ងៃ ក្បែណាក្បែ ផ. ផ:ងរស់ក្បត់ស្រី ។
ខ្លះគៀកពេគ្នាឆ្ងាយ [illegible] [illegible]

តែស្មានមិនខុសប្រុសនិងស្រី　　គ្មានអ្វីក្រៅផ្សេងពីការទុំង ។
ខ្វះទៀតធ្មៀតក្រោមដើមអំពិល　　ងងឹតព្រិលៗ ឃើញខ្មៅស្លុង
ប្រឡែងប្រឡូសតូសព្រយុង　　ពីព្រោះវៀងនុងដៃរមើលទៅ ។
អ្នកមានសង្សារសែនសប្បាយ　　គៀកគេះក្អាកក្អាយ ទាល់យប់ជ្រៅ
ឯងអត់ក្រៀមផ្លេះគេះតែក្តៅ　　រអ៊ូស៊ូទៅលេបទឹកមាត់ ។
មើលគេត្ចិះៗ ទង្គិះចិត្ត　　ព្រោះផ្សិតមានដៃតែប្រាសព្រាត់
ទុកម្មអ៊ីហាមករាំងឃាត់　　បំភ្លាត់ឲ្យឃ្លាងពីកល្យាណ ។
ទឹកសព្វៗ ទៅកាន់តែព្រួយ　　ស្មើរប្រេះលួយកុងសន្តាន
ដល់ណាស់ថាណាស់ត្រាំមិនបាន　　ស្រែកប្រៀនកំសាន្តថាហាហៃ ។

## ពាក្យ ៩

តាំងពីចិត្តគិតពីចង់បង់ស្នេហា
លើដីក៏ថាដីតែវិមិត្តថ្ងៃ
ទៅមិនស្មៀមរៀមមិនស្ងាត់បាត់អាល័យ
ហាក់ស្រមៃផ្អែស្រមោលពោលជិតព្រាណ ។
ពេលបងគេងលេងបងគងរងលើខ្នើយ
ធ្លាប់បានកើយហើយបានគិតជិតកុំផាន
ធ្លាប់ប្រឡែងតែងប្រឡូកលូកស្មោះស្មាន
តែកំសាន្តបានកំសត់កត់កាលណោះ ។
ឥឡូវប្រែតែមិនប្រែបកបង្ខូចចិត្ត

ខកខានស្និទ្ធខិតខានស្នេហ៍ថែរថែកស្មោះ
ឥតទឹកនាគ្នាទឹកនិត្យគិតស្រណោះ
ពំគួរសោះដោះដៃសូន្យណាំអូនទៅ ៗ
ប្រសិនប្រាណបានមកប្របកបរិញអេះ
រួមសំណេះកេះសំណាលកាលហួសទៅ
បរិបីធោមដោមដុគ្គធើតទើតលើភ្លៅ
នាយប់ជ្រៅទៅយប់ជ្រុលពុលតណ្ហា ៗ
សែនតម្រេកត្រេកតម្រង់អង្គឥតអាក់
ពេញចិត្តស្ម័គ្រជាក់ចិត្តស្មោះអស់ក្រឡា
កែក្រឡៃដៃក្រឡិចបិចក័ព្រា
នៃកល្យាណ៍ថ្វាកល្យាណឲ្យបានស្កប់ ៗ
ចាប់ក្រសារការក្រសោបឱបមាសផ្អិន
កៀកសង្កិនសិនសង្កត់បត់ប្រឡប់
ស្ទាបបះបោសកោសបវែលអង្អែលសព្វ
រួចបញ្ចប់តប់បញ្ចើចសើចក្អាកក្អាយ ៗ
ឱបណ្តួលមួលបណ្តាច់សាច់ទ្រលន់
កន្លត់ល្វន់ទន់ល្វតស្វាសនិកសធ្លាយ
បើជាពោះទៅជាពិតដិតកន្ទកាយ
រៀរស៊ិចាយកាយស៊ិចេញដេញតាមសួន ៗ

តែនេះផុតសុខនេះផុងប្រុងមិនកើត
ព្រោះឆោមឆើតស្អើតឆោមឆាយផាយបាត់ខ្លួន
គ្មានដំណឹងដឹងដំណាលកាលនឹមនួន
នៅស្រុកយួនពួនស្រុកយក្សស្នាក់ត្រង់ណា ៗ
នេះស្រឡាញ់ចាញ់ស្រឡះប៉ះលើក្តៅ
សឹងសោកសៅមៅសោកសាំរកាំផ្សា
នាំទុរធាបជាបទុរនេះឱក
បង់អាសាណាអសោចខ្មោចជង្សតស្រី ៗ
ហេតុដូចេះអេះដួបឹងគូរប្រឹងខាត់
លះវិបត្តិកាត់វិបាកចាកលោកិយ
រៀនធម៌អាថ៌សារធម៌អាទ៍បាឡីបាលី
លាងចិត្តថ្មីបួចបួតទៅអឺយ ៗ

ញុង-សៀង

" អត្ថបទនេះធ្លាប់បានចុះផ្សាយក្នុងទស្សនាវដ្ដី មិត្តសាលាបាលី លេខ ៧
ឆ្នាំ ១៩៥០ "

ឯកសារ

# ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង

ដោយ

ឧកញ៉ាប្រសើរលិខិត ម៉ែង-ឆន់

ធ្វើការនៅទីចាត់ការគរុកោសល្យ ភ្នំពេញ

## ៤–ប្រវត្តិ វត្តពាមក្រសោប (វត្តសុវណ្ណកោគាទីបារាម)

អ្នកផ្តល់ពត៌មានគឺលោកគ្រូព្រះនាម ពុត-ផ្លុង ចៅអធិការវត្តពាមក្រសោប និង ការពិនិត្យផ្ទាល់ របស់អ្នកនិពន្ធ កាលពីថ្ងៃ ២២-២-៦៨ ។

វត្តពាមក្រសោប ហៅតាមផ្លូវការថា "វត្តសុវណ្ណកោគាទីបារាម" ។ វត្តនេះស្ថិតនៅត្រង់ក្បាលជ្រោយ ជាប់នឹងភូមិពាមក្រសោប ក្នុងសង្កាត់កោះកាពិ ស្រុកកោះកុង ខេត្តកោះកុង ។

វត្តនេះចាប់កសាងពីឆ្នាំ ១៩៤៧ មានលោកគ្រូ ព្រះនាម វើន-មុំ ជាអ្នកផ្តួចផ្តើម ទើបបានជាចៅអធិការ ។ ជាដំបូងមានតែរោងឧបោសថមួយ សង់អំពីឈើ ប្រក់ស្លឹក និងកុដិតូចមួយ កុដិបាយតូចមួយប៉ុណ្ណោះ លុះដល់មកឆ្នាំ ១៩៦១ ទើបរុះរើកសាងជាថ្មីទៀត ដែលមានសភាពមាំមួនជាងមុន គឺព្រះវិហារសង់អំពីឥដ្ឋប្រក់ស័ង្កសី ប៉ុន្តែពុំបានលើកខឿន

ឲ្យខ្ពស់ទេ ។ ក្រៅអំពីព្រះវិហារ មានកុដិធំ ១ សាលាសម្រាប់ធ្វើបុណ្យ ១ កុដិបាយ ១ ដែលសុទ្ធតែសង់អំពីឈើ ប្រក់ស័ង្កសី ។

នៅក្នុងទីធ្លាវត្តភាគខាងជើង មានសាលារៀន ១ គឺសាលាបឋមសិក្សាបំពេញវិជ្ជាពាមក្រសោបនោះឯង ។ នៅខាងជើងសាលារៀនបន្តពីព្រំវត្តទៅទៀត គឺភូមិពុទ្ធបរិស័ទដែលនៅអយមាត់ព្រែក ។ នៅខាងកើតគឺដៃសមុទ្រ ខាងត្បូងលំហសមុទ្រ និងខាងលិចមានព្រៃលិចទឹកដែលដុះសុទ្ធតែដើមកោងកាង ។

នៅក្នុងវត្តក៏ដូចជាភូមិអ្នកស្រុកដែរ កាលណាដល់ពេលទឹកជោរ ត្រូវលិចទឹកមានជម្រៅពី ០ម២០ ទៅ ០ម៧០ កាលណាពេលទឹកនាច ត្រូវគោកវិញ ប៉ុន្តែមានកន្លែងខ្លះពុំអាចដើរបានទេ នៅសើមល្បៀចៗ ហើយមានកន្លែងខ្លះគោកមែនទែន គឺនៅខាងត្បូង ត្រង់ព្រះវិហារ និងនៅមុខកុដិលោក អាចឲ្យគ្រូនិងសិស្សតៀតហាត់ប្រាណបានខាងវ៉ូឡីកីឡា ។ ដូច្នេះ ការធ្វើដំណើរពីកុដិ ១ ទៅ កុដិ ១ និងពីសាលា ១ ទៅ សាលា ១ សុទ្ធតែមានស្ពានភ្ជាប់គ្នា រហូតដល់ភូមិអ្នកស្រុក ។

ចៅអធិការវត្តពាមក្រសោប ដែលមានជាលំដាប់ត ៗ គ្នា តាំងពីកើតវត្តនេះមក មានដូចតទៅ គឺលោកគ្រូ វ៉ែន-ម៉ុម លោកគ្រូ វៀម គួច លោកគ្រូ វ៉ៃ-ថន លោកគ្រូ សម-រុន លោកគ្រូ ផាក់ ចាង (សុទ្ធតែចាកសិក្ខាបទ) លោកគ្រូ គង់-ជី និមន្តទៅធ្វើចៅអធិការវត្តកោះស្រឡៅ និងលោកគ្រូ ពុត-ឆ្លូង ជាចៅអធិការបច្ចុប្បន្ន ។

សព្វថ្ងៃនេះ វត្តពាមក្រសោប មានព្រះសង្ឃ ៤ អង្គ គឺភិក្ខុ ២អង្គ សាមណេរ ២ អង្គ ដែលមានលោកគ្រូ ព្រះនាម ពុត ផូង ព្រះជន្ម៦៦ វស្សា ជាចៅអធិការ ។

## ៥- ចេតិយឃុនឆាង

តាមការពិនិត្យផ្ទាល់ដល់ទីកន្លែងរបស់អ្នកនិពន្ធ កាលពីថ្ងៃ ១៨-២-៦៨ ។
ម៉ែន ទន់

ចេតិយឃុនឆាង ស្ថិតនៅក្នុងស្រុកមណ្ឌលសេមា ខេត្តកោះកុង ទល់មុខក្រុងខេមរភូមិន្ទ នាត្រើយខាងលិច ។ ចេតិយនេះ ត្រូវបានគេកសាងលើផ្ទាំងសិលា ដូចជាកូនកោះមួយ នៅលើផ្ទៃទឹកនៃដៃសមុទ្រ ចម្ងាយ ប្រហែល ១០០ម. ពីមាត់ច្រាំង និងប្រហែល ៥០០ម ខាងទិសអគ្នេយ៍ នៃសាលាស្រុកមណ្ឌលសេមា ។

ផ្ទាំងសីលាដែលចេតិយស្ថិតនៅនោះ មានទំហំបណ្ដោយប្រហែល ២០ម និងទទឹងប្រហែល ១០ម- និងមានសភាពជាផែនៗ ខ្ពស់-ទាប ត្រួតលើគ្នា ។

ទ្រនាប់ខ្សាច់នៃចេតិយ ៣,ម. បួនជ្រុង ឯតួចេតិយ ចាប់ពីចង្កេះឡើងទៅលើមានរាងមូល-ស្រួច មានក្បាច់ព័ទ្ធជុំវិញជាថ្នាក់ ៗ បួនជាន់ និងមានកំពស់ប្រហែល ៥ម ។ តួចេតិយទាំងមូលកសាងពីឥដ្ឋ កំពូលបំផុតកសាងពីឈើ ។ ឥដ្ឋដែលកសាងនោះមានបណ្ដោយប្រហែល

០ម៣ៈ និងទទឹងប្រហែល ៖ម៦៥ ៗ ខាងក្រៅមានបូកកំបោរពណ៌ស កំបោរនោះឃើញមានកំទេចសំបកលៀស-គ្រុំ ដែលអាចឲ្យយល់បានថា គេយកសំបកលៀស-គ្រុំទៅដុតធ្វើជាកំបោរ ដូចជាកំពែងស្រះសារពើយុត្ត នៅឧដុង្គដែរ ៗ

តួចេតិយនៅល្អទាំងអស់ មានតែកំពូលដែលធ្វើអំពីឈើនោះទេ ដែលពុកបាក់ខ្លះទៅហើយ ៗ នៅជើងចេតិយទិសចង្កេះចេតិយមានដើមជ្រៃលៀបជុំ ៦ កន្លែងនៅតូចៗនៅឡើយ ប៉ុន្តែកំពុងតែចាក់ឬស និងបន្ត្រួយជានិច្ច ៗ ក្រៅអំពីនេះ ឃើញមានស្មៅមានកន្ទុយមាន់ដុះនៅតាមកន្ទៀតតួចេតិយនិងមានស្លែខ្មៅៗ កាន់កាសពេញ ៗ

បើមើលពីចម្ងាយ គេឃើញចេតិយនោះហាក់ដូចជាជាប់នឹងផ្ទៃទឹក ប៉ុន្តែលុះចូលទៅជិត ទើបដឹងស្ថិតនៅលើផែនថ្មខ្ពស់ពីទឹកទៅវិញ ៗ តាមដំនៀររបស់អ្នកស្រុកខ្លះ គេដំណាលថាចេតិយនេះពុះចេះលិចទឹកទេ ទោះបីមានទឹកជំនន់ធំយ៉ាងណាក៏ដោយ បើខ្លាំងណាស់លិចតែផែនថ្មខាងក្រោមប៉ុណ្ណោះ ៗ

# ៦ ប្រវត្តិចេតិយឃុនភាង

អ្នកផ្ដល់ពត៌មាន គឺលោក ទៀវ ចាន់ ស្មៀនសាលាសង្កាត់កោះកាពិ ដែលលោកបានដឹងដោយសារអ្នកស្រុកនៅភូមិនាងកុក ពីឆ្នាំ ១៩៥៩ ហើយ លោកផ្ដល់ឲ្យអ្នកនិពន្ធនៅថ្ងៃ ២១-២-៦៨

តាំងពីយូរឆ្នាំណាស់មកហើយពុំដឹងជាសករាជប៉ុន្មាន និងពុំដឹងជាក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយអង្គណា មានគ្រួសារមួយពីរនាក់ប្ដីប្រពន្ធ មាននាមពុំប្រាកដ បានតាំងទីលំនៅ និងប្រកបរបរកសិកម្មក្នុងតំបន់មួយ នៅត្រើយខាងលិចនៃឈូងសមុទ្រ ទំនងជានៅខាងលិចសាលាស្រុកមណ្ឌលសេមាសព្វថ្ងៃ ។

គ្រួសារនេះមានធនធានគ្រាន់បើ ហើយជាអ្នកមានសទ្ធាផង ។ អ្នកនៅក្នុងភូមិជាមួយគាត់ក្ដី នៅភូមិនាងកុកក្ដី សុទ្ធតែស្រឡាញ់រាប់អានគាត់គ្រប់គ្នា ។ គាត់មានគុណសម្បត្តិពិសេសមួយទៀត គឺបើអ្នកភូមិជិតខាងដែលខ្វះលុយកាក់ឬស្រូវអង្ករ តែងតែរត់រកគាត់ហើយគាត់តែងផ្ដល់ឲ្យឥតជ្រើសមុខ ។

នាពេលមួយគាត់ពិចារណារវាងប្ដីប្រពន្ធ គិតឃើញថានៅដំបន់នេះមានមនុស្សរស់នៅក្រាស់ក្រៃលដែរ ប៉ុន្តែពុំទាន់មានវត្តអារាមសម្រាប់ជាទីសក្ការៈបូជា និងធ្វើបុណ្យទានៈ បើយើងកសាងជាវត្តក៏ដូចជាហួសសមត្ថភាព ដូច្នេះយើងត្រូវកសាងជាចេតិយមួយសម្រាប់ជាបូជនីយ [illegible] តាមគន្ធ

ព្រះពុទ្ធសាសនា ។ គំនិតដ៏ប្រសើរនេះបានយល់ស្របគ្នាទាំង ២ នាក់ប្តីប្រពន្ធ ហើយក៏ចាប់ជ្រើសរើសរកកន្លែងដែលត្រូវកសាងចេតិយ ។

ជាដំបូងគាត់បំរុងកសាងនៅលើដីគោកត្រង់កន្លែងណាមួយ ប៉ុន្តែដូចជាពុំសូវរុងរឿងហើយដូនជាគាត់នឹកឃើញដល់កូនកោះមួយ ដែលមានសុទ្ធតែផ្ការីកថ្កុំត្រួតគ្នា ។ គាត់គិតឃើញម៉្យាងទៀតថា នៅតំបន់នេះ អ្នកស្រុកប្រកបមុខរបរខាងនេសាទក៏មាន ខាងស្រែ-ចំការក៏មាន ចំណែកទូក-សំពៅក៏មានស្ទើរតែគ្រប់គ្នា បើបានធ្វើចេតិយលើកូនកោះនេះ ហើយដល់ពេលធ្វើបុណ្យទានម្តងៗ នាំគ្នាធ្វើជាស្ពាន និងយកទូកសំពៅមកចតឲ្យពេញត្រៀបត្រា ឃើញថាមានសភាពរុងរឿង ហើយសប្បាយផង ។

លុះជ្រើសរើសឃើញថា ត្រូវយកទីនេះធ្វើជាកន្លែងកសាងហើយ គាត់ក៏ចាត់ការឲ្យកេណ្ឌ ទិញដុតកំបោរព្រមទាំងសម្ភារៈផ្សេងៗទៀត ។ ចំណែកញាតិមិត្តជិតខាងវិញ ក៏មានសទ្ធាជួយជាកម្លាំងកាយខ្លះ ជួយជាធនធានខ្លះកសាងកើតបានជាចេតិយនេះឡើង ។

ចាប់តាំងពីពេលនោះមក ពុទ្ធបរិស័ទនៅភូមិជិតខាង ដូចជា នៅភូមិនាងកុក ភូមិចាំយាម ភូមិអាត់ព្រែក (ចាក្វង) កោះប៉ោ ស្ទឹងវែងជាដើម បាននិមន្តព្រះសង្ឃមកប្រជុំគ្នាធ្វើបុណ្យនៅចេតិយនេះជារៀងរាល់រដូវ ៗ ពិធីនេះមានសភាពរុងរឿងហើយសប្បាយណាស់ គេបានសង់ជាស្ពានពីដីគោកភ្ជាប់មកនឹងកូនកោះ ហើយនៅលើផ្ទៃទឹកវិញឃើញ

សុទ្ធតែទូកសំពៅ តម្រៀបត្រៀបត្រា ដោយមានពេលខ្លះគេអុំ និង បើកក្តោងប្រណាំងគ្នាជាការកំសាន្តផង ។

លុះបំណេរក្រោយមក នៅភូមិឯទៀត ៗ មានវត្តសម្រាប់ធ្វើបុណ្យ ផងដោយចាស់ៗ ជំនាន់មុន ស្លាប់អស់ទៅហើយផង ការប្រជុំគ្នាធ្វើបុណ្យ នៅចេតិយនេះ ក៏រលាយបន្តិចម្តង ៗ រហូតដល់ខានធ្វើសោះ ដរាប ដល់សព្វថ្ងៃ ។

អ្នកផ្តល់ពត៌មានបានបញ្ជាក់ថា រឿងចេតិយនេះមានប្រវត្តិដូចខាង លើ ឯត្រង់មានឈ្មោះថា ចេតិយឃុនឆាងនោះ ពុំដឹងជាមានមកពីត្រឹម ណាទេ ប៉ុន្តែមានទិដ្ឋភាពមួយគួរឲ្យយកមកពិចារណាដែរ គឺនៅត្រើយ ខាងលិច ឃ្លាតពីសាលាស្រុកមណ្ឌលសេមាឆ្ងាយបន្តិចទៅ មានដំណែល បុរាណមួយក្នុងភូមិដើងគ្រក់ ឃើញមានស្នាមដូចជាមនុស្សអុកគូថ ហើយ ជាស្នាមនោះ មានរឿងដំណាលដូចតទៅ :

ថាឃុនឆាង ជាកូនអ្នកមានសម្បត្តិច្រើន គាត់បានចាប់ចិត្តស្នេហា លើនារីម្នាក់ឈ្មោះនាងកឹម ដែលមានរូបសម្បត្តិឥតពីរ ប៉ុន្តែនាងកឹម ពុំ ស្រឡាញ់ឃុនឆាងទេ ព្រោះគាត់ក្បាលតំពែក ពោះកំប៉ោង ហើយព្រ. ហើន គឺស្រឡាញ់តែឃុនផែន ដែលជាសុភាពបុរស ។ ពេល ១ ត្រូវ ឃុនឆាង និងឃុនផែន ទាត់សីប្រកួតគ្នា ដើម្បីដណ្តើមនាងកឹម ដែលជាគូ ស្នេហារបស់ខ្លួនរៀងខ្លួន ប៉ុន្តែដោយស្នៀតរបស់ខ្លួនពុំសូវប៉ិន ឃុនឆាង ក៏គាត់ដើររកគូទល់ផ្លូវធ្វើមាត់សេញ ធ្វើឲ្យនាងកឹម និងទស្សនិកជន

សើចរីងពោះ ។ រីឯស្នាមដែលឃុនធាន ដួលអុកគូចកាលណោះ ក៏គាំងក្រាំងរឹងទៅជាថ្មរហូតដល់សព្វថ្ងៃនេះ ។

## ៧—ប្រវត្តិកោះកាពិ

> អ្នកផ្ដល់ពត៌មានគឺលោក តាន់-ឡឹក នាយតំបន់អធិការកិច្ចបឋមសិក្សា ស្រុកកោះកុង និងលោក ទាំ.ប៊ុនលឿ ចៅសង្កាត់កោះកាពិ ។ ក្រៅអំពីនេះ ដោយការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ កាលពីថ្ងៃ ២១-២-៦៨ ។

ដែលបានឈ្មោះថា កោះកាពិ មកពីកោះនេះមានកំពឹសសមុទ្រច្រើន ដែលខ្មែរយើងខ្លះហៅថា គី សៀមហៅថាកាពិ ។ កាលពីដើមពុំមានមនុស្សនៅទេ ប៉ុន្តែក្រោយមកមានខ្មែរ-ចិន ៣-៤ គ្រួសារមកនៅដោយប្រកបមុខរបរធ្វើកាពិ ហើយក៏ជាប់ឈ្មោះថា កោះការពិ ។ រហូតដល់សព្វថ្ងៃ ។

កោះការពិត្រូវចែកជា ២ ប្រភេទ គឺមួយប្រភេទជាដីភ្នំ មានបណ្ដោយប្រហែល ៧០០ម ទទឹងប្រហែលជាង ១០០ ម-ស្ថិតនៅប៉ែកខាងជើងនៃកោះ តាំងនៅទទឹងថ្ងៃ ។ មួយប្រភេទទៀតជាទីទំនាប គិតចាប់ពីជើងភ្នំទៅជ្រោយគយ សៀមហៅ ឡែម ដាន គឺឡែម ថាជ្រោយ ដាន ថាគយ ក្លាយមកជា ឡាំ ដាំ មានបណ្ដោយប្រហែលជាង ២ គ-ម និងទទឹងប្រហែល ២០០ ម ស្ថិតនៅប៉ែកខាងត្បូងនៃកោះ ។ ខាងលិច គឺលំហរសមុទ្រឃើញទឹកនិងមេឃហើយៈនៅខាងកើត គឺព្រៃនាម ដែលដុះស្ទុះដើមកោងកាងលាតសន្ធឹងបណ្ដោយតាមត្រកោះ ។

ប៉ែកខាងជើងជាភ្នំមួយមានទំហំដូចខាងលើ ហើយមានវត្ត ១ ឈ្មោះវត្ត ប្រជុំជនក្រោយមកកែជាវត្ត សុវណ្ណបពិត ប៉ុន្តែគ្រាមភាសាហៅថាវត្ត កោះកាពិ ។ នៅតាមជម្រាលភ្នំខាងជើងមានសាលាបឋមសិក្សាបំពេញវិជ្ជា មានមន្ទីរកងពលតម្រួត មានក្រុមគង្គារក្ខា និងនេសាទ មានសហករណ៍ខាងនេសាទ និងសាលាសង្កាត់កោះកាពិ ។ នៅតាមជើងភ្នំខាងកើត មានផ្សារលក់ដូរអមផ្លូវ ២ ជួរយ៉ាងវែង ដែលសង់អំពីឥដ្ឋ ប្រក់ក្បឿនខ្លះ និងឈើប្រក់ក្បឿង ឬស័ង្កសីខ្លះ ។ ក្រៅអំពីនេះមានផ្ទះ ២ ជួរទៀតនៅអមមាត់ព្រែក ដែលច្រើនតែសង់អំពីឈើប្រក់ស័ង្កសី និងឈើប្រក់ស្លឹក គឺជាផ្ទះអ្នកប្រកបរបរនេសាទ ។ ដទៃអំពីផ្ទះលក់ដូរ និងអ្នកនេសាទ នៅមានអ្នកប្រកបអាជីវកម្មឯកជន និងអគ្គាររដ្ឋផ្សេង ៗ នៅលាយឡំគ្នា ដូចជាឱសថស្ថានរង ការិយាល័យនាយដំបន់អធិការកិច្ចបឋមសិក្សា គិលានដ្ឋាន សហករណ៍ឧបភោគបរិភោគ ក្រុមព្រះនគរបាលជាតិ ពេនកាពយន្ត ដំណាងក្រុមហ៊ុន ណាំ.លឿង នៅសិង្គបុរីខាងការទិញត្រី -ប្រឡាក់ត្រី កន្លែងធ្វើក្តាមប្រៃ កន្លែងធ្វើត្រីងៀត កន្លែងធ្វើទឹកត្រី និងធ្វើកាពិ ។

នៅភាគខាងត្បូងមានសាលាស្រុកកោះកុង , មានបន្ទាយកងពលតម្រួត , បន្ទាយផ្នែកសិករង និងបន្ទាយកងនាវាចរ នៅជ្រោយគយ (ឡាំដាំ) ។

ប្រជាពលរដ្ឋនៅកោះកាពិ ១៣២ គ្រួសារ ហើយប្រកបមុខរបរសំខាន់

បំផុតគឺការនេសាទបន្ទាប់មកគឺការលក់ដូរ ប៉ុន្តែពុំមានប្រកបមុខរបរកសិ-កម្មទេ ។ នៅក្នុងភូមិមានតែដើមដូងនិងដំណាំស៊ីផ្លែបន្តិចបន្តួចដូចជា : ជម្ពូ មៀន ត្របែក ទឹកដោះគោ ។

ចំណែកភាសាវិញ គេប្រើភាសាខ្មែរ តែគេចេះចិនហៃណាំ និងសៀម ប៉ុន្តែភាសាទាំងនោះពុំសូវជាច្បាស់លាស់ទេ គឺច្រើនប៉ៃឡាំតាមរបៀបអ្នករស់នៅជាយដាយដែន ។ ចំពោះក្មេងៗជំនាន់ក្រោយវិញពុំចេះភាសាសៀមនិងចិនទេ ហើយអាចនិយាយភាសាខ្មែរយ៉ាងច្បាស់លាស់ដោយមកពីការអប់រំនៃក្រសួងអប់រំជាតិ តាមវិធីបង្រៀនសិស្សសាលាធម្មតាផង តាមវិធីអក្ខរកម្មផង ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះប្រមុខរដ្ឋ និងជាព្រះប្រធាននៃចលនាសង្គមរាស្ត្រនិយម ។

ផ្នែកខាងជំនឿ គេគោរពព្រះពុទ្ធសាសនា ប៉ុន្តែមានគេជឿវត្តស័ក្តិសិទ្ធិទៀតដែរ ដូចជាយាយមៅគ្រូបញ្ចាន់រូប និងទស្សន៍ទាយ ។

ជីវភាពពលរដ្ឋច្រើនធូរធារគ្រាន់បើ ពុំមានបញ្ហាខ្វះខាតជំពាក់ជំពិនគ្នាចងការគ្នាតាមរបៀប ៥ ជា ៦ និង ១០ ជា ១២ ឡើយ ហើយស្ទើរតែគ្រប់ផ្ទះគេពុំរវល់ពីរៀងបិទទ្វារ-បង្អួចទេ មានផ្ទះខ្លះពុំមានទ្វារ-បង្អួចនោះផង ព្រោះគេពុំដែលទទួលគ្រោះថ្នាក់អំពើចោរកម្ម ។

រីឯសំលៀកបំពាក់វិញ មិនខុសអំពីប្រជាពលរដ្ឋក្នុងខេត្តឯទៀតៗ នៅជិតកដងនេះទេ គឺពេលធ្វើការគេស្លៀកពាក់តាមតែបាន ប៉ុន្តែនៅពេលមានបុណ្យទាន គេស្លៀកពាក់ខោប៉ុបា ហើយច្រើនតែរបស់

មានតម្លៃធំ ។ ចំណែកស្រាច្រើនប្រើឆ្នាំងនិងពាងយូព្រោះស្រុកនោះសម្បូណ៌ភ្លៀង ។ ចំពោះម្ហូបអាហារសោត ត្រូវការប្រើម្ទេសជាចាំបាច់តាំងពីមនុស្សចាស់រហូតដល់កូនក្មេង ទាំងប្រុស ទាំងស្រី គឺសម្ភក្ដិ ទឹកជ្រលក់ក្ដី គេដាក់ម្ទេសយ៉ាងចាស់ដៃជាទីបំផុត ។

នៅកោះកាពិមានវិបត្តិមួយ ដែលពិបាកដោះស្រាយ គឺការខ្វះទឹកសាបទទួលទាន ។ ទឹកដែលគេប្រើប្រាស់ ត្រូវដឹកនាំតាំងពីកោះកុងឬកោះស្រឡៅ ឬគេត្រងដាក់ពាងនៅពេលមានភ្លៀង ។

# ប្រវត្តិ " ភូមិក្បាលអ្នក "

ឬ

# " ភូមិ ប៉ូអង់ "

មុននឹងខ្ញុំជូនប្រវត្តិ " ភូមិក្បាលអ្នក ឬ ភូមិប៉ូអង់ " នេះ ខ្ញុំចង់ឲ្យលោកអ្នកស្គាល់ភូមិ "ប៉ាលហាល" សិន ។

នៅចម្ងាយ ៤ គ.ម ពីកំពង់ប្រណាកទិសខាងត្បូង មានភូមិមួយឈ្មោះថា "ភូមិប៉ាលហាល" ដែលតាំងនៅក្នុងឃុំព្រះឃ្លាំងស្រុករវៀង ខេត្តព្រះវិហារសព្វថ្ងៃ ។ ភូមិនេះមានផ្ទះប្រហែលជា ៧០ ខ្នង ដែលមានមនុស្សប្រុស-ស្រី ជាង ២០០ នាក់សំណាក់នៅ ។ ជាភូមិនៃកុលសម្ព័ន្ធមួយពួកដែលខ្មែរយើងទម្លាប់ហៅ "កួយ"(១) កួយនៅភូមិប៉ាលហាលនេះជាពួកកួយអន្ទ្រ ។

តាមលោកតាលាស់-ឃួន គាត់ជាកួយអន្ទ្រ ប្រាប់ខ្ញុំថា : ដំបូងឡើយពុំទាន់មានភូមិប៉ាលហាលហ្នឹងនៅឡើយទេ គឺមានភូមិមួយតាំងនៅខាងជើងភូមិហ្នឹងហៅថា " ភូមិកេងកំ " ។ ភូមិកេងកំនេះដំបូងបង្អស់មានតាចាស់ប្តីប្រពន្ធគាត់ពីរនាក់ គាត់កាប់គាស់ហែកព្រៃនេះធ្វើជាចំការ មានដាំដំឡូង-ចេក-ពោត សព្វសារពើសម្រាប់ផ្គត់ផ្គង់ជីវិតគាត់ តែដោយហេតុមានខ្លាដំរីចេះតែមក ឆានៅបៀតបៀនដំណាំគាត់ជាញឹកញាប់ពេក

(១) ក្នុងខេត្តព្រះវិហារ មានកួយចំនួន ៤ សាសន៍គឺ ១ កួយអន្ទ្រ, ២ កួយអេក, ៣ កួយម៉ាលែ, ៤ កួយបាន់ត្រើ ។

ហើយគាត់ក៏ខ្លាចផងដែរ គាត់ក៏នាំយាយសង់ពេនមួយយ៉ាងខ្ពស់ចំកណ្ដាល ចំការនេះឡើង ដើម្បីស្រណុកមើលជុំវិញចំការគាត់ ។

លុះក្រោយមកមានអ្នកភូមិខ្លះដើរទៅដើរមកចុះឡើង ឃើញពេនតានេះ ខ្ពស់យោលយោកឡើងចុះដូចគេកំក៏សន្មតហៅថា ភូមិពេនកំរហូតមក ។ ភូមិពេនកំនេះ តាមដំណាលថា : មានមនុស្សគុះគរច្រើនណាស់សំណាក់ នៅ តែថ្ងៃក្រោយមកមានអាសន្នរោគកើតម្ដង ក៏បណ្ដាលឲ្យស្លាប់មនុស្ស អស់ជាច្រើនក្នុងភូមិទាំង ក្មេង ទាំងចាស់ ព្រមជាមួយនឹងអាសន្នរោគនោះ មានអព្ភូតហេតុមួយកើតឡើងទៀត ដែលពាក្យកួយហៅថា "ឡុតកឹន" ប្រែជាខ្មែរ "ព្រះធរណីស្រុត" គឺស្រុតនៅកណ្ដាលភូមិមួយកន្លែងដែល ទឹកហូរធ្លាក់ចុះ មិនដឹងជាទៅទីណា ។

ហេតុដូចខាងលើនេះហើយដែលអ្នកភូមិយល់ថាជាភូមិចង្រៃឧត្បាទ មនុស្សនៅចេះតែស្លាប់បន្ត ៗ គ្នា ទើបយប់មួយប្រហែលរំលងអធ្រាត្រ មានចាស់ម្នាក់នៅក្នុងភូមិក្រោកឡើងដុតចន្ទុះដាស់គ្នីគ្នា ប្រជុំហើយរត់ ចេញពីភូមិពេនកំនេះទាំងយប់ ឆ្ពោះទៅរកកន្លែងមួយដែលនៅជុំវិញសុទ្ធ តែត្រពាំង ចម្ងាយពីភូមិពេនកំជាប់ ២ គ.ម. ។

ការដែលនាំគ្នារត់មកតាំងភូមិករថ្មីនេះ ពិតមែនតែអាសន្នរោគមិន តាមមកយាយី ហើយមនុស្សក៏ពុំមានស្លាប់ដូចភូមិចាស់ក៏ទេដែរតែទាំង អស់គ្នាពានទឹកមុខស្រពាប់ស្រពោនជានិច្ច ដូនកាលក៏ស្រក់ទឹកភ្នែកស្រែក យំសោកសង្រេងការឡោះរកប្ដី-បង-ប្អូន-កូនសំឡាញ់ ដែលស្លាប់

ដោយអាសន្នកេតថ្មី ៗ នេះ ។ ការអាឡោះអាល័យគ្រួសារនេះឯងដែល អ្នកភូមិគេសន្មតឲ្យឈ្មោះភូមិគេថា “ ភូមិហេលហាល ” ជាភាសាកួយអន្ទីរ ប្រែជាខ្មែរថា “ភូមិអាឡោះអាល័យ” ។

លុះចំណេរក្រោយមកអ្នកភូមិថ្មីនេះ ក៏បានសេចក្ដីសុខសាន្តរហូតពុំមានឧបសគ្គអ្វីឡើយ មានអន្ទ្រើសាច់ បរិភោគហូរហៀរដោយអាស្រ័យមានត្រពាំង ៣ ជុំវិញភូមិ គឺ ត្រពាំងម្រះ ត្រពាំងចិក ដែលខ្មែរប្រែថា: ត្រពាំងកំង និងត្រពាំងមួយទៀតហៅថា: “ដាកគ្រែត” ប្រែថា “ ត្រពាំងទឹកត្រជាក់” នៅក្បែរភូមិផងហើយដែលគេជឿជាក់ថាជាភូមិត្រជាក់ត្រជុំផងនោះ ទើបមានអ្នកចំណូលថ្មី ៣ ភូមិទៀតមកសុំនៅជាមួយ “ភូមិហេលហាល” គឺភូមិអន្ទៀ ១ ភូមិខ្វង់ព័រ ១ និងភូមិ “ប៉ូអង់”១ “ភូមិប៉ូអង់” នេះជាភាសាកួយអន្ទីរ ដែលបកមកជាខ្មែរប្រែថា “ភូមិក្បាលអ្នក ,, ។

ភូមិនេះមានរឿងនិទាន បរម្បរាត ៗ គ្នាមកថា ៖

“ មានថ្ងៃមួយកួយអន្ទីរពីរនាក់ បងថ្លៃ-ប្អូនថ្លៃ (គឺបងថ្លៃប្រុស ប្អូនថ្លៃស្រីក្រមុំ) ដោយនៅផ្ទះពុំមានត្រីបរិភោគក៏នាំបងប្អូនជិះទូកទៅបង់សំណាញ់នៅអន្លង់មួយនាស្ទឹងកំពង់ត្រណាកសព្វថ្ងៃនេះ ។ លុះបង់សំណាញ់ទៅសំណាញ់ក៏ពាក់ទៅលើសាកសល់ឈើក្នុងទឹក ជាប់ជំពាក់ទាញមកវិញមិនរួច ទើបហៅប្អូនថ្លៃឲ្យមកអង្គុយលើក្បាលទូកចាំចាប់ទាញខ្សែសំណាញ់ឯខ្លួនឯងក៏ចុះទៅមុជដោះ សំណាញ់កង់ទឹកបយសនេះក្រោយមក ដោះ

ពុំទាន់ហើយនៅឡើយទេ តែថប់ដង្ហើមពេក ក៏ងើបផុសមកគោងក្បាលទូក វិញ និមិត្តតែយកដៃជូតមុខហើយបើកភ្នែកភ្លាម ក៏ប្រទះឃើញវត្ថុសំខាន់ (យោនី) របស់ប្អូនថ្លៃលេចចេញមកក្រៅសំពត់ដែលសាមីខ្លួនគ្មានពុំបានដឹងខ្លួនផង ៗ ពេលនោះនាយយើងពិនិត្យច្បាស់ហើយ លេបទឹកមាត់ក្អឹក មុជក្លួបទៅវិញហើយគិតថា: "អញអស់បងអស់ប្អូនហើយពេលនេះ,, ធ្វើឧបាយកលយ៉ាងណាឲ្យតែបានធប្អូនថ្លៃអញ ប្រុសកំហូចនេះ គិតហើយក៏លើកជើងសំណាញ់ឲ្យត្រីចេញអស់ ហើយងើបផុសឡើងនិយាយថា: ហ៊ឹះ ត្រីសម្បូណ៌ដល់ហើយមេនាង ប៉ុន្តែឈើច្រើនពេក ណ្ហើយយើងទៅរកបង់កន្ទ្រងផ្សេងទៀតទៅ ... ថាហើយនាងក្រមុំក៏ក្រោកទាញប្រវែសន្សឹម ៗ ទៅមុខរីឯបងថ្លៃក៏ដំរៀបសំណាញ់ហើយត្រវត់ទៅមុខទៀត ហើយវាធ្វើជាជាប់សំណាញ់រួចវាចុះទៅលើកជើងសំណាញ់ ឲ្យត្រីចេញអស់លើងដូចមុនទៀត ៗ អន្ទិតនេះបានធ្វើរបៀបដូចខាងលើនេះ ជាច្រើនលើកច្រើនគ្រា ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ៗ ម៉្លោះហើយ ១ ថ្ងៃនេះពុំបានត្រីទាល់តែសោះ លុះល្ងាចក៏នាំប្អូនថ្លៃទៅផ្ទះវិញ ៗ

លុះព្រហាមស្រាងឡើង បងថ្លៃ ក៏បាននិយាយទៅកាន់ប្អូនថ្លៃថា យប់មិញ បងដេក ទៅយល់សប្តិឃើញអ្នកតាព្រះព្រៃមកប្រាប់ថា "បើបង់បានត្រីក្នុងអន្លង់នោះ លុះណាតែមេនាងឯងយកទៀនធូប ទៅបន់ស្រន់លោកតាបានលោកតាឲ្យ" ៗ

– បន់នៅឯណាអក ! ( ប្អូនថ្លៃនិយាយ )

– ណ្ហ៎ះ ! អ្នកតាព្រះព្រៃ ហ្នឹះក្បែរអន្លង់យើងបង់នោះ ។ ពេលនោះប្អូនថ្លៃក៏បានធ្វើតាមពាក្យដែលបងថ្លៃប្រាប់ ។

ក្នុងខណៈដែលនាងកាន់ទៀនធូបដើរតម្រង់ទៅអ្នកតាព្រះព្រៃ អន្ទិតយើងក៏ដើរគេចពួនទៅនៅចាំបន្ទំក្រោមខ្ទមអ្នកតាដែរ ។ លុះនាងទៅដល់ហើយក៏ចាប់ដុតទៀនធូបដង្ហាយរួចហើយ លើកដៃថ្វាយបង្គំ៣ដងនិយាយបន់ថា: សុំលោកតាអត់ទោសឲ្យកូនចៅផងចុះ, ពីលើកមុនមិនបានសុំ ឥឡូវសុំឲ្យលោកតាអាណិតជួយចៅ ឲ្យបងបានត្រីផង ពីត្រឹមថ្ងៃនេះតទៅសុំកុំឲ្យប្រកាន់ទោសអ្វីសដំណើរអី ។ ថាហើយអ្នកតាក៏ឆ្លើយតបយ៉ាងគ្រលរមកវិញថា: "មិនបាច់ទេចៅស្រី បើចៅចង់បានត្រីចៅឯងត្រូវរួមរស ជាមួយនឹងបងថ្លៃចៅឯងចុះ ចៅឯងចង់បានត្រីប៉ុន្មានក៏បានដែរ" ទៅវិញចុះ ។

លុះឮអ្នកតានិយាយដូច្នោះ នាងព្រឺក្បាលសំពោងថយខ្លួនដើរមករកបងថ្លៃវិញ ទាំងភ័យអរ ... ។ រីឯបងថ្លៃក៏ហូបនេះ គ្រាន់តែបន្លំធ្វើអ្នកតារួចហើយ ក៏ស្ទុះមករង់ចាំប្អូនថ្លៃធ្វើព្រងើយ ប្អូនថ្លៃទៅដល់គេក៏សួរថា: "ម៉េចមេនាងបានការយ៉ាងណា ?" ប្អូនថ្លៃមានអាកប្បកិរិយាអៀនខ្មាសបងថ្លៃដែរ ... តែទីបំផុតនាងក៏បាននិយាយសារស័ព្ទប្រាប់បងថ្លៃដូចពោលខាងលើស្រាប់ ។ បងថ្លៃឮហើយក៏ធ្វើជានិយាយថា: "ហ៊ុះបងទ័លគំនិតដែរ បើលោកតាប្រាប់អ៊ីចឹងហើយ ម៉េចមេនាងឯងគិតយ៉ាងណា ? ។

- នាងក្រមុំអឹមអៀមបៀមដៃហើយនិយាយថា: ហ៊ុះខ្ញុំមិនដឹងគិតយ៉ាងណាដែរ ... ។ បងថ្លៃក៏បន្តទៅទៀតថា ណ្ហើយយើងប្រថុយមួនលមើលមើស៍ តើបានឬមិនបាន ដូចពាក្យអ្នកតាថាទេ ? ។ អើស្រេចតែអ្នកឯងចុះ ... ប្រថុយក៏ប្រថុយដែរ ... អត់ត្រីស៊ីយូរហើយ ... ។

- ក្រោយពីចាត់ការរួចហើយ អ្នកទាំងពីរក៏បាននាំគ្នាទៅបង់សំណាញ់ជាលើកទី ២ ទៀត ការបង់លើកនេះបានត្រីត្រីហូតគ្រប់សំណាញ់ កាលបើបានត្រីច្រើនយ៉ាងនេះ អនិ្ទតយើងក៏និយាយថា "មេនាងហ្នុះ: អ្នកតាព្រះព្រៃជ្រៃពូកែដល់ហើយជាគ្មានខុសតែមួន" ថ្ងៃក្រោយមេនាងឯងទៅបន់ទៀតហ្នុះ ។ ប្អូនថ្លៃមិននិយាយតបទេតែងក់ក្បាលញញឹមសំដែងអាកប្បកិរិយាយល់ព្រមគ្មានជំទាស់ចំពោះបងថ្លៃ ។ កន្ទងយូរថ្ងៃក្រោយមកទៀតទាំងពីរនាក់បានទៅបង់សំណាញ់ អន្លង់ដដែលទៀតហើយមិនបានត្រីដូចលើកទី ១ ដែរ ដូច្នោះនាងក៏បានទៅបន់ស្រន់អ្នកតាព្រះព្រៃជ្រៃមួនទៀតតាមបង្គាប់បងថ្លៃ ។ រីឯបងថ្លៃក៏បន្ទំទៅពួនធ្វើជាអ្នកតាដូចមុនទៀតដែរ ។ កន្លងខណៈដែលនាងនិយាយបន់ស្រន់រួចហើយ អ្នកតាព្រះព្រៃជ្រៃនិយាយដូចមុនទៀត នាងឮសំដីអ្នកតានិយាយឆ្លើយមកនាងក៏នឹកចាប់ភ្ញាក់ថា ... យី ... សំឡេងអ្នកតាដូចជាសំឡេងបងថ្លៃអញបេះបិទតែកងវែបត្រលបន្តិច រួចនាងក៏ទំលើតពិនិត្យមើលតាមសូរសម្លេងដែលនិយាយមករកនាង ស្រាប់តែឃើញក្បាលអៃបទង់ឬសព្រៃដែលនៅក្រោមខ្ទម ទើបនាងភ្ញាក់ហើយនិយាយជាកាព្យាក្លួយអន្ទរថា:

"យ៉ីៈ បុនិ" ដូចជាប៉ុអង់ ? ប្រែថា ៖

យ៉ីះក្បាលនេះ ដូចជាក្បាលអ្នកឬ ?

អន្ទិតយើងកាលបើគេឃើញ ក្បាលខ្លួនច្បាស់ហើយគេចមិនរួចផង ទើបឆ្លើយថា "ប៉ុអង់ ថា មិនប៉ុអង់" ប្រែថា: "ក្បាលអ្នកថាមិនក្បាលអ្នក" រួចចេញពីក្រោមខ្លួនអ្នកតាមក រីឯប្អូនថ្ងៃក៏នឹកហួសចិត្តនឹងអ្នកតា "មនុស្សរស់" នេះណាស់ដែរ តែបានជាជ្រុលហួសទៅហើយៗ

អន្ទង់នេះក្រោយពីមានរឿងក៉ាវ ដូចពោលខាងលើមក កួយអន្ទួរគេហៅអន្ទង់នេះថា: "អន្ទង់ប៉ុអង់" បកថា: អន្ទង់ក្បាលអ្នក ៗ លុះក្រោយមកមានមនុស្សមកតាំងភូមិនៅកុះករច្រើននៅមាត់ "អន្ទង់ប៉ុអង់" អ្នកភូមិក៏គេហៅភូមិនេះថា: "ភូមិប៉ុអង់" ទៅវិញ តែអ្នកភូមិនេះបាននាំគ្នារើមកនៅភូមិហេលហាល លុះសព្វថ្ងៃដូចខ្ញុំបាទជំរាបខាងលើស្រាប់

រីឯភូមិហេលហាល ឬ "ភូមិអាឡោះអាល័យ" តាំងពីមានមនុស្សមកពីភូមិផ្សេង ៗទៀត ចូលមកនៅកកកុញច្រើនគ្នា មកកាលណាអ្នកភូមិ ក៏នាំគ្នាឈប់ហៅភូមិហេលហាលនោះទៅ ហើយនាំគ្នាសន្មតហៅថា: "ភូមិប៉ាលហាល" ទៅវិញលុះសព្វថ្ងៃនេះ ៗ

ហ៊ុន-សារី

សមាជិកសមាគមអ្នកនិពន្ធខ្មែរ

# ល្បើកអក

លោកអ្នកអានធ្លាប់បានជ្រាបមកហើយ នូវជីវៈប្រវត្តិលោកវិសេស ជួង ដែល លោកបណ្ឌិតមហា ឈឹម-ស៊ុម បានស្រាវជ្រាវ ហើយរៀបរៀងចុះផ្សាយ ក្នុងទស្សនាវដ្ដី « កម្ពុជសុរិយា » កាលពី គ.ស. ១៩៦៨ ហើយក្នុងប្រវត្តិនោះ បានបង្អុលថា លោក វិសេស ជួង បានសរសេរ ល្បើកអក នេះឯង ជាស្នាដៃ សំខាន់របស់លោកផង ។

ដូច្នេះនៅវេលានេះ ខ្ញុំបានស្រាវជ្រាវយកអត្ថបទ «ល្បើកអក» មកចម្លងពី សាស្ត្រាស្លឹករឹត ហើយចុះផ្សាយក្នុងនេះ ដើម្បីបញ្ជាក់ជូនអ្នកអានឲ្យបានជ្រាបច្បាស់ អំពីស្នាដៃរបស់កវីដ៏ឆ្នើមខ្មែរយើងនេះ ។

លី-ធាមតេង

ពាក្យ ៧

៙ នេះនឹងថាថ្លែងចែងសាសង លើកតាមទំនងល្បងប្រាជ្ញា
ប្រាំពីរពាក្យពិតគិតបួនឃ្លា ចងជានិទានមានសេចក្ដី ។
គ្រានោះមានសត្វអកទាំងគូ នៅកំផ្សួរមានកូនខ្ចី
តែងត្រេចជជ្រែករកចំណី មកចិញ្ចឹមនៃកូនប្រពន្ធ ។
លុះដល់ខែចេត្រជួនរីងកំង គោកអស់ត្រពាំងគ្មានជោរជន់
សត្វអកទាំងពីរកើតទុក្ខធ្ងន់ ទឹងត្រេបរកគន់ត្រីពុំបាន ។
ហើរមកប្រឈមមើលមុខគ្នា ថាទុរនិច្ចាកូនកល្យាណ
ម្ល៉េះសមប៉ាទឹងស្រែកអត់ឃ្លាន គឹកម្ពុកណាបកទាន់ហើយ ។

សត្វអកតាំងពីវេងស្គមពេក ក្រឡេកមើលមេឃឆ្ងាយនៅឡើយ
ខ្ញុំយើងជាប់ពោះស្លាប់ដឹងអើយ កម្មអើយមកឲ្យវេទនា ៗ
ហើយមកនិយាយនឹងប្រពន្ធ ថាហៃប្អូនគន់ស្ងួនពុំផា
បងនឹងបង់គ្រេចចរលីលា ទៅរកម្ហូបនឹងបរិភោគ ៗ
ចូរប្អូននាងនៅរក្សាកូន ឲ្យមូលនឹងខ្លួនកុំវិយោគ
បងទៅរកបានបងវិលមក ប្អូនកុំសោយសោកនឹកបងឡើយ ៗ
គ្រានោះអកញីសោតបានស្តាប់ ឮប្តីប្រាប់ប្រាប់ដូច្នោះហើយ
ត្រេកអរក្នុងចិត្តថាអ្នកអើយ ទៅហើយអ្នកវិលមកឲ្យឆាប់
ឆ្នាំថាឈើពុកអ្នកកុំទំ ត្រីណាធំៗអ្នកកុំចាប់
ក្រែងវានាំរត់លិចលង់ស្លាប់ ទៅហើយប្រញាប់វិលវិញផ្គងៗ
គ្រានោះអកឈ្មោលកាន់ស្តាប់ហើរ ក្នុងចិត្តស្អាក់ស្អើរកាត់រំលង
ដល់វាលហើយរំហាចហើរឆ្លង រំលងវាលនោះចូលព្រៃធំ ៗ
ឮតែសម្លេងសត្វទៀវពោច យាសយំលន្លោចស្វាត់ជ្រងំ
តាពើស្រែកធ្លងផងព្រៃភ្នំ បានឮមាសមកសមសប្បាយៗ
បងមើលឯអស់សត្វហ៊ូប ទំទឹមតាំងគួរពុំព្រាត់ព្រាយ
លលកចាបព្រៃផងតាំងម្លាយ ហើរសាយគគ្រឹកក្នុងព្រឹក្សា ៗ
ខ្ញុំហាន់ទាំងគួរហើរត្រសង កម្មអ្វីអញបង់មកកំព្រា
គ្រេចហើរម្នាក់ឯងឥតគ្នីគ្នា ចរចាហើរលេងពុំសប្បាយ ៗ
ស្រណោះវៃយំកណ្តាលទួល បើអញបានមូលប្អូននោះឆាយ

ទឹងនាំមើលឈើផងទាំងឡាយ    និយាយប្រាប់ប្រាយឲ្យសព្វគ្រប់ ៗ
ទុក្ខផ្កាក៏ក្អឹងរឹងតែរីក    រំបេកស្វាកែតក្រអូបឈ្ងប់
រាប់អស់ព្រឹក្សាផងពុំសព្វ    គេសឹងដឹងគ្រប់សព្វសាស្ត្រា ៗ
អកហើរឆ្ពងព្រៃដល់ទៅបឹង    ឃើញគេទ្រហឹងចាប់មច្ឆា
អកហើរបន្ទាបខ្ទុនសិរសា    ប្រាប្តាទឹងសូមត្រីបរិភោគ ៗ
អ្នកអើយអ្នកអកអ្នកនៅបឹង    ចូរអ្នកកុំខឹងខ្ញុំសូមជ្រក
ឲ្យមានត្រីសាច់គ្រាន់បរិភោគ    អញ្ជោគឲ្យខ្ញុំរកស៊ីផង ៗ
គ្រានោះអកបឹងឆ្លើយទៅថា    អ្នកមកពីណានៃអ្នកបង
ចូរប្រាប់មកខ្ញុំតាមទំនង    សាសងឲ្យអស់គ្រប់សេចក្តី ៗ
ទើបអកក្អំឆ្លើយទៅវិញថា    ខ្លួនខ្ញុំនេះជាអ្នកក្រក្រី
នៅក្នុងព្រៃក្អំគ្មានបានអ្វី    ស៊ីជាចំណីដល់តិចឡើយ ៗ
ទឹកសោតក៏គោកស្ងួតសោះគេង    ដីបែកក្រហែងគ្មានសល់ឡើយ
បានជាហើរមកណាអ្នកអើយ    កម្មអើយស្មើរស្លាប់ក្លូនប្រពន្ធ ៗ
អកបឹងព្រថាអាណិតពេក    កម្មអ្វីចំឡែកក្រលើសលន់
នឿយព្រួយលំបាកយ៉ាករាប់ចុន    កែកុនគិតមករកចំណី ៗ
អ្នកនៅបឹងនេះក្រែងពុំបាន    ត្រីពុំសូវមានក្រណាស់នៃ
ទៅរកបឹងទៀតក្រៅផងទៃ    មានត្រីច្រើនរាយទឹងបរិភោគ ៗ
ភៅចុះខ្លួនខ្ញុំទឹងជូនទៅ    ដល់ហើយអ្នកនៅខ្ញុំវិលមក
តាមតែរកស៊ីដោយឈ្លបនិងក    លែលកឲ្យបានដើរប្រពន្ធ ៗ

គិតហើយអកហើរទៅតាំងសង		ហើរកាត់រលងវែងដំបន់
ដល់បឹងធំឆ្ងាយទូលាយលន់		ហើយគន់មើលសព្វគ្រប់ទិសាៗ
ហើយអ្នកដែលជូនត្រឡប់ទៅ		ដល់ទីលំនៅឋានអាត្មា
ចូលទៅនែបនៅនឹងភរិយា		ក្សេមក្សាន្តសុខាឥតអំពល់ ៗ
ថ្ងៃពីអកក្អំទំមាត់បឹង		គន់គិតជញ្ជឹងនឹកខ្វាយខ្វល់
ហើយហើរចរចុះទៅបានដល់		យន់យល់អកបឹងទំគ្រៀបគ្រាៗ
ទើបអកក្អំទៅនិយាយសុំ		ត្បិតខ្ញុំមកនេះអត់អាហារ
យូរថ្ងៃស្គាំងស្គមតាំងកាយា		សូមរកគោក្តាដោយសារអ្នក ៗ
គ្រានោះអកបឹងស្តាប់សំដី		សួរសាកទៅវិញដោយស្មោះស្ម័គ្រ
និយាយពេះពយពាក្យពក់ពាក់		ថាអ្នកអកមកពីឋានណា ៗ
ចូរអ្នកប្រាប់មកជាដំណឹង		ឲ្យយើងបានដឹងដោយវាចា
អកមកសូមសុំរកគោក្តា		យើងក៏មេត្តាព្រមឲ្យអ្នក ៗ
ចូរមកបរិភោគកុំបារម្ភ		មច្ឆាតូចធំតាមចិត្តស្ម័គ្រ
កុំមានគោតក្រែងឡើយណាអ្នក		រកបរិភោគកក្យតាមចិន្តា ៗ
អកក្អំគ្រេកអរមុខរីករាយ		និយាយប្រាប់ប្រាយពីអាត្មា
ខ្ញុំនៅព្រៃក្អំអត់អាហារ		ទំស្ងួនយាត្រាមកដល់អាយ ៗ
ត្បិតបឹងគ្រពាំងឯព្រៃក្អំ		រីងបឹងតូចធំទោះជិតឆ្ងាយ
មច្ឆាតូចធំផងតាំងឡាយ		អន្តរាយវិនាសស្លាប់គ្មានសល់ៗ
អកបឹងស្តែងស្តាប់គ្រប់សេចក្តី		មានចិត្តមេត្រីនឹកខ្វាយខ្វល់

បបួលអកក្អំទៅបានដល់ ទីវែងមណ្ឌលដើររកស៊ី ៗ
អកបឹងត្រឡប់វិលមកវិញ អកក្អំនោះមិញចាំនៅទី
ត្រីឆ្តោរហែលមកទាំងឈ្មោលញី អកធ្មឹមមើលោភ្ញាក់ខ្លួន ៗ
អកលោស្ទុះផាំងទៅទឹងចាប់ ត្រីនោះបានខ្ជាប់នាំលេបលួន
អកប្រឹងទទះភ័យរឹងខ្លួន ទុប្រពន្ធកូនសមកំព្រា ៗ
អកភ័យស្ងាំងស្ងឹងក្អែកសព្រាត ខំប្រឹងសង្វាតស្ទុះម្នីម្នា
ទទះរបួតរូបហើយណា អកប្រឹងប្រវាដល់មាត់បឹង ៗ
ហើយទំកំព្រោបានទុនកក្ងក់ មុខស្ងាំងស្ងឹតស្ងក់នៅទ្រមឹង
កំព្រារងានៅក្បែរឆ្អឹង រំពៃរំពឹងទឹងគិតគន់ ៗ
ថាទុអទិប្ដាខ្លួនអញពេក កម្មអ្វីចំឡែកក្រៃលើសលន់
ខំស្ងែងម្នាក់ឯងពោលប្រពន្ធ សមទឹងបង់ជន្មមិនលែងឡើយ ៗ
ឃើញត្រីសង្វាតចាប់ទឹងស៊ី រូបទៅទទេហែលព្រងើយ
វានាំខ្លួនឯងលិចលង់ហើយ អញអើយកុំអីស្លាប់អសារ ៗ
អកមានកំឡាំងហិចហើរទៅ ឃើញអកញីនៅលើរុក្ខា
មេម៉ាយស្លាប់ប្ដីនៅឯកា កំព្រាកំព្រនតែម្នាក់ឯង ៗ
អកក្អំហិចហើរចូលសំដៅ ដល់ហើយទំនៅគិតថ្ងាថ្ងង
និយាយចំអន់ចំអកលេង ចាបែងទៅជាថៃនាងអក ៗ
នាងនៅម្នាក់ឯងកន្គឯកា ឥតគូកំព្រាបងសូមជ្រក
ផើខ្លួនលើបួនសូមអធ្យាគ បងមកសង្វាតរកអាហារ ៗ

សូមឲ្យប្អូនមាសនាងអាណិត — រំពឹងរិះគិតក្នុងប្រាជ្ញា
ជាម្ដេចជាចុះឲ្យឃើញការ — ចិន្ដាបងអ្នកបង់ស្គាល់ប្អូន ៗ
ទើបអកញីស្ដាប់សងរ៉ាតា — ខ្លួនខ្ញុំនេះជាស្រីសុទ្ធសូន
ពុំគួរមកពឹងពំនាក់ប្អូន — ផ្ញើខ្លួនដូច្នោះយល់ពុំសម ៗ
ខ្លួនខ្ញុំមានប្ដីស្លាប់ពេលទៅ — មេម៉ាយមកនៅដូចក្រមុំ
កំព្រាអោរដោយព្យុះធំ — អ្នកអើយអ្នកកុំក្រែងសៅហ្មង ៗ
មានពាក្យដំនៀលអាស្រូវកាស — ខ្មាសអស់ទាំងផ្ដាសគេជាឆ្គង
មេម៉ាយយកប្រុសមកនៅផង — កុំចុះអ្នកបងក្រែងកើតវៀរ ៗ
ទើបអ្នកកុំសងសព្វសេចក្ដី — ព្ធពាក្យប្អូនស្រីស្ដីគយរ
ត្រូវពិតប្រាកដហើយមែនហ្ន៎ — បារម្ភថ្វីនឹងវរប៉ុណ្ណោះឡើយ ៗ
បងសោកពោះម៉ាយស្លាប់ប្រពន្ធ — ដូចប្អូនមាសតន់ដៃនាងអើយ
ស្ទែងស្ទះលាកលះមកជាល្មើយ — កែវអើយចូរប្អូនអាសូរបង ៗ
បងនឹងសូមបងជាមេត្រី — នឹងប្អូនស្រស់ស្រីជាគូគ្រង
តាមតែអាណិតចិត្តចុះហោង — មាសបងសោកប្អូនស្ងួនកំព្រា ៗ
ទើបអកមេម៉ាយត្រាសឆ្លើយទៀត — ជាអ្នកកុំបៀតហ៊ានពុះពារ
លួងលោមបញ្ឆោតឲ្យបានជា — សង្សារហើយណាបែរដោះដៃ ៗ
ខ្លួនខ្ញុំពុំសូវជាចេះដោត — ឲ្យអ្នកបំពោតដូចអស់ស្រី
ណ្ហើយចុះប្រុសអើយកុំចេតី — អ្នកទៅរកស្រីឯទៀតវិញ ៗ
ខ្លួនខ្ញុំពុំបានព្រមនឹងអ្នក — ជាគូររួមរក្សាហាក់ចំណេញ

ទៅចុះតាមចិត្តរើសស្រឡាញ់ អកច្រើននៅពេញតែមាត់បង ៗ
អកក្នុំហើយសើចចំទមាត់ ថាទុះគេកាត់ពោលសោះដឹង
អង្វរទៅថាប្អូនកុំខឹង ជញ្ជឹងស្ដាប់បងនឹងប្រាយប្រាប់ ៗ
អំពីដំណើរបងស្រឡាញ់ ស្រីច្រើនពាសពេញមិនមានចាប់
ចិត្តបងស្រឡាញ់ជាគួរគាប់ ឃើញប្អូនប្រទាប់ត្រូវចិត្តបង ៗ
បងបានជាស្ម័គ្រនឹងប្អូនស្រី សូមប្អូនប្រណីមេត្រីបង
កុំអាលក្រេវក្រោធលោភលង មាសបងបងនឹងផ្ញើជីវិត ៗ
នាងអកព្រួសសូរសព្ទសំដី មានចិត្តមេត្រីនឹកអាណិត
តែជាពាក្យក្រៅថាមិនស្និត ប៉ុន្តែឯចិត្តស្រឡាញ់ណាស់ ៗ
នឹងព្រមទៅហាក់អៀនរឹងមាត់ ហើយខុសបន្ទាត់នឹងច្បាប់ចាស់
លោកតែងទុកមកឲ្យដឹងច្បាស់ ចាំងក្មេងចាំងចាស់រក្សាកេរ្តិ៍ ៗ
នាងអកអៀនទុនធ្វើមមិច បើភ្លេចបព្រិចភ្នែកមមី
អកក្នុំដើរចូលជិតទៅទី អកញីថាឃើញពេញចិត្តធំ ៗ
ជិនណាស់កុំមកលេងវឹកវរ យើងមិនស្រីចោរបើកក្រមុំ
ហ៊ានសុំមកឈរជិតទន្ទឹម សុខុមធ្វើមុខរាំហើយសោះ ៗ
នាងអកប្រានផាងថាចុះទៅ កុំអ្នកមកនៅធ្វើនេះនោះ
រញ្ជាញទៅស្រុកវិញទៅចុះ ធ្វើយ៉ាងដូច្នោះមិនព្រមឡើយ ៗ
អកក្នុំថាទុះអកុសលកម្ម នានាំអញមកដល់ស្រីហើយ
បានតែជួបមុខទុកគានស្បើយ ប្អូនអើយផ្ដើមបើចុះតាមបុរាណ ៗ

បើប្អូនបណ្តេញបងចុះទៅ បងទឹងខំទៅម្តេចទឹងបាន
ចិត្តគេគោះតើយស្បើយក្នុងប្រាណ ទឹងទៅបំពានម្តេចបានឡើយ ។
នីនែ ! ប្អូនបែរមកឯណាយ បងទឹងនិយាយលាប្អូនហើយ
ចូរប្អូននាងនៅឲ្យល្ហៃល្ហើយ ប្អូនអើយនាងនៅឲ្យសាន្តសុខ ។
ត្បិតបងបានជាអកំពើហើយ ប្អូនអើយបងលាប្អូនទៅស្រុក
កុំទឹកដើមបងក្រែងរាំយុក នាងអកកើតទុក្ខពុំស្តីសោះ ។
អកក្តាំផ្តាំស្រេចហើយបើកស្លាប ដាក់ក្បាលទន្ទាបធ្វើទឹងស្លុះ
អកញ៉ីចីកស្លាបទឹងជំពុះ ថានែអកប្រុសកុំគាលទៅ ។
អកក្តាំបែរមុខវិលមកវិញ ថាប្អូនសំឡាញ់ចិត្តនោមនៅ
ប្អូនឃាត់បងប៉ុន្មានឲ្យទៅ ប្តីទុកបងនៅជាគូគ្រង ។
នាងអកអៀនខ្មាសហើយដាក់មុខ ក្នុងពោះប៉ុផ្អុកពុំសាសង
ហើយលួចមើលអកក្តាំម្តង ៗ គិតពុំធ្លាស់ធ្លងទៅទៀតឡើយ
គ្រានោះអកក្តាំចូលចាប់ស៊ី អកញ៉ីក្រញួក្រាបទន្ទាបហើយ
ទទួលរាបរងផ្គងផើងផើយ ដិតហើយអកប្រឹងរឹងទាំងប្រាណ ។
អស្ចារ្យទឹងឈានត្រួសត្រួវ ទឹកហូរជន់ជោរលិចត្រើយត្រាណ
រលកបោកក្រែងរិចពុំមាន សល់ខាងដល់មួយដើមតិចឡើយ ។
ក្រពើលលើហែលចុះកោះ ល្អិចចូលក្នុងជ្រោះមុជផើងផើយ
ខ្ទុលទឹកលេងស្រេចហែលថយក្រោយ ផើបហើយមានក្បាលនោះពេញស្ញើ ។
អកសត្វទាំងពីរធ្វើស្នេហាស្និទ្ធ នៅទឹងរួមរ័តពុំល្ហើយល្ហៃ

ចូលចិត្តគិតតែលែកស៊ី ទាំងឈ្មោលទាំងញីពុំឃ្លាតឡើយ ។
យើងនឹងឈប់ស្នេះត្រង់នេះនៃ ត្បិតផុតសេចក្តីប៉ុណ្ណោះហើយ
អកញីនៅក្នុំពុំព្រងើយ ពុំដឹងដើមឡើយរឹងទន្ទឹង ។
សង្កាតសង្វែងវែងមើលផ្លូវ ពុំឃើញប្តីកូវនៅទមឹង
ស្តាំងស្តមទ្រមខ្លួននៅតែថ្អឹង រំពៃរំពឹងគិតទៅគ្រប់ ។
ស្រមើលស្រមៃក្រៃពេក សន្ទៃសន្ធឹកនឹកគ្មានឈប់
វង្វេងស្មារតីប្រឹងតែផ្អប់ ហើយទប់ពុំបានស្រែកខ្ញួញថា ។
ថាឱអ្នកអើយនែអ្នកអក លាប្អូនទៅរកចាប់មច្ឆា
ឥឡូវបាត់ស្ងួនយូរពន់វេលា តើមានប្រការហេតុដូចម្តេច ។
ឬមួយអ្នកស្លាប់ទៅដឹងអើយ ឬរស់នៅឡើយហើយគិតគេច
មានស្រីថ្មីទៀតក្រែងអ្នកភ្លេច គិតគេចឲ្យប្អូននៅកំព្រា ។
បើពិតប្រាកដដូច្នោះមែន បាត់ហើយផ្អែតណែនក្នុងឧរា
មានស្រីប្តីទៀតដូចខ្ញុំថា ឧរាតានតឹងស្មើនឹងព្រាយ ។
បើអ្នកពុំមែនដូច្នោះទេ ខ្ញុំគិតក្រែងតែអ្នកក្សយកាយ
ហោលភ្លោចម្នាក់ឯងនៅព្រៃឆ្ងាយ ខ្លួនខ្ញុំនៅអាយពុំដឹងឡើយ ។
នាងអកទ្រហោយំកន្ទេង សង្រេងស្រែកសព្ទស្ងួរលើយៗ
បៀងបោរប្រមុខងក់ងើបងើយ ម្តេញហើយនាងអកសន្ទប់វង់ ។
លុះដល់ព្រលប់យប់ជ្រៅស្ងាត់ ព្រះពាយផាយផាត់ខ្លាំងពេកពន់
សន្សើមសោតធ្លាក់ត្រជាក់ស៊ុន ស្វាងមុខៈក្រោកគន់សព្វទិសា ។

ឃើញតែកូនគូនៅសំបុក
រីឯតែកើតទុក្ខចុកខ្លោចផ្សា
អន់អួលក្ដួលក្ដៅក្នុងឧរ
ទួញថាឱកូនមាសម្ដាយអើយ ។
បានៅចាំម្ដាយរកភក្សា
ម្ដាយនឹងយាត្រាទៅឆ្ងាយហើយ
តាមរកចុំបាណាកូនអើយ
បាអើយបានៅសមកណ្ដាង ។
ហើយអកស្រែកផ្ដាំអស់ទេវតា
សូមលោកមេត្ដាជួយគាត់តែង
ថែចាំកូនខ្ញុំត្បិតកូនក្មេង
កុំឲ្យឆ្មាតខ្លែងឆាបឆក់ឡើយ ។
ឲ្យបានសាន្ដសុខកុំឲ្យខ្វល់
ទុក្ខទោសមកផ្ដល់ខ្ញុំលោកអើយ
លោកចម្លងដាក់ឲ្យដល់ត្រើយ
ម្ចាស់អើយលោកជួយឲ្យសព្វគ្រប់ ។
អកទួញស្រេចហើយកាច់ស្លឹកឈើ
មកគ្របពីលើឈើជាម្លប់
ផ្ដាំថាមាសម្ដាយចូរអ្នកស្រប់
ចាំងថ្ងៃចាំងយប់កុំចេញក្រៅ ។
ក្រែងក្អែកខ្លែងវាមើលឃើញបា
ចូលចាប់កោក្ដាគ្មានសល់នៅ
ស៊ីអស់លើងហើយហើរទៅ
កូនពៅបាកុំប្រហែសប្រាណ ។
អកផ្ដាំស្រេចហើយស្ទុះហើរទៅ
ក្នុងទ្រូងក្ដួលក្ដៅគិតរំខាន
ប្រឹងកាត់ហើរហោចលុះលេចបាន
ដល់បឹងទឹលមានអកត្រៀបត្រា ។
ប្រឹងគន់មើលប្ដីមិនឃើញសោះ
មើលតាមចន្លោះគ្រប់ទិសា
ចូលទៅសួរគេឆាប់ម្នីម្នា
ថានែអ្នកអកអ្នកនៅឆាយ ។
ក្រែងអ្នកយល់ប្ដីខ្ញុំផងពី
បើឃើញអ្នកបងអ្នកប្រាប់ប្រាយ
ឲ្យបានស្បើយទុក្ខចិត្តកាយមាយ
និយាយប្រាយប្រាប់ពីទុក្ខខ្លួន ។
អកបឹងប្រាប់ថាយើងយល់
ឃើញគាត់មកដល់បានជួបជួន

និយាយប្រាយប្រាប់ពីរឿងខ្លួន
ថាប្រពន្ធកូននៅឯភ្នំ ។
ខ្ញុំក្រែងគាត់ទៅបាត់ទៅហើយ
ឥឡូវម្ដេចឡើយបាត់ជ្រងំ
ទៅរកគាត់ចុះឯបឹងធំ
ម្ល៉េះសមគាត់មានទៀតដឹងអើយ ។
អកញ្ញីស្ដាប់ជាក់ហើយលាទៅ
ប្រឹងហើរសំដៅដល់បឹងហើយ
ប្រឹងគន់មើលប្ដីពុំយល់ឡើយ
ជាក់ហើយគេសព្វគ្រប់ទិសា ។
លុះឃើញប្ដីជាក់ក្អាក់ខ្លួនព្រើត
កន្ទុយផងខ្ទើតទំទឹមគ្នា
ជាក់កក្វក់លើព្រឹក្សា
ឧកគានតឹងស្ទើរទឹងធ្លាយ ។
អកញ្ញីទំមើលតែពីក្រៅ
ក្នុងទ្រូងក្ដួលក្ដៅគ្មានស្រាយ
ពុះពោរឧកផ្សាក្រហាយ
ស្ទើរទឹងប្រេះធ្លាយជាពីរភាគ ។
អកក្នុំទំទឹមទាំងឈ្មោលញី
ធ្មេចភ្នែកមមើមមិនមានស្រាក
ភ្លេចកូនប្រពន្ធមិនចាំពាក្យ
ទឹងមករកខ្លាចប្រពន្ធចុង ។
អនិច្ចាអកញ្ញីរងកើតទុក្ខ
ខ្យល់ស្ទុះស្ទុះរត់នៅក្នុងទ្រង់
វង្វេងស្មារតីឡប់ឡិងឡង់
ខំផ្គង់ស្មារតីញ័រចំប្រប់ ។
ចង់បោកខ្លួនស្លាប់តាមចិត្តខឹង
កំដឹងទៅកូននៅក្នុងស្រប់
កូនអើយបាកើតមកឥតក័ព្វ
ពុំគាប់ពុំគួរបើដូច្នេះ ។
ម្ដាយស្វែងបោលកូនៈនាំឯនាយ
គ្រៀមក្រំទ្រូងម្ដាយស្ទើរទឹងប្រេះ
មិនដឹងជាចិត្តគេដល់ម្ល៉េះ
អើនេះហោះពេញវង្វេងស៊ុន ។
បើគេមិនគិតអាសូរញាយ
គួរតែទឹងស្ដាយទៅកូនគន់
មិនគួរកូនម្ដាយឥតលោកលង់
កូនគន់សំឡាញ់មាសម្ដាយអើយ ។

ម្តាយក្រុងក្រញូក្រាបរក្សាបា ទ្រាំរងវេទនាពុំបានស្បើយ
ជាទិច្ចព្រួយចិត្តឥតល្ហែល្ហើយ កូនអើយគៀតគេចេញចាកទៅ ។
សន្ទូតតែត្រឹមបីទិវា ទឹងវិលលីលាមកនៃបនៅ
ក្រួចក្រុងរក្សាគ្រងកូនពៅ ពាក្យម្តាយចាំនៅមិនឃ្លាតឃ្លា ។
ម្តាយតែងទន្ទឹងចាំក្រង្ហូវ មើលផ្លូវហួបផល់សត្តទិវា
ចាំងកូនចាំងម្តាយរងវេទនា អាហារសោកគ្មានពោះសោះចេង ។
សុខទុក្ខខ្លួនម្តាយៗមិនគិត អាណិតតែបាៗនៅក្រុង
អត់ចាំងអាហារឃ្លានសម្រេង ដោយពុំដែលព្យួងគិតស្រេកឃ្លាន ។
នាងអកស្រែកខ្លួញពីកំសត់ ញាប់ញ័ររង្វត់កសល់អង្គប្រាណ
ដោយគត់អាហាររកពុំបាន ស្គមប្រាណស្រកស្ងួនទៅតែឆ្អឹង ។
សោយសោកសោកខ្លួនស្លាប់ទៅជា បុខគួររមិលាគិតរំពឹង
អាស្ទូរនាងអកនៅមាត់បឹង ខំប្រឹងការសូបឡើងវន្ទា ។
គ្រប់ទីគ្រប់ទិសចាំងប្រាំបី ចាំងសួណាស្រីគាមា
ចាំងទេពសោឡសព្រះព្រហ្ម ខ្ញុំនបស្ការថ្វាយបង្គំ ។
សូមជាសាក្សក្នុងជាតិនេះ ប្រុសចិត្តផ្តេះខ្ញុំសូមសុំ
លាសព្វគ្រប់ជាតិកុំឲ្យខ្ញុំ ជួបជុំរៀនព្រេងផល់ទិញាន ។
អកស្រែកឃោសនាសំទេវតា សូមសុំសព្វតាំងប្រណិធាន
រូបស្រេចរន្ធត់ក្នុងអង្គប្រាណ គិតកូនកល្យាណនៅក្នុងព្រៃ ។
ម៉េះសមទន្ទឹងមើលផ្លូវម្តាយ កូនកយម៉េះសមបាសថ្ងៃ

សន្ទឹកទឹកម្តាយអត់ចំណី ហាលខ្យល់ហាលថ្ងៃតែពីរនាក់ ៗ
អកកុំស្រែកយំទួញក្តែងៗ អកឈ្មោលនោះតែងស្តាប់ទៀងជាក់
ធ្វើតើយព្រាងើយមិនភ្ញាភ្ញាក់ ទំទឹមពីរនាក់ប្រពន្ធបុង ៗ
រីឯរឿងការដំណើរនេះ ទុកស្នេះថ្លែងពីកូននៅក្នុង
ព្រៃធំជ្រងំស្ងាត់សូន្យសុង តែងរង់ទន្ទឹងមើលផ្លូវម្តាយ ៗ
សន្ទៃសន្ទឹកញ័រចំប្រប់ ត្រូវថ្ងៃសន្ទប់តាំងពីកាយ
លុះភ្ញាក់ស្មារតីធ្វេសកាយមាយ បើកភ្នែកមើលម្តាយមិញមិនយល់ ៗ
ជាហេតុកម្មកូនសូន្យតាំងពី ពៀរព្រេងបុព្វកម្មមកផ្តល់
ហេតុសត្វតាំងពីសាងអកុសល មិនផ្តល់ឲ្យយល់ឃើញថ្មីៗ ៗ
គ្រានោះមានសត្វត្មាតកំណាច ជាសត្វកាយកាចចោរអប្រិយ
តែងទឹងឆាបឆក់កូនបក្សី ស៊ីជាចំណីសព្វទិវា
មានកាលសម័យថ្ងៃនេះនៃ ត្មាតហើរព្រៀវប្រែសព្វព្រឹក្សា
សំកាំងស្ទាបរកមើលរក លើចុងព្រឹក្សាបានឃើញជាក់ ៗ
បានយល់កូនអកនៅទាំងពីរ មិនឃើញមានមេនៅរួមរក្ស
ត្មាតត្រេកអរសោទរអរតេតក់ ត្មាតភ្ញាក់គិតថាទុលាភហើយ ៗ
គិតភ្លាមត្មាតចរចូលចឹកស៊ី កូនអកតាំងពីរពុំលង់ឡើយ
ហែកយកថ្លើមស៊ីស្រេចព្រាងើយ អស់ហើយទម្លាក់ចោលទៅដី ៗ
ហើយត្មាតហើរទៅលំនៅបាន បរិបូណ៌ក្សេមក្សាន្តឥតហេតុអ្វី
រកស៊ីដូចកាលដើមប្រក្រតី ឥតបីឥតបើមានអំពល់ ៗ

ឈប់ស្ទុះនឹងថ្ងៃងើតមេអក ក្រឡាប់វិលមកដល់មណ្ឌល
ពេលក្អែកក្រឡេកមើលមិនយល់ កូនតូចមិលនៅសំបុក ៗ
អករង់កើតទុក្ខក្តៅផ្សា ញ័រអស់អង្គាទ្រូងចេសចុក
រំខានគានគឹងរងថែមទុក្ខ រំភុកសោយសោកបោកប្រះប្រាណ
បម្រះនទៀលនៅសំបុក បែរមុខមើលកូនសព្វទិសឋាន
ពុំឃើញកូនស្ងួនកែវកល្យាណ អកប្រឹងប្រែប្រាណចុះដល់ដី ៗ
បើកវែករកសព្វសទ្ទឹកឈើ អកមើលទៅបាទឃើញជាក់ខ្ចី
ដែលក្អាតចិកស្លាប់ធ្លាក់មកដី នាងស្រីអកខ្ញូញទំនួញថា ៗ
ឱកូនកំសត់មាសម្តាយអើយ ម្តេចឡើយបាមកស្លាប់អសារ
ពេលម្តាយឲ្យនៅអង្គឯកា ម្តាយសូមប្រាប់ដូចនឹងអ្នក ៗ
ម្តាយនឹងរស់នៅតែអង្គឯង ទ្រូងម្តាយចំបែងតែងអួលណាក់
នឹងរស់នៅថ្វីពុំយល់ភ័ក្ត្រ កូនស្ងួនវិលក្សណ៍ព្រាសអស់ហើយ ៗ
នាងអកសោយសោកឱបខ្មោចកូន សន្ធប់សុងសូន្យសោះជាត្រើយ
លុះភ្ញាក់ស្មារតីពុំលង់ឡើយ អកខ្ញូញល្ហើយ ៗ ក្នុងអត្ថា ៗ
ហើយអកកាងស្លាបឡើងបង្គំ ប្រណម្យគាំងចិត្តសូមសច្ចា
និងអស់ឥន្ទព្រហ្មនូវទេវតា ទាំងឆកាមាសួគ៌ាល័យ ៗ
សូមលោកមូលមកជាប្រធាន សាក្សីពេជ្ញាណខ្ញុំនេះនៃ
ជាតិនេះខ្ញុំប្រាសនឹងកូនថ្លៃ ជាតិក្រោយដទៃកុំឃ្លាតឃ្លា ៗ
រៀង ៗ ដរាបដល់និព្វាន បរិបូណ៌កេរ្យមកព្រាន្តឥតទុក្ខា

អកផ្សែងរូបស្រេចខុនសិរសា បក្សាទទះស្មើរផ្ទុកផ្ទោះ ។
ហើយឡើងទៅលើអាកាសនាយ សង្រួមអង្គកាយសំយុងចុះ
ខ្យល់ផាត់អណ្ដែតធ្លាក់ចេញស្មោះ ជ្រុះត្រង់ចន្លោះដែលកូនក្ស័យ ។
ស្លាប់ប្រួតតម្រួតគរលើគ្នា មុខគួរអនិច្ចាអាណិតក្រៃ
សត្វទាំងបីប្រាណសិងក្សិណក្ស័យ ប្រល័យស្លាប់មួលមួយនឹងគ្នា ។
ហៃអស់សប្បុរសផងទាំងឡាយ គួរខ្លាចគួរណាយកម្មវេរ
សត្វហោងមនុស្សហោងសិងដូចគ្នា គួរគិតអនិច្ចាពល់រូបកាយ ។
បញ្ឈប់រឿងក៏ឈប់ នៅនេះ យើងនឹងគិតកែប្រែនិយាយ
ពីអកឈ្មោលដែលនៅឯនាយ និយាយលួងលោមប្រាប់ប្រពន្ធ ។
ថាហៃមាសស្នេហកែវព្រលឹង បូស្ងួនកុំខឹងអើយប្អូនតង់
បងសូមទៅទៅរកដំបន់ បូរតន៍នាងនៅរក្សាប្រាណ ។
ត្បិតបងមានកូននៅឯនាយ កំព្រាតម្ដាយណាកល្យាណ
បងណាប្អូនពៅទៅទីឋាន សួរកូនកល្យាណបើកប្ដីទេ ។
អកញីព្រហើយភ្ញាក់ខ្លួនព្រើត បំភើតស្ដីទៅថាឱមេ
ខ្ញុំស្មានថាអ្នកគ្មានកូនទេ ម្ដេចឡើយប្រុសស្នេហ៍មិនប្រាប់ប្អូន ។
ថាបើអ្នកមានកូនឯនោះ អាពញ្ញាទៅចុះរកសួរកូន
អ្នកទៅកុំនៅយូរពេលប្អូន ស្ងាត់សូន្យនៅអាយមើលផ្លូវចាំ ។
អកឈ្មោលត្រេកអរតែឧបមា និយាយផ្ដាំគ្នាគ្រប់ទៅ(១)

១ - ត្រង់នេះពាក់ក្លួន ប៉ុន្តែយើងមិនហ៊ានកែ ទុកតាមក្បួនដើមស្ទើរពិត ។

ផ្តាំហើយស្ទុះផ្ទោះលោតសំដៅ តម្រង់ត្រង់ទៅឯព្រៃភ្នំ ។
អកទឹកអំពីកូនប្រពន្ធ ក្នុងទ្រូងអួលអន់មុខក្រៀមក្រំ
ខំហើរកាត់ដោយដងព្រៃភ្នំ ពិតពុំសម្រាន្តកាយឈរឈប់ ។
ខំប្រឹងហើរស្រូតរូតសំដៅ ដល់ទីលំនៅទៀបព្រលប់
អកឡើងរកមើលគន់សព្វគ្រប់ ក្នុងសំបុកសព្វមិញមិនយល់ ។
ទាំងកូនទាំងម្តាយបាត់ស្ងាត់យើង អករឹងតែងកើតទុក្ខរំពល់
គន់សព្វព្រឹក្សាពុំបានយល់ អកឆ្ងល់ក្នុងចិត្តហើយគិតថា ។
ឱកូនទាំងពីរមាសឪអើយ ម្តេចឡើយបាបាត់ទៅឯណា
មកឲ្យឪពុកកើតទុក្ខា មាតាបាៈសោតក៏ព្រាត់ទៅ ។
អកស្រែកទ្រហោយំក្តួចៗ ព្រួសព្រួះល្វើយល្វេងក្នុងព្រៃជ្រៅ
នទៀលប្រះប្រាណស៊ុងស៊ុបសៅ សន្ទប់សូន្យទៅបាត់វិញ្ញាណ ។
លុះភ្ញាក់ស្មារតីឡើយសោយសោក សែនសល់អមោក្ខមោកប្រះប្រាណ
បម្រះនទៀលនៅនាឋាន គិតស្មានថាឱកូនអញហើយ ។
ឬជាសត្វអ្វីមកចឹកចាប់ ឬស្លាប់ដាច់ពោះទដឹងអើយ[១]
ទាំងម្តាយទាំងកូនពុំយល់ឡើយ កូនឡើយម្តេចមកស្លាប់អសារ ។
បើដឹងស្លាប់រស់លែងឲ្យបាន ឃើញប្រាណខ្មោចកូននៅតិចក៏
ឱអញព្រោះស្រើបដោយតណ្ហា ប្រហែលសង្សារនៅឯនាយ ។
គិតស្មានបានរស់រួមជន្មា ប្រឹងចាប់មច្ឆាផងទាំងឆ្ងាយ

---

១ - បុរាណ អានថាដឹង - ឡើយ ទើបបានជាប្រើចាប់ដូនជាមួយ អញហើយ ។

ពាពាំពីនាយមកដល់អាយ ឱកូនឆោមឆាយមាសឪពុក ៗ
មិនដឹងមកដល់បាត់កូនទៅ កួលក្ដៅកង្វចិត្តគិតវិតក្ក
រកកូនមិនឃើញនៅសំបុក ឱស្រស់ឪពុកម្ចាស់ៗអើយ ៗ
សត្វអកសោយសោកពីប្រពន្ធ ថាឱប្អូនគន់មាសបងអើយ
ពុំគួរបើបងធ្វើតោះតើយ ស្រីអើយពីកាលប្រើទៅតាម ៗ
ស្រីថ្ងួញស្រីតូចស្រីអំពល់ ស្រីស្រស់និមលយំរហាម
មុខស្រីមុខស្រស់មុខស្រក់ឈាម ខំតាមខំហៅខំរកបង ៗ

(នៅមានត)

# កវីន្ទ្របណ្ឌិត

អ្នកនិពន្ធសតវត្សទី ១០

ដោយ

## ឱក-គាម

---

## លំនាំដើម

ការសរសេរប្រវត្តិនិងស្នាដៃរបស់អ្នកនិពន្ធ កវីន្ទ្របណ្ឌិតនេះ បានជួបនឹងសេចក្តីលំបាកជាច្រើន ព្រោះឯកសារដែលត្រូវយកមកសរសេរនេះមិនមែននៅជុំគ្នាទេ ។ ខ្ញុំចង់ក្រងឲ្យបានជាកូនអត្ថបទមួយដ៏ខ្លីនេះ ដោយខ្ញុំបានប្រមែប្រមូលឯកសារត្រង់នេះបន្តិចត្រង់នោះបន្តិចឲ្យបានជាប្រវត្តិនេះឡើង ។

ជីវប្រវត្តិនិងស្នាដៃអ្នកនិពន្ធនេះ នៅមានកំបាំងទៀត តែខ្ញុំមិនទាន់រកឃើញ ខ្ញុំរកឃើញបានតែត្រឹមប៉ុណ្ណេះ ។ ដូច្នេះ ក្នុងការសរសេរមិនបានវែងឆ្ងាយ មិនបានគ្រប់គ្រាន់ សូមលោកអ្នកអានមេត្តាអភ័យទោស ហើយបើមានយោបល់ឬ បានជួបប្រទះប្រវត្តិ និងស្នាដៃរបស់អ្នកនិពន្ធនេះ សូមជួយបំពេញ ឲ្យបានត្រឹមត្រូវ ដើម្បីជួយរចនាជីវប្រវត្តិនិងស្នាដៃនេះឲ្យបានគ្រប់គ្រាន់ ។

អ្នកនិពន្ធ

# ភិរិន្ទបណ្ឌិត

តាមឯកសារនៃសិលាចារឹក ដែលខ្ញុំបានប្រមូលជូនយកមកចងក្រងនូវស្នាដៃ និងជីវប្រវត្តិនៃអ្នកនិពន្ធដ៏ល្បីឈ្មោះ នៅសតវត្សទី ១០ នេះ មិនបានអធិប្បាយនូវប្រវត្តិនិងស្នាដៃអ្នកនិពន្ធនេះ ឲ្យបានវែងឆ្ងាយឬក្បោះក្បាយទេ ៗ ពោះបើឯកសារដ៏ស្តួចស្តើងក៏ដោយ ក៏ឯកសារនេះបានទុកជាជំហានឬទុកជាគន្លឹះមួយក្នុងការសរសេរនេះដែរ ហើយបន្ទាប់នេះទៅនឹងបានជាប្រយោជន៍ដល់អ្នកដែលស្រាវជ្រាវ ខាងក្រោយជាមិនខាន ៗ

ប្រវត្តិនិងស្នាដៃរបស់អ្នកនិពន្ធភិរិន្ទបណ្ឌិត អាចចែកទៅដូចខាងក្រោមនេះ ៖

១- ត្រកូល

ទុកណាជា យើងមិនអាចស្រាវជ្រាវរកថ្ងៃខែ ឆ្នាំកំណើតរបស់ភិរិន្ទបណ្ឌិតឃើញក៏ដោយ ក៏យើងអាចរកវង្សត្រកូលរបស់លោកនេះបានដែរ ៗ ការដែលយើងស្រាវជ្រាវរកឃើញនូវជីវប្រវត្តិ និងស្នាដៃអ្នកនិពន្ធភិរិន្ទបណ្ឌិតនេះឃើញ ក៏ដោយសារតែសិលាចារឹកខ្មែរ ៗ

ភិរិន្ទបណ្ឌិត មុននឹងបានឈ្មោះជា ភិរិន្ទបណ្ឌិតនេះ គឺជា-

តាកែត្រពាំងវុន បានប្រាប់ថា លោកមានឈ្មោះថា ព្រះកម្តែងផលប្រិយ[1] ជាបុត្ររបស់ទានវនាថ[2] ហើយត្រូវជាចៅរបស់លោកគោវិន្ទ ។ គោវិន្ទនេះសោត ត្រូវជាកូនចំរើផ្កាលរបស់ព្រះបាទជ័យវរ្ម័ន នៅដើមសតវត្សទី ៩ ។

អាស្រ័យឯកសារបរទេស និងសិលាចារឹក យើងអាចពិនិត្យទៅឃើញថាកវីន្ទ្របណ្ឌិតមានបុត្រប្រុសម្នាក់ ឯបុត្រដទៃទៀតយើងរកមិនទាន់ឃើញ ។ បុត្រប្រុសរបស់លោក មាននាមប្រាកដថា នាកយណៈ ឬ កវីន្ទ្រវិជ័យ ។ តែចំណែកមាតាទិងកិរិយារបស់លោកមិនអាចរកឃើញឡើយ ។

កូននេះក៏មានឈ្មោះល្បីល្បាញទៅសម័យនោះដែរ លោកបានធ្វើជាអាចារ្យនៅក្នុងពិធីទៀតផង ។

ដើម្បីឲ្យងាយយល់នូវវង្សត្រកូលនៃកវីន្ទ្របណ្ឌិត សូមលោកអ្នកមើលតារាងត្រួសារ ដូចតទៅនេះ :

1- Inscription du Cambodge, volume III. page 271.
2- Inscription of Kambuja, by R. Majumdar, page 332.


គោវិន្ទ
ជយេន្ទ្រវាស ឬ ជយេន្ទ្រលោក : នៅអនិន្ទិតបុរី (រាជ្យជ័យវរ្ម័នទី២)
វាសុទេវ ឬ ឧបេន្ទ្រលោក : (រាជ្យជ័យវរ្ម័នទី៣ និងឥន្ទ្រវរ្ម័នទី១)
ប្រទ្យុម្ន ឬ នវរ (បានសាងលិង្គមួយ នៅឆ្នាំ៨៨០)
សំកមិណ (រាជ្យព្រះបាទយសោវរ្ម័ន, ហរ្សវរ្ម័ននិងឥសាណវរ្ម័នទី២)
វរិនាថ (រាជ្យជ័យវរ្ម័នទី៤, ហរ្សវរ្ម័នទី២ និងរាជេន្ទ្រវរ្ម័ន)
កូន
បញ្ចគវ្យ ឬ កវីន្ទ្របណ្ឌិត
នារាយណៈ ឬ កវីន្ទ្រវិជ័យ

២- ងារសក្តិ

ដូចខ្ញុំបានជំរាបមកហើយថា កវិន្ទ្របណ្ឌិតមិនមែនមានឈ្មោះដូច្នេះទេ តែដល់លោកមានចំណេះវិជ្ជាគ្រប់គ្រាន់ហើយ ទើបលោកបានទទួលងារនេះជាខាងក្រោយថា កវិន្ទ្របណ្ឌិត ។ កវិន្ទ្របណ្ឌិតជាសិស្សរបស់ជយេន្ទ្របណ្ឌិត តែក្រោយមកព្រះបាទសុរ្យវរ្ម័នទី ១ បានព្រះរាជទានងារសក្តិពីផលប្រិយ ទៅជាកវិន្ទ្របណ្ឌិតដូចមានគាថា ថា:

តស្យាសិច្ឆិម្យរយៀ្យ យ:
ផលប្រិយ ឥតិរិត:
គ្រីកវិន្ទ្រានាមម
បណ្ឌិតាន្តំ ឥប្បាជ្ឈយា

ប្រែថា :

"សិស្សដ៏ឆេតរបស់ (ជយេន្ទ្របណ្ឌិត)

ឈ្មោះផលប្រិយ បានទទួលងារសក្តិពីព្រះរាជាថាកវិន្ទ្របណ្ឌិត ។

លោកបានធ្វើជាព្រះរាជគ្រូនៃព្រះបាទជ័យវរ្ម័នទី ៥ (ព្រះបរមវីរលោក" ។

មិនតែប៉ុណ្ណោះ លោកជាអ្នករៀបចំពិធីសព្វសារពើ ថ្វាយព្រះ

បាទច័យវរ្ម័នទី ៤ ដែលត្រូវរៀបចំធ្វើនៅក្នុងសម័យនោះ ដូចគាថាថា : :

សបញ្ចគវ្យស្តស្យាសី   ទ្រាផ្ចិតគ្រីជយវម៌្មណះ
អភិសេកក្រិយាការី   គបឋាបាយ៉្យស្សទាប្ចិតៈ

ប្រែថា :

"លោកជាអ្នករៀបចំពិធីថ្វាយព្រះបាទច័យវរ្ម័ន ឈ្មោះបញ្ចគវ្យបាន ជាកជគ្រូ ដ៏ជាទីគោរពរបស់ព្រះអង្គរហូតមក" ។

លោកបានធ្វើជាតង្វាយហ្វាងខាងតុលាការនៅ ម.ស. ៩៤៦[1] ។ មិនតែប៉ុណ្ណោះ លោកជាសាស្ត្រាចារ្យមួយរូបដែលមានសិស្សគណចូលចិត្តរាប់អានសក្ការជាមួយលោកជាច្រើន។

## ៣– ចំណេះវិជ្ជា

កវីន្ទ្របណ្ឌិត ជាអ្នកប្រាជ្ញខាងកាព្យសំស្ក្រឹតយ៉ាងធំមួយរូប ដែលបានទុកស្នាដៃរហូតមកដល់សព្វថ្ងៃនេះ ។ លោកចេះក្បួនវេយ្យាករណ៍សំស្ក្រឹតយ៉ាងហ្មត់ចត់ ជាអ្នកចេះចាំខាងការតែងកាព្យ ចេះក្បួនខាងសាសនា ការគៈនិងរាមាយណៈ ។ ក្រៅពីអក្សរសាស្ត្រ លោកក៏ជាអ្នកនយោបាយមួយរូបសម័យនោះដែរ ។

## ៤– ស្នាដៃ

លោកកវីន្ទ្របណ្ឌិតជាអ្នកអក្សរសាស្ត្រដែលចេះវេយ្យាករណ៍យល់

1— Insciption of Kambuja. by R. Majumdar, p.315.

ព្យាស់ហើយជាសាស្ត្រាចារ្យទៀតនោះ   បានចារសិលាចារឹកត្រពាំងរុនទាំងផ្នែកសំស្ក្រឹតនិងខ្មែរ ។ សិលាចារឹកត្រពាំងរុននៅខាងនិរតីភូមិដំដែក ខេត្តកំពង់ធំ ចម្ងាយប្រហែល៤គ-ម នៅបស្ចិមភូមិរុន ចម្ងាយពីផ្លូវជាតិគីឡូម៉ែត្រ ២៨០ ផ្លូវភ្នំពេញ-សៀមរាប ប្រហែល ១ គីឡូម៉ែត្រកន្លះប៉ុណ្ណោះ ។

៥– បែបអក្សរ

សិលាចារឹកត្រពាំងរុនមានលំនាំបែបអក្សរ   ដែលប្រើសម័យនោះដូចតទៅនេះ

ក)- បែបព្យញ្ជនៈ



១)- បែបស្រៈនិស្ស័យ :





សិលាចារឹកត្រពាំងរុន ភាសាខ្មែរ ។

# អត្ថបទនៃសិលាចារឹកត្រពាំងរុន

ជាភាសាសំស្ក្រឹត បារដោយកវីន្ទ្របណ្ឌិត (១)

---

សិទ្ធិ ស្វស្តិ ជយ នមោ ភគវតេ វាសុទេវាយ

១. យេនាធិឞ្ឋិតមព្យក្ត- មលំ សកលសម្ភវេ

បុរុឞស៑ ស យទីយាង្គោ វាសុទេវនមន្តុ តម៑ ។

២- យស្យ នាភិភវាម្ភោជ- ជន្មាម្ភោជជន្មា

ខ្យាតំ បរមកិឞ្ឋិតំ ស្រឞ្ដ្រាគេបតន្ទ្បកាម៑ ។

៣- មាហាត្ម្យមន្យទ យស្យាស្ត- ន្នាភិជាម្ភុជសម្ភវះ

មេរុឞ្ឋិត បទ្មយោន្យាទិ- ទេវនាមាទិកលយះ ។

៤- បាទាទ៑ យស្យ ជគទ្វន្ទ្យាត៑[2] ប្រភវន្តី សុរាបគា

ត្រៃលោក្យបាវនី ប្រាហ មហត្វំ បរតោធិកម៑ ។

៥- វាមនស្យ ត្រិភិល៌ោកាន៑ ក្រមតោ វិក្រមក្រមៃះ

យស្យាក្រាហ្យស្វកាវត្វំ វិទ្ធិទ្នុមីយតេ ។

៦- វហុធាបិ វិវ្ឍានាំ យទីយាការកម្មណាម៑

អចិវ្ទិព្វណ្ណ នាម្នៃវ ឝ្រទ្ធេយត្វមុទាហ្ឫតម៑ ។

៧- អនុគ្យា ‘នុត្តមោ’ វ្យក្តំ យស៑ សាវិត្រ ប្រវេឞនាតិ

អន្តិន៑វេគយន៑ សារ៉ឹ មហាទេវ្យាបិ មហាត្តមះ ។

---

១- ខ្ញុំចំឡងសិលាចារឹកសំស្ក្រឹតនេះ តាមតែលំនាំដើមទេ ឯអក្ខរាវិរុទ្ធខ្ញុំទុកនៅដូចដើម ។

២.ជគទ្វន្ទ្យាត្រៀកវិន្ទ ។

៨. សាមញ្ញ សរិត្តិ ភូតេហុ　　　យស្ស សំសេវ្យសេវិនាមិ
អត្ថាទេវិ គតិស្ស　　　　ពញ្ចិតាឫនពិបក្កត ។

៩. បុរ្រោតុមនាមែរ　　　　សមស្តាស្វជគា បពទ
សរិតះ ស្តុជមាខ្យាតំ　　　បរមត្តមក្ខត្រិមមិ ។

១០. ក្រមេណ ក្រមតោ យស្ស　　ត្រិលោកិ វរិកគតះ
មុហុលិលាដំកោរស្ត-　　　មណិហោមាឞ្ជ្រីបឋិតាមិ ។

១១. យត្រោធសំប្រសត្តិក្យំ　　រុក្រោជៅ សរិភូរត្តុះ
នមស្តាក្តវាតាន្តស្តៃ　　　វិប្បវេ ប្រកវិប្បវេ ។

១២. នមធុំ គូលិនំ យស្ស　　ត្រិគូលានិ រិវេជិរេ
យុគបត្រ្តិបុរពោត្តុ-　　　ជយស្តុមា ឥវ ត្រយះ ។

១៣. ហិរណ្យរេតសា តស្ត-　　ហិរណ្យសត្ថមាច្ចិថេ
ហិរណ្យគតិយ នមោ　　　ហិរណ្យាក្សាវិដន្ទះទេ ។

១៤. អាសីតាពារិតេរវ្សំ　　　វហាន្ទេវេតាធិភូធវៃះ
ពជា គ្រីជយវម្ទិតិ　　　　មហេន្ទ្រាទ្រិក្សិតាស្យទះ ។

១៥. សោមាន្ទយប្រទីបោ យ-　　សេរ្យាមស្យជ្ជដីវនេ
សោមេត្សរេ សទា ភក្តះ　　សោមសោម្យោ វហុមត្រិយោ ។

១៦. ដរយេន្ទ្រទាសនាមាកូ-(១)　ទន្និនិតបុកេក្តវះ
ជរយេន្ទ្រវលុកាទិ្យ យេ-　　ស្តស្យ ក្ររត្យាវហត្យុទះ ។

---

១ . . . ភូទន្និត . . . > ភូរិ + អន្និត . . . ។

១៧- គោវិន្ទនាមោ វិប្បស្ស | វេទវេទង្គវេទិនះ
គោវិន្ទកត្តស្ស សុតោ | យោ គោវិន្ទនិមាក្ខតះ ។

១៨- អាគ្នោទេគេ តំ វិញ្ញាម្ហិ | វលិកប្បុរនាម្ហិ ប
កុលទេវាទនគ្យឡស៊ិ[1] | សូយញ្ញា សមតិប្ពិបតី ។

១៩. ជយេន្ទវិល្លកគ្រាគា | វាសុទេវេ ជយន្យជះ
ក្ខគោ្យកវេ្យស្តត្យនោ | វាជម្ម៊ី[2] គ្រីជយវម្មិណះ

២០- ន្ធបេន្ទវិល្លកាទ្យាំ យម៉ | គ្រីឡាំ គ្រីជយវម្មិណះ
តតះ ប្រាប បុនក្ខគោ្យ | វក្ខុវ គ្រីន្ទ្រវម្មិណះ ។

២១. តយោគ្រាគា កន៏ហ្វោយះ | ប្រទ្យម្នម្យ គ្រីន្ទ្រវម្មិណះ
ក្ខត្យម៉ គ្រីនរើពទ្យា- | មជាទ យោ កក្ខិកក្កតះ ។

២២. គ្រីន្ទ្រគុពលយេ លិង្គំ | ឋម្ពោរជាម្ពុកប្ពតិះ
សំស្ថាប្យ យោទ ទៅ តត្រ | ទាសែស៊ី សិទ្ធិបុរំ យុតម៉ ។

២៣- ភាតិនេយវវស្តបាំ យស៊ | សង្កមិណនាមក្ខក
គ្រីន្ទ្រវម្មិសុតស្យាប្តតិ | គ្រួយគោវម្មិណោ កវតិ ។

២៤- គ្រីយគេវម្មិណោ ក្ខត្យ- | ស្យ វាជោស្តទបត្យយោះ
គ្រីមាតិវម្មិគ្រីគាន- | វម្មិណាវបិ ទារកះ ។

២៥. សង្កមិណស្យ តស្យាបិ | គោតិនេយោ វក្ខុវ យះ
វេនាថាហ្វាយោ ក្ខត្យតិ | គ្រេឞ្ឋគ្រិជយវម្មិណះ ។

---

១- កុលទេវាទនក្សេត្យ-ស៊ុរ . ស៊ុរ . . ។ ២- រាជ្យគ្រីជយវម្មណះ ។

២៦- យស្តតះ ប្រាប្តសន្នានោ ភូតស្ត ត្បូត្រយោរបិ
ត្រីហបិវម្មិភូបាល- ត្រីមព្រោះដន្ទ្រូវម្មិណោះ ៗ
២៧ - តស្ស ទប្តា វិភូវាយិ- សព្វត្វតស្ស មតស្សតាមិ
បញ្ញាតវ្យាកិដាទោ យះ បញ្ញាវ្យាតវណាន្តគះ ៗ
២៨- គព្ឋជាតិមគា ស្រ្តាណិ កាវ្យំ ភាវតវិស្តរមេ
រាមាយណញ្ញា យោធីត្យ គីមព្យាទបព្យធ្យដីគបតិ ៗ
២៩ - កុលកម្មិត្រុតិទ្រៃវ្យ- រុទ្ធតោ៎បិ ស្វភាវតះ
វិទយោវិស្មយាភព្វំ យោ ទីថៃពភូតិកវតៅ ៗ
៣០ - ជាត្យន្ទះ បរេទ្រុទ្ធិ ភ្វីះ បវគ្រហេបុ យះ
កលៅ បក្រេ ភូតាបារ- មបិ កាលានុរូបវិតិ ៗ
៣១ - (វ៉ា) ទ្យាម្ភូតប្រុតា យស្ស សត្រ្យីត្យុទធិរេវ ទ
វរ្វេធ សទ្ធទគ្គាបិ ភាសេវេន្ទ្នាហិមាទ្រិតះ ៗ
៣២- ត្រីមព្រោះជន្ទ្រូវម្មិត្រ្យ- សូទ្ទិយស្សយសន្នំភះ
រាជា ត្រីជយវម្មេតិ វេព្យាមមាគ្គាភ្តពជ្យភាក ៗ
៣៣- មហាវិទីគោលក្យវ៉ាទ ទ្វមទ្ទិវិធវិទ្វធាមិ
អហីទភោគសម្ពា យោ វភៅ វិបុវិវ៉ាបរះ ៗ
៣៤- ធម្មិជ្ជាំ វលិទំ គូរំ ភូតវិទ្យ ប្រិយមូទមិ
យំ ប្រាប្យេកបតិមិ ប្ញ ដហាស ទ្រុបតាគ្គជាមិ ៗ
៣៥- ភីណ្ណាំដ្យស្យ រណេទុប ទ្វមទ្ទិវិធវិទ្វធាមិ

ស្រស្តាគ្គនាកបាមោទ-    លុវៃភ្ញិ យស្ស កីស្សមា ។

៣៦- យស្ស ធុបិតទេគ្រេវ    កិត្តិយិជ្ជហាវិកុជាមិ

ធូមៃវកិទ្រុតា ទិក្យ    វិវេគាវិបុកណ្យបិ ។

៣៧- សបញ្ចុតវ្យស្តស្សាសិ-    ព្រាជ្ជតិ គ្រឹជយវម្មណះ

អភិសេកក្រិយាការី    តថាចាយ្យិស្សព្វាច្ចិតះ ។

៣៨- សវៃប្ដុវមីមាមច្ចាមិ    វិបុកក្ដោ វិធានគះ

ពហិធរគតិទ្វារៈ    បុរេសិទ្ធិ សមតិម្ពបតិ ។

៣៩- សគេវ្រត្រ កិង្ករគ្រោមមិ    សបតុទ្រេវ្យ សំយុតមិ

កក្កព្រាក់ហេប្រាបចារចំ    ទទៅ ចានវិវៃរណេ ។

៤០- ជាតាមហាសុតស្តស្ស    បញ្ចុតវ្យស្ស យោ យតិះ

កៃវសិឲ្ចាន្តនិច្ឆាគោ    វិធីនាតិម្ពិបតិ(១)កុតី ។

៤១- បិតុកក្កតយា ទេវេ    វៃបតុកេស បិនាកិនះ

សិង្គំ វិនាយកញ្ចុំ    វីធីនាតិម្ពិបតិ កុតី ។

៤២- និសេវ្រមឧទ្រាវនិបាលមៅលិ    មាលាវជោរុក្រោតស្រុតបិថះ

វេតាធិវៃទ្រឧធិណិន្ទុធានោ    យោ កុបិតតិ គ្រឹជយវីវម្មោ ។

៤៣- ទត្តះ ស្វាគិ    គឹកកលះ កលង្កី

កាន្តិកិវេត កុត្រ    មទិយសគេ

---

១ -តាមសេចក្ដីដើមថា; នត្ថិតាបាយ្យិតាមក្ដុត ។

ឥតិ សុសគាតិគយាកិលាហាគុំ

កាន្ទ្យធិកោ យោ វិទេ វិជាត្រា ។

៤៦. និជ្ជិតពោធា មហតះ ប្រវត្តា

វិហាយ ភក្ខុនិវហានវ្យនី

គន្ធេវ វិទ្យា យមនេកមាគ្គា

ជគាម ភុម្មា គុណវត្តសិន្ធុមី ។

៤៧. នីលោត្បលក្យាមរុចាមសិនា-

មាយូណ្ណិតានាមី សមទនី ទុមទ្ធិះ

ទ្ឋេ ទ្ឋគាមី រ៉ា ហរិណេក្យណាកិ-

វិយោទ្ធិតោ យសី សមជីវ្ភូវ ។

៤៨. សូវន្នុមេជ្យ បិ គតាសេនា

សសាធនាបគ្រត្តសុហទ្ធតាបិ

ឯកេវ និគ្ខាសបរ សមុគ្ឃា

សំស្ទត្យ យំ កាមវគេវ យោមិតី ។

៤៩. គេក្រំ វិជាយោទ្ធតរហិនីនាមី

ជេតាសក្ខុទេក្រា យុធិ រជនាគានី

យគោសម្មំ លោកកុជាមី សរក្យ-

ញាហារ បក្យុទ្ធិ ឥរោសុតូះ ។

៥០. មគ្គិតិទេ បេម្យ វិនប្រមវត្រិះ

ប្រាកប្បធិតាយា មម វញ្ចិតាយោះ
កិញ្ញាវតេះនតិ រុមេវ កិត្តិះ
ប្រិយាបិ យាតា ទបទិក្យ ។

៥១- ស បញ្ចគវ្យស្តសព្វាបិ ន្ទ្របសព្វាបារយៀបុង្គវះ
វក្ខូរាតិមតោ មន្ត្រី សទន្តៈ បុរទគនះ ។

៥២- កវិន្ទ្របណ្ឌិតាខ្យាមិ៍ សគ្រីឡាមិ៍ វិក្រកន្ទូនធីះ
តោលាទិវិកវៃស្តេន សត្ប្តះ កម្មក្ប្តុតា ។

៥៣- បុរស្តាទស្យ គេស្រ្តមេតិ៍ ក្ប្តាវធិ
តស្មិន៍ មន្ត្រីវរេ ប្រាតា- ឡាម្ដោះថ ស មហីបតិះ ។

៥៤- ទត្តមេតតិ៍ ក្សីតេគន គេស្រ្តំ កិលាង្គិតំ ក្ប្តី
ស ស្វយំ ស្នាបិតេប្រាតាទិ៍ កក្ដ្រា គេតកវិទ្វិបិ ។

៥៥- សៅជនេ្យជន្ទក្បិវ្យាន៍ កុលីនំ កុលនន្ទនះ ។
នាកយណាហ្វាយស្តស្យ ស្វន្ទុស្វរិតុនណាករះ

៥៦- ប្រេម្ណា ប្រេយសិ សត្យនៅ តស្មិន៍ ស សមកល្បយតិ៍
សគេស្រ្តកិង្ករគ្រាម ន្ទេវតាច្ចិនបាលនំ ។

៥៧- វិវៃធះ បត្រៃគេលិខ្យៃ- ទ្វិជគាលាគ្គៃគត្តសះ
សាក្យកិន្ទូបរាក្យេគ្ន ម្មិតតិ៍ក្ប្តរាទ្ធធំ ។

៥៨- កវិន្ទ្រវិជយាខ្យាំ យតិ៍គ្រិមតិ៍ម គ្រីបតិប្រិយះ
រាត្ន៍ នាកយណាវិទ្វានា- ប្ដរាន៍ ពដ់សម្ពតះ ។

៥៩. គេន ទេវលុកំ រក្សយំ សតាសកេ្យត្រធារំ

បិត្រយញាបិ កុលំ សរិមិ តិ បិត្រោ ប្រកល្បិតំ ។

៦០. កត្តិវ្យ នានាវិធ យោគនាហំ

គិក្សញារត្ថិយិមតិង្គកៅយៃះ

លក្សក្ខតសិ សោៈសុ្ត សតា យុតាន្តាទ

យោ លង្ឃយេត កល្បិតមស្យ សីរំ ។

## សេចក្តីប្រែសម្រួលពីអត្ថបទសំស្ក្រឹត

របស់កវីន្ទ្របណ្ឌិត

១_សូមថ្វាយបង្គំព្រះវាសុទេវ ដែលជាម្ចាស់នៃបឋមវត្ថុបរិបូណ៌ ដើម្បីបង្កើតនូវពិភពលោក ដែលមានព្រះបុរុសៈ មួយចំណែកៈក្នុងពិភពលោកនេះ ។

២- ព្រះអង្គមានគុណសម្បត្តិជាបឋមហេតុ ហើយដែលបានប្រកាសដោយអាទិទេព និងដោយសត្វលោកទាំងអស់ និងដោយព្រះព្រហ្មដែលកើតអំពីផ្កាឈូក ដែលដុះចេញអំពីព្រះនាភីរបស់ព្រះអង្គ ។

៣- ដោយសុតវាចារបស់ព្រះអង្គ គឺព្រះមេរុដែលមានពីកំណើតព្រះព្រហ្ម ហើយនឹងអាទិទេពដទៃទៀតក៏ចេញមកអំពីផ្កាឈូកដែលចេញមកអំពីនាភីរបស់ព្រះអង្គដែរ ។

៤- កើតចេញអំពីព្រះបាទជាទីគោរពនៃសព្វសត្វទាំងឡាយ នទីទាំងឡាយដែលអាចជម្រះឲ្យបរិសុទ្ធនូវលោកទាំង ៣ បានប្រកាសនូវមហាទិក្ខភាពដ៏ឧត្តមខ្ពង់ខ្ពស់ប្រសើរជាងអ្វីទាំងអស់ ។

៥ រំលងនូវពិគគៈលោកក្នុងការនិមិត្តរូបជាមនុស្សគៀ ដោយវិរិយៈ ជំហាន ៣ ធ្វើឲ្យអ្នកប្រាជ្ញមុនីប្រមើលឃើញវិសាលភាពនៃធម្មជាតិរបស់ព្រះអង្គ ។

៦– សូម្បីច្បាំងនឹងមនុស្ស ១.០០០ នាក់ ជនណាដែលមានកិរិយាត្រឹមត្រូវ បានប្រកាសនូវសេចក្ដីស្មោះស្ម័គ្ររបស់ខ្លួន ដោយនាមតែមួយគឺវិស្ណុ ដែលពេញដោយអត្ថន័យ ។

៧– បាក់ធ្នុះទៅក្នុងសម្ភារៈវត្ថុគ្រប់យ៉ាង ព្រះអង្គជាអតិបរមាណូតូចបំផុត ជ្រាបចូលទៅក្នុងចក្រវាឡរបស់ព្រះអង្គទាំងអស់ ព្រះអង្គជាបុគ្គលធំបំផុតជាងវត្ថុដែលធំបំផុតទាំងអស់ទៀត ។

៨– សមត្ថភាពរបស់ព្រះអង្គចំពោះសព្វសត្វទាំងអស់ ដែលមានអនុភាពស្មើនឹងព្រះអគ្និ ហើយនឹងស្មើនឹងអាទិទេពដទៃទៀត គឺព្រះអង្គសម្រាប់ជាអ្នកគោរពបូជាចំពោះអ្នកដែលគោរពបូជាទាំងឡាយ ។ ហើយព្រះអង្គជាមូលហេតុ នៃសោមនស្សនិងទោមនស្ស នៃតណ្ហារបស់សត្វលោក ។

៩– ព្រះនាមរបស់ព្រះអង្គ គឺបុរុសុត្តមៈតែមួយប៉ុណ្ណោះ ដែលអាចកំចាត់ចេញនូវសត្រូវដទៃ ។ ហើយប្រកាស នូវឧត្តមភាពគ្រប់ទីកន្លែងទាំងអស់ ។

១០– ក្នុងពេលដែលពិគគៈលោកកើតឡើងបន្តិចម្ដង ។ ព្រះអាទិត្យបានទៅជាគ្រឿងអលង្ការខាងមុខព្រះអង្គបន្ថែមទៀត ហើយបានទៅជា

វដីកលង្ការសំកប់ព្រះឧក ហើយទឹងអាសន ជាវិការនៃមាសរបស់ព្រះអង្គ ។

១១- សូមគោរពព្រះវិស្ណុដ៏រុងរឿង ដែលមានក្រោធនិងសន្តិឲ្យជាកំណើតនៃរុទ្រ:និងអជព្រហ្ម ។

១២- សូមបន្ទន់កាយចំពោះព្រះសិវ: ដែលមានត្រីសូលជាពុំនឹងនៃជយជំនះដ៏មហាស្ចារ្យលើត្រីបុរ :

១៣- សូមគោរពព្រះព្រហ្ម ដែលមានរស្មីដូចជាមាសដែលគេដុតដោយភ្លើងដល់ហិរណ្យគភ៌:ជាបុត្រនៃបច្ចាមិត្តរបស់ហិរណ្យក្ស ។

១៤- កាលណោះ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមស្រីជយវរ្ម័ន[១] ទ្រង់សោយរាជ្យរហូតដល់ទៅសមុទ្រ នៅស័ក ៧២៤ (គ.ស. ៨០២) ហើយមានព្រះរាជដំណាក់នៅលើភ្នំមហេន្ទ្រ[២] ។

១៥- ព្រះអង្គជាពន្លឺនៃព្រះវង្សរបស់សោមា ជាព្រះចន្ទធ្វើឲ្យសម្បុរសជនមានអាយុជីវិតឡើងជាថ្មី គោរពព្រះឥស្សូរនិងឧមា ព្រះអង្គមានព្រះទ័យទន់ភ្លន់ដូចព្រះចន្ទ ហើយមានព្រះកាយប្រកបដោយលំអ ។

១៦- កាលណោះ មានបុរសម្នាក់ឈ្មោះជយេន្ទ្រកាស: បានទទួលនាមថាជយេន្ទ្រវល្លភ: មានដើមកំណើតនៅអនិន្ទិតបុរ: ជារាជបំរើរបស់ព្រះរាជា ។

១៧- រាជបំរើនេះ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ឈ្មោះគោវិន្ទ ដែលជាអ្នកប្រចាំហ្មត់ចត់វេទៈនិងវេទង្គៈ គាត់ជាអ្នកគោរពគោវិន្ទ(វិស្ណុ) ហើយ

---

១- ជ័យវរ្ម័ន ។ ២ ភ្នំគូលេន ។

បានធ្វើរូបសំណាកគោរិន្ទផង ។

១៨. នៅក្នុងស្រុកកំណើតរបស់គាត់ឈ្មោះតំរ៉ង និងវលិការបុរៈគាត់គោរពទេវតាដែលនៅក្យាគ្រួហរបស់គាត់ ហើយគាត់សាងរូបទេវតាថ្មីៗទៀតជាច្រើននៅក្នុងភូមិទាំងនោះ ។

១៩. ប្អូនរបស់ជយេន្ទ្រលោកៈ ឈ្មោះវាសុទេវជាព្រះរាជបំរើ នៃព្រះបាទជយវរ្ម័ន(១)ជាព្រះរាជបុត្រនៃព្រះឧទជយវរ្ម័នទី ១ ។

២០. គាត់បានទទួលនាមដ៏គាប់ប្រសើរ មួយទៀតថានូបេន្ទ្រលោកៈ អំពីជយវរ្ម័នហើយបន្ទាប់មកបានធ្វើជារាជបំរើ នៃព្រះបាទឥន្ទ្រវរ្ម័នទី(២) ។

២១. ប្អូនបន្ទាប់នៃបងទាំងពីរនាក់ខាងដើមឈ្មោះប្រទ្យុម្ន ជាព្រះរាជបំរើនៃព្រះបាទឥន្ទ្រវរ្ម័ន ហើយដោយភក្តីភាពចំពោះព្រះអង្គ គាត់បានទទួលគោរមងារជាគ្រឹនវរៈ ។

២២. គាត់បានកសាងសម្ភុលិង្គនៅសករាជ ៨០២ ហើយតម្កល់ទុកនៅក្នុងប្រាសាទគ្រឹតន្ទ្រគុរៈ(៣) ហើយគាត់បានថ្វាយសទ្ធបុរៈនិងខ្ញុំកំដរជាច្រើនទៀតផង ។

២៣. កូនប្រុសរបស់បងស្រីគាត់ ឈ្មោះសំកសិណៈបានទទួលនូវសេចក្តីគ្រោសប្រោសប្រាណឲ្យនៅក្នុងសំណាក់ព្រះបាទយសោវរ្ម័ន ជាព្រះរាជបុត្រនៃព្រះបាទឥន្ទ្រវរ្ម័ន ។

---

១ ជយវរ្ម័នទី ៣ វិស្ណុលោក (គ.ស.៨៥៤-៨៧៧) ។ ២- ឥន្ទ្រវរ្ម័នទី ១ (ឥស្វរលោក គ.ស. ៨៧៧-៨៨៩) ។ ៣ ប្រាសាទនេះសព្វថ្ងៃហៅថាប្រាសាទបាគងនៅរលួស ។

២៤- រាជបំរើ (សំគសិណា) របស់ព្រះបាទយសោវរ្ម័ន បានធ្វើជារាជបំរើនៃព្រះរាជបុត្រទាំងពីររបស់ព្រះអង្គ គឺហសិវរ្ម័ននិងឥសានវរ្ម័ន (១) ។

២៥- គួនរបស់បងស្រីសំគសិណៈឈ្មោះវិនាថា ជាព្រះរាជបំរើដ៏ជិតរបស់ព្រះបាទជយវរ្ម័ន(២) ។

២៦- ដោយបានទទួលកិត្តិយសអំពីព្រះអង្គលោក(វិនាថ)ក៏បានធ្វើជារាជបំរើព្រះរាជបុត្រទាំងពីរព្រះអង្គ នៃព្រះបាទយសោវរ្ម័នគឺព្រះបាទហសិវរ្ម័ននិងរាជេន្ទ្រវរ្ម័ន (៣) ។

២៧- ចៅរបស់លោកដែលជាសិស្សដ៏ឧត្តមនៃក្រិស្ណុះ (សាត្វត:) ហើយជាមនុស្សមានធម៌សប្បុរសបានទទួលនាមថា: បញ្ញាគវ្យ: ជាអ្នកចេះចាំស្ទាត់នូវវេយ្យាករណៈ ។

២៨- ដោយលោកបានចេះវេយ្យាករណសាស្ត្រ នយោបាយសាស្ត្រសាសនសាស្ត្រ កាវ្យសាស្ត្រ ក្បួនភាគរ:និងរាមាយណៈ យ៉ាងស្ទាត់ លោកក៏បានធ្វើជាសាស្ត្រាចារ្យថែមទៀតផង ។

២៩- ទោះជាមានវណ្ណៈដ៏ឧត្តមក្តី ទោះជាបានបំពេញកិច្ចដ៏ថ្លៃថ្នូរក្តី, ទោះជាមានចំណេះវិជ្ជា និងសម្បត្តិដ៏បរិបូណ៌ក្តី លោកក៏នៅតែកាន់កិរិយាសុភាពរាបសាស្រគត់ស្រគំជាដរាប ។

៣០- កំហុសរបស់អ្នកដទៃ លោកមិនអើពើជាច់អហង្ការ លោក

---

១- ហសិវរ្ម័នទី ១ (រុទ្រលោក) ។ ២- ជយវរ្ម័នទី ៤ បរមសិវលោក ៩២៨-៩៤២ ។
៣- ហសិវរ្ម័នទី ២ (៩៤២-៩៤៤) និងរាជេន្ទ្រវរ្ម័ន (៩៤៤-៩៦៨) ។

វៀរចាកគិលេសតណ្ហាជាដាច់ខាតទាំងអស់ សូម្បីតែនៅក្នុងពាលវ័យក៏លោកប្រតិបត្តិនូវក្បួនសាស្ត្រដែរ ។

៣១- លោកមានគុណវិស័យដូចសាគរ ប្រកបដោយភក្តីដ៏ទិនិន សំដែងអាការៈដ៏ថ្លៃថ្នូរមានតម្លៃដូចទឹកអម្រឹត ប្រៀបដូចជាដុំសិលាមួយមិនអាចនឹងរិចរិលដោយសារដំណក់ទឹកដ៏ត្រជាក់ ដែលធ្លាក់មកពីលើមហាមេឃ ។

៣២. ព្រះរាជបុត្រច្បងនៃព្រះបាទរាជេន្ទ្រវរ្ម័ន មានបារមីដូចជាព្រះអាទិត្យទ្រង់ព្រះនាមថាព្រះបាទជ័យវរ្ម័ន (១) បានឡើងគ្រងរាជ្យនៅសក: ៨៩០ ។

៣៣ - ព្រះអង្គមានចរិយាសមសួនឥតខ្ចោះ ប្រកបដោយព្រះរាជសម្បត្តិបរិបូណ៌ មានព្រះទ័យស្អប់បច្ចាមិត្រនៃព្រះអាទិទេព ទ្រង់ស្ថិតនៅក្នុងព្រះបរមសុខប្រកបដោយគតិបណ្ឌិតដ៏ថ្លៃថ្នូរ ដូច្នេះហើយបានជាព្រះអង្គមានស្នេហ៍ដូចជាព្រះវិស្ណុមួយព្រះអង្គទៀត ។

៣៤. ព្រះធរណីចំអកមើលងាយក្សត្រីនៃទ្រូបទ: កាលដែលស្រីនេះរៀបអភិសេកជាមួយព្រះអង្គឯក អ្នកប្រាជ្ញខាងធម្ម មានមហិទ្ធិឫទ្ធិក្លាហានមានវិជ្ជាច្រើនមានព្រះមធុរវាចា ។

៣៥- សរព្រួញរបស់បច្ចាមិត្រ ដែលបាញ់មកនៅក្នុងពេលចម្បាំងទៅលើស្តេចអង្គនោះ ដែលមានព្រះអង្គរាងធំទូលាយ ធ្វើឲ្យព្រះអង្គព្រឺ

---

១- ព្រះបាទជយវរ្ម័នទី ៥ (បរមវីរលោក ៩៦៨-១០០១) ។

ស៊ើបត្រឹមស៊ើនឹងទ្រទិចឃ្មុំ ដែលស្រែកឃ្លានកូនគេសា នៃស្ត្រីទន់ខ្សោយៗ

៣៦- កិត្តិគុណរបស់ព្រះអង្គ ផ្សាយទៅក្នុងចតុទិសរហូតទៅដល់ធានីនៃបច្ចាមិត្ររបស់ព្រះអង្គ វិស័យដូចផ្សែងនៃគ្រឿងសក្ការៈបូជា ដែលធ្វើឲ្យក្អកឈ្ងក់នឹងផ្សែង ។

៣៧- លោកដែលរៀបចំពិធីថ្វាយព្រះបាទជយវរ្ម័ន ឈ្មោះបញ្ចគវ្យ បានធ្វើជាកដគ្រូជាទីគោរពរបស់ព្រះអង្គរហូតមក ។

៣៨- លោកជាអ្នកគោរពព្រះវិស្ណុ បានឲ្យសាងរូបព្រះវិស្ណុមួយទុកជាទីសក្ការៈបូជានៅក្នុងទីក្រុងនោះ ។

៣៩- លោកបានធ្វើអំណោយ ដោយសេចក្តីមេត្តាចំពោះបច្ចាមិត្រនៃពានរ: ដែលបានបំពេញកិច្ចការក្រៅជូនលោកនូវភូមិមួយ ព្រមទាំងចំការច្បារដំណាំមានទាំងមនុស្សបំរើ គោក្របី និងប្រាក់កាសផង ។

៤០- អ្នកចាត់ចែងពិធីនោះជាបុត្រដ៏ល្បីល្បាញរបស់បញ្ចគវ្យ ជាអាចារ្យដែលចេះចាំគ្រប់គ្រងនូវលទ្ធិព្រះឥស្វរ ហើយបានកសាងបដិមា-ករព្រះឥស្វរមួយតាមទំនៀម ។

៤១- ដោយសេចក្តីស្នេហាចំពោះបិតាព្រះអង្គ ទ្រង់បញ្ចាក្នុងព្រះយោបល់ដ៏ឈ្លាសវៃនិងគម្រូវតាមទំនៀមទាន ឲ្យសាងសិវលិង្គ និងរូបគណេសក្នុងស្រុកបិតាព្រះអង្គ ។

៤២ • ព្រះបាទជយវរ្ម័ន បានជាម្ចាស់ផែនដីនៅសកាជ ៩២៤ ។ ព្រះអង្គមានកំណាត់ព្រះបាទាជាវិការនៃមាស ស្ថិតនៅលើសុវណ្ណមាលា ដែលធ្លាក់ពីសិរសា នៃស្តេចទាំងឡាយ ដែលយាងមកក្រាបថ្វាយបង្គំព្រះអង្គ ។

៤៣ ដោយសេចក្តីស្នេហាបាននាំមកឲ្យមានការពាក់ខាន ព្រះចន្ទមានការអាប់អួរ តើធ្វើដូចម្តេចនឹងរកសិរីសួស្តីក្នុងការស្ថាបនា? ហេតុដូច្នោះ ដោយព្រះអាទិទេពដែលមានព្រះទ័យចង់បង្កើតឋានៈសត្វដែលលោកបង្កើតឡើងឲ្យមានឋានៈខ្ពស់ ទើបព្រះអង្គបង្កើតនូវកល្យាណធម៌ទៀត ។

៤៤. វិទ្យាសាស្ត្រមានមាគ៌ាច្រើន តម្រង់ឆ្ពោះទៅរកមហាសាគរនៃ ( កល្យាណធម៌ ) ពីព្រោះវិទ្យាសាស្ត្រនោះបរិសុទ្ធដោយអំណាចព្រះអាទិទេព ដោយមិនបានយកចិត្តទុកដាក់ដល់ក្លុំទាំងឡាយលើផែនដី ត្លួយ៉ាងដូចទឹកទន្លេគង្គា ។

៤៥. ទោះជាឃើញមុខងាររបស់សត្រូវ ឆាត្រីដោយសេចក្តីប្រណែនប្តូនគ្រារបស់ស្ត្រីសំឡក់មកចំពោះព្រះអង្គ ព្រះអង្គនៅតែមានសេចក្តីអន់អាចជាដំកប នៅតែរក្សាទឹកព្រះទ័យឲ្យស្ងប់ស្ងៀម មិនឲ្យរន្ធត់ញាប់ញ័រដូចជាផ្កាឈូកដែលរក្សានូវពណ៌ទៀត ។

៤៦. កិរិយារបស់បច្ចាមិត្តនៃព្រះអង្គ សូម្បីតែនៅជួបជុំក្នុងគ្រួសារ ប្រកបដោយកាយពលបរិបូណ៌ មានមិត្តភក្តិនៅជុំវិញក្តី កាលបើទ័ពបច្ចាមិត្តទៅបាត់ ហើយក៏នៅតែនឹកមមៃចំពោះព្រះអង្គ ហាក់ដូចជានៅស្ងាត់ម្នាក់ឯង ត្រមង់ត្រមោចអាណោចអធមព្រោះលង់ទៅក្នុងសេចក្តីស្នេហា ។

៤៧. ព្រះអង្គមានជ័យជំនះលើស្តេចទាំងអស់ ក្នុងពេលសង្គ្រាមជាច្រើនលើក ដោយហេតុព្រះអង្គមានឫទ្ធានុភាពធ្វើក្នុងទ័ពមានអំណាចឲ្យមានកន្ទល់ ហើយព្រះអង្គដណ្តើមបាននូវកិត្តិយសដ៏អស្ចារ្យក្នុងចំបាំង ប្រៀបដូចបក្សីក្រុឌដែលមានថាមពលខ្លាំងក្លា ។

៤៨. បើនរណាអួតសរសើរពីព្រះអង្គ ព្រះអង្គទម្លាក់ព្រះភក្ត្រចុះដោយអឹមអៀន ។ បើខ្ញុំត្រូវស្នេហាបោកបញ្ឆោតហើយ តើមានប្រយោជន៍ធ្វើនឹងនៅរស់ ។ ថ្វីបើកិត្តិគុណជាការចាំបាច់របស់ខ្ញុំតែកិត្តិគុណនេះហាក់ដូចជាមានកំហឹងហើយ ចេញតាមទៅក្នុងទសទិស ។

៤៩. បញ្ញវ័ន្តជាអាចារ្យធំរបស់ព្រះរាជាអង្គនេះ ជាទីប្រឹក្សា ដ៏ជាទីគោរពមានសិទ្ធិចូលក្រាបបង្គំគាល់ព្រះអង្គក្នុងព្រះរាជដំណាក់ផ្ទាល់បាន ។

៥០. ដោយលោកមានប្រាជ្ញាដ៏វាងវៃ លោកបញ្ញវ័ន្តក៏បានទទួលនាមជាកវីន្ទ្របណ្ឌិត ហើយព្រះរាជានៃប្រទេសកម្ពុជា បានព្រះរាជទានអគ្រឹងស្នែងព្រមទាំងលក្ខណសញ្ញាដទៃទៀតជាច្រើន ។

៥១. ព្រះរាជាបានមានព្រះបន្ទូល ឲ្យបោះគោលចំណុចមួយជុំក្នុងព្រះរាជអាណាចក្រ ហើយព្រះរាជទានទីនោះឲ្យលោក (កវីន្ទ្របណ្ឌិត) ជា

ទីប្រឹក្សារបស់ព្រះអង្គដើម្បីសង់ទីលំនៅ ។

៩២- ដីវែល (កវិន្ទ្របណ្ឌិត) បានទទួលពីព្រះរាជានោះ លោកក៏បានរៀបថ្វាយចំពោះវិស្ណុ ហើយលោកបានកសាងរូប (ព្រះវិស្ណុ) ដោយខ្លួនលោក ដោយសេចក្ដីអនុគ្រោះ ។

៩៣- កូនរបស់លោកឈ្មោះ នារាយណៈនេះ ជាបុត្រមានត្រកូលខ្ពង់ខ្ពស់ ជាអ្នកប្រាជ្ញ ជាអភិជន ជាទីសួស្ដីក្នុងគ្រួសាររបស់លោកបានន័យថាជាវីរជនមានលក្ខណៈដូចជា (បិតា) ។

៩៤- ដោយសិនេហភាពចំពោះកូន បិតាបានឲ្យកូនព្រមទាំងស្រែចំការខ្ញុំកំដរ ហើយប្រគល់ភារៈឲ្យកូនជាអ្នករក្សាអាទិទេព (ព្រះវិស្ណុ) ។

៩៥- លោកបានបញ្ជាក់នូវអំណោយនោះ ជាលាយលក្ខណ៍អក្សរសរសេរនៅលើស្លឹករឹត ហើយនៅលើផ្ទាំងសិលានៅក្នុងសាលាព្រាហ្មណ៍ ដោយមានកសិណាផងនឹងតាមព្រះរាជបញ្ញាផង ។

៩៦- នារាយណៈនោះជាកូនគោរពព្រះវិស្ណុមានកេហារ ដ៏ពិរោះ ព្រះរាជាបានលើកតម្កើងឋានៈជាកវិន្ទ្រវិជ័យ ។

៩៧- ដោយកវិន្ទ្រវិជ័យនេះហើយបានជាប្រាសាទតម្កល់រូបព្រះវិស្ណុមានអ្នកថែរក្សា ព្រមទាំងខ្ញុំកំដរស្រែចំការសត្វពាហនៈ ព្រមទាំងគ្រួសារទាំងបិតាទាំងអស់នោះហើយព្រមទាំងបណ្ដាំនៃបិតា ៖

៩៨- បើនរណាមិនគោរពតាមសេចក្ដីបង្គាប់របស់ (កវិន្ទ្របណ្ឌិត) ទេ អ្នកនោះនឹងត្រូវទណ្ឌកម្មរបស់ពលយមរាជរហូតអស់មួយយុគៈ ។

# អត្ថបទនៃសិលាចារឹកត្រពាំងរុន

## ជាភាសាខ្មែរ

កវីន្ទ្របណ្ឌិតនិពន្ធ

(១)[១] ៩២៩ សកបិកេតជ្យេស្ឋ គុក្រវារអារទេនក្សត្រធូ-
លិព្រះកម្រតេងអញ គ្រិជយវីរម្មទេវ (២) ស្វេយព្រះរាជ្យនុគ ក
៩២៤·០ [២] ស្តាប(ឆា) ព្រះគិលាតតាក [៣] ព្រះគិយគោ ធរ
បុរីបិ (៣) ម្រតាញខ្លោង គ្រិកវីន្ទ្របណ្ឌិត ស្រុកវ្នង្វក្រ៉ិ . . . បុរ
និវេទកគ្លោកបិ ស្វំ ភូមិព្រះករុណាប្រសាទលេង(៤) ជាព្រះទាន
បិជ្វត្តព្រះកម្រតេងអ័ញតាវាយនម៉ន ម្រតាញខ្លោញស្តាបឆាត
ស្រុក វ្រៃករងតតិអជិ (៥) ម្រតាញខ្លោញ តោយមាតួបក្ស
ទារព្រះករុណាប្រសាទតគិព្រះរាជ្យព្រះបាទបរមគួរ[៤] ០ព្រះករុណា
កម្រតាញ (៦) តនត្បូងវរភូមិបិខ្ញុំម្រតាញខ្លោញបង្គំប្លុងនិវេទ
នម៉នមាន ភូមិអនិន្ទ្របបុតនិម្ហិល(៧) បិអាយត្តតាកជ្វាល
គុសតោយប្វុំ ស្រុកវ្រៃករងបិសមិបនុព្រះម្រតាញខ្លោញនោះ
គិបិម្រតាញ (៨) ខ្លោញស្វំលេងព្រះទាន បិជ្វត្តព្រះ អាយ

---

១- លេខរៀងបន្ទាត់សិលាចារឹកនៅផ្ទាំងថ្ម ។ ២- ០ ជាល្បះដែលគេប្រើនៅសម័យនោះ។
៣- ប្រហែលជា „ព្រះ. លាតជាក” ប្រែថាល្អាងភ្នំ ទេដឹង ។ ៤- ស្លាយណាស់ដោយទុក្ខ
មិនសម្បូណ៌ អក្សរ ក្រ ខេះ ។

ព្រែករងប់ន្យនៃព្រះករុណាកម្រតាញខ្ញោញ ឱយប្រសាទ (៩)
ភូមិនោះជាព្រះទាន ០ អ្នកសញ្ជក្ដសេរិតនោះនាព្រះទ័យប្រសាទ
ភូមិកម្រតាញខ្ញោញ (១០) ម្រតាញខ្ញោញគ្រឹប្រើ បិរិន្ទ្រវម៌្ម ០
ម្រតាញតោញខ្ញោញគ្រឹភគិ គួរវម៌្មស្តេង អ័ញតរញ៉ាវ្យងម្រតាញ
ខ្ញោញបិ(១១) គ្រឹកវិន្ទ្រជយស្បង្គគុណទោមទវស្បិស្តេង ទន្លេ
ជ្រៃអាចាយ៌្យប្រធាន សភាសត ០ ម្រតាញខ្ញោញ(១២) គ្រឹរា
សអ្កល្ប ស្ចតព្រះធម្មសាស្ត្រ ០ ម្រតាញខ្ញោញ គ្រឹក្បិតិន្ទ្រវម្ម
ខ្ញោញក្លុងឯក ០ ម្រតាញខ្ញោញគ្រឹន្ទបតិន្ទ្រ(១៣) វម៌្មខ្ញោញក្លាង
ទោម្រតាញខ្ញោញគ្រឹក្បិតិន្ទ្រវម៌្មខ្ញោញក្លាងត្រៃលោំម្រតាញខ្ញោញ
គ្រឹ នរេន្ទ្រ បណ្ឌិតបាមព្រះបញ្ជួយ (១៤) ព្រះ បន្ទូលស្តេង
អ័ញ ទន្លេជ្រៃប្រេទៅឱយភូមិនោះ កម្រតាញខ្ញោញ ជាព្រះ
ទានព្រះបន្ទូលប្រេស្តេង (១៥) អ័ញទន្លេជ្រៃគុណទោ រែទ
ក្ដៅដោង ស្បង្គបុញកបាតកម្រងតេងអ័ញព្រះគុរុម៉ន ឱយករុណា
ប្រសាទ(១៦) ភូមិកម្រ តាញខ្ញោញ គ្រឹកវិន្ទ្របណ្ឌិត ព្រ
សបក្ខព្រះសភាដោង អយព្រះសភាស្តេងអ័ញទន្លេជ្រៃ (១៧)
គុគុណទោ [illegible] រថានោះជាព្រះគាសបតាកប្រ

តេងអញព្រះគុរុកម្រតេងអញព្រះគុរុបន្ទូល (១៨) ព្រះគាសនត
លោញ គ្រឹធរភាគវតបម្រេព្រះក្រលាសោងតខ្លោញ សំតា
បនុភាបយោគ្យឹងវ្យវហារាធិ (កាធិ) (១៩) ការិ នុភាបរាប៖គ
ធិតតរង្វាងឯកប្រេទៅនុស្តេងអញ៖ន្លេជ្រៃ ប្រេច្វៃយោព្រះគា
សនស្តេងអញ៖ន្លេជ្រៃ (២០) នុព្រះសភា រង្វាងទៅល្វោះតគិ
ស្រុកវ្រៃករងស្តេងអញ៖ន្លេជ្រៃប្រេ រង្វាងទៅបោគ្រាមវ្ន៖
បុរុស (២១) ប្រធានតសមីបនុស្រុកវ្រៃករងបុំប្វាន តោយ
បន្ទូលព្រះគាសនប្រេស្យង តយុគបតនាគង្វោលតភូមិ (២២)
នោះបិឱយកម្រតាញខ្លោញគ្រឹករិន្ទ្របណ្ឌិតតគិ ៖គមីរោបជ្យេ
ម្ននោសោរវារវេរតីនក្សត្រស្តេង៖ន្លេជ្រៃ (២៣) នុព្រះសភា
បង្គោល តភូមិ្យនោះឱ្យជាព្រះទានកម្រតាញខ្លោញរោះបាព្រះ
គាសន (២៤) ម្រតាញខ្លោញជូន្តព្រះកម្រតេងអញនវាយន
អាយវ្រៃករង គ្រាមវ្ន៖តជាសាក្សីនាំសង្គោលខ្លោញ (២៥)
វលប្វាញត្រេះរេលា ០ វាប៖គគ្រាមស្រុកអង្វាជិត ០ វាបបាំ
ស្រុកត្រវាំងគ្រុ ០ វាបគម ប្រធាន (២៦) ស្រុកកំលុងលំវាង
០ វាបត្បូរ ៖គគ្រាអត្រាកកំពង់ពាំងតវុត ០ ម្រតាញព្រះទ្រក

លេ  យោនរាយនខ្ញុំវ្រះ (២៧) ថ្កូលបាសស្រុកវ្រៃករងសិប្បូទ្ធ យវិន្ទុខ្ញុំកំស្តេង  បរាជិតស្រុក្កន្តាលវិលរាបព្រៅគ្រាប្បូរទ្ធ  ស្តេញ (២៨) ប្រត្យុយស្រុកសម្វ៉ិប  រាបទគគ្រាមស្រុកទាន្យកតិក រាបគិរវ្រាហ្មណ រាបប្រ  រាបទាន បរាឯមរាប  (២៩) វិទ្យាមយ ខ្លោញផ្សាលអ្និន(១) រាបបិត មេអ្យក  មេនំមេទេស  មេសាន មេទូត នេះស្យេង ស្រុកអមរាលយ (៣០)  ម៉នស្តេងអ័ញទន្លេ ជ្រៃវិងអំវិសង្គោល ត ភូមិបិ ឱយកម្រតាញខ្លោញ ០ វ្រះស្តាប អាយវ្រះបត្ទ៉ារ (៣១)  នាមេលវ្រះវ្នូតគិប្រេប្ថៃន័ម្នាំណ ០ ម្រតាញខ្លោញ  គ្រឹកវិន្ទ្របណ្ឌិត  ស្វតក្លោកនាវ្រះវីប្ណុ ធម្មិបង្គម ប្យេង (៣២)  និវេទនពោះហាធិលផ្លេយឱយទានភូមិស្តេងអញ ទន្លេជ្រៃបង្គុំ  ប្យេងនិវេទនម័នមានភូមិតគិខ្លោញផ្សាល  (៣៣) អនិនលកផ្តាត  អ្នកតប្វុលកំលុងប (ង្វា) ត គោលនោះបិអ្នក រោលរាទវ្រះគាសនិប្រេទៅស្វេងបិត្យង  (៣៤) នាមានភូមិតនិ អូលិ  ប្រេឱយស្មោង ។ ស្តេងអ័ញទន្លេជ្រៃនុម្រតាញខ្លោញគ្រី ប្រឹបិវិន្ទ្រវម្មិនគុណទោគទស្សិ (៣៥ ) ផោង្វបុញ្យកបាពោះហាវ្រះ

---

(១) ជាពាក្យសង្ខេបពីពាក្យថា អនិន្ទិតបុរ

ឝាសនតកម្រតាញអញគ្រីគុរុ ០ កម្រតេងអញព្រះគុរុបន្ទូលព្រះ (៣៦) ឝាសនគលោញព្រហ្មភាគវិតបម្រេតខ្មោញសំតាបនុម្រ តាញគ្រីគ្រុតភក្តិតជិតខ្លោញសំតាបនុ (៣៧) រង្វាងឯក ប្រេ ទៅថ្ងៃពោះបាព្រះឝាសនព្រះសភាតពោះបានេះទៅ ល្វោះតស្រុក ព្រៃកង្វ ប្រេវង្វាង (៣៨) ហៅគ្រាមវ្នុំបុញ្ញត្តោយស្រុក បន្ទូលព្រះឝាសនឱយគបឋិតឥត្យងទបាមានភូមិ វណ្ណាំគ្រមតិ (៣៩)មូល ០ គ្រាមវ្នុំស្បង្គគបឋកបាវភូមិ អធិនតតិមូល តោយក្រៅគោល ០ ព្រះសភាវិសអំរុងភូមិតមាន (៤០)អបវិទ កំលុង គោលទេបវិសអំរុងភូមិតនុជាស្មោងម្វាយអំរុងសង្គោល សមក្សនុគ្រាមវ្នុំបរុរុម (៤១)ប្រធានដោងបន្ទូលព្រះឝាសនតរិ បគិមត្វយ៉ស្រុក្កំលុងលំវិងនុភិក្សព្រះស្រមោតមានភូមិ (៤២) ប្វលកំលុងគោល...ភូមិនោះស្មោងម័នព្រះស្តាបនាព្រះគិលាត តាកនាព្រទិកតព្រះទានបិឱយត (៤៣) ព្រះបំ (... ម្រតា) ញ ខ្លោញគ្រីករិត្រ្នបណ្ឌិតបង្គំប្ឬង្ហៃវេទនម័នភូមិស្រាបតំព្រះសភាទៅ (៤៤) ឱយស្មោង ... ដោង ០ ព្រះឝាសនប្រេសិទ្ធភូមិនោះ ម័នឱយទានកម្រតាញខ្លោញតរាបផ្នែកហៅ *(៤៥)* នោះមាន...

(ម្រតាញខ្លោញ) បង្គំប្ញ្សងនិវេទសោតលេងអាប្តិទុក្តព្រះរក្តអា
យព្រះសភាលេង (៤៦) អាប្តិបារតិគិលា... ព្រះព្រៃហ្ម្គាលា
លេងអាប្តិទុក្តផ្តោត នាបំរេព្រះក្រលាស្រោងលេងអាប្តិទុក្ត (៤៧)
ប្រគស្តត... (ស្រុ)ក ព្រៃករងលេង វ្ញុំអាប្តិ កុលសត្ថានម្រ
តាញខ្លោញយោកភូមិនេះបិលក (៤៨) ផ្តុតអ្នក.. .អវធិត
អំបាលនេះរោះបាតប្តុម្រតាញខ្លោញ ០ ភូមិព្រះទាឥតទិង (៤៩)
ផ្សាយ... បិតទិងប្វាបប្ញុ វ្ញុំគតប្ញ្សៃធេបិ ១៩ បន្តោយប្វាយ
ស្លឹកគត..(ប្វា)ន (៥០)ភូមិ... .ល្មោះគោលឱត្តរឱត្តរតេរិ
នៅរិស្លិក ១គតវ្ញ្ស ៥០(៥១)ក្វនម្រ (តាញខ្លោញគ្រីកវិន្ទ្រ)
បណ្ឌិតតផ្ទុះលោញនារាយណទារផ្ទុះម្រតាញគ្រីកវិន្ទ្រ (វិជយ
...) កន្សង្ស្យ(៥២)បរម្រព្រះក្រលាស្រោងជារាជបុរោហិតឱត្តរ
ម្រតាញខ្លោញតរបាម្រតាញបង្គំប្ញ្សង (៥៣)និវេទនកុលេម្រ
តាញគ្រីកវីន្ទ្រវិជយម្វាយមូលនុលេម្រតាញខ្លោញ នាភាគវតបំ
ប្រេទបា (៥៤)កុលេម្រតាញខ្លោញ មលតកលេម្រតាញគ្រីក
វិន្ទ្រវិជយអាបទហាកុលេម្រតាញគ្រីកវិន្ទ្រវិជយ (៥៥) មូលតកុ
លេម្រតាញខ្លោញអាចារ្យ...ភាគតា ព្រះកម្រតេងអញតារាយ

ណានភ្នំប្រាក[1]ខ្ញុំ (៥៦)ផ្ទើយនោះអាយត្តតកុលម្រតាញ គ្រឹក
វិគ្រូវិជយនាភាគព្រះកម្រតេងអញគីរលិង្គនុ(៥៧) ខ្ញុំភ្នំប្រាផ្ទើយ
អាយត្តតកូនម្រតាញខ្លោញ តោយភាគកុលេស្តេងនត្និកាបាយៀ
(៥៨ )អាយៀហោមបិបាំតសំមូលនុម្រតាញខ្លោញផ្ទើនាភាគវិត
បំរេនេះ កល្បនាតរោះនេះ(៥៩) នៅរកុលេម្រតាញខ្លោញ
កុលអ្នកនេះតរ្យូវ លោះតមានភក្តិបរិបាលនលេងរោះហានេះ វ្ជំ
(៦០)អាប្តបនហ្យុតទមាន្តបនហ្យុតកល្បនានេះបញ្ញុ (?) តវ្រុ
ហារ កម្រតេងផ្នែករោំ ឆណ្ដោយត (៦១,តបរលោកព្រះយមយា
នាតនរកតទំទេប្រអរបីល្វះសង្ហារ ០ នាភូមិភាគ ០ ភូមិ ឧត្តរនុ
(៦២ ភូមិព្រះទានតិម្រតាញខ្លោញជ្វន្តព្រះម្រតេងអញនាវាយណា
ភូមិតិទក្សេកណានុស្រែះព្រះទានបិ (៦៣ ) តិម្រតាញខ្លោញជួន
តកម្រតេងអញគិរលិង្គ ។

## បទានុក្រម

*សិលាចារឹកនេះ ខ្ញុំមិនបាច់សរសេរតាមបែបភាសាខ្មែរយើងសម័យ បច្ចុប្បន្ននេះទេ ខ្ញុំគ្រាន់តែជូនពាក្យខ្លះដែលលោកអ្នកអានមិនបាច់បាន ឃើញដូចតទៅនេះ :*

---

១ ពកពី "ភ្នំ" "ភ្នំពក ឬពកពក់ពក់ភ្នំ"

| | | | |
|---|---|---|---|
| ករាំ | ក្រោម | ផោង | ផង |
| កម្រតេង | គម្ដែង | ផ្លេយ | ផ្លៃ |
| កេត | កើត | ម៉ន | ម៉ុន |
| ក្រលាស្រោង | ក្រឡាស្រង់ | ម្រតាញខ្មោញ | គម្ដែងខ្លោង |
| គ្លង់ | ឃ្លាំង | ម្ទាយ | មួយ |
| ឃោ | ឃោសកៈ | ឈោញ | ខ្លោញ |
| ញាម | ញាំ | ល្ងោះ | លុះ |
| ជួន្ត | ជួនដ៏ | វល | ពល |

## ផ្នែកកំណត់-ប្រវត្តិការណ៍

ពុទ្ធសាសនបណ្ឌិត្យ ព្រះរាជាណាចក្រកម្ពុជា

# សេចក្ដីជូនដំណឹង

## អំពីលទ្ធផលនៃការប្រឡងប្រជែងខាងទំនៀមទម្លាប់ នៅឆមាសទី ១ ឆ្នាំ ១៩៦៩

ក្រុមទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ មានសេចក្ដីរីករាយ ទឹងផ្សាយដំណឹងចំពោះព្រះតេជព្រះគុណ អស់លោក-អ្នកជាសមាជិក ផ្ញើយថ្លង និង បេក្ខជនទូទៅថា : នៅក្នុងឆមាសទី ១ ឆ្នាំ ១៩៦៩ កន្លងទៅនេះ ក្រុមទំនៀមទម្លាប់បានបើកការប្រឡងប្រជែងខាងទំនៀមទម្លាប់ខ្មែរ ២ មុខគឺ : "អំពីប្រផ្នូលផ្សេងៗ និងអំពីសត្វដែលគេចិញ្ចឹមនៅក្នុងប្រទេសកម្ពុជា" ដើម្បីប្រមូលឯកសារផ្នែកនេះមកតម្កល់ទុក សម្រាប់ធ្វើជា គោលចារិកនៃប្រពៃណីខ្មែរតទៅ ។ តាំងពីបើកសម័យប្រឡងប្រ-ជែងមក មានបេក្ខជនទាំងបព្វជិតទាំងគ្រហស្ថ បានផ្ញើអត្ថបទជាច្រើនមកចូលរួមប្រឡងប្រជែង ។ ក្រុមទំនៀមទម្លាប់ បានពិនិត្យនូវវិញ្ញាសាទាំងនោះយ៉ាងហ្មត់ចត់ហើយបានសម្រេចលទ្ធផល ដូចតទៅនេះ :

### អំពីប្រផ្នូលផ្សេងៗ

ក្នុងចំណោមឯកសារផ្នែកនេះ គ្មានឯកសារណាមួយល្អល្មមឲ្យជាប់

ដល់លេខ ១ បាន ក្រុមជំនុំកំសម្រេច ជូនត្រឹមតែរង្វាន់លេខ ២ ចុះមក ដូចតទៅនេះ :

- រង្វាន់លេខ ២ : ភិក្ខុ ទុំ-យី គង់នៅវត្តខ្នារ សង្កាត់ព្រៃទឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ត្រូវបានរង្វាន់ ៨០០រ០០

- រង្វាន់លេខ៣ : លោក ចាប-រិត គ្រូបង្រៀននៅសាលាបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ត្រូវបានរង្វាន់ ៦០០រ០០

- រង្វាន់លេខ ៣ : លោក សាំង-ឡុង គ្រូបង្រៀននៅសាលារៀនជ្រៃ សង្កាត់ព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង ត្រូវបាតរង្វាន់ . . . . . . ៦០០រ០០

- រង្វាន់លេខ ៤ : លោកប្រាក់-មៃ ភូមិស្នាច់ដែង សង្កាត់ពាម ស្រុកព្រៃឆប់ ខេត្តកំពត ត្រូវបានរង្វាន់ . . . ៤០០រ០០

## អំពីសត្វដែលគេចិញ្ចឹមនៅក្នុងប្រទេសកម្ពុជា

- រង្វាន់លេខ ១ : លោក ចាប-រិត គ្រូបង្រៀននៅសាលាបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ត្រូវបានរង្វាន់ ១.០០០រ០០

- រង្វាន់លេខ ២ : លោក ស៊ូ-សែម នាយត្រួតរង់ថ្នាក់ទី ១ នៅទីបញ្ជាការផ្នែក ក-រ-ត ស្រុកត្រាំកក់ ខេត្តតាកែវ ត្រូវបានរង្វាន់ . . . . . . ៨០០រ០០

- រង្វាន់លេខ ៣ : លោក សេក-សេត សង្កាត់តាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ត្រូវបានរង្វាន់ . . . ៦០០៛០០

- រង្វាន់លេខ ៤ : លោក ទិត-សុខ ហៅ សាត សង្កាត់កំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល ត្រូវបានរង្វាន់ ៤០០៛០០

រង្វាន់ទាំងនេះ ក្រុមចំនៀមទម្លាប់ បានចាត់ការផ្ញើទៅជូនសាមីខ្លួន តាមរយៈប្រៃសណីយ៍ និង ទូរគមនាគមន៍រួចហើយ ។

ម្យ៉ាងទៀត នៅក្នុងខែមាសទី ២ ឆ្នាំ ១៩៦៩ នេះ ក្រុមចំនៀមទម្លាប់បានបើកការប្រឡងប្រជែង ២ មុខទៀត គឺ ៖

១- ចម្រៀងប្រជាប្រិយ

២- ទោសនិងការផ្ដន្ទាតាមរបៀបបុរាណ

ឯប្រកាសប្រឡងប្រជែងដែលមានសេចក្ដីពិស្ដារនោះ ក្រុមចំនៀមទម្លាប់បានចាត់ការ ផ្ញើទៅជូនសមាជិកឆ្លើយឆ្លង និង បេក្ខជនព្រមទាំងផ្សាយទៅគ្រប់សាលាខេត្ត សាលាស្រុក និងចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយារួចអស់ហើយ ។ យើងសង្ឃឹមថា នឹងមានអស់លោក-អ្នកដែលចេះដឹងរឿងនេះ ផ្ដល់ឯកសារជាច្រើនទៅក្រុមចំនៀមទម្លាប់ជាមិនខាន ។

ក្រុមទំនៀមទម្លាប់ សូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះព្រះតេជព្រះគុណអស់លោកដែលបានយកព្រះទ័យ យកចិត្តទុកដាក់ជួយរក្សាកេរ្តិ៍ដំណែលរបស់ជាតិ ដ៏ថ្លៃថ្លាទាំងឲ្យបានគង់វង្សតទៅអនាគត ។

ភ្នំពេញ ថ្ងៃទី ៧ សីហា ១៩៦៩

នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

ហត្ថលេខា : ឈាង-ហ័បអាន

៨

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤១ ខែ សីហា

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-

៨

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ — ទំព័រ

## ផ្នែកសាសនា


១— មហាសីល លោក ប៊ូ-ប៊ូ រៀបរៀង . . . . . ៧៨៩
២— ទស្សនវិជ្ជាពុទ្ធសាសនា ព្រះមហាវីរិយបណ្ឌិតោ ប៉ាង-ខាត់ រៀបរៀង ៧៩៧


## ផ្នែកអក្សរសាស្ត្រ


៣— វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង ខាត់ . . . . ៨១៤
៤— រឿងសាមកុក (ត) ឧកញ៉ានូ-កន ប្រែរៀបរៀង . . . . ៨១៧
៥— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ សហជីវិន ពេជ-សល់ ប្រែរៀបរៀង ៨២៩
៦— ល្បើកអក សហ. លី-ធាមតេង ស្រាវជ្រាវ . . . . ៨៤៤
៧— ឯកសារ : ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង ឧកញ៉ា
ប្រសើរលិខិត ម៉ែន-ទន់ រៀបរៀង. . . . . . ៨៦១


## ផ្នែកកំណត់-ប្រវត្តិការណ៍


៨— ពិធីបូជាសព ព្រះសុមេធាវង្ស ប្រាជ្ញ-ប៊ុល . . . . ៨៨៥
៩— សុន្ទរកថា ព្រះពុទ្ធវង្ស លោក-ខាង ថ្លែងក្នុងឱកាសបូជាព្រះសព
ព្រះសុមេធាវង្ស ប្រាជ្ញ-ប៊ុល នៅថ្ងៃ២៤ ខែសីហា ឆ្នាំ ១៩៦៩
នៅឈាបនដ្ឋាន វត្តឧណ្ណាលោម ក្រុងភ្នំពេញ . . . . ៨៨៦
១០— ពិធីប្រគេនព្រះរាជអំណោយរបស់សម្តេចឪ ថ្វាយចំពោះសម្តេចព្រះពោធិវង្ស . ៨៩៤

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ៛

## ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក | ឲ្យធ្វើល្អទៅ, |
| ឲ្យដុសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា • |

ប. ៣

# មហាសីល

លោក ប៊ូ ប៊ូ រៀបរៀង

---

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ គឺចិញ្ចឹមជីវិតខុស ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ៗ គឺ សាស្ត្រា (ក្បួន) និយាយអំពីអវយវៈខ្លះ ទាយនិមិត្ត គឺហេតុខ្លះ ឧត្បាតគឺធ្លាក់ចុះនៃហេតុធំៗ មានរន្ទះបាញ់ជាដើមខ្លះ ទាយយល់សប្តិខ្លះ ទាយលក្ខណៈខ្លះ ទាយវត្ថុដែលកណ្តុរកាត់(មានសំពត់ជាដើម)ខ្លះ និយាយអំពីការបូជាដោយភ្លើងខ្លះ និយាយអំពីការបូជាដោយវែកខ្លះ និយាយអំពីការបូជាដោយអង្កាមខ្លះ និយាយអំពីការបូជាដោយកុណ្ឌកខ្លះ និយាយអំពីការបូជាដោយអង្ករខ្លះ និយាយអំពីការបូជាដោយ

ទឹកដោះរាវខ្លះ និយាយអំពីការបូជាដោយប្រេងខ្លះ និយាយអំពីការបូជាដោយមាត់(១)ខ្លះ និយាយអំពីការបូជាដោយឈាមខ្លះ វិជ្ជាសម្រាប់ទាយនូវអវយវៈខ្លះ វិជ្ជាសម្រាប់ទាយភូមិឋានខ្លះ វិជ្ជាសម្រាប់ទាយទីស្រែចម្ការខ្លះ វិជ្ជាស្គាល់ព្រៃខ្មោចខ្លះ វិជ្ជាចាប់ខ្មោចខ្លះ វិជ្ជាសម្រាប់ការពាររក្សាភូមិផ្ទះខ្លះ វិជ្ជាស្តោះពស់(២)ខ្លះ វិជ្ជារក្សាពិសខ្លះ វិជ្ជាស្តោះខ្ទួយទិចខ្លះ វិជ្ជាស្តោះកណ្ដុរខាំខ្លះ វិជ្ជាសម្រាប់ទាយសម្រែកសត្វស្លាបខ្លះ វិជ្ជាសម្រាប់ទាយសម្រែកក្អែកខ្លះ វិជ្ជាសម្រាប់ទាយអាយុខ្លះ វិជ្ជាសម្រាប់ពក់ព័ន្ធនូវសរខ្លះ វិជ្ជាសម្រាប់មើលនូវស្នាមជើងម្រឹគ គឺសត្វជើង ៤ ទាំងអស់ខ្លះ ។ ភិក្ខុជាអ្នកវៀរចាកការចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចម្រើនពួកមួយបរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ។ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ។ គឺការទាយលក្ខណៈកែវមណីខ្លះ ទាយលក្ខណៈសំពត់ខ្លះ ទាយលក្ខណៈដំបងឬឈើច្រត់ខ្លះ ទាយលក្ខណៈគ្រឿងសាស្ត្រាខ្លះ ទាយលក្ខណៈដាវ

---

១- ភត្តបិណ្ឌ បាយមាំទុំក្រុមឧ្រុបក្តិលទើប យកទៅដាក់ក្នុងភ្លើង ឬ ស្តីព្រហៀរសប្តុះបាយ ។ ២- វិជ្ជាបើកសាស្ត្រឲ្យពស់ខាំ ឬហាមពស់ ។

ខ្លះ ទាយលក្ខណៈសរខ្លះ ទាយលក្ខណៈធ្នូខ្លះ ទាយលក្ខណៈអាវុធខ្លះ ទាយលក្ខណៈស្ត្រីខ្លះ ទាយលក្ខណៈបុរសខ្លះ ទាយលក្ខណៈក្មេងប្រុសខ្លះ ទាយលក្ខណៈក្មេងស្រីខ្លះ ទាយលក្ខណៈខ្ញុំប្រុសខ្លះ ទាយលក្ខណៈខ្ញុំស្រីខ្លះ ទាយលក្ខណៈដំរីខ្លះ ទាយលក្ខណៈសេះខ្លះ ទាយលក្ខណៈក្របីខ្លះ ទាយលក្ខណៈគោឧសភខ្លះ ទាយលក្ខណៈគោខ្លះ ទាយលក្ខណៈពពែខ្លះ ទាយលក្ខណៈកែះខ្លះ ទាយលក្ខណៈមាន់ខ្លះ ទាយលក្ខណៈចាបឬក្រួចខ្លះ ទាយលក្ខណៈរូបគំនូរឬគ្រឿងប្រដាប់ធ្វើដោយរូបទន្សងខ្លះ ទាយលក្ខណៈគ្រឿងប្រដាប់ ឬ កំពូលផ្ទះខ្លះ ទាយលក្ខណៈរូបគំនូរ ឬ គ្រឿងប្រដាប់ធ្វើដោយរូបអណ្ដើកខ្លះ ទាយលក្ខណៈម្រឹគ គឺសត្វជើង ៤ ទាំងអស់ខ្លះ ។ ភិក្ខុជាអ្នកវៀរចាក មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ។ តិរច្ឆានវិជ្ជា នោះតើដូចម្ដេចខ្លះ ។ គឺទាយការលើកទ័ពថា ព្រះរាជាគួរស្ដេចចេញទៅ ( ក្នុងថ្ងៃនោះ ) ព្រះរាជាគួរស្ដេចត្រឡប់មកវិញ ( ក្នុងថ្ងៃនោះ ) ព្រះរាជាខាងក្នុងនឹងរុករានចូលទៅ ព្រះរាជាខាងក្រៅនឹងថយចេញទៅ ព្រះរាជាខាងក្រៅនឹងរុក

កាលចូលមក ព្រះភជាខាងក្នុងនឹងថយចេញទៅ ព្រះភជាខាងក្នុងនឹងមានជ័យជម្នះ ព្រះភជាខាងក្រៅនឹងបរាជ័យ ព្រះភជាខាងក្រៅនឹងមានជ័យជម្នះ ព្រះភជាខាងក្នុងនឹងបរាជ័យ ព្រះភជាអង្គនេះនឹងមានជ័យជម្នះ ព្រះភជាអង្គនេះនឹងបរាជ័យ ។ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយបរិភោគនូវភោជនទាំងឡាយដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ។ តិរច្ឆានវិជ្ជា នោះតើដូចម្តេចខ្លះ ។ គឺការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមានចន្ទគ្រាះ នឹងមានសូរ្យគ្រាះ នឹងមាននក្ខត្តគ្រាះ គឺផ្កាយព្រះគ្រោះដើររួមចូលគ្នា ឬដើរលង្ឃព្រះអាទិត្យព្រះចន្ទ ឬផ្កាយណាមួយ ព្រះចន្ទព្រះអាទិត្យនឹងដើរតាមផ្លូវត្រូវគ្នា ព្រះចន្ទព្រះអាទិត្យនឹងដើរខុសផ្លូវគ្នា ផ្កាយទាំងឡាយនឹងដើរតាមផ្លូវត្រូវគ្នា ផ្កាយទាំងឡាយនឹងដើរខុសផ្លូវគ្នា នឹងមាន ឧក្កាបាត[១] នឹងកើតមានកម្តៅក្នុងទិស នឹងមានការកម្រើកផែនដី នឹងមានផ្គរលាន់ (ឥតមាន

---

១ ក្នុងលីនត្ថប្បកាសនាដីកាថា កាលបើអាកាសមានខ្យល់ទង្គិចគ្នាខ្លាំង ក៏កើតអានុភាពនីរស្មីដូចជាពន្លឺប្រទីបធ្លាក់ចុះមកអំពីអាកាស ហៅថាឧក្កាបាត ។

ភ្លៀង ) ព្រះចន្ទព្រះអាទិត្យផ្កាយនឹងរះឡើង ឬលិចទៅវិញនឹងសៅហ្មង ឬផូរផង់ ចន្ទគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ សូរ្យគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ នក្សត្រគ្រាះ នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទនឹងព្រះអាទិត្យដើរតាមផ្លូវត្រូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទនឹងព្រះអាទិត្យដើរខុសផ្លូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ពួកផ្កាយដើរខុសផ្លូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ពួកផ្កាយដើរខុសផ្លូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ឧក្កាបាតនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ កម្ដៅក្នុងទិស នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ការកក្រើកផែនដីនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ផ្គរលាន់ (ឥតមានភ្លៀង) នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទព្រះអាទិត្យ នឹងផ្កាយរះឡើង លិចទៅវិញ សៅហ្មងឬផូរផង់នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ភិក្ខុជាអ្នកវៀរចាក មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជា នោះតើដូចម្ដេចខ្លះ ៗ គឺការទាយថា (ក្នុងឆ្នាំនោះ) នឹងមានភ្លៀងធ្លាក់ស្រួល នឹងមានភ្លៀង

ធ្លាក់មិនស្រួល នឹងមានបាយសម្បូណ៌ នឹងមានបាយក្រ នឹងមានសេចក្ដីក្សេមក្សាន្ត នឹងមានភ័យ នឹងមានរោគ នឹងមិនមានរោគ ការរាប់ដោយដៃទទេ ការរាប់ដោយវិធីខព្វន្ត រាប់បូក(១)កាព្យឃ្លោង គម្ពីរលោកាយតៈ ៗ ភិក្ខុជាអ្នកវៀរចាក មិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយ មិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជា នោះតើដូចម្ដេចខ្លះ ៗ គឺវិធីរៀបអាពាហមង្គលខ្លះ វិធីរៀបវិវាហមង្គលខ្លះ វិធីធ្វើឲ្យព្រមព្រៀងគ្នា (សេហ្ន៍)ខ្លះ វិធីធ្វើឲ្យព្រាត់ប្រាសគ្នា(បង់ចំណែង) ខ្លះ វិធីប្រមូលទ្រព្យខ្លះ វិធីប្រកបជំនួញខ្លះ វិធីធ្វើឲ្យចូលចិត្តស្រឡាញ់គ្នា ឬធ្វើឲ្យមានសិរីខ្លះ វិធីធ្វើឲ្យស្អប់គ្នាខ្លះ វិធីធ្វើគភ៌ដែលបម្រុងវិនាសមិនឲ្យវិនាសខ្លះ វិធីចងអណ្ដាតឲ្យរឹងដោយមន្តខ្លះ វិធីចងចង្កាឲ្យរឹងខ្លះ វិធីសូត្ររៀនដើម្បីផ្លាស់ប្ដូរដៃខ្លះ វិធីសូត្ររៀនដើម្បីមិនឲ្យឮសំឡេងដោយត្រចៀកខ្លះ ប្រស្នាកញ្ចក់ គឺមន្តអាបយកទេវតាឲ្យមកនៅនឹងកញ្ចក់ហើយសួរប្រស្នាខ្លះ ប្រស្នាកុមារី

---

១ អដ្ឋកថា ថា ការរាប់នេះ បើស្ទាត់ដល់បុគ្គលណា បុគ្គលនោះ កាលបើឃើញដើមឈើ ក៏អាចនឹងដឹងថា ឈើនោះមានស្លឹកប៉ុណ្ណោះៗ បាន ។

គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃកុមារីហើយសួរប្រស្នាខ្លះ ប្រស្នាទេវតា គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃទាសីហើយសួរប្រស្នាខ្លះ វិធីបម្រើព្រះអាទិត្យខ្លះ វិធីបម្រើមហាព្រហ្មខ្លះ វិធីបញ្ចេញភ្លើងអំពីមាត់ដោយមន្តខ្លះ វិធីហៅសិរីឲ្យស្ថិតក្នុងសរីរៈខ្លះ ។ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើន ពួកមួយបរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះ តិរច្ឆានវិជ្ជាមានសភាពដូច្នេះ ។ តិរច្ឆានវិជ្ជា នោះ តើដូចម្តេចខ្លះ ។ គឺការបន់ស្រន់ខ្លះ ការលាបំណន់ខ្លះ ធ្វើមន្តសម្រាប់ការពារបិសាចខ្លះ ធ្វើមន្តសម្រាប់ការពារផ្ទះខ្លះ ធ្វើខ្ទើយឲ្យដូចជាបុរសខ្លះ ធ្វើបុរសឲ្យដូចជាខ្ទើយខ្លះ ធ្វើវិធីសង់ផ្ទះលើទីដីដែលមិនធ្លាប់បានធ្វើខ្លះ ធ្វើពលិកម្មនៅលើទីដីដែលសង់ផ្ទះខ្លះ ជម្រះមុខឲ្យស្អាតដោយទឹកឲ្យគេខ្លះ បន្តក់ប្រសិទ្ធឲ្យគេខ្លះ បូជាភ្លើងឲ្យគេខ្លះ ធ្វើថ្នាំសម្រាប់ឲ្យក្អួតខ្លះ ធ្វើថ្នាំបញ្ចុះខ្លះ ធ្វើថ្នាំកម្ចាត់បង់នូវទោសខាងលើខ្លះ ធ្វើថ្នាំកម្ចាត់បង់នូវទោសខាងក្រោមខ្លះ ធ្វើថ្នាំកម្ចាត់បង់នូវទោសក្នុងក្បាលខ្លះ ស្ងោប្រេងសម្រាប់បន្តក់ត្រចៀកខ្លះ ធ្វើថ្នាំសម្រាប់ស្អំភ្នែកខ្លះ ធ្វើថ្នាំសម្រាប់ហិតខ្លះ ធ្វើថ្នាំសម្រាប់លាបបង្អាត់ខ្លះ ធ្វើថ្នាំត្រជាក់សម្រាប់ស្រលាបខ្លះ ធ្វើវេជ្ជកម្មក្យៈភ្នែកខ្លះ

ធ្វើពេទ្យវះខ្លះ ធ្វើពេទ្យរក្សាក្មេងខ្លះ ដាក់ថ្នាំក្រោយឲ្យជួយកម្លាំងថ្នាំមុនខ្លះ លាងថ្នាំដើមចេញ(១)ខ្លះ ។ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះដែរ ។

បពិត្រមហារាជ ភ័យណា ដែលគប្បីកើតឡើង ព្រោះសេចក្តីសង្រួមក្នុងសីល ភិក្ខុនោះឯងបរិបូណ៌ដោយសីលយ៉ាងនេះហើយ រមែងមិនបានឃើញនូវភ័យនោះ អំពីទីណាមួយឡើយ ។ បពិត្រមហារាជ ប្រៀបដូចជាភ័យណា ដែលគប្បីកើតឡើងអំពីសត្រូវ ក្សត្រិយ៍ដែលបានមុទ្ធាភិសេក(២)ហើយ កម្ចាត់បង់នូវពួកសត្រូវអស់ហើយ រមែងមិនបានឃើញនូវភ័យនោះ អំពីទីណាមួយឡើយ ដូចម្តេចមិញ, បពិត្រមហារាជ ភ័យណាដែលគប្បីកើតឡើង ព្រោះសេចក្តីសង្រួមក្នុងសីល ភិក្ខុអ្នកបរិបូណ៌ដោយសីលយ៉ាងនេះហើយ រមែងមិនបានឃើញនូវភ័យនោះ អំពីទីណាមួយឡើយ ដូច្នោះឯង ។ ភិក្ខុនោះ បើបានប្រកបដោយសីលក្ខន្ធជារបស់ព្រះអរិយៈនេះហើយ រមែងសោយនូវសេចក្តីសុខ ដែលមិនមានទោសក្នុងសន្តានចិត្តនៃខ្លួន ។ បពិត្រមហារាជ ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។

---

១- អដ្ឋកថា ថា កាលបើមានដំបៅ ដាក់ថ្នាំមានថ្នាំផ្សារជាដើមក្នុងដំបៅនោះ ពេលបើដំបៅស្រួលសមគួរហើយ ក៏នាំយកថ្នាំនោះចេញ ។

២ ព្រះរាជាដែលគេបានអភិសេកស្រោចទឹកលើព្រះសិរៈ ក្សត្រ[illegible] ។

ចប់ មហាសីល ។

# ទស្សនវិជ្ជាពុទ្ធសាសនា

ព្រះមហាវីរយ បណ្ឌិតោ ទ៉ាង . ខាត់ រៀបរៀង

---

អ្នកផងទូទៅតែងនិយាយថា ៖ ពុទ្ធសាសនា ជាលទ្ធិសាសនា (Religion); ពាក្យថា Religion នេះ មិនគួរយកទៅប្រើសម្រាប់ហៅ ពុទ្ធសាសនាទេ ព្រោះពុទ្ធសាសនា ជាផ្លូវប្រតិបត្តិមិនទាក់ទងទៅខាងលទ្ធិ ទិដ្ឋិ (Dogme), វាទ (Doctrine) ដូចលទ្ធិសាសនា(Religion) ដទៃ ៗ នោះឡើយ ។ ក្នុងគម្ពីរពុទ្ធសាសនាមានពាក្យចោទឆ្លើយថា ៖" សាសនាមានប៉ុន្មាន ?

ឆ្លើយថាមាន២យ៉ាងគឺ ១-ពុទ្ធសាសនា ២-ពាហិរសាសនា ។ សាសនាទីពីរ គឺពាហិរសាសនា ( Religion ) សំដៅយកលទ្ធិសាសនាទាំងអស់ក្រៅពីពុទ្ធសាសនា ព្រោះសុទ្ធតែជាលទ្ធិ ទិដ្ឋិ ( Dogme ) វាទ ( Doctrine ) ។ល។ ឯពុទ្ធសាសនាជាបដិបទាផ្លូវប្រតិបត្តិជាកម្មនិយម បូជាវិធីបំបាត់អវិជ្ជា តណ្ហា ឧបាទានកម្ម ។ សេចក្តីពិត អង្គព្រះសម្ពុទ្ធមិនមែនជាអ្នកបង្កើតពុទ្ធសាសនាទេ ព្រះអង្គគ្រាន់តែជាសាស្តា ព្រះអង្គគ្រាន់តែជាអ្នកឃើញធម៌ ហើយប្រកាសធម៌ដែលទ្រង់ត្រាស់ដឹងនោះ ៗ ទ្រង់មិនដែលប្រកាសព្រះអង្គថាជាអ្វីដទៃ ក្រៅពីព្រះអង្គជា

មនុស្សឡើយ ពោលគឺទ្រង់ជាមនុស្សសុទ្ធសាធ ។ មេសាសនាដទៃច្រើនតែលើកខ្លួនថាជាទេពតា ជាអាទិទេពនៅឋានសួគ៌ ឬជាអវតារ នៃអាទិទេព ក្នុងការបែងភាគទៅជារូបផ្សេង ៗ ។ ព្រះអង្គជាមនុស្សហើយ ទ្រង់មិនដែលប្រកាសថា ព្រះអង្គមានអ្នកណា ឬទេពតាណា មានសក្តានុភាពចូលមកណែនាំព្រះអង្គឲ្យប្រកាសសាសនា ដូចសាសនាទាំងពួងទេ ។ ផលប្រសើរដែលទ្រង់បានសម្រេចអភិសម័យគឺការលុះធម៌ ការត្រាស់ដឹងធម៌ មិនមែនបានដោយឫទ្ធិអំណាចទេពតា ជួយផ្តល់ឲ្យបានសម្រេចទេ គឺទ្រង់បានសម្រេចដោយវិរិយភាពព្រះអង្គជាមនុស្ស ដោយបញ្ញាញាណព្រះអង្គជាមនុស្សពិតប្រាកដ ។ មនុស្សយើង បើគ្រាន់តែបានភាពជាមនុស្សប៉ុណ្ណឹង អាចលុះភាពនៃខ្លួនជា « ពុទ្ធ » បានឥតសង្ស័យឡើយ ។ មនុស្សគ្រប់រូប អាចប្រែសក្តានុភាពខ្លួន ជាមនុស្សឲ្យបានសម្រេចភាពជាព្រះពុទ្ធបាន ចាំបើមានបំណងមាំទាំងមានវិរិយភាពធំ ។ ដូច្នេះ យើងអាចពោលបានថា អង្គព្រះសម្ពុទ្ធជាមនុស្សដោយប្រពៃមិនខុសតាសអ្វីទេ ព្រោះព្រះអង្គទ្រង់បំពេញបារមីធម៌ក្នុងមនុស្សភាព មិនមែនក្នុងទេវភាពឡើយ ហើយទ្រង់បានសម្រេចភាពជាមហាបុរសរតន៍ឆ្នើមបំផុត ក្នុងចំណោមមនុស្សជាមេសាសនាធំ ៗ ក្នុងពិភពលោក ពាល់តែមនុស្សលោកពិលក្មេកមើលព្រះអង្គ ឃើញព្រះអង្គ ហើយសំគាល់ថា ទ្រង់ជាឧត្តមមនុស្ស ( Super humain ) ។

ការបានភាពនៃខ្លួនជាមនុស្សប្រសើរបំផុត (កិច្ឆោ មនុស្សបដិលាភោ) ។ មនុស្សជាម្ចាស់ខ្លួនឯង ឥតមានទេពតាណា ឬអំណាចអ្វីណាមួយប្រសើរជាងកំណើតនាខ្លួនជាមនុស្សនេះទេ ។ មនុស្សម្នាក់ៗ ជាកោះទីពឹងរបស់ខ្លួន អត្តទីបោ =អ្នកណាជាសរណៈខ្លួនឯង ជាងខ្លួនឯង ? ព្រះសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា "ខ្លួនជាទីពឹងខ្លួន" មនុស្សម្នាក់ៗមិនត្រូវដើរទៅស្វែងរកសរណៈដទៃក្រៅពីខ្លួនទេ ។ កាលទ្រង់គង់ធមាំនៅឡើយ ព្រះសម្ពុទ្ធទ្រង់តែងទេសនាប្រៀនប្រដៅថា៖ ត្រូវកសាងខ្លួនដោយខ្លួនឯង (អត្តសម្មាបណិធិ) ហើយយកអានុភាពខ្លួនឯងទៅដោះទុក្ខ (មោក្ខ) ខ្លួនឯង ឲ្យរួចស្រឡះពីចំណងតណ្ហា ដោយវិរិយភាព និងបញ្ញា ជារបស់ខ្លួនឯងជាមនុស្ស ។ ទ្រង់ផ្តាំទុកទីបំផុតថា:(១) ចូលធ្វើប្រយោជន៍ខ្លួនឲ្យសម្រេចដោយក្តីមិនប្រមាទ (អប្បមាទេន សម្បាទេថ) ឯពាក្យដែលអ្នកផងតែងពោលថា "ព្រះអង្គស្រង់សត្វ" នោះ គ្រាន់តែជាពាក្យពោលដោយន័យថា ព្រះអង្គត្រាស់ដឹងធម៌ ទេសនាបង្អុលប្រាប់ផ្លូវឲ្យសត្វដើរ គឺប្រៀនប្រដៅសត្វលោកឲ្យចំរៀនឲ្យចេះដឹង ហើយឲ្យដើរដោយខ្លួនឯង ព្រមទាំងធ្វើបានលុះមោក្សធម៌ ដោយខ្លួនឯងតែប៉ុណ្ណោះទេ ដោយពិត យើងត្រូវដើរដោយខ្លួនយើងគ្រប់គ្នា ទើបឲ្យព្រះអង្គស្រង់យើងដូចស្រង់មនុស្សលង់ទឹកដូចម្តេចបាន ? តែមនុស្សលោក

១- មហាបរិនិព្វានសូត្រ ។

ចូលចិត្តឲ្យគេស្រង់ខ្លួនទាំងស្រកាក ដូចស្រង់មនុស្សលង់ទឹកកណ្តាលទន្លេ ដូច្នោះឯង ។

តាមគោលការណ៍ មនុស្សម្នាក់ៗ ត្រូវទទួលខុសត្រូវដោយខ្លួនឯង ។ សេចក្តីត្រង់នេះ ក្នុងពុទ្ធសាសនា ឃើញមានច្រើនកន្លែងណាស់ ទ្រង់តែងតែប្រទានសេរីភាពដល់សាវកព្រះអង្គ ។ ក្នុងមហាបរិនិព្វានសូត្រ ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះព្រះអានន្ទត្ថេរថា[1] : ។

– អានន្ទ ! ភិក្ខុសង្ឃ ត្រូវការអ្វីចំពោះតថាគតទៀត =(កឹ បនា- នន្ទភិក្ខុសង្ឃោ មយិ បច្ចាសីសតិ ) ។

អានន្ទ ធម៌ដែលតថាគតសំដែងប្រាប់ហើយ មិនមានក្នុង មិនមានក្រៅទេ បានសេចក្តីថា ធម៌វិន័យនេះ មិនមែនជាអន្តោគុត្តវាទ (Doctrine ésotérique)

មានអ្វីលាក់លៀមទុកក្រោយទៀតទេ =(ទេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ) ។

“ អានន្ទ ! អាចរិយមុដ្ឋិ ក្នុងធម៌តថាគតមិនមានទេ បានសេចក្តីថា ធម៌វិន័យនេះ មិនមែនបិទនៅក្នុងកណ្តាប់ដៃអាចារ្យ គឺមិនមែនជាទិដ្ឋិ (Dogme) របស់អាចារ្យ និយាយក្រៅពីអាចារ្យមិនបាននោះទេ នត្ថានន្ទ តថាគតស្ស ធម្មេសុ អាចរិយមុដ្ឋិ ។

---

១- ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ សៀវភៅទី ១៦ ទំព័រ ២ ៣ ។

សេចក្ដីតទៅ ព្រះសម្ពុទ្ធទ្រង់ត្រាស់ទៀតថា ៖

អានន្ទ ! តថាគត មិនដែលបានគិតថា មិនត្រូវត្រួតត្រាសង្ឃមណ្ឌល ... ឬក៏សង្ឃមណ្ឌលត្រូវនៅក្រោមឱវាទតថាគតដូច្នេះក៏ទេដែរ ឥឡូវនេះ តថាគត គ្រាំគ្រាហើយ ចម្រើនហើយ ចាស់ហើយ កន្លងបច្ឆិមវ័យហើយ មានអាយុ ៨០ ឆ្នាំ ហើយ ។

សេរីភាពក្នុងការគិត ដែលព្រះអង្គទ្រង់ប្រទានដល់សាវកព្រះអង្គនេះ មិនដែលឮថាមានប្រាកដនៅក្នុងប្រវត្តិសាសនា នៃសកលលោកសោះឡើយ ។ សេរីភាពក្នុងការគិតនេះ មានប្រយោជន៍ណាស់ ព្រោះថា អត្តាធិនភាព (Emancipation) នៃមនុស្សលោក ឋិតនៅក្នុងអភិសម័យ (Réalisation) អាយសច្ចធម៌ មិនមែននៅក្រោមការប្រោសប្រាណនៃព្រះអាទិទេព ឬអំណាចនៃបុគ្គលណាមួយសោះឡើយ ។ សេចក្ដីនេះ បើយើងមើលក្នុងគម្ពីរ ដែលជាពុទ្ធវចនៈ នឹងឃើញមានច្រើនអនេ្វីណាស់ ។

ក្នុងសម័យមួយ កាលព្រះសម្ពុទ្ធស្ដេចយាងទៅកាន់ចារិកក្នុងក្រុងកេសបុត្ត ក្នុងដែនកោសល មានប្រជាជនកាលាមៈ[១] ច្រើននាក់បានចូលមកក្រាបទូលសួរព្រះអង្គថា :

---

១- មើលកាលាមសូត្រ សេចក្ដីប្រែព្រះតេជព្រះគុណ ព្រះមហាវិមលធម្ម ថោង ពុទ្ធសាសនបណ្ឌិត្យ ។ អង្គុត្តរនិកាយ តិកនិបាត មហាវគ្គ សៀវភៅទី ៤១ ទំព័រ ២១៦ ។

សូមទ្រង់មេត្តាប្រោស ពួកតាបសឬសី ពួកព្រាហ្មណ៍ច្រើននាក់ ដែលបានចូលមកកាន់ក្រុងកេសបុត្តនេះ តែងតែទេសនា អួតសរសើរ លើកតម្កើងវាទៈរបស់ខ្លួនសឹងតែពល់គ្នា ហើយបន្ទះបន្ទាប់វាទ នៃសាស្តាដទៃ ៗ ថាមិនត្រឹមត្រូវ ៗ យើងខ្ញុំព្រះអង្គគ្រប់គ្នាមានសេចក្តីសង្ស័យ មានក្តីងល់ថា តើបណ្តាពួកតាបសឬសី ពួកព្រាហ្មណ៍ទាំងនោះពួកណា និយាយត្រូវ ពួកណានិយាយខុស ៗ

កាលនោះព្រះសម្ពុទ្ធទ្រង់ប្រតានធម៌ទេសនា ដោយអនេកបរិយាយ ទ្រង់វិសជ្ជនា ដោះស្រាយប្រស្នានេះ ដោយពិស្តារ ៗ សេចក្តីដោះស្រាយបែបនេះ មានតែក្នុងពុទ្ធសាសនាមួយទេ មិនដែលមានប្រាកដទៅក្នុងប្រវត្តិសាសនាសកលលោកឡើយ ដូចសេចក្តីដែលអង្គព្រះសម្ពុទ្ធ ទ្រង់ត្រាស់ ដូចតទៅនេះ ៖

„ ហៃកាលាម: ! អ្នកគួរមានក្តីសង្ស័យមែន អ្នកគួរកើតក្តីងល់មែន ចំពោះប្រស្នាសង្ស័យដែលគួរឲ្យសង្ស័យនេះ ឥឡូវ ចូរប្រុងស្តាប់ដោយគោរពចុះ អ្នកទាំងឡាយកុំប្រព្រឹត្តអាការ ១០ យ៉ាងគឺ ៖

១- អនុស្សវា ការប្រកាន់ជឿ ដោយអាងពាក្យដែលពួកៗ គ្នា គឺមិនបានពិនិត្យពិចារណា រកហេតុផល ដោយបេះតែជឿតាមៗ គ្នា ៗ

២- បរម្បរា ការប្រកាន់ជឿ ដោយអាងធ្វើតៗ គ្នា មិនដឹងដើម

មិនដឹងបុន ដូចជាកាន់មំនៀមទម្លាប់ជាដើម ។

៣- ឥតិកិរ ការប្រកាន់ជឿ ដោយអាងថាបានឮមក ឬការប្រកាន់ជឿដោយអាងថា បានឮគេនិយាយមកយ៉ាងនេះ ដូចជាការប្រកាន់ជឿរឿងព្រេងជាដើម ។

៤- បិដកសម្បទា ការប្រកាន់ជឿ ដោយអាងថាពាក្យនេះ សមនឹងគម្ពីរដីកាយើងហើយ គឺអាងក្បួនតម្រាដូចគម្ពីរវេទជាដើម,

៥- តក្កហេតុ ការប្រកាន់ជឿ ដោយអាងហេតុ ឬអនុមាន ដោយស្មានយកខ្លួនឯង ឃើញយ៉ាងណា ក៏កាន់យកយ៉ាងនោះ ,

៦- នយហេតុ ការប្រកាន់ជឿ ដោយអាងន័យគ្នេរគ្នាន់កាត់ តម្រួយផ្ទៀផ្ទាំយក សំគាល់យកសេចក្ដីណាមួយដែលមានន័យប្រហែលគ្នាមកប្រកបហើយប្រកាន់ជឿតាមគ្នា,

៧- អាការបរិវិតក្កា ការប្រកាន់ជឿ ដោយអាងការត្រិះរិះនូវអាការៈគឺហេតុអ្វីដែលកើតឡើង តែមិនមែនជាការពិត ត្រិះរិះផ្គូងមើលទៅឃើញថា ពេញចិត្តខ្លួនយល់ថា ត្រឹមត្រូវហើយ ក៏ប្រព្រឹត្តកាន់តាមទៅ,

៨- ទិដ្ឋិនិជ្ឈានក្ខន្តិ ការប្រកាន់ជឿ ដោយអាងការចូលចិត្ត គឺហេតុអ្វីមួយដែលមិនមែនជាការពិត តែត្រូវនឹងគំនិតដែលខ្លួនធ្លាប់គិតទុកមក ចូលចិត្តថាហេតុនោះល្អហើយ ពិតហើយ ក៏ប្រព្រឹត្តតាមហេតុ

ការណ៍នោះ ។

៩- គព្វូបតា ការប្រកាន់ជឿដោយគាថា អ្នកនេះជាអ្នកបេះ ដឹង គួរតែយើងជឿកាន់តាម បានសេចក្តីថា អ្នកណាមួយប្រសប់ប៉ុនប៉ាវ ខាងសម្តីមាត់តែងពាក្យអ្នកនិយាយនេះមិនពិតទេ គ្រាន់តែពិរោះស្តាប់ ហើយប្រកាន់ជឿតាមអ្នកនោះទៅ ។

១០-សមណោ នោ គរុ ការប្រកាន់ជឿដោយគាថា សមណៈនេះជាគ្រូយើង គួរយើងកាន់យកតាម ពាក្យលោក គឺការ ប្រកាន់ជឿតាមលទ្ធិគ្រូខ្លួន បើទុកជាលទ្ធិគ្រូខ្លួនខុសក៏ដោយ ក៏បេះតែ ប្រកាន់ជឿតាមទាំងអស់ រីឯៈអ្នកដទៃដែលមិនមែនជាគ្រូខ្លួន តែត្រឹមត្រូវ មិនប្រកាន់ជឿតាមទេ ។

នែកាលាម: ! អ្វីមួយដែលអ្នកបានឃើញខ្លួនឯងថា នេះជាកុសល ជារបស់ប្រសើរ អ្នកចូរប្រព្រឹត្តតាមចុះ ! អ្វីមួយដែលអ្នកបានឃើញ ខ្លួនឯងថា ជាអកុសលជាធម៌លាមក ខុសគន្លងធម៌ អ្នកគួរលះបង់ចោល ទៅ កុំប្រព្រឹត្តតាមឡើយ ។

សាវកព្រះពុទ្ធ វៀរអាការ ១០ យ៉ាងនេះ លោកប្រើសទ្ធា និង បញ្ញាពិចារណារកហេតុផល ទើបជឿកាន់តាម ប្រតិបត្តិតាម ។

គម្ពីរដែលជាពុទ្ធវចនៈ មានសេចក្តីជាសំនៀន ឲ្យសាវកព្រះអង្គ បេះគិតប្រើគំនិតគឺការប្រទានសេរីភាព ក្នុងការគិតមានច្រើនអន្លើណាស់

ដូចព្រះតម្រាស់ចំពោះភិក្ខុទាំងឡាយថា[១] ភិក្ខុទាំងឡាយ សាវក តថាគត ត្រូវពិនិត្យមើលពាក្យតថាគត សាវកតថាគតត្រូវច្បាំងចំពោះសច្ចធម៌ តថាគតដែលជាគ្រូឲ្យឃើញត្រឹមត្រូវសិន សឹមប្រតិបត្តិតាម ដូចជាយើងនិយាយថា "ឲ្យឃើញសឃើញខ្មៅ" សិន ។

ក្នុងពុទ្ធសាសនា វិចិកិច្ឆា សេចក្ដីសង្ស័យ (Doute, Doubt) នេះជាធម៌មួយ នៅក្នុងនីវរណធម៌[២] (Empêchements, Hindrances) ទាំង ៥ ប្រការ ជាធម៌រាំងខ្ទប់មិនឲ្យយល់អរិយសច្ចធម៌ ឬ មិនឲ្យកើតសេចក្ដីចម្រើនគ្រប់ប្រការ ។ តែ វិចិកិច្ឆានេះ មិនមែនជាអំពើបាបកម្មទេ ព្រោះថាមិនមានទិដ្ឋិដែលត្រូវប្រើជំនឿ សទ្ធា នៅក្នុងពុទ្ធសាសនាឡើយ ។ ក្នុងពុទ្ធសាសនា មិនមានអំពើបាបកម្ម (Péché, sin) ដូចនៅក្នុងលទ្ធិសាសនា (Religion) ដទៃ ៗ ទេ ។ ឯមូលៈ (Racine, Root) ឬ ឫសគល់នៃបាបកម្មនោះ គឺអវិជ្ជា (Ignorance) និង

---

១- មជ្ឈិមនិកាយ មូលបណ្ណាសក វីមំសកសូត្រ សៀវភៅទី ២២ ទំព័រ ៣៣៧ ។

២- នីវរណធម៌ (Empêchements, Hindrances) ៥ ប្រការ គឺ :

១- កាមច្ឆន្ទ (La convoitise sensuelle, Sensual Lust) ; ២- ព្យាបាទ (La malveillance, Ill-will) ; ៣- ថីនមិទ្ធ (La torpeur physique et mentale et la langueur, physical and mental torpor and languour) ; ៤- ឧទ្ធច្ច កុក្កុច្ច (L'inquiétude et le tracas, Restlessness and worry); ៥- វិចិកិច្ឆា (La doute, Doubt) ។

មិច្ឆាទិដ្ឋិ (Vues fausses, False views) ។ នេះជាធម៌ដែលគេប្រកែកជជែកមិនបាន បើមានវិចិកិច្ឆា មានការងឿងឆ្ងល់ មានសន្ទិះសង្ស័យហើយសេចក្ដីចម្រើនពិតជាមិនអាចកើតឡើងបានទេ ។ មួយទៀត ធម៌នេះក៏គេប្រកែកជជែកមិនបានដែរថា គេមិនត្រូវទុកវិចិកិច្ឆានេះ ឲ្យនៅយូរលង់ទេ បើគេមិនយល់ ឬ បើគេមិនឃើញច្បាស់ ។ បើគេចង់ឲ្យសេចក្ដីចម្រើនដើរលឿនទៅមុខ ត្រូវតែបំបាត់វិចិកិច្ឆានេះចោលចង់ឲ្យស្រឡះ តែដើម្បីនឹងបំបាត់វិចិកិច្ឆា ក៏ត្រូវតែគេឃើញច្បាស់សិនដែរ ។

តែសេចក្ដីនេះ មិនមែនត្រូវយល់ថា គេមិនត្រូវឲ្យមានក្ដីសង្ស័យ ឬ មិនត្រូវឲ្យមានជំនឿនោះទេ បើគ្រាន់តែនិយាយថា "ខ្ញុំជឿ" ក៏មិនមែនបានសេចក្ដីថា "យល់ ឬ ឃើញ" នោះទេ ។ សេចក្ដីនេះ ប្រៀបដូចជាសិស្សគណិតសាស្ត្រ ដែលគិតចំណោទគណិតសាស្ត្រ ជួនកាលខ្លះតែងមានចំណុចមួយ ដែលសិស្សនេះមិនដឹងធ្វើដូចម្ដេចនឹងឲ្យទៅមុខរួច ឬ ខ្លួនលង់ទ្រទេសនៅក្នុងវិចិកិច្ឆា ឬ ក្នុងការងឿងឆ្ងល់ដែរ ។ ដរាបណាសិស្សនេះ នៅតែមានវិចិកិច្ឆា ដរាបនោះ សិស្សនេះនៅតែធ្វើទៅមុខមិនបានទេ ។ បើសិស្សនេះ ចង់ធ្វើឲ្យទៅមុខរួច លុះត្រាតែសិស្សនេះដោះវិចិកិច្ឆានេះបានសិន ទើបទៅមុខបាន ។ ក្នុងករណីនេះ តើលោកគ្រូបាធ្យាយអាចជួយឲ្យសម្រេចបានដែរឬទេ ? បើ

គ្រាន់តែនិយាយថា "ខ្ញុំជឿ" ឬ "ខ្ញុំមិនសង្ស័យទេ" នេះទៀត ក៏មិនអាចដោះស្រាយចំណោទបានពិតប្រាកដទៀត បើទុកជាបង្ខំជឿអ្វីមួយ ហើយព្រមទទួលយកអ្វីមួយនោះ ដោយឥតបានយល់សោះ នេះអាចទៅបានដែរ បានខាងវិស័យការរដ្ឋ តែមិនទុកជាបានការខាងវិស័យធម្មៈ ឬខាងវិស័យចំណេះដែលមានហេតុផលពុំបានឡើយ ។

ព្រះសម្មាសម្ពុទ្ធត្រាស់ទេសនាប្រដៅជានិច្ចថា ត្រូវបំបាត់ វិចិកិច្ឆា ចោលឲ្យស្រឡះបង់ពេលមុនបរិនិព្វាន ព្រះអង្គត្រាស់ហើយត្រាស់ទៀត ឲ្យព្រះសង្ឃសាវកសាកសួរព្រះអង្គ កុំឲ្យទុកវិចិកិច្ឆា នេះ ចំពោះធម្មវិន័យព្រះអង្គ ដើម្បីកុំឲ្យកើតវិប្បដិសារធម៌ទៅថ្ងៃក្រោយ ហើយមិនអាចកំចាត់ វិចិកិច្ឆា នេះបាន ។ តែកាលនោះ ព្រះសង្ឃសាវកតាំងនៅក្នុងតុណ្ហីភាពគ្រប់អង្គ ទើបទ្រង់ត្រាស់ទៀតថា[១] ៖ ។

ភិក្ខុទាំងឡាយ ! បើអ្នកទាំងឡាយ មានគារវធម៌ មិនអាចហ៊ានលើកប្រស្នាឡើងសួរទេ ឲ្យសទ្ធិវិហារិកណាម្នាក់ចូលមកសួរតថាគតចុះ កុំទុកឲ្យមាន វិចិកិច្ឆា នេះ តទៅទៀត ។

សេចក្តីខាងលើនេះ អ្នកសិក្សាប្រវត្តិសាស្ត្រលទ្ធិសាសនាគោតមស្ងើចក្រៃលែងចំពោះអង្គព្រះសម្ពុទ្ធ ដែលទ្រង់មានព្រះហឫទ័យទូលាយ ទ្រង់មិនមែនព្រះរាជទានត្រឹមតែសេរីភាពក្នុងការគិតតែប៉ុណ្ណោះទេ ទ្រង់ប្រគប

---

១- ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ សៀវភៅទី ១៦ ទំព័រ ២១៣ តទៅ ។

ដោយខន្តីធម៌ មេត្តាប្រោសសន្តោសព្រះសង្ឃសាវកទៀតផង ។ សម័យមួយ នៅស្រុកនាលន្ទា និគន្ថនាដបុត្ត ដែលយើងបានស្គាល់ថា តិត្ថង្ករ មហាវីរ បានបញ្ជូនសិស្សជំនិតម្នាក់ ជាគហបតី មានទ្រព្យសម្បត្តិស្តុកស្តម្ភ ឈ្មោះឧបាលិ(១) ឲ្យទៅគាល់អង្គព្រះសម្ពុទ្ធ ដើម្បីដេញដោលសួរព្រះអង្គពីទ្រឹស្តីកម្ម ធ្វើព្រះអង្គឲ្យចាល់ចាញ់យ៉ាងគាម៉ាស់មុខ ។ ទីបំផុត បុច្ឆាវិសជ្ជនា ឧបាលិគហបតីប្រកាសជាឧឡារិកថា កាយទណ្ឌ វចីទណ្ឌ មនោទណ្ឌ ជាប្រវចនៈ និគន្ថនាដបុត្ត មិនប្រសើរស្មើដោយ ពុទ្ធវចនៈ កាយកម្ម វចីកម្ម មនោកម្ម នោះឡើយ ហើយសូមថ្វាយខ្លួនជាឧបាសកចូលសាសន៍ពុទ្ធតេន៍ បានដល់ត្រៃសរណគមន៍ ។ កាលនោះព្រះសម្ពុទ្ធទ្រង់ត្រាស់ទូន្មានឧបាលិគហបតី ឲ្យពិចារណាទុកមុនឲ្យបានម៉ត់ចត់សិន ព្រោះការពិចារណាម៉ត់ចត់ ទើបសម្រេចចិត្ត ជាការប្រសើរបំផុត តែឧបាលិគហបតី ទទូចសូមថ្វាយខ្លួនជាឧបាសក ទើបទ្រង់ប្រទានដំបូន្មាន សំឧបាលិគហបតីឲ្យគោរពគ្រូដើមរបស់ខ្លួនដូចដើមដដែល ។

បណ្ដា មេលទ្ធិសាសនាទាំងអស់ក្នុងលោក ព្រះសម្ពុទ្ធជាអគ្គបុគ្គលប្រសើរលើសក្នុងការប្រទានសេរីភាព ប្រទានខន្តីមេត្តាប្រោសប្រ-

១- មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ឧបាលិវាទសូត្រ សៀវភៅទី ២៣ ទំព័រ ៩[illegible]

ណី ប្រទានការយោគយល់ទៅវិញទៅមក ។ ធម៌ទាំងនេះ ជាប្រពៃណីពុទ្ធសាសនារៀងរហូតមក ។ ព្រះបាទអសោកមហារាជ ជាឧបាសកដ៏ប្រសើរ បានយកធម៌ជាប្រពៃណីពុទ្ធសាសនា នេះមកប្រតិបត្តិក្នុងរជ្ជកាលព្រះអង្គ មានសេចក្តីប្រាកដនៅក្នុងព្រះរាជប្រកាសព្រះអង្គស្រាប់ដូចសេចក្តីតទៅនេះ (១) ៖

“អ្នកគ្រប់គ្នា មិនគួរលើកតម្កើងសរសើរតែលទ្ធិសាសនារបស់ខ្លួន ហើយប្រទូស្តលទ្ធិសាសនាដទៃទេ ត្រូវគោរពលទ្ធិសាសនាដទៃៗ ឲ្យដូចជាខ្លួនគោរពរបស់ខ្លួនដែរ ។ ការគោរពលទ្ធិសាសនាដទៃៗ ឈ្មោះថា ជួយលើកតម្កើងហើយជួយពង្រីកលទ្ធិសាសនារបស់ខ្លួនផង ហើយធ្វើប្រយោជន៍ចំពោះលទ្ធិសាសនាដទៃផងដែរ បើមិនដូច្នោះទេ ឈ្មោះថាជីករណ្តៅកប់លទ្ធិសាសនារបស់ខ្លួនឲ្យកប់បាត់ទៅ ព្រមទាំងធ្វើលទ្ធិសាសនាដទៃៗ ឲ្យវិនាសទៅផងដែរ ។ អ្នកណាមួយគោរពតែលទ្ធិសាសនារបស់ខ្លួន ហើយប្រទូស្តលទ្ធិសាសនាដទៃ គ្រាន់តែបានឈ្មោះថា ធ្វើឲ្យគេឯងបានដឹងថាខ្លួនមានភក្តិភាពចំពោះលទ្ធិសាសនារបស់ខ្លួន ដោយគិតថា “ អាត្មាអញបានលើកតម្កុំតម្កើងលទ្ធិសាសនារបស់ខ្លួនហើយ” ។ គំនិតនេះខុសស្រឡះទេ ការប្រព្រឹត្តនេះ ឈ្មោះថាបំផ្លាញលទ្ធិសាសនារបស់ខ្លួនដោយឥតសង្ស័យឡើយ ។ ដូច្នេះ សាមគ្គី

១- ព្រះរាជប្រកាស ព្រះបាទអសោកមហារាជ លេខ ១២ ។

ជាគុណធម៌ប្រសើរណាស់ សូមឲ្យអ្នកគ្រប់គ្នាស្ដាប់ ហើយសូមមេត្តាស្ដាប់វាទៈនៃលទ្ធិសាសនាដទៃផង ,, ។

ការសន្ដោសដោយសមានចិត្តនេះ ជាគុណធម៌ប្រសើរណាស់ ប្រសិនបើយកធម៌នេះមកអនុវត្តសម្រាប់ជាប្រយោជន៍ទូទៅ មិនមែនបានផលចំពោះតែលទ្ធិសាសនាទេ សូម្បីទុកជាច្បាប់សម្រាប់ប្រទេសជាតិ នយោបាយ សង្គមកិច្ច ឬសេដ្ឋកិច្ច ក៏រឹតតែបានផលប្រសើរណាស់ទៅទៀត ។

ខន្តីធម៌និងមេត្តាប្រោសប្រាណនេះ ជាឧត្តមគតិប្រសើរខ្ពង់ខ្ពស់ណាស់ ទុកជាវប្បធម៌និងអរិយធម៌នៃពុទ្ធសាសនា ចាប់ដើមតាំងពីពុទ្ធសាសនាកើតឡើង ។ ការបៀតបៀន (ហិង្សា = La violence) ទោះជាបែបណាក៏ដោយ ឬទោះជាប្រើលេសមកបន្ទំក៏ដោយ ក៏សុទ្ធតែផ្ទុយនឹងពុទ្ធវចនៈទាំងអស់ ។ ដោយពុទ្ធសាសនាមានលក្ខណៈ ប្រាកដដូច្នេះហើយ បានជាពិភពលោកមិនបានឃើញមានសង្គ្រាមការកាប់សម្លាប់គ្នាទុកជាឧទាហរណ៍ មានការស្រក់ឈាមមួយដំណក់ដោយការប្រកាសពុទ្ធសាសនា ឬផ្សាយពុទ្ធសាសនានេះឡើយ នៅក្នុងប្រវត្តិសាស្ត្រពុទ្ធសាសនាដ៏វែងប្រមាណជា ២៥០០ ឆ្នាំ ដែលកន្លងទៅនេះ ។ សព្វថ្ងៃនេះ ពុទ្ធសាសនាផ្សាយទូទៅពេញទ្វីបអាស៊ី ហើយជ្រួតជ្រាបរហូតទៅដល់ទ្វីបអឺរ៉ុបនិងអាមេរិកទៀត មានអ្នកចូលកាន់សាសន៍ពុទ្ធរាប់ប្រមាណ

ជាប្រាំរយលាននាក់ ។

មានប្រស្នាមួយទៀតកើតឡើងហើយ ។ គេតែងចោទសួរថា ពុទ្ធសាសនាជាលទ្ធិសាសនា (Religion) ឬជាទស្សនវិជ្ជា (Philosophie ? មានអ្នកខ្លះ ឆ្លើយដែរ ឆ្លើយដោយអាការ ដូចអ្នកទស្សនវិទូ គេឆ្លើយថា ពុទ្ធសាសនាមិនមែនជាលទ្ធិសាសនា (Religion) ទេ ទំនងជាទស្សនវិជ្ជា (Philosophie) ក៏មិនមែនទៀត ពុទ្ធសាសនាគឺ មិនមែនជាអ្វីទាំងអស់ ឬ ទំនងជាអ្វីដូចអ្នកគិតនោះក៏មិនមែនដែរ ពុទ្ធសាសនា គឺពុទ្ធសាសនា ។ សំនួរនេះ ជាការដាក់ស្លាកឬដាក់យីហោឲ្យពុទ្ធសាសនា មិនជាការអ្វីធំឬតាស់ខុសទេ ហៅថាដូចម្តេចក៏បាន ពុទ្ធសាសនាមិនយកចិត្តទុកដាក់ចំពោះស្លាកឬយីហោ ដែលគេដាក់ឲ្យខ្លួននោះទេ ។ ស្លាកឬយីហោ គ្រាន់តែជានាមបញ្ញត្តិ ស្លាកឬយីហោដែលគេសន្មតថា „ពុទ្ធសាសនានេះ ក៏មិនមានការសំខាន់អ្វីពេកណាស់ដែរ ។ នាមដែលគេដាក់ឲ្យនេះ មិនមែនជាការសារវន្តទេ ។

មានអ្វីក្នុងឈ្មោះ    ព្រះហើយពីកេះ ?
ដូចផ្កាកុលាប    បើគេហៅអ្វី
កុលាបពិសី    ក្រអូបដដែល ។

សច្ចធម៌មិនមានយីហោទេ គឺមិនមែនជាយីហោ "ពុទ្ធ គ្រិស្ត ហិណ្ឌូ មូស្លីម ឡៅត្សឺ ខុងត្សឺ ឈិនតូ „ ទេ ។ សច្ចធម៌មិនមែនជាឯកាធិភាព

(Monopole) របស់ជនណាតែម្នាក់ទេ ។ ស្លាក ឬ យីហោថា និកាយនេះ និកាយនោះ ជានីវរណធម៌ រាំងបាំងមិនឲ្យយល់សច្ចធម៌បាន ហើយបង្កើតជាឧបក្កិលេសដល់សន្តានចិត្តមនុស្ស ធ្វើចិត្តឲ្យសៅហ្មងទៀត ។

សេចក្ដីពិតធម៌នេះមិនមែនផ្ដល់សេចក្ដីវិនាសឲ្យតែខាងលទ្ធិសាសនា ឬខាងបញ្ញាតែប៉ុណ្ណោះទេ ធ្វើឲ្យចូលរហូតទៅដល់ការពាក់ទងរវាងមនុស្ស និងមនុស្សទៀតផង ឧបមាថា យើងជួបមនុស្សម្នាក់យើងមិនមែនគ្រាន់តែទុកគេថាជាមនុស្សប៉ុណ្ណឹងទេ យើងថែមទាំងទៅដាក់ស្លាក ឬ យីហោឲ្យពាក់ទៀតថាគេ ជាអង់គ្លេស ជាបារាំង ជាអល្លឺម៉ង់ ជាអាមេរិកកាំង ឬជាជីហ្វ ម្ល៉ោះហើយចិត្តយើងក៏ជាប់នៅក្នុងស្លាក ឬ យីហោនោះឯង ។ ជួនកាលមនុស្សដែលយើងសំគាល់នោះ មិនមែនជាជាតិដែលយើងដាក់ស្លាក ឬ យីហោឲ្យនោះផង ។.

មនុស្សលោកចូលចិត្តដាក់ស្លាក ឬ យីហោណាស់ ដាក់រហូតទៅដល់គុណធម៌ដ៏ប្រសើររបស់មនុស្សលោកទៀត ។ នេះជាសន្តានចិត្តនៃមនុស្សសាមញ្ញទូទៅក្នុងពិភពលោក ។ ដូច្នេះហើយ បានជាយើងឃើញមានស្លាកឬយីហោ នៃការឲ្យទាន (Charité) គេថា នេះទានពុទ្ធ ទានគ្រិស្ត ទានហិណ្ឌូ ហើយមើលងាយទាននៃជនទាំងនោះថាជាទានមិនមានអានិសង្ស ។ សេចក្ដីពិត ទានគឺទាន ប្រាកដជាទានៗ មិនមែនជាពុទ្ធ ជាគ្រិស្ត ជាហិណ្ឌូ ឬជាមុស្លីម ទេ ។ ព្រហ្មវិ.

ហារធម៌នៃមាតាបិតា មិនមែនជាពុទ្ធ មិនមែនជាគ្រិស្ត មិនមែនជាហិណ្ឌូ ឬជារបស់អ្នកណាទេ គឺជារបស់មាតាបិតា ។ គុណធម៌ ឬទោសធម៌ដែលកើតក្នុងសន្តានចិត្តមនុស្ស ដូចសិនេហធម៌ សប្បុរសធម៌ ករុណា ខន្តី វីរិយៈ មិត្តភាព រាគៈ ទោសៈ មោហៈ មានៈ-ធម៌ទាំងអស់នេះ មិនមែនជាស្លាក ឬ ជាយីហោនៃនិកាយទេ មិនមែនជាធម៌នៃលទ្ធិសាសនាណាមួយពាំពោះទេ ។ បុណ្យ បាប ដែលកើតឡើង កុសលចិត្តនិងអកុសលចិត្ត មិនមែនកើតចំរើនឡើង ឬ អន់ថយទៅវិញ ដោយសារតែយើងជួបមនុស្សដែលកាន់លទ្ធិសាសនានោះទេ ។

អ្នកស្វែងរកសច្ចធម៌ មិនមានប្រយោជន៍អ្វីនឹងដឹងថា សច្ចធម៌នេះកើតមកពីណាទេ ។ ការរកកំណើត ឬ ការចំរើនឡើងនៃឧត្តមគតិនេះ ជាភារៈនៃអ្នកប្រវត្តិសាស្ត្រដោយឡែក ។ ដើម្បីលុះសច្ចធម៌ មិនបាច់នឹងដឹងថា ពុទ្ធវចនៈនេះ ជាធម៌អង្គព្រះសម្ពុទ្ធ ឬរបស់លោកអង្គណាក៏បាន ។ កិច្ចការដែលជាសារវន្តនោះ គឺការឃើញធម៌ពិត ហើយបានលុះធម៌នោះដោយប្រពៃ សេចក្តីនេះ មានឧទាហរណ៍ពិតប្រាកដនៅគម្ពីរមជ្ឈិមនិកាយ(១) ដូចសេចក្តីទៅនេះ ៈ ។ (នៅមានត)

---

១- មជ្ឈិមនិកាយ ឧបរិបណ្ណាសក ធាតុវិភង្គសូត្រ សៀវភៅទី ២៨ ទំព័រ ១៧០ ។

## ផ្នែកអក្សរសាស្ត្រ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ទាំង-ខាត់ រៀបរៀង*

អភិវិបញ្ច ធាតុ ពេញចិត្តក្រៃលែង ។

អភិវិសឫជ ធាតុ បោះបង់ចោល ។

អភិវិហា ធាតុ ចេញចាក ។

អភិវិក្ឞ (ត្វៀក្ឞ) ធាតុ ក្រឡេកមើល. មៀងមើល ។

អភិវីជ់ ធាតុ វះពោះ ។

អភិវ្ឫ ធាតុ បិទផ្លូវ ។ -វ្ឫត គុ. ដែលព័ទ្ធជុំវិញ ។

អភិវ្ឫ ធាតុ ជ្រើសរើស ។– វ្ឫត គុ. ដែលជ្រើសរើស ។

អភិវ្ឫត៑ ធាតុ ចូលទៅជិត, កិរិយាចូលវាយ, កិរិយាចាប់ផ្ដើម។

អភិវ្ឫទ្ធិ ស្ត្រី. អភិព្រឹទ្ធិ កិរិយារីក, កិរិយាចំរើន ។

អភិវ្ឫធ៑ ធាតុ ចំរើន, លូតលាស់, រីក; កបន្ទាយ ។

អភិវ្ឫឞ៑ ធាតុ ភ្លៀង, ជន់លិច ។– វ្ឫឞ្ត គុ. ដែលជោរជន់,

ដែលឲ្យភ្លៀង ។

អភិវេដ្ឋ ធាតុ គ្រប, បិទបាំង ។

អភិវ្យក្តិ ស្ត្រី. អភិវ្យក្តិ កិរិយាកើតឡើង, កិរិយាធ្វើឲ្យប្រាកដ ធ្វើជាតុកម្ម ។

អភិវ្យញ្ជ ធាតុ លេចឡើង ។—ក្ត គុ. ដែលលេចឡើង, ដែលច្បាស់ ។

អភិវ្យញ្ជក គុ. ដែលធ្វើឲ្យប្រាកដឡើង ។

អភិវ្យញ្ជន នបុំ. អភិវ្យញ្ជន៍, កិរិយាបើកបង្ហាញ ។

អភិវ្យធ ធាតុ ធ្វើឲ្យរបួស, បាញ់ត្រូវ ។

អភិវ្យាហារ បុំ. អភិវ្យាហារ កិរិយាថ្លាថ្លែង, សម្តី ។

អភិវ្យាហ្ឫ ធាតុ និយាយ, ថ្លែង ។ – ហ្ឫត នបុំ. រឿងដែលសំដែងហើយ ។

អភិវ្យុទស៍ ធាតុ បោះបង់ចោលទាំងអស់ ។

អភិវ្រជ៍ ធាតុ ដើរត្រង់, ដើរតម្រង់ ។

អភិឝម្ស៍ ធាតុ សរសើរ ។ ខ្ទួល ។

អភិឝម្សន នបុំ. កិរិយាដេរ, កិរិយាតិះដៀល ។

អភិឝម្សិន៍ គុ. ដែលចោទទោស ។

អភិគកិ ធ.គុ. បង្រៀន ។

អភិគង្ក ធ.គុ. សង្ស័យ ។

អភិគង្កា ស្រ្តី. អភិសង្កា, កិរិយាសង្ស័យ ។ - សង្កិត គុ. ដែលសង្ស័យ ។

អភិគត្រ ក្រ.វិ. ដោយសត្រូវចំពោះបច្ចាមិត្រ ។

អភិគប៉ ធ.គុ. ប្រទេច ។ -គប្ត គុ. ដែលប្រទេច ដែលប្រវញ្ច។

អភិគព្ទិត គុ. ដែលកត់សម្គាល់, ដែលតែងតាំ ។

អភិគម៉ ធ.គុ. ឈប់, ស្ទេះទុក ។

អភិគស្ត គុ. ដែលចោទទោស ដែលតិះដៀល ដែលជេរ ។

អភិគាន្ត- បុំ. ភាវៈនៃកិរិយាធ្វើដោយក្មេងកម្សាន្ត ។

អភិគាបិ បុំ. កិរិយាធ្វើឆ្អប់ កិរិយាដាក់ស្នេហ៍ ។

អភិគាស៊ ធ.គុ. គ្រប់គ្រង ។

អភិគុប៊ ធ.គុ. កាន់ទុក្ខ សោយសោក ។

អភិគោភិត គុ. ដែលលំអ ដែលតុបតែង ។

អភិគោប បុ. កិរិយាហាល កិរិយាធ្វើឲ្យស្ងួត ។

(នៅមានទៀត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

នូ-កាន

ប្រែ-រៀបរៀង

(ត)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ   អ្នកភាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលចំណាន   ទាំងមានសន្ដានស្នេហាជាតិ
>
> យូរ-អ៊ុន

បេងហោកឆ្លើយថា ដែលលោកទឹងឲ្យយើងព្រមចំណុះចុះចាញ់នោះ មិនត្រូវសោះ ពីព្រោះយើងមិនមែនចាញ់ដោយថ្វីដៃរបស់លោកទេ គឺអៀវហាងកៀនសំឡាញ់របស់យើងធ្វើកលឧបាយឲ្យយើងទុកចិត្ត ហើយគិតចាប់យើងមកឲ្យលោក, បើលោកទឹងសម្លាប់យើង ក៏តាមចិត្តទៅចុះ ឯយើងមិនចំណុះចុះចូលជាដាច់ខាត ៗ ខុងបេងថា ត្រោះទះអ្នកឯងតែដោះខ្លួនពីយើងមកនៅក្នុងទីចង្អៀតពិបាក ប្រាថ្នានឹងបញ្ឆោតយើងនិងពួកម៉ាក ឲ្យអន្តរាយជីវិតដោយទឹកសាក្រក់មានពិស កណ្ដាលផ្លូវ តែហាក់ថា ទេព្ដាលោកមកជួយគម្រង់បម្រុងរក្សាយើង ឲ្យរួចមកបានដល់ទីនេះហើយ ម្ដេចឡើយអ្នកឯង នៅតែកាន់ទិដ្ឋិមានះ មិនព្រមចំណុះចុះចាញ់យើងដល់ណាទៀត ?

ចេងហោកថា បើយើងនៅក្នុងស្រុកនិងទៃ មានទីស្នាក់ពឹង បន្ទាយជាមាំមួន ហើយលោកចាប់យើងបាននៅទីនោះ យើងក៏គួរចំណុះលោកតកូនចៅចៅសន្ដាន, នេះយើងមិនមែននៅក្នុងទីនោះ ចំពោះមកនៅទីដទៃ បានជាមានសេចក្ដីក្ដោយថ្ងស់ ឲ្យលោកបញ្ឆោតចាប់បាន ដូច្នេះ, យើងមិនអស់ចិត្តនឹងចាញ់សោះ ។

ខុងបេងឮដូច្នោះក៏គិតថា បេងហោកនៅមានមានះនៅឡើយ, គិតហើយក៏ថា បើដូច្នោះ យើងនឹងលែងអ្នកឯងទៅម្ដងទៀត, អ្នកឯងត្រូវទៀតរកទីជយភូមិឲ្យមួនមាំ ហើយត្រូវខំបម្រុងសេនាទាហាន ឲ្យព្រមព្រៀងទុកចុះ, យើងនឹងលើកទ័ពទៅតស៊ូនឹងអ្នកឯង ១ ក៏នឹងបានឃើញថ្វីដៃយើងជាប្រាកដ, បើយើងចាប់អ្នកឯងបានម្ដងទៀត ហើយនៅតែនិយាយដូច្នេះ យើងនឹងសម្លាប់ឲ្យអស់ទាំងដួរគោត្រ, ថាហើយបង្គាប់ឲ្យស្រាយចំណងបេងហោកចេញ, បេងហោកក៏លាខុងបេងចេញទៅ, ខុង-បេងក៏ឲ្យទាហានស្រាយចំណងបេងហ៊ុំ និងគោស៊ូតៃអង់ចេញទៅ រួចក៏តាំងអៀវហាងជាទីមន្ត្រីធំ ហើយឲ្យបំណាច់រង្វាន់ដល់ស្រីទាំង ១០ នាក់ និងទាហានទាំងពួងតាមសមគួរ, អៀវហាង ក៏លាខុងបេងទៅកាន់ទីឋានវិញ, ឯបេងហោក បេងហ៊ុំ និងគោស៊ូតៃអង់ ក៏ស្រូតនាំគ្នាទៅទាំងយប់ទាំងថ្ងៃ ដល់ស្រុកសាំកាំង, ក្រៅស្រុកនោះ មានស្ទឹងព័ទ្ធទាំង ៣ ជ្រុង ក្រៅពីនោះទៀត ខាងទិសឯជើងជាទីរាបទូលាយប្រមាណ ៤០០ ហ៊ិន

(១៦គីឡូម៉ែត្រ) មានផ្លែឈើផ្សេងៗជាច្រើនណាស់, ខាងទិសឯលិច ២០០ សិន (៨គីឡូម៉ែត្រ) ជាវាលស្រែអំបិល, ខាងទិសឯត្បូង ជិតក្បែរស្រុក ៣០០សិន (១២គីឡូម៉ែត្រ) ដល់ស្រុកលង់តតង់ហើយ ទើបដល់ទៅស្រុកគ្រុងមានកំពែងជុំវិញ; ក្នុងស្រុកនោះ មានភ្នំធំ ១ ឈ្មោះជិនខែ, លើកំពូលភ្នំនោះមានប្រាសាទឈ្មោះគង់តៀន មានបន្ទាយជាទីលំនៅពៅមិនអង់, ក្បែរប្រាសាទនោះមានសាលទេព្រក្សជាសម្រាប់ផែនដីជាទីសក្តិ-សិទ្ធិ, ពួកអ្នកស្រុកឆ្ងាយជិតទាំងពួងរមែងជឿកប់អានកាន់ តែងកំណាន់ឡើងទៅតាំងគ្រឿងសែនថ្វាយ ទៅកែគុយ នៅលើសាលា ១ ឆ្នាំ៤ដង, អ្នកដែលសម្រាប់ប្រតិបត្តិទទួលគ្រឿងសែននោះឈ្មោះ ប៉ក គុយ, ហើយអ្នកស្រុកទាំងពួង ត្រូវជូនទៅចាប់មនុស្សពីដែនស្រុកសែឈួន យកមកសែនគ្រប់ឆ្នាំមិនដែលដាច់, បើរកមិនបាន ក៏បណ្តាលឲ្យឈឺថ្កាត់ជារោគវិបត្តិផ្សេងៗ ។

ប្រការ ១ ក្នុងស្រុកជិនខែនោះ មិនមានរបៀបច្បាប់សម្រាប់ស្រុកទីងទំនុកបម្រុងតាមទំនៀមទម្លាប់ ដូចជាច្បាប់ស្រុកឯទៀតនោះទេ, បើនរណាហើយធ្វើឲ្យទៅហ្វាយស្រុកនោះទាស់អធ្យាស្រ័យ ដោយប្រការអ្វីនីមួយ ក៏ឲ្យយកខ្លួនទៅសម្លាប់ចេញ, ប្រសិនបើមនុស្សនោះមិញជាស្រីបរទេសនៅក្នុងស្រុកនោះ ទឹងធ្វើល្មើសក្រៅពាក្យមាតាបិតាឬស្វាមី ក៏មិនបាន ឲ្យមានទោស, មួយៈទៀត បើមានភ្ញៀវធ្លាក់មកមិនបរិបូណ៌ ខ្វះ

ខាតដោយស្រូវអង្ករស្បៀងអាហារ ពួកអ្នកស្រុកពល់គ្នា ក៏យកសាច់សត្វមានជីវ៍ នេះ ជាដើមបរិភោគចិញ្ចឹមជីវិត ។

ឯចេងហោកនោះ លុះទៅដល់ស្រុកនិទរៃហើយ ក៏ចេះតែបញ្ចុះបញ្ចូលពលទាហាន បានប្រមាណ ១.០០០ បាយ, ចេងហោកក៏និយាយនឹងទាហានទាំងពួងថា យើងធ្វើសឹកមកនឹងខុនចេង ក៏ចាញ់ប្រៀបគេច្រើនគ្រា បានសេចក្ដីវេទនា គួរឲ្យអាប់យសណាស់ អស់អ្នកពល់គ្នាដែលមានប្រាជ្ញាស្មារតី ចូរមានសេចក្ដីឈឺចិត្តគិតជួយយើងឲ្យកែខ្លួនបានឡើងវិញ ធ្វើម្ដេចមិញនឹងបានមានជ័យជម្នះខុនចេងឲ្យបាន, តួហៃហូ ជាប្អូនប្រពន្ធចេងហោកឆ្លើយថា បើខុនចេងលើកទ័ពតាមមក ខ្ញុំបាននឹងសុំយកអាសាសងសឹកឲ្យបាន, ចេងហោកថា អ្នកឯងមានប្រាជ្ញានឹងគិតធ្វើម្ដេច ។

តួហៃហូឆ្លើយថា បុកឡុកតែអង ចៅហ្វាយស្រុកប៉ុតហ៊ុំបតង់ នៅខាងទិសឯលិចស្រុកយើងនេះ មានសេចក្ដីចេះដឹងឈ្លៀវឈ្លាស បើឡើងជិះលើដំរី ហើយកាយមន្តគាថា ហៅឲ្យកើតខ្យល់ព្យុះសង្ឃ្រា ហៅដុំថ្មសិលា ឲ្យខ្ទាតកណ្ដាតទៅត្រូវខ្មាំងសត្រូវ ឬហៅសត្វអាសិរពិសកាចផ្សេងៗ មកប្រើក៏បានតាមប្រាថ្នា ហើយមានព្រាយមាយាជាបិសាចអាចចេះសម្ដែងរិទ្ធិប្រមាណ ៣០.០០០ តាមជិតដោយឲ្យប្រើប្រាស់ មិនចេះដាច់, សូមឲ្យលោកតែងសំបុត្រ ១ ច្បាប់ នឹងចាត់គ្រឿងប្រដាប់ ជា

បណ្ណាការឲ្យមានតម្លៃ ខ្ញុំបាទនឹងនាំទៅគំនាប់ ប្រស្រ័យដល់ពុកឡុក-តៃអង់ សុំអង្វរឲ្យលើកទ័ពមកជួយលោកជាបង់ឲ្យបាន, ការដែលយើងគិតទាំងប៉ុន្មាន ក៏នឹងសម្រេច ។

បេង់ហេកបានឮហើយ ក៏ត្រេកអរណាស់ ក្រោកឡើងរហ័សទៅសរសេរសំបុត្រតាមគំនិតដែលគិតឃើញគ្រប់ប្រការ ហើយចាត់នូវរបស់ជាគ្រឿងបណ្ណាការប្រគល់ឲ្យគួៃហួ ។ ក៏គំនាប់នាំរបស់ទ្រព្យនិងសំបុត្រចេញទៅ, ឯបេង់ហេកនោះកូវ ក៏ចាត់ប្រើតោស៊ូតៃអង់ ឲ្យនាំពួកទា-ហានមួយកងទៅឈរក្បែរស្រុកសាំកាំង ។

ខុងបេង់ក៏លើកកងទ័ពតាមបេង់ហេកទៅដល់ស្រុកសាំកាំង ហើយឲ្យជូឡុងនិងអ៊ុយអៀន នាំទាហានលើកទៅព័ទ្ធស្រុក ខាងទិសឯជើង, នោះតោស៊ូតៃអង់ ក៏ឲ្យទាហានដែលចំណានស្ទាត់ (បាញ់ស្នា) ឡើងរក្សាសើនបន្ទាយ ជាមាំមួនណាស់, ទាហានទាំងនោះ ក៏ត្រៀមស្នាសម្រាប់ដែលាបថ្នាំពិស បើបាញ់ត្រូវអ្នកឯណា ក៏រលួយបែកទាល់ស្លាប់, លុះជូឡុងលើកទាហានចូលទៅជិត, ទាហានលើកំពែង ក៏យកស្នាបាញ់ចម្រុះត្រូវទាហានជូឡុងរបួសពិការស្លាប់ជាច្រើន, ជូឡុងនិងអ៊ុយអៀនក៏ថយត្រឡប់ទៅរកខុងបេង ។ ឃើញទាហានត្រូវ (ព្រួញ) របួសពិការជាសាហាស ក៏យកថ្នាំកទៅគ្លូរលាបឲ្យពិស (ព្រួញ) នោះ ក៏សះជាបាត់

ហើយក៏ឡើងរទេះបរសំដៅទៅមើល ឃើញគូមិនមានរបៀបរៀបរយ, ខុងបេងក៏ថយទ័ពត្រឡប់ចេញទៅតាំងបន្ទាយជាមាំមួន ចម្ងាយពីទីក្រុង ៦០ សិន (២,៤០០ ម៉ែត្រ), ទាហានក្នុងស្រុក សាំកាំង ឃើញខុងបេងថយទ័ពត្រឡប់ចេញ ទៅតាំងបន្ទាយពីចម្ងាយ ក៏មានសេចក្ដីមើលងាយប្រមាថធ្វេសសម្គាល់ថា ខុងបេងចាញ់ថ្វីដៃនៃខ្លួន មិនហានតស៊ូ ។

លុះខុងបេងថយចេញទៅតាំងនៅទីនោះអស់រវាង ៧ ថ្ងៃ ក៏កើតព្យុះខ្យល់បក់បោកមកក្នុងបន្ទាយ, ខុងបេងក៏និយាយបង្គាប់ទាហានទាំងពួងថា យើងនឹងត្រូវការយកខោអាវឲ្យបានក្នុងម្នាក់ ១ ប្រដាប់គ្រប់គ្នា ក្នុងវេលាថ្ងៃនេះ បើនរណាមិនបាន យើងនឹងកាត់ក្បាលអ្នកនោះចេញ, អស់ពួកទាហាននោះមិញ ឮដូច្នោះ ក៏ទឹកសន្ទុះសង្ស័យណាស់ តែខ្លាចអាជ្ញាខុង-បេងជាម្ចាស់ ក៏នាំគ្នាទៅរកខោអាវបានម្នាក់១ ប្រដាប់ចូលទៅជូនខុងបេង, លុះដល់ពេលយាម ១ ខុងបេងក៏ឲ្យទាហានយកគ្រឿងសម្លៀកនោះរុំបត់ម្នាក់ ១ដុំ លើកចូលទៅតម្រល់ទឹងកំពែងស្រុក ទាល់តែខ្ពស់ឡើងស្មើនឹងសន្ទឹកសីមា ហើយនិយាយនឹងទាហានទាំងនោះថា បើនរណាចូលទៅក្នុងស្រុកបានមុនគេ យើងនឹងឲ្យបំណាច់រង្វាន់ឲ្យពេញចិត្ត; អស់ពួកទា-ហាន បានឮខុងបេងដាក់កម្រិតដូច្នោះ ក៏ស្ទុះដណ្ដើមគ្នាចូលទៅបានជាច្រើន ហើយសញ្ញាគ្នាដេញកាប់សម្លាប់ខ្មាំងជាជ្រួលច្របល់, តោស៊ីតែអង

មិនទាន់ដឹងកលការច្បាស់ជាសត្រូវចូលទៅពីដើមពីត្បូង ក៏ឡើងសេះនាំទាហានចេញពីបន្ទាយ, ទាហានខុនបេងឃើញ ក៏ពារម្ខាយដេញសន្ធុញតាមហើយយកលំពែងចាក់ត្រូវតោស៊ូថៃអង់ធ្លាក់ពីលើសេះស្លាប់, កងទ័ពក៏បែកធ្លាយខ្ចាត់ខ្ចាយគ្នា ខ្ចបស្រុកក្នុងគ្រានោះ ខ្លះក៏រត់ទម្លុះទៅរកបេង-ហោក ប្រហែលពាក់កណ្ដាល, ខុនបេងមានជ័យជម្នះ ក៏លើកទ័ពទាំងអម្បាលនោះចូលទៅតាំងនៅក្នុងស្រុកសាំកាំង ហើយក៏ចាត់ការឲ្យត្រួតរាំងរក្សា ហើយគិតនឹងលើកទៅស្រុកផិនឡែទៀត ។

ឯបេងហោកដឹងថា ខុនបេងវាយបានស្រុកសាំកាំងហើយ ក៏មានសេចក្ដីព្រួយខ្វាំងណាស់ ខណៈនោះមានទាហានចូលទៅប្រាប់ថា ខុន-បេងលើកទាហានចូលពីត្រើយម្ខាងចូលមកដែនខាងនេះហើយ, បេងហោកក៏ស្លុតព្រលឹងរឹងអស់ទាំងខ្លួន, គ្រានោះនាង ចុកយ៉ុង ជាភរិយាបេងហោកលបអែបស្ដាប់ពីក្នុងផាក ក្រឡេកឃើញប្ដីភ័យយ៉ាងលំបាកដូច្នោះ ក៏ស្ទុះចេញមកហើយអស់សំណើចថា ខ្លួនអ្នកជាប្រុសឈ្មោះថាជាជាតិទាហានមានថ្វីដៃ គួរអៀមគស់សេចក្ដីគិតនឹងការសឹកប៉ុណ្ណោះ, អ្នកកុំបីព្រួយជាទុក្ខឡើយ, ឯខ្ញុំឯងហើយជាកូនស្រី នឹងសុំចេញទៅយកអាសាអ្នកជាស្វាមីធ្វើសឹកតថ្វីដៃនឹងខុនបេងឲ្យបាន, បេងហោកបានឮភរិយាថាដូច្នោះក៏នឹកឡើងបានថា នាងចុកយ៉ុង ដែលជាមនុស្សមានវិជ្ជាការប្រើអាវុធ-សាស្ត្របានដូចចិត្ត, បើសត្រូវដេញជិតចូលមក ក៏ពោះអាវុធនោះឡើង

ទៅលើអាកាសវេហាស៍ ដោយអំណាចនៃវិជ្ជានោះក៏បណ្ដាលឲ្យអាវុធធ្លាក់ចុះ រុះរាយទៅត្រូវលើសត្រូវទាំងឡាយឲ្យវិនាសអន្តរាយបាន ឃើញល្មមនឹងតស៊ូច្បាំងយកជ័យជម្នះខុនបេងបាន, បេងហោកគិតហើយ ក៏ឲ្យមានសេចក្ដីត្រេកអរពន់ប្រមាណណាស់ គំនាប់ទទួលគួរសមនឹងកិរិយា ហើយម្នីម្នាចេញទៅ ជ្រើសរើសបានទាហានឯក ១០០ នាក់ និងទាហានរេ ៥០.០០០ ប្រគល់ឲ្យនាងចុកយ៉ុងជាកិរិយា, នាងក៏គំនាប់លាស្វាមីលើកយោធានិករចេញចាកស្រុកទៅ, ខណៈនោះ, ទទួលទៀវង៉ឺ និងម៉ាតង់ជាទាហានខុនបេង លើកមកដល់ទទួលតទល់គ្នា ។

នាងចុកយ៉ុងឃើញកងទ័ពជួបគ្នា ក៏តែងខ្លួនកាន់អាវុធវិសេសសៀតបង្កប់ពីក្រោយខ្នង ៤ អាវុធ ហើយឡើងជិះសេះកាន់លំពែងវែង ៣ ព្យាម រាំក្បួនអាវុធចូលប្រយុទ្ធគ្នានឹងទៀវង៉ឺបាន ៩ ក្បួន នាងចុកយ៉ុងធ្វើជាចាញ់ញាក់សេះរត់, ទៀវង៉ឺមិនបានដឹងកលឧបាយ ក៏បំផាយសេះដេញតាមនាងចុកយ៉ុង, នាងចុកយ៉ុង ក៏ក្រឡាក់ដកយកអាវុធវិសេសបោះឡើងទៅលើអាកាស, អាវុធនោះក៏ធ្លាក់ចុះមកត្រូវទៀវង៉ឺធ្លាក់ពីលើសេះ, ទាហានទាំងអស់ ក៏ស្ទុះស្រូចូលទៅចាប់ខ្លួនទៀវង៉ឺចងបាន, ម៉ាតង់ឃើញដូច្នោះ ក៏បំបោលសេះចូលទៅដណ្ដើមទៀវង៉ឺ ក្រឡេកឃើញនាងចុកយ៉ុងបញ្ឈរសេះកាន់លំពែងនៅពីមុខ ក៏នឹកខឹងណាស់ បំផាយសេះចូលទៅច្បាំងនឹងនាងចុកយ៉ុង នៅមិនទាន់ចាញ់ - ឈ្នះគ្នា, នាងចុកយ៉ុង ធ្វើកលយក

ខ្សែព្រួរបោះទៅរុំជើងសេះដួលចុះ, ម៉ាតង់ក៏របូតធ្លាក់ពីលើសេះ, នាងចុកយ៉ុង ក៏ឲ្យទាហានស្ទុះទៅចាប់ចងខ្លួនម៉ាតង់បាន ហើយឲ្យនាំខ្លួនទៀវង៉ីនិងម៉ាតង់ចូលទៅក្នុងស្រុក ។

បេងហោកឃើញដូច្នោះ ក៏មានអំណរណាស់ ទើបតែងតុលៀងអាហារឲ្យនាងចុកយ៉ុងបរិភោគផឹកសុរា, នាងចុកយ៉ុង ក៏បង្គាប់ទាហានឲ្យយកទៀវង៉ី និងម៉ាតង់ទៅសម្លាប់, បេងហោកឆ្លើយឡើងថា យើងបានធ្វើការទឹងខុងបេង ៗ ចាប់បានយើង ៤ ដងហើយនៅទុកជីវិតយើងលែងមកវិញមិនបានធ្វើអន្តរាយ, វេលានេះ បើយើងនឹងសម្លាប់ទៀវង៉ី-ម៉ាតង់ចេញឃើញមិនគួរសោះ, មនុស្សទាំងពួង ក៏នឹងតរហានិន្ទាបាន, គួរតែយើងបង្អង់ទានកុំសម្លាប់សិនចុះ បើយើងចាប់បានខុងបេងទាំងរស់ វេលាណាសឹមសម្លាប់ឲ្យព្រមគ្នាតែម្តង, នាងចុកយ៉ុងយល់ឃើញត្រូវផង ទើបឲ្យទាហានយកខ្លួនទៀវង៉ី-ម៉ាតង់ទៅឃុំទុក ។

ឯទាហានទៀវង៉ីដែលបែកខ្ញីតទៅនោះ នាំរឿងហេតុទៅជម្រាបខុងបេងគ្រប់ប្រការ, ខុងបេងក៏ឲ្យហៅម៉ាតាយមកបង្គាប់ថា ត្រូវឲ្យអ្នកឯងនាំទាហានទៅចាំនៅផ្លូវតូច បើឃើញនាងចុកយ៉ុងដេញដូឡុងនិងអ៊ុយអៀនមក ឲ្យយកខ្សែព្រួរទាក់ជើងសេះចាប់យកខ្លួននាងចុកយ៉ុងឲ្យបាន, ម៉ាតាយទទួលប្រសាសន៍ហើយ ក៏ចេញទៅចាត់ការ នាំទាហានទៅបង្កប់តាមទីកន្លែង, ហើយខុងបេងក៏បង្គាប់ដូឡុងនិងអ៊ុយអៀនឲ្យនាំទាហានទៅច្បាំង

គាដែនទឹងនាងចុកយ៉ុង ហើយឲ្យធ្វើជាចាញ់ បញ្ជាតឲ្យដេញទៅតាមផ្លូវដែលម៉ាតាយបន្ទប់នៅនោះ, ជួឡុងនិងអ៊ុយអៀន ក៏ទទួលបង្គាប់ខុង-បេង ហើយលើកទាហានចេញទៅ ។

លុះដល់ពេលព្រឹក មានពួកល្បាតទៅប្រាប់បេងហេកថា ជួឡុងលើកទាហានចូលមកច្រើនណាស់, នាងចុកយ៉ុងបានឮច្បាស់ក៏ឡើងសេះលើកទាហានចេញទៅច្បាំងនឹងជួឡុងបាន ៩ ក្បួន, ជួឡុងញាក់សេះវេះត្រឡប់ទៅក្រោយ បណ្ដោយឲ្យដេញជាកលបញ្ឆោត, នាងចុកយ៉ុងខ្លាចក្រែងខុងបេងនឹងប្រើកលឧបាយ ក៏ថយទាហាន ទឹងត្រឡប់ចូលទៅក្នុងស្រុកវិញ, អ៊ុយអៀនឃើញដូច្នោះ ក៏បង្រុះទាហានទន្ទ្រានដេញតាមទៅ, នាងចុកយ៉ុងក៏កន្ត្រាក់សេះប្រែមកតដៃនឹងអ៊ុយអៀនវិញ, អ៊ុយអៀនធ្វើជាចាញ់ទាញសេះរត់, នាងចុកយ៉ុងក៏បញ្ឈប់កងទ័ពតាំងភ្ជាប់នៅក្រៅស្រុក ១ យប់, លុះពេលព្រឹកឡើងជួឡុងក៏នាំទាហានចូលទៅបបួលច្បាំងទៀត, នាងចុកយ៉ុង ក៏បំបោលសេះចេញមកតដៃនឹងជួឡុងបាន ៤ ក្បួន, ជួឡុងញាក់សេះរត់, នាងចុកយ៉ុងក៏មិនបានលើកតាម ត្រឡប់សេះទឹងចូលទៅក្នុងស្រុក, អ៊ុយអៀនឃើញដូច្នេះ ក៏បំផាយសេះតាមទៅ ហើយស្រែកជេរនាងចុកយ៉ុងជាពាក្យទ្រគោះអសុរសផ្សេង ៗ, នាងចុកយ៉ុងឮហើយក៏ខឹងណាស់ ត្រឡប់វិលមកច្បាំងនឹងអ៊ុយអៀន ៗ បំផាយសេះរត់ទៅ ហើយ

ចេះតែស្រែកជេរបញ្ចោរបណ្ដើរ, នាងចុកយ៉ុងក៏បំផាយសេះតាមទៅដោយកម្លាំងទោសៈ លុះទៅដល់ផ្លូវតូចក្បែរជើងភ្នំ ដែលម៉ាតាយបង្កប់ទាហាននៅនោះ, ម៉ាតាយក៏ឲ្យទាហានស្ទុះស្រែចេញមក យកខ្សែព្រួរទាក់ជើងសេះដួលចុះ, នាងចុកយ៉ុងក៏ខ្ទាត់ធ្លាក់ពីលើសេះ, ម៉ាតាយនិងទាហានក៏ស្ទុះពានទៅចាប់ខ្លួននាងចុកយ៉ុងបាន ហើយចងនាំទៅជូនខុងបេង, ចូឡុងក៏ដេញកាប់សម្លាប់កងទ័ពនាងចុកយ៉ុងស្លាប់ជាច្រើនណាស់ ខ្លះក៏រត់ត្រឡប់ចូលទៅក្នុងស្រុកបាន ។

ខុងបេង ឃើញម៉ាតាយចាប់បានខ្លួននាងចុកយ៉ុងនាំទៅជូន ក៏មានអំណរណាស់ ឲ្យទាហានស្រាយចំណងចេញ ហើយអញ្ជើញនាងចុកយ៉ុងឲ្យឡើងតុផឹកស្រា ហើយខុងបេងប្រើមេម្រើឲ្យចូលទៅប្រាប់បេងហេកថាឲ្យបង្វិលខ្លួនទៀវធីនិងម៉ាតងមកឲ្យវិញចុះ ទើបនឹងបើកខ្លួននាងចុកយ៉ុងឲ្យរួចទៅ, ផងណោះបេងហេកបានឮដូច្នោះ ក៏ដោះលែងខ្លួនទៀវធី និងម៉ាតងវិលទៅដល់បន្ទាយខុងបេង ទើបខុងបេងបើកលែងខ្លួននាងចុកយ៉ុងទៅ, បេងហេកឃើញភរិយាចូលមកក៏មានអំណរណាស់ ទទួលទាហានចូលមកប្រាប់ថាបុកឡុកលើកទ័ពមកដល់, បេងហេកក៏មានអំណរណាស់ចេញទៅទទួលដល់ក្រៅស្រុក ឃើញបុកឡុកតែអង្គ ពាក់អាវចានមាសប្រដាប់ត្បូងពេជ្រសៀតគ្រប់ជាំផ្ទៃ ២ ជិះដំរីសម្បុរលឿងចញ្ចេះកណ្ដាល

រណារង្គ មានទាហានដែលជាទ្រមាក់សម្រាប់ជិះសត្វកាច ១ ពួក, ចេង-ហោក ក៏ចូលទៅគំនាប់សាសព្វសេចក្ដីឲ្យបុកឡុកតែអង់ស្ដាប់គ្រប់ប្រការៗ

បុកឡុកតែអង់ថា អ្នកកុំវិតក្កទៀយ ខុងចេងធ្វើការមក ហើយឲ្យអ្នកបានសេចក្ដីអាប់យសនោះ យើងនឹងទទួលជួយជាធុរៈសងសឹក, ចេង-ហោកបានស្ដាប់ ក៏ចាប់ចិត្តរឹតតែសោមនស្សត្រេកអរ អញ្ជើញបុកឡុក-តែអង់ចូលទៅក្នុងស្រុក ហើយតែងតុលៀងអាហារស្រាបាយ ពួកពលទាំងឡាយ ក៏ឲ្យចរិកាគផារច្រើនណាស់, លុះវេលាព្រឹក បុកឡុកតែអង់ក៏លើកកងទ័ពចេញអំពីស្រុក តម្រង់ទៅបន្ទាយខុងចេង, ខុងចេងឃើញដូច្នោះ ក៏ចាត់ឲ្យជូឡុងនិងអុិយអៀន លើកពលចេញតខាងក្រៅបន្ទាយ, លុះឃើញបុកឡុកតែអង់លើកមកដល់ ជូឡុងនិងអុិយអៀន ក៏បំផាយសេះចេញទៅបំពារមុខទ័ព ឃើញទង់ជ័យក្បួនទ័ពរៀបរយ តែឃើញពួកពលទាំងឡាយមិនមានពាក់អាវក្រោះសោះ, កិរិយានិងមុខមាត់ពលទាំងអស់ ក៏ខុសនឹងចរិតមនុស្សធម្មតា ហើយក៏មិនគោះគងទូងកេរជាទីរបៀបសោះ គ្រាន់តែវាយឃ្មោះហៅពលជាសម្គាល់, ឯខ្លួនបុកឡុកតែអង់តែងតួជាក្សត្រ ជិះដំរីលឿង សៀតគ្រឿងអាវុធដាវផ្ទួពីរ មានទាហានកាន់ទង់ជ័យកាយក្បែរមុខដំរីម្នាក់ ៗ

(នៅមានត)

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក ហ៊ិច្រ្គ ឈាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ២៥

ព្រៃល្ពាស់ដែលដុះដាដួរនៅលើមាត់ច្រាំង ប្រៀបបាននឹងខ្សែបូខៀវមួយយ៉ាងវែង ដែលក្រវាត់ព័ទ្ធលើអាវពណ៌លឿងទុំ នៃទេសភាពកាលអស្តង្គត ។ មើលទៅលើអាកាស ហ្វូងចាព្រៃខ្មៅដាសហើរត្រឡប់មកកាន់បឹងដែលជាទីជម្រករបស់ខ្លួនវិញ ក្រោយពីបានទៅរកគ្រាប់ផលាបរិភោគនៅទីវាលឆ្ងាយអស់ចិរវេលាពេញមួយថ្ងៃ ។ រាត្រីកាលក៏កាន់តែសន្ធឹមចុះគ្របព្រះធរណី ហ្វូងក្អែកដែលស្រែកឈាន់ទ្រហឹងក៏នាំគ្នាចូលទ្រនំស្ងាត់មាត់បន្តិចម្តង ៗ នាវទាំងឡាយដែលត្រេចតាមដងទន្លេក៏ចូលរកចំណតបន្ទាប់គ្នាអស់ នៅសល់តែកប៉ាល់អភ័ព្វធំជ្រើងដែលគៀងជាប់តាំងពីថ្ងៃនោះឯង ដែលចំរេចឡើងប្រាស់ខ្សែទឹកតែម្នាក់ឯង ៗ

ហ៉ាមេស្ហូសកៅអីសំពត់មួយទៅអង្គុយលើក្បាលកប៉ាល់ បណ្តែតអារម្មណ៍ក្រោមពន្លឺព្រះចន្ទដែលទើបនឹងរះឡើង ៗ មួយរាត្រីកាល ឃាក់ដូចជាផាត់ប្រានពន្លឺព្រះអាទិត្យចេញអស់រលីង ឯផ្ទៃព្រះធរណីនៅក្រោមពន្លឺព្រះចន្ទក៏ត្រចះត្រចង់ដែរ ក៏ឃាក់ដូចជាក្លាយទៅជាផ្សែងភាប

សក្បុះ ៗ ក៏មេស្ត្រីដែលមានអាត្មានពោរពេញទៅដោយអនុស្សាវរីយ៍មិន
អាចបំភ្លេចបានគ្រប់យ៉ាង នៃនាងហិមណាលីទីស្រីបណ្ដូលចិត្តកំពោល
ឈ្មោះនាងអេ៊្វ ៗ តែម្នាក់ឯង ៗ គ្រាន់តែនឹកដូច្នេះក្លាម អ្នកស្រីវៃឃើញ
គូស្នេហារបស់អ្នក រណ្ដែតតាមផ្សែងអាប់មកនៅចំពោះមុខអ្នកក្លាម អ្នក
ស្រីមៃឃើញនាងមានទឹកមុខព្រួយស្រពោន អ្នកនឹកអាណិតព្រួយហើយ
អន្ទុយសម្រក់ទឹកភ្នែកតែម្នាក់ឯង អ្នកនឹកឃើញកាលដែលធ្លាប់បាននៅ
ប្រាស្រ័យលេងជាមួយគ្នាយ៉ាងស្និទ្ធស្នាលអស់រយៈវេលា ២ ឆ្នាំមកហើយ
នឹកឃើញពេលដែលបានស្គាល់នាង ហើយអ្នកមិនបាននឹកស្មានថា ការ
ដែលបានស្គាល់នាងនោះ ធ្វើឲ្យអនាគតអ្នកធ្លាក់ដល់ថ្នាក់នេះសោះ ៗ
ដោយដេន្ទ្រាគេបាននាំអ្នកទៅលេងផ្ទះគេ កាលនោះអ្នកនៅក្មេងហើយ
រៀនច្រើននៅឡើយ លុះឃើញនាងហិមណាលីទី ចូលមកបរិភោគ
ទឹកតែនៅតុជាមួយអ្នក អ្នករៀនស្ទើរតែធ្វើអ្វីមិនកើត ៗ ក្រោយ
មកអ្នកក៏គាន់តែស៊ាំបន្តិចម្ដង ៗ ឯពាក្យកាព្យឃ្លោងនៅក្នុងសៀវភៅ
ទាំងប៉ុន្មាន ក៏ក្លាយទៅជាមានរូបរាងលើសមនុស្សនារីជាទីស្នេហានោះ
ទាំងស្រុង ៗ អ្នកសប្បាយចិត្តក្រៃលែងនឹងការដែលបានពើបប្រទះ
នឹងស្នេហា ច្បាស់ក្រឡែតអណ្ដែតមកទង្គិចអ្នកបាក់ដួចជាជប់ ៗ
ទាល់តែមកទល់នឹងថ្ងៃនេះ ទើបអ្នកដឹងខ្លួនច្បាស់ថា « អ្នកទើបតែនឹង
[illegible] លុះនាងកាមាលាចូល

មកជាបញ្ហាមួយស្រាយមិនរួចក្នុងឆាកជីវិតរបស់អ្នក ទើបអ្នកយល់ច្បាស់ថា សេចក្ដីស្នេហារបស់អ្នកចំពោះនាងហិមណាលិនី គឺត្រូវសន្ធឹកមហាព្យុះសង្ឃរាគួបត្រឡប់ក្នុងពេលនេះតែម្ដង ។

ទឹកឃើញសេចក្ដីកង្វល់ស្មុគស្មាញរាយមិនបែកសេចក្ដី យ៉ាងនេះអ្នកយកដៃទ្រក្បាលហាក់ដូចជាក្បាលនោះធ្ងន់សែនធ្ងន់ “ ឱ ! ជីវិតអាត្មាអញតទៅអនាគត ជីវិតឋិតនៅក្នុងសំណាញ់ ដែលអាត្មាអញគេចចេញមិនរួច តើអញត្រូវខំប្រឹងបំរះឲ្យរួចយ៉ាងពេញទំហឹងឬយ៉ាងណា ? ” អ្នកងើបក្បាលឡើងភ្លាមហាក់ដូចជាសម្រេចចិត្តថា “ត្រូវតែធ្វើ” ស្រាប់តែឃើញនាងកាមាលាឈរច្រត់លើខ្នងកៅអីមួយនៅបង្កើយក្បែរអ្នក កាយវិកាក៉ាមេស្ហទាញអារម្មណ៍នាងវិប នាងសួរ ?

– បងសម្រាន្តអីអំបាញ់មិញ ? ខ្ញុំមកធ្វើឲ្យបងភ្ញាក់អស់ ជាហើយនាងបង្វិលខ្លួនទឹងត្រឡប់ចូលទៅបន្ទប់វិញ

– ខ្ញុំឥតគេងទេ (ក៉ាមេស្ហឆ្លើយ) កាមាលាទាញកៅអីនោះមកអង្គុយជិតខ្ញុំមក ខ្ញុំនិយាយរឿងមួយឲ្យស្ដាប់ ។

ឮក៉ាមេស្ហថាដូច្នេះនាងអរណាស់ កំរុញកៅអីទាល់តែទៅប៉ះនឹងកៅអីក៉ាមេស្ហហើយអង្គុយរង់ចាំស្ដាប់រឿង ។ ក៉ាមេស្ហគិតនឹងនិយាយរឿងពិតប្រាប់នាងហើយម្ដងនេះទុកយូរមិនកើតទេ ប៉ុន្តែត្រូវរៀបសេចក្ដីឲ្យស្រួលសិន ។

កាមេសូហ្គេីមនិយាយ :

– កាលនោះមានក្រុមកដព្វុ . . .

– ពីកាលណាបង ប៉ុន្មានឆ្នាំកន្លងទៅហើយ ?

– តាំងពីកាមាណាឯងមិនទាន់កើតម៉្លេះ

– បងកើតហើយប្រហែល និយាយតទៅលោកតាពុកមាត់ស្គរ ។

– ពួកកដព្វុនោះ មានទំនៀមប្លែកណាស់ គឺថា បើប្រុសណារៀបការប្រពន្ធ ប្រុសនោះមិនត្រូវទៅទទួលប្រពន្ធខ្លួនឯងទេ គេត្រូវផ្ញើតែដាវទៅបានហើយ កូនស្រីត្រូវរៀបចំអាពាហ៍ពិពាហ៍ជាមួយនឹងដាវនោះសិនទៅ រួចទើបគេនាំយកនាងនោះមករៀបការធំដុំមែនទែននៅឯផ្ទះខាងប្រុស ។

– ចុះទំនៀមអ្វីក៏ប្លែកខុសគេម៉្លេះបង ?

– មែនហើយ រឿងហ្នឹងក៏ដូចជារឿងខ្វិះខ្វុះដែរ ពួកកដព្វុនោះគេយល់ថា ប្រុសទៅផ្ទះខាងស្រីជាការថោកទាប ។ ឯស្តេចដែលត្រូវរៀបអាពាហពិពាហនោះ គឺជាពួកកដព្វុនោះឯង ។ ថ្ងៃមួយ ស្តេច . . .

– ស្តេចនោះសោយរាជ្យនៅនគរណាទៅបង ?

– នៅម៉ាឌុក ថ្ងៃមួយស្តេច . . .

– ស្តេចនោះឈ្មោះអីបង ? ( កាមាណាចេះតែសួរបញ្ឆក )

នាងកាមាណាស្មានថាជារឿងពិត ក៏ចេះតែសួរដេញដោលឲ្យអស់

សេចក្តី ក៏មេស្ហទឹកស្តាយ នឹងមិនបានរកទឹកទុកជាមុន អ្នកទប់មួយសន្ទុះ ទើបហាប់និទានតទៅទៀត ។

— ស្ដេចនោះមានព្រះនាមថា "វញ្ជិតសិង្ហ"

"ថ្ងៃមួយលោកបានទទួលដំណឹងអំពីអ្នកដើរប្រៀងម្នាក់ថា មានស្ដេចមួយព្រះអង្គសាសន៍ជាមួយនឹងព្រះអង្គដែរ ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គប្រកបដោយរូបឆោមដ៏ល្អឥតខ្ចោះ ។

— ស្ដេចដែលមានកូនស្រីនោះ គង់នៅនគរណាបង ?

— យើងថានៅនគរកុងដេវេក៏មទៅចុះ

— យី ម្ដេចក៏បងបេះតែជាដូច្នេះ បើអីចឹងរឿងនេះមិនមែនជារឿងពិតទេឬ ?

— ប្រហែលជាមិនពិតមែនហើយ រួចនាងចង់ដឹងព្រះនាមស្ដេចនោះទៀតឬ ? ព្រះអង្គទ្រង់ព្រះនាមថាអមរសិង្ហ ។

ចុះព្រះរាជបុត្រី ?

— មែនហើយ ព្រះនាងឈ្មោះចន្ទ្រា ។

— បងភ្លេចអ្វីក៏ភ្លេចម៉្លេះទេ ភ្លេចទាំងឈ្មោះខ្ញុំផងទៅហើយទេដឹង ។

— ខ្ញុំនិយាយតទៅទៀត លុះដល់ស្ដេចក្រុងអ៊ុធនោះ ទ្រង់ព្រះសណ្ដាប់ អ្នកចម្រៀងនោះហើយ . . .

.. ១ នស្ដេចក្រុងអ៊ុធពីណាមកទៀត ក្រែងថាស្ដេចនៅម៉ាឌុក៏ឬបង?

– ថាគេសោយរាជ្យនគរពីរ (កាមេស្ហបេះតែថែម) នៅពេលក៉ាមេស្ហនិទានរឿង នាងកាមាណាបេះតែចាប់កំហុស តែអ្នកបេះតែដោះរួច ឯរឿងដែលក៉ាមេស្ហប្រឌិតក្នុងពេលនោះ មានដូចខាងក្រោម... ។

– រញ្ចិតសិង្ហ ស្តេចក្រុងម៉ាឌូក៏ទ្រង់ប្រើមហាមាត្យធំម្នាក់ឲ្យទៅក្រុងដេវេក៉មនគរ ដើម្បីសុំចងស្ពានមេត្រីនឹងព្រះអង្គ ។ ព្រះចៅក្រុងកុងដេវេក៉ម ទ្រង់សព្វព្រះរាជហឫទ័យ តាមសេចក្តីស្នើនោះ ។

ព្រះចៅរញ្ចិតសិង្ហ ទ្រង់ប្រើព្រះអនុជពៅរបស់ព្រះអង្គព្រះនាមឥន្ទ្រជិតសិង្ហ ឲ្យនាំពលរេហ៍ទៅឯនគរព្រះចៅអមរសិង្ហ ដល់ហើយក៏នាំគ្នាទៅបោះព្រះពន្លានៅក្នុងព្រះរាជឧទ្យាន ។ នៅឱកាសនោះនៅក្រុងកុងដេវេក៉ម គេមានធ្វើបុណ្យមួយយ៉ាងឧឡារិក កំដរអាពាហ៍ពិពាហ៍ព្រះរាជបុត្រីនៃព្រះរាជា ។

ព្រះរាជហោរាបានរើសយកឫក្សពារពេលាល្អ ដើម្បីនឹងរៀបអាពាហ៍ពិពាហ៍ព្រះអង្គម្ចាស់ក្សត្រី គេទៅត្រូវបានពេលានៅយប់ថ្ងៃ ១៦ កើត វេលាម៉ោង ២ ភ្លឺ ។ ផ្ទះនានាក្នុងទីក្រុងនោះសុទ្ធតែប្រដាប់ដោយភ្លើង ទង់ភ្លើក្រដាសពណ៌ចងខ្វាត់ខ្វែងដែលជានិមិត្តរូបនៃសេចក្តីអបអរសាទររបស់ប្រជារាស្ត្រនិងពិធីមង្គលការព្រះនាងចន្ទ្រា ។

ប៉ុន្តែដល់ថ្ងៃកំណត់ការហើយ ព្រះនាងមិនទាន់ស្គាល់មុខមាត់ព្រះស្វាមីព្រះនាងនៅឡើយទេ កាលព្រះនាងទើបនឹងទ្រង់ប្រសូត្រចេញមក

ភ្លាម តាបសបរមានន្ទ្រាស្វាមិ បានទំនាយថ្វាយព្រះបិតាព្រះនាងថា " តារាប្រចាំជីវិតរបស់ព្រះនាង មិនថ្វាយប្រផ្នូលល្អដល់ព្រះនាងសោះ ដូច្នេះកាលណាត្រូវរៀបចំព្រះនាងឲ្យមានស្វាមី សូមព្រះអង្គប្រយ័ត្ន កុំប្រាប់ឈ្មោះស្វាមីឲ្យព្រះនាងទ្រង់ជ្រាបជាមុនឲ្យសោះ " ។

លុះដល់ថ្ងៃកំណត់ហើយ ក៏ពបអាពាហ៍ពិពាហ៍ព្រះនាងជាមួយតែនឹងព្រះខ័នរបស់ស្វាមីតាមទំនាមទៅ ឥន្ទ្រាជិតសិង្ហក៏នាំបណ្ណាការរបស់ស្វាមីព្រះនាង ទៅថ្វាយព្រះនាងតាមទំនៀមហើយក៏សច្ចាថានឹងគោរពកិរិយារបស់ព្រះរៀមលុះអស់កិច្ច ។ ព្រះលក្ស្មណ៍ទ្រង់គោរពព្រះរាមជាច្បងយ៉ាងណាមិញ ឥន្ទ្រាជិតសិង្ហ ក៏គោរពបងរបស់គេយ៉ាងនោះដែរ ហេតុនោះហើយទើបនៅពេលរៀបមង្គលការ ដែលព្រះរាជធីតាត្រូវបើកព្រះភក្ត្របង្ហាញព្រះអនុជថ្ងៃនោះ ឥន្ទ្រាជិតមិនហ៊ានងើបមុខមើលព្រះនាងទេ ទៅជាឈ្មោកសំឡឹងព្រះបាទព្រះនាង ដែលបន្ទំលក្ខណ៍ក្រហមរលោងឯណោះទៅវិញ ។

ថ្ងៃបន្ទាប់មក ឥន្ទ្រាជិតទៅស្ដេចព្រះនាងឲ្យគង់ក្នុងបុស្បុកល្អវិចិត្ររួចក៏នាំរេហ៍ពលដង្ហែព្រះនាងទៅព្រះនគរខ្លួន ។ មុនពេលក្បួនដែលដង្ហែចេញទៅព្រះចៅក្រុងកុងដេវេក៏ ទ្រង់នឹកឃើញទំនាយតាបស ទ្រង់ព្រួយព្រះរាជហឫទ័យក្រៃពេក ក៏លើកព្រះហស្តស្ដាំទៅដាក់លើព្រះកេសាបុត្រីជានិមិត្តរូបនៃព្រះពរដ៏ប្រសើរបំផុត ព្រះអគ្គមហេសីទ្រង់មានព្រះទ័យក្ដួល

ណាស់ លាព្រះរាជធីតាបណ្ដើរ បង្ហូរទឹកព្រះនេត្របណ្ដើរ ។ នៅទីអាកមនានាព្រះសង្ឃ នាំគ្នាសូធ្យាយធម៌ជយន្តោដើម្បីបម្ដូងព្រះនាងឲ្យចាកផុតអំពីគ្រោះកាចដែលគេទាយទុកនោះ ។

ក្រុងកុងដេវើមនៅឆ្ងាយអំពីក្រុងម៉ាឌូរ៉ណាស់ គេត្រូវចំណាយពេលមួយខែទើបទៅដល់ ។ ក្រោយពីបានធ្វើដំណើរអស់ ១ ថ្ងៃហើយ លុះពេលល្ងាច ពួករាជពុទ្ធទាំងនោះនាំគ្នាបោះជម្រំសម្រាកនៅក្បែរមាត់ទន្លេវេតស្នា ពលសេហ៍ទាំងប៉ុន្មានរៀបចំទីចូលសម្រាកស្រាប់ តែគេឡកទៅកន្ទៃព្រៃឃើញភ្លើងចន្ទុះសន្ធោសន្ធៅដើរតម្រង់មក ឥន្ទ្រាជិតប្រើទាហានម្នាក់ឲ្យទៅមើលបម្រើត្រឡប់មកវិញទូលព្រះអង្គថា „ភ្លើងដែលយើងមើលទៅឃើញនោះ គឺពួករាជពុទ្ធដូចយើងហ្នឹង ១ ក្រុមគេត្រឡប់មកពីរៀបអាពាហ៍ពិពាហ៍ដូចយើងដែរ គ្នាខ្លាចជួបគ្រោះកាចតាមផ្លូវ ទើបចូលមកសុំជ្រកកោនទីងយើង ឲ្យបានជាគ្នាក្នុងការធ្វើដំណើរតាមផ្លូវឆ្ងាយនេះ តែគេមិនមានដំណើរស្របតាមយើងរហូតទេ” ។

ទ្រង់ព្រះសណ្ដាប់ហើយ ព្រះអង្គម្ចាស់ក៏ត្រាស់ថា“ចូរឯងឲ្យគេមកចូលជាមួយនឹងយើងផងចុះ បើមានអាសន្នយ៉ាងណា យើងនឹងជួយការពារឲ្យ កុំឲ្យគេព្រួយ នេះជាកិច្ចដែលយើងពេញចិត្តនឹងទទួលជាទីបំផុត„

ជនទាំងពីរពួកក៏ចករួមបញ្ចូលគ្នា ដើម្បីបន្តដំណើរទៅទៀត ។

យប់ស្អែកឡើង គឺត្រូវលើថ្ងៃខែងាច់ ក្នុងដំណើរមើលទៅមុខ

ឃើញផ្លូវតូចមួយវែងអន្លាយ ឆកទៅក្រោយវិញ ព្រៃឈើដ៏ក្រាស់ គេក៏នាំគ្នាសម្រាកនៅទីនោះទៀត ។ មិនយូរប៉ុន្មានពួកទ័ពសេះដែលបាននឿយហត់ក្នុងការធ្វើដំណើរ ក៏លង់លក់ស្ងាត់ស្ងប់ ហាក់ត្រូវសណ្ដំនៃសូរទឹកធ្លាក់ចុះទៅជ្រោះ ។

ខណៈនោះ ការជ្រួលច្របល់មួយយ៉ាងសម្បើម បានផ្ទុះឡើងមួយរំពេច ធ្វើឲ្យពួកពលភ្ញាក់ក្រញេងក្រញាងក្នុងជំរំពួកម៉ាឌុក សេះទាំងប៉ុន្មានដែលគេបានបង់ពីល្ងាច ស្រាប់តែផ្អើលផ្ដាច់ រត់ប្រសេកប្រសាច ជំរំខ្លះឆេះ អណ្ដាតភ្លើងឡើងក្រហមវន្លាលអស់ទាំងមេឃ ។

ឃើញសភាពដូច្នោះភ្លាមពួកអ្នកដំណើរយល់ភ្លាមថា គ្មានអ្វីក្រៅអំពីការវាយប្រហាររបស់ពួកចោរកម្មឡើយ ការវាយតស៊ូយ៉ាងសាហាវក៏ចាប់ធ្វើឡើងគ្មានបង្អង់ ក្នុងពេលប្រយុទ្ធពួកច្របូកច្របល់នោះ មិនដឹងណាជាចោរ ណាជាពួកគ្នាឯង ម្ល៉ោះហើយពួកចោរក៏បានឱកាសវាយលុកយកជោគជ័យ ហើយប្លន់យកទ្រព្យសម្បត្តិ រត់គៀសខ្លួនចូលក្នុំអស់ ។

ផុតអំពីការជ្រួលច្របល់នោះទៅ ព្រះអង្គម្ចាស់ក្សត្រីចន្ទ្រាក៏បាត់ទៅដែរ ដោយព្រះនាងភ័យពេករត់តាមគេទៅ ស្មានជាគ្នាឯង ។

ឯពួកអ្នករត់ទាំងនោះ គឺជាក្រុមដែលបានចូលមកសុំធ្វើដំណើរជាមួយកាលពីថ្ងៃមុន ហើយស្ដេចស្រីរបស់គេនោះ ចោរវាយចាប់បានយកបាត់ទៅ ប៉ុន្តែគេស្មានថាព្រះនាងចន្ទ្រានេះហើយដែលស្ដេចបានប្រគល់មក

ឲ្យគេជូននោះ ក៏ចំតែស្រុកនាំព្រះនាងទៅ ដើម្បីឲ្យបានដល់ស្រុកឆាប់ ក្រែងមានភ័យអន្តរាយមកដល់ថ្មីទៀត ។

ស្រុករបស់ក្រុមនោះជាស្រុកតូចមួយ ស្ថិតនៅលើមាត់ព្រែកដ៏កៗ លុះបានពេលល្អហើយ គេក៏រៀបចំនាំព្រះនាងទៅថ្វាយបង្គំព្រះអង្គម្ចាស់ជេតសិង្ហជាស្វាមីរបស់ក្សត្រីដែលពួកចោរចាប់ទៅនោះ ។

គ្រួសាររបស់ព្រះអង្គម្ចាស់ជេតសិង្ហ ចេញមកទទួលព្រះនាងចន្ទ្រា ហើយលាន់មាត់សរសើរអំពីសម្ផស្សព្រះនាងគ្រប់ ៗ គ្នា ។ ព្រះវរមាតាព្រះអង្គទ្រង់ចេញមកទទួលព្រះសុណិសា នាំទៅប្រគល់ឲ្យព្រះរាជបុត្រ ពិធីផ្សេងៗក៏ចាប់ធ្វើជាបន្តបន្ទាប់គ្នាតាមទំនៀមទៅ ។

ព្រះអង្គម្ចាស់ជេតសិង្ហ សព្វព្រះរាជហឫទ័យនឹងព្រះជាយាពន់ពេកណាស់ ដោយរូបឆោមលោមពណ៌ព្រះនាងល្អផង ដោយព្រះនាងចន្ទ្រាចេះបំពេញករណីយកិច្ចជាភរិយាគ្រប់បែបយ៉ាងចំពោះព្រះអង្គផង ហើយទ្រង់ស្រឡាញ់ព្រះស្វាមីស្មើជីវិតផង មិនបានប៉ុន្មានថ្ងៃផង នៅពេលដែលព្រះអង្គម្ចាស់ជេតសិង្ហ ទ្រង់ប្រាស្រ័យក្រសាលជាមួយនឹងព្រះនាង ក៏ទ្រង់ជ្រាបថាជាយាព្រះអង្គនេះ គឺជាព្រះនាងចន្ទ្រាទេ មិនមែនជាក្សត្រីដែលព្រះអង្គបានទៅដណ្តឹងនោះទេ !

## វគ្គទី ២៦

មកដល់ត្រង់នេះ នាងកាមាលាសួរកាំមេស្វា ៖

–បើអីចឹងធ្វើម្ដេចទៅបង? (នាងបានស្ដាប់រឿងនោះដោយយកចិត្តទុកដាក់ណាស់មែន បានជាឆ្ងល់)។

កាំមេស្វាឆ្លើយ ,

–ខ្ញុំមិនដឹងជាយ៉ាងម៉េចទៅទៀតទេ

តើកាមាលាឯងយល់ថារឿងនោះត្រូវចប់ដូចម្ដេចទើបសម ?

–ទេ ទេ! បងត្រូវនិយាយឲ្យចប់ទៅ មកសួរខ្ញុំម្ដេច អីចឹងទៅវិញ? ។

–មែនណាកាមាលា ខែទី ១ ចប់តែត្រឹមហ្នឹងហើយខ្ញុំមិនដឹងជារឿងនោះយ៉ាងណាទៅទៀតទេក្នុងខែទី ២ ។

–បងឯងនេះចំតែម្ដងហើយ និយាយអីមិនឲ្យចប់ទេ

–ត្រូវខឹងនឹងអ្នកនិពន្ធឯនោះទើបត្រូវ ...បងដឹងអី បើគេមិនបន្ត

ប៉ុន្តែខ្ញុំចង់ឲ្យនាងប្រាប់ខ្ញុំថា តើជេតស្វិងត្រូវធ្វើដូចម្ដេច ? បើដឹងថាព្រះនាងចន្ទ្រាមិនមែនជាព្រះជាយារបស់ព្រះអគ្គបុត្រ ។

នាងកាមាលាបោលខ្សែភ្នែកឆ្ងាយទៅលើផ្ទៃទន្លេ សញ្ជឹងគិតមួយសន្ទុះទើបឆ្លើយមួយៗថា ៖

–ខ្ញុំមិនដឹងទេហ្នឹង តែមិនដឹងជាត្រូវធ្វើម្ដេចទេ ។

កាមេស្ហសម្លំចាំស្តាប់ចម្លើយនាងមួយសន្ទុះ ទើបចាប់និយាយត ទៅទៀត ។

- បងជាដេតសិរ្ហត្រូវតែនិយាយការពិតប្រាប់ព្រះនាងចន្ទ្រាណា ?

- បងនិយាយអី អីចឹង ? ចុះបើនិយាយទៅ តើអ្នកទាំងពីរទៅជា យ៉ាងណាទៅ ពីព្រោះចិត្តស្តាប់ហើយបង !

- មែនហើយ ឥឡូវយើងឧបមាថា ...

- ឧបមាថាអីបង ?

- ថាខ្ញុំជាដេតសិរ្ហ កាមាណាឯងជាព្រះនាងចន្ទ្រា ...

- បងកុំនិយាយលេងអីចឹង ខ្ញុំមិនចូលចិត្តទេ

- ទេខ្ញុំគ្រាន់តែចង់ដឹងថា តើករណីយកិច្ចរបស់ខ្ញុំត្រូវធ្វើដូចម្តេច ប៉ុណ្ណោះទេតើ ។

ប៉ុន្តែនាងកាមាណាមិនឆ្លើយ បែរជាក្រោកដើរចេញកន្លែង ទុកកា មេស្ហឲ្យនៅអង្គុយគិតតែឯង ។ នាងដើរចូលទៅកងបន្ទប់សឹងតែជាន់ ភ្លុយមេស្ហដែលអង្គុយក្បែរខ្លួននៅមាត់ទ្វារ ។

- ភ្លុយមេស្ហដែលខ្លាចលងទេ ? (នាងសួរក្មេង)

- បាទដែលម្តងដែរម៉ែ

- រាលងធ្វើម្តេចខ្លះទៅ និយាយប្រាប់ម៉ែមើល ? (នាងកាមាណា ទាញដើងម៉ា បកអង្គុយក្បែរក្មេង) ។

ក៏មេស្ហមិនហៅនាងត្រឡប់មកវិញទេ ព្រោះដឹងថានាងខឹងមែនៗ នៅលើផ្ទៃមេឃ ចំណិតព្រះចន្ទតូចមួយសន្សឹមចុះទៅក្នុងគុម្ពោតឫស្សី ពួកសារិកនាំគ្នាចុះ សើបៗ ទៅរកចាយបរិភោគនិងរកកន្លែងសម្រាក ពួកអ្នកដំណើរនាំគ្នាចុះទៅរកម្ហូបអាហារសម្រាប់ពេលល្ងាចបន្តៗគ្នា នៅឯលើគោកឯនោះ គេឃើញពន្លឺភ្លើតៗ តាមបន្ទោះស្លឹកឈើខ្ទៅស៊ុង យូរៗ កប៉ាល់អង្រើមង ដោយកម្លាំងទឹកហូរប៉ះខ្លាំងទៅលើខ្សែយុថ្កា ៗ

ក៏មេស្ហនៅអង្គុយសញ្ជឹងគិតម្នាក់ឯង ក្រោមផ្ទៃមេឃដ៏ល្វឹងល្វើយ ព្រោះបញ្ហារបស់អ្នកនោះស្មុគស្មាញ ធ្វើឲ្យអ្នកខ្វល់គំនិតអស្ចារ្យ គឺថាត្រូវចោលកាមាលា ឬហិមណាលិនី ? ចុះបើទុកទាំងពីរនាក់នៅជាមួយគ្នាទៅវិញ តើរាំយ៉ាងណា ប៉ុន្តែទោះជាអ្នកគិតឃើញថា បញ្ហានេះពិបាកយ៉ាងណា ក៏គេនៅតែយល់ច្បាស់នូវករណីយកិច្ចរបស់គេដែរ គឺថា នាងហិមណាលិនី នឹងអាចផ្សាំបចិត្តទៅបាន នាងអាចបំភ្លេចរឿងចាស់ ហើយទទួលគូដណ្តឹងថ្មីទៀតបាន ឯរូបគេនេះ មិនមែនជាពិសេសអ្វីជាងអ្នកដទៃទេ ចំពោះរូបនាងកាមាលាវិញ តែអ្នកលែងនាងចោលទៅ វិស័យដូចជាទូកនៅកណ្តាលសមុទ្រ ព្រោះនាងគ្មានអ្នកណារំពឹងសោះៗ ទោះជាយល់ឃើញច្បាស់យ៉ាងនេះហើយក៏ដោយ ពុទ្ធោអើយ ! ចិត្តបុរសដែលគិតតែបំរើចិត្តខ្លួនមួយប៉ុណ្ណោះ មាននៅស៊ុខចិត្តឲ្យនាងហិមណាលិនីបំភ្លេចរូបខ្លួន ដើម្បីទៅរកសុភមង្គលក្នុងរង្វង់ដៃបុរសដទៃក្រៅឯណា

កើតអំពីដៃខ្ញុំទ? គ្រាន់តែនឹកដល់នេះភ្លាម សេចក្ដីស្នេហារបស់អ្នកចំពោះនាងរឹតតែខ្លាចផ្សាខ្លាំងឡើង ៗ

ក៏មេស្វាយកដៃទាំងពីរទ្រកក្បាល គេព្រួសរបចកល្បក្រលួចល្មើយៗ ពីចម្ងាយ បណ្ដាលឲ្យហួនក្នៃស្រុកផ្ញើលព្រុសលាន់ទ្រហឹង ក៏មេស្វាងើបក្បាលឡើង ឃើញនាងកាមាលាឈរនៅជិតអ្នក អ្នកស្ទុះងើបឡើងហើយ និយាយថា :

–មិនទាន់គេងទេកាមាលា ថាវនេះហើយ ?

- ចាំខ្ញុំទៅគេងឥឡូវហើយបង ខ្ញុំលើកពូកខ្ញុំមកដាក់ជិតបងហើយបងក៏ត្រូវចូលសម្រាន្តដែរ យប់យូរណាស់ហើយណា ៗ

តាមពិតគឺនាងកាមាលាខ្លាច មិនហ៊ានចូលគេងតែឯង ក្រោយអំពីបានស្ដាប់អ៊ុយមេស្វានិយាយរឿងខ្មោចលង ប៉ុន្តែនាងមិនហ៊ានសារភាពប្រាប់ក៏មេស្វា កំដើរធ្វើយឺត ៗ ចូលទៅក្នុងបន្ទប់ ក៏មេស្វាឃើញដូច្នោះនឹកអាណិតក៏ស្រែកប្រាប់នាងថា ៖

–កុំខ្លាចអី កាមាលា បន្ទប់ខ្ញុំនៅជាប់នឹងបន្ទប់កាមាលាឯងទេ តើខ្ញុំមិនបិទទ្វារធ្នើបន្ទប់នោះទេ ៗ

– អ្នកណាថាខ្ញុំខ្លាច ? បង ! (នាងឆ្លើយទាំងបំពាន)

ព្រោះដូច្នោះក៏មេស្វាគិតក្នុងចិត្ត «បើយ៉ាងហ្នឹងតើឲ្យអ្នកហៅលនាងម្ដេចទៅ ណ្ហើយ ! ខ្ញុំលែងកកើតទៀតហើយ ឈប់គិតដល់នាងហាបណាលីនី

តែប៉ុណ្ណោះជាការស្រេច ប៉ុន្តែ គិតទៅគិតមក អ្នកនៅតែយល់ថា ការអៀនខ្មាស និងសេចក្ដីវេទនារបស់អ្នកនៅតែធំ ហើយគ្មានព្រំដែន វិស័យដូចជាផ្ទៃមេឃនិងពេលវេលាដូច្នោះដែរ ។ ឯសេចក្ដីស្នេហារបស់អ្នកក៏ប្រៀបបាននឹងពន្លឺនៃតារា ដែលដេញផ្ទូកៗនៅលើក្បាលអ្នក ហើយមិនអាចរលត់បានយ៉ាងនោះដែរ អ្នករំពឹងគិតទៀតថា តើទឹកទន្លេនៅតែហូរច្រោះខ្សាច់ដូចឥឡូវនេះប៉ុន្មានទំរាំទៅទៀត ។ ឱ ! ពុះធ្លាអើយ លុះណាតែសរីរៈរាងកាយរបស់ខ្ញុំហុយជាផេះ រលាយសាច់មួយទៅនឹងផងព្រះធរណី ទើបគេឃើញសេចក្ដីស្ងប់ជាអវសាននៃជីវិតខ្ញុំឃើញ ។

(នៅមានត)

# ល្បើកអក

(ចម្លងពីសាស្ត្រាស្លឹករឹត)

## ពាក្យ ៧

បានជួបបានជួនបានឃើញប្ដី ឃើញស្រីហើយស្រស់មិនឡូហ្មង
ឃើញស្រីទំពិតជិតខានបង ស្រស់នោមមិនហ៊ានដើរទៅជិត ។
និយាយស្រីព្រានតែពីក្រៅ ទីងហៅក្រែងបងអាក់អន់ចិត្ត
បងសោកធ្ងើតើយហាក់មិនស្និត នុំអាសូរចិត្តអាណិតស្រី ។

## ពាក្យ ៩

អាណិតស្រស់មិនគួរសោះបើមកប្រាស
អាណិតមាសមិនគួរសោះបើឃ្លាតថ្លៃ
អាណិតស្ងួនមិនគួរសោះបើមកក្ស័យ
អាណិតថ្លៃមិនគួរបើបង់បោលបង ។
មិនគួរបើបងមកប្រែបែរបែកចិត្ត
មិនគួរបើឲ្យបងគិតក្បត់ទងវង់
មិនគួរបើបងបោលប្អូនស្ងួនគ្រមង់
មិនគួរសោះឲ្យបងបង់ប្អូនកំព្រា ។
នៅកំព្រើងរំងើកំប្រោននេកំព្រយ
ព្រោះចិត្តខ្លោយបេបណ្ដាយធ្លាក់ទៅយកញ្ហា

ពោលទូលនាងឲ្យទិត្យទៅអស្ដង្គឯកា
ឈើឱកផ្កាឱរ៉ើបទិនក្បួន ៗ
អកទួញតាំងតែអំពីពន់ព្រលប់
លង់លុះយប់គំរប់យាមពីរបីបួន
ស្រែកយំណាស់បម្រះទឹងពុំដឹងខ្លួន
ប្រាសប្រាណស្ទូវសន្ទប់លន់បាត់ស្មារតី ៗ
ព្រះពាយផាយផាត់ខ្ទាត់មកពាល់ដល់កាយ
រំហើយផាត់រំហើរផាយសាយសព្វព្រៃ
សន្សើមសោតចុះជ្រុះធ្លាក់មកដល់ថ្ពី
ភ្ញាក់ស្មារតីស្រែកយំទួញទំនួញថា ៗ
ឱប្អូនស្ងួនទទួនកំសត់មាសបងអើយ
ឱះម្ដងទៀយទួនបាត់ទៅឋានឯណា
អកយំទួញទំនួញល្វើយកង់អធ្យា
កណ្ដាលយប់សន្ធិយាជ្រៅស្រងាត់ ៗ
កណ្ដាលយប់រញ្ញាត្រចៀកទៅផាស់ទំ
ពួសត្វយំបន្ទឺថស្ងួរស្រងាត់
អកសាជ្រែងតែង...ស្រែកសាល់យក្ដាត់
រអែកសត្វសោយសោកសែនសំវេយ្យា ៗ

អកទំនួញទួញយាសយំទុរគមគិត
ខ្លោចព្អោបល្អិតឆ្អិតឆ្អន់ណែនក្តុខជុក
អណោចគិតអាណិតកូនរែងខ្លោចផ្សា
ឈឺកាយាផ្សាការយើតែម្នាក់ឯង ៗ
អកទួញទៀតចង្អៀតចិត្តអាណិតខ្លួន
ជាទុក្ខមួនប្រឈួនថប់គ្រប់កន្លែង
គ្រប់កន្ទៀតប្របៀតសព្វគ្រប់ទីល្វែង
គ្រប់បឹងខ្វែងកន្លែងជ្រោះអូរឈូងឆក ៗ

( ពាក្យ ៧ )

គ្រប់បឹងត្រពាំងទាំងព្រៃភ្នំ   គ្រប់អូរតូចធំគ្រប់ជ្រោះប្រែក
គ្រប់លើគ្រប់ព្រៃគិតលៃលក   ខំស្វែងហើររកចាប់មច្ឆា ៗ
អកសោករៀបរាប់ទីកន្លែង   ទ្រហោក្តែង ៗ ក្នុងអដ្វា
តាំងពីព្រលប់យប់សន្ធយា   លុះព្រះសុរិយារៀបនឹងរះ ៗ
អកឆ្មៀងរកមើលកូនប្រពន្ធ   សព្វគ្រប់ដំបន់ទិសទីផ្តាស
ពុំឃើញប្រពន្ធនឹងកូនមាស   អកប្រាសហើរចុះទៅដល់ដី ៗ
អកឈ្មោលរកកូនក្រោមមណ្ឌល   ក្រិណាយល់ប្រពន្ធកូនទាំងបី
ស្លាប់គរត្រួមគ្នានៅដី   អកខ្ទើបខ្លោចកូនសោកា ៗ
ឱកែវព្រាត់ចាកទាំងបីអាស   ម្តេចឡើយមកប្រាសស្លាប់អសោះ

ឬមួយក្រែងអកអត់អាហារ  ព្រោះកម្មវេរពីព្រេងនាយ ៗ
ឲ្យបានយើងប្រែបែរព្រាត់ប្រាស  ទិសខ្ចាយខ្ចាត់ប្រាសព្រាត់ព្រាយ
អកឪពុកបាទៅឯនាយ  ចោលកូននៅអាយរងវេទនា ៗ
កូនអើយនេះហើយហេតុតែកម្ម  ពីព្រេងនាយនាំឲ្យឪបា
ឲ្យស្រើបឲ្យស្រាលដោយតណ្ហា  ចោលកូនសង្ក្រទាំងពីរនៃ ៗ
ពុំគួរបាកើតមកឥតកំព្ង  មកស្លាប់នៅនាកណ្ដាលព្រៃ
កូនអើយឪនឹកឡើងស្រមៃ  ហាក់ថ្ងៃនៅរូបរស់នៅឡើយ ៗ
អកខ្ញុំឱបខ្មោចកូនប្រពន្ធ  រងថែមទុក្ខធ្ងន់ពុំមានស្បើយ
បម្រះនេះនៀលសោកល្ហើយ ៗ  ឱបកើយខ្មោចកូនសន្ធប់លង់ ៗ
ដូចគេប្រគរទាំងបីប្អូន  សន្ធប់សុងសូន្យពុំលើកអង្គ
តាំងពីព្រហាមលុះថ្ងៃត្រង់  អកពុំភ្ញាភ្ញាក់ដឹងស្មារតី ៗ
វាយោផាយផាត់ក្លិនគន្ធា  ចូលផ្សព្វកាយាអកបក្សី
បានភ្ញាក់ដឹងខ្លួនហើយយំខ្ទី  ឱបស្រីអកខ្ញុំទំនួញគ្រប់ ៗ
ស្រណោះអកយំពេលថ្ងៃត្រង់  រន្ធត់អស់អង្គខ្ញុំស្ញាប់
ឱកែវវិណាសមាសទឹកដប់  . . . . . . . (១) ៗ
ពីដូចបងកព្វទិនប្អូនស្រី  ចូរប្អូនប្រណីណានាងអើយ
ពីកាលស្រីទៅតាមធ្វើតើយ  ស្រីអើយបងសូមសុំសច្ចា ៗ

---

១-ត្រង់នេះ ក្នុងសាស្ត្រាដើមបាត់មួយឃ្លាដូច្នេះ ឯច្បាប់ខ្លះដែលបោះពុម្ពហើយមិនមានសេចក្ដីវែងមកដល់នេះទេ ។

ខឹងត្បិតបងអកមានប្រពន្ធ    ពោលជូនពោលនាងនៅឯកា
នាងផ្សងឥន្ទព្រហ្មសុំសច្ចា    ប្រាថ្នាមិនឲ្យជួបនឹងបង ៗ
បងបានជាភ្លាយនឹងប្អូនស្រី    សេចក្តីបងអ្នកឃើញជាធ្គង
ថ្ងៃនេះបងសូមសច្ចាផង    សូមចងជាតិមុខជាសង្សារ ៗ
ទើបអកនុនអង្គហើយក្រួញក្រាប    កាងស្វាបបង្គំគ្រប់ទិសា
អកផ្សងឥន្ទព្រហ្មនូវទេវតា    សូមសុំសច្ចាបានដូចការ ៗ
ក្នុងជាតិនេះខ្ញុំមកព្រាត់ប្រាស    ទ័កសប្រពន្ធកូនពីរប្រាណ
ជាន់នេះជាតិនាយកុំឲ្យមាន    សូមចងជាស្ពានទឹងកូនថ្ងៃ ៗ
សូមឲ្យមូលមកកុំឲ្យខាន    ឲ្យបានដូចខ្ញុំប្រាថ្នាទៃ
សូមជាសង្សារនឹងប្អូនស្រី    នូវកូនមាសថ្ងៃទាំងពីរពង្ស ៗ
អកផ្សងសច្ចារួចស្រេចខ្សេះ    ទទះស្លាបហើរឡើងពុំលង់
ទំលើចុងឈើធ្វើឡើងឡង់    ទំផ្ចង់ស្លាបតតម្រង់កាយ ៗ
ហើយអកស្រែកផ្តាំទឹកថ្វែង    ទ្រហោរក្តែងៗស័ព្ទសោយ
យំពេលថ្ងៃត្រង់លន្ទោបផ្ទាយ    ហើយអកនុនកាយស្រយោកជ្រប់ ៗ
ថានុទីឋានព្រៃនេះហើយ    ឋានអើយយើងធ្លាប់ពីរវែងឈប់
ធ្លាប់កាប់ស្វិតឈើធ្វើជាម្ជប់    ជាស្រប់ឡៀស្រើរក្សាកូន ៗ
ឥឡូវគ្មាននៅទឹកថ្វែង    រលើងខ្លួនជេងបាត់សោះសូន្យ
ឋានអើយកម្មព្រេង:យើងទាំងប្អូន    មកជួនជួបទីឋានខ្ញុំអើយ ៗ

បាទអើយថ្ងៃនេះខ្ញុំសូមលា  ខ្ញុំនឹងមរណាឥឡូវហើយ
ស្លាប់កូនប្រពន្ធខ្ញុំអស់ហើយ  បាទអើយនេះខ្ញុំលាបាទទៅ ៗ
អកផ្ដាំទំបានជាទកន្ទង  ស្លុះស្លុងហើរហិចគេចសំដៅ
ហើរឡើងតម្រង់អាកាសស្ទៅ  សំកាំងស្លាបទៅកាំងឈប់ឈរ ៗ
អកទួញថាឱអាកាសអើយ  និយាយផ្ដាំហើយហើរចេញចរ
លិលាហើរទៅលើអម្ពរ  ររក៏ស្រកយនិយាយថា ៗ
ខ្ញុំប្រាសប្រពន្ធនិងកូនថ្ងៃ  អាកាសអើយថ្ងៃនេះខ្ញុំលា
ខ្ញុំនឹងរងទ្រាំវេទនា  ខ្ញុំសូមមរណាឥឡូវហើយ ៗ
អកនឹកតែប្អូនកូនគូគ្រង  ស្ងួនអើយទ្រង់បងមិនមានស្បើយ
កម្មក្ខួចមកផ្ដាច់ក្នុងទ្រូងហើយ  ប្អូនអើយបងរងក្ដៅខ្លោចផ្សា ៗ
អកស្រែកទ្រហោយំកងៗ  ស្បូរសព្ទល្ហើយល្ហេងក្នុងអធ្វា
ដូចមនុស្សវង្វេងស្រែកហៅគ្នា  មុខគួរអនិច្ចាអកបក្សី ៗ
ក្សិណអកសម្រេចឱបអង្គកាយ  ពុំមាននឹកស្ដាយខ្លួនឡើយនៃ
នឹងឲ្យមរណាតាមប្អូនស្រី  អកធ្លាក់ដល់ដីលុះបង់ផ្ដាត់ ៗ
និយាយចាំថែងថ្ងៃស្រដី  ពីសត្វបក្សីជាអកសត្វ
លើកលយតាមដោយន័យបរមត្ថ  រឿងនៃពាក្យសត្យសច្ចានៅ ៗ
ថ្ងៃងពីអកញីមេម៉ាយមិញ  កាលឈ្មោលចរចេញហើរហួសទៅ
ក្នុងចិត្តតែកក្កុក្ខលក្ដៅ  ទុក្ខម្នាមួមៅមិះចេញស្ដី ៗ

អ្នកទឹករលឹកសាប់សង្ការ　　គិតថាទុប្រុសសំឡាញ់ថ្មី
ទើបកត្បប្រុសត្បូនឹងប្អូនស្រី　　កម្មពីឲ្យប្រុសអ្នកប្រាសទៅ ៗ
អកុសលផ្តល់ប្អូនពីម្ល៉េះទេ　　អស់គេមើលដូចជាប្អូនពៅ
ប្តីមុនឥតក័ត្យស្លាប់ចោលទៅ　　មិញទៅចោលខ្ញុំនសូន្យកំព្រា ៗ
ត្រាំនៅមេម៉ាយកាយកើតទុក្ខ　　វិតក្កកល់ពេលកល់វេលា
ចំណីយប់ព្រឹកមិនទឹកនា　　ឲ្យជាទ័រទេសធ្វេសស្មារតី ៗ
ទាល់បានរួមបាំទនឹងអ្នកប្រុស　　រក្សសេស្នេហ៍ជាស្វាមី
ប្អូនផ្ញើចិត្តតាប់តាំងជាប្តី　　ជាម្ចាស់ប្អូនស្រីដល់អស់ជន្ម ៗ
មិនដឹងកម្មពីឲ្យប្រុសប្រែ　　ប្រុសប្រាសប្អូនស្នេហាយូរលង់លន់
ប្អូននៅម្នាក់ឯងតែងទុក្ខធ្ងន់　　ទូរន់ឥតល្ហែតែសព្វថ្ងៃ ៗ
អកអើយអ្នកអកអ្នកឲ្យប្អូន　　និត្យនៅស្ងាត់សូន្យពន់ពេកក្រៃ
រងំរងំទន្ទឹងៈមើលផ្លូវថ្ងៃ　　ស្រមៃស្រមាក់ហាក់ថ្ងៃមក ៗ
សន្ទឹកផ្គរលាន់រន្ទាន់ឆ្ងើយ　　រំភើយព្រះពាយផាយពពក
ទឹកបឹងល្ហើយល្ហឹងរំរលក　　រលាបលោតជ្រកបូលកមរង ៗ
ពពកសាត់ជ្រែកព្រៃព្រឹក្សា　　ប្អូនស្មានដេជ្ជាធូរក្នុងទ្រូង
អរពេកខំស្រែកហៅរលូង　　ឈោនឈោងប្រុងហើរទទួលថ្ងៃ ៗ
យល់ពិតមិនមែនជាមិត្តមក　　ជ្រប់ជ្រកផ្អកផ្អឹសទង្គិះក្រៃ
ក្រៀមក្រំជាទុក្ខតែកល់ថ្ងៃ　　ស្ញើរក្សែយជីវិតគិតតែអ្នក ៗ

កាលប្រុសប្រាប់ប្អូនថាទៅឆាប់ ប្រញាប់វិលមករកគូស្ន័គ្រ
ថាបើសុខសាន្តគ្មានធុរៈ ប្រុសអ្នកវិលមករកប្អូនស្រី ៗ
ឥឡូវទៅបាត់បីថ្ងៃហើយ ប្រុសអើយក្រែងអ្នកមានក្រក្រី
ធុរៈពាក់ព័ន្ធនឹងការអ្វី ប្អូនស្រីថប់ណាស់អ្នកថ្លៃអើយ ៗ
ស្រណោះទ្រទំទំពីរនាក់ រមែងក្បែរបន្ទិតជិតបង្កើយ
ខ្ញុំអ្នកជាក់ពុំមានស្បើយ ប្រុសអើយប្រុសធ្លាប់សព្វវេលា ៗ
ឥឡូវប្រុសទៅតែឯងអាទ៌ សង្ហាតហោះហើរលើវេហាស៍
ត្រូវថ្ងៃក្តៅក្រៃក្រៀមអង្គា ត្រូវភ្លៀងរងារំងាប់ចិត្ត ៗ
ខ្ញុំធ្លាប់ប្រសព្វនៅនឹងប្អូន ក្តៅខ្លួនបក់ស្វាបកាន់ជាផ្ចិត
រងាប្អូនកទៅផ្តេកផ្តិត ខុបរិតរួមកាយសប្បាយក្រៃ ៗ
អកញ្ញាវិវេកសង្វេគនឹក សន្ធឹកហាក់ហៀបទៀបនឹងក្ស័យ
ចំណីត្រីសាច់សិងច្រើនក្រៃ អត់មិនអាស្រ័យដល់តិចឡើយ ៗ
អង្គុយតែយំទំសំកុក ដាក់មុខស្រពោនពេកពុំស្បើយ
ស្គមស្គាំងមុខមាត់មិនរីកឡើយ ល្ងង់ល្ងើយកម្ចាំងកាំងស្មារតី ៗ
លុះភ្ញាក់យំថាឱអកអូរ អកទៅបាត់យូរហោលប្អូនស្រី
អ្នកមិនស្រណោះសោះអ្នកប្តី ឬមានក្រក្រីនៅឋាននាយ ៗ
ប្អូនរិះប្អូនរង់ទុក្ខទ្វេញ ទ្រូងតឹងចង្អៀតស្មើរនឹងធ្លាយ
បែកថ្លើមប្រមាត់ខ្ទាត់រុះរាយ គ្មានអ្នកចេះទាយឲ្យដឹងជាន ៗ

ប្អូនគិតតែវែងតែងអាឡោះ ស្រណោះពាក្យមត់ទឹងរលួថ្កាន
អ្នកផ្ដាំប្អូនចាំនៅក្នុងប្រាណ ឥឡូវគ្រប់បានបីថ្ងៃហើយ ៗ
ខ្ញុំក្រែងអ្នកទៅដោយផ្លូវព្រៃ កើតហេតុកេខភ័យពុំដឹងឡើយ
ជាប់ជង់អន្ទាក់គេដឹងអើយ ប្រុសអើយប្អូនថប់គ្រប់ប្រការ ៗ
ថប់មួយព្រួយចិត្តឥតមនុស្សផង រាចងសន្ទូចយកមច្ឆា
ក្រែងអ្នកប្រុសប្រាណឃ្លានអាហារ ដោយសារហោះហើរហាលថ្ងៃក្ដៅ ៗ
អ្នកប្ដីឃើញត្រីជាប់សន្ទូច ស្ទុះប្របតម្រង់ត្រង់ស្ទុងស្មៅ
ដល់ចិចក្របកតាប់ក្រពៅ សំដៅខុសត្រីត្រូវដើងជាប់ ៗ
ទឹងផ្ទៃសន្ទូចនៃនេសាទ សង្កាតស្ទុះទៅសំពង់ជាប់
ប្រុសអើយប្អូនគិតតែរឹងថប់ ភ័យញ័រចំប្រប់ប្រាណប្អូនស្រី ៗ
ស្អែកហើយប្រុសអើយប្អូនទឹងទៅ តាមអ្នកប្រុសពៅជាស្វាមី
ឲ្យបានដឹងជាទពីអ្នកប្ដី ហេតុអ្វីក៏បានជាបាត់ម៉្លេះ ៗ
អកញីជាទុក្ខសំកុកគិត កង់ចិត្តថៃជាគ្រោមគ្នំនេះ
តាមប្ដីឲ្យល្អាចខ្មោចជួបផេះ ជួបគ្នាសិបរះរំលែមកបាន ៗ
បើប្អូនះសាះប្ដូឡមិនជួបផិត មិនជួបជួនទឹងមិត្រប្ដីបុកណា
ស្លិស្លាប់អន្តរាយមិនស្ដាយប្រាណ ទឹងរស់រូបខានមិនបានឡើយ ៗ
ទឹងរស់ថ្វីព្រោះប្ដីមួយពីរ អាប់កេរ៍អស្រូវអត្ថឥតត្រើយ
ចង់តែស្លាប់ឥឡូវឲ្យហើយ ប្រុសអើយក្រែងអ្នករស់រួចមក ៗ

ដល់ឋានពុំបានយល់ប្អូនស្រី　　អ្នកប្តីព្រួយចិត្តគិតហើររក
ដោយព្រៃតូចធំចំជ្រៀតជ្រក　　ពន្លកយាប់យ៉ាកលំបាកកាយ ៗ
អ្នកយំយូរពេកស្រែកគ្មានឈប់　　តាំងពីព្រលប់លុះសូរ្យាហាយ
រះរុងរឿងភ្លឺពន្លឺឆ្ងាយ　　ព្រះពាយផាត់ផាយពពកមីរ ៗ
ត្រសុំត្រសែតអណ្តែតជ្រះ　　ស្រឡះមេឃមើលមានរស្មី
គ្រានោះមេអកសត្វបក្សី　　ហៀបហើរតាមប្តីដាំទ្រទំ ៗ
ជានុងដើមស្រលប្អូនអ្នកនៅ　　ខ្ញុំលាអ្នកទៅទីទូរគម
តាមរកអ្នកប្តីឯព្រៃភ្នំ　　បើខ្ញុំទៅដល់យល់ស្វាមីហើយ[1] ៗ
ខ្ញុំគិតរកអ្នកជាទ្រទំ　　តែងទំនិត្យនៅជាប្រក្រតី
បើខានពុំបានជួបនឹងប្តី　　លក់ថ្លៃទ្រទំខ្ញុំលាស្លាប់ ៗ
ទ្រទំនៅក្រោយឲ្យសុខសាន្ត　　កុំឲ្យមានមនុស្សណាមកកាប់
សូមឲ្យអ្នកលាប់ស្រស់ចំណាប់　　បើខ្ញុំស្លាប់ឲ្យរស់តែទ្រទំ
ទុះទុបឯប្អូនឯនិត្យនៅ　　មិនគាប់បើទៅទីមុខគម
ស្រណោះកោះត្រីយល្វើងធារធំ　　ឈូកឧកជ្រោយជ្រុំជ្រើនអនេក ៗ
អកបើរដើរដោយនិតាល័យ　　រំភើបលើនរំសស្នេហ៍

---

១ - ត្រង់នេះលាត់ត្រូវតៅហ្មាញ្ញាយ តែយើងខ័ះបាកនែក ។ ឬថ្នូយជាថា ៖ បើខ្ញុំ [illegible]
[illegible]

ទឹកដល់សន្ធ្យាហោយំយែក ទឹកក្អែកហ្វូរស្រែកហក់ហូរខ្វាយ ៗ
ឈើជ្រុះជុះច្រើនដោយឈូងឆក មេអកមើលយល់ខ្វល់ក្នុងកាយ
ផ្អែតផ្អិតចិត្តនឹកមិនរសាយ ទឹកស្តាយកន្ទ្វងតែងអាស្រ័យ ៗ
ខ្ញុំញាំជាទុណាអ្នកថ្លៃអើយ ទីត្រង់នេះហើយដែលអ្នកថ្លៃ
អ្នកហើរនាំប្អូនមកពល់ថ្ងៃ ពិសម័យមូលមិត្តស្និទ្ធស្នេហា
នូកោះបន្ទោះកណ្ដាលបឹង ត្រង់ហ្នឹងអ្នកប្រុសចាប់មច្ឆា
បានមកឲ្យខ្ញុំបរិភោគា វៀមអើយឥឡូវទៅណាបាត់ ៗ
មិនមករកត្រីឲ្យខ្ញុំប្អូន ប្ដីនៅក្នុងព្រៃស្ងប់ស្ងាត់
ហៅហើយមិនឆ្លើយប្អូនមួយម៉ាត់ ប្ដីកាត់ចិត្តចោលសោះទៅហើយ ៗ
បើអ្នកសម្ងំទំត្រង់ណា មេត្តាឆ្លើយប្អូនកុំយូរឡើយ
អ្នកនៅព្រៃណាអ្នកប្ដីអើយ ប្រុសអើយអាណិតចិត្តប្អូនស្រី ៗ
ប្អូនអស់កម្លាំងកាំងកាយា អាហារប្អូនអត់ទេណាប្ដី
ប្អូនផ្អែតតែទុក្ខពល់ពត្រី ស្វាមីមិនមកយកប្អូនពី ៗ
ឱប្ដីសម្លាញ់ពេញចិត្តប្អូន បាត់សូន្យតើអ្នកទៅឯណា
ទៅស្រុកព្រៃស្រ[illegible]ចំការ ប្អូនមហាចំបែងតែងថប់ព្រៃ ៗ
ប្អូន[illegible] ស្រៀតស្រែកនាមកមើព្រៃ

ប្រាសប្អូនរពុកទឹកអាល័យ    អ្នកថ្លៃត្បិតជាប់ប្រុសព្រហ្មា    ៗ
អ្នកយំបណ្ដើរហើរតិចទៅ    ឃើញស្មោញទំនៅដើមទន្ទា
ទាំងពីរកៀកកិតជិតគ្នូក    អកកាធៀងធាបទន្ទាបទំ    ៗ
ប្អូនស្រណោះទឹកបុស្ដិមិនរួច    ក្រលួចកន្ទុអង្គុចង់តែយំ
ប្រឹងហាថាបងអាណិតខ្ញុំ    បងកុំលាក់លៀមនឹងប្អូនឡើយ    ៗ
ក្រែងបងបានឃើញប្ដីខ្ញុំប្អូន    គាត់មកបាត់សូន្យយូរណាស់ហើយ
មិនដឹងទៅណាអ្នកថ្លៃអើយ    ស្មោញឆ្លើយថាប្អូនបងមិនដែល    ៗ
ឃើញអកឯណាមកក្រែត្រើ    លាក់ថ្ងូបងនៅនេះយូរក្រែល
បើមើលមិនជាក់ហាក់ប្រហែល    ក្រែងទៅក្រវែលបឹងឯនាយ    ៗ
អកស្ដាប់ស្មោញប្រាប់ប្រាកដស្មោះ ទុក្ខមនោទោមនស្សទឹកពាយមាយ
ក្ដៅថ្លើមបេះដូងទ្រូងស្ទើរធ្លាយ    និយាយលាស្មោញប្រញាប់ប្រឹងហើរ    ៗ
ស្ទុះស្ទើតអើតកទទះស្លាប    ស្រែកយំដកបរៀងបណ្ដើរ
បណ្ដាយព្រៃព្រឹក្សាសរសើរ    ថាអើត្រង់ណោះអ្នកថ្លៃអើយ    ៗ
ប្រសិនប្រុសប្រាណបានមូលមិត្ត    ប្អូនគិតនាំអ្នកមកលេងហើយ
ព្រៃនេះល្អម្ល៉េះអ្នកថ្លៃអើយ    ម្ដេចឡើយអ្នកប្រុសប្រាសមិននៅ    ៗ
ព្រៃប្របមាត់បឹងសឹងស្រួលស្រោង រំលោងរំលិចទឹកជ្រោលជ្រៅ
ជាកម្មប្រុសឲ្យមកប្រាសទៅ    ប្អូនពៅពុំយល់អំពល់ទឹក    ៗ
ស្មោញហើរបានតិចលេចឃើញក្អែក    ទំមទំយំស្រែកសូរសន្ទឹក

ខ្ទះមុជហែលហក់កៅរើក　　អកទឹកស្គរក្អែកស្រែកទៅថា ៗ
អ្នកបង់ក្អែកទឹកទំនៅនេះ　　ប្រើនម៉្លេះអ្នកមកពីទីណា
ប្រយោជន៍យកត្រីទៅពិសា　　មេត្តាប្រោសប្រាប់ខ្ញុំដោយពិត ៗ
ក្អែកទឹកឮហើយឆ្លើយប្រាប់ទៅ　　ព្រៃជ្រៅនេះឯងតែងនៅទិត្យ
ទីនេះសុខសាន្តគ្មានភ័យកិត　　ចុះមិត្តឯងមកពីឋានណា
កំព្រាម្នាក់ឯងឥតគូគ្រង　　ទំនងជាមិត្តមកមានការ
រវល់កលកិច្ចដូចម្ដេចម្ដា　　ប្រាប់ពីមាសបងកុំលាន់ឡើយ ៗ
អកស្ដាប់ប្រាប់ក្អែកទៅតាមពិត　　ថាមិត្តសំឡាញ់ម្ចាស់ប្អូនអើយ
ប្អូនមានទុក្ខធំឥតស្បើយ　　បងអើយកាលណានឹងបាត់ទុក្ខ ៗ
លាក់ថ្ងៃប្ដីប្រាសពីទ្រូងប្អូន　　ស្ងាត់សូន្យទ្រនំនឹងសំបុក
ចោលប្អូនម្នាក់ឯងតែងវិតក្ក　　ប្រឹងរុកជ្រងំយំគិតគាត់ ៗ
ខ្ញុំត្រាំចាំមើលផ្លូវប្ដី　　លាក់ថ្ងៃអាហារខ្ញុំក៏អត់
តែទឹកមិនទឹកស្រែកប្រាកដ　　ឲ្យស្បថក៏ហ៊ានមិនមានក ៗ
អ្នកបង់នៅនេះជាប្រក្រតី　　ក្រែងឃើញស្វាមីខ្ញុំហើរមក
ក្អែកស្ដាប់ប្រាប់ទៅដោយសាទរ　　យើងរកស៊ីសព្វគ្រប់វេលា ៗ
ប្រទះខ្ទះផែរតែគេមាន　　គួរគ្រួមបានមិត្តប្អូនគ្នា
ទឹងទំមកទំមិនឃ្លាតឃ្លា　　យល់ជាពុំមែនជាគូប្អូន ៗ
ក្រែតែហើរទៅត្រើយឯជើង　　នោះយើងមិនដែលទៅសោះសូន្យ

បើហ្នោះអ្នកថ្ងៃម៉ៃខាងល្ហូន ក្រែងជួនប្រទះនឹងគេឯង ៗ
អកស្តាប់ក្រឡាប់ណាក្អែកទឹក ហើរហៅរឭកនឹកយំក្តែង
ប្រឹងក្រែស្រែកទឹកក្អែកហូរហែង ចាំថែងក្នុងចិត្តឥតស្រាកស្រាន្ត ៗ
ហើរកាត់តម្រង់ត្រង់ត្រើយបឹង ក្អែកគយគន់ប្រឹងមើលដែនដាន
ដោយដែនដីឈើព្រឹក្សាសាន្ត ព្រឹក្សាសោតមានមិនឃើញប្តី ៗ
ឃើញខ្ទមចំខែងទំដើមកំង ទំដើមរៃរទាំងទើបបក្ស
អកសត្វហើរកាត់ទៅដល់ខ្ទី ស្រដីសួរថាអ្នកបងខ្វង ៗ
អ្នកបានឃើញប្តីខ្ញុំផងឬ គាត់ហើរបោលខ្ញុំមកតែឯង
ប្រាំពីរថ្ងៃហើយបងអើយក្រែង មកត្រង់កន្លែងនៃអ្នកបង ៗ
បើបានឃើញផាក់កុំលាក់ឡើយ បងអើយអាណិតប្រាប់ប្អូនផង
ខ្វែងស្តាប់ឆ្លើយប្រាប់ទៅនាងសួង ថាបងមិនឃើញទេអ្នកថ្លៃ ៗ
បើបងឃើញផាក់ទឹងលាក់ថ្វី ប្រាប់ស្រីតាមត្រង់កុំសង្ស័យ
សង្សារប្អូនប្រាសប្រាំពីរថ្ងៃ ម៉េចថ្ងៃក៏បានជាព្រាត់គ្នា ៗ
អកស្តាប់ប្រាប់ខ្វែងថាបងអើយ មិនខបងស្តីឡើយរឿងប្អូនក្វា
កើតជាតិនេះមិញពេញវេទនា មេម៉ាយពីរគ្រានឹងនេះហើយ ៗ
ប្តីមុនចំណាប់ស្លាប់ទៅហោល ខ្ញុំនៅតែលគោលឯងឥតត្រើយ
កំព្រាម្នាតុំមានស្បើយ ល្វេងល្វើយគំនិតគិតផេងផោង ៗ
ផេទុក្ខរឿងកល់ភាល់មានប្តី ប្អូនស្រីបានហើរហៀនចូលហ្វូង

បានស្បើយក្នុងចិត្តឥតធេងធោង   បានប្តីដំបូងដំបន់ចិត្ត ៗ
បានគ្រាន់ស្រន់ស្រាលស្រយាលទុក្ខ   រីកមុខរីកមាត់ប្រាកដពិត
សប្បាយក្នុងប្រាណគ្មានភ័យគិត   ព្រោះត្បិតបានប្តីជាត្រីមុខ ៗ
ឥឡូវនេះកូវគាត់លាប្អូន   ថាទៅសួរគូនឯស្រែស្រុក
បើជាស្មោះស្មាទមិនមានទុក្ខ   ថាមុខជាមករកប្អូនឆាប់ ៗ
ឥឡូវទៅបាត់យូរថ្ងៃហើយ   បងអើយប្អូនភ័យស្ទើរនឹងស្លាប់
ខំហើរដើរមករកប្រញាប់   ប្អូនប្រាប់បងអស់ប៉ុណ្ណោះហើយ ៗ
ខ្វែងស្តាប់អកប្រាប់សព្វសេចក្តី   ខ្វែងស្តីថានុមាសបងអើយ
ជាកម្មអីប្អូនមិនមានស្បើយ   ស្រីអើយធ្វើម្តេចឥឡូវនេះ ៗ
តើកម្មពីព្រេងតែងតាមផ្តល់   អកប្អូនកុំឆ្ងល់វល់វិលវេះ
ប្រៀបដូចដំរីក្របីសេះ   មិនធ្លុះហៅរួចពីគេប្រើ ៗ
ចូរប្អូនកំសាន្តកុំសោយសោក   កុំសែនអាមោកមិនប្រសើរ
នាំនៀយអាត្មាណាប្រឹងហើរ   បើម្ល៉េះតើកាលណានឹងបានឆាប់ ៗ
មកស្រីយកត្រីទៅកោក្តា   មេរ៉ាកុំអត់កុំឲ្យស្លាប់
ស៊ីទៅប្អូនពៅបើប្រញាប់   តែស្តាប់ពាក្យបងកុំសង្កា ៗ
វិស័យហោះហើរប្រើកម្លាំង   មានហើយចង់ខ្លាំងដូចម្តេចម្តា
ចង់ឆាប់ប្រញាប់ដូចចិន្តា   ប្រសិនណាបើបានដូចនឹងប្តី ៗ
ស្បើយទុកជាសុខក្នុងកាយា   ញីញាក់យ៉ាងណាអ្នកអូនស្រី

កម្លាំងមានស្រោបចំណាប់ថ្មី ចំណុចប្តីចំណីប្អូនមិនសូន្យសោះ ៗ
មិនសូន្យទេមាសមេមាន់ជឿចុះ ស្រីប្រុសជួបប្រាណស្មានស្ម័គ្រស្មោះ
បើចាស់ក្រឡាស់ដូចគម្លោះ ប្រកោះប្រកិតជិតមិនឃ្លាត ៗ
ធម្មតាយើងសត្វបំបាត់កម្ម មិនដឹងលិចចាំយប់អធ្រាត្រ
មិនចេះវេះពួនដោយស្ងាត់ញាត មិនគិតមារយាទខាងតែបាន ៗ
មេអកស្តាប់ខ្ទង់កំហែងប្រាប់ ក្រឡាប់លាហើរលើថ្កាន
ទឹកពីពាក្យខ្ទង់តែងរំខាន គិតដល់ប្តីប្រាណប្រាសទៅឆ្ងាយ ៗ
ប្រឹងហើរហើយយំទំស្រែករក ទុប្រុសពន្ធករួចឆោមឆាយ
អ្នកល្អលើសអកនៅដើកាយ ប្អូនស្តាយគំនិតគិតឲ្យខុស ៗ
ប្រសិនបើប្អូនមកទឹងអ្នក សមបានរួមរក្សរូបឆ្មើមប្រុស
គ្មានទុក្ខជាសុខមិនមានមោះ ទាំងនេះជាគ្រោះផងប្អូនឯង ៗ
ឥឡូវទឹងទៅទីបានណា គនិច្ចាប្រុសត្រេចដាច់សង្វេង
ប្អូនតាមរកសព្វគ្រប់កន្ទែង ចំបែងចិត្តពេកស្ទើរបែកថ្លើម ៗ
អកហើរទៅលិចគេចទៅជើង ហើរឡើងទៅកើតគេចទៅត្បូង
ដល់ស្ទឹងវែងល្វឹងព្រៃស្រឡូង ឈើច្រើនច្រុះជ្រោងជ្រំជ្រៀតគ្នា ៗ
ប្រកិតជាប់ជិតជួរមាត់ស្ទឹង អករឹងអាណិតខ្លួនកំព្រា
ព្រួយប្រាណសង្វេគឯកអង្គា រេរករកគូគ្រេហាយ ៗ
ជានុប្រុសស្ងួនផងស៊ែរត ប្អូនពិតកើតទុក្ខប៉ុប៉ុនក៏

អ្នកចាកហោលប្អូនសូម្បីជ្រនំ    ទូរគមម្នាក់ឯងចំបែងក្រៃ ។

អ្នកនៅទីណាអ្នកថ្លៃអើយ    ប្រុសអើយប្អូនមករកយូរថ្ងៃ

ប្រុសមិនបានកញ្ញប្រុសពូថ្ងៃ    យើងនៅអាស្រ័យព្រៃនេះស្ងាត់ ។

អ្នកអើយដើមស្រលពពូលថ្កូ    ដើមក្រៈដើមគ្រលក្របពោធិសាត់

រាំងក្នុំសុក្រំព្រៃកំចាត់    ដើមផាត់ប្រមូលផ្កាលផ្អូរផ្គាប់ ។

(នៅមានត)

ឯកសារ

# ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង

ដោយ


ទេពញ៉ាប្រសើរលើវិត ម៉ែន-ឆន់

ធ្វើការនៅទីចាត់ការគរុកោសល្យ ភ្នំពេញ


## ៨- ប្រវត្តិ វត្តកោះកាពិ (សុវណ្ណបពិត)

អ្នកផ្តល់ពត៌មានគឺលោក ទៀវ-ចាន់ អាយុ ៤៥ ឆ្នាំ ជាស្មៀនសាលាសង្កាត់កោះកាពិ ។ លោក.ទៀវ-ចាន់ បានពត៌មាននេះ ពីលោក តា ង៉ែត នៅកោះកាពិ ដែលគាត់បានអនិច្ចកម្មយូរឆ្នាំហើយ ។ ក្រោយអំពីនេះ ដោយការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ កាលពីថ្ងៃ ២១-២-៦៨ ។

វត្តកោះកាពិ មានការពាក់ព័ន្ធនឹងព្រះបដិមាករ ១ អង្គ ដែលអ្នកស្រុកនិយមហៅថា ព្រះពុទ្ធអណ្តែត ។ ដូច្នេះ ការនិយាយអំពីវត្តកោះកាពិ ត្រូវតែមានរឿងព្រះអណ្តែតផងដែរ ដូចមានតទៅនេះ ។

ជាយូរឆ្នាំកន្លងមកហើយ ពុំដឹងជាសតវត្សទីប៉ុន្មាន មានព្រះពុទ្ធរូបថែបប្រក់នាគ ២ ព្រះអង្គកសាងអំពីថ្មកំ ទំហំក្នុងប្រវែង ០ម៦០ កំពស់ប្រវែង ០ម៩០ ទាំងបព្វក្តិ បានអណ្តែតតាមក្បូនឫស្សីមកពីប្រទេសកូចា មកកើតនៅក្បាលកោះកុងខាងជើង ។ អ្នកស្រុកនៅក្នុង

ជ្រោយគយ (ឡាំដាំ) បាននាំគ្នានិមន្តព្រះពុទ្ធរូបនេះ មកទុកនៅភូមិរបស់ខ្លួន ដោយកសាងជាសាឡា ១ តម្កល់ព្រះពុទ្ធរូបសម្រាប់ជាទីសក្ការៈបូជា និងធ្វើបុណ្យទានតាមគន្លងព្រះពុទ្ធសាសនា ។

ចាប់តាំងពីពេលនោះមក បេះតែមានឧបទ្ទវហេតុ ធ្វើឲ្យអ្នកស្រុកកើតជម្ងឺ និងមានគ្រោះថ្នាក់ផ្សេងៗ ទើបអ្នកទាំងអស់គ្នាសន្និដ្ឋានថាប្រហែលជាព្រះពុទ្ធរូបនេះឯងដែលជាអ្នកឲ្យទុក្ខទោស ហើយក៏នាំគ្នាដង្ហែយកទៅតម្កល់ទុកនៅកោះប៉ោ ។

បន្ទាប់អំពីនេះ អ្នកភូមិនៅជ្រោយគយ បានរុះរើទីលំនៅមកនៅកោះកាពិ ដោយរុះទាំងសាឡាមកផង ហើយក៏កសាងជាវត្ត ១ នៅត្រង់ចង្កេះភ្នំកោះកាពិខាងទិសអគ្នេយ៍ បានដាក់នាមថា វត្តប្រជុំជន ដែលមានលោកគ្រូព្រះនាម និត ជាចៅអធិការ ។ វត្តប្រជុំជននេះ មានសភាពរុងរឿង ហើយមានលោកគ្រូចៅអធិការបន្តបន្ទាប់គ្នាដូចតទៅ គឺ លោកគ្រូភ និត លោកគ្រូយ៉ុង លោកគ្រូ ឡេក លោកគ្រូប៊ើម និង លោកគ្រូដីត ។

បំណោះក្រោយមក ពុំដឹងជាក្នុងឆ្នាំណា ក្នុងពេលលោកគ្រូព្រះនាម ពៀម-វៀន ជាចៅអធិការនិងជាព្រះអនុគណ បានរុះរើព្រះវិហារពីចង្កេះភ្នំនេះ ទៅកសាងនៅលើកំពូលភ្នំវិញ នៅត្រង់កន្លែងសព្វថ្ងៃនេះ ទុកតែពុំឲ្យស្ថិតនៅចង្កេះភ្នំដដែល ។

បន្ទាប់អំពីការរុះរើព្រះវិហារមក កសាងលើកំពូលភ្នំនេះបានប្រហែល ៩ ឬ ១០ ឆ្នាំ ទើបអ្នកស្រុកនៅកោះប៉ោ បាននាំគ្នាដង្ហែព្រះអណ្ដែតនោះមកប្រគល់ឲ្យអ្នកស្រុកកោះកាពិវិញ ព្រោះគេយល់ឃើញថា តាំងពីព្រះពុទ្ធរូបនេះទៅតង់នៅស្រុកគេវេលាណា អ្នកស្រុកពុំបានសេចក្ដីសុខសោះ ។ អ្នកស្រុកកោះកាពិក៏ទទួលយកព្រះពុទ្ធរូបនេះមកតម្កល់ទុកនៅព្រះវិហារ ។

លោកគ្រូ ជៀប-វៀន សុគតនៅថ្ងៃទី ៩ កុម្ភៈ ១៩៥០ ក្នុងព្រះជន្មាយុ ៥៦ ហើយត្រូវលោកគ្រូព្រះនាម ឥន្ទ-សំអ៊ាន ឡើងជាចៅអធិការ ។ លោកគ្រូ ឥន្ទ-សំអ៊ាន បានសុំកែនាមវត្តពីវត្តប្រជុំជនមកជាវត្តសុវណ្ណបពិតវិញ ។ ក្រៅអំពីនេះលោកបានសាងព្រះចេតិយ ១ នៅខាងត្បូងព្រះវិហារសម្រាប់បញ្ចុះព្រះអដ្ឋិធាតុលោកគ្រូ ជៀម-វៀន គឺកសាងក្នុងឆ្នាំ ១៩៦០ ព.ស. ២៥០៤ ។ លោកគ្រូ ឥន្ទ-សំអ៊ាន បានប្រព្រឹត្តអាស់ខុសខាងផ្លូវនយោបាយ ថេរសភាបានផ្សឹកអំពីភិក្ខុភាព ហើយរាជការចាប់ខ្លួនឃុំឃាំងក្នុងឆ្នាំ ១៩៦៤ ។

បន្ទាប់មក បានលោកគ្រូព្រះនាម ចៅ-ទួន ជាចៅអធិការ ប៉ុន្តែមិនយូរប៉ុន្មានលោកគ្រូអង្គនេះក៏លាចាកសិក្ខាបទក្នុង គ.ស. ១៩៦៧ ទើបបានលោកគ្រូព្រះនាម ហេង-ឡុន ជន្ម ២៣ ធ្វើជាចៅអធិការ ក្នុងបច្ចុប្បន្ននេះ ។

នៅក្នុងឆ្នាំ ១៩៦៥ រាជាមានទិមន្តព្រះគ្រូ ព្រះនាម ហ៊ី វ៉ើ ពីបាត់ដំបងមកធ្វើជាព្រះអនុគណស្រុកកោះកុង ហើយឲ្យមកគង់នៅ វត្តសុវណ្ណបពិតនេះ ។

នៅឆ្នាំ ១៩៦៦ មានកិក្ខុ ១ អង្គកើតរោគវិកលចរិត បានទៅប្រានព្រះពុទ្ធរូបអណ្តែតទឹកនោះដួលធ្លាក់ពីលើបល្ល័ង្ក បណ្តាលឲ្យបាក់ព្រះសុរង ហើយរំលងពីនោះបាន ២-៣ ខែព្រះគ្រូអនុគណព្រះនាម ហ៊ីវ៉ើ បានផ្ទុចផ្តើមដង្ហែព្រះអណ្តែតនោះតម្កល់នៅវត្តជោតញាណ ក្រុងខេមរភូមិន្ទ (ដងទង់) ។

សមិទ្ធិនៅវត្តសុវណ្ណបពិតមានដូចតទៅ :

–នៅលើកំពូលភ្នំ មានព្រះវិហារ សាងអំពីឥដ្ឋប្រក់ក្បឿង ១ និងចេតិយ ១ ។

នៅចង្កេះភ្នំ មានកុដិ ២ សាលាបុណ្យ១, កុដិបាយ ១ ដែលសុទ្ធតែសង់អំពីឈើប្រក់ក្បឿង ។

–ជ្រុងផ្លូវទៅខាងកើត មានបន្ទប់រៀនសង់អំពីឈើ ប្រក់ស្លឹក ដែលជាសាខា នៃសាលាបឋមសិក្សាបំពេញវិជ្ជាកោះកាពិ ។

ព្រះសង្ឃក្នុងវត្តសព្វថ្ងៃគឺ :

| | | |
|---|---|---|
| ព្រះគ្រូអនុគណ | ១ | អង្គ |
| លោកគ្រូចៅអធិការ | ១ | – |

ភិក្ខុបរិស័ទ ២ អង្គ

មានបុរាណវត្ថុមួយមុខ ដែលគួរតែលើកយកមកនិយាយផងដែរ គឺត្រង់កន្លែងកុដិដែលព្រះសង្ឃគង់សព្វថ្ងៃនេះ បានជីកដីលាក់ចង្កេះកំផ្ទើ ជាទីណាន់ ៗ កាលជីកដីនោះ គេប្រទះឃើញព្រះពុទ្ធរូបតូច ៗ ជាច្រើនអង្គកប់នៅក្នុងដី មានទំហំតាំងពីប៉ុនកដៃ ប៉ុនមេដៃ រហូតដល់ប៉ុនកូនដៃ ហើយភាគច្រើនបានកសាងអំពីស្ពាន់ ប៉ុន្តែមានអង្គខ្លះដែលតូច ៗ ប៉ុនកូនដៃ កសាងអំពីវត្ថុមួយប្រភេទផុយ ៗ ដូចជាដីឥដ្ឋ ប៉ុន្តែពុំលាយទេ ហើយច្រើនតែបែបប្រក់នាគ មានអង្គខ្លះពណ៌សប្រផេះ និងមានអង្គខ្លះពណ៌ខ្មៅ ៗ បើតាមការយល់របស់អ្នកនិពន្ធថា ប្រហែលជាចាស់ ៗ ជំនាន់មុន បានកសាងព្រះពុទ្ធរូបនេះហើយសេកមន្តអាគម សម្រាប់ជួយការពារខ្លួនក្នុងគ្រាមានចម្បាំង ដោយយកមកចងក ឬក្រវាត់ចង្កេះ ឬបៀម ឬបង្កប់ក្នុងដងអាវុធ លុះផុតពេលចម្បាំង ក៏ប្រមូលយកមកកប់ទុកនៅទីនេះ ៗ ព្រះពុទ្ធរូបដែលគាស់បានមកនោះ ត្រូវបានគេយកទៅតម្កល់នៅ លើបល្ល័ង្កព្រះ ក្នុងព្រះវិហារចំនួន ១២៦ អង្គ នៅសល់អំពីនោះមានទុកតាមកុដិលោកខ្លះ និងអង្គខ្លះទៀតត្រូវអ្នកស្រុកគេរើសយកទៅទុកជាទីសក្ការៈ ហើយបើតាមការយល់របស់លោកគ្រូព្រះនាម ហេង-ឡុន ជាចៅអធិការថា ប្រហែលជានៅមានកប់ក្នុងដីទៀត ព្រោះយូរ ៗ មានគេប្រទះឃើញឯនេះ ១ អង្គ ឯនោះ ១ អង្គ ដែលទើបនឹងលេចចេញពីក្នុងដីដោយសារមានភ្លៀងហូរច្រោះ ៗ

## ៥- អំពីកោះមូល

| |
|---|
| ដោយការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ ម៉ែន-ទន់ កាលពីថ្ងៃ ២១-២-៦៨ ។ |

កោះមូលស្ថិតនៅក្នុងសង្កាត់កោះកាពិ - ស្រុកកោះកុង - ខេត្តកោះកុង ។ កោះនេះជាកូនកុំតូចមួយ បើវាស់កាត់ទទឹងមានទំហំប្រហែល ២០០ម. ហើយនៅដាច់អំពីដីគោក ។ ប៉ែកខាងកើតឃ្លាតអំពីជ្រោយគយ (ឡាំដាំ) ប្រហែលជាង ២០០ម. ប៉ែកខាងត្បូងឃ្លាតអំពីក្បាលកោះកុងប្រហែល ៦០០ម. ហើយនៅប៉ែកខាងលិច និងខាងជើង ជាលំហសមុទ្រដ៏ធំធេង ។

បានជាហៅកោះមូល ព្រោះគេចង់និយាយថា កោះនេះរាងមូល ប៉ុន្តែតាមពិតកោះនេះពុំមែនរាងមូលដូចផែនស្ករនោះទេ គឺរាងទ្រវែងកោងបន្តិចដូចផ្លែស្វាយ ។

កាលពីសម័យមុន កោះនេះជាទីតាំងដំបន់រដ្ឋបាល ក្រោយមកទៀត ក្នុងសម័យអាណាព្យាបាលបារាំង ជាទីតាំងសាលាស្រុក និងក្រុមគយ ។ ដូច្នេះហើយ បានជានៅលើកោះមូល ឃើញមានគេហ-ស្ថានចាស់ៗ សង់អំពីឥដ្ឋ និងបេតុងអារមេ ដូចជាសាលាស្រុក អាងទឹកនិងឃ្លាំងដាក់អំបិល ។ គេហស្ថានទាំងនេះ មានសភាពទ្រុឌទ្រោមទៅហើយ ក្រៅអំពីនេះមានគេហស្ថានមួយនៅល្អ គឺមន្ទីរគយ ដែល

សព្វថ្ងៃនេះមានបុគ្គលិកក្រុមគយនៅធ្វើការជាអចិន្ត្រៃយ៍ ។ នៅជុំវិញគេហស្ថានខាងលើនេះឃើញមានដំណាំដូងខ្ពស់ៗ និងរុក្ខជាតិឯទៀតៗ ដុះតាមចន្លោះថ្មផ្ទាំងសីលា ដែលគួរប្រដូចទៅនឹងព្រៃភ្នំទាំងឡាយដែរ ។

នៅតាមចង្កេះភ្នំ មានដំណែលផ្លូវព័ទ្ធជុំវិញ ហើយនៅខាងកើត មានផ្លូវថ្មលំមួយបើកដោយបំណែកថ្មភ្ជាប់នឹងប្រជាយគយ មានទទឹងប្រហែល ៤ម. ។ កាលពីមុន ផ្លូវដែលព័ទ្ធជុំវិញភ្នំ និងថ្មលំធ្លងទៅប្រជាយគយនោះ គេអាចបើកបររថយន្តបាន ប៉ុន្តែតាំងអំពីស្រុកកើតអសន្តិសុខដោយយៀកមិញកុកត្បាត ហើយថែមត្រូវរុះរើសាលាស្រុកមកតាំងនៅត្រើយខាងកោះកាពិះវាលរណា ផ្លូវដែលព័ទ្ធជុំវិញភ្នំនោះត្រូវបាក់ក្រហេងក្របូង់ និងមានដើមឈើដុះទ្រុបទ្រុល ហើយក្លាយទៅជាផ្លូវដើរយ៉ាងតូចសម្រាប់បុគ្គលិកនៅទីនោះដើរចេញ-ចូល ។

កោះមូលជាដំបន់គយសំខាន់បំផុតនៅខេត្តកោះកុង ។ ឈ្មួញបរទេស មានសិង្ហបុរីនិងសៀម ជាដើម ដែលមកទិញត្រី ត្រូវតែចូលមកចតនាវានៅ កោះមូលនេះ ហើយនៅពេលចូលមកដល់ក្តី មុននឹងចេញដំណើរទៅវិញក្តី ត្រូវបានទទួលការពិនិត្យអំពីអ្នករាជការក្រុមគយ ។

នៅលើកោះមូល ពុំមានប្រជាពលរដ្ឋរស់នៅជាឯកជនទេ មានតែបុគ្គលិករាជការស៊ីវិល និងទាហាន គឺបុគ្គលិកក្រុមគយមាន ៤នាក់ ទាហានខាងក្រុមនាវិក ១ នាក់ និងក្រុមគ្រួសារនៃបុគ្គលិកទាំងនេះ ។

# ១០– ប្រវត្តិយាយម៉ៅ

អ្នកផ្តល់ពត៌មានគឺលោក ទៀវ-ចាន់ អាយុ ៤៥ ឆ្នាំ ជាស្មៀនសាលាសង្កាត់កោះកាពិ ។ លោក ទៀវ ចាន់ បានដឹងរឿងនេះដោយសារលោកតា ង៉ែត នៅកោះកាពិ ដែលគាត់បានទទួលអនិច្ចកម្មយូរឆ្នាំហើយ ។

យាយម៉ៅ ជានាមនៃវត្ថុសក្តិសិទ្ធិមួយ ដែលប្រជាពលរដ្ឋនៅតាមមាត់សមុទ្រនិងកោះនានានៃខេត្តកោះកុង បានគោរពបូជាស្ទើរគ្រប់គ្នា ។ ឯប្រវត្តិនៃវត្ថុសក្តិសិទ្ធិនោះមានដូចតទៅ :

ក្នុងកាលដែលកន្លងយូរហើយ ពុំដឹងជាសតវត្សទីប៉ុន្មាន និងពុំដឹងជាក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយអង្គណា មានមន្ត្រីសក្តិធំម្នាក់នាមពុំប្រាកដ បានកាន់កាប់ការពារការជានាយដំបន់នៅតាមឆ្នេរសមុទ្រចាប់តាំងពីភមរហូតទៅទលនឹងព្រំដែនសៀម ។

មន្ត្រីនេះបានតាំងដំបន់ធ្វើការនៅកោះមូល ព្រោះកោះនេះនៅជិតទល់ដែនសៀម ហើយមានលំហសមុទ្រដ៏ធំ អាចមើលឃើញទូក-សំពៅចេញចូលបានដោយងាយក្នុងកិច្ចការពារព្រំដែន ។

លោកនាយដំបន់នេះមានភរិយា ឈ្មោះ ម៉ៅ ។ លោកស្រី ម៉ៅ ជានារីមានសន្តានចិត្តប្រាកដនិយម និយាយម៉ាត់ណោ ម៉ាត់ហ្នឹង ហើយរឹងរុះផង ។ ប្រជាពលរដ្ឋទាំងប្រុស ស្រី ចាស់-ក្មេង តែងខ្លបខ្លាច

អំណាចលោកស្រីជាងលោកប្រុសទៅទៀត ។ ក្រៅអំពីនេះ លោកស្រីមានបុគ្គលិកលក្ខណៈមួយទៀត គឺកំណាញ់គ្រឿងកាមគុណ ។ ស្វាមីរបស់លោកស្រី ។ បានប្តេជ្ញាចិត្តជាដាច់ខាត ថាមិនឲ្យមានស្រីដទៃណាមកលាយឡំមួយជាពីរឡើយ ។

ចំណែកលោកស្រីវិញ មានអធ្យាស្រ័យផ្ទុយស្រឡះអំពីគំនិតលោកស្រី គឺលោកមានប្រជាប្រិយភាព មានការរាប់អានក្រៅប្រជា មិនប្រកាន់ឋានៈអ្នកមាន ឬអ្នកក្រឡើយ ហើយក្រៅអំពីនេះលោកក៏ពុំប្រកាន់ថា ក្នុងជាតិនេះអាត្មាអញត្រូវមានប្រពន្ធតែមួយនោះទេ ដូច្នេះហើយបានជាលោកហានក្បត់ចិត្តលោកស្រី មៅ ដោយបានទៅស្រឡាញ់ស្រីមួយរូបទៀត ឈ្មោះនាង ប៉ែន ។

នាង ប៉ែន មានរូបសម្បត្តិឆើតឆាយជាងលោកស្រី មៅ ហើយវ័យក៏នៅក្មេងជាង ធ្វើឲ្យលោកងាយដិបទន់ចិត្តលែងខ្លាចលោកស្រីជាភរិយា ហើយថែមទាំងពុំសូវបាននៅបរិត្យនឹងលោកស្រីទៀត ។

ដោយកម្លាំងតាមតណ្ហាព័ទ្ធពេលលោកស្រី ធ្វើឲ្យលោកស្រីក្តៅក្រហាយចិត្តដូចគេយកភ្លើងក្ដៅមកដុតក្នុងដើមទ្រូង ។ លោកស្រីបានដាក់កំហិតថា បើលោកប្រុសមិនលះបង់នាង ប៉ែនចោល ទេលោកស្រីនឹងធ្វើអត្តឃាតខ្លួនដោយវិធីណាមួយពុំខាន ។ ពាក្យប៉ុណ្ណោះគួរតែលោកប្រុសស្តាប់បាន ហើយប្រញាប់ប្រញាល់ពោះក្រោយជាបន្ទាន់ ព្រោះ

ផ្ទាប់ដឹងចិត្តលោកស្រីស្រាប់ ប៉ុន្តែដោយស្នេហាជាប់ជាំងកម្លាំងតាមជាប់ទ ធ្វើឲ្យសំដីលោកស្រីសាត់តាមខ្យល់ ពុំចូលត្រចៀកលោកប្រុសសោះឡើយ មួយលើកជាដែល, ពីរលើកព្រងើយ, បីលើកលើសដើម ។

ឱ ! កម្លាំងស្នេហា ពេកកាមគុណ តើរាបន្ទំចិត្តលោកស្រីឲ្យលោតដល់កម្រិតណា ! ពាក្យប្ដេជ្ញារបស់លោកស្រីមានប្រសិទ្ធិភាពឬទេ ! ។

មែន មនុស្សប្រមើទឹកឆ្ងល់គ្រប់គ្នា ថាតើលោកស្រីសម្រាន្តអីកយូរម្ល៉េះ ! ម៉ោង ៦-៧ ហើយនៅមិនទាន់ក្រោក ទើបចាត់គ្នាឲ្យទៅលបមើល ។ ពេលនោះការងឿងឆ្ងល់កាន់តែខ្លាំងឡើង ព្រោះពុំឃើញរូបលោកស្រីនៅសម្រាន្តសោះឡើយ ។ សភាពជ្រួលច្របល់ក៏កើតមានឡើង ទាំងលោកនាយដំបន់ ទាំងអ្នកធ្វើការក្រោមបង្គាប់ ព្រមទាំងអ្នកបម្រើប្រុស-ស្រី នៅខ្ទង់ដើង អ្នកខ្លះរកមើលសព្វកៀនកោះក្នុងផ្ទះ ខ្លះមើលតាមដើមឈើក្រែងលោកស្រីចង់ក ខ្លះដើរមើលតាមមាត់ទឹក ប៉ុន្តែនៅតែពុំឃើញទៀត ទើបចាត់គ្នាឲ្យទៅរកនៅទីឆ្ងាយៗ ក្រែងលោកស្រីនិរទេសខ្លួន ខ្លះទៅជ្រោយគយ (ឡាំងជាំ) ខ្លះទៅកោះកាពិ ខ្លះទៅពាមក្រសោប និងខ្លះទៀតទៅកោះកុង . . . ។

ពុំខ្វះ នៅព្រឹកនៃថ្ងៃបន្ទាប់ គេឃើញសពលោកស្រីអណ្ដែតទឹកក្នុងទៅជាប់បោះកោះអូល ប៉ែកខាងទិសពាយព្យ ហើយនៅកៀរូបកាយ

សពពុំមានស្នាមដាំដំអ្វី ទើបនាំគ្នាសន្និដ្ឋានថាលោកស្រីប្រាកដជាលោតទឹកសម្លាប់ខ្លួន ។

ក្រោយដែលស្រង់សពយកមកលើគោកហើយ លោកនាយដំបន់ និងសហការី បានចាត់ចែងធ្វើកេងតម្កល់សព និងរៀបធ្វើបុណ្យតាមប្រពៃណីយ៉ាងអុកធឹក ។ បន្ទាប់មក លោកនាយដំបន់ក៏លើកនាងប៉ែនឲ្យឡើងជាភរិយាពេញទី ហើយត្រូវបានគេហៅថាលោកស្រី ។ ជាប់រហូតទៅ ។

រំលងអំពីមរណកាលនៃលោកស្រី ម៉ៅ បាន ៣-៤ ខែ អ្នកស្រុកនៅក្នុងដំបន់នេះបេះតែមានជម្ងឺ បន្តិចអ្នកនេះឈឺ បន្តិចអ្នកនោះឈឺ ប្រុសក៏មាន ស្រីក៏មាន ចាស់ក៏មាន ក្មេងក៏មាន ហើយពុំមានគ្រូហ្មណាមើលជា ទោះបីបន់ស្រន់អារក្ស-អ្នកតា ឬសែនព្រេនថ្វាយអ្វីៗ ពុំជាដែរ ខ្លះក៏បាត់បង់ជីវិត ខ្លះក៏នៅទុរនទុក ស៊ើរស្លាប់ស៊ើររស់ ។

ហេតុតែសំណាងមាន អាយុមិនទាន់អស់មិនស្លាប់ ស្រាប់តែមានស្រីម្នាក់យំគក់ទ្រូង គក់ស្មា ហើយស្រែកសួរអ្នកកំដរជម្ងឺថា ស្គាល់យើងទេ ! យើងជានរណា ! យើងស្លាប់ដោយសារអ្វី! អ្នកទាំងអស់គ្នាស្រឡាំងកាំង ក្នុងភាពសន្និដ្ឋានថាច្បាស់ជាខ្មោចចូល ហើយក៏បន្លឺឡើងថា យើងខ្ញុំពុំស្គាល់ទេ សូមមេត្តាប្រាប់យើងខ្ញុំផង លោកជាអ្នកណា ! លោកស្លាប់ដោយសារអ្វី ! រូបនោះឆ្លើយថា : យើងជាលោក

ស្រី មៅ យើងស្លាប់ដោយឈឺចិត្តនឹងប្ដីមានសហាយ បើចង់ជា ត្រូវរករបស់មកថ្វាយយើង ៗ

គ្រួសារអ្នកជម្ងឺក្រេកអរណាស់ នាំគ្នាសួរអំពីរបស់ដែលត្រូវថ្វាយ តើរបស់អ្វីទៅ ? មាន់ស្ងោរឬ ? ទេ ក្បាលជ្រូកឬ ? ទេ អាហារសាហាវឬ ? ទេ កន្ទួនបាក់កឬ ? ទេ កីរឬ ? ទេ ស្រោមឬ ? ទេ អ្នកទាំងអស់គ្នាដេញដោលសួរអំពីរបស់ដែលខ្មោចបីសាចតែងត្រូវការ ប៉ុន្តែរូបនោះចេះតែឆ្លើយបដិសេធដាច់អហង្ការ យូរណាស់ទើបឆ្លើយទាំងអិមអៀមថា : រកគ្រឿងកាម ១ គូ មកថ្វាយយើង ទើបយើងឲ្យជា ៗ អ្នកទាំងអស់គ្នានៅតែស្ដាប់ពុំទាន់យល់ច្បាស់ ក៏នាំគ្នាសួរបញ្ជាក់ទើបរូបនោះឆ្លើយទាំងកំហឹងថារកលឹង្គឲ្យយើង ១ គូព្រោះយើងខ្វះគ្រឿងនេះយូរហើយ ថាតែប៉ុណ្ណោះក៏ចេញពីរូបបាត់ទៅ ហើយទាំងរូប ទាំងស្នំ អត់ព្រាំពុំបានក៏នាំគ្នាសើចគឹលឡើង ។

អ្នកទាំងអស់គ្នាឈប់សង្ស័យ ហើយក៏ចាត់ចែងយកឈើមកធ្វើជាលឹង្គ ១ គូរដាក់ថ្វាយ ឯអ្នកជម្ងឺក៏បានជាសះស្បើយតែរៀងខ្លួន ៗ មុនដំបូងគេពុំទាន់កំណត់កន្លែងដែលត្រូវដាក់ថ្វាយទេ គឺគេយកលឹង្គតថ្វាយទៅដាក់នៅក្រោមដើមឈើធំ ឬនៅលើដុំថ្ម ហើយអុជធូបនិយាយទៅ លុះយូរ ៗ ទៅ ទើបគេនាំគ្នាសង់ជាអាស្រម ៗ ទី ១ គេសង់នៅកោះមូលខាងទិសពាយព្យ ត្រង់កន្លែងដែលឃើញពស់អណ្ដែតជាដំបូង បន្ទាត់

មកៈនៅកោះកាពិ រួចនៅតាមមាត់សមុទ្រ និងកោះនានា ។

ចំណែកអ្នកនិយមជឿវិញ មិនគ្រាន់តែអ្នកមានជម្ងឺប៉ុណ្ណោះទេ ទោះបីអ្នកធ្វើដំណើរដោយទូក សំពៅ តាមសមុទ្រដែលភ័យខ្លាចអំពីព្យុះខ្យល់ និងគ្រោះកាចផ្សេង ៗ ទៀតក៏តែងសំបូងសង្រួងបន់ស្រន់លោកស្រី មៅ សុំសេចក្ដីសុខគ្រប់គ្នា ។

ចាប់តាំងពីពេលនោះមក ប្រជាពលរដ្ឋនៅតាមមាត់សមុទ្រ និងតាមកោះនានា តាំងពីភូមិកមហូតដល់ព្រំប្រទល់ដែនសៀម តែងគោរពបូជាលោកស្រី មៅ គ្រប់គ្នា ព្រោះកាលនៅរស់នៅឡើយ លោកស្រីមានអានុភាពលើប្រជាពលរដ្ឋនៅដំបន់នេះ លុះអនិច្ចកម្មទៅហើយ ក៏វិញ្ញាណក្ខន្ធលោកស្រីនៅមានឥទ្ធិពលខ្លាំងក្លាលើដំបន់នេះទៀត ។ ព្រាយបីសាចអារក្សអ្នកតា ឯទៀត ៗ ក៏ខ្លបខ្លាចអំណាចលោកស្រីទាំងអស់ ដូច្នេះហើយបានជាអ្នកស្រុកនៅដំបន់នេះ បើមានជម្ងឺ បួងបន់ស្រន់ព្រះឿងអ្វី គេពុំដែលបន់ស្រន់គុសក្ដិសិទ្ធណាក្រៅពីលោកស្រីមៅ ឡើយ ហើយចំណេរយូរៗទៅ ពាក្យថាលោកស្រី មៅ ក៏ក្លាយមកជា យាយមៅ រហូតដល់សព្វថ្ងៃ ។

រីឯសំណែនដែលគេសែនថ្វាយវិញ នៅគ្រប់អាស្រមទាំងអស់ឃើញមានសុទ្ធតែរូបលិង្គរជាតំនរៈដែលគេធ្វើអំពីស៊ីម៉ងក៏មាន អំពីឈើក៏មាន ប៉ុន្តែភាគច្រើនគឺឈើ ដែលមានខ្វះត្រូវបានលាបពណ៌ជាលំអផង លុះ

មានច្រើនពេកទៅ បណ្ដាលឲ្យគណៀវស៊ីលិង្គឈើតាំងនោះដូច្នេះហើយ បានជានៅឆ្នាំ ១៩៦៦ បរិស័ទ បាននាំគ្នាធ្វើពិធីមួយ សុំរើយកតង្វាយលឹង្គឈើចាស់ ៗ ទៅដុតចោលមួង ហើយសាងរូបលឹង្គថ្មីថ្វាយជំនួសវិញ ។

ក្រៅអំពីរូបលឹង្គដូចបានពោលខាងលើនេះ ឃើញមានតង្វាយដទៃទៀតគឺឡេង់ទិងគេងឡានខ្លះដែរ ទំនងជាអ្នកនិយមចិនគេដាក់ថ្វាយ ជាពិសេសតាមរបៀបអ្នកតាចិន ។

តាមពត៌មានមួយផ្នែកទៀតថា លោកស្រី ប៉ែន ជាភរិយាចុងនៃលោកនាយដំបន់ក៏ស្លាប់ទៅកើតជាព្រាយបិសាចដែរ ដូច្នេះហើយបានជានៅកោះមូលមានអាស្រម ២ គឺអាស្រម ១ នៅជ្រុងខាងទិសពាយព្យនៃកោះ ជាអាស្រមរបស់យាយ មៅ និងអាស្រម ១ ទៀតនៅជ្រុងខាងទិសទក្សិណនៃកោះ ជាអាស្រមរបស់យាយ ប៉ែន ប៉ុន្ដែយាយ ប៉ែននេះពុំសូវមានគេស្គាល់ និងពុំមានអ្នកណាបន់ស្រន់អ្វីទេ ។

## ភាសាដែលគួរបញ្ជាក់ក្នុងរឿងនេះ

– អាការសាហាវ គឺស្រា ភាសាសម្រាប់និយាយចំពោះខ្មោចបិសាច

– កន្ទួនបាក់ក ,, បេក -ដ-

– កីរ ,, ក្បេង -ដ-

– ស្រោម ,, អាវ -ដ-

— ឡង់ គឺ កូនច័ត្រតូច ៗ គ្រឿងសំណែនខាងអ្នកតាចិន

គេងឡាង " គោមធ្វើអំពីក្រដាសក្រហម

— ស៊ុំ " អ្នកនិយាយភាសាផ្ទាល់នឹងខ្មោច

## ១១– ឈូងខ្លែង

អ្នកផ្ដល់ពត៌មានគឺលោក តាន់-ឡឹក នាយជំបន់អធិការកិច្ចបឋមសិក្សា ស្រុកកោះកុង និងតាមការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ កាលពីថ្ងៃ ២០-២-៦៨ ។

ឈូងខ្លែង ស្ថិតនៅត្រង់ក្បាលកោះកុងខាងជើង និងខាងទិសនិរតីនៃ កោះមូលមានចម្ងាយប្រហែល ៣ គម ពីកោះមូល នៅក្នុងសង្កាត់កោះកុង ស្រុកកោះកុង ខេត្តកោះកុង ។ បានជាគេហៅថា ឈូងខ្លែងមកពីឈូងនេះផតចូលទៅដីគោក មានកងដូចខ្លែង "អ្នកខ្លះហៅ កៅកើ មកពីភាសាសៀមថា កៅ ខ្មែរថាឈូង សៀមថាកើ ខ្មែរថា ខ្លែង ។

ឈូងនេះមានទំហំផតចូលទៅប្រហែល ៩០០ ម. និងទទឹងមាត់ប្រហែល ៦០០ ម ។ នៅពីមុខមានលំហសមុទ្រ ហើយនៅពីខាងក្រោយមានសុទ្ធតែព្រៃ និងភ្នំ ប៉ុន្តែពុំមានបណ្ដាជនសង់ផ្ទះនៅ ឬប្រកបរបរស្រែ ចំការនៅទីនោះទេ ។ នៅមាត់ឈូងខាងលិច ឃើញមានម៉ុងបញ្ចុះសព ១ (ផ្នូរខ្មោច) ដែលអ្នកស្រុកនៅកោះកាពិបាន យកទៅ

កប់តាមរបៀបចិន ។

នៅក្នុងផ្ទៃឈូង មានឡចំហុយត្រីបាតូ ២ កន្លែង ដែលជារបស់ឯកជន ។ ឡទាំង២ នោះគេសង់ពេងយ៉ាងវែងនៅកណ្ដាលទឹក សសរសុទ្ធតែកូនឈើ ឯជំបូលប្រក់ស្លឹក ហើយនៅក្នុងពេងនោះមានឡជាច្រើនតម្រៀបគ្នាជាជួរ ឡនីមួយ ៗ មានទំហំទទឹងមាត់ប្រហែល ៨០ ស.ម. និងកំពស់ប្រហែល ១ម. ដោយមានក្ដាប់ខ្ទះសម្រាប់ចំហុយនៅមាត់ឡនោះផង បើនឹងហៅថា ជើងក្រានគុកជួរច្រះវិញក៏បាន ។ ក្រៅអំពីឡ ឬជើងក្រានគុកនេះយើងឃើញមានសម្ភារៈឯទៀត ៗ និងពួកកម្មករជាច្រើននាក់នៅធ្វើការផង ។

ឡដែលធំសម្បើមជាងគេ គឺឡយីហោ ប៉ោ-លី ។ ថៅកែឡនេះទៅពីស្រុកកោះធំ ខេត្តកណ្ដាល ឯឡ ១ ទៀតជារបស់ថៅកែ ពិន ប៉ុន្តែយើងពុំបានចូលទៅក្នុងពេងនោះទេ ។

នៅពេលដែលអ្នកនិពន្ធយើងទៅមើលឡនោះ អ្នកស្រីម្ចាស់ឡយីហោ ប៉ោ-លី បានពន្យល់អំពីរបៀបចំហុយត្រី និងអំពីបច្ចេកទេសផ្សេងៗខាងអាជីវកម្មចំហុយត្រី ។

# ១២- ភូមិ និងវត្តកោះស្រឡៅ

អ្នកផ្ដល់ពត៌មានគឺលោក ផាំ-ញា អាយុ ៥១ ឆ្នាំ មេភូមិនៅកោះស្រឡៅ និង លោក លី-គុង សេង នាយកសាលារៀនកោះស្រឡៅ និងដោយការពិនិត្យផ្ទាល់ ដល់ទីកន្លែងនៃអ្នកនិពន្ធ កាលពីថ្ងៃ ២៤-២-៦៨ ។

ភូមិនិងវត្តកោះស្រឡៅ ពុំមានប្រវត្តិវែងឆ្ងាយពេកទេ ហើយនៅពេលដែលអ្នកនិពន្ធយើងធ្វើដំណើរទៅនោះ ចំលើពេលដែលលោកគ្រូចៅអធិការពុំគង់នៅ ជាហេតុឲ្យយកពត៌មានពុំបានសព្វគ្រប់ ៗ ដូច្នេះយើងសូមបញ្ចូលភូមិ និងវត្តកោះស្រឡៅឲ្យមកនៅតែរឿងមួយវិញ ។

បានជាមានឈ្មោះថា កោះស្រឡៅ មកពីហេតុខុស ៗ គ្នាដូចតទៅ:

១- ខ្លះថា កាលពីយូរអង្វែងមកហើយ មានបុរសម្នាក់ឈ្មោះ ចៅ-ពៅ មកតាំងទីលំនៅ នៅលើកោះនេះមុនគេ ហើយអ្នកឯទៀត ៗ ក៏សន្មតហៅថា កោះចៅពៅ តាមភាសាសៀមថា ចៅឡៅ លុះយូរ ៗ ទៅក៏ក្លាយជាកោះស្រឡៅ ។

២- ខ្លះថា កោះនេះជាកន្លែងបិទស្រា ភាសាសៀម ហៅស្រាថា ឡាវ លុះយូរ ៗ ទៅក្លាយជាកោះស្រឡៅ ។

៣- ខ្លះកាលពីដើមមានលាវម្នាក់ មក តាំងទីកន្លែងនៅកោះ ភាសាសៀមហៅលាវថាឡាវ គឺកោះតាឡាវ លុះយូរ ៗ ទៅក្លាយជា កោះស្រឡៅ នេះឯង ។

កោះស្រឡៅ ស្ថិតនៅក្នុងសង្កាត់កោះកាពិ-ស្រុកនិងខេត្តកោះកុង ។ មានបណ្ដោយប្រហែល ១.៨០០ម. និងទទឹងប្រហែល ១.៥០០ម. ហើយនៅខាងទិសឦសាននៃកោះកាពិ ចម្ងាយប្រហែល ៧-៨គ.ម.។ នៅទិសខាងត្បូង-ខាងកើត-ខាងជើងនៃកោះ មានដៃសមុទ្រតូច ។ និងនៅខាងលិចមានព្រៃលិចទឹក ដែលដុះសុទ្ធតែដើមកោងកាង ។

ភូមិកោះស្រឡៅជាភូមិតូចមួយ នៅកណ្ដាលព្រៃលិចទឹកនិងដៃសមុទ្រ មានប្រជាពលរដ្ឋរស់នៅ ៥០ គ្រួសារ ។ គេហដ្ឋានភាគច្រើនរបស់គេសង់នៅតាមមាត់សមុទ្រ ពាក់កណ្ដាលផ្ទះខាងមុខនៅក្នុងទឹក ពាក់កណ្ដាលផ្ទះខាងក្រោយនៅដីគោក ។ គេសង់យ៉ាងនេះប្រយោជន៍ងាយចតទូក ប៉ុន្តែមានផ្ទះខ្លះ សង់នៅតាមចង្កេះភ្នំ និងនៅដីទំនាបដែរ ។

មុខរបរសំខាន់បំផុតនៃប្រជាពលរដ្ឋ គឺនេសាទត្រី បង្កង ក្ដាម ដោយមាន មង សន្ទូច ជាឧបករណ៍ ។ ក្រៅអំពីនេះ មានប្រកបរបរខាងកសិកម្មខ្លះដែរ ដូចជា ដាំសាវម៉ាវ ដូរេន ដូង ម្នាស់ ដំឡូង ត្របែក ។ល។ ប៉ុន្តែមិនជាច្រើនពេកទេ គេដាំសម្រាប់តែទទួលទានក្នុងគ្រួសារ ។ ការលក់ដូរមានតែផ្ទះ ២-៣ ដាក់អីវ៉ាន់លក់បន្តិចបន្តួច និងលក់នំបញ្ចុកចំណី ប៉ុន្តែពុំមានផ្ទះលក់កាហ្វេ-គុយទាវ ទេ ។

នៅកោះស្រឡៅមានវត្តមួយ កសាងជាយូរឆ្នាំមកហើយ ហៅតាម

ផ្លូវការជាវត្តពរវង្កត ។ ជាដំបូងសាងនៅជិតទំនាបត្រង់ខាងកើតភ្នំ ជិតដែនសមុទ្រ ប៉ុន្តែត្រូវរុះរើទៅសាងនៅលើចង្កេះភ្នំវិញចំនួន ២៩ ឆ្នាំមកហើយ ។ វត្តនេះមានព្រះវិហារសាងអំពីឥដ្ឋប្រក់ស័ង្កសី មានកុដិ ២ សាលាបុណ្យ ១ កុដិបាយ ១ ដែលសុទ្ធតែសាងអំពីឈើប្រក់ស័ង្ក-សី ។ ព្រះសង្ឃក្នុងវត្តមានតែ ១ អង្គគឺលោកគ្រូចៅអធិការព្រះនាមរតន៍-ជី ព្រះជន្មបានជាង ៦០ វស្សា ហើយ ។

នៅខាងត្បូងវត្ត មានសាលាបឋមសិក្សាបំពេញវិជ្ជា ១ បង្កើតឡើងជាង ១០ ឆ្នាំហើយ ។ មុនដំបូងសង់អំពីឈើ ប្រក់ស្លឹក ប៉ុន្តែឥឡូវនេះសង់អំពីឈើប្រក់ស័ង្កសី ។ សាលារៀននេះ មានបន្ទប់រៀន ៣ ប៉ុន្តែមានសិស្សរៀនដល់ទៅ ៧ ថ្នាក់ គឺអង្គុយរៀនរួមថ្នាក់ ព្រោះសិស្សមានចំនួនតិចពេក ។

នៅត្រង់កន្លែងវត្តចាស់ មានគិលានដ្ឋានតូច ១ ទំហំប្រហែល ៤ ម៉ែត្រ ៤ ជ្រុងសង់អំពីឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ ខ្ពស់អំពីដី ។ គិលានដ្ឋាននេះកើតពីឆ្នាំ ១៩៦៧ មានគិលានុបដ្ឋាក ១ នាក់ ប្រចាំការជាអចិន្ត្រៃយ៍ ។

ប្រជាពលរដ្ឋមានជំនឿខាងព្រះពុទ្ធសាសនា ប៉ុន្តែបើមានជម្ងឺក៏ងាកទៅរកការបន់ស្រន់ខាងខ្មោច ព្រាយ បិសាច ខ្លះដែរ ។ កាលពុំទាន់មានគ្រូពេទ្យ បើមានជម្ងឺអ្នកស្រុកនាំគ្នាប្រើសំបកឈើជាបង្សា

បាយព្យាបាលពេទ្យ និងមានមន្ទីរពេទ្យ ស្តុក ឬសៃនព្រៃនផងដែរ ប៉ុន្តែមកដល់សម័យសង្គមរាស្ត្រនិយម ដែលមានមន្ទីរពេទ្យ ឬគិលានដ្ឋាន ប្រជាពលរដ្ឋបាននិយមចូលទៅព្យាបាលនៅមន្ទីរពេទ្យក្រុងខេមរភូមិន្ទ ឬចូលទៅសុំថ្នាំលេប-ចាក់ នៅគិលានដ្ឋានកោះកាពិ ឬនៅកោះស្រឡៅនេះឯង ។

ភាសានិយាយ គឺមនុស្សអាយុ ៦០-៧០ ឆ្នាំ ច្រើនចេះភាសាសៀមជាងខ្មែរអាយុ ៣០-៤០-៥០ ឆ្នាំ ចេះខ្មែរនិងសៀមប្រហែលគ្នា បើពីអាយុ ៣០ ចុះមក ២០ ឆ្នាំចេះខ្មែរច្រើនជាងសៀម ប៉ុន្តែចំពោះក្មេងៗ ដែលមានអាយុពី ២០ ឆ្នាំចុះមក សុទ្ធតែចេះភាសាខ្មែរ ហើយច្បាស់លាស់ផង ចំណែកភាសាចិនវិញ ទាំងចាស់ទាំងក្មេង គេពុំចេះសោះទេ ។

ប្រជាពលរដ្ឋនៅកោះស្រឡៅ មានភ័ព្វសំណាងមួយ គឺធម្មជាតិបានផ្តល់ឲ្យ ដោយមានទឹកសាបសម្រាប់ប្រើប្រាស់បរិបូណ៌ ហើយទឹកសាបនៅកោះនេះ បានចិញ្ចឹមដល់ប្រជាពលរដ្ឋនៅកោះកាពិ និងអ្នកនៅតាមត្រសោបទៀតផង ។

# ១៣-កោងកាងសមុទ្រ

តាមការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ ម៉ែន-ទន់ ខេត្តកោះកុង កាលពីខែ កុម្ភៈ ១៩៦៨ ។

កោងកាងសមុទ្រ ជារុក្ខជាតិមួយយ៉ាងមានលក្ខណៈពិសេស គួរឲ្យចាប់អារម្មណ៍ និងគួរឲ្យកោតស្ញែងអំពីធម្មជាតិ និងអំពីគុណសម្បត្តិនៃដើមឈើនេះ ។

ឈើកោងកាងដុះនៅតែតាមមាត់សមុទ្រ-មាត់ព្រែក ដែលមានទឹកប្រៃ មានកំពស់ប្រហែលពី ៥ម.ទៅ ៨ម. និងមានទំហំដើមប្រហែលពី ០ម០៧ ទៅ ០ម១៥,។ បើដុះឃ្លាត ១ ពីគ្នា ឯណេះ ១ ដើម ឯណោះ ១ ដើម ដើមកោងកាងមានទម្រង់ស្លឹក និងសំណុំមែក មិនខុសអំពីដើមទ្ទរឡើយ ប៉ុន្តែកម្រដុះឃ្លាតពីគ្នាណាស់ គឺដុះប្រជ្រៀតគ្នា ហើយមានមែកសឹកកេគ្នាទៅវិញទៅមក ។ រីឯឫសវាវិញ ពុំមែនបែកចេញតែពីត្រង់គល់ដូចដើងគ្រុឌប៉ុណ្ណោះទេ គឺបែកចេញពីពាក់កណ្ដាលដើមក៏មាន បែកចេញពីមែកក៏មាន ។ ឫសនោះបែកត ១ ទៅទៀតសំដៅទៅចាប់នឹងដី ហើយចាក់ស្រែះប្រទាក់ប្រទងគ្នាគួរឲ្យចង់ពិតពិលរមិលមើល ។

រុក្ខជាតិកោងកាងពុំមានជ្រុះស្លឹកព្រមគ្នាទៅតាមរដូវ ដូចជារុក្ខជាតិឯទៀតទេ វាជ្រុះនិងលាស់ឡើងវិញបន្ត ១ គ្នាពុំមានពេលចន្លោះ ម្ល៉ោះ

ហើយនៅរដូវណាក៏ដូចជាខែណាដែរ   រុក្ខជាតិកោងកាងនៅតែមានស្លឹកស្រស់ចំប្រប៉   មានទិដ្ឋភាពគួរជាទីមនោរម្យយ៉ាងក្រៃលែង ។ បើយើងធ្វើដំណើរដោយនាវានៅកណ្ដាលសមុទ្រ   ហើយចោលនេត្រាមើលទៅមាត់ច្រាំង យើងនឹងឃើញព្រៃខៀវស្រងាត់   មានចុងត្រឹមដូចគេច្រិបនឹងកន្ត្រៃ   លាតសន្ធឹងយ៉ាងវែងជាប់និងផ្ទៃទឹក   នោះហើយគឺជាដើមកោងកាង ៗ   បើនៅពេលរសៀលវិញយើងឃើញស្លឹកកោងកាងត្រដាងខ្លួនទទួលរស្មីព្រះអាទិត្យ   បញ្ចេញពណ៌ស្រអែត ស្មើរលឿងស្មើរបៃតងទាក់ទាញខ្សែចក្ខុអ្នកទេសចរណ៍ឲ្យមើលហើយមើលទៀតពុំចង់ឃ្លាតឆ្ងាយ និងធ្វើឲ្យទឹកស្រណោះ ស្រងេះស្រងោចឥតព្រំដែន ។

ដើមកោងកាងមានធម្មជាតិពិសេសមួយ ដែលសង្ខារបានតាក់តែងឲ្យ   គឺឈើនេះចាប់កំណើតគត ៗ ពីមេទៅកូន   ខុសអំពីឈើទាំងពួង ។ តើឈើកោងកាងកើតគត ៗ គ្នារបៀបណា ? ។

រុក្ខជាតិកោងកាងដុះនៅតែតាមមាត់សមុទ្រ ដែលមានទឹកជោរនាចត្រាំគល់ឈើនេះមានផ្លែដូចជាឈើដទៃដែរ   មានទំហំប្រហែល ១ សង្ទី-ម៉ែត្រ ឬធំជាងនេះបន្តិច   មានបណ្ដោយពី ០ ម៣០ ទៅ ០ ម៤០   និងមានរាងមូលដូចផ្លែននោង ឬផ្លែម្រុំ ឬក៏ដូចផ្លែថ្ពឹង ។ ផ្លែនោះរាងស្រួចចុងហើយសំយុងចុះសំដៅដី   នៅចុងខាងលើដែលជាប់នៅក្នុងសណ្ដង់ទងមានបិចផ្កាពន្ធុកហើយស្រេច   ពេលណាទុំ ,   ផ្លែនោះរបូតធ្លាក់ចុះទៅដី

ហើយដោតជាប់ត្រង់ត្អឹងឡើងលើដូចគេដាំ ។ ចុងខាងដែលដោតជាប់ទៅក្នុងដីនោះ មិនយូរប៉ុន្មានក៏មានចេញឫសចាប់ជាប់ទៅនឹងដី រីឯចុងខាងលើដែលមានប៉ុចជាពន្លកហើយស្រួចនោះ ក៏បែកជាត្រួយ-បន្លឹក និងមែកតទៅ ។

ដើមកោងកាងទីមួយ ១ មានផ្លែច្រើនណាស់ ហើយជ្រុះមកដុះប្រូងប្រាងនៅក្រោមដើម ។ លុះដុះបានធំបន្តិចហើយ ក៏ទៅជាចំរែងសម្រាប់ទប់ដីខ្សាច់ គឺនៅពេលទឹកជោរហើយដែលមានរលកបោកបញ្ជូនដីខ្សាច់មកផង ដីខ្សាច់នោះក៏គៀងជាប់នឹងគល់កោងកាង ។ ការដែលដើមកោងកាងចេះតែដុះតគ្នាឆ្ងាយទៅ ១ ដីខ្សាច់ចេះតែគៀងលូតវែងទៅរកទឹកសមុទ្រដែរ លុះយូរ ១ ក៏កើតជាដីគោក ហើយការជម្រុះស្លឹកនៃដើមកោងកាងក៏នាំឲ្យមានជីជាតិ និងបំរើនសាប់ដីឲ្យកាន់តែខ្ពស់ថែមទៀត ។ ដូច្នេះ យើងគួរឲ្យឈ្មោះដើមកោងកាងថា : ជាវត្ថុសម្រាប់បង្កើតដី ឬ ជាជាអ្នកឈ្លានពានសមុទ្រ ។ ប៉ុន្តែដើមកោងកាងគ្រាន់តែមាននាទីខាងបង្កើតដីប៉ុណ្ណោះ លុះដីដុះបានខ្ពស់ហើយ ខ្លួនឯងក៏ត្រូវងាប់ទៅវិញ ហើយទុកកន្លែងឲ្យដើមស្នាច់គេដុះមុន ឯចំណែកដើមកោងកាងត្រូវបន្តសកម្មភាពទៅមុខទៀត ។ ដូច្នេះហើយបានជាគេឃើញទីណាមានដើមកោងកាង នៅខាងក្រោយនោះឃើញមានដីគោកហើយមានដើមស្នាច់ និង រុក្ខជាតិឯទៀត ដ៏ឡើមគ្នាដុះម៉ាដេរដាស ។

ក្រៅអំពីការបង្កើតដីដូចបានពោលខាងលើនេះ ដើមកោងកាងមាន គុណប្រយោជន៍ផ្សេងទៀត គឺដើមវា គេយកទៅដុតធ្វើជាធ្យូងសម្រាប់ប្រើការយ៉ាងល្អឯក ឯសំបកវាគេយកទៅធ្វើជាថ្នាំសម្រាប់សម្លាប់ស្បែក ។

## ផ្នែកកំណត់-ប្រវត្តិការណ៍

# ពិធីបូជាសពព្រះសុមេធាវង្ស ព្រាជ្ញ-ប៉ុល

ព្រះសុមេធាវង្ស ព្រាជ្ញ-ប៉ុល ព្រះរាជាគណថ្នាក់ត្រីគង់នៅវត្តឧណ្ណាលោម ដែលបានបានសុគតពីថ្ងៃទី ១៩ សីហា ១៩៦៩ នោះពុទ្ធបរិស័ទជាសិក្សានុសិស្ស បានរៀបចំធ្វើពិធីដង្ហែចេញពីកុដិរបស់សពព័ទ្ធជុំវិញវត្ត រួបចូលទៅកាន់ឈាបនដ្ឋានវត្តឧណ្ណាលោម ដើម្បីប្រារព្ធបូជាព្រះសព ។ កាលពីថ្ងៃអាទិត្យទី ២៤ ខែសីហា ១៩៦៩ វេលាម៉ោង ១៣ ។

នៅពេលរំកិលព្រះសពដាក់លើជើងថ្ករហើយ ព្រះសង្ឃបង្សុកូលចំពោះព្រះវិញ្ញាណក្ខន្ធនៅកណ្ដាលចំណោមពុទ្ធបរិស័ទទាំងអស់ដែលខាងព្រះសង្ឃមាន សម្ដេចព្រះសង្ឃរាជ ព្រះរាជាគណៈឋានានុក្រម ព្រមទាំងព្រះសង្ឃសហធម្មិក ឯផ្នែកគ្រហស្ថមានសហជីវិន ឌី-ធូច រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ មន្ត្រីរាជការក្រសួងធម្មការ និងបណ្ដាសិស្សគណជាច្រើនកុះករ ។

ដើម្បីជូនអ្នកអានជ្រាបអំពីព្រះសពឲ្យបានច្បាស់លាស់ យើងសូមចុះជូននូវសន្ទរកថា របស់ព្រះតេជព្រះគុណ ព្រះពុទ្ធវង្ស សេង-ផាង ដែលថ្លែងក្នុងឱកាសនោះ ដូចតទៅ ៖

# សុន្ទរកថា

ព្រះពុទ្ធវង្ស សេខ- ឆាង ថ្លែងក្នុងឱកាសបូជាសព ព្រះសុមេធវង្ស ប្រាជ្ញ-ប៉ុល នៅថ្ងៃ ២៤ សីហា ១៩៦៩ នៅឈាបនដ្ឋាន វត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

---

សូមព្រះតេជៈតម្កល់លើត្បូង

*សូមក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ*

*សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជជាអម្ចាស់*

*សូមទ្រង់ព្រះមេត្តាប្រោសជ្រាប ។*

*សូមពិតថេរដីកា ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ, សូមចម្រើនពរ លោកអ្នកឧកញ៉ាវដ្ឋលេខាធិការក្រសួងធម្មការ និងពុទ្ធបរិស័ទទាំងឡាយ*

*សូមមានជ្រាប - សូមជ្រាប ។*

*ក្នុងនាមសិស្សានុសិស្ស និងញាតិមិត្តនៃសពព្រះសុមេធវង្ស ប្រាជ្ញ-ប៉ុល និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព ដែលជាអ្នកជួយចាត់ការបុណ្យសពនេះ, សូមព្រះរាជទាន ព្រះបរមរាជវរោកាស ដើម្បីថ្លែងទទួលនូវអំណរព្រះមហាករុណាធិគុណដ៏លើសលប់ ដោយកតញ្ញូកតាធម៌យ៉ាងស្មោះជាទីបំផុត ចំពោះសម្តេចជាទីគោរពនៃពុទ្ធសាសនិកជនទូទៅ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមក*

ជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបុណ្យឈាបនកិច្ចសពព្រះសុមេធ-វង្ស ទ្រា-ជ្ញ-ប៉ុល នាពេលនេះ ។

ចំពោះព្រះរាជវត្តមានដ៏ឧត្តមនេះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមកត់សម្គាល់ទុកក្នុងហទយរតដ៏ជ្រាលជ្រៅជាទីបំផុត ព្រោះថាក្នុងបច្ចុប្បន្នកាលនេះ សូម្បីសម្តេចជាអម្ចាស់ទ្រង់មានព្រះសុខភាពនិងព្រះកាយពលពុំបរិបូណ៌ យ៉ាងណាក៏ដោយ ព្រះអង្គក៏ទ្រង់ខ្នៀតយាងមកក្នុងពិធីនេះ ដើម្បីបានជាទីបន្ទាត់បង់ នូវសេចក្តីក្រៀមក្រំក្រៀមក្រំរបស់ទូលព្រះបង្គំទាំងឡាយ ដែលជាសិស្សគណនិងញាតិមិត្តនៃសពព្រះសុមេធវង្ស ។

មួយទៀត ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោកាស ដើម្បីថ្លែងនូវអំណរគុណចំពោះព្រះករុណាគ្រប់ព្រះអង្គ និងចំពោះលោកអ្នកឧកញ៉ារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ ព្រមទាំងអស់លោក ជាពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ ដែលបាននិមន្ត-អញ្ជើញមកជួយឧបត្ថម្ភក្នុងពិធីឈាបនកិច្ចនេះ ឲ្យបានចំរើនរុងរឿងឡើង ។

សូមទ្រង់ព្រះមេត្តាប្រោស !

លំដាប់តទៅនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព សូមព្រះរាជទាន ព្រះបរមរាជានុញ្ញាត និងអនុញ្ញាត ថ្លែងនូវជីវប្រវត្តិសង្ខេបនៃព្រះសុមេធវង្ស ទ្រា-ជ្ញ-ប៉ុល ថ្វាយ ប្រគេន ជូនដូចតទៅនេះ :

ព្រះសុមេធាវង្ស ទ្រាង-ប៉ុល កើតក្នុងភូមិព្រៃម្នាស់ សង្កាត់ព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង នៅថ្ងៃសៅរ៍ ខែមាឃ ឆ្នាំច ទោស័ក ព.ស. ២៤៥៣ គ.ស ១៩០៩, មាតានាម សៅ-យ៉ាង បិតានាម លក្ខណ៍-ទ្រាង ។

ព្រះសុមេធាវង្ស ទ្រាង-ប៉ុល កាលនៅជាកុមារ អាយុ ១៤ ឆ្នាំ បានចូលទៅសិក្សាអក្សរសាស្ត្រខ្មែរ និងធម៌អាថ៌ផ្សេងៗ ក្នុងសំណាក់លោកគ្រូធម្មកេសរ គង់-ម៉ៅ ចៅអធិការវត្តប្រាសាទ សង្កាត់ប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង អស់រយៈកាល ៣ ឆ្នាំទើបអាចមើលបានសរសេរកើត ។

លុះដល់ឆ្នាំខាលអដ្ឋស័ក ព.ស. ២៤៦៩ គ.ស. ១៩២៦ កុមារ ទ្រាង-ប៉ុល មានអាយុ ១៧ឆ្នាំ បានបួសជាសាមណេរក្នុងវត្តប្រាសាទ ដោយមានលោកគ្រូធម្មកេសរ គង់-ម៉ៅ ជាព្រះឧបជ្ឈាយ៍ ។

នៅឆ្នាំមមីនក្សត្រ ទោស័ក ព.ស.២៤៧៤ គ.ស.១៩៣០ សាមណេរ ទ្រាង-ប៉ុល មានអាយុគម្រប់ ២១ឆ្នាំ បានទទួលឧបសម្បទាជាភិក្ខុ ក្នុងព័ទ្ធសីមាវត្តប្រាសាទ ដោយបាននិមន្តលោកគ្រូធម្មកេសរ គង់-ម៉ៅ ជាព្រះឧបជ្ឈាយ៍, លោកគ្រូឥន្ទបញ្ញាវិន័យ រាជ-សាំង និងលោកគ្រូឥន្ទបញ្ញា អ៊ុក-ទៀវ ជាឧបសម្បទាចារ្យ បាននាមបញ្ញត្តិថា សុវណ្ណប្បញ្ញោ ។

លុះដល់អាយុ ២៤ ឆ្នាំវស្សាទី ៤ ភិក្ខុ ច្រាជ្-ប៉ុល បានទៅសិក្សាព្រះបរិយត្តិធម៌នៅវត្តព្រះនាង សង្កាត់កំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ ។

អាយុ ២៥ឆ្នាំ វស្សាទី ៥ ភិក្ខុ ច្រាជ្-ប៉ុល បានទៅសិក្សាព្រះបរិយត្តិធម៌នៅវត្តពាមមង្គល សង្កាត់កោះកោង ស្រុកមុខកំពូល ខេត្តកណ្ដាល ។

អាយុ ២៨ ឆ្នាំវស្សាទី ៨ ភិក្ខុ ច្រាជ្ - ប៉ុល បានមកនៅជាមេកុដិលេខ ៣ ក្នុងក្រុមសម្ដេចព្រះរាជវង្ស វត្តឧណ្ណាលោមនេះជាប់រហូតមក ។

អាយុ ២៩ ឆ្នាំវស្សាទី ៩ ភិក្ខុ ច្រាជ្ - ប៉ុល បានចូលសិក្សាព្រះបរិយត្តិធម៌ក្នុងសាលាបាលីរង់វត្តឧណ្ណាលោម បានសញ្ញាប័ត្រសាលាបាលីរង់មាននាមថា មហាបរិយត្តិបឋមវិជ្ជា ។

អាយុ ៣៣ ឆ្នាំវស្សាទី ១៣ ភិក្ខុមហា ច្រាជ្ - ប៉ុល បានទទួលសមណសក្តិជាព្រះគ្រូវិសុទ្ធមុនី ។

ពីអាយុ ៤១ ដល់ ៤៣ ឆ្នាំវស្សាទី ២១ ដល់ ២៣ ព្រះគ្រូវិសុទ្ធមុនី ច្រាជ្ - ប៉ុល បានចូលអប់រំធម្មវិន័យថ្នាក់ត្រី - ទោ ឯក បានវិញ្ញាបនប័ត្រទាំង ៣ ថ្នាក់ មាននាមថាធម្មកោសលត្រី - ទោ - ឯក ហើយបានបង្រៀនធម្មវិន័យដល់ភិក្ខុសាមណេរក្នុងវត្តឧណ្ណាលោមតមកដល់មកថ្ងៃទី ២១ មករា ឆ្នាំ ១៩៥៤ ព្រះគ្រូវិសុទ្ធមុនី ច្រាជ្ - ប៉ុល បាន

ទទួលសមណស័ក្តិជាព្រះទេពមុនី ពជាគណៈថ្នាក់ទី ៤ ក្នុងអាយុ ៤៤ ឆ្នាំ វស្សាទី ២៣ និងជាអតីតសមាជិកនៃថេរសភាផង ។

ដល់មកថ្ងៃទី ២៧ ឧសភា ១៩៦៣ ព្រះទេពមុនី ច្រាជ្ញ-ប៉ុល បានឡើងសមណស័ក្តិជា ព្រះសុមេធវង្សពជាគណៈថ្នាក់ទី ៣ ក្នុងអាយុ ៥៣ ឆ្នាំវស្សា ៣២ ។

ថ្ងៃទី ១២ មេសា ១៩៦៤ ព្រះសុមេធវង្ស ច្រាជ្ញ-ប៉ុល បានទទួលគ្រឿងឥស្សរិយយសមេដាយសុវត្ថា ទីអស្សបុទ្ធិ ។

ក្រៅពីនេះព្រះសុមេធវង្ស ច្រាជ្ញ-ប៉ុល បានចេះចាំកិច្ចប្បាតិមោក្ខ បាលីអាចសូត្រមាត់ទទេបាន, បានជាវគម្ពីរធម៌អាចិវេន្រ្ទ ១ មានគម្ពីរព្រះត្រៃបិដកបាលី-សម្រាយជាដើម បានស្ថាបនាកុដិ១ ខ្នង ដោយឥដ្ឋស៊ីម៉ង់ត៍ គ្រឿងឈើប្រក់ក្បឿងក្នុងវត្តឧណ្ណាលោម, បានជួសជុលសម្អាតព្រះចេតិយ ១ អង្គក្នុងវត្តប្រាសាទ, បានសាងព្រះចេតិយ ២ អង្គទៀត ក្នុងភូមិព្រៃមាស់ សង្កាត់ព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង, បានជួយស្ថាបនាវិហារវត្តប្រាសាទនិងវិហារវត្តសាទគរ ស្រុកស្ទោង ខេត្តកំពង់ធំ ដែលកំពុងតែស្ថាបនាសព្វថ្ងៃពុំទាន់ហើយនៅឡើយ ។

ជាអកុសលទទួលរោគទឹកមូត្រផ្អែម លបលួចចូលមកក្នុងសរីរកាយរបស់លោកបន្តិចម្តងៗ ហើយកាន់តែចម្រើនឡើងៗ ។ សិស្សគណនិងញាតិមិត្រមានលោកវេជ្ជបណ្ឌិតវ័ន្ត គុត ជាដើម បាននាំលោកទៅ

ព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា ។ ទោះបីគ្រូពេទ្យខំប្រកបឱសថដ៏ពិសេសៗ មកព្យាបាលយ៉ាងណាក៏ដោយ នៅតែពុំអាចទប់ទល់នឹងរោគនោះបានឡើយ ។ ដោយអស់សង្ឃឹមក្នុងការព្យាបាលតទៅទៀត, គ្រូពេទ្យ ក៏ឲ្យលោកនិមន្តត្រឡប់មកកុដិរបស់លោកវិញ ។

ដល់មកថ្ងៃអង្គារ ទី ៦ កើត ខែស្រាពណ៍ ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ១៩ សីហា ១៩៦៩ វេលាម៉ោង ២៣ និង ០០ នាទី, ស្រាប់តែមច្ចុរាជដ៏កាចសាហាវចូលមកផ្តាច់ផ្តិលជីវិត នៃព្រះសុមេធ-វង្ស ប្រាជ្ញ-ប៉ុល នាកណ្ដាលចំណោមសិស្សានុសិស្ស ញាតិមិត្ត នៅទីកុដិរបស់លោកក្នុងអាយុ ៦០ ឆ្នាំ វស្សាទី ៣៩ ។

សូមទ្រង់ព្រះមេត្តាប្រោស !

លំដាប់តទៅនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងនូវវិយោគសេចក្តីស្ដាយស្រណោះអាឡោះអាល័យចំពោះសពព្រះសុ-មេធាវង្ស ប្រាជ្ញ-ប៉ុល ដូចតទៅនេះ ៖

## ព្រះសុមេធាវង្ស ប្រាជ្ញ-ប៉ុល !

ថ្ងៃនេះ សិស្សានុសិស្ស ញាតិមិត្តនិងពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ បានជូនដំណើរលោកគ្រូ មកដល់តែត្រឹមទីនេះទេ បន្ទិចទៀតរូបកាយរបស់លោកគ្រូនឹងបាត់បង់ទៅហើយ នៅសល់តែគុណបំណាច់និងសេចក្ដីល្អ ដែលលោកគ្រូសាងទុកជាភស្តុតាងប៉ុណ្ណោះ ។

# លោកគ្រូព្រះសុមេធវង្ស !

សូមលោកគ្រូកុំតូចចិត្តក្នុងការបាត់បង់រូបកាយនេះ ព្រោះរូបកាយនេះ មានការកើតឡើង និងបែកធ្លាយទៅវិញជាទំនៀមដូចថ្ងៃបណ្ដើរកូន ឬដូចជាដុំពពុះទឹកដែលប៉ោងឡើង ហើយបែកធ្លាយទៅវិញដូច្នោះដែរ ។

ហេតុនេះ ការបាត់បង់រូបកាយមិនមែនមានចំពោះតែលោកគ្រូមួយរូបប៉ុណ្ណោះទេ គឺប្រាកដជាមានដល់រូបយើងខ្ញុំទាំងអស់គ្នាផងដែរ គ្រាន់តែខុសពេលគ្នាត្រង់មុននិងក្រោយប៉ុណ្ណោះ ។

លោកគ្រូព្រះសុមេធវង្ស ! ទោះបីដូច្នោះក៏ដោយ យើងខ្ញុំទាំងអស់គ្នា ក៏នៅតែមានសេចក្ដីស្ដាយចំពោះការបាត់បង់នេះ ព្រោះការបាត់បង់រូបលោកគ្រូនេះ ចាត់ទុកជាការបាត់បង់មហាថេរមួយរូប ដែលមានចិត្តស្មោះត្រង់ចំពោះជាតិ សាសនា និងព្រះរាជបល្ល័ង្ក ស៊ូទ្រាំនៅក្នុងភេទបព្វជិតរហូតដល់អស់ជីវិត ។ នេះជាគំរូមួយដ៏ល្អ គួរបព្វជិតជំនាន់ក្រោយយកជាតម្រាប់តាម ។

យើងខ្ញុំទាំងអស់គ្នាជាសិស្សគណនិងជាញាតិមិត្ត គ្មានវត្ថុប្រសើរថ្លៃប្រគេនចំពោះលោកគ្រូទេ មានតែបុណ្យកុសលដែលយើងខ្ញុំបានធ្វើនាពេលនេះ ទុកជាគ្រឿងសក្ការៈបូជាចំពោះលោកគ្រូ សូមលោកគ្រូបានប្រកបដោយសេចក្ដីសុខ ចម្រើនក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

ជាអវសាន ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុសក្តិសិទ្ធិក្នុងលោក សូមជួយអភិបាលរក្សាអង្គសម្ដេចព្រះសង្ឃរាជជាម្ចាស់ សូមព្រះអង្គប្រកបដោយព្រះបរមសុខសួស្ដីមានព្រះជន្មាទីឃាយុយឺនយូរតរៀងទៅ !

មួយចំណែកទៀត សូមគុណបុណ្យព្រះរតនត្រ័យជួយថែរក្សា ព្រះករុណាគ្រប់ព្រះអង្គ និងលោកអ្នកឧកញ៉ារដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ដែលបាននិមន្តអញ្ជើញមកជួយឧបត្ថម្ភពិធីបុណ្យសពនាពេលនេះ សូមបានប្រកបដោយសេចក្ដីសុខចម្រើនគ្រប់ទិវារាត្រីកុំឃ្លៀងឃ្លាតឡើយ ! ។

សេចក្ដីគួរពុំគួរសូមទ្រង់ព្រះករុណាប្រោស ៕

# ពិធីប្រគេនព្រះរាជអំណោយសម្តេចឪ
## ចំពោះសម្តេចព្រះពោធិវង្ស

ថ្ងៃអង្គារទី ២៦ សីហា ១៩៦៩ វេលាម៉ោង ៩ ព្រឹក នៅក្នុងសាលបណ្ណាល័យនៃពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ មានធ្វើពិធីមួយ ដោយមាន ឯ.ឧ. ឡុង-គីម ទេសាភិបាលធនាគារជាតិ ជាព្រះរាជបម្រើនាំព្រះរាជអំណោយសម្តេចឪជាប្រាក់មួយលានរៀល មកប្រគេនសម្តេចព្រះពោធិវង្ស ដើម្បីឧបត្ថម្ភក្នុងការស្ថាបនា អគារពុទ្ធសាសនបណ្ឌិត្យ ។

នៅវេលាម៉ោង ៩ គត់ ជួបជុំព្រះសង្ឃនិងគ្រហស្ថ ដែលយើងសង្កេតឃើញផ្នែកព្រះសង្ឃមានសម្តេចព្រះពោធិវង្ស សកលវិទ្យាធិការនៃពុទ្ធិកសកលវិទ្យាល័យ និងជាអគ្គាធិការ នៃពុទ្ធិកសិក្សា ក្នុងព្រះរាជាណាចក្រ មួយអន្លើដោយព្រះសង្ឃជាសាស្ត្រាចារ្យនៅពុទ្ធិកសកលវិទ្យាល័យ ពុទ្ធិកវិទ្យាល័យ និងសមាជិកក្រុមជំនុំព្រះត្រៃបិដក; ផ្នែកខាងគ្រហស្ថមាន ឯ.ឧ. ឡុង-គីម ទេសាភិបាលធនាគារជាតិ សហជីវិន ឌី-ឡុង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុក ក្រសួងធម្មការ,

សហ. ម៉ុំ-ឈួ-ស៊ុយហួ នាយកការិយាល័យក្រសួងធម្មការ,

សហ. ណាង-ហ៊ាបអាន នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ,

សហ. តែ-ម៉េងឃាប់ អគ្គលេខាធិការនៃពុទ្ធិកសកលវិទ្យាល័យ

ព្រះសីហនុរាជ, សហ. ជាច សីវណ្ណា ទីប្រឹក្សាបច្ចេកទេស នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សា និងអស់លោកសាស្ត្រាចារ្យពុទ្ធិកសាកលវិទ្យាល័យ, ពុទ្ធិកវិទ្យាល័យ និងមន្ត្រីអក្សរកាជការនៅក្រសួងធម្មការ និងក្រុមនានានៅក្រោមឱវាទ ។

ក្រោយដែលបានក្រាបបង្គំ សម្តេចព្រះពោធិវង្ស និងព្រះសង្ឃគ្រប់ព្រះអង្គហើយ ឯ.ឧ. ឡូច-គីម បានថ្លែងសុន្ទរកថាយ៉ាងខ្លីមួយ បញ្ជាក់អំពីព្រះរាជអំណោយមួយលានរៀល ដែលសម្តេចឪជាអម្ចាស់ ទ្រង់សព្វព្រះរាជហឫទ័យ ព្រោសប្រទានក្នុងវេលានេះ ។ គឺថា ដើមឡើយ ឯ.ឧ. អ៊ុង-ហ៊ុងសារ៉ាត កាលលោកនៅកាន់ដំណែងជាឧបនាយករដ្ឋមន្ត្រីទី ២ ទទួលបន្ទុកក្រសួងធម្មការនោះ លោកបានថ្វាយបុគ្គលហាយមួយចំពោះសម្តេចឪជាអម្ចាស់ ដើម្បីសុំខ្ចីប្រាក់អំពីហិបប្រាក់ស្ថាបនាជាតិចំនួនមួយលានរៀល យកមកចាត់ចែងការសិក្ស ទម្រាំបានទទួលពីថវិកាជាតិសម្រាប់ការស្ថាបនាអគារពុទ្ធសាសនបណ្ឌិត្យ ដែលសព្វថ្ងៃនេះជិតបានរួចទៅហើយ ។ ក្រោយដែលទ្រង់ជ្រាបដំណឹងនេះ សម្តេចឪជាអម្ចាស់ ទ្រង់សព្វព្រះរាជហឫទ័យព្រោសប្រទានមួយលានរៀលនេះ ដើម្បីប្រគេនសម្តេចព្រះពោធិវង្ស ជាចំណុះកិច្ចការស្ថាបនាអគារនេះ ដោយមិនបាច់សងវិញឡើយ ។

បន្ទាប់មក សម្តេចព្រះពោធិវង្ស ព្រះអង្គមានពុទ្ធដីកា ថ្លែងអំណរ

ព្រះមហាករុណាទិគុណនៃសម្តេចព្រះប្រមុខរដ្ឋ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ប្រោសប្រទានការឧបត្ថម្ភដ៏មុតមាំនៅវេលានេះ បន្ថែមលើព្រះរាជូបត្ថម្ភដ៏ច្រើនអនេក ដែលព្រះអង្គទ្រង់តែងប្រោសប្រទានចំពោះព្រះពុទ្ធសាសនា និងចំពោះជាតិ ។ បន្តមក សម្តេចមានពុទ្ធដីកាបន្ថែមអំពីប្រវត្តិខ្លះនៃមន្ទីរពុទ្ធសាសនបណ្ឌិត្យ ដែលដើមឡើយនៅដោយឡែកអំពីក្រសួងធម្មការ លុះមកដល់ពេលខ្មែរយើងបានឯករាជ្យម្តង កាលពីសម័យជប៉ុន សម្តេចឧបយុវរាជកាលព្រះអង្គគង់នៅក្នុងរាជសម្បត្តិនោះព្រះអង្គសព្វព្រះរាជហឫទ័យឲ្យក្រសួងធម្មការមកនៅអែបជាមួយ ហើយគ្រប់គ្រងលើពុទ្ធសាសនបណ្ឌិត្យរហូតមក ។ ទីបំផុតព្រះអង្គថ្វាយព្រះពរចំពោះសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះឧបយុវរាជព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ និងអំណោយគុណចំពោះឯកឧត្តមជាព្រះរាជដំណាង ដែលបានអញ្ជើញមកក្នុងវេលានេះ ។

តមកទៀត សហជីវិន ឌិ-ធ្វូច ក៏បានថ្លែងសន្ទកថាមួយដែរ ដើម្បីបញ្ជាក់អំពីសេចក្តីត្រេកអរឥតឧបមា របស់បុគ្គលិកក្រសួងធម្មការនិងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ចំពោះព្រះរាជអំណោយដ៏ថ្លៃថ្លាវិសេសនេះ ព្រមទាំងសេចក្តីកោតសរសើរចំពោះសម្តេចព្រះពោធិវង្ស ដែលព្រះអង្គបានធ្វើព្រះពលិកម្មជាច្រើនចំពោះពុទ្ធិកសិក្សាក្នុងព្រះរាជាណាចក្រ មិនតែប៉ុណ្ណោះ ព្រះអង្គបានប្រឹងប្រែងពេញកម្លាំងព្រះកាយដើម្បីស្ថាបនាអគារពុទ្ធសាសន

បណ្ឌិត្យ នៅក្នុងវេលានេះជាអាទិ៍ ៗ ទីបំផុត សហជីវិន រដ្ឋលេខាធិការ បានថ្លែងអំណរគុណចំពោះព្រះសង្ឃទាំងអស់ ព្រមទាំងឯកឧត្តម ទូច-គីម ដែលជាព្រះរាជតំណាង ដែលបាននិមន្តនិងអញ្ជើញមកធ្វើជាអធិបតី ឲ្យបានឧឡារិកក្នុងពិធីនេះ ៗ មួយទៀត សហជីវិន ថ្លែងអំណរគុណផងដែរ ចំពោះបុគ្គលិកទាំងអស់នៅក្រសួងធម្មការ ដែលបានធ្វើការយ៉ាងស៊ុខដមបម្រើកិច្ចការអាណាចក្រ និងពុទ្ធចក្រ ឲ្យបានចម្រើនហូរហែមក ៗ

ពិធីនេះ បានចប់សព្វគ្រប់នៅម៉ោង ១០ ដោយមានការលៀងភេសជ្ជៈ ជាកិច្ចបង្ហើយផង ៗ

លី-ឈាមពេង

បន្ទាប់ពីបានទទួលព្រះរាជអំណោយនេះហើយ សម្ដេចព្រះពោធិវង្ស ព្រះអង្គបានថ្វាយចុតហ្មាយមួយច្បាប់ចំពោះសម្ដេចព្រះប្រមុខរដ្ឋ ដែលយើងសូមចុះផ្សាយ នៅទំព័របន្ទាប់នេះ ៗ

# សូមថ្វាយព្រះពរចំពោះសម្តេចព្រះប្រមុខរដ្ឋ
# ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ព្រះមេត្តាប្រោស

អាត្មាភាព, តាងនាមសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក លោករដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ, ព្រះភិក្ខុសង្ឃសជាគ្គិតិកាចារ្យខាងក្រុមជំនុំព្រះត្រៃបិដក ព្រមទាំងបុគ្គលិកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ និងក្នុងនាមនៃអាត្មាភាពផ្ទាល់ អាត្មាភាពសូមព្រះពរប្រកាសថ្លែងនូវព្រះមហាកតញ្ញុតាធម៌ចំពោះសម្តេចជាម្ចាស់ ដែលបានប្រោសព្រះរាជទានព្រះរាជអំណោយចំនួនមួយលានរៀល (១.០០០.០០០) ដើម្បីចាត់ចែងការ កសាងអគារ នៃវិជ្ជាឋាន ពុទ្ធសាសនបណ្ឌិត្យ និងក្រសួងធម្មការ ដែលកំពុងតែប្រព្រឹត្តទៅបានហើយស្រេចជិតបីភាគបួននៃការងារ ។ ពិធីប្រគល់នូវព្រះរាជអំណោយដ៏ថ្លៃថ្លានេះ បានធ្វើនៅពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ នៅក្នុងថ្ងៃទី២៦ សីហា ១៩៦៩ នេះ វេលាម៉ោង ៩ ព្រឹក ក្រោមអធិបតីភាពនៃឯកឧត្តម ទូច គឹម ទេសាភិបាលនៃធនាគារជាតិកម្ពុជា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ហើយ ដោយមានលោករដ្ឋលេខាធិការក្រសួងធម្មការ ព្រមទាំងសហការី និងមន្ត្រីសង្ឃពុទ្ធិកសិក្សាបកប្រែជាច្រើនផង ។

សម្តេចជាម្ចាស់

ព្រះកាយវិការប្រកបដោយសប្បុរសធម៌ ប្រៀបបាននឹងមហាសាគរនេះ បានញ៉ាំងអាត្មាភាពឲ្យកាន់តែមានវិរិយភាព និងកម្លាំងពលំក្នុងការស្ថាបនាគ្រឹះស្ថាននៃពុទ្ធសាសនបណ្ឌិត្យនិងក្រសួងធម្មការ ព្រមទាំងសមិទ្ធិខាងសង្គមកិច្ច ដន្ទែតាមព្រះរាជមាគ៌ាកសាងខ្លួនរាស្ត្រនៃប្រទេស ។ ព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ព្រះករុណាវិសេសក្នុងគ្រានេះទៀត គឺជាសក្តិភាពយ៉ាងឧត្តម ថែមទៅលើព្រះរាជអំណោយកប់មិនអស់ហើយមិនចេះដាច់ ដែលសម្តេចជាអម្ចាស់ទ្រង់បានប្រោសព្រះរាជទានចំពោះក្លូនចៅ គ្រប់និគមជនបទ,ចំពោះអង្គការកសាងជាតិគ្រប់វិស័យ, គឺដូចជាការឧបត្ថម្ភព្រះពុទ្ធសាសនា ដែលមានក្រសួងធម្មការ និងវិជ្ជាឋានពុទ្ធ-សាសនបណ្ឌិត្យជានិមិត្តរូប ។

ក្នុងការទទួលព្រះរាជអំណោយថ្ងៃនេះ អាត្មាភាពនឹកទៅដល់ ព្រះមហាគុណូបការៈ របស់សម្តេចជាម្ចាស់ កាលទ្រង់គង់នៅជាព្រះមហាក្សត្រក្នុងសិរីរាជសម្បត្តិនៅឡើយ ហើយស្តេចយាងផ្ទាល់ព្រះអង្គមកកាន់វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យនាគ្រិស្តសករាជ ១៩៤៥ ដើម្បីទ្រង់រៀបចំក្រសួងធម្មការឲ្យរើតនៅធ្វើការរួមជាមួយគ្នាក្នុងគ្រឹះស្ថានតែមួយ ។ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យនោះគឺជាមជ្ឈមណ្ឌលដ៏វិសេស តំណាងនូវវប្ប-ធម៌និងអារ្យធម៌ជាតិ ជាព្រះកេរ្តិ៍ណែលនៃព្រះករុណាព្រះបាទសម្តេចព្រះ

ស៊ីសុវត្ថិ-មុនីវង្ស បរមខត្តិយកោដិ , ព្រះករុណាព្រះបាទ សម្តេចព្រះ ស៊ីហនុវរ្ម័ន ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សុរាម្រិត ព្រះ មហាកោញ្ញនកោដិ ហើយក្នុងបច្ចុប្បន្នកាល នេះ គឺជាស្មើនៃពុទ្ធសាសនា ចិញ្ចោងលើផ្ទៃភពអន្តរជាតិ ក្នុងសម័យ សង្គមរាស្ត្រនិយម ព្រះ នរោត្តម-សីហនុ ព្រះអគ្គប្រមុខរដ្ឋនៃកម្ពុជា ឯករាជ្យ អព្យាក្រឹត្យ អនុស្សាវរីយ៍ទាំងអស់នេះហើយ បានជាបញ្ជាក់នូវ ព្រះរាជហឫទ័យនៃសម្តេចជាម្ចាស់ដែលទ្រង់ជាប់ជំពាក់ជានិច្ច ចំពោះកិច្ច ទ្រទ្រង់ពុទ្ធសាសនា ដែលជាព្រះភារកិច្ចយ៉ាងសំខាន់ឯករបស់ព្រះរាជ បល្ល័ង្ក និងរបស់សង្គមរាស្ត្រនិយម ។ អាត្មាភាពព្រមទាំងពុទ្ធបរិស័ទ ទាំងអស់ មានជំនឿយ៉ាងខ្ជាប់ខ្ជួនចំពោះព្រះរាជបុត្តមកនៃសម្តេចជាអម្ចាស់ ក្នុងវិស័យពុទ្ធសាសនា ដោយសង្ឃឹមថា នឹងចេះតែរុងរោចន៍ជានិច្ចលើ ឆាកអន្តរជាតិដើម្បីសេចក្តីសុខ សន្តិភាព ចំពោះកម្ពុជរដ្ឋនិងសកលលោក ផង ។

ជាទីអវសាន អាត្មាភាព សូមប្រមូលនូវបុញ្ញរាសីដែលកើតឡើង អំពីព្រះរាជកុសលដ៏ថ្លៃថ្លានេះ ថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានីជា អម្ចាស់ជីវិត ចំពោះសម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់, សូមទ្រង់បានប្រកបតែ ព្រះបរមសុខសួស្តី ជោគជ័យមង្គល ឈ្នះអស់មារសត្រូវជិតឆ្ងាយ សូម ព្រះករុណាទាំងពីរព្រះអង្គ មានព្រះបរមសុខភាពបរិបូណ៌ មានព្រះជន្មា

ទីឃាយុជាងរយព្រះវស្សា ដើម្បីជាម្លប់ដល់ពុទ្ធបរិស័ទ និងប្រជាពលរដ្ឋជាកូនចៅ អស់កាលជានិច្ចនិរន្តរ៍តទៅ ៖

គួរពុំគួរសូមសម្តេចជាអម្ចាស់ទ្រង់ព្រះករុណាប្រោស

សូមថ្វាយនៅភ្នំពេញ ថ្ងៃទី ២៥ សីហា ២៥១៣ / ១៩៦៩

អាត្មាភាព :

សម្តេចព្រះពោធិវង្ស ហួត - តាត